# អដ្ឋកថា ព្រះសុត្តន្តបិដក

## ឈ្មោះបបញ្ចសូទនី

## មជ្ឈិមនិកាយ មូលបណ្ណាសក

## តតិយភាគ

២២

នត្ថិ សន្តិ បរំ សុខំ

ព្រះរាជាណាចក្រកម្ពុជា

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មូលបណ្ណាសក

## តតិយភាគ

## ភាគ ២២

ឈ្មោះ

# បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

**មហាយមកវគ្គ – ចូឡយមកវគ្គ**

**រួមទាំងអស់មាន ២០ សូត្រ**

# ស្រៈពេញតួ
# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

A

# ស្រៈនិងស្រៀយ

# *Signes et accents:*



# ព្យញ្ជនៈ

# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ᨠ | ᨡ | ᨣ | ᨥ | ᨦ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

D

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຍ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

E


Cambodgien
Romain
t ṭh ḍ ḍh ṇ
Siamois
Laotien
Cinghalais
Birman

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| [illegible]<br>Français | *t* | *th* | *d* | *dh* | *n* |
| សៀម<br>Siamois | ต | ถ | ท | ธ | น |
| លាវ<br>Laotien | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
| [illegible]<br>Cinghalais | ත | ථ | ද | ධ | න |
| ភូមា<br>Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | [illegible] | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ្ឡ | ° | ។ |
| Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ° | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ° | ຯ |
| Cinghalais | ය | ර | ල | ව | ස | හ | ළ | ° | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ° | ။ |

# ពាក្យផ្តើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងដោយសោមនស្សញ្ញាណ ។*

*ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្តើមឡើងដោយពាក្យថា សេចក្តីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្តែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្តី*

វិកកាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្ដីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ  ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌  ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណី បាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថាមហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើមក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់របោតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយាបានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថាឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថាព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថាមហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុដៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសកករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀង ផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែល មានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោក រចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈ បានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយ បទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបាន សាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញ សេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បាន ប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយនមស្ការព្រះពុទ្ធឃោស:និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ:ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោស:បានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធ: មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋ: និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបោរាណាចារ្យយ៉ាងសំខាន់ក្រៃ-លែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ន
ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទូន
ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត
ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី
ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម រ៉ៃយ៉ា
ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ
ឧបាសក ម៉ៅ ផុន

ឧបាសក ជា ស៊ីបាន
ឧបាសិកា ថាប់ លឿម

ឧបាសិកា ហាយ សារ៉ាត់
ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ
ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៊ុត សេដាដួង
ឧបាសិកា ប៉ែន រម្មណីយ

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ឆំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

សាមណេរ អគ្គកាមោ អ៊ឹម សុជាន សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ចាន់ បូណា សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ិន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទូន ឧបាសក ហុក សឹងហួត

ឧបាសក ឈួន សំណាង ឧបាសក ឃឿម សារ៉ែន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
| --- | --- |
| **អដ្ឋកថា ចូឡគោសិង្គសាលសូត្រ ទី១** | ១ |
| អធិប្បាយ ព្រៃសិង្គសាលវ័ន | ២ |
| ធម៌នៅរួមគ្នាជាសុខ ៩ ប្រការ | ១០ |
| **អដ្ឋកថា មហាគោសិង្គសាលសូត្រ ទី២** | ២៣ |
| កិត្តិសព្ទរបស់ព្រះមហាថេរ: | ៣០ |
| សេចក្តីស្និទស្នាលរវាងព្រះអានន្ទ និងព្រះសារីបុត្ត | ៣៣ |
| អ្នកសិក្សា និងពោលធម៌ដោយប្រពៃ | ៣៦ |
| ពាក្យជាសុភាសិត | ៤៥ |
| **អដ្ឋកថា មហាគោបាលសូត្រ ទី ៣** | ៤៨ |
| ភាពមិនឆ្លាតរបស់នាយគោបាល | ៤៨ |
| ភាពនៃភិក្ខុមិនឆ្លាត | ៥៥ |
| បវារណា ២ ប្រការ | ៦១ |
| **អដ្ឋកថា ចូឡគោបាលសូត្រ ទី ៤** | ៦៣ |
| ការចម្លងគោកាន់ត្រើយទន្លេ | ៦៤ |
| **អដ្ឋកថា ចូឡសច្ចកសូត្រ ទី ៥** | ៦៩ |
| ប្រវត្តិសង្ខេបរបស់សច្ចកនិគ្រន្ថ | ៧០ |
| ការលើកវាទ:រវាងព្រះសារីបុត្ត និងបរិញ្ជិកា | ៧២ |
| ការចចាររបស់សច្ចក: និងព្រះអស្សជិត្ថេរ | ៧៦ |

ព្រះមានព្រះភាគគ្រប់សង្កត់វាទៈរបស់និគ្រន្ថ ៧៩
ឧបមាបញ្ចក្ខន្ធ ៨៦
ការគម្រាមរបស់ស្ដេចសក្កទេវរាជ ៩០
ឧបមាដូចអសិរពិស ៩៣
ឧបមាដូចដើមចេក ៩៤
ការថ្វាយចង្ហាន់ដល់ព្រះមានព្រះភាគ ១០០

**អដ្ឋកថា មហាសច្ចកសូត្រ ទី ៦ ១០៤**
កាយភាវនា និងចិត្តភាវនា ១០៦
ពោលអំពីវេទនា ១០៩
ឧបមា ៤ ប្រការ ១១១
ការផ្សេងគ្នាក្នុងការបំពេញទុក្ករកិរិយា ១១៣
ហេតុអស្ចារ្យរបស់ព្រះមហាសត្វ ១១៧
ការចូលផលសមាបត្តិរបស់មានព្រះភាគ ១២១
ឧបនិស្ស័យរបស់សច្ចកនិគ្រន្ថ ១២៤

**អដ្ឋកថា ចូឡតណ្ហាសង្ខយសូត្រ ទី ៧ ១៣០**
ប្រវត្តិសង្ខេបព្រះនាងវិសាខា ១៣០
គ្រឿងប្រដាប់ លតាមហាបសាទ ១៣១
វត្តបដិបត្តិដើម្បីអស់ទៅនៃតណ្ហា ១៣៣
វិភាគៈ ២ ប្រការ ១៣៦
កិច្ចរបស់ទេវតាមានច្រើន ១៤២
ប្រវត្តិសង្ខេបរបស់ស្ដេចសក្កៈ ១៤៥
ព្រះមោគ្គល្លានញ៉ាំងវេជយន្តប្រាសាទឲ្យកម្រើក ១៤៩

**អដ្ឋកថា មហាតណ្ហាសង្ខយសូត្រ ទី ៨** ១៥២

*ទិដ្ឋិរបស់សាតិភិក្ខុ* ១៥២

*ធម៌អាស្រ័យបច្ច័យទើបកើត* ១៥៦

*ការតាំងឡើងនៃសត្វក្នុងគភ៌* ១៦៥

**អដ្ឋកថា មហាអស្សបុរសូត្រ ទី ៩** ១៧០

*អធិប្បាយ ពាក្យថា អស្សបុរៈ* ១៧០

*កិច្ចរបស់សមណៈ ៣ ប្រការ* ១៧២

*សុក្កធម៌ ២ ប្រការ* ១៧៤

*កាយសមាចា ២ ប្រការ* ១៧៧

*ការដេក ៤ ប្រការ* ១៨០

*ការប្រៀបធៀបនីវរណធម៌ ៥ ប្រការ* ១៨៤

*សុខក្នុងបឋមជ្ឈាន* ១៩២

*សុខក្នុងទុតិយជ្ឈាន* ១៩៣

*សុខក្នុងតតិយជ្ឈាន* ១៩៤

*សុខក្នុងចតុត្ថជ្ឈាន* ១៩៥

*ឧបមា ក្នុងបុព្វេនិវាសញ្ញាណ* ១៩៦

*ឧបមា ក្នុងទិព្វចក្ខុ , អាសវក្ខយញ្ញាណ* ១៩៧

**អដ្ឋកថា ចូឡអស្សបុរសូត្រ ទី ១០** ២០០

**ចូឡយមកវគ្គ** ២០៤

**អដ្ឋកថា សាលេយ្យកសូត្រ ទី ១** ២០៤

*ការសួរ ២ ប្រការ* ២០៩

| | |
|---|---|
| ពាក្យថា មាតាគ្រប់គ្រងជាដើម | ២១២ |
| ពាក្យថា និយាយកុហកជាដើម | ២១៤ |
| ពាក្យថា សម្ងំនរំពៃជាដើម | ២១៨ |
| ទេវលោក ២៦ ជាន់ | ២២១ |
| **អដ្ឋកថា វេរញ្ជកសូត្រ ទី ២** | **២២៣** |
| **អដ្ឋកថា មហាវេទល្លសូត្រ ទី ៣** | **២២៤** |
| ការសួរ ៥ យ៉ាង | ២២៤ |
| បុគ្គលអ្នកមានបញ្ញាតិច | ២២៧ |
| ការរៀនក្នុងសច្ចៈ ៤ | ២៣២ |
| ឧបមាឥន្ទ្រិយ ៥ | ២៣៩ |
| អធិប្បាយពាក្យថា បញ្ញា វិញ្ញាណ វេទនា សញ្ញា | ២៤៣ |
| បញ្ញា ២ យ៉ាង | ២៥១ |
| អធិប្បាយ ភព | ២៥៥ |
| វិមុត្តិ ២ យ៉ាង | ២៥៧ |
| កិច្ចបសាទរូប ៥ | ២៥៨ |
| សង្ខារ ៣ | ២៦៥ |
| ធម៌ប្រមាណមិនបាន | ២៧២ |
| វត្ថុ ៩ យ៉ាង | ២៧៣ |
| វត្ថុ ១៣ យ៉ាង ឈ្មោះថា ការរួបផុតនៃចិត្ត | ២៧៤ |
| **អដ្ឋកថា ចូឡវេទល្លសូត្រ ទី ៤** | **២៧៦** |
| ប្រវត្តិសង្ខេបព្រះនាងធម្មទិន្នាភិក្ខុនី | ២៨១ |
| ឧបាទាន និងឧបាទានក្ខន្ធ | ២៨៤ |

| | |
|---|---|
| ប្រៀបធៀបសក្កាយទិដ្ឋិ | ២៨៥ |
| មគ្គប្រកបដោយអង្គ ៨ | ២៨៨ |
| សង្ខារ ៣ យ៉ាង | ២៩៥ |
| អធិប្បាយ អនុស័យ | ៣០៤ |
| ឈ្មោះថា បណ្ឌិត | ៣០៩ |
| **អដ្ឋកថា ចូឡធម្មសមាទានសូត្រ ទី ៥** | **៣១១** |
| កម្ម និងវិបាកនៃកម្ម | ៣១៦ |
| **អដ្ឋកថា មហាធម្មសមាទានសូត្រ ទី ៦** | **៣១៩** |
| ពុទ្ធគុណ | ៣១៩ |
| មិច្ឆាចារ អភិជ្ឈា មិច្ឆាទិដ្ឋិ | ៣២២ |
| បាណាតិបាត ផរុសវាទ ព្យាបាទ | ៣២២ |
| ធម្មសមាទានសូត្រជាទីត្រេកអររបស់ពួកអមនុស្ស | ៣២៦ |
| **អដ្ឋកថា មហាវីមំសកសូត្រ ទី ៧** | **៣២៩** |
| ការសាកសួរ ៣ យ៉ាង | ៣២៩ |
| កល្យាណមិត្តជាព្រហ្មចារ្យទាំងមូល | ៣៣០ |
| ភ័យ ៤ ប្រការ | ៤៤៣ |
| សទ្ធារបស់នាយសូរៈ | ៣៥២ |
| **អដ្ឋកថា កោសម្ពិយសូត្រ ទី ៨** | **៣៥៥** |
| រឿង ឃោសិតសេដ្ឋី | ៣៥៥ |
| ឧបោសថពាក់កណ្តាល | ៣៥៧ |
| ការសាងវិហារបីកន្លែង | ៣៦២ |
| ការវិវាទរវាងភិក្ខុ ២ ពួក | ៣៦៣ |

រឿង សារាណិយធម៌ ៣៦៥
មេត្តា ៣ ប្រការ ៣៦៦
រឿង ការបំពេញសារាណិយធម៌របស់ភិក្ខុ ៣៧៣
រឿង ការបំពេញសារាណិយធម៌របស់នាងភិក្ខុនី ៣៧៦

**អដ្ឋកថា ព្រហ្មនិមន្តនិកសូត្រ ទី ៩** ៣៨០
ការត្រិះរិះរបស់មារមានចិត្តបាប ៣៨១
ព្រះមានព្រះភាគគ្របសង្កត់ព្រហ្ម ៣៨៩
បុព្វកម្មរបស់ព្រហ្ម ៤០០
កម្មដ្ឋាន ៣៨ ឈ្មោះថាជាកំពង់ចូលទៅកាន់ព្រះនិព្វាន ៤០៨

**អដ្ឋកថា មារតជ្ជនិយសូត្រ ទី ១០** ៤១៥
កាយនេះជារបស់មិនស្អាត ៤២៤

# អដ្ឋកថា ព្រះសុត្តន្តបិដក

# មជ្ឈិមនិកាយ

# ឈ្មោះ បបញ្ចសូទនី

# ភាគ ២២

## មហាយមកវគ្គវណ្ណនា

## ចូឡគោសិង្គសាលសូត្រទី ១

[១] *ចូឡគោសិង្គសាលសូត្រ មានបទផ្តើមថា* ***ឯវម្មេ សុតំ*** *។*

*បណ្តាបទទាំងនោះ បទថា* ***នាទិកេ វិហរតិ*** *សេចក្តីថា ក្នុងស្រុកមួយកន្លែង ក្នុងបណ្តាស្រុកពីរកន្លែងរបស់បុត្រជាក្មួយ និងរបស់អ៊ំ ទាំងពីរនាក់ អាស្រ័យស្រះទឹកមួយកន្លែង ឈ្មោះ* ***នាទិកា*** *។* ***បទថា គិញ្ជកាវសថេ*** *បានដល់ ទីសម្រាកធ្វើដោយឥដ្ឋ ។ បានឮថា សម័យមួយ ព្រះមានព្រះភាគ កាលនឹងធ្វើការសង្គ្រោះមហាជន ស្តេចចារិកទៅក្នុងដែនវជ្ជី ស្តេចយាងដល់នាទិកគ្រាម ។ អ្នកស្រុកនាទិកគ្រាមថ្វាយមហាទានចំពោះព្រះមានព្រះភាគ ស្តាប់ធម្មីកថា មានចិត្តជ្រះថ្លា ប្រឹក្សាគ្នាថា យើងនឹងសាងទីប្រថាប់ថ្វាយចំពោះព្រះសាស្តា សម្តែងរូបសត្វកាចជាដើម ត្រង់ជញ្ជាំង ជណ្តើរ និងសសរដោយឥដ្ឋទាំងនោះ សាងប្រាសាទ លាបដោយកំបោរ.ស ញ៉ាំង*

មាលាកម្ម និងលតាកម្មជាដើមឲ្យសម្រេច ក្រាលកម្រាលផែនដី គ្រែ និងតាំងជាដើម បង្អោនថ្វាយចំពោះព្រះសាស្តា ។ តមក ពួកអ្នកស្រុកក្នុងទីនេះសាងទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ មណ្ឌប និងទីចង្ក្រមជាដើមថ្វាយចំពោះភិក្ខុសង្ឃ ។ វិហារនោះ បានជាមហាវិហារដោយប្រការ ដូច្នេះ ។ លោកសំដៅយកវិហារនោះ ទើបពោលថា **គិញ្ជកាវសថេ** ដូច្នេះ ។ ប្រគាបឈើមានសណ្ឋានដូចស្នែងគោ តាំងឡើងពីដើមរបស់ដើមឈើធំមួយដើម ក្នុងបទថា **គោសិង្គសាលវនទាយេ** នោះ ។ ព្រៃនោះសូម្បីទាំងអស់ អាស្រ័យដើមឈើនោះ ទើបឈ្មោះថា គោសិង្គសាលវន ដូច្នេះ ។ បទថា **ទាយោ** នេះជាឈ្មោះរបស់ព្រៃ ដោយមិនផ្សេងគ្នា ព្រោះដូច្នោះ បទថា **គោសិង្គសាល-វនទាយេ** មានសេចក្តីថា ក្នុងព្រៃឈ្មោះគោសិង្គសាលវន ។

បទថា **វិហរន្តិ** បានដល់ សោយសាមគ្គីរសហើយ ។ វេលាកុលបុត្រទាំងនេះជាបុថុជ្ជន លោកពោលទុកក្នុងឧបរិបណ្ណាសកៈហើយ ។ ក្នុងទីនេះលោកពោលវេលាជាព្រះខីណាស្រព ។

ពិតហើយ ក្នុងវេលានោះ កុលបុត្រទាំងនោះ បានសេចក្តីពេញចិត្តបានទីពឹង សម្រេចបដិសម្ភិទាជាព្រះខីណាស្រព សោយសាមគ្គីហើយ ក្នុងទីនោះ ។ បទថា **យេន គោសិង្គសាលវនទាយោ តេនុបសង្កមិ** នេះ លោកពោលសំដៅ

ដល់ព្រៃនោះ ។

ព្រះមានព្រះភាគ មិនបានត្រាស់ប្រាប់អ្វីៗ ក្នុងបណ្ដាព្រះធម្មសេនាបតី ព្រះមហាមោគ្គល្លានត្ថេរ ឬព្រះអសីតិមហាសាវក ដោយទីបំផុតសូម្បីព្រះអានន្ទត្ថេរដែលជាឃ្លាំងធម៌ ទ្រង់កាន់បាត្រ និងចីវរដោយព្រះអង្គឯង ដូចដំរីចៀសចេញចាកសត្វ ដូចកេសរសីហរាជចេញចាកហ្វូង ដូចពពកត្រូវខ្យល់ទ្រង់ស្ដេចចូលទៅរកតែមួយព្រះអង្គឯង យ៉ាងនេះឯង ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបស្ដេចយាងទៅដោយព្រះអង្គឯងក្នុងនេះ ។ ឆ្លើយថា កុលបុត្រទាំង ៣ រមែងសោយសាមគ្គីរស ព្រោះទ្រង់នឹងលើកតម្កើងកុលបុត្រទាំងនោះ ព្រោះទ្រង់អនុគ្រោះពួកជនកើតក្នុងខាងក្រោយ និងព្រោះសេចក្ដីធ្ងន់ក្នុងព្រះធម៌ ។

បានឮថា ព្រះមានព្រះភាគនោះ បានទ្រង់ត្រិះរិះយ៉ាងនេះថា តថាគតនឹងលើកតម្កើងសរសើរកុលបុត្រទាំងនេះ ធ្វើបដិសណ្ឋារៈ សម្ដែងធម៌ដល់កុលបុត្រទាំងនោះ ព្រោះនឹងទ្រង់លើកតម្កើងយ៉ាងនេះប៉ុណ្ណោះ ទើបស្ដេចទៅ ។ ព្រះអង្គទ្រង់មានព្រះតម្រិះតទៅថា ក្នុងអនាគត កុលបុត្រទាំងឡាយគប្បីសម្គាល់ការនៅព្រមព្រៀងគ្នាថា ព្រះសម្មាសម្ពុទ្ធ ស្ដេចយាងមកកាន់សម្នាក់របស់កុលបុត្រ អ្នកនៅព្រមព្រៀងគ្នាដោយព្រះអង្គឯង ធ្វើបដិសណ្ឋារៈ

ទ្រង់សម្ដែងធម៌ លើកតម្កើងកុលបុត្រទាំង ៣ នរណានឹងមិនគប្បីទៅព្រម-
ព្រៀងគ្នា ដូច្នេះ នឹងធ្វើទីបំផុតនៃទុក្ខបានដាច់រហ័ស ដូច្នេះ សូម្បីព្រោះទ្រង់
នឹងអនុគ្រោះពួកជន អ្នកកើតក្នុងខាងក្រោយ ទើបស្ដេចយាងទៅ ។ ក៏ធម្មតា
ថា ព្រះពុទ្ធទ្រង់ជាអ្នកជូន់ក្នុងធម៌ ក៏សេចក្ដីជូន់ក្នុងធម៌របស់ព្រះពុទ្ធទាំងនោះ
មកហើយក្នុងរថវិនីតសូត្រ ព្រោះហេតុនោះ ព្រះអង្គទ្រង់ត្រិះរិះថា តថាគត
នឹងលើកតម្កើងធម៌ សូម្បីព្រោះសេចក្ដីជូន់ក្នុងធម៌នេះ ដូច្នេះ ។ ទើបបានស្ដេច
យាងទៅ ។

បទថា **ទាយបាលោ** ប្រែថា អ្នករក្សាព្រៃ អ្នករក្សាព្រៃនោះ រមែង
អង្គុយរក្សាគ្រប់គ្រងត្រង់ទ្វារព្រៃនោះ ដែលគេធ្វើរបងលោមព័ទ្ធទុកដោយប្រការ
ដែលពួកមនុស្សក្នុងប្រទេសគេប្រាថ្នាហើយ ហើយរមែងមិននាំផ្កាឈើ ផ្លែឈើ
ផឹរឈើ ឬសម្ភារៈក្នុងទីនោះចេញបាន ព្រោះដូច្នោះ លោកពោលថា **ទាយ-
បាលោ** ។ បទថា **អត្តកាមរូបា** សេចក្ដីថា ជាអ្នកប្រាថ្នា ប្រយោជន៍
ខ្លួនជាសភាវៈ ។ ពិតណាស់ បុគ្គលណាសូម្បីបួសហើយ ក្នុងសាសនានេះ
ចិញ្ចឹមជីវិតដោយអនេសនា ២១ មានវេជ្ជកម្ម ទូតកម្ម និងការបញ្ជូនដំណឹង
ជាដើម នេះនៅមិនទាន់ឈ្មោះថា ជាអ្នកប្រាថ្នាប្រយោជន៍ខ្លួន ។ ចំណែកបុគ្គល
ណាបួសហើយក្នុងសាសនានេះ លះបង់អនេសនា ២១ ហើយតាំងនៅក្នុងចតុ-

ប្បារិសុទ្ធិសីល រៀនព្រះពុទ្ធវចនៈ អធិដ្ឋានធុតង្គល្មមសប្បាយ កាន់យកកម្មដ្ឋាន ដែលពេញចិត្តក្នុងអារម្មណ៍ ៣៨ លះលង់ស្រុក ចូលព្រៃ ញុំាងសមាបត្តិ ឲ្យកើត ត្រាច់ធ្វើវិបស្សនាកម្មដ្ឋាន នេះឈ្មោះថា ជាអ្នកប្រាថ្នាប្រយោជន៍ខ្លួន ។ កុលបុត្រទាំង ៣ នោះ បានជាបែបនេះ ។ ព្រោះហេតុនោះ លោកពោលថា **អត្តកាមរូបា វិហរន្តិ** ។ គេសូមអង្វរព្រះមានព្រះភាគថា សមណៈកុំធ្វើសេចក្តី មិនសុខស្រួលដល់កុលបុត្រទាំងនោះឡើយ ។

បានឮថា នាយទាយបាលនោះ មានវិតក្កៈយ៉ាងនេះថា កុលបុត្រទាំង នេះ នៅព្រមព្រៀងគ្នា សេចក្តីទាស់ទែង ឈ្លោះ និងវិវាទ រមែងប្រព្រឹត្តទៅ ក្នុងទីពួកមនុស្សខ្លះទៅហើយ ទាំងពីរមិនទៅផ្លូវមួយជាមួយគ្នា ដូចគោកាច់ ស្នែងស្រួច ដើរវាត់ គ្រាខ្លះសូម្បីព្រះពុទ្ធ កាលទ្រង់ធ្វើយ៉ាងនេះ គប្បីទម្លាយ សេចក្តីនៅយ៉ាងព្រមព្រៀងរបស់កុលបុត្រទាំងនេះ ក៏ឯព្រះអង្គគួរជ្រះថ្លា មាន ព្រះឆវីវណ្ណដូចមាស ឃើញនឹងចង់ក្នុងរស គប្បីទម្លាយអប្បមាទវិហារធម៌ របស់កុលបុត្រទាំងនេះ ដោយការពោលសរសើរអ្នកថ្វាយរបស់ដ៏ប្រណីត និង អ្នកឧបដ្ឋាកខ្លួនតាំងពីស្តេចយាងទៅដល់ សូម្បីស្ថានទីនៅរបស់កុលបុត្រទាំង នេះ កំណត់ទុកពិតប្រាកដ គឺ បណ្ណសាលា ៣ ទីចង្ក្រម ៣ ទី សម្រាកពេល ថ្ងៃ ៣ គ្រែតាំង ៣ ចំណែកសមណៈនេះ មានកាយធំ ប្រាកដជាចាស់ជាង

នឹងដេញកុលបុត្រទាំងនេះ ចេញចាកសេនាសនៈក្នុងកាលដែលមិនគួរ សេចក្តីសុខស្រួលនឹងមានដល់កុលបុត្រទាំងនោះ សូម្បីក្នុងទីទាំងពួង ដោយប្រការដូច្នេះ គេមិនប្រាថ្នាយ៉ាងនោះ ទើបសូមអង្វរព្រះមានព្រះភាគថា ព្រះអង្គកុំធ្វើសេចក្តីមិនសុខស្រួលដល់កុលបុត្រទាំងនោះឡើយ ។

សួរថា ក៏នាយទាយបាលនោះដឹង ទើបហាម ឬមិនដឹង ទើបហាម ។ ឆ្លើយថា ពិតហើយ តាំងពីព្រះតថាគតចាប់បដិសន្ធិ បាដិហារិយ៍ដែលញុំាងម៉ឺនចក្រវាឡឲ្យញាប់ញ័រជាដើម ប្រព្រឹត្តទៅហើយក៏ពិត សូម្បីដូច្នោះ តែអ្នកមិនមានកម្លាំងនៅព្រៃ ខ្វល់ខ្វាយតែការងារ មិនអាចនឹងកំណត់ដឹងបាដិហារិយ៍ទាំងនោះបាន ។ ក៏ធម្មតាថា ព្រះសម្មាសម្ពុទ្ធ កាលណាមានភិក្ខុច្រើនពាន់ជាបរិវារ ត្រាច់សម្តែងពុទ្ធានុភាពដោយព្រះរស្មីមួយព្យាម ដោយអនុព្យញ្ជនៈ ៨០ និងដោយព្រះសិរី គឺ មហាបុរិសលក្ខណៈ ៣២ កាលនោះ គេសួរថា នុ៎ះជាអ្នកណា ហើយគប្បីនឹងស្គាល់ ។ ក៏គ្រានោះ ព្រះមានព្រះភាគទ្រង់បិទបាំងពុទ្ធានុភាពទាំងអស់នោះទុក ក្នុងស្រទាប់ចីវរ ទ្រង់ប្រដាប់បាត្រ និងចីវរដោយព្រះអង្គឯង ស្តេចទៅដោយភេទដែលមិនមានអ្នកណាស្គាល់ ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ដែលត្រូវបិទបាំងទុកក្នុងស្រទាប់ពពក ។ នាយទាយបាលមិនដឹងសេចក្តីនោះ ទើបហាមដោយប្រការដូច្នេះ ។ បទថា ឯត-

**ទវោច** សេចក្តីថា បានឮថា ព្រះថេរៈស្តាប់ពាក្យរបស់នាយទាយបាលថា **មា សមណា** ដូច្នេះ ទើបគិតថា យើងនៅជាមួយគ្នា ៣ នាក់ ក្នុងទីនេះ មិនមានបព្វជិតដទៃឡើយ ក៏នាយទាយបាលនេះ និយាយដូចគ្នានិយាយនឹងបព្វជិត នុ៎ះជាអ្នកណាហ្ន៎ ។ ដូច្នេះហើយ ចេញចាកទីសម្រាកពេលថ្ងៃ ឈរត្រង់ទ្វារសម្លឹងមើលផ្លូវ ក៏បានឃើញព្រះដ៏មានព្រះភាគ ។ សូម្បីព្រះដ៏មានព្រះភាគ ក៏ទ្រង់បញ្ចេញព្រះរស្មីពីព្រះវរកាយ ព្រមគ្នាដែលព្រះថេរៈឃើញព្រះរស្មីមួយព្យាម ក្លឹដោយព្រះអនុព្យញ្ជនៈ ៨០ រុងរឿងដូចផែនមាសដែលផ្សាយចេញ ។ ព្រះថេរៈគិតថា នាយទាយបាលនេះ និយាយនឹងបុគ្គលដ៏ប្រសើរក្នុងលោកនៅមិនទាន់ស្គាល់ និយាយដូចនឹងភិក្ខុរូបណាមួយ ដូចលូកដៃចាប់អាសេរ្តិសបើកពពារត្រង់ក កាលនឹងហាម ទើបបានពោលពាក្យជាដើមថា **មា អាវុសោ ទាយបាល** ដូច្នេះ ។ បទថា **តេនុបសង្កមិ** សេចក្តីថា ព្រោះហេតុអ្វី មិនធ្វើការទទួលព្រះមានព្រះភាគហើយ ទើបចូលគាល់ ។

បានឮថា ព្រះអនុរុទ្ធៈមានសេចក្តីត្រិះរិះយ៉ាងនេះថា យើង ៣ នាក់នៅព្រមព្រៀងគ្នាក៏នឹងមិនមាន យើងនឹងនាំយកមិត្តជាទីស្រឡាញ់ ទៅធ្វើការទទួលព្រះមានព្រះភាគ ជាទីស្រឡាញ់របស់យើងយ៉ាងណា ក៏ជាទីស្រឡាញ់ សូម្បីរបស់សម្មាញ់របស់យើងយ៉ាងនោះ ដូច្នេះ ជាអ្នកប្រាថ្នា នឹងធ្វើការទទួល ព្រម

ដោយបិយមិត្តទាំងនោះ ទើបមិនធ្វើដោយខ្លួនឯង ចូលទៅគាល់ ចំណែកអាចារ្យពួកខ្លះពោលថា ផ្លូវជាទីស្តេចមករបស់ព្រះមានព្រះភាគ មាននៅក្នុងទីបំផុតនៃទីចង្រ្កម ជិតទ្វារបណ្ណសាលារបស់ព្រះថេរៈទាំងនោះ ព្រោះដូច្នោះ ព្រះថេរៈទើបទៅឲ្យសញ្ញាដល់ព្រះថេរៈទាំងនោះ ។ បទថា **អភិក្កមញ្ញថ** ប្រែថា មកផ្លូវនេះចុះ ។ បទថា **បាទេ បក្ខាលេសិ** សេចក្តីថា ព្រះថេរៈកាន់យកទឹកពណ៌កែវមណីដោយដៃ ដូចក្រឡាសំណាញ់ ស្រដៀងបទុមដែលរីក ប្រូចទឹកត្រង់ខ្នងព្រះបាទទាំង ២ មានពណ៌ដូចមាស ដុសជម្រះសម្អាតព្រះបាទ ធូលីមិនបានពាល់ត្រូវព្រះវរកាយរបស់ព្រះពុទ្ធ ។

សួរថា ព្រោះហេតុអ្វី ទើបត្រូវលាង ។ ឆ្លើយថា ដើម្បីកំណត់រដូវរបស់ព្រះវរកាយ និងដើម្បីឲ្យចិត្តរបស់ភិក្ខុទាំងនោះរីករាយ ចិត្តរបស់ភិក្ខុទាំងនោះ ត្អែតស្កប់ស្កល់ដោយសោមនស្សដ៏មានកម្លាំងថា ព្រះមានព្រះភាគទ្រង់លាងព្រះបាទដោយទឹកដែលយើងនាំមកហើយ ទ្រង់បានធ្វើការប្រើប្រាស់ដូច្នេះ ព្រោះដូច្នោះ ទើបលាង ។

[២] បទថា **អាយស្មន្តំ អនុរុទ្ធំ ភគវា ឯតទវោច** សេចក្តីថា បានឮថា ព្រះអនុរុទ្ធនោះ ជាអ្នកចាស់ជាងភិក្ខុទាំងនោះ កាលធ្វើការសង្គ្រោះដល់លោកអនុរុទ្ធនោះ ក៏ជាការធ្វើដល់លោកដ៏សេសផងដែរ ព្រោះដូច្នោះ

ព្រះមានព្រះភាគ បានត្រាស់ពាក្យជាដើមនេះថា **កច្ចិ វោ អនុរុទ្ធា** ដូច្នេះ ព្រោះព្រះថេរៈមួយអង្គ ។

បណ្ដាបទទាំងនោះ បទថា **កច្ចិ** ជានិបាត ចុះក្នុងអត្ថថា ពាក្យសួរ ។ បទថា **វោ** ជាឆដ្ឋីវិភត្តិ ។ មានអធិប្បាយថា ព្រះមានព្រះភាគត្រាស់សួរដល់ភិក្ខាចារវត្តថា ម្នាលអនុរុទ្ធៈ នន្ទិយៈ កិម្ពិលៈ ពួកអ្នកល្មមអត់ធន់បានឬ ឥរិយាបថរបស់ពួកអ្នកទ្រាំបានឬ ល្មមឲ្យប្រព្រឹត្តទៅបានឬ ពួកអ្នកល្មមញុំាងជីវិតឲ្យប្រព្រឹត្តទៅ គឺ បន្តទៅបានឬ មិនលំបាកដោយដុំបាយ បិណ្ឌបាតឬ ពួកអ្នករកដុំបាយបានងាយឬ ពួកមនុស្សឃើញពួកអ្នកមកព្រមគ្នាហើយ ទើបសម្គាល់បាយយាគូមួយវែកឬ ភិក្ខាមួយវែកដែលគួរថ្វាយ ព្រោះដូច្នោះ ក៏អ្នកមិនលំបាកដោយបច្ច័យ អាចបំពេញសមណធម៌បាន ឬថា នេះជាវត្តរបស់បព្វជិត កាលដូច្នោះ ព្រះអង្គប្រទានពាក្យតបហើយ កាលនឹងទ្រង់សួរដល់សាមគ្គីរសថា ម្នាលអនុរុទ្ធៈ នន្ទិយៈ និងកិម្ពិលៈ ពួកអ្នកជារាជបព្វជិត មានបុណ្យច្រើនពួកមនុស្ស មិនថ្វាយដល់ពួកអ្នកដែលនៅក្នុងព្រៃហើយ នឹងសម្គាល់វត្ថុដែលគួរឲ្យដល់អ្នកណាដទៃហ្ន៎ ក៏ពួកអ្នកឆាន់របស់នេះហើយ នៅចង្អៀតគ្នានិងគ្នាដូចកូនម្រឹគឬ ឬថា ពួកអ្នកនៅមានសេចក្ដីព្រមព្រៀងគ្នា ទើបត្រាស់ពាក្យជាដើមថា **កច្ចិ បន វោ អនុរុទ្ធា សមគ្គា** ដូច្នេះ ។ បណ្ដាបទទាំងនោះ

បទថា **ខីរោទកីភូតា** សេចក្តីថា ទឹកដោះ និងទឹកផ្សំគ្នា រមែងមិនបែកគ្នា ចូលដល់ដូចជាចំណែកតែមួយ ត្រាស់សួរថា ពួកអ្នកនៅដោយការសាមគ្គីយ៉ាងនេះ ឬ ដូចចិត្តប្បាទ ចូលដល់ភាពជាចំណែកតែមួយឬ ។ បទថា **បិយចក្ខូហិ** សេចក្តីថា ចក្ខុ គឺ ការចូលទៅតាំងមេត្តាចិត្ត សម្លឹងមើល ឈ្មោះថា **បិយចក្ខុ** ។ ត្រាស់សួរថា ពួកអ្នកក្រឡេកមើលគ្នានិងគ្នា ដោយចក្ខុបែបនោះឬ ។ បទថា **តគ្ឃ** ជានិបាតចុះក្នុងអត្ថថា ចំណែកតែមួយ ដូចលោក ពោលថា **មយំ ភន្តេ** ដោយចំណែកតែមួយ ។ បទថា **យថា** ក្នុងបទថា **យថាកថំ បន** នេះត្រឹមតែជានិបាត ។ បទថា **កថំ** ប្រែថា សួរដល់ហេតុ មានអធិប្បាយថា ពួកអ្នកនៅរួមគ្នាយ៉ាងនេះ បានយ៉ាងណា គឺ នៅដោយហេតុណា ពួកអ្នកចូរប្រាប់ហេតុនោះដល់តថាគតចុះ ។

[៣] បទថា **មេត្តំ កាយកម្មំ** បានដល់ កាយកម្ម ដែលប្រព្រឹត្តទៅដោយអំណាចមេត្តាចិត្ត ។ បទថា **អាវិ ចេវ រហោ ច** បានដល់ ចំពោះមុខនិងកំបាំងមុខ ។ សូម្បីក្នុងបទក្រៅនេះ ក៏មានន័យនេះឯង ។

ក្នុងបទនោះ កាយកម្ម និងវចីកម្ម រមែងបានក្នុងការនៅរួមគ្នាចំពោះមុខក្រៅនេះ រមែងបានក្នុងការនៅបែកគ្នា មនោកម្មបានក្នុងទីទាំងអស់ ពិតណាស់ កាលនៅរួមគ្នា គ្រែតាំងក្តី ភណ្ឌៈឈើក្តី ភណ្ឌៈដីក្តី យ៉ាងណា ដែលបុគ្គល

ម្នាក់រក្សាទុក មិនល្អក្នុងខាងក្រៅ ឃើញវត្ថុនោះ មិនធ្វើសេចក្ដីមើលងាយថា វត្ថុនេះ អ្នកណាប្រើហើយ កាន់យកមករក្សាទុក ដូចដែលខ្លួនរក្សាទុកមិនល្អ ក៏ឬថា ផ្គត់ផ្គង់ បានដែលគួរផ្គត់ផ្គង់ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ កាលបុគ្គលម្នាក់ចៀសទៅ រក្សាសេនាសនៈ បរិក្ខារ ដែលគេរក្សាទុកមិនល្អ ឬថា ចាំមើលទីដែលគួរចាំ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។ កាលនៅរួមគ្នា ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ រមែងមានក្នុងការធ្វើ មានជាដើមយ៉ាងនេះ ថា សម្មោទនីយកថា ដ៏ពីរោះ បដិសណ្ឋារៈ សារាណីយកថា ធម្មកថា សរ-កញ្ញៈ សួរបញ្ហា ឆ្លើយបញ្ហានឹងព្រះថេរៈទាំងឡាយ ។ ក៏កាលព្រះថេរៈចៀស ទៅពោលគុណ មានជាដើមថា ព្រះនន្ទិយត្ថេរ ព្រះកិម្ពិលត្ថេរ ជាមិត្ត ជាទី ស្រឡាញ់របស់យើង ដល់ព្រមដោយសីលយ៉ាងនេះ ដល់ព្រមដោយអាចារៈ យ៉ាងនេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ។ ក៏កាលប្រមូលមកយ៉ាងនេះថា សូមព្រះនន្ទិយត្ថេរ កិម្ពិលត្ថេរ ដែលជាបិយមិត្តរបស់យើង ចូរជាអ្នកមិនមាន ពៀរ ចូរជាអ្នកមិនបៀតបៀន ចូរជាអ្នកមានសេចក្ដីសុខចុះ ដូច្នេះ ឈ្មោះថា មេត្តាមនោកម្ម ទាំងចំពោះមុខ ទាំងកំបាំងមុខ ។

បទថា **នានា ហិ ខោ នោ ភន្តេ កាយា** សេចក្ដីថា អ្នកណាៗ មិន អាចធ្វើកាយឲ្យរួមគ្នាបាន ដូចញ៉ីម្សៅ និងជីស្អិត ។ បទថា **ឯកញ្ច បន**

**មញ្ញេចិត្តំ** លោកសម្តែងថា ចំណែកចិត្តរបស់ពួកខ្ញុំព្រះអង្គ ឈ្មោះថា ដូចគ្នាតែម្យ៉ាង ព្រោះអត្ថថា រួមគ្នា មិនដាច់សូន្យ មិនប្រាសចាកគ្នា ព្រមព្រៀងគ្នា សួរថា ក៏ភិក្ខុទាំងនោះ រក្សាចិត្តរបស់ខ្លួន ប្រព្រឹត្តតាមអំណាចចិត្តរបស់លោក ក្រៅនេះយ៉ាងណា ។ ឆ្លើយថា ស្មឹមឡើងក្នុងបាត្ររបស់ភិក្ខុមួយរូប ចីវររបស់ភិក្ខុមួយរូបសៅហ្មង បរិកណ្ឌកម្មរមែងមានដល់ភិក្ខុមួយរូប បណ្តាភិក្ខុទាំងនោះ ស្មឹមកើតឡើងដល់បាត្ររបស់អ្នកណា កាលអ្នកនោះ ប្រាប់ថា ម្នាលអ្នកមានអាយុ ស្មឹមកើតឡើងដល់បាត្ររបស់ខ្ញុំ គួរដុត ដូច្នេះ អ្នកក្រៅអំពីនេះ មិននិយាយថា ចីវររបស់ខ្ញុំសៅហ្មង គួរបោក គ្រឿងប្រើរបស់ខ្ញុំគួរធ្វើ ដូច្នេះ ហើយចូលព្រៃ នាំឧសមកកាត់ជាកំណាត់គរទុកលើបាត្រ ហើយដុតបាត្រ តមកបោកចីវរខ្លះ ធ្វើរបស់ប្រើខ្លះ ។ កាលអង្គណាមួយប្រាប់មុនថា ម្នាលអ្នកមានអាយុ ចីវររបស់ខ្ញុំសៅហ្មងគួរបោក បណ្ណសាលារបស់ខ្ញុំទ្រុឌទ្រោម គួរជុសជុលថ្មី ដូច្នេះ មានន័យដូចគ្នា ។

[៤] បទថា **សាធុ សាធុ អនុរុទ្ធា** សេចក្តីថា កាលភិក្ខុក្រាបទូលក្នុងខាងក្រោយថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាត ដូច្នេះ ព្រះមានព្រះភាគ មិនប្រទានសាធុការ ។

សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះឈ្មោះថា កវឡិង្ការាហារនេះ

របស់សត្វទាំងនេះ ប្រព្រឹត្តគ្នាមកជាអាចិន្ត្រៃ ចំណែកលោកសន្និវាសនេះ ទាស់ទែងគ្នាដោយច្រើន ។ សត្វទាំងនេះខុសចិត្តគ្នា ទាំងក្នុងអបាយលោក ទាំងក្នុងទេវតា និងមនុស្សលោក វេលាដែលសត្វទាំងនោះព្រមព្រៀងគ្នា រកបានលំបាក មានពេលខ្លះបានប៉ុណ្ណោះ ហេតុដូច្នោះ ព្រះមានព្រះភាគ បានប្រទានសាធុការក្នុងទីនេះ ព្រោះការនៅព្រមព្រៀងគ្នារកបានលំបាក ។

ឥឡូវនេះ កាលត្រាស់សួរលក្ខណៈ សេចក្តីមិនប្រមាទរបស់ភិក្ខុទាំងនោះ ទើបត្រាស់ពាក្យជាដើមថា **កច្ចិ បន វោ អនុរុទ្ធា** ។ បណ្តាបទទាំងនោះ បទថា **វោ** ត្រឹមតែជានិបាត ម្យ៉ាងទៀត ជាបឋមាវិភត្តិ សេចក្តីថា **កច្ចិ តុម្ហេ** ដូច្នេះ ។ បទថា **អម្ហាកំ** គឺ ក្នុងពួកយើង ៣ នាក់ ។ បទថា **បិណ្ឌាយ បដិក្កមតិ** សេចក្តីថា ត្រាច់ទៅបិណ្ឌបាតក្នុងស្រុកខាងក្រោយ ។ បទថា **អវក្កការបាតិំ** សេចក្តីថា ចោលបិណ្ឌបាតដ៏សេសចេញ លាងភាជនៈមួយ ៗ តាំងទុកដើម្បីរក្សាទុក ។

បទថា **យោ បច្ឆា** សេចក្តីថា បានឮថា ព្រះថេរៈទាំងនោះ ចូលទៅភិក្ខាចារមិនព្រមគ្នា ។

ក៏ព្រះថេរៈទាំងនោះ ចេញចាកផលសមាបត្តិ ជម្រះរាងកាយ ពីព្រឹកព្រលឹម បំពេញវត្តបដិបត្តិ ចូលទៅកាន់សេនាសនៈ កំណត់វេលាអង្គុយចូល

ផលសមាបត្តិ បណ្ដាព្រះថេរៈទាំងនោះ អង្គណាដែលអង្គុយមុន ក្រោកឡើងមុន ដោយការកំណត់វេលារបស់ខ្លួន អង្គនោះត្រាច់បិណ្ឌបាត ត្រឡប់មកទីឆាន់អាហារ រមែងដឹងថា “ ភិក្ខុ ២ រូបមកខាងក្រោយ យើងមកមុន ” កាលបើដូច្នោះ ចាត់ចែងបាត្រ ក្រាលអាសនៈជាដើម បើក្នុងបាត្រមានគ្រប់គ្រាន់ លោកក៏អង្គុយឆាន់ បើមាននៅសល់ ក៏រៀបទុកដាក់ក្នុងថាស គ្របថាសទុកឆាន់ ធ្វើភត្តកិច្ចស្រេចហើយ លាងបាត្រជូតឲ្យអស់ទឹក ដាក់ទុកក្នុងស្បោក រក្សាអាសនៈ កាន់បាត្រ និងចីវរ ចូលទៅកាន់ទីសម្រាករបស់ខ្លួន ៗ សូម្បីអង្គទី ២ មកហើយ រមែងដឹងបានថា មួយអង្គមកមុន មួយអង្គមកក្រោយ បើក្នុងបាត្រ មានភត្តល្មមប្រមាណ លោកក៏ឆាន់ បើមានតិច កាន់យកពីភាជនៈ ហើយឆាន់ បើមាននៅសល់ ក៏ដាក់ទុកក្នុងថាស ឆាន់តែល្មមប្រមាណ ចូលទៅកាន់ទីសម្រាក ដូចព្រះថេរៈអង្គមុន ៗ សូម្បីអង្គទី ៣ មកហើយ រមែងដឹងថា ពីរអង្គមកមុន យើងមកខាងក្រោយ សូម្បីលោកធ្វើភត្តកិច្ចស្រេច ដូចព្រះថេរៈអង្គទី ២ ក៏លាងបាត្រជូតឲ្យអស់ទឹក ដាក់ទុកក្នុងស្បោក លើកអាសនៈឡើងរក្សាទុក ចាក់ទឹកដែលសល់ក្នុងផ្ទាំងទឹកផឹកឬក្នុងផ្ទាំងទឹកប្រើ ហើយផ្កាប់ផ្ទាំង បើមានភត្តនៅសល់នៅក្នុងថាស នាំភត្តនោះទៅ ដោយន័យដែលពោលហើយ លាងថាស រក្សាបោសរោងឆាន់ ៗ

តមកចាក់សម្រាម លើកអំបោសឡើងរក្សា ក្នុងស្ថានទីផុតពីកណ្តៀរ កាន់បាត្រ និងចីវរចូលទៅកាន់ទីសម្រាក នេះជាវត្តក្នុងរោងឆាន់ ក្នុងការធ្វើកត្ត-កិច្ចក្នុងព្រៃ ខាងក្រៅវិហាររបស់ព្រះថេរៈទាំងឡាយ ទ្រង់សំដៅដល់សេចក្តីនេះ ទើបត្រាស់ពាក្យជាដើមថា **យោ បច្ឆា** ដូច្នេះ ។

ចំណែកពាក្យជាដើមថា **យោ បស្សតិ** គប្បីជ្រាបថា ជាវត្តខាងក្នុងវិហាររបស់ព្រះថេរៈទាំងឡាយ ។ បណ្តាបទទាំងនោះ បទថា **វច្ចឃដំ** ប្រែថា ឆ្នាំងជម្រះ ។

បទថា **រិត្តំ** គឺ ទទេ ។ បទថា **តុច្ឆកំ** ជាវេវចនៈរបស់បទថា **រិត្តំ** នោះឯង ។

បទថា **អវិសយ្ហំ** បានដល់ មិនអាចនឹងលើកឡើងបាន គឺ ធ្ងន់ខ្លាំង ។ បទថា **ហត្ថវិការេន** គឺ ដោយសញ្ញាដៃ បានឮថា ព្រះថេរៈទាំងនោះ កាន់ឆ្នាំងទឹកណាមួយ មានឆ្នាំងទឹកផឹកជាដើម ទៅស្រះបោក្ខរណី លាងខាងក្នុងនិងខាងក្រៅហើយ ត្រងទឹកដាក់ទុកត្រង់មាត់ប្រាំង ហៅភិក្ខុអង្គដទៃមកដោយវិការនៃដៃ មិនបញ្ចេញសំឡេងចំពោះ ឬមិនចំពោះ សួរថា ព្រោះហេតុអ្វី មិនបញ្ចេញសំឡេងចំពោះ ។ ឆ្លើយថា សំឡេងគប្បីរំខានភិក្ខុនោះ ។ សួរថា ព្រោះហេតុអ្វី បញ្ចេញសំឡេងមិនចំពោះ ឆ្លើយថា កាលឲ្យសំឡេងមិនចំពោះ

ភិក្ខុ ២ រូបគប្បីចេញទៅដោយយល់ថា យើងមុន យើងមុន ដូច្នេះ ។ តពីនោះ ក្នុងការងារ ២ រូបគប្បីធ្វើ អង្គទី ៣ គប្បីសម្រោក លោកជាអ្នកសង្រួមសំឡេង ទៅជិតទីសម្រោកពេលថ្ងៃរបស់ភិក្ខុមួយអង្គ បានឮថា ភិក្ខុឃើញហើយធ្វើសញ្ញាដៃ ភិក្ខុក្រៅអំពីនេះ រមែងមកដោយសញ្ញាដៃនោះ តពីនោះ ជនទាំងពីរយកដៃប្រទាក់គ្នាក្រោកឡើងដាក់លើដៃទាំងពីរ ព្រះមានព្រះភាគ ទើបត្រាស់សំដៅយកសេចក្តីនោះថា **ហត្ថវិការេន ទុតិយំ អាមន្តេ ត្វា ហត្ថវិលង្ឃិកេន ឧដ្ឋបេម** ដូច្នេះ ។

បទថា **បញ្ចាហិកំ ខោ បន** សេចក្តីថា ពាក្យនេះថា ក្នុងថ្ងៃ ១៤ កោច ថ្ងៃ ១៥ កោច តិថីទី ៨ កោច ជាថ្ងៃធម្មស្សវនៈតាមប្រក្រតី ព្រះថេរៈទាំង ២ អង្គ ផ្ទូតទឹក ក្នុងវេលាមិនទាន់ងងឹតពេកទេ រាល់ៗ ថ្ងៃ ធ្វើការងារនោះមិនឲ្យដាច់ រមែងទៅកាន់ទីសម្រោករបស់ព្រះអនុរុទ្ធត្ថេរ ។ ព្រះថេរៈសូម្បីទាំង ៣ អង្គ អង្គុយក្នុងទីនោះ សួរបញ្ហា ឆ្លើយបញ្ហាគ្នានិងគ្នា ក្នុងព្រះត្រៃបិដក បិដកណាមួយ កាលព្រះថេរៈទាំងនោះធ្វើយ៉ាងនេះដរាបអរុណរះ ។ បទថា **កច្ចិ បន វោ អនុរុទ្ធា អប្បមត្តា អាតាបិនោ បហិតត្តា វិហរថ** នេះ ព្រះមានព្រះភាគ ត្រាស់សំដៅដល់សេចក្តីនោះ ។ ព្រះថេរៈត្រូវព្រះមានព្រះភាគ ត្រាស់សួរលក្ខណៈ របស់សេចក្តីមិនប្រមាទហើយ ឆ្លើយលក្ខណៈរបស់សេចក្តី

មិនប្រមាទ ថ្វាយក្នុងទីតាំងនៃសេចក្តីប្រមាទ ដោយពាក្យមានប្រមាណប៉ុណ្ណោះថា គឺ វេលាចូលទៅទីភិក្ខាចារ វេលាចេញទៅ ការស្លៀកស្បង់ ការដណ្តប់ចីវរ ការត្រាច់ទៅដើម្បីបិណ្ឌបាតខាងក្នុងស្រុក ធម្មកថា អនុមោទនា ការចេញចាកស្រុកហើយ ធ្វើភត្តកិច្ច ការលាងបាត្រ រក្សាបាត្រ និងចីវរឲ្យរៀបរយ ទាំងនេះជាការធ្វើឲ្យយឺតយូរសម្រាប់ភិក្ខុពួកដទៃ ព្រោះដូច្នោះ ព្រះថេរៈកាលសម្តែងថា ដែលឈ្មោះថា វេលាប្រមាទ រមែងមិនមានដល់ខ្ញុំព្រះអង្គ ព្រោះការបណ្តែតបណ្តោយមានប្រមាណប៉ុណ្ណេះបានហើយ ទើបឆ្លើយលក្ខណៈរបស់សេចក្តីមិនប្រមាទថ្វាយ ក្នុងទីតាំងនៃសេចក្តីប្រមាទ ។

[៥] លំដាប់នោះ ព្រះមានព្រះភាគ ប្រទានសាធុការដល់ព្រះថេរៈនោះហើយ កាលទឹងត្រាស់សួរបឋមឈាន ទើបត្រាស់ទៀតថា **អត្ថិ បន តេ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧត្តរិមនុស្សធម្មា** គឺ ធម៌ដ៏ក្រៃលែងជាងធម៌របស់មនុស្ស ។

បទថា **អលមរិយញាណទស្សនវិសេសោ** បានដល់ គុណវិសេស គឺ ញាណទស្សនៈ អាចធ្វើភាពឲ្យជាព្រះអរិយៈ ។

បទថា **កឹ ហិ នោ សិយា ភន្តេ** សេចក្តីថា ព្រោះហេតុណា គុណវិសេសដែលសម្រេចហើយ នឹងមិនសម្រេចហ្ន៎ ។ បទថា **យាវទេវ** គឺ ត្រឹម

ណានោះឯង ។

កាលការសម្រេចបឋមឈាន ដែលព្រះថេរៈឆ្លើយបន្លាញច្បាស់ហើយយ៉ាងនេះ ព្រះមានព្រះភាគ កាលត្រាស់សួរទុតិយឈានជាដើម ទើបត្រាស់ថា **ឯត្តស្ស បន តេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សមតិក្កមាយ** គឺ ដើម្បីសេចក្តីឈានកន្លង ។ បទថា **បដិបស្សទ្ធិយា** គឺ ដើម្បីសេចក្តីស្ងប់រម្ងាប់ ។ ដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយក្នុងបទទាំងពួង ។

ចំណែកក្នុងបញ្ហាចុងក្រោយ កាលត្រាស់សួរនិរោធសមាបត្តិដែលបានសម្រេចដោយអំណាចលោកុត្តរញ្ញាណទស្សនៈ ទើបត្រាស់ថា **អលមរិយញ្ញាណទស្សនវិសេសោ** ដូច្នេះ ។ ព្រះថេរៈក្រាបទូលឲ្យច្បាស់ តាមសមគួរដល់ការសួរ ។ ក្នុងសេចក្តីនោះ ព្រះថេរៈពោលថា ព្រោះសេចក្តីសុខដែលមិនបានសោយ ស្ងប់ជាង ប្រណីតជាង សេចក្តីសុខដែលសោយហើយ ដូច្នោះ ពួកខ្ញុំព្រះអង្គពិចារណាមិនឃើញ សុខវិហារដទៃដ៏ក្រៃលែងជាង ប្រណីតជាងឡើយ ។

[៦] បទថា **ធម្មិយា កថាយ** សេចក្តីថា ភិក្ខុសូម្បីទាំងពួង សម្រេចកិច្ច ក្នុងសច្ចៈទាំង ៤ ដោយធម្មកថា ប្រកបដោយអានិសង្សនៃសាមគ្គីរសមិនមានពាក្យអ្វី ដែលលោកនឹងគប្បីពោលដើម្បីប្រយោជន៍ដល់ការសម្រេច

សច្ចៈទាំងនោះ ចំណែកព្រះមានព្រះភាគ ត្រាស់អានិសង្សនៃសាមគ្គីរសដល់ភិក្ខុទាំងនោះថា នេះជាអានិសង្ស និងនេះជាអានិសង្ស ដូច្នេះ ដោយសាមគ្គីរស ។ បទថា **ភគវន្តំ អនុសារេត្វា** គឺ តាមស្តេច ។

បានឮថា ពួកភិក្ខុទាំងនោះ ទទួលបាត្រ និងចីវររបស់ព្រះមានព្រះភាគ បានទៅបន្តិច ។ ក្នុងវេលាដែលភិក្ខុទាំងនោះ ជូនដំណើរស្តេចដល់ទីបំផុតបរិវេណនៃវិហារ ព្រះមានព្រះភាគទើបត្រាស់ថា យកបាត្រ និងចីវររបស់តថាគតមកចុះ ពួកអ្នកចូរនៅក្នុងទីនេះ ហើយទ្រង់ចៀសទៅ ។ បទថា **តតោ បដិនិវត្តិត្វា** បានដល់ ត្រឡប់អំពីទីទៅហើយ ។

បទថា **កិន្នុ ខោ មយំ អាយស្មតោ** សេចក្តីថា ភិក្ខុទាំងឡាយអាស្រ័យព្រះមានព្រះភាគ សម្រេចគុណ មានបព្វជ្ជាជាដើមហើយ ក៏វង្វៀសដោយការពោលគុណរបស់ខ្លួន ពោលហើយ ព្រោះជាអ្នកប្រាថ្នាតិចក្នុងមគ្គផលដែលសម្រេច ។ បទថា **ឥមាសញ្ច ឥមាសញ្ច** បានដល់ លោកិយធម៌ និងលោកុត្តរធម៌ មានបឋមឈានជាដើម ។

បទថា **ចេតសា ចេតោ បរិច្ច វិទិតោ** សេចក្តីថា ព្រះថេរៈកំណត់ចិត្តដោយចិត្តហើយ ដឹងយ៉ាងនេះថា " ថ្ងៃនេះលោកដ៏មានអាយុរបស់យើងញុំាងវេលាឲ្យកន្លងទៅដោយលោកិយសមាបត្តិ ថ្ងៃនេះញុំាងវេលាឲ្យកន្លងទៅ

ដោយលោកុត្តរសមាបត្តិ ។ បទថា **ទេវតាបិ មេ** សេចក្តីថា សូម្បីពួកទេវតាប្រាប់យ៉ាងនេះថា បពិត្រលោកម្ចាស់អនុរុទ្ធដ៏ចម្រើន ថ្ងៃនេះ លោកម្ចាស់នន្ទិយត្ថេរ ញុំាងវេលាឲ្យកន្លងទៅដោយសមាបត្តិ , ថ្ងៃនេះ លោកម្ចាស់កិម្ពិលត្ថេរ ញុំាងវេលាឲ្យកន្លងទៅដោយសមាបត្តិនេះ បទថា **បញ្ហាភិបុដ្ឋេន** សេចក្តីថា យើងត្រៀមមាត់ ទុកដោយហេតុមានប្រមាណប៉ុណ្ណោះថា សូម្បីសេចក្តីនោះ យើងដឹងហើយដោយខ្លួនឯង ឬទេវតាប្រាប់ ដូច្នេះ ។ លើកពាក្យដែលមិនទាន់សួរ ក៏មិនពោលសួរ ។ ចំណែកព្រះមានព្រះភាគ ត្រូវសួរបញ្ហា គឺ ត្រូវភិក្ខុសួរបញ្ហា ទ្រង់បានត្រាស់បញ្ជាក់ ព្រះអង្គទើបត្រាស់ថា ពួកអ្នកមិនទាន់ពេញចិត្តក្នុងសេចក្តីនោះឬ ។

[៧] បទថា **ទីឃោ** មកហើយក្នុងគាថា យ៉ាងនេះថា **មណិ មានិច វេទីឃោ អថោ សេរីសកោ សហ** ជាទេវកជមួយអង្គ ក្នុងចំនួនយក្ខសេនាបតី ២៨ អង្គអ្នកត្រូវសួរ ។ បទថា **បរជនោ** ជាឈ្មោះរបស់យក្ខនោះ ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា បានឮថា យក្ខនោះ ត្រូវស្តេចវេស្សវ័ណបញ្ជូនទៅ កាលទៅកាន់ទីកន្លែងមួយ ឃើញព្រះមានព្រះភាគ ទ្រង់ប្រដាប់បាត្រនិងចីវរដោយព្រះអង្គឯង ចេញចាកទីសម្រាកសាងដោយឥដ្ឋ ចន្លោះព្រៃគោសិង្គសាលវ័ន គិតថា ព្រះមានព្រះភាគទ្រង់ប្រដាប់បាត្រ និងចីវរ ដោយ

ព្រះអង្គឯង ស្តេចទៅកាន់សម្នាក់របស់កុលបុត្រទាំង ៣ ក្នុងព្រៃគោសិង្គ-សាលវ័ន ព្រះធម៌ទេសនានឹងមានច្រើនក្នុងថ្ងៃនេះ សូម្បីយើងគប្បីជាអ្នកមានចំណែកនៃទេសនានោះ ដើរតាមស្នាមព្រះបាទរបស់ព្រះសាស្តា ដោយកាយដែលប្រាកដ ឈរស្តាប់ធម៌ក្នុងទីមិនឆ្ងាយ កាលព្រះសាស្តាស្តេចទៅ ក៏មិនទៅឈរក្នុងទីនោះ ដើម្បីនឹងមើលថា ព្រះថេរៈទាំងនោះ នឹងធ្វើអ្វីគ្នា ដូច្នេះក្នុងខណៈនោះ ឃើញព្រះថេរៈទាំងពីររូបនោះ ហួងហែង ព្រះអនុរុទ្ធត្ថេរៈគិតថា ព្រះថេរៈទាំងនេះ អាស្រ័យព្រះមានព្រះភាគ សម្រេចគុណទាំងពួង មានបព្វជ្ជាជាដើម កំណាញ់ចំពោះព្រះមានព្រះភាគ មិនក្លាហាន ពួនសម្ងំហួសប្រមាណ បិទបាំង ឥឡូវនេះ យើងនឹងមិនឲ្យលោកបិទបាំង យើងនឹងប្រកាសគុណរបស់ព្រះថេរៈទាំងនោះ តាំងពីផែនដីដរាបដល់ព្រហ្មលោក ។ ទើបចូលគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។ បទថា **លាភា ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកដែនវជ្ជី រមែងបានគាល់ព្រះមានព្រះភាគ និងបានឃើញកុលបុត្រទាំង ៣ នេះ រមែងបានថ្វាយបង្គំ ថ្វាយទេយ្យធម៌ បពិត្រព្រះអង្គដ៏ចម្រើន ជាលាភរបស់អ្នកដែនវជ្ជីទាំងនោះ ។ បទថា **សទ្ទំ សុត្វា** សេចក្តីថា បានឮថា យក្ខនោះ បញ្ចេញសំឡេងខ្លាំង ដោយអានុភាពនៃយក្ខបន្ទឹវាចានោះគ្របដណ្តប់ដែនវជ្ជីទាំងមូល ។ ព្រោះហេតុនោះ ភូម្មទេវតាដែល

ស្ថិតនៅត្រង់ដើមឈើ និងភ្នំជាដើមទាំងនោះៗ បានឮសំឡេងរបស់យក្ខនោះ ។ លោកសំដៅយកសេចក្ដីនោះ ពោលថា **សទ្ទំ សុត្វា** ដូច្នេះ ។

បទថា **អនុស្សាវេសុំ** បានដល់ បានឮសំឡេងខ្លាំងហើយ ស្រែកប្រកាសទៅ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។

[៨] បទថា **យាវ ព្រហ្មលោកា** បានដល់ ដរាបដល់អកនិដ្ឋព្រហ្មលោក ។ បទថា **តញ្ចេបិកុលំ** សេចក្ដីថា គប្បីជ្រាបសេចក្ដីក្នុងបទទាំងពួងយ៉ាងនេះថា កុលបុត្រទាំងនេះ ចេញពីត្រកូលរបស់យើងបួសហើយ មានសីល មានគុណ ដល់ព្រមដោយអាចារៈ មានកល្យាណធម៌យ៉ាងនេះ បើត្រកូលនោះមានចិត្តជ្រះថ្លា គប្បីរលឹកដល់កុលបុត្រទាំង ៣ នោះ យ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះធម៌ទេសនាដោយអនុសន្ធិ ដោយប្រការដូច្នេះឯង ។

( ចប់ អដ្ឋកថា ចូឡគោសិង្គសាលសូត្រ ទី ១ )

# អដ្ឋកថា

## មហាគោសិង្គសាលសូត្រ ទី ២

[៩] មហាគោសិង្គសាលសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ។

បណ្ដាបទទាំងនោះ បទថា **គោសិង្គសាលវនទាយេ** នេះ លោកពោលដើម្បីសម្ដែងទីអាស្រ័យ ។ ក៏សូត្រដទៃលោកសម្ដែងគោចរគ្រាមយ៉ាងនេះមុនថា ព្រះមានព្រះភាគប្រថាប់នៅក្នុងវត្តជេតពនវិហារ គោចរគ្រាមរបស់ព្រះមានព្រះភាគមិនប្រចាំ ក្នុងមហាគោសិង្គសាលសូត្រនេះ តែនឹងជាគោចរគ្រាមពេលខ្លះ ព្រោះដូច្នោះ លោកសម្ដែងដល់ទីនៅតែម្យ៉ាងថា ព្រះសូត្រនោះ មានព្រៃជាទីតាំង ។ បទថា **សម្ពហុលេហិ** គឺ ច្រើនណាស់ ។ បទថា **អភិញ្ញាតេហិ អភិញ្ញាតេហិ** បានដល់ មានឈ្មោះបោះសំឡេងប្រាកដក្នុងទីគ្រប់កន្លែង ។ បទថា **ថេរេហិ សាវកេហិ សទ្ធឹ** សេចក្ដីថា ព្រម គឺ រួមដោយលោកជាព្រះថេរៈ ព្រោះប្រកបដោយធម៌ធ្វើសេចក្ដីតាំងមាំ មានសេចក្ដីសង្រួមក្នុងបាតិមោក្ខជាដើម ជាព្រះសាវក ព្រោះកើតក្នុងទីបំផុតនៃការស្ដាប់ ។

ឥឡូវនេះ កាលទ្រង់សម្ដែងព្រះថេរៈទាំងនោះដោយសរុប ទើបត្រាស់ថា **អាយស្មតា ច សារីបុត្តេន** ដូច្នេះជាដើម ។ បណ្ដាព្រះថេរៈទាំងនោះ

ព្រះសារីបុត្រ មានឈ្មោះបោះសំឡេងក្នុងព្រះពុទ្ធសាសនាដោយគុណ មានសីល ជាដើមរបស់ខ្លួន គឺ ប្រាកដហើយ ដូចព្រះអាទិត្យព្រះចន្ទនៅកណ្ដាលផ្ទៃអាកាស ប្រាកដដល់អ្នកមានចក្ខុ និងដូចសាគរ ប្រាកដដល់អ្នកឈរលើច្រាំងនៃសមុទ្រ ។ ក៏គប្បីជ្រាបសេចក្ដីដែលព្រះថេរៈនោះជាធំ ដោយអំណាចនៃគុណ ដែលមក ហើយក្នុងព្រះសូត្រនេះតែម្យ៉ាងមិនបាន ។ គួរនឹងជ្រាបសេចក្ដីដែលព្រះថេរៈ ជាធំដោយអំណាចនៃព្រះសូត្រសូម្បីទាំងនេះ ដទៃចាកពីព្រះសូត្រនេះ គឺ ធម្ម-ទាយាទសូត្រ អនង្គណសូត្រ សម្មាទិដ្ឋិសូត្រ ចូឡសីហនាទសូត្រ មហាសីហ-នាទសូត្រ រថវិនីតសូត្រ មហាហត្ថិបទោបមសូត្រ មហាវេទល្លសូត្រ វត្ថុ-បមសូត្រ ទីឃនខសូត្រ អនុបទសូត្រ សេវិតព្វាសេវិតព្វសូត្រ សច្ចវិភង្គសូត្រ បិណ្ឌបាតបារិសុទ្ធិសូត្រ សម្បសាទនីយសូត្រ សង្គីតិសូត្រ ទសុត្តរសូត្រ បវារណាសូត្រ សុសិមសូត្រ ថេរបញ្ហសូត្រ មហានិទ្ទេស បដិសម្ភិទាមគ្គ ថេរសីហនាទសូត្រ ការបួស ឯតទគ្គៈ ដូច្នេះ ។ ពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះសារីបុត្រជាកំពូលនៃភិក្ខុ សាវកដែលមានបញ្ញារបស់តថាគត ។

សូម្បីព្រះមហាមោគ្គល្លាន ជាអ្នកចំប្រាកដដូចព្រះថេរៈ មានឈ្មោះបោះ សំឡេងដោយគុណ មានសីលជាដើម និងដោយគុណ មកហើយក្នុងព្រះសូត្រនេះ ។

មួយទៀត គួរជ្រាបសេចក្ដីដែលព្រះថេរៈនោះជាធំ ដោយអំណាចព្រះសូត្រសូម្បីទាំងនេះ គឺ អនុមានសូត្រ ចូឡតណ្ហាសង្ខយសូត្រ មារតជ្ជនីយសូត្រ ការញុំាងប្រាសាទឲ្យញាប់ញ័រ ការទូន្មាននន្ទោបនន្ទនាគរាជ ប្រកបដោយឥទ្ធិបាទទាំងអស់ ។ ការទៅកាន់ទេវលោកក្នុងកាលសម្ដែងយមកបាដិហារ្យ វិមានវត្ថុ បេតវត្ថុ ការបួស ឯតទគ្គៈ ដូច្នេះ ។ ពិតណាស់ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះមហាមោគ្គល្លានជាកំពូលនៃភិក្ខុសាវក ដែលមានឫទ្ធិរបស់តថាគត ។

សូម្បីព្រះមហាកស្សបៈជាអ្នកធំ ប្រាកដមកដូចព្រះថេរៈ មានឈ្មោះបោះសំឡេងដោយសីលាទិគុណ និងដោយគុណមកហើយក្នុងព្រះសូត្រនេះ ។ មួយទៀត គួរជ្រាបសេចក្ដីដែលព្រះថេរៈនោះ ជាធំដោយអំណាចព្រះសូត្រទាំងនេះ គឺ ចីវរប្បរិវត្តនសូត្រ ចន្ទោបមសូត្រ កស្សបសំយុត្តទាំងអស់ មហាអរិយវង្សសូត្រ ការបួសរបស់ព្រះថេរៈ ឯតទគ្គៈ ដូច្នេះ ។ ពិតណាស់ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះមហាកស្សបៈជាកំពូលនៃភិក្ខុសាវក ដែលទ្រទ្រង់ធុតង្គរបស់តថាគត ។

សូម្បីព្រះអនុរុទ្ធៈជាអ្នកធំប្រាកដ ដូចព្រះថេរៈ មានឈ្មោះបោះសំឡេងដោយសីលាទិគុណ និងដោយគុណ មកហើយក្នុងព្រះសូត្រនេះ មួយទៀត

គួរជ្រាបសេចក្តីដែលព្រះថេរៈនោះជាធំ ដោយអំណាចនៃព្រះសូត្រសូម្បីទាំងនេះ គឺ ចូឡគោសិង្គសូត្រ នឡកបានសូត្រ អនុត្តរិយសូត្រ ឧបក្កិលេសសូត្រ អនុរុទ្ធសំយុត្ត មហាបុរិសវិតក្កសូត្រ ការបួសរបស់ព្រះថេរៈ ឯតទគ្គៈ ដូច្នេះ ពិតណាស់ ក្នុងឯតទគ្គៈព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះអនុរុទ្ធ ជាកំពូលនៃភិក្ខុសាវកអ្នកមានទិព្វចក្ខុរបស់តថាគត ។

ក៏ព្រះរេវតៈ មាន ២ រូប គឺ ខទិរវនិយរេវតៈ ១ កង្ខារេវតៈ ១ ក្នុងបទថា **អាយស្មតា ច រេវតេន** នេះ ក្នុង ២ រូបនោះ ក្នុងទីនេះមិនប្រាថ្នាយកព្រះខទិរវនិយរេវតៈ ដែលជាប្អូនប្រុសរបស់ព្រះធម្មសេនាបតី ។ ចំណែកព្រះថេរៈច្រើនដោយសេចក្តីសង្ស័យយ៉ាងនេះថា ទឹកអំពៅគួរទេ ស្ករណ្តកបាយគួរទេ ប្រាថ្នាហើយថា រេវតៈក្នុងទីនេះ ។ ក៏ព្រះរេវតៈនោះ ជាអ្នកធំ ប្រាកដដូចព្រះថេរៈ មានឈ្មោះបោះសំឡេងដោយសីលាទិគុណ និងដោយគុណ មកហើយក្នុងព្រះសូត្រនេះ ។

មួយទៀត គួរជ្រាបសេចក្តីដែលព្រះថេរៈនោះជាធំក្នុងការបួស សូម្បីក្នុងឯតទគ្គៈនោះ ។ ពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះកង្ខារេវតៈ ជាកំពូលនៃភិក្ខុសាវក ដែលជាអ្នកមានឈានរបស់តថាគត ។

*សូម្បីព្រះអានន្ទត្ថេរ ជាអ្នកធំ ប្រាកដដូចជាព្រះថេរៈ មានឈ្មោះបោះសំឡេង ដោយសីលាទិគុណ និងដោយគុណ មកហើយក្នុងព្រះសូត្រនេះមួយទៀត គួរជ្រាបសេចក្ដីដែលព្រះថេរៈនោះ ជាធំដោយអំណាចនៃព្រះសូត្រទាំងនេះ គឺ សេលសូត្រ ពាហិតិយសូត្រ អនេញ្ជសប្បាយគោបកសូត្រ មោគ្គលល្លាន ពហុធាតុកៈ ចូឡសុញ្ញតៈ មហាសុញ្ញតៈ អច្ឆរិយព្ភូតសូត្រ ភទ្ទេករត្តៈ មហានិទាន មហាបរិនិព្វាន សុភសូត្រ ចូឡនិយលោកធាតុសូត្រ ការបួស ឯតទគ្គៈ ដូច្នេះ ពិតណាស់ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះអានន្ទជាកំពូលនៃភិក្ខុសាវក អ្នកជាពហុស្សូតរបស់តថាគត ។*

*បទថា* ***អញ្ញេហិ ច អភិញ្ញាតេហិ*** *សេចក្ដីថា ព្រះមានព្រះភាគប្រថាប់នៅក្នុងព្រៃគោសិង្គសាលវ័ន ព្រមដោយថេរសាវកជាច្រើន ជាអ្នកមានឈ្មោះបោះសំឡេង ព្រោះជាអ្នកមានគុណធំទាំងនេះ និងពួកដទៃក៏ទេ ។ ពិតហើយក្នុងគ្រានោះ ព្រះសារីបុត្រខ្លួនឯង មានបញ្ញាច្រើន នាំពួកភិក្ខុដែលមានបញ្ញាច្រើនសូម្បីពួកដទៃជាច្រើន នៅហែហមព្រះទសពល ។ ព្រះមហាមោគ្គល្លានខ្លួនឯងមានឫទ្ធិ ព្រះមហាកស្សបៈខ្លួនឯងជាធុតវាទៈ ព្រះអនុរុទ្ធខ្លួនឯងបានទិព្វចក្ខុ ព្រះរេវតៈខ្លួនឯងត្រេកអរក្នុងឈាន ព្រះអានន្ទខ្លួនឯងជាពហុស្សូត*

នាំពួកភិក្ខុអ្នកពហុស្សូតពួកដទៃ នៅហែហមព្រះទសពលក្នុងកាលនោះ ។ ព្រះមហាថេរៈ ដែលមានឈ្មោះបោះសំឡេងទាំងនោះ និងពួកដទៃ ក្នុងកាលនោះ គប្បីជ្រាបថា ពួកភិក្ខុប្រមាណបីម៉ឺននៅហែហមព្រះទសពល ដោយប្រការដូច្នេះឯង ។

បទថា **បដិសល្លានា វុដ្ឋិតោ** សេចក្តីថា ព្រះមហាមោគ្គល្លាន ចេញចាកវិវេកក្នុងផលសមាបត្តិ ។ បទថា **យេនាយស្មា មហាកស្សបោ តេនុ-បសង្កមិ** សេចក្តីថា បានឮថា ព្រះថេរៈចេញចាកទីពួនសម្ងំក្រឡេកមើលលោកធាតុខាងទិសបច្ឆិម បានឃើញសុរិយមណ្ឌល ៥០ យោជន៍គត់ កំពុងអស្តង្គត ដូចក្រវិលកំពុងធ្លាក់ចាកពីព្រះកណ្ណក្សត្រិយ៍ ដែលស្រវឹងទន់ទ្រេតទ្រោតក្នុងដងព្រៃ ដូចសំពត់កម្ពលក្រហមដែលគេប្រមូលដាក់ទុកក្នុងហិប ដូចថាសមាស ដែលមានតម្លៃមួយសែនកំពុងធ្លាក់ចាកពីក្អក ដែលប្រដាប់ដោយកែវមណី លំដាប់នោះ ក្រឡេកមើលលោកធាតុខាងទិសបស្ចិម បានឃើញចន្ទមណ្ឌលរះឡើងចាកផ្ទៃសមុទ្រ មានពណ៌ដូចពពក ដែលប្រដាប់ព្រមទាំងលក្ខណៈ មាន ៤៩ យោជន៍ លើកំពូលភ្នំចក្រវាឡផ្នែកខាងទិសបស្ចិម ដូចកង់ប្រាក់ភ្ជាប់ត្រង់ជុំវិលទៅ ដូចធ្លារទឹកដោះហូរចាកពីទប្រាក់ និងដូចហង្សសដែលទទះស្លាបទាំងពីរហើរទៅក្នុងផ្ទៃអាកាស ។ តពីនោះ ក៏ឯសាលវ័នក្នុង

សម័យនោះ តាំងពីគល់ដើមសាលៈរហូតដល់ចុង ផ្ការីកព្រោងព្រាត រុងរឿង ដូចគ្របដោយសំពត់បាវារ ២ ជាន់ ដូចចងទុកដោយចង្កោមមុក្តា កាលកេសរ ផ្កាឈើធ្លាក់ទៅក្នុងទីនោះ ៗ ផ្ទៃផែនដីដូចជាគ្រឿងបូជាដែលដេរជាស់ដោយ ផ្កាឈើ ដូចស្រោចដោយទឹកល័ក្ត ហួងឃ្មុំល្មមស្រវឹងកេសរផ្កាឈើ ហើរទៅ ក្នុងព្រៃស្រដៀង បញ្ចេញសំឡេងមួយៗ ក៏ថ្ងៃនោះ ជាថ្ងៃឧបោសថ លំដាប់ នោះ ព្រះថេរៈគិតថា ថ្ងៃនេះ យើងនឹងញ៉ាំងវេលាឲ្យកន្លងទៅដោយសេចក្តី ត្រេកអរក្នុងអ្វីហ្ន៎ ។ ក៏ជម្មតាថា ព្រះអរិយសាវក ស្រឡាញ់ការស្តាប់ធម៌ ព្រះថេរៈមានសេចក្តីត្រិះរិះថា ថ្ងៃនេះ យើងទៅកាន់សម្នាក់របស់ព្រះធម្ម-សេនាបតីត្ថេរៈដែលជាបងប្រុសរបស់យើង ហើយនឹងឲ្យវេលាកន្លងទៅដោយ សេចក្តីត្រេកអរក្នុងធម៌ ។ កាលទៅ ក៏មិនទៅតែម្នាក់ឯង ដោយគិតថា យើង នឹងនាំយកព្រះមហាកស្សបត្ថេរ ដែលជាសម្លាញ់របស់យើងទៅផង ដូច្នេះ ក៏ក្រោកចាកទីអង្គុយ រលាស់កម្រាលស្បែក ចូលទៅរកព្រះមហាកស្សបៈ ។

បទថា **ឯវមាវុសោតិ ខោ អាយស្មា មហាកស្សបោ** សេចក្តីថា ព្រោះព្រះថេរៈជាអរិយសាវកស្រឡាញ់ការស្តាប់ធម៌ ដូច្នោះ បានស្តាប់ពាក្យ របស់ព្រះមហាមោគ្គល្លានហើយ មិនអាងលេសអ្វីៗ ថា ម្នាលអ្នកមានអាយុ លោកទៅចុះ ខ្ញុំឈឺសិរសៈ ឬឈឺខ្នង ក៏មានចិត្តត្រេកអរ ពោលពាក្យជាដើម

ថា **ឯវមាវុសោ** ។ ក៏ព្រះថេរៈទទួលពាក្យហើយ ក្រោកចាកទីអង្គុយ រលាស់កម្រាលស្បែក តាមព្រះមហាមោគ្គល្លានទៅ ។ សម័យនោះព្រះមហាថេរៈ ២ រូប រុងរឿងដូចព្រះចន្ទ ២ ដួង រះឡើងរៀងគ្នា ដូចព្រះអាទិត្យ ២ ដួង ដូចស្តេចដំរីឆទ្ទន្ត ២ ដូចរាជសីហ៍ ២ និងដូចខ្លាធំ ២ ។ សម័យនោះព្រះអនុរុទ្ធត្ថេរ អង្គុយក្នុងទីសម្រាកពេលថ្ងៃ ឃើញព្រះមហាថេរៈ ២ រូប ទៅកាន់សម្នាក់របស់ព្រះសារីបុត្រ កាលក្រឡេកមើលលោកធាតុផ្នែកបច្ឆិមទិស បានឃើញព្រះអាទិត្យកំពុងកំបាំងព្រៃ កាលក្រឡេកមើលលោកធាតុផ្នែកខាងទិសបស្ចិម បានឃើញព្រះចន្ទកំពុងរះឡើងផុតជើងព្រៃ និងកាលក្រឡេកមើលដើមសាលៈ បានឃើញដើមសាលៈ មានផ្ការីកព្រោងព្រាត គិតថា ថ្ងៃនេះជាថ្ងៃឧបោសថ និងព្រះមហាថេរៈទាំងនេះជាបងប្រុសរបស់យើង ទៅកាន់សម្នាក់របស់ព្រះធម្មសេនាបតី ការស្តាប់ធម៌គប្បីមានច្រើន សូម្បីយើងនឹងជាអ្នកមានចំណែកនៃការស្តាប់ធម៌ ដូច្នេះ ហើយក្រោកចាកទីអង្គុយ រលាស់កម្រាលស្បែក ដើរទៅតាមស្នាមជើងព្រះមហាថេរៈ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះឯង ព្រះមហាមោគ្គលានៈ ព្រះមហាកស្សបៈ និងព្រះអនុរុទ្ធចូលទៅរកព្រះសារីបុត្រ ដូច្នេះ ។ បទថា **ឧបសង្កមឹសុ** សេចក្តីថា ព្រះមហាថេរៈទាំង ៣ រូប ឈររៀងគ្នា រុងរោចន៍ដូចព្រះចន្ទ ដូចព្រះអាទិត្យ និងដូច

រាជសីហ៍ ចូលទៅរក ។

[១០] ក៏ព្រះអានន្ទអង្គុយក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួន ឃើញព្រះមហាថេរៈចូលទៅរកយ៉ាងនេះហើយ គិតថា ការស្តាប់ធម៌ជាច្រើននឹងមានក្នុងថ្ងៃនេះ សូម្បីយើងក៏គប្បីជាអ្នកមានចំណែកនៃការស្តាប់ធម៌នោះ ក៏ឯយើងនឹងមិនទៅតែម្នាក់ឯងទេ នឹងនាំព្រះរេវតត្ថេរជាសម្លាញ់របស់យើងទៅផង រឿងទាំងអស់ គប្បីជ្រាបសេចក្តីពិស្តារតាមន័យដែលពោលហើយ ក្នុងការចូលទៅរករបស់ព្រះមហាមោគ្គល្លាន ព្រះមហាកស្សបៈ ព្រះអនុរុទ្ធ ព្រះថេរៈទាំង ២ រូបនោះ ឈរជ្រៀងគ្នា រុងរោចន៍ ដូចព្រះចន្ទ ២ ដួង ដូចព្រះអាទិត្យ ២ ដួង និងដូចរាជសីហ៍ ២ ក្បាល ចូលទៅរកដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ លោកទើបពោលថា ព្រះសារីបុត្របានឃើញហើយដែរ ដូច្នេះជាដើម ។ បទថា **ទិស្វានអាយស្មន្តំ អានន្ទំ ឯតទវោច** សេចក្តីថា ព្រះសារីបុត្រឃើញពីចម្ងាយ ទើបបានពោលពាក្យជាដើមនេះ ប្រកបដោយឧបចារកថា ដោយលំដាប់ថា សូមលោកចូរមកចុះ ដូច្នេះ ។ ក្នុងបទថា **រមណីយំ អាវុសោ** នេះ បានដល់ ព្រៃដែលគួររីករាយ ១ បុគ្គលដែលគួររីករាយ ១ ក្នុង ២ យ៉ាងនោះ ឈ្មោះថា ព្រៃដេរដាសដោយដើមខ្លឹម សាលៈ និងចម្បាជាដើម មានម្លប់ក្រាស់ មានដើមឈើផ្សេង ៗ បញ្ចេញផ្កា និងផ្លែ មានទឹកព្រម ក្រៅពីស្រុក , ព្រៃ

នេះឈ្មោះថា ជាទីគួររីករាយ លោកពោលសំដៅយកថា ព្រៃទាំងឡាយជាទីគួររីករាយ អ្នកដែលមានរាគៈទៅប្រាសចាកហើយ នឹងត្រេកអរក្នុងព្រៃដែលមិនជាទីត្រេកអររបស់ជន ព្រោះលោកទាំងនោះ មានរាគៈទៅប្រាសចាកហើយជាអ្នកមានប្រក្រតីមិនស្វែងរកកាម ដូច្នេះ ។

បើថា ព្រៃជាទីទួល ទឹកមិនមាន មួយជាទីរីករាយមានបន្ទាដុះ ចំណែកព្រះអរិយៈ មានព្រះពុទ្ធជាដើម ប្រថាប់នៅក្នុងព្រៃនេះ ព្រៃនេះ ឈ្មោះថា បុគ្គលគួររីករាយ លោកពោលសំដៅយកថា ព្រះអរហន្តទាំងឡាយនៅក្នុងទីណា ក្នុងស្រុកក៏ដោយ ក្នុងព្រៃក៏ដោយ ទីទំនាបក៏ដោយ ទីទួលក៏ដោយ ទីនោះជាភូមិស្ថានគួររីករាយ ដូច្នេះ ។ ចំណែកក្នុងទីនេះ បានទាំង ២ យ៉ាងនោះ ។ គ្រានោះ ព្រៃគោសិង្គសាលវ័ន មានផ្ការីកស្គុះស្គាយ ក្លិនផ្កាឈើក្រអូបសុសសាយ ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលដ៏ប្រសើរក្នុងលោកនេះ ព្រមទាំងទេវលោក ប្រថាប់នៅជាមួយនឹងពួកភិក្ខុដែលមានឈ្មោះបោះសំឡេង ប្រមាណបីម៉ឺនរូប ។ លោកសំដៅយកព្រៃនោះ ទើបពោលថា ម្នាលអានន្ទដ៏មានអាយុ ព្រៃគោសិង្គសាលវ័នជាស្ថានទីគួររីករាយ ដូច្នេះ ។

បទថា **ទោសិនា រត្តិ** គឺ ប្រាសចាកទោស មានអធិប្បាយថា វៀរចាកកាពងងឹតទាំងនេះ គឺ អ័ព្ទ ពពក ផ្សែង ធូលី រាហូ ។ បទថា **សព្វផា**

*លិផុល្លា* សេចក្ដីថា សាលៈមានផ្ការីកក្នុងទីគ្រប់កន្លែង តាំងពីគល់ដរាបដល់ចុង ឈ្មោះថា ផ្កាដែលមិនទាន់រីកហើយ រមែងមិនមាន ។ បទថា **ទិព្វា មញ្ញា គន្ធា សម្បវន្តិ** សេចក្ដីថា ក្លិនក្រអូបជារបស់ទិព្វ រមែងផ្សាយត្រឡប់ទូទៅ ដូចក្លិនក្រអូបរបស់ផ្កាមណ្ឌារវមាស និងកម្ទេចផង់ឈើចន្ទន៍ មានអធិប្បាយថា រមែងផ្សាយទៅ ដូចស្ថានទីរីករាយពេញចិត្តរបស់ស្ដេចសក្កៈ សុយាម សន្តុសិត និម្មានរតី បរនិម្មិតវសវត្តី និងស្ដេចមហាព្រហ្ម ។ បទថា **កថំ រូបេន អាវុសោ អានន្ទ** សេចក្ដីថា ព្រះអានន្ទត្ថេរ ជាសង្ឃនវកៈ នៃព្រះថេរៈ ៥ រូបនោះ ។ សួរថា ព្រោះហេតុអ្វី ព្រះថេរៈទើបសួរសេចក្ដីនោះមុន ? ឆ្លើយថា ព្រោះរាប់អានគ្នា ។

ក៏ព្រះថេរៈ ២ រូបនោះ រាប់អានគ្នានិងគ្នា ។ ព្រះសារីបុត្តត្ថេរគិតថា ព្រះអានន្ទត្ថេរឧបដ្ឋាកព្រះសាស្ដា ដែលយើងគួរធ្វើ ដូច្នេះ បានរាប់អានព្រះអានន្ទត្ថេរ ។ ព្រះអានន្ទត្ថេរគិតថា ព្រះសារីបុត្តត្ថេរ ជាកំពូលសាវករបស់ព្រះមានព្រះភាគ ដូច្នេះ បានរាប់អានព្រះសារីបុត្តត្ថេរ លោកឲ្យទារកក្នុងត្រកូលបព្វជ្ជាហើយ ឲ្យកាន់ឧបជ្ឈាយ៍ក្នុងសម្នាក់របស់ព្រះសារីបុត្តត្ថេរ ។ សូម្បីព្រះសារីបុត្តត្ថេរ ក៏បានធ្វើយ៉ាងនោះដូចគ្នា ។ កិក្ខុមួយអង្គឲ្យបាត្រ និងចីវររបស់ខ្លួនឲ្យបព្វជ្ជាហើយ ឲ្យមួយអង្គទៀតជាឧបជ្ឈាយ៍ប្រមាណ ៥០០ អង្គ

ព្រះអានន្ទបានចីវរជាដើម ដែលប្រណីតហើយថ្វាយព្រះថេរៈ ប៉ុណ្ណោះ ។ បាន ឮថា ព្រាហ្មណ៍ម្នាក់គិតថា ការបូជាពុទ្ធរតនៈ និងសង្ឃរតនៈ នៅប្រាកដ ឈ្មោះ ថា ការបូជាធម្មរតនៈ យ៉ាងណាហ្ន៎ ។ ទើបគេចូលទៅគាល់ព្រះមានព្រះភាគ ទូលសួរសេចក្ដីនោះ ។ ព្រះមានព្រះភាគត្រាស់ថា ព្រាហ្មណ៍ បើអ្នកប្រាថ្នា នឹងបូជាធម្មរតនៈ ចូរបូជាភិក្ខុដែលពហុស្សុតមួយរូបចុះ ។ ព្រាហ្មណ៍ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រាប់ភិក្ខុដែលពហុស្សុតចុះ ។ ព្រះមាន-ព្រះភាគត្រាស់ថា អ្នកចូរសួរភិក្ខុសង្ឃចុះ ។ គេចូលទៅរកភិក្ខុសង្ឃ ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ប្រាប់ភិក្ខុដែលជាពហុស្សុត ។ ភិក្ខុពោលថា ព្រះអានន្ទត្ថេរ ព្រាហ្មណ៍ ។ ព្រាហ្មណ៍បូជាព្រះថេរៈ ដោយ ត្រៃចីវរមានតម្លៃមួយពាន់ ។ ព្រះថេរៈទទួលត្រៃចីវរហើយ បានទៅកាន់ សម្នាក់របស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ត្រាស់សួរថា បានសំពត់ មកពីណាអានន្ទ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ ម្នាក់ថ្វាយ តែខ្ញុំព្រះអង្គប្រាថ្នានឹងប្រគេនចីវរនេះ ដល់លោកម្ចាស់សារីបុត្រ ។ ព្រះមានព្រះភាគត្រាស់ថា ប្រគេនចុះ អានន្ទ ។

អា. បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្រចៀសទៅកាន់ទីចារិកហើយ ។

ព. ចូរប្រគេន វេលាលោកមកចុះ ។

អា. ព្រះអង្គទ្រង់បញ្ញត្តិសិក្ខាបទទុកហើយ ។

ព. ក៏ព្រះសារីបុត្រនឹងមកកាលណា ។

អា. ប្រមាណ ១០ ថ្ងៃព្រះអង្គ ។ ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តិសិក្ខាបទ ដោយព្រះតម្រាស់ថា ម្នាលអានន្ទ តថាគតអនុញ្ញាតឲ្យភិក្ខុរក្សាអតិរេកចីវរទុកបាន ១០ ថ្ងៃ ជាយ៉ាងក្រៃលែង ។ សូម្បីព្រះសារីបុត្តត្រូវបានវត្ថុណាដែលពេញចិត្ត ថ្វាយវត្ថុនោះដល់ព្រះអានន្ទត្រូវយ៉ាងនោះដូចគ្នា ។ ព្រះថេរៈទាំងនោះរាប់អានគ្នានិងគ្នាយ៉ាងនេះ ។ ព្រះថេរៈទើបសួរមុន ព្រោះសេចក្តីរាប់អានគ្នា ដោយប្រការដូច្នេះ ។

មួយទៀត ឈ្មោះថា សួរសេចក្តីឃើញនោះ គប្បីសួរតាំងពីវត្ថុតិចទៅ ព្រោះដូច្នោះ ព្រះថេរៈគិតថា នឹងសួរព្រះអានន្ទមុន ព្រះអានន្ទនឹងឆ្លើយប្រាប់តាមបដិភាណរបស់ខ្លួន តមក ទើបនឹងសួរព្រះរេវតៈ អនុរុទ្ធ មហាកស្សបៈ មហាមោគ្គល្លាន ព្រះមហាមោគ្គល្លាននឹងឆ្លើយប្រាប់តាមបដិភាណរបស់ខ្លួន បន្ទាប់ពីព្រះថេរៈទាំង ៥ រូប ទើបនឹងសួរយើង សូម្បីយើងនឹងឆ្លើយប្រាប់តាមបដិភាណរបស់ខ្លួន ព្រះធម៌ទេសនានេះនឹងដល់ទីបំផុត ដល់សេចក្តីបរិបូណ៌ ដោយពាក្យមានប្រមាណប៉ុណ្ណេះក៏មិនមែន កាលបើដូច្នោះ ពួកយើងទាំងអស់ នឹងចូលទៅក្រាបទូលសួរព្រះទសពល ព្រះសាស្តានឹងទ្រង់

ឆ្លើយប្រាប់ដោយព្រះសព្វញ្ញុតញ្ញាណ ព្រះធម៌ទេសនានឹងដល់ទីបំផុត ដល់សេចក្តីបរិបូណ៌ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ក៏មិនមែន ដូចកាលរឿងក្តីកើតក្នុងជនបទ រឿងក្តីរមែងដល់មេស្រុក កាលមេស្រុកមិនអាចនឹងកាត់រឿងក្តីបាន រមែងដល់ចៅហ្វាយខេត្ត កាលគេមិនអាច រមែងដល់អ្នកពិភាក្សា កាលគេមិនអាច រមែងដល់សេនាបតី កាលសេនាបតីនោះមិនអាច រមែងដល់ឧបរាជ កាលឧបរាជនោះមិនអាចនឹងកាត់ក្តីបាន រមែងដល់ព្រះរាជា តាំងពីវេលាព្រះរាជាមានព្រះរាជវិនិច្ឆ័យហើយ រឿងក្តីរមែងដាច់ដោយព្រះរាជឱង្ការ សេចក្តីរមែងមិនផ្លាស់ប្តូរ យ៉ាងណា យើងក៏ដូច្នោះនឹងសួរព្រះអានន្ទមុន... កាលបើដូច្នោះ ពួកយើងទាំងអស់ នឹងចូលទៅទូលសួរព្រះទសពល ព្រះសាស្តានឹងទ្រង់ឆ្លើយប្រាប់ដោយព្រះសព្វញ្ញុតញ្ញាណ ធម៌ទេសនានេះនឹងដល់ទីបំផុត ដល់សេចក្តីបរិបូណ៌ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ដូច្នេះ ព្រះថេរៈកាលយល់ឃើញយ៉ាងនេះ ទើបបានសួរព្រះអានន្ទត្ថេរមុន ។

បទថា **ពហុស្សុតោ ហោតិ** សេចក្តីថា ភិក្ខុនោះស្តាប់ច្រើន អធិប្បាយថា រៀននវង្គសត្ថុសាសន៍ ដោយអំណាចអក្ខរៈខាងដើម និងខាងចុងនៃបាលី និងអនុសន្ធិ ។

បទថា **សុតធរោ** គឺ ជាអ្នកទទួលសុតៈទុកបាន ។ ពិតហើយ ព្រះពុទ្ធ-

វចនៈ ដែលភិក្ខុបានរៀនតែបាលីត្រង់នេះ វិនាសបាត់ទៅតែបាលីត្រង់នេះ មិនតាំងនៅ ដូចទឹកក្នុងថ្នាំងធ្លុះ លោកមិនអាចនឹងពោល ឬប្រាប់សូត្រ ឬជាតកប្រការតែមួយ ក្នុងកណ្តាលបរិស័ទបាន ភិក្ខុនេះ មិនឈ្មោះថា អ្នកទ្រទ្រង់សុតៈទេ ។ ចំណែកព្រះពុទ្ធវចនៈដែលភិក្ខុណារៀនហើយ រមែងដូចជាវេលាដែលខ្លួនរៀនមកហើយនុ៎ះឯង កាលលោកមិនធ្វើការស្វាធ្យាយទាំង ១០ ឆ្នាំ ទាំង ២០ ឆ្នាំ ក៏មិនវិនាសបាត់ ភិក្ខុនេះឈ្មោះថា អ្នកទ្រទ្រង់សុតៈ ។

បទថា **សុតសន្និចយោ** បានដល់ អ្នកសន្សំសុតៈ ក៏សុតៈដែលភិក្ខុណាសន្សំទុកក្នុងហឫទ គឺ ហទយៈតាំងនៅ ដូចស្នាមចារឹកលើសិលា និងដូចខ្លាញ់រាជសីហ៍ ដែលគេដាក់ទុកក្នុងថ្នាំងមាស ភិក្ខុនេះ ឈ្មោះថា អ្នកមានសុតៈជាទីសន្សំ ។ បទថា **ធតា** បានដល់ តាំងនៅ ទ្រទ្រង់ចាំទុកជំនាញមិនឃ្លៀងឃ្លាត ភិក្ខុនោះ កាលអ្នកណាៗ និយាយថា លោកចូរពោលសូត្រ ឬជាតកឯណោះ ដូច្នេះ រមែងពោលថា យើងទន្ទេញ ប្រៀបធៀប សាកសួរហើយ នឹងដឹង តែសម្រាប់រូបខ្លះ ទ្រទ្រង់ចាំទុក ជំនាញដូចជាកវត្តសោត ។ កាលអ្នកណាៗ ពោលថា សូមលោកចូរពោលសូត្រ ឬជាតកឯណោះ លោករមែងលើកឡើងពោលសូត្រ ឬជាតកនោះបានភ្លាម ។ បទថា **ធតា** លោកសំដៅយកភិក្ខុនោះ ទើបពោលហើយ ។ បទថា **វចសា បរិចិត្តា** បានដល់

លោកទន្ទេញហើយដោយវាចា ដោយអំណាចនៃសុត្តទសកៈ វគ្គទសកៈ បណ្ណាសទសកៈ ។ បទថា **មនសានុបេក្ខិតា** បានដល់ សម្លឹងដោយចិត្ត ។ កាលភិក្ខុណា គិតដោយចិត្ត នូវព្រះពុទ្ធវចនៈ ដែលខ្លួនទន្ទេញហើយដោយវាចា ព្រះពុទ្ធវចនៈ រមែងប្រាកដក្នុងទីនោះៗ គឺ ប្រាកដ ដូចរូបប្រាកដដល់បុគ្គល ដែលឈរកាន់ភ្លើងយ៉ាងធំ ដូច្នោះ ។ បទថា **មនសានុបេក្ខិតា** នោះ លោកសំដៅយកភិក្ខុនោះ ទើបពោល ។ បទថា **ទិដ្ឋិយាសុប្បដិវិទ្ធា** បានដល់ ចាក់ធ្លុះដោយល្អ ដោយបញ្ញា ដោយហេតុ និងផល ។ ក្នុងបទថា **បរិមណ្ឌលេ ហិ បទព្យញ្ជនេហិ** នេះ ឈ្មោះបទព្យញ្ជនៈ ព្រោះធ្វើសេចក្តីឲ្យប្រាកដ ធ្វើបទនោះឲ្យបរិបូរ ដោយអក្ខរៈ ពោលព្យញ្ជនៈ ១០ យ៉ាង មិនឲ្យខូច ឈ្មោះថាបទព្យញ្ជនៈរៀបរយ ម្យ៉ាងទៀត ភិក្ខុណា កាលនឹងសម្តែងធម៌ក្នុងបរិស័ទ អាងសូត្រ ឬជាតកហើយ យកព្រះសូត្រ ឬជាតកដទៃមកអធិប្បាយ ពោលឧបមារបស់សូត្រនោះ ឲ្យរឿងនោះកន្លងទៅ ចាប់រឿងនេះ ដាក់រឿងនោះ ត្រឡប់ទៅអធិប្បាយរឿងមួយផ្សេង បានវេលាក៏ក្រោកឡើង ចំណែកសូត្រដែលលោកអាងទុកក៏ត្រឹមតែពោលអាងទុកប៉ុណ្ណោះ ។ ពាក្យរបស់ភិក្ខុនោះ ឈ្មោះថាមិនរៀបរយ ។ ចំណែកភិក្ខុណាអាងសូត្រ ឬជាតក មិនយកបទខាងក្នុងសូម្បីមួយបទ មកលុបអនុសន្ធិ និងខាងដើម ខាងចុងនៃបាលី តាំងនៅក្នុងន័យ

ដែលអាចារ្យឲ្យទុក ប្រព្រឹត្តទៅ ដូចកំណត់ដោយការប្រឹង ដូចបញ្ចូលទឹកទៅក្នុងអណ្តូងជ្រៅ ដូចសិន្ធពអាជានេយ្យត្រូវគ្រាំជើង ពាក្យរបស់ភិក្ខុនោះ ឈ្មោះថា រៀបរយ លោកសំដៅយកពាក្យបែបនេះ ទើបពោលថា **បរិមណ្ឌលេហិ បទ-ព្យញ្ជនេហិ** ដូច្នេះ ។

ក្នុងបទថា **អនុប្បពន្ធេហិ** សេចក្តីថា ភិក្ខុណា ពោលធម៌ តាំងពីវេលាផ្តើមសូត្រ ឬជាតក ប្រារព្ធប្រញាប់ប្រញាល់ដូចអ្នករលាកភ្លើង ដូចអ្នកទំពាររបស់ក្តៅ ធ្វើទីកាន់យកហើយ និងមិនកាន់យកហើយ ក្នុងអនុសន្ធិខាងដើមខាងចុងនៃបាលី កុហកក្នុងទីនោះៗ ចប់ក្រោកទៅ ដូចអ្នកចិញ្ចឹមសត្វទន្សោងត្រាច់ទៅក្នុងចន្លោះស្លឹកឈើចាស់ ភិក្ខុណា កាលពោលធម៌ ពេលខ្លះក៏រហ័ស ពេលខ្លះក៏យឺត ពេលខ្លះធ្វើសំឡេងខ្លាំង ពេលខ្លះធ្វើសំឡេងតិចៗ ដូចភ្លើងឆេះសាកសព ពេលខ្លះឆេះ ពេលខ្លះក៏រលត់ យ៉ាងណា ភិក្ខុនោះឈ្មោះថា ព្រះធម្មកថិក ប្រៀបផ្ទឹមដូចភ្លើងឆេះសាកសព ដូច្នោះដែរ កាលបរិស័ទប្រាថ្នានឹងក្រោក ក៏ផ្តើមឡើងទៀត ។ សូម្បីភិក្ខុណា កាលពោលឲ្យពិស្តារក្នុងទីនោះបាន តែលោកពោលដូចការដកដង្ហើម ដូចទួញយំ ពាក្យរបស់ភិក្ខុទាំងនេះសូម្បីទាំងអស់ ឈ្មោះថា មិនជាប់តគ្នា ។ ចំណែកអ្នកណាផ្តើមសូត្រតាំងនៅក្នុងន័យដែលអាចារ្យឲ្យទុក ធ្វើមិនឲ្យដាច់ខ្សែប្រព្រឹត្តទៅ ដូចក្រសែទឹក

ញ៉ាំងពាក្យឲ្យជាប់មិនដាច់ ដូចទឹកធ្លាក់ ពាក្យរបស់គេឈ្មោះថា ជាប់តគ្នាដោយលំដាប់ លោកសំដៅយកពាក្យនោះ ទើបពោលថា **អនុប្បពន្ធហិ** ដូច្នេះ ។ បទថា **អនុសយសមុគ្ឃាតាយ** បានដល់ ដើម្បីដកអនុស័យ ៧ យ៉ាង ។ បទថា **ឯវរូបេន** សេចក្ដីថា ព្រៃគោសិង្គសាលវ័ន គប្បីល្អដោយភិក្ខុពហុស្សូតបែបនេះ ឬប្រាកដដូចជាភិក្ខុរូបបែបនោះឯង ជាយសន្ធ្យាជិនិងជាយសន្ធ្យាជិទល់គ្នា ឬជន្គង់នឹងជន្គង់ទល់គ្នា គប្បីជ្រាបសេចក្ដីក្នុងវារៈទាំងពួងដោយន័យនេះ ។

[១១] ភិក្ខុឈ្មោះ **បដិសល្លានារាមា** ព្រោះអត្ថថា ការពួនសម្ងំជាទីមកត្រេកអររបស់ភិក្ខុនោះ ។ បទថា **បដិសល្លានរតោ** គឺ ត្រេកអរហើយក្នុងការពួនសម្ងំ ។

[១២] បទថា **សហស្សំ លោកានំ** គឺ លោកធាតុមួយពាន់ ។ ពិតហើយ ការសេពគុរៈជាប់ដោយការពិចារណារបស់ព្រះថេរៈ មានប្រមាណប៉ុណ្ណោះ ។ ចំណែកព្រះថេរៈកាលប្រាថ្នា រមែងត្រួតមើលបានច្រើនសែនចក្រវាឡ ។ បទថា **ឧបរិបាសាទវរគតោ** បានដល់ បុរសអ្នកទៅខាងលើប្រាសាទដែលល្អ ៧ ជាន់ ។ ឬ ៩ ជាន់ ។ បទថា **សហស្សំ នេមិមណ្ឌលានំ វោលោកេយ្យ** សេចក្ដីថា គប្បីបើកបង្អួចក្រឡេកមើលមណ្ឌលនៃកង់ទាំងពាន់

តាំងនៅត្រង់ជុំ ខ្នងកង់នឹងខ្នងកង់តាំងទល់គ្នា ក្នុងបរិវេណប្រាសាទបាន ជុំក្តី កាំក្តី ចន្ទោះកាំក្តី ខ្នងក្តី ទើបប្រាកដដល់បុរសនោះ ។ បទថា **ឯវមេវ ខោ អាវុសោ** សេចក្តីថា ភិក្ខុដែលមានទិព្វចក្ខុសូម្បីនេះ រមែងត្រួតមើលលោកមួយពាន់ដោយទិព្វចក្ខុ កន្ទង់ចក្ខុរបស់មនុស្ស ភ្នំសិនេរុមួយពាន់ ក្នុងចក្រ-វាឡមួយពាន់ រមែងប្រាកដដូចជុំកង់ ដែលប្រាកដដល់បុរសអ្នកឈរលើប្រាសាទនោះ ទ្វីប ប្រាកដដូចកាំ មនុស្សដែលឈរនៅលើទ្វីប ប្រាកដដូចចន្ទោះកាំ ភ្នំចក្រវាឡ រមែងប្រាកដដូចខ្នងកង់ ។

[១៣] បទថា **អរញ្ញកោ** គឺ អ្នកសមាទានអរញ្ញធុតង្គ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

[១៤] បទថា **នោ ច សំសាទេន្តិ** គឺ មិនជំទាស់គ្នា ។ ពិតហើយ បុគ្គលដែលអាចនឹងសួរបញ្ហា ធ្វើឲ្យមានហេតុមានផល ឈ្មោះថា រមែងទាស់គ្នា ។ អធិប្បាយថា ពួកភិក្ខុ រមែងមិនពោលយ៉ាងនេះ ។ បទថា **បវត្តិនី ហោតិ** បានដល់ រមែងប្រព្រឹត្តទៅ ដូចក្រសែទឹកក្នុងទន្លេ ។

[១៥] បទថា **យាយ វិហារសមាបត្តិយា** សេចក្តីថា ដោយវិហារ-សមាបត្តិជាលោកិយៈ ឬលោកុត្តរៈណា ។

[១៦] បទថា **សាធុ សាធុ សារីបុត្ត** សេចក្តីថា សាធុការនេះ ព្រះ-

មានព្រះភាគប្រទានដល់ព្រះអានន្ទត្ថេរ ព្រះមានព្រះភាគ ត្រាស់នឹងព្រះសារី-បុត្តត្ថេរ ។ ក្នុងទីទាំងពួងក៏មានន័យនេះ ។ បទថា **យថាតំ អានន្ទោ** សេចក្ដីថា ក៏អានន្ទ កាលនឹងព្យាករណ៍ដោយប្រពៃ គប្បីព្យាករណ៍យ៉ាងណា ព្យាករណ៍ហើយដូច្នោះ ។ អធិប្បាយថា ព្រះអានន្ទ ព្យាករណ៍តាមសមគួរ គឺ សមរម្យដល់អជ្ឈាស្រ័យរបស់ខ្លួនទុំះឯង ។

ពិតហើយ ព្រះអានន្ទត្ថេរ ជាពហុស្សូតដោយខ្លួនឯង សូម្បីអជ្ឈាស្រ័យរបស់លោក តាំងនៅយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីក្នុងសាសនា គប្បីជាពហុស្សូត ដូច្នេះ ។ ព្រោះហេតុអ្វី ព្រោះថា វត្ថុដែលគួរ ឬមិនគួរ វត្ថុដែលមានទោស ឬមិនមានទោស ទោសធ្ងន់ ឬស្រាល កែខៃបាន កែខៃមិនបាន រមែងប្រាកដដល់ភិក្ខុពហុស្សូត ភិក្ខុដែលជាពហុស្សូតពិចារណាព្រះពុទ្ធវចនៈដែលខ្លួនរៀនហើយ គិតថា សីល លោកពោលទុកហើយក្នុងទីនេះ សមាធិលោកពោលទុកហើយក្នុងទីនេះ វិបស្សនា លោកពោលទុកហើយក្នុងទីនេះ មគ្គផលនិព្វាន លោកពោលទុកហើយក្នុងទីនេះ បំពេញសីលក្នុងទីមករបស់សីល បំពេញសមាធិក្នុងដែលមករបស់សមាធិ ញុំាងវិបស្សនាឲ្យកាន់យកក្នុងទីមកនៃវិបស្សនា ចម្រើនមគ្គ រមែងធ្វើឲ្យច្បាស់នូវផល ព្រោះដូច្នោះ អជ្ឈា-ស្រ័យរបស់ព្រះថេរៈ រមែងដូច្នេះថា ឱហ្ន៎ សព្រហ្មចារីរបស់យើង រៀននិកាយ

មួយ ឬពីរ បី ឬបួន ឬប្រាំនិកាយហើយ ពិចារណា បំពេញសីលជាដើម ក្នុងការមកនៃសីលជាដើម គប្បីធ្វើឲ្យច្បាស់នូវមគ្គផល និងនិព្វានដោយលំដាប់ ។ សូម្បីក្នុងវារៈដ៏សេស ក៏មានន័យនេះឯង ។

[១៧] ពិតហើយ ព្រះរេវតៈ ពេញចិត្តក្នុងឈាន ត្រេកអរហើយក្នុងឈាន ព្រោះដូច្នោះ លោកមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីរបស់យើងអង្គុយតែម្នាក់ឯង ធ្វើកសិណបរិកម្ម ញុំាងសមាបត្តិ ៨ ឲ្យកើត ចម្រើនវិបស្សនា មានឈានជាបទដ្ឋាន គប្បីធ្វើឲ្យច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករណ៍យ៉ាងនេះ ។

[១៨] ព្រះអនុរុទ្ធ មានទិព្វចក្ខុ លោកមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារី ចម្រើនអាលោកកសិណឃើញសត្វទាំងឡាយកំពុងចុតិ និងឧប្បត្តិក្នុងចក្រវាឡច្រើនពាន់ ដោយទិព្វចក្ខុ ញុំាងចិត្តឲ្យសង្វេគ ព្រោះវដ្តភ័យ ចម្រើនវិបស្សនា គប្បីធ្វើឲ្យច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករណ៍ហើយយ៉ាងនេះ ។

[១៩] ព្រះមហាកស្សបៈ ជាធុតវាទ លោកមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីជាធុតវាទ ញុំាងតណ្ហាព្រមទាំងបច្ច័យឲ្យស្ងួតទៅ ដោយអានុភាពនៃធុតង្គ ហើយកម្ចាត់កិលេស ដោយប្រការផ្សេង ៗ សូម្បីពួកដទៃ

ចម្រើនវិបស្សនា គប្បីធ្វើឲ្យច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករណ៍ហើយយ៉ាងនេះ ។

[២០] ព្រះមហាមោគ្គល្លាន ដល់ទីបំផុតនៃសមាធិបារមី ចែកលំដាប់ចិត្តដ៏សុខុម លំដាប់ខន្ធ លំដាប់ធាតុ លំដាប់អាយតនៈ ការចូលឈាន ការឈានចុះកាន់អារម្មណ៍ ការកំណត់អង្គ ការកំណត់អារម្មណ៍ ការកាត់អង្គ ការកាត់អារម្មណ៍ ចម្រើនដោយចំណែកមួយ ចម្រើនដោយចំណែក ២ ដូច្នោះ ទើបប្រាកដដល់អ្នករៀនអភិធម្មប៉ុណ្ណោះ ។ ក៏អ្នកមិនបានរៀនអភិធម្ម កាលនឹងពោលធម៌ រមែងមិនដឹងថា នេះជាសកវាទៈ នេះជាបរវាទៈ ការសម្តែងបរវាទៈថា យើងនឹងសម្តែងសកវាទៈ ការសម្តែងសកវាទៈថា យើងនឹងសម្តែងបរវាទៈ រមែងពោលលំដាប់ធម៌ឲ្យខុស ចំណែកអ្នករៀនអភិធម្ម រមែងសម្តែងសកវាទៈដោយសកវាទៈពិតប្រាកដ ឬបរវាទៈដោយបរវាទៈពិតប្រាកដ រមែងមិនពោលលំដាប់ធម៌ឲ្យខុស ព្រោះដូច្នោះ ព្រះថេរៈមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីជាអ្នករៀនអភិធម្ម ញ៉ាំងឈានឲ្យធ្លាក់ចុះក្នុងទីដ៏សុខុម ចម្រើនវិបស្សនា គប្បីធ្វើឲ្យច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករណ៍ហើយយ៉ាងនេះ ។

[២១] ព្រះសារីបុត្រ ដល់ទីបំផុតនៃបញ្ញាបារមី រមែងអាចញ៉ាំងចិត្ត

ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបានដោយបញ្ញា អ្នកមានបញ្ញាខ្សោយមិនអាចទេ ។

ពិតហើយ អ្នកមានបញ្ញាទន់ខ្សោយ ប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តដែលកើតឡើង ក្តៅក្រហាយទៅខាងនេះ និងខាងឯណោះ ២-៣ ថ្ងៃ ដល់ភាពជាគ្រហស្ថ ប្រសព្វសេចក្តីវិនាសមិនមែនប្រយោជន៍ ព្រោះដូច្នោះ ព្រះថេរៈមានការគិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារី មិនប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន បង្ក្រាបសេចក្តីសេពជាប់សត្រូវ និងសេចក្តីក្តៅក្រហាយទាំងអស់របស់ចិត្តនោះ មិនឲ្យចេញទៅខាងក្រៅ សូម្បីបន្តិចបន្តួច ៗ ចម្រើនវិបស្សនា គប្បីធ្វើឲ្យច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះទើបព្យាករណ៍ហើយយ៉ាងនេះ ។

[២២] បទថា **សព្វេសំ វោ សារីបុត្ត សុភាសិតំ បរិយាយេន** សេចក្តីថា ម្នាលសារីបុត្រ ហេតុនៃសេចក្តីស្អាតដោយពួកភិក្ខុ ដែលត្រេកអរក្នុងឈានខ្លះ អ្នកបានទិព្វចក្ខុខ្លះ អ្នកធុតង្គវាទៈខ្លះ អ្នករៀនអភិធម្មខ្លះ អ្នកមិនប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តខ្លះ សម្រាប់សង្ឃារាមមាន ។ ព្រោះដូច្នោះ ពាក្យរបស់ពួកភិក្ខុទាំងអស់ ជាសុភាសិតដោយបរិយាយ គឺ ជាសុភាសិតដោយហេតុនោះឯង មិនជាទុព្ភាសិតទេ ។ បទថា **អបិច មមាបិ សុណាថ** សេចក្តីថា

ម្យ៉ាងទៀត ពួកអ្នកចូរស្តាប់ពាក្យរបស់តថាគត ។

បទថា **ន តាវាហំ ឥមំ បល្លង្កំ ភិន្ទិស្សាមិ** សេចក្តីថា តថាគតតាំងសេចក្តីព្យាយាមមានអង្គ៤ នេះ ហើយនឹងមិនទម្លាយ គឺ នឹងមិនក្រោកចាកការអង្គុយបម្រើនសមាធិត្រឹមនោះ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់លះសិរីរាជសម្បត្តិនេះបាន ដោយព្រះញាណដែលចាស់ក្លា ទ្រង់ចេញអភិនេស្រ្កមន៍ស្តេចឡើងកាន់ពោធិមណ្ឌល ដោយលំដាប់ ទ្រង់តាំងសេចក្តីព្យាយាមប្រកបដោយអង្គ ៤ ប្រថាប់អង្គុយចម្រើនសមាធិ ជាការជោគជ័យ មានព្រះទ័យតាំងមាំ ទ្រង់ទម្លាយមារ និងកងទ័ពរបស់មារទាំង ៣ ហើយទ្រង់ញ៉ាំងម៉ឺនលោកធាតុឲ្យបន្លឺហើយ ទ្រង់ចាក់ធ្លុះព្រះសព្វញ្ញុតញ្ញាណ ក្នុងវេលាជិតភ្លឺ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកមហាពោធិបល្ល័ង្កនោះរបស់ព្រះអង្គ ទើបត្រាស់យ៉ាងនេះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ សូម្បីកាលទ្រង់អនុគ្រោះជនអ្នកកើតក្នុងខាងក្រោយ ទ្រង់សម្តែងវត្តបដិបត្តិ ដែលជាសារៈដល់កល្យាណបុថុជ្ជន ទើបត្រាស់យ៉ាងនេះ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញថា ក្នុងអនាគត កុលបុត្រអ្នកមានអធ្យាស្រ័យយ៉ាងនេះ នឹងសញ្ជឹងគិតឃើញ ដោយប្រការដូច្នេះ ព្រះមានព្រះភាគ កាលត្រាស់មហាគោសិង្គសូត្រ ទើបត្រាស់ថា ម្នាលសារីបុត្រ ភិក្ខុក្នុងសាសនានេះ ក្នុងខាងក្រោយកត្ត ... ម្នាលសារីបុត្រ

ព្រៃគោសិង្គសាលវ័នគប្បីរុងរឿង ដោយភិក្ខុបែបនេះឯង ។ ភិក្ខុទាំងឡាយ គិតថា ពួកយើងនឹងកាន់យកអជ្ឈាស័យរបស់ព្រះមានព្រះភាគ ដូច្នេះ ត្រឡប់ពីបិណ្ឌបាត ក្នុងខាងក្រោយភត្ត តាំងសេចក្ដីព្យាយាមមានអង្គ ៤ មានចិត្តតម្កល់មាំ នឹងកំណត់សមណធម៌ដែលខ្ជួនគួរធ្វើថា ពួកយើងនៅមិនទាន់សម្រេចអរហត្ត នឹងមិនទម្លាយការអង្គុយចម្រើនសមាធិនេះ ដូច្នេះ ភិក្ខុពួកនោះ បដិបត្តិហើយយ៉ាងនេះ នឹងធ្វើទីបំផុតនៃជាតិ ជរា និងមរណៈបាន ដោយថ្ងៃបន្តិចបន្តួចប៉ុណ្ណោះ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះជនជំនាន់ក្រោយនេះ ទ្រង់សម្តែងវត្តបដិបត្តិ ដែលជាសារៈដល់កល្យាណបុថុជ្ជន ទើបត្រាស់យ៉ាងនេះ ។ បទថា **ឯវរូបេន ខោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យ** សេចក្តីថា ម្នាលសារីបុត្រ ព្រៃគោសិង្គសាលវ័ន គប្បីរុងរឿងដោយភិក្ខុបែបនេះ យ៉ាងនេះឯង ចប់ព្រះធម៌ទេសនា ដោយអនុសន្ធិដូច្នេះឯង ។

( ចប់ អដ្ឋកថា មហាគោសិង្គសាលសូត្រទី ២ )

# អ ដ្ឋ ក ថា

## មហាគោបាលសូត្រទី ៣

[២៣] មហាគោបាលសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ។ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ក្នុងមហាគោបាលសូត្រនោះ មាន ៣ កថា គឺ **ឯកនាលិកា ចតុរស្សា និសិន្នវត្តិកា** ។ ការពោលបាលីក្នុងកថា ទាំង ៣ នោះ និងពោលសេចក្ដីតែមួយបទ ឈ្មោះថា **ឯកនាលិកា** ។ ការសម្ដែងនាយគោបាលអ្នកមិនឆ្លាត សម្ដែងភិក្ខុអ្នកមិនឆ្លាត សម្ដែងនាយគោបាលអ្នកឆ្លាត សម្ដែងភិក្ខុអ្នកឆ្លាត ពោលប្រមូលទុកជា ៤ ពួក ឈ្មោះថា **ចតុរស្សា** ។ ការសម្ដែងនាយគោបាលអ្នកមិនឆ្លាតឲ្យដល់ទីបំផុត ការសម្ដែងភិក្ខុអ្នកមិនឆ្លាត ឲ្យដល់ទីបំផុត ការសម្ដែងនាយគោបាលអ្នកឆ្លាត ឲ្យដល់ទីបំផុត ការសម្ដែងភិក្ខុអ្នកឆ្លាត ឲ្យដល់ទីបំផុត នេះឈ្មោះថា **និសិន្នវត្តិកា** ។ កថានេះ អាចារ្យទាំងពួងក្នុងធម្មវិន័យបានប្រព្រឹត្តមកហើយ ។

[២៤] បទថា **ឯកាទសហិ ភិក្ខវេ អង្គេហិ** គឺ ដោយចំណែកនៃទោស ១១ យ៉ាង បទថា **គោគណំ** ប្រែថា ហ្វូងគោ ។ បទថា **បរិហរិតុំ** បានដល់ នាំទៅ ។ បទថា **ផាតិកាតុំ** បានដល់ ឲ្យដល់សេចក្ដីចម្រើន ។ បទថា **ឥធ** គឺ ក្នុងលោកនេះ ។ បទថា **ន រូបញ្ញូ ហោតិ** បានដល់ រមែងមិនស្គាល់រូបដោយ

ដោយការរាប់ ឬដោយពណ៌ ។ ឈ្មោះថា រមែងមិនស្គាល់ដោយការរាប់ គឺ រមែងមិនដឹងគោរបស់ខ្លួនថា មួយរយ ឬមួយពាន់ ។ នាយគោបាលនោះ កាល មេគោត្រូវសម្លាប់ ឬចៀសចេញទៅអំពីហ្វូងហើយ ជ្រាបថា "ថ្ងៃនេះ មេគោ ប្រមាណប៉ុណ្ណេះ បាត់ទៅ" ដូច្នេះ ត្រាច់ទៅរហូតអស់ ២-៣ ស្រុក ឬព្រៃ រមែងមិនស្វែងរក កាលមេគោរបស់អ្នកដទៃចូលទៅកាន់ហ្វូងគោរបស់ខ្លួន រាប់ ចំនួនហើយជ្រាបថា "គោទាំងនេះប្រមាណប៉ុណ្ណេះ មិនមែនរបស់យើង" ដូច្នេះ មិនយករំពាត់ឈើវាយចេញទៅ មេគោរបស់គេដែលបាត់ទៅហើយ ក៏ជាការបាត់ ទៅ ។ គេដេញកៀងមេគោរបស់អ្នកដទៃត្រាច់ទៅ ។ ពួកម្ចាស់របស់គោ ឃើញហើយគម្រាមថា "នាយគោបាលនេះ រឹតទឹកដោះមេគោរបស់ពួកយើង រហូតអស់កាលជានិច្ច ប្រមាណប៉ុណ្ណេះហើយ" នាំយកមេគោរបស់ខ្លួនទៅ ។ សូម្បីហ្វូងគោរបស់គេ រមែងវិនាសទៅ គេរមែងឃ្លាតឆ្ងាយចាកការបរិភោគ បញ្ចគោរស ។

នាយគោបាលដែលឈ្មោះថា មិនដឹងដោយពណ៌ គឺ មិនដឹងថា គោ ពណ៌សមានប្រមាណប៉ុណ្ណេះ ពណ៌ក្រហមប្រមាណប៉ុណ្ណេះ ពណ៌ខ្មៅប្រមាណ ប៉ុណ្ណេះ ពណ៌ដាំងប្រមាណប៉ុណ្ណេះ ពណ៌ខៀវប្រមាណប៉ុណ្ណេះ នាយគោបាល នោះ កាលមេគោត្រូវសម្លាប់ឬចៀសចេញទៅ ។ល។ គេរមែងឃ្លាតឆ្ងាយចាក

ពីការបរិភោគបញ្ចគោរស ។ បទថា **ន លក្ខណកុសលោ ហោតិ** សេចក្តីថា រមែងមិនដឹងគ្រឿងសម្គាល់ដែលផ្សេងគ្នា មានធ្នូ លំពែងជាដើម ដែលខ្លួនធ្វើជាគ្រឿងសម្គាល់ទុកត្រង់ខ្លួនរបស់មេគោ នាយគោបាលនោះ កាលមេគោត្រូវសម្លាប់ ឬចៀសចេញទៅ រាប់ចំនួនគោ ហើយដឹងថា ថ្ងៃនេះគោលក្ខណៈឯណោះបាត់ទៅ ។ល។ គេរមែងឃ្លាតឆ្ងាយ សូម្បីចាកការបរិភោគបញ្ចគោ-រស ។ បទថា **ន អាសាដិកំ សាដេតា** សេចក្តីថា ដំបៅរបស់គោមានដោយការប៉ះដង្គត់ និងបន្លាជាដើមមុត រុយក្បាលខៀវបន្តក់ពងទុកត្រង់ដំបៅនោះឈ្មោះថា មិនក្តិះពងរុយរបស់រុយក្បាលខៀវទាំងនោះ នាយគោបាលយកឈើក្តិះពងរុយទាំងនោះចេញ ហើយគប្បីដាក់ថ្នាំ នាយគោបាលល្ងង់ មិនធ្វើយ៉ាងនោះ ។ ព្រោះដូច្នោះ លោកទើបពោលថា មិនក្តិះពងរុយ ។ ដំបៅគោរបស់គេរាលដាល ជាដំបៅជ្រៅ ពួកសត្វតូចៗ ចោះ ចូលពោះបាន មេគោទាំងនោះត្រូវសេចក្តីឈឺចាប់គ្របសង្កត់ មិនអាចដើម្បីនឹងទំពារស៊ីស្មៅ និងផឹកទឹកបានតាមត្រូវការ ទឹកដោះរបស់មេគោទាំងឡាយក្នុងទីនោះក៏ដាច់ ពួកគោក៏ថយកម្លាំងសូម្បីអន្តរាយជីវិត រមែងមានដល់គោទាំង ២ ហ្វូង គោរបស់គេរមែងសាប-សូន្យខ្លះ គេរមែងឃ្លាតឆ្ងាយចាកបញ្ចគោរសខ្លះ ដោយប្រការយ៉ាងនេះ ។ បទថា **ន វណំ បដិច្ឆាទេតា ហោតិ** សេចក្តីថា ដំបៅដែលកើតហើយដល់គោ

ដោយន័យដែលពោលហើយ គប្បីយកផ្ទៃ ឬព្រាលរុំបិទ ។ នាយគោបាលល្ងង់ មិនធ្វើយ៉ាងនោះទេ ។ កាលបើដូច្នោះ ខ្ទុះរមែងហូរចេញពីដំបៅនៃគោរបស់គេ គោត្រដុសគ្នានិងគ្នា ព្រោះការត្រដុសនោះ ដំបៅកើតដល់គោពួកដទៃ គោត្រូវសេចក្ដីឈឺចាប់គ្រប់សង្កត់ហើយយ៉ាងនេះ មិនអាចនឹងទំពារស៊ីស្មៅតាមត្រូវការបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **ន ធូមំ កត្តា ហោតិ** សេចក្ដីថា ក្នុងវេលាខាងក្នុងរដូវភ្លៀងរបោម និងមូសជាដើមសម្បូណ៌ កាលហ្វូងគោចូលក្រោលហើយ គួរបំពក់ដោយផ្សែងឲ្យ ក្នុងក្រោលនោះ នាយគោបាលអ្នកមិនឆ្លាត រមែងមិនបំពក់ផ្សែងឲ្យហ្វូងគោ ត្រូវរបោមជាដើម បៀតបៀនរហូតអស់មួយយប់ទល់ភ្លឺ ក៏ដេកមិនលក់ ក្នុងថ្ងៃស្អែក ដេកលក់ក្បែរគល់ឈើជាដើម ក្នុងទីនោះៗ ក្នុងព្រៃ មិនអាចដើម្បីនឹងទំពារស៊ីស្មៅតាមសេចក្ដីត្រូវការបាន ។ល។ គេរមែងឃ្លាតឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា **ន តិត្ថំ ជានាតិ** សេចក្ដីថា មិនស្គាល់កំពង់ថា រាបស្មើ ឬមិនរាបស្មើ មានសត្វកាច ឬមិនមានសត្វកាច ដូច្នេះ ។ នាយគោបាលនោះ លែងមេគោឲ្យចុះទៅដោយមិនស្គាល់កំពង់ កាលមេគោទាំងនោះជាន់ថ្មាំងថ្មជាដើម ត្រង់កំពង់មិនរាបស្មើ ជើងរមែងបែក មេគោក៏ធ្លាក់ត្រង់កំពង់ជ្រៅ មានសត្វ

កាច មានក្រពើជាដើម ក៏ខាំយក គេនឹងត្រូវពោលថា "ថ្ងៃនេះគោបាត់ទៅហើយប្រមាណប៉ុណ្ណេះ ថ្ងៃនេះប្រមាណប៉ុណ្ណេះ" ហ្វូងគោរបស់គេ រមែងវិនាសខ្លះ គេរមែងឃ្លាតឆ្ងាយចាកបញ្ចគោរសខ្លះ ដោយប្រការយ៉ាងនេះ ។

បទថា **ន បិតំ ជានាតិ** សេចក្តីថា មិនដឹងគោដែលផឹក ក៏នាយគោបាលគប្បីដឹងគោដែលផឹក និងមិនផឹកយ៉ាងនេះថា គោនេះផឹក គោនេះមិនទាន់ផឹក គោនេះបានឱកាសត្រង់កំពង់ទឹកសម្រាប់ផឹក គោនេះមិនបានដូច្នេះ ។ តែនាយគោបាលនេះ រក្សាហ្វូងគោក្នុងព្រៃរហូតអស់មួយថ្ងៃ គិតថា យើងនឹងឲ្យផឹកទឹក ដូច្នេះ ក៏ដេញទៅទន្លេ ឬត្រពាំង គោធំ គោតូចយកស្នែង ឬធ្មឹងខ្នងទន្ទិចមេគោដែលមិនមានកម្លាំង និងគោដែលមានកម្លាំងតិច និងគោចាស់ ខ្លួនបានឱកាសចុះទឹកត្រឹម-ក ផឹកតាមសេចក្តីប្រាថ្នា គោដែលសល់កាលមិនបានឱកាស ឈរនៅលើច្រាំង ផឹកទឹកលាយភក់ខ្លះ មិនបានផឹកខ្លះ កាលបើដូច្នោះ នាយគោបាល វាយត្រង់ខ្នង ដេញឲ្យគោទាំងនោះត្រឡប់ចូលព្រៃទៀត ក្នុងគោទាំងនោះ មេគោដែលមិនបានផឹក ចុកពោយដោយសេចក្តីក្តៅក្រហាយមិនអាចនឹងទំពារស៊ីស្មៅតាមសេចក្តីត្រូវការបាន ទឹកដោះរបស់មេគោក្នុងទីនោះក៏ដាច់ទៅ ហ្វូងគោក៏ថយកម្លាំង ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **ន វីថឹ ជានាតិ** សេចក្តីថា មិនដឹងថា ផ្លូវនេះជាផ្លូវរាបស្មើ

រួចផុតអំពីភ័យ ផ្លូវនេះមិនរាបស្មើ គួរសង្ស័យ មានភ័យចំពោះមុខ ។ គេវៀរផ្លូវដែលរួចផុតភ័យ រាបស្មើ ដេញហ្វូងគោឲ្យដើរទៅផ្លូវមួយទៀត គោបានក្លិនរាជសីហ៍ និងខ្លាជាដើម ឬអន្តរាយពីចោរគ្របសង្កត់ ប្រៀបដូចម្រឹគភ្ញាក់ឈរអើត-ក នឹងទំពារស៊ីស្មៅ ផឹកទឹកមិនបានតាមសេចក្ដីប្រាថ្នា ទឹកដោះរបស់មេគោក្នុងទីនោះ ក៏ដាច់ទៅ ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **ន គោចរកុសលោ ហោតិ** សេចក្ដីថា ក៏នាយគោបាលគប្បីឆ្ងាតក្នុងស្ថានទីដែលគោត្រាច់រកស៊ី គប្បីដឹងពេល ៥ ថ្ងៃម្ដង ឬ ៧ ថ្ងៃម្ដងឲ្យហ្វូងគោត្រាច់រកស៊ីក្នុងទិសមួយហើយ ថ្ងៃស្អែក មិនគប្បីឲ្យត្រាច់ទៅទីនោះ ។ ក៏ស្ថានទីដែលហ្វូងគោធំធ្លាប់ត្រាច់ទៅ ស្មៅអស់ រាបស្មើដូចមុខស្គរ សូម្បីទឹកក៏កករល្អក់ ព្រោះដូច្នោះ ក្នុងថ្ងៃទី ៥ ឬទី ៧ ទើបគួរដេញឲ្យទៅរកស៊ីក្នុងទីនោះទៀត ព្រោះថា សូម្បីស្មៅ ក៏ត្រឡប់ដុះល្អ សូម្បីទឹកក៏ថ្លា ដោយហេតុប្រមាណប៉ុណ្ណោះ ចំណែកនាយគោបាលនេះ មិនស្គាល់កាល ៥ ថ្ងៃម្ដង ឬ ៧ ថ្ងៃម្ដង រមែងរក្សាស្ថានទីដែលខ្លួនរក្សាហើយនោះ និងរាល់ៗ ថ្ងៃ កាលបើដូច្នោះ ហ្វូងគោរបស់គេមិនបានទំពារស៊ីស្មៅដែលខៀវស្រស់ កាលទំពារស៊ីស្មៅស្ងួត ផឹកទឹកលាយភក់ ទឹកដោះរបស់មេគោក្នុងទីនោះក៏ដាច់ទៅ ។ល។ គេរមែងឃ្លាតឆ្ងាយ ។

*បទថា **អនវសេសទោហី ហោតិ** សេចក្ដីថា សាច់ និងឈាមរបស់កូនគោ នឹងតាំងនៅបានត្រឹមណា នាយគោបាលអ្នកឆ្លាត គប្បីរីតទឹកដោះឲ្យនៅសល់ ១-២ ក្រសោមដោះ ត្រឹមតែប៉ុណ្ណោះ នាយគោបាលនេះ រីតទឹកដោះមិនបាននៅសល់អ្វី សម្រាប់កូនគោឡើយ កូនគោដែលនៅបៅដោះ រមែងហេវហត់ ដោយការស្រេកទឹកដោះ កាលមិនអាចទប់ខ្លួននៅបាន ក៏ដួលចុះស្លាប់ចំពោះមុខមេ មេឃើញកូនតូចហើយគិតថា កូនតូចរបស់យើង មិនបានសូម្បីនឹងបៅដោះរបស់មេខ្លួន មិនអាចដើម្បីនឹងទំពារស៊ីស្មៅ ផឹកទឹកតាមសេចក្ដីត្រូវការបាន ព្រោះសេចក្ដីសោកដល់កូន ទឹកដោះក្នុងក្រសោមក៏ដាច់ទៅ ហ្វូងគោរបស់គេ រមែងវិនាសខ្លះ គេរមែងឃ្លាតឆ្ងាយចាកបញ្ចគោរសខ្លះ ដោយប្រការយ៉ាងនេះ ។ ឈ្មោះថា **គោបា** ព្រោះអត្ថថា ធ្វើមុខនាទីដែលជាបារបស់គោទាំងឡាយ ។ ឈ្មោះថា **មេគោ** ព្រោះអត្ថថា នាំហ្វូងគោ គឺ នាំទៅបានតាមសេចក្ដីពេញចិត្ត ។*

*បទថា **ន អតិរេកបូជាយ** សេចក្ដីថា ពិតហើយ នាយគោបាលដែលឆ្លាត បំប៉នគោធំបែបនេះ ដោយការបំប៉នជាពិសេស គឺ រមែងឲ្យអាហារដ៏ប្រណីត តាក់តែងដោយរបស់ក្រអូប និងការចិញ្ចឹម ៥ យ៉ាង ប្រដាប់ផ្កាឈើពាក់ស្រោមមាស និងប្រាក់ត្រង់ស្នែង អុជភ្លើងឲ្យភ្លឺរហូតមួយយប់ ឲ្យដេក*

ខាងក្រោមពិតានសំពត់ ចំណែកនាយគោបាលនេះ រមែងមិនធ្វើការអើពើតែ ម្យ៉ាងពីការឲ្យអាហារដែលប្រណីតជាដើមនោះ គោធំកាលមិនបានបំប៉នជាពិសេស ក៏មិនរក្សាហ្វូងគោ មិនការពារអន្តរាយ ហ្វូងគោរបស់គេរមែងវិនាសទៅ គេរមែង ឃ្លាតឆ្ងាយចាកបញ្ចគោរស ដោយប្រការយ៉ាងនេះ ។

[២៥] បទថា ឥធ គឺ ក្នុងសាសនានេះ ។ បទថា ន រូបញ្ញូ ហោតិ សេចក្ដីថា រមែងមិនដឹងនូវរូប ដែលពោលហើយយ៉ាងនេះថា មហាភូតរូប ៤ ដោយអាការ ២ គឺ ដោយការរាប់ ឬដោយសមុដ្ឋាន ។ ឈ្មោះថា មិនស្គាល់ ដោយការរាប់ គឺ មិនដឹងថា ចំណែកនៃរូប ២៥ មកហើយ ក្នុងបាលីយ៉ាងនេះ ថា អាយតនៈគឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត និងកាយ អាយតនៈ គឺ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ អាបោធាតុ សេចក្ដីស្រាលនៃរូប សេចក្ដីទន់នៃរូប សេចក្ដីគួរដល់ការងារ សេចក្ដីកកើតឡើង សេចក្ដីបន្ត សេចក្ដីចាស់គ្រាំ ដែល រូបជារបស់មិនទៀង អាហារ គឺ ពំនូតបាយ ។ ភិក្ខុនេះ ប្រៀបដូចនាយ គោបាលនោះ មិនស្គាល់រូបនៃគោទាំងឡាយដោយការរាប់ដូច្នោះ ភិក្ខុកាល មិនស្គាល់រូបដោយការរាប់ ក៏មិនអាចដើម្បីនឹងកំណត់រូប កាន់យករូប កំណត់ បច្ច័យ លើកឡើងកាន់សាមញ្ញលក្ខណៈ ហើយកំណត់អរូប កាន់យកអរូប

កំណត់បច្ច័យ លើកឡើងកាន់សាមញ្ញលក្ខណៈ ឲ្យកម្មដ្ឋានដល់ទីបំផុតបាន ភិក្ខុនោះ រមែងមិនចម្រើនដោយសីល សមាធិ វិបស្សនា មគ្គ ផល និងនិព្វាន ក្នុងសាសនានេះ ដូចហ្វូងគោរបស់នាយគោបាលនោះ រមែងមិនចម្រើន ដូច្នោះ ។ ដូចនាយគោបាលនោះ រមែងឃ្លាតឆ្ងាយចាកបញ្ចគោរស យ៉ាងណា ភិក្ខុនោះក៏ឃ្លាតឆ្ងាយចាកធម្មក្ខន្ធ ៥ គឺ សីលក្ខន្ធ សមាធិខន្ធ បញ្ញាខន្ធ វិមុត្តិ-ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលជារបស់ព្រះអសេក្ខៈ ដូច្នោះ ឈ្មោះថា មិនស្គាល់ដោយសមុដ្ឋាន គឺ មិនដឹងថា រូបប្រមាណប៉ុណ្ណេះ មានសមុដ្ឋាន តែមួយ ប្រមាណប៉ុណ្ណេះ មានសមុដ្ឋានពីរ ប្រមាណប៉ុណ្ណេះ មានសមុដ្ឋានបី ប្រមាណប៉ុណ្ណេះ មានសមុដ្ឋានបួន ប្រមាណប៉ុណ្ណេះ រមែងមិនតាំងឡើងពី សមុដ្ឋានណាឡើយ ដូច្នេះ ។ ភិក្ខុនេះ ប្រៀបដូចនាយគោបាលនោះ មិនស្គាល់ រូបនៃគោទាំងឡាយដោយពណ៌ដូច្នោះ ភិក្ខុមិនស្គាល់រូបដោយសមុដ្ឋាន កាន់ យករូប កំណត់រូបហើយ ។ល។ រមែងឃ្លាតឆ្ងាយ ។

បទថា **ន លក្ខណកុសលោ ហោតិ** សេចក្តីថា រមែងមិនស្គាល់ថា កុសលកម្ម អកុសលកម្ម ជាលក្ខណៈពាល និងបណ្ឌិត ដែលពោលហើយ យ៉ាងនេះថា បុគ្គលពាលមានកម្មជាលក្ខណៈ បុគ្គលជាបណ្ឌិតមានកម្មជាលក្ខណៈ គេកាលមិនស្គាល់យ៉ាងនេះ មិនវៀរបុគ្គលពាល មិនគប់រកបណ្ឌិត កាលមិន

វៀរបុគ្គលពាល មិនគប់រកបណ្ឌិត មិនស្គាល់វត្ថុដែលគួរ មិនគួរ ជាកុសល អកុសល វត្ថុដែលមានទោស មិនមានទោស ទោសធ្ងន់ ទោសស្រាល កែខៃបាន កែខៃមិនបាន ហេតុ មិនមែនហេតុ កាលមិនដឹងវត្ថុនោះ រមែងមិនអាចដើម្បីនឹងកាន់យកកម្មដ្ឋានទៅចម្រើនបាន ភិក្ខុនោះរមែងមិនចម្រើនដោយគុណមានសីលជាដើម តាមដែលពោលហើយក្នុងសាសនានេះ ដូចហ្វូងគោរបស់នាយគោបាលនោះ មិនចម្រើន គឺ ជាអ្នកឃ្លាតឆ្ងាយចាកធម្មក្ខន្ធ ដូចនាយគោបាលឃ្លាតឆ្ងាយចាកបញ្ចគោរស ដូច្នោះ ។

បទថា **ន អាសាដិកំ សាដេតា ហោតិ** សេចក្ដីថា រមែងមិនបន្ទោបង់កាមវិតក្កជាដើម ដែលពោលហើយយ៉ាងនេះថា កាមវិតក្កកើតឡើងហើយដូច្នេះមិនជ្រាប់ផ្ដើះពន្យល់ជាអកុសលវិតក្កនេះ កាលប្រព្រឹត្តទៅក្នុងអំណាចរបស់វិតក្ករមែងមិនអាចដើម្បីនឹងកាន់យកកម្មដ្ឋានទៅចម្រើនបាន ភិក្ខុនោះរមែងឃ្លាតឆ្ងាយដូចនាយគោបាល ។ល។ ។

បទថា **ន វណំ បដិច្ឆាទេតា ហោតិ** សេចក្ដីថា កាលកាន់យកនិមិត្តក្នុងអារម្មណ៍គ្រប់យ៉ាង ដោយន័យជាដើមថា ឃើញរូបដោយចក្ខុហើយ កាន់យកនិមិត្ត ដូច្នេះ រមែងមិនញាំងសេចក្ដីសង្រួមឲ្យដល់ព្រម ដូចនាយគោបាលនោះមិនបិទដំបៅ ដូច្នោះ ភិក្ខុនោះកាលបើកទ្វារត្រាច់ទៅ រមែងមិនអាចដើម្បីនឹង

កាន់យកកម្មដ្ឋានទៅចម្រើនបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **ន ធម្មំ កត្ថា ហោតិ** សេចក្តីថា ភិក្ខុមិនបំពក់ផ្សែង គឺ ធម្មទេសនា ដូចនាយគោបាលនោះមិនបំពក់ផ្សែងដូច្នោះ គឺ មិនធ្វើធម្មកថា ឬសរភញ្ញៈ ឧបនិសិន្នកថា ឬអនុមោទនា អំពីនោះ ពួកមនុស្សមិនស្គាល់គុណនោះថា ភិក្ខុដែលជាពហុស្សូតមានគុណ ដូច្នេះ មនុស្សទាំងនោះ កាលមិនស្គាល់គុណ និងទោស រមែងមិនធ្វើការសង្គ្រោះដោយបច្ច័យ ៤ លោកកាលលំបាកដោយបច្ច័យ ក៏មិនអាចដើម្បីនឹងធ្វើការសូធ្យាយព្រះពុទ្ធវចនៈ បំពេញវត្តបដិបត្តិ ញុំាងកម្មដ្ឋានទៅចម្រើនបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **ន តិត្ថំ ជានាតិ** សេចក្តីថា ភិក្ខុរមែងមិនចូលទៅរកភិក្ខុដែលជាពហុស្សូត ដូចជាកំពង់ កាលចូលទៅរក មិនសាកសួរ កាន់យក សាកសួរឲ្យដឹងយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ព្យញ្ជនៈនេះគប្បីមានអត្ថយ៉ាងណា សេចក្តីនៃភាសិតនេះតើដូចម្តេច បាលីក្នុងទីកន្លែងនេះ បាលីពោលទុកយ៉ាងណា សេចក្តីក្នុងទីនេះសម្តែងទុកយ៉ាងណា ភិក្ខុអ្នកជាពហុស្សូតទាំងនោះ ដែលលោកមិនសាកសួរយ៉ាងនេះ រមែងមិនបើកបង្ហាញសេចក្តីដែលនៅកំបាំង មិនបែកចេញ មិនសម្តែង មិនធ្វើសេចក្តីដែលជ្រៅឲ្យរាក់ មិនធ្វើសេចក្តីដែលមិនប្រាកដ ឲ្យប្រាកដដល់លោក ។

បទថា **អនេកវិហិតេសុ ច កន្ខាដ្ឋានីយេសុ ធម្មេសុ** បានដល់ រមែងមិនបន្ទោបង់សូម្បីសេចក្ដីសង្ស័យយ៉ាងណាមួយ ក្នុងសេចក្ដីសង្ស័យទាំងឡាយមានអធិប្បាយថា ក៏សេចក្ដីសង្ស័យ ឈ្មោះថា ធម៌ជាទីតាំងនៃសេចក្ដីសង្ស័យរមែងមិននាំសូម្បីសេចក្ដីសង្ស័យយ៉ាងណាមួយ ក្នុងធម៌នោះចេញទៅបាន ។ លោកមិនចូលទៅរកកំពង់ គឺ ភិក្ខុដែលជាពហុស្សូតយ៉ាងនេះ ទើបពេញដោយសេចក្ដីសង្ស័យ មិនអាចដើម្បីនឹងញុំាងកម្មដ្ឋានទៅចម្រើនបាន ដូចនាយគោបាល រមែងមិនស្គាល់កំពង់ យ៉ាងណា ភិក្ខុនេះមិនស្គាល់កំពង់ គឺ ធម្មៈដូច្នោះ កាលមិនដឹង បានសួរបញ្ហាមិនមែនជាវិស័យ ចូលទៅរកភិក្ខុអភិធម្មបានសួរវត្ថុដែលគួរមិនគួរ ចូលទៅរកភិក្ខុវិន័យធរ បានសួរការ កំណត់រូបនិងអរូប ភិក្ខុទាំងនោះ ត្រូវភិក្ខុសួរក្នុងធម៌ដែលមិនមែនវិស័យ រមែងមិនអាចដើម្បីនឹងឆ្លើយបាន លោកទើបពេញទៅដោយសេចក្ដីសង្ស័យដោយខ្លួនឯងទើបមិនអាចដើម្បីនឹងញុំាងកម្មដ្ឋានទៅចម្រើនបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **បិតំ ន ជានាតិ** សេចក្ដីថា ភិក្ខុរមែងមិនដឹង គឺ មិនបានបាមោជ្ជៈប្រកបដោយធម៌ ដូចនាយគោបាលនោះ រមែងមិនស្គាល់គោដែលផឹក និងមិនផឹកដូច្នោះ ភិក្ខុអាស្រ័យបុញ្ញកិរិយាវត្ថុ សម្រេចដោយការស្ដាប់រមែងមិនប្រសព្វអានិសង្ស ទៅកាន់រោងស្ដាប់ធម៌ហើយ រមែងមិនស្ដាប់ដោយ

សេចក្តីគោរព អន្តួយលក់ រមែងនិយាយគ្នា ជាអ្នកមានចិត្តបញ្ចូនទៅទីដទៃ ភិក្ខុកាលមិនស្តាប់ធម៌ដោយសេចក្តីគោរព រមែងមិនអាចដើម្បីនឹងញុំាងកម្មដ្ឋានទៅចម្រើនបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **ន វីថឹ ជានាតិ** សេចក្តីថា ភិក្ខុរមែងមិនដឹងច្បាស់អរិយមគ្គមានអង្គ ៨ តាមសេចក្តីពិតថា ផ្លូវនេះជាលោកិយៈ ផ្លូវនេះជាលោកុត្តរៈ ដូច្នេះ ដូចនាយគោបាលនោះ មិនដឹងនូវផ្លូវ និងមិនមែនផ្លូវ ដូច្នោះ កាលលោកមិនដឹង ក៏តាំងនៅក្នុងផ្លូវដែលជាលោកិយៈ រមែងមិនអាចនឹងញុំាងលោកុត្តរ-ធម៌ឲ្យកើតឡើងបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **ន គោចរកុសលោ ហោតិ** សេចក្តីថា ភិក្ខុរមែងមិនដឹងច្បាស់សតិប្បដ្ឋាន ៤ តាមសេចក្តីពិតថា ធម៌ទាំងនេះជាលោកុត្តរៈ ដូចនាយគោបាលនោះ មិនដឹងនូវកាល ៥ ថ្ងៃមួង និង ៧ ថ្ងៃមួង ដូច្នោះ កាលលោកមិនដឹងបណ្តុះញាណរបស់ខ្លួនទុកក្នុងធម៌ត្រង់ទីដែលសុខុម តាំងនៅក្នុងសតិប្បដ្ឋានជាលោកិយៈ រមែងមិនអាចដើម្បីនឹងញុំាងលោកុត្តរធម៌ឲ្យកើតឡើងបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **អនវសេសទោហី** សេចក្តីថា ភិក្ខុ កាលមិនស្គាល់ប្រមាណក្នុងការទទួល រមែងរឹតចេញអស់មិនបានបន្សល់ទុក ចំណែកក្នុងនិទ្ទេសវារៈ ពួក

គហបតីអ្នកមានសទ្ធាមកបវារណាដល់ភិក្ខុនោះថា **អភិហដ្ឋុំ បវារេន្តិ** ក្នុងការបវារណានេះ **បវារណាមាន ២** គឺ បវារណាដោយវាចា ១ បវារណាដោយបច្ច័យ ១ ។ ពួកមនុស្សទៅកាន់សម្នាក់របស់ភិក្ខុហើយ បវារណាថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់គប្បីប្រាប់វត្ថុដែលត្រូវការ ដូច្នេះ ឈ្មោះថាបវារណាដោយវាចា ។ ពួកមនុស្សកាន់សំពត់ ឬភេសជ្ជៈ មានទឹកដោះ និងទឹកអំពៅជាដើម ទៅសម្នាក់របស់ភិក្ខុ ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទទួលតាមសេចក្ដីត្រូវការចុះ ដូច្នេះ ឈ្មោះថា បវារណាដោយបច្ច័យ ។ បទថា **តត្រ ភិក្ខុ មត្តំ ន ជានាតិ** មានអធិប្បាយថា ភិក្ខុមិនស្គាល់ប្រមាណក្នុងបច្ច័យទាំងនោះ មិនទទួលតែល្មមប្រមាណ ដោយន័យដែលលោកពោលទុកក្នុងរថវិនីតសូត្រថា គប្បីដឹងប្រមាណក្នុងទាយក ដឹងប្រមាណក្នុងទេយ្យធម៌ គប្បីដឹងកម្លាំងរបស់ខ្លួន ទទួលវត្ថុដែលគេនាំមកថ្វាយទាំងអស់ ។ មនុស្សក្តៅក្រហាយនឹងមិនបវារណាទៀត ។ ភិក្ខុកាលលំបាកដោយបច្ច័យរមែងមិនអាចនឹងញ៉ាំងកម្មដ្ឋានទៅចម្រើនបាន ។ល។ គេរមែងឃ្លាតឆ្ងាយ ។

បទថា **តេ ន អតិរេកបូជាយ បូជិតា ហោតិ** សេចក្ដីថា ភិក្ខុមិនបូជាភិក្ខុទាំងនោះដែលជាព្រះថេរៈ ដោយបូជាជាអតិរេក មានមេត្តាកាយកម្មជាដើមនេះ ទាំងក្នុងទីចំពោះ ទាំងក្នុងទីកំបាំងមុខ ដូចនាយគោបាលមិនបំប៉ន

គោធំ ដោយការបំប៉នពិសេស ដូច្នោះ ព្រោះដូច្នោះ ព្រះថេរៈគិតថា ភិក្ខុទាំងឡាយមិនធ្វើសេចក្ដីគោរព និងសេចក្ដីកោតក្រែងក្នុងពួកយើងទាំងនេះហើយ ទើបមិនបានសង្គ្រោះពួកនវកភិក្ខុ ដោយការសង្គ្រោះ ២ យ៉ាង គឺ មិនសង្គ្រោះដោយធម៌ ១ ដោយអាមិស ១ មិនទំនុកបម្រុងនវកភិក្ខុដែលលំបាក ខ្វះខាតដោយចីវរ ឬបាត្រ វត្ថុទាក់ទងដោយបាត្រ ឬទីនៅ មិនឲ្យសិក្សាបាលី ឬអដ្ឋកថា គម្ពីរជាប់ទាក់ទងដោយធម្មកថា ឬគម្ពីរដែលអាថ៌កំបាំង ពួកនវកភិក្ខុកាលមិនបានការសង្គ្រោះដោយ ២ យ៉ាងទាំងនេះ អំពីសម្នាក់របស់ព្រះថេរៈទាំងឡាយដោយប្រការទាំងពួង រមែងមិនអាចដើម្បីនឹងតាំងនៅក្នុងសាសនានេះបាន ។ ពួកលោករមែងមិនចម្រើនដោយគុណ មានសីលជាដើម ដូចហ្វូងគោរបស់នាយគោបាល រមែងមិនចម្រើន ដូច្នោះ ។ នាយគោបាលនោះរមែងជាអ្នកឃ្លាតឆ្ងាយចាកបញ្ចគោរស យ៉ាងណា លោករមែងជាអ្នកឃ្លាតឆ្ងាយចាកធម្មក្ខន្ធ ៥ យ៉ាងនោះ សុក្កបក្ខ លោកប្រកបទុកហើយ គប្បីជ្រាបដោយអំណាចផ្ទុយគ្នា ដូចពោលហើយក្នុងកណ្ហបក្ខ ។

( ចប់ អដ្ឋកថា មហាគោបាលសូត្រទី ៣ )

# អ ដ្ឋ ក ថា

## ចូឡគោបាលសូត្រទី ៤

[២៨] ចូឡគោបាលសូត្រ មានបទផ្តើមថា **ឯវម្មេ សុតំ** ។

បណ្តាបទទាំងនោះ បទថា **ឧក្កចេលាយំ** គឺ ក្នុងក្រុងមានឈ្មោះយ៉ាងនោះ ។

បានឮថា កាលគេកំពុងសាងក្រុងនោះ ត្រីលោតចេញពីក្រសែទន្លេគង្គាឡើងគោកក្នុងពេលយប់ ពួកមនុស្សជ្រលក់សំពត់ក្នុងថាសប្រេងឲ្យសើមធ្វើជាគប់ភ្លើងចាប់ត្រី ។ កាលក្រុងនោះសាងសម្រេចហើយ ពួកគេកាលនឹងតាំងឈ្មោះក្រុងនោះ ទើបបានតាំងឈ្មោះក្រុងនោះថា **ឧក្កចេលា** ដោយគិតថា ក្នុងថ្ងៃសាងក្រុង ពួកយើងចាប់ត្រីបានដោយគប់ភ្លើងសំពត់ ។ បទថា **ភិក្ខូ អាមន្តេសិ** សេចក្តីថា ទន្លេគង្គាទាំងអស់ រមែងប្រាកដដល់អ្នកអង្គុយក្នុងស្ថានទីណា ព្រះមានព្រះភាគ មានភិក្ខុសង្ឃជាច្រើនហែហម ប្រថាប់អង្គុយក្នុងស្ថានទីនោះជាឆ្នេរខ្សាច់មាត់ទន្លេគង្គា វេលាល្ងាច ទ្រង់ទតព្រះនេត្រដល់ទន្លេគង្គា ដែលពេញប្រៀប កំពុងហូរ ទ្រង់ពិចារណាថា មានអ្នកណាៗ ហ្ន៎ អាស្រ័យទន្លេគង្គានេះហើយ បានទទួលសេចក្តីចម្រើន និងសេចក្តីសាបសូន្យក្នុងកាលមុន ទ្រង់បាន

ឃើញថា ហ្វូងគោច្រើនពាន់ អាស្រ័យនាយគោបាលល្ងង់ម្នាក់ ធ្លាក់ក្នុងក្រសែទឹកគួចនៃទន្លេគង្គានេះ ចូលទៅកាន់សមុទ្រ ចំណែកហ្វូងគោច្រើនសែនមានសេចក្ដីសួស្ដី សេចក្ដីចម្រើន សេចក្ដីមិនមានរោគ ព្រោះអាស្រ័យនាយគោបាលឆ្លាតម្នាក់ទៀត ។ លុះទ្រង់ឃើញហើយ ទ្រង់ត្រិះរិះថា តថាគតនឹងអាស្រ័យហេតុនេះ សម្ដែងធម៌ដល់ពួកភិក្ខុនេះ ដូច្នេះ ទើបត្រាស់ហៅភិក្ខុទាំងឡាយ ។

[២៩] បទថា **មាគធកោ** គឺ អ្នកមគធរដ្ឋ បទថា **ទុប្បញ្ញជាតិកោ** បានដល់ ពួកមហាជនមិនមានបញ្ញាជាសភាវៈ ។ បទថា **អសមវេក្ខិត្វា** បានដល់ មិនកំណត់ គឺ មិនពិចារណា ។ បទថា **បតារេសិ** ផ្ដើមដើម្បីនឹងឲ្យឆ្លង បទថា **ឧត្តរំ តីរំ សុវិទេហានំ** សេចក្ដីថា ឲ្យគោឆ្លងទៅកាន់ត្រើយខាងនាយ ដោយគិតថា យើងនឹងនាំអ្នកមគធរដ្ឋត្រង់ត្រើយនេះនៃទន្លេគង្គា ទៅកាន់វិទេហរដ្ឋខាងត្រើយឯណោះ នាំគោពីមគធរដ្ឋ ទៅកាន់វិទេហរដ្ឋ ហើយរក្សា ព្រះមានព្រះ-ភាគ ទ្រង់សំដៅយកនាយគោបាលនោះ ទើបត្រាស់ថា **ឧត្តរំ តីរំ សុវិទេហានំ** ដូច្នេះ ។ បទថា **អាមណ្ឌលិកំ ករិត្វា** បានដល់ ធ្វើឲ្យវិល ។ បទថា **អនយ-ព្យសនំ អាបជ្ជឹសុ** បានដល់ ដល់សេចក្ដីវិនាស គឺ មិនចម្រើន គឺ ចូលទៅកាន់មហាសមុទ្រ ។ ក៏នាយគោបាលនោះ កាលឲ្យគោឆ្លង គប្បីពិនិត្យមើលកំពង់ដែលរាបស្មើ និងមិនរាបស្មើត្រង់ត្រើយនេះនៃទន្លេគង្គា គប្បីកំណត់ទីទួល

ខ្សាច់ទុក ២-៣ កន្លែង ដើម្បីជាកន្លែងសម្រាកគោកណ្ដាលទន្លេគង្គា ម្យ៉ាងទៀត គប្បីកំណត់កំពង់ទុក ៣-៤ កំពង់ ខាងត្រើយឯណោះថា គោចុះហើយពីកំពង់នេះ នឹងទៅឡើងកំពង់នេះ ចុះពីកំពង់នេះ នឹងមិនឡើងកំពង់នេះ ដូច្នេះ ។ ចំណែកនាយគោបាលល្ងង់នេះ មិនពិចារណាមើលកំពង់សម្រាប់គោ ត្រង់ប្រាំងនេះរាបស្មើ ឬមិនរាបស្មើ មិនកំណត់ទីទួលខ្សាច់ទុក ២-៣ កន្លែង ដើម្បីជាទីកន្លែងសម្រាកគោកណ្ដាលទន្លេគង្គា មិនពិចារណារកកន្លែងជាទីឡើងទុក ៤-៥ កន្លែង ត្រង់ត្រើយម្ខាងទៀត ឲ្យគោចូងទៅត្រង់ស្ថានទីមិនមែនកំពង់ ។ គ្រានោះ គោធំរបស់គេហែលកាត់ទទឹងក្រសែទឹកទន្លេគង្គាទៅដល់ត្រើយឯណោះ ព្រោះដល់ព្រមដោយភាពរហ័សរហួន និងព្រោះដល់ព្រមដោយកម្លាំង ឃើញវាលំបាកនិងបន្ទា គុម្ពឈើក្រាស់ណែន ហើយដឹងថា ទីនោះចេញទៅបានលំបាក ដូច្នេះ មិនបានទីទួលសម្រាប់ឈរ ក៏ហែលត្រឡប់វិញ ។ គោទាំងឡាយគិតថា គោធំហែលត្រឡប់ហើយ សូម្បីពួកយើងក៏នឹងហែលត្រឡប់ ដូច្នេះ ក៏ហែលត្រឡប់ជាមួយគ្នា ។ ក្នុងពួកហ្វូងគោចំនួនច្រើនត្រឡប់ ទឹកគួចកាត់ទឹក តាំងឡើងកណ្ដាលទន្លេគង្គា ហ្វូងគោចូលទៅក្នុងទឹកគួចដល់សមុទ្រ គោណាមួយឈ្មោះថា មិនមានអន្តរាយ មិនមានឡើយ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា គោទាំងឡាយដល់ហើយនូវសេចក្ដីវិនាស មិនបានប្រយោជន៍ក្នុងទី

នោះឯង បទថា **អកុសលា ឥមស្ស លោកស្ស** បានដល់ សមណព្រាហ្មណ៍ ជាអ្នកមិនឆ្លាត គឺ វាងវៃក្នុងលោកនេះ គឺ ១២ អាយតនៈ ធាតុ ។ សូម្បី ក្នុងបរលោក ក៏មានន័យនេះឯង ។ **អន្ទាក់មារ** លោកហៅ **តេភូមិកធម៌** មិន មែនអន្ទាក់មារ លោកហៅថា **លោកុត្តរធម៌** សូម្បីទីតាំងមច្ចុ លោកហៅ តេ-ភូមិកធម៌ សូម្បីទីតាំងអមច្ចុ លោកហៅថា នវលោកុត្តរធម៌ សមណព្រាហ្មណ៍ អ្នកមិនឆ្លាត គឺ វាងវៃក្នុងធម៌ទាំងនោះ ចំណែកដោយសេចក្តីរបស់ពាក្យ អន្ទាក់ មារ ឈ្មោះថា **មារធេយ្យា** គោចរដែលជាឋានៈ ទីនៅ និងទីអាស្រ័យ ឈ្មោះ **ធេយ្យា** សូម្បីក្នុង **មច្ចុធេយ្យា** ក៏មានន័យនេះឯង ។ បទថា **តេសំ** បានដល់ សមណព្រាហ្មណ៍ពួកនោះ គឺ បែបនោះ ។ គប្បីជ្រាបថា គ្រូទាំង ៦ លោក សម្តែងទុកហើយដោយបទនេះ ។

[៣០] ព្រះដ៏មានព្រះភាគ កាលទ្រង់បញ្ចប់កណ្ហបក្ខយ៉ាងនេះហើយ ទើបទ្រង់សម្តែងសុក្កបក្ខ ត្រាស់ពាក្យជាដើមថា **ភូតបុព្វំ ភិក្ខវេ** ដូច្នេះ បណ្តាបទទាំងនោះ បទថា **ពលវគាវេ** គឺ គោដែលទូន្មានហើយ និងមេគោ ។ បទថា **ទម្មគាវេ** គឺ គោដែលគួរទូន្មាន និងគោក្រមុំ បទថា **វច្ឆតរេ** បានដល់ កូនគោមានកម្លាំង ដែលកន្លងភាពជាកូនគោ ។ បទថា **វច្ឆកេ** គឺ កូនគោ ជំទង់នៅបៅដោះ ។ បទថា **កីសពលកេ** គឺ មានសាច់ និងឈាមតិច កម្លាំង

តិច ។ បទថា **តាវទេវ ជាតកោ** គឺ កូនគោដែលកើតក្នុងថ្ងៃនោះ ។ បទថា **មាតុ គោរវកេន វុយ្ហមានោ** សេចក្ដីថា មេគោបញ្ចេញសំឡេងខាងមុខ ហ៊ុំ ហ៊ុំ ឲ្យសញ្ញាហែលកាត់ទឹកទៅ ។ កូនគោហែលទៅតាមទឹក តាមមេគោនោះឯង ដោយសំឡេងស្រែករបស់មេគោនោះ លោកហៅថា អណ្ដែតតាមសំឡេងស្រែករបស់មេ ។

[៣១] បទថា **មារស្ស សោតំ ឆេត្វា** សេចក្ដីថា កាត់ក្រសែនៃតណ្ហារបស់មារ ដោយអរហត្តមគ្គ ។ បទថា **បារំ គតា** បានដល់ ភិក្ខុដល់ត្រើយសង្សារ គឺ និព្វាន ដូចគោធំហែលទៅដល់ត្រើយទន្លេដូច្នោះ ។ បទថា **បារំ អគមំសុ** សេចក្ដីថា ក្នុងខណៈដែលគោធំដល់ត្រើយ គោទាំងឡាយហែលកន្លង ៣ ចំណែកក្រសែទន្លេគង្គាហើយ ឃើញគោធំដល់ត្រើយ ទើបទៅតាមផ្លូវដែលគោធំទាំងនោះទៅហើយ ។ បទថា **បារំ គមិស្សន្តិ** សេចក្ដីថា អ្នកញុំាងកិលេស ដែលមគ្គ ៤ គប្បីសម្លាប់ ៣ ចំណែក ឲ្យអស់ហើយតាំងនៅ ។

ឥឡូវនេះ គប្បីជ្រាបសេចក្ដីក្នុងវារៈទាំងពួងដោយន័យនេះថា ភិក្ខុអ្នកកាត់ក្រសែតណ្ហាអស់ទៅ ដោយអរហត្តមគ្គហើយ នឹងដល់ត្រើយសង្សារ គឺ និព្វាន ដូចគោដែលកំពុងហែលកាត់ក្រសែទន្លេគង្គាដល់ត្រើយទន្លេ ដូច្នោះ ។ ភិក្ខុ ២ រូបទាំងនេះ គឺ ជាធម្មានុសារី សទ្ធានុសារី ជាអ្នកប្រកបព្រមដោយ

មគ្គខាងដើម ។ បទថា **ជានតា** គឺ ព្រះពុទ្ធទ្រង់ដឹងនូវធម៌ទាំងពួង ។ បទថា **សុបកាសិតោ** ប្រែថា ពោលទុកល្អហើយ បទថា **វិវដំ** ប្រែថា បើកហើយ ។ បទ **អមតទ្វារំ** បានដល់ អរិយមគ្គ ។ បទថា **និព្វានបត្តិយា** គឺ បើកដើម្បីប្រយោជន៍ដល់និព្វាននោះ ។ បទថា **វិនឡីកតំ** គឺ ធ្វើមានះ ដូចដើមបបុសឲ្យវិនាសទៅ ។ បទថា **ខេមំ បត្ថេថ** សេចក្តីថា ពួកលោកជាអ្នកប្រាថ្នាព្រះអរហត្ត គឺ ជាអ្នកត្រូវការឲ្យព្រះអរហត្តកើតឡើង ដោយកត្តុកម្យតាឆន្ទះ ។ បាលីថា **បត្តត្ថ** ដូច្នេះក៏មាន ។ មានអធិប្បាយថា ពួកលោក បានព្រះសាស្តាបែបនេះ ឈ្មោះថា សម្រេចហើយដូចគ្នា ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយទាំងអស់នោះឯង ក៏ព្រះមានព្រះភាគ ទ្រង់បញ្ចប់ការសម្តែងធម៌តាមអនុសន្ធិដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថា ចូឡគោបាលសូត្រ ទី ៤ )

# អ ដ្ឋ ក ថា

## ចូឡសច្ចកសូត្រទី ៥

[៣២] ចូឡសច្ចកសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ។

បណ្ដាបទទាំងនោះ បទថា **មហាវនេ កូដាគារសាលាយំ** សេចក្ដីថា ព្រៃធំមានកំណត់កើតឯង មិនបានដាំ ឈ្មោះថា មហាវន ។ ចំណែកព្រៃមហាវនជិតក្រុងកបិលវត្ថុ ជាប់តគ្នានឹងព្រៃហិមពាន្ត មិនមានកំណត់ រហូតដល់មហាសមុទ្រ ។ ព្រៃនេះ មិនជាដូច្នោះទេ ឈ្មោះថា ព្រៃមហាវន ព្រោះអត្ថថា ជាព្រៃធំមានកំណត់ ។ ចំណែកកូដាគារសាលា កាលសាងអារាមសម្រេចហើយ ទើបធ្វើកូដាគារទុកខាងក្នុង ប្រក់ដំបូលដោយគ្រឿងប្រក់ ដូចសត្វហង្ស និងសត្វចាបប្រក់ហើយ គប្បីជ្រាបថា ជាព្រះគន្ធកុដិរបស់ព្រះមានព្រះភាគ ដល់ព្រមដោយអាការទាំងពួង ។

បទថា **សច្ចកោ និគណ្ឋបុត្តោ** សេចក្ដីថា បានឮថា ក្នុងកាលមុន បុរសនិគ្រន្ថម្នាក់ ស្រីម្នាក់ បានរៀនវាទៈម្នាក់ៗ ៥០០ ហើយ គិតថា យើងនឹងលើកវាទៈ ដូច្នេះ កាលត្រាច់ទៅក្នុងជម្ពូទីប មកនៅរួមគ្នាក្នុងក្រុងវេសាលី ។ ពួកស្ដេចលិច្ឆវីឃើញហើយ ទើបសួរថា លោកជានរណា លោកជានរណា

ដូច្នេះ ៗ បុរសនិគ្រន្ថក្រាបទូលថា ទូលបង្គំត្រាច់ទៅក្នុងជម្ពូទ្វីបដោយ គិតថា យើងនឹងលើកវាទៈ ដូច្នេះ ៗ ស្ត្រីនិគ្រន្ថ ក៏បានក្រាបទូលយ៉ាងនោះ ៗ ស្តេចលិច្ឆវីត្រាស់ថា សូមលោកចូរលើកវាទៈចំពោះគ្នានិងគ្នាក្នុងទីនេះចុះ ៗ ស្ត្រីនិគ្រន្ថ ទើបបានសួរវាទៈ ៥០០ ដែលខ្លួនរៀនហើយ បុរសនិគ្រន្ថបានតបហើយ, កាលបុរសនិគ្រន្ថសួរ ស្ត្រីនិគ្រន្ថក៏តបបានអស់ ៗ សូម្បីម្នាក់មិនមានឈ្នះ មិនមានចាញ់គ្នា ទាំង ២ នាក់ បានជាអ្នកស្មើៗ គ្នា ៗ ស្តេចលិច្ឆវីត្រាស់ថា លោកសូម្បីទាំង ២ នាក់ ស្មើគ្នា នឹងត្រាច់ទៅធ្វើអ្វី ចូរនៅក្នុងទីនេះចុះ ទ្រង់ព្រះរាជទានផ្ទះ និងតាំងសួយឲ្យ ៗ ព្រោះការនៅរួមគ្នារបស់អ្នកទាំង ២ នោះ ក៏មានធីតា ៤ នាក់ គឺ ឈ្មោះសច្ចា ១ ឈ្មោះលោលា ១ ឈ្មោះបដាចារា ១ ឈ្មោះសិវាវតកា ១ ធីតាទាំងនោះ ក៏បានជាបណ្ឌិតដូចគ្នា បានរៀនវាទៈម្នាក់ៗ ៥០០ ដែលមាតាបិតាបានបង្រៀនមក ៗ ស្ត្រីទាំងនោះ ចម្រើនវ័យ បានពោលនឹងមាតាបិតាថា ម៉ែ ឈ្មោះថា កុលទារិការបស់យើង មិនត្រូវឲ្យប្រាក់ និងមាសជាដើម ហើយបញ្ជូនទៅកាន់ផ្ទះនៃត្រកូល ចំណែកអ្នកណានៅគ្រប់គ្រងផ្ទះ រមែងអាចដើម្បីនឹងញាំញីវាទៈ របស់ស្ត្រីទាំងនោះបាន ស្ត្រីទាំងនោះ នឹងជាបាទបរិចារិការបស់អ្នកនោះ អ្នកណាជាអ្នកបួស រមែងអាចដើម្បីនឹងញាំញីវាទៈរបស់ស្ត្រីទាំងនោះបាន ស្ត្រីទាំងនោះ ក៏នឹងបានបួសក្នុង

សម្នាក់របស់អ្នកនោះ ពុកម៉ែនឹងធ្វើយ៉ាងណា ដូច្នេះ ។ ស្ត្រី ៤ នាក់ កាន់ភេទជាអ្នកបួស ដោយគិតថា សូម្បីពួកយើងនឹងធ្វើយ៉ាងនេះឯង គិតថា ឈ្មោះថា ជម្ពូទ្វីបនេះ រមែងប្រាកដដោយដើមព្រីង ដូច្នេះ ក៏កាន់យកមែកព្រីងដើរទៅដល់ស្រុកណា ក៏បោះទង់មែកព្រីង ពូនធូលី ឬគំនរខ្សាច់ ហើយទើបពោលថា អ្នកណាអាចលើកវាទៈ អញ្ជើញអ្នកនោះ ជាន់ទង់នេះចុះ ទើបចូលទៅក្នុងស្រុក ពួកគេត្រាច់ទៅគ្រប់ៗ ស្រុកយ៉ាងនេះ ដល់ក្រុងសាវត្ថី បោះទង់មែកព្រីងទុកត្រង់ទ្វារស្រុក ដូចយ៉ាងនោះ ប្រាប់ដល់ពួកមនុស្សដែលមកដល់ រួចចូលទៅខាងក្នុងព្រះនគរ ។

សម័យនោះ ព្រះមានព្រះភាគ ទ្រង់អាស្រ័យក្រុងសាវត្ថី ប្រថាប់នៅក្នុងវត្តជេតពន កាលនោះព្រះសារីបុត្រ សួរអាការអ្នកជម្ងឺ រវល់តែចាត់ទីកន្លែងដែលគេមិនបានចាត់ កាលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ទើបថ្ងៃជាងភិក្ខុពួកដទៃ ព្រោះមានកិច្ចច្រើន បានឃើញទង់មែកព្រីងត្រង់ទ្វារស្រុក ទើបសួរពួកក្មេង នេះជាអ្វី ពួកគេបានប្រាប់សេចក្តីនោះ ។ ព្រះថេរៈពោលថា បើយ៉ាងនោះ ពួកអ្នកឯងចូរជាន់ចុះ ។ ពួកក្មេងពោលថា បពិត្រលោកដ៏ចម្រើន ពួកខ្ញុំមិនហាន ព្រោះខ្លាច ។ ព្រះថេរៈពោលថា ពួកអ្នកមិនចាំបាច់ខ្លាចទេ ។ ព្រះថេរៈពោលថា កាលនាងបរិព្វជិកាសួរថា អ្នកណាឲ្យជាន់ទង់មែកព្រីង

របស់យើង ពួកអ្នកគប្បីប្រាប់ថា ព្រះសារីបុត្រ ជាពុទ្ធសាវកឲ្យជាន់ លោកចង់លើកវាទៈ ចូរទៅកាន់សម្នាក់របស់ព្រះថេរៈ ឯវត្តជេតពន ។

ពួកក្មេង ស្តាប់ពាក្យរបស់ព្រះថេរៈ ទើបនាំគ្នាជាន់ទង់មែកព្រីងចោលទៅ ។ ព្រះថេរៈ ត្រាច់បិណ្ឌបាតហើយត្រឡប់ទៅកាន់វិហារ ។ ពួកបរិព្វាជិកាចេញអំពីស្រុកហើយ ទើបសួរថា អ្នកណាឲ្យជាន់ទង់របស់យើង ។ ពួកក្មេងប្រាប់សេចក្តីនោះ ។ ពួកបរិព្វាជិកា ចូលទៅក្នុងស្រុកទៀត ទៅម្នាក់មួយផ្លូវៗ បានប្រាប់ថា បានឮថា សារីបុត្រ ជាពុទ្ធសាវកនឹងឆ្លើយតបវាទៈជាមួយពួកយើង លោកប្រាថ្នានឹងស្តាប់ចូរទៅចុះ ។ មហាជនទៅហើយ ។ បរិព្វាជិកាបានមកកាន់វត្តជេតពន រួមនឹងមហាជននោះ ។ ព្រះថេរៈគិតថា មាតុគ្រាមនឹងមកក្នុងទីសម្រាករបស់យើង មិនជាការល្អ ដូច្នេះ ទើបអង្គុយត្រង់កណ្តាលវិហារ ។

នាងបរិព្វាជិកាសួរទៅកាន់ព្រះថេរៈថា លោកឲ្យគេជាន់ទង់របស់យើងឬ ?

ព្រះថេរៈពោលថា ត្រូវហើយ យើងឲ្យគេជាន់នោះឯង ដូច្នេះ ។

នាងបរិព្វាជិកា ពោលថា យើងនឹងលើកវាទៈជាមួយលោក ។

ព្រះថេរៈពោលថា ល្អហើយ អញ្ជើញលើកចុះ អ្នកណាសួរ អ្នកណា

ឆ្លើយ ។

នាងបរិព្វាជិកាពោលថា ខ្ញុំជាអ្នកសួរ ។

ព្រះថេរៈពោលថា ក៏អ្នកជាមាតុគ្រាម អញ្ជើញសួរមុនចុះ ។

ពួកនាងបរិព្វាជិកាទាំង ៤ នាក់នោះ ឈរនៅក្នុង ៤ ទិស បានសួរបញ្ហាមួយពាន់វាទៈ ដែលបានរៀនក្នុងសម្នាក់របស់មាតាបិតា ។

ព្រះថេរៈពោលឆ្លើយពាក្យសួរមិនឲ្យលំបាក មិនឲ្យមានតំណារ ដូចកាត់ទងឈូកដោយកាំបិត ដូច្នោះ ។ គ្រាដោះស្រាយហើយ ទើបពោលឲ្យសួរទៀត ។

នាងបរិព្វាជិកាពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ចេះប៉ុណ្ណេះឯង ។

ព្រះថេរៈពោលថា នាងសួរពាន់វាទៈហើយ យើងក៏បានឆ្លើយហើយ តែយើងនឹងសូមសួរបញ្ហាត្រឹមតែមួយ នាងត្រូវឆ្លើយបញ្ហានោះ ។

នាងបរិព្វាជិកាទាំងនោះ ឃើញវិស័យរបស់ព្រះថេរៈ មិនអាចនឹងនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន សួរចុះ ពួកខ្ញុំម្ចាស់នឹងឆ្លើយ ដូច្នេះ ទើបពោលទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកចូរសួរចុះ កាលពួកខ្ញុំម្ចាស់ដឹងនឹងឆ្លើយប្រាប់ ។ ព្រះថេរៈពោលថា បញ្ហានេះ ត្រូវឲ្យកុលបុត្របព្វជ្ជាឲ្យសិក្សាជាគ្រាដំបូង ហើយទើបសួរថា អ្វីឈ្មោះថាមួយ ។

នាងបរិព្វាជិកាទាំងនោះ មិនឃើញខាងដើម មិនឃើញខាងចុង ។

ព្រះថេរៈពោលថា ឆ្លើយចុះ ។

នាងបរិព្វាជិកាពោលថា ពួកខ្ញុំម្ចាស់ មិនឃើញទេលោកម្ចាស់

ព្រះថេរៈពោលថា នាងសួរទាំងពាន់វាទៈ យើងក៏ឆ្លើយហើយ តែនាង មិនអាចនឹងឆ្លើយបញ្ហាសូម្បីតែមួយរបស់យើង បើដូច្នោះ អ្នកណាហ្ន៎ ជាអ្នកឈ្នះ អ្នកណាហ្ន៎ ជាអ្នកចាញ់ ។

នាងបរិព្វាជិកាពោលថា លោកម្ចាស់ជាអ្នកឈ្នះ ពួកខ្ញុំម្ចាស់ជាអ្នកចាញ់ លោកម្ចាស់។

ព្រះថេរៈពោលថា គ្រានេះ នាងនឹងធ្វើយ៉ាងណា ។ នាងបរិព្វាជិកាប្រាប់ពាក្យដែលមាតាបិតាពោលហើយ ទើបពោលថា ពួកខ្ញុំម្ចាស់នឹងបួសក្នុងសម្នាក់លោកម្ចាស់ ។ ព្រះថេរៈពោលថា នាងជាមាតុគ្រាម មិនគួរនឹងបួសក្នុងសម្នាក់របស់យើង តែនាងកាន់សាសន៍របស់យើងទៅកាន់សម្នាក់ភិក្ខុនីបួសចុះ ។ នាងបរិព្វាជិកាទទួលថា សាធុ កាន់សាសន៍របស់ព្រះថេរៈ ទៅសម្នាក់ភិក្ខុនីសង្ឃសូមបួស កាលបួសហើយ ជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាមមិនយូរ ក៏បានសម្រេចព្រះអរហត្ត ។

សច្ចកនិគ្រន្ថនេះ ជាប្អូនប្រុសរបស់នាងបរិព្វាជិកា ៤ នាក់នោះ ជាអ្នក

មានបញ្ញាក្រៃលែងជាងនាងទាំង ៤ នាក់នោះ បានរៀនទូវពាន់វាទៈពីសម្នាក់របស់មាតាបិតា និងតពីនោះ បានរៀនលទ្ធិខាងក្រៅច្រើនជាង មិនទៅណាបង្រៀនរាជកុមារឲ្យសិក្សាសិល្បៈនៅក្នុងក្រុងវេសាលីនោះ គេខ្វាចថា ពោះរបស់យើងគួរនឹងបែក ព្រោះពេញដោយបញ្ញាពេកទៅ ក៏យកបន្ទះដែកក្រវាត់រុំពោះត្រាច់ទៅ ។ លោកសំដៅនិគ្រន្ថនេះ ទើបពោលថា **សច្ចកោ និគន្ថបុត្តោ** ដូច្នេះ ។

បទថា **ភស្សប្បវាទិកោ** បានដល់ កថាមគ្គ លោកពោល **ភស្ស** ឈ្មោះថា ជាអ្នកឆ្លើយតប ព្រោះអត្ថថា និយាយ គឺ ពោលតបភស្សៈនោះ ។ បទថា **បណ្ឌិតវាទោ** បានដល់ និយាយលើកខ្លួនថា ជាបណ្ឌិត ។ បទថា **សាធុ សម្មតោ ពហុជនស្ស** សេចក្តីថា រមែងអាងវត្ថុណាៗ មកដោយទក្ខត្តវារៈ ។ ដោយច្រើនវត្ថុនោះៗ រមែងយ៉ាងនោះ ព្រោះដូច្នោះ ជនជាច្រើនរមែងថា ជាមេលទ្ធិល្អ ចម្រើន ។ បទថា **វាទេន វាទំ សមារទ្ធោ** បាន ដល់លើកសេចក្តីខុសឡើងដោយកថាមគ្គ ។ បទថា **អាយស្មា អស្សជិ** បានដល់ព្រះអស្សជិត្ថេរជាអាចារ្យរបស់ព្រះសារីបុត្តត្ថេរ ។

បទថា **ជង្ឃាវិហារំ អនុចង្កមមានោ** សេចក្តីថា ចង្រ្កមអំពីព្រះតំណាក់របស់ស្តេចលិច្ឆវីនោះៗ ដើម្បីទៅកាន់ព្រះតំណាក់នោះៗ ។ បទថា **យេនា**-

**យស្មា អស្សជិតេនុបសង្កមិ** សេចក្តីថា សួរថា ចូលទៅរកព្រោះហេតុអ្វី ។ ឆ្លើយថា ដើម្បីដឹងលទ្ធិ ។

បានឮថា សច្ចកនិគ្រន្ថបានមានគំនិតយ៉ាងនេះថា យើងត្រាច់ដើរដោយគិតថា យើងនឹងលើកវាទៈចំពោះព្រះសមណគោតម មិនលើកឡើងថា យើងមិនដឹងលទ្ធិរបស់ព្រះសមណគោតម ក៏អ្នកដែលដឹងលទ្ធិរបស់អ្នកដទៃ លើកវាទៈឡើង ជាការសម្គាល់ថា លើកឡើងល្អហើយ ចំណែកព្រះអស្សជិត្ថេរនេះប្រាកដជាសាវករបស់ព្រះសមណគោតម លោកជាអ្នកឆ្លាតក្នុងលទ្ធិរបស់សាស្តារបស់ខ្លួន យើងសួរលទ្ធិនោះហើយ ញ៉ាំងពាក្យឲ្យតាំងនៅ នឹងលើកវាទៈចំពោះព្រះសមណគោតម ដូច្នេះ ព្រោះដូច្នោះ ទើបចូលទៅរក ។ បទថា **វិនេតិ** សេចក្តីថា សច្ចកនិគ្រន្ថសួរថា ព្រះសមណគោតម ណែនាំយ៉ាងណា ឲ្យសិក្សាយ៉ាងណា ដូច្នេះ ។

ក៏ព្រោះកាលព្រះថេរៈពោលថា ជាទុក្ខ រមែងជាឱកាសនៃការជំទាស់ ក៏មគ្គផល មកហើយដោយបរិយាយថា ជាទុក្ខ កាលព្រះថេរៈពោលថា ទុក្ខ ដូច្នេះ សច្ចកនិគ្រន្ថនេះ គប្បីសួរព្រះថេរៈថា អស្សជិដ៏ចម្រើន លោកបួសដើម្បីអ្វី តពីនោះ ព្រះថេរៈឆ្លើយថា ដើម្បីមគ្គផល គប្បីលើកសេចក្តីខុសឡើងថា អស្សជិនេះ មិនមែនពាក្យទូន្មានរបស់លោកនោះ សេចក្តីអាឃាត

យ៉ាងខ្លាំង សេចក្ដីណែនតាន់តាប់ក្នុងនរកនោះ មិនមានដើម្បីសេចក្ដីសុខរបស់លោក លោកនឹងមករំភើបត្រាច់ធ្វើទុក្ខឲ្យវិនាស ឲ្យថយចុះ ដូច្នោះ មិនគួរធ្វើបរិយាយកថាដល់អ្នកដែលជាអ្នកឆ្លើយតប គិតថា គេនឹងតាំងនៅមិនបានយ៉ាងណា យើងនឹងពោលកថាដោយត្រង់ដល់គេ ដូច្នោះ ទើបលើកព្រះតម្រាស់នេះថា **រូបំ ភិក្ខវេ អនិច្ចំ** ជាដើម ដោយអំណាចអនិច្ចំ អនត្តា ។ បទថា **ទុស្សុតំ** គឺ មិនគួរស្ដាប់ ។

[៣៤] បទថា **សណ្ឋាគារេ** បានដល់ សាលា គឺ អាគារទីប្រជុំបង្រៀនអត្ថដល់រាជត្រកូល ។ បទថា **យេន តេ លិច្ឆវី តេនុបសង្កមិ** សេចក្ដីថា បានឮថា សច្ចកនិគ្រន្ថនោះ បានមានគំនិតយ៉ាងនេះថា យើងមិនលើកវាទៈចំពោះព្រះសមណគោតម ព្រោះមិនដឹងលទ្ធិក្នុងកាលមុន តែឥឡូវនេះ យើងដឹងលទ្ធិដែលព្រះមហាសាវករបស់សមណគោតមនោះ ពោលហើយ ក៏ឯលិច្ឆវី ៥០០ ទាំងនេះ ជាសិស្សយើង មកប្រជុំគ្នាហើយ យើងនឹងទៅព្រមនឹងលិច្ឆវីទាំងនោះ ហើយទើបលើកវាទៈឡើងចំពោះព្រះសមណគោតម ដូច្នេះ ព្រោះដូច្នោះទើបចូលទៅរក ។ បទថា **ញាតញ្ញតរេន** សេចក្ដីថា បណ្ដាព្រះបញ្ចវគ្គិយត្ថេរអ្នកមានឈ្មោះបោះសំឡេងទាំងនោះ អង្គណាមួយ ។ បទថា **បតិដ្ឋិតំ** សេចក្ដីថា ព្រះអស្សជិត្ថេរនោះ តាំងនៅយ៉ាងណា ព្រះសមណគោតមនឹងតាំងនៅ

ដូច្នោះ កាលបើដូច្នោះ គេនឹងពោលប្រការដទៃទៀត ។ ឥឡូវនេះ កាលនឹងបែរក្រោយត្រឡប់ ទើបទូលថា យើងនឹងធ្វើអ្វីក៏បាន ក្នុងទីនោះ ។ បទថា **អាក-ឌ្ឍេយ្យ** បានដល់ គប្បីទាញឲ្យបែរមុខមករកខ្លួន ។ បទថា **បរិកឌ្ឍេយ្យ** សេចក្ដីថា គប្បីទាញមកឲ្យមើលខាងមុខ ។ បទថា **សម្បរិកឌ្ឍេយ្យ** សេចក្ដីថា ទាញទៅមក ។ បទថា **សោណ្ឌិធុត្តោ** ប្រែថា អ្នកលេងសុរា ។ បទថា **ថាលំ កណ្ណេ គហេត្វា** សេចក្ដីថា អ្នកប្រាជ្ញនឹងលាងខ្វះ សម្រាប់បិតស្រា ចាប់ត្រង់ត្រចៀកទាំង ២ ហើយរលាស់កាកចោល ។ បទថា **ឱធុនេយ្យ** បានដល់ ផ្កាប់មុខ ។ បទថា **និទ្ធុមេយ្យ** បានដល់ ផ្ងារមុខឡើង ។ បទថា **និប្ផោដេយ្យ** បានដល់ គប្បីប៉ះទង្គិចរឿយៗ មនុស្សនាំយកសំបកឈើចងជាបាច់ៗ ត្រាំទឹកដើម្បីធ្វើសំពត់ឈើ ។ ក្នុងបទថា **សាណធោវិកំ នាម** នេះ ក្នុងថ្ងៃទី ៣ សំបកឈើទាំងនោះ ជារបស់សើមជោកល្អ ។ តមកពួកមនុស្សនាំយកទឹកក្រូច បបរ និងសុរាជាដើមទៅទីនោះ កាន់យកបាច់ឈើទៅដំលើបន្ទះក្ដា ៣ ដង ខាងស្ដាំ ខាងឆ្វេង ឬខាងមុខ គឺ លើបន្ទះក្ដាខាងស្ដាំម្ដង ខាងឆ្វេងម្ដង ខាងមុខម្ដង ស៊ីបណ្ដើរ ផឹកបណ្ដើរ ទំពារស៊ីបណ្ដើរ ទឹកក្រូច បបរ និងសុរាជាដើម នាំគ្នាលៀងសុរាជាដើម ជាកីឡាធំ ដ៏វិរបស់ព្រះរាជា ឃើញកីឡានោះហើយ ចុះទឹកជ្រៅ យកប្រមោយប៉ឺតទឹក ហើយសាចលេងលើក្បាលម្ដង លើខ្នងម្ដង ត្រង់

ពណ៌ខាងទាំងពីរម្ខាង លើចន្លោះខ្នងម្ខាង ព្រោះអាស្រ័យហេតុនោះ ការលេង កីឡានោះ ហៅឈ្មោះថា លេងបោកផ្ទៃ សច្ចកនិគ្រន្ថសំដៅយកការលេងនោះ ទើបពោលថា លេងកីឡាបោកផ្ទៃ ។

ក្នុងបទថា ***កឹ សោ ភវមានោ សច្ចកោ និគន្ថបុត្តោ យោ ភគវតោ វាទំ អារោបេស្សតិ*** នេះ មានអធិប្បាយថា សច្ចកនិគន្ថបុត្រនឹងតទល់វាទៈ នឹងព្រះមានព្រះភាគ សច្ចកនិគ្រន្ថនោះជាអ្វី ជាយក្ខ ឬជាព្រះឥន្ទ្រ ឬជាព្រះ ព្រហ្មដែលនឹងតទល់វាទៈនឹងព្រះមានព្រះភាគ ចំណែកមនុស្សតាមប្រក្រតីមិន អាចដើម្បីនឹងតទល់វាទៈនឹងព្រះមានព្រះភាគបាន ដូច្នេះ ។

[៣៥] បទថា ***តេន ខោ បន សមយេន*** សេចក្តីថា ក្នុងសម័យដែល សច្ចកៈចូលទៅកាន់អារាម ។ សួរថា ចូលទៅក្នុងសម័យណា ? ឆ្លើយថា ក្នុងសម័យថ្ងៃត្រង់ ។ សួរថា ព្រោះហេតុអ្វី ? ភិក្ខុទាំងឡាយទើបចង្ក្រមនៅ ក្នុងសម័យនោះ ។ ឆ្លើយថា ដើម្បីបន្ទោបង់ថីនមិទ្ធៈមានភោជនដែលប្រណីត ជាបច្ច័យ ។ មួយវិញទៀត ភិក្ខុទាំងនោះ ប្រកបសេចក្តីព្យាយាមក្នុងវេលាថ្ងៃ ។ កាលភិក្ខុនោះចង្ក្រម ផឹកទឹកខាងក្រោយអាហារ ឲ្យរាងកាយបានទទួលសេចក្តី សប្បាយហើយ អង្គុយបំពេញសមណធម៌ ចិត្តក៏មានអារម្មណ៍តែមួយ ។ បទ ថា ***យេន តេ ភិក្ខូ*** សេចក្តីថា បានឮថា សច្ចកនិគន្ថបុត្រនោះគិតថា ព្រះ-

សមណគោតមនៅទីណា ទើបដើរទៅជុំវិញគិតថានឹងសួរ ហើយចូលទៅ កាល
សម្លឹងមើលឃើញពួកភិក្ខុដែលកាន់សំពត់បង្សុកូលជាវត្ត ចង្រ្កមនៅលើទីចង្រ្កម
ធំ ដូចដីវាំព្រៃ ទើបបានទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ ។ ពាក្យមានជាដើមថា
**យេន តេ ភិក្ខូ** សច្ចកនិគន្ថបុត្រ ពោលសំដៅយកភិក្ខុនោះ ។ បទថា **កហំ
នុខោ ភោ** សេចក្តីថា ព្រះគោតមដ៏ចម្រើននោះ នៅក្នុងអាវាស ក្នុងល្អាង
ឬមណ្ឌបណា ។ បទថា **ឯស អគ្គិវេស្សន ភគវា** សេចក្តីថា បានឮថា ក្នុង
កាលនោះក្នុងវេលាជិតភ្លឺ ព្រះមានព្រះភាគ ទ្រង់ចូលមហាករុណាសមាបត្តិ
ទ្រង់ផ្សាយសំណាញ់ គឺ ព្រះសព្វញ្ញុតញ្ញាណទៅក្នុងម៉ឺនចក្រវាឡ កាលទ្រង់
ត្រួតមើលសត្វដែលគួរណែនាំឲ្យត្រាស់ដឹង ទ្រង់ឃើញថា ស្អែកនេះ សច្ចក-
និគន្ថបុត្រនាំស្តេចលិច្ឆវីជាបរិស័ទចំនួនច្រើន នឹងមកត.ទល់វាទ:ជាមួយតថាគត
ដូច្នេះ ។ ដូច្នោះ ទ្រង់ជម្រះព្រះវរកាយពីព្រឹកព្រលឹម មានភិក្ខុសង្ឃជាបរិវារ
ស្តេចត្រាច់បិណ្ឌបាតក្នុងក្រុងវេសាលី ស្តេចត្រឡប់ពីបិណ្ឌបាត ទ្រង់ត្រិះរិះថា
តថាគតនឹងអង្គុយក្នុងទីសប្បាយ ដើម្បីនឹងប្រថាប់ អង្គុយក្នុងបរិស័ទចំនួនច្រើន
ទើបស្តេចមិនចូលទៅក្នុងព្រះគន្ធកុដិ ប្រថាប់អង្គុយសម្រាកកណ្តាលថ្ងៃ ត្រង់
គល់ដើមឈើមួយកន្លែងក្នុងព្រៃមហាវ័ន ។ ភិក្ខុទាំងនោះមកសម្តែងវត្តចំពោះ
ព្រះមានព្រះភាគ ត្រូវសច្ចនិគ្រន្ថសួរ កាលនឹងសម្តែង ព្រះមានព្រះភាគប្រថាប់

អង្គុយហើយក្នុងទីឆ្ងាយ ទើបពោលថា **អគ្គិវេស្សនៈ** នុ៎ះ ព្រះមានព្រះភាគ ដូច្នេះ ។ បទថា **មហតិយា លិច្ឆវិបរិសាយ សទ្ធឹ** មានអធិប្បាយថា ស្តេចលិច្ឆវីប្រមាណ ៥០០ ហែហមខាងក្រោយ ។ ស្តេចលិច្ឆវីទាំងនោះ ជាកូនសិស្សរបស់សច្ចកៈនោះ ។ ចំណែកសច្ចកៈ ខាងក្នុងក្រុងវេសាលី នាំស្តេចលិច្ឆវីប្រមាណ ៥០០ ស្តាប់ហើយថា អ្នកត្រូវការនឹងតទល់វាទៈចូលទៅគាល់ព្រះមានព្រះភាគ ដូច្នេះ ដោយច្រើន ពួកមនុស្សនាំគ្នាចេញទៅដោយគិតថា យើងនឹងស្តាប់ការសន្ទនារបស់បណ្ឌិត ២ នាក់ ។ បរិស័ទមានចំនួនច្រើនយ៉ាងនេះ កំណត់រាប់មិនបានឡើយ ។ ពាក្យនោះ សច្ចកៈពោលហើយ សំដៅដល់បរិស័ទនុ៎ះ ។ បទថា **អញ្ជលឹ បណាមេត្វា** សេចក្តីថា ជនទាំងនោះមាន ២ ចំណែកពួកគេគិតយ៉ាងនេះថា បើពួកមិច្ឆាទិដ្ឋិជំទាស់នឹងយើងថា លោកសំពះព្រះសមណគោតមធ្វើអ្វី ពួកយើងនឹងប្រាប់ដល់គេទាំងនោះថា សំពះអ្វី ត្រឹមតែលើកដៃប្រណមប៉ុណ្ណោះ បើពួកជាសម្មាទិដ្ឋិជំទាស់នឹងយើងថា ហេតុអ្វីលោកមិនថ្វាយបង្គំព្រះមានព្រះភាគហ្ន៎ ពួកយើងនឹងប្រាប់ថា ហេតុអ្វី ការថ្វាយបង្គំនឹងចាំបាច់ត្រូវយកសិរសៈទល់ផែនដី ត្រឹមតែអញ្ជលីកម្ម ក៏ជាការថ្វាយបង្គំមិនមែនឬ ។ បទថា **នាមគោត្តំ** សេចក្តីថា ពួកខ្លះទូលថា ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះទត្តៈ ឈ្មោះមិត្តៈ ជាបុត្ររបស់អ្នកឯណោះ

មកក្នុងទីនេះហើយ ឈ្មោះថា ប្រកាសឈ្មោះ ។ ពួកខ្លះទូលថា ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថា វាសិដ្ឋៈ , ឈ្មោះថា កច្ចាយនៈ មកក្នុងទីនេះហើយ ឈ្មោះថា ប្រកាសគោត្រ ។ បានឮថា ជនក្រីក្រទាំងនោះ បានប្រកាសធ្វើយ៉ាងនោះ ដោយគិតថា យើងជាបុត្ររបស់ត្រកូលចាស់ នឹងប្រាកដឈ្មោះនិងគោត្រ ក្នុងកណ្ដាលបរិស័ទ ។ ចំណែកពួកណាអង្គុយស្ងៀម ពួកទាំងនោះជាមនុស្សស្រាហាវ និងអន្ធពាល ។ បណ្ដាជនទាំងនោះ មនុស្សស្រាហាវគិតថាមនុស្សអ្នកធ្វើការសន្ទនាគ្នាមួយម៉ាត់ ពីរម៉ាត់ ជាអ្នកជិតជិតគ្នា កាលសេចក្ដីជិតស្និទមានដូច្នោះ នឹងមិនថ្វាយភិក្ខាមួយ ឬពីរវែក មិនគួរ ដើម្បីនឹងឲ្យខ្លួនផុតពីសេចក្ដីជិតស្និទនោះ ទើបនាំគ្នាអង្គុយស្ងៀម ។ ពួកអន្ធពាល ជាអ្នកអង្គុយស្ងៀមក្នុងទីកន្លែងណាមួយ ព្រោះមិនដឹង ដូចដុំដីដែលត្រូវបោះទៅខាងក្រោម ។

[៣៦] បទថា **កិញ្ចិទេវ ទេសំ** សេចក្ដីថា ឱកាសណាមួយ ហេតុណាមួយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ឲ្យសច្ចកនិគ្រន្ថនោះ កើតសេចក្ដីឧស្សាហ៍ក្នុងការសួរបញ្ហា ទើបត្រាស់ថា អគ្គិវេស្សនៈ អ្នកប្រាថ្នានឹងសួរបញ្ហាណាក៏សួរចុះ ។ បទនោះ មានដើម្បីសេចក្ដីថា បើអ្នកប្រាថ្នានឹងសួរក៏សួរ ក្នុងការឆ្លើយបញ្ហាមិនជាការៈធ្ងន់សម្រាប់តថាគត ។ មយ៉ាងទៀត អ្នកប្រាថ្នាវត្ថុ

ណា ក៏ចូរសួរ តថាគតនឹងឆ្លើយវត្ថុទាំងអស់នោះដល់អ្នក ព្រោះដូច្នោះ ព្រះសមណគោតមបវារណាហើយ បវារណាព្រះសព្វញ្ញុតញ្ញាណ ដែលមិនទូទៅដល់ព្រះបច្ចេកពុទ្ធ អគ្គសាវក និងព្រះមហាសាវក ។ ក៏លោកទាំងនោះ មិនពោលថា បើលោកប្រាថ្នានឹងពោលថា ពួកយើងស្តាប់ហើយនឹងជ្រាប ដូច្នេះ ។ ចំណែកព្រះពុទ្ធទាំងឡាយ រមែងបវារណា បវារណាសព្វញ្ញុតញ្ញាណដល់យក្ខមនុស្សជាធំ ទេវ សមណព្រាហ្មណ៍ និងបរិព្វាជកប៉ុណ្ណោះថា ម្នាលអ្នកមានអាយុ បើអ្នកប្រាថ្នា ក៏ចូរសួរចុះ ឬថា ម្នាលមហារាជ បើព្រះអង្គមានព្រះរាជប្រាថ្នា ក៏ចូរសួរ ឬថា ម្នាលស្តេចវាសវៈ លោកទាក់ចិត្តបញ្ហាយ៉ាងណាមួយ ចូរសួរតថាគតចុះ តថាគតនឹងឆ្លើយបញ្ហានោះៗ ឲ្យដល់ទីបំផុតដល់លោក ឬថា ម្នាលភិក្ខុ បើយ៉ាងនោះ អ្នកអង្គុយលើអាសនៈរបស់ខ្លួនហើយ បើប្រាថ្នាក៏ចូរសួរចុះ ឬពួកអ្នកនៅមានចិត្តសង្ស័យយ៉ាងណាមួយ នឹងជាសេចក្តីសង្ស័យរបស់ព្រាហ្មណ៍ពាវរី និងរបស់អ្នក ឬរបស់ពួកជន តថាគតឲ្យឱកាសហើយចូរសួរចុះ ឬថា ម្នាលសភិយៈ អ្នកនៅទាក់ចិត្តបញ្ហាណាមួយ ចូរសួរតថាគត តថាគតនឹងឆ្លើយបញ្ហានោះៗ ឲ្យដល់ទីបំផុតដល់អ្នក សេចក្តីនោះមិនអស្ចារ្យព្រះមានព្រះភាគ ទ្រង់សម្រេចពុទ្ធភូមិយ៉ាងណា ទ្រង់បវារណាពុទ្ធភូមិនោះយ៉ាងនេះ អ្នកដែលតាំងនៅក្នុងប្រទេសញ្ញាណ ក្នុងភូមិព្រះពោធិសត្វ អ្នកដែល

ឥសីទាំងឡាយអាភពនាហើយ ដើម្បីប្រយោជន៍ដល់ស្តេចសក្កៈជា ដើមយ៉ាងនេះថា

កោណ្ឌញ្ញៈ អ្នកចូរឆ្លើយបញ្ហាទាំងឡាយ ពួកឥសីអ្នកមានសេចក្តីជីងល្អ រមែងសូមអង្វរអ្នកកោណ្ឌញ្ញៈ ធម៌ក្នុងពួកមនុស្សនេះ រមែងដល់សេចក្តីចម្រើន នោះជាភារៈ ។

គ្រាប់ទៅ ៣ ជង ក្នុងវេលាជាសរភង្គតាបស ក្នុងសម្ភវជាតក និងក្នុងជម្ពូទ្វីបយ៉ាងនេះថា

លោកដ៏ចម្រើនទាំងឡាយ បានឱកាសហើយ ចូរសួរបញ្ហាយ៉ាងណាមួយ ទាំងតាំងចិត្តទុក ក៏យើងដឹងលោកនេះ លោកខាងមុខដោយខ្លួនឯង នឹងឆ្លើយបញ្ហាឲ្យដល់ទីបំផុតដល់ពួកលោក ដូច្នេះ ។

មិនឃើញអ្នកធ្វើទីបំផុតនៃបញ្ហាទាំងឡាយ ត្រូវសុចិរកព្រាហ្មណ៍សួរបញ្ហា កាលឱកាសដែលព្រះអង្គធ្វើហើយក្នុងព្រះជន្ម ៧ វស្សាដោយកំណើតទ្រង់លេងធូលីត្រង់ផ្លូវ ទ្រង់អង្គុយចម្រើនសមាធិចន្លោះផ្លូវ ទ្រង់បវារណាបវារណាព្រះសព្វញ្ញុតញ្ញាណថា

អញ្ជើញចុះ យើងនឹងប្រាប់បញ្ហាដល់លោក នូវភាពដែលជា

អ្នកឆ្លាត មួយវិញទៀត ព្រះរាជាទ្រង់ជ្រាបប្រការនោះ ប្រសិន
បើទ្រង់នឹងធ្វើ ឬទ្រង់មិនធ្វើ ដូច្នេះ ។

កាលបវារណាព្រះសព្វញ្ញុតញ្ញាណ ដែលព្រះមានព្រះភាគទ្រង់បវា-
រណាយ៉ាងនេះ សច្ចកនិគ្រន្ថ មានចិត្តរីករាយ កាលទទួលសួរបញ្ហា ទើប
បានពោលពាក្យជាដើមថា **កថំ បន ភោ គោតម** ដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់ដល់សច្ចកនិគ្រន្ថនោះថា អ្នកដ៏ចម្រើន អ្នក
ឃើញសាវកពោលពាក្យដទៃ ព្រះសាស្តាត្រាស់ពាក្យដទៃ តថាគតពោលហើយ
មិនមែនឬថា សាវករបស់ព្រះសមណគោតមតាំងនៅហើយយ៉ាងណា ព្រះសមណ-
គោតមនឹងតាំងនៅដូច្នោះ តថាគតក៏លើកវាទៈយ៉ាងនោះ កាលនឹងត្រាស់ដោយ
ការកំណត់ ដែលព្រះអស្សជិត្ថេរពោលហើយក្នុងកាលមុនថា ឱកាសនៃពាក្យ
របស់និគ្រន្ថ ចូរកុំមានយ៉ាងនេះថា ក៏និគ្រន្ថនេះ រមែងពោលពាក្យដទៃ យើង
អាចនឹងធ្វើអ្វីក៏បានក្នុងទីនោះបាន ទើបត្រាស់ពាក្យជាដើមថា **ឯវំ ខោ អហំ
អគ្គិវេស្សន** ដូច្នេះ ។ បទថា **ឧបមា មំ ភោ គោតម បដិភាតិ** សច្ចកនិគ្រន្ថ
ពោលថា ព្រះគោតមដ៏ចម្រើន ឧបមាប្រការមួយ រមែងប្រាកដដល់ខ្ញុំព្រះអង្គ
ខ្ញុំព្រះអង្គនឹងនាំឧបមានោះមក ។ បទថា **បដិភាតុ តំ អគ្គិវេស្សន** ព្រះមាន-
ព្រះភាគបានត្រាស់ថា អគ្គិវេស្សនៈ ឧបមាចូរប្រាកដដល់អ្នក គឺថា សច្ចក-

និគ្រន្ថជិតជិតហើយ ចូរនាំឧបមានោះមក ។ បទថា **ពលករណីយា** សេចក្ដីថា ការងារមានកសិកម្ម និងពាណិជ្ជកម្ម ត្រូវធ្វើដោយកម្លាំងដៃ ។ បទថា **រូបត្តាយំ បុរិសបុគ្គលោ** សេចក្ដីថា ឈ្មោះថា **រូបត្តា** ព្រោះអត្ថថា គេមានរូបជាខ្លួន លោកសម្ដែងបុគ្គលដែលប្រកាន់ថា រូបជាខ្លួន ។ បទថា **រូបេ បតិដ្ឋាយ** សេចក្ដីថា តាំងនៅក្នុងរូបដែលប្រកាន់ថា ខ្លួននៅក្នុងរូបនោះ ។

បទថា **បុញ្ញំ វា អបុញ្ញំ វា បសវតិ** គឺ រមែងបានកុសល ឬអកុសល សូម្បីបទមានវេទនាជាខ្លួនជាដើម ក៏មានន័យនេះឯង ។

បទនេះ លោកសម្ដែងទុកយ៉ាងណា ? លោកនាំឧបមាព្រមទាំងហេតុដែលគួរស្ដាប់ថា បញ្ចក្ខន្ធទាំងនេះ ជាទីនៅអាស្រ័យ ដូចផែនដីជាទីនៅអាស្រ័យរបស់ពួកសត្វទាំងនេះ សត្វទាំងនោះតាំងនៅក្នុងបញ្ចក្ខន្ធទាំងនេះ រមែងរួបរួមយកកុសលកម្ម និងអកុសលកម្មទុក លោកកាលបដិសេធខ្លួនដែលមានសភាពបែបនេះ សម្ដែងថា បញ្ចក្ខន្ធមិនមែនខ្លួន ដូច្នេះ ។ ក៏ឧបមាដែលនិគ្រន្ថនាំមកប្រៀបផ្ទឹមពិតប្រាកដហើយ មិនមានអ្នកដទៃក្រៅពីព្រះសព្វញ្ញុពុទ្ធ ដែលឈ្មោះថា អាចកាត់ពាក្យរបស់និគ្រន្ថនោះ ហើយឲ្យទោសក្នុងវាទៈបាន ពិតហើយបុគ្គលមាន ២ ចំពួក គឺ ពុទ្ធវេនេយ្យ ១ សាវកវេនេយ្យ ១ ។ ក្នុងសាវកវេនេយ្យ ព្រះសាវកណែនាំខ្លះ ព្រះពុទ្ធទ្រង់ណែនាំខ្លះ ចំណែកក្នុងពុទ្ធវេនេយ្យ

ព្រះសាវកមិនអាចណែនាំ ព្រះពុទ្ធប៉ុណ្ណោះទ្រង់ណែនាំបាន និគ្រន្ថម្នាក់នេះ ជាពុទ្ធវេនេយ្យ ព្រោះដូច្នោះ មិនមានអ្នកដទៃដែលឈ្មោះថា អាចកាត់ពាក្យរបស់និគ្រន្ថនោះ ហើយឲ្យទោសក្នុងវាទៈបាន ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងទោសក្នុងវាទៈរបស់សច្ចកនិគ្រន្ថនោះដោយព្រះអង្គឯង ទើបត្រាស់ថា **ននុ ត្វំ អគ្គិវេស្សន** ដូច្នេះ ។

លំដាប់នោះ និគ្រន្ថគិតថា ព្រះសមណគោតម ទ្រង់ញាំញីវាទៈរបស់យើងក្រៃលែងណាស់ បើទោសយ៉ាងណាមួយនឹងមានក្នុងខាងលើ ព្រះអង្គនឹងគ្របសង្កត់តែយើងម្នាក់ ណ្ហើយចុះ យើងនឹងបោះវាទៈនេះទៅលើសីរសៈមហាជន ព្រោះដូច្នោះ ទើបពោលថា ព្រះគោតមដ៏ចម្រើន ខ្ញុំពោលហើយយ៉ាងនេះថា រូបជាខ្លួនរបស់យើង ។បេ។ វិញ្ញាណជាខ្លួនរបស់យើង ប្រជុំជនជាច្រើនក៏ពោលយ៉ាងនោះ ។

ចំណែកព្រះមានព្រះភាគ ទ្រង់មានវាទៈល្អជាងនិគ្រន្ថ ដោយគុណទាំងរយ ទាំងពាន់ ទាំងសែន ព្រោះដូច្នោះ ទើបទ្រង់ត្រិះរិះថា និគ្រន្ថបង់ឲ្យខ្លួនរួចផុត ទើបបោះវាទៈទៅលើសីរសៈមហាជន តថាគតនឹងមិនឲ្យគេរួចខ្លួនទៅបាន តថាគតនឹងដោះវាទៈចេញពីមហាជន ហើយគ្របសង្កត់តែគេម្នាក់ លំដាប់នោះទើបត្រាស់ចំពោះនិគ្រន្ថថា **កឹ ហិ តេ អគ្គិវេស្សន** ដូច្នេះជាដើម ។ បទនោះ

មានអធិប្បាយថា ប្រជុំជននេះ មិនមកតទល់វាទៈនឹងតថាគត អ្នកប៉ុណ្ណោះ ខ្វល់ខ្វាយពេញទាំងក្រុងវេសាលី មកតទល់វាទៈនឹងតថាគត ព្រោះដូច្នោះ អ្នកចូរប្រកាសវាទៈរបស់ខ្លួនឲ្យគ្រប់គ្នាដឹង អ្នកបោះអ្វីទៅលើសីរសៈមហាជន ។ និគ្រន្ថនោះ កាលទទួលសេចក្តីពិត ទើបក្រាបទូលថា ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គពោលយ៉ាងនោះពិត ដូច្នេះជាដើម ។

[៣៧] ព្រះមានព្រះភាគ ទ្រង់ញាំញីនូវវាទៈរបស់និគ្រន្ថ ទ្រង់ប្រារព្ធពាក្យសួរថា **តេនហិ អគ្គិវេស្សន** ដោយប្រការដូច្នេះឯង ។

បណ្តាបទទាំងនោះ បទថា **តេនហិ** ជានិបាត ចុះក្នុងអត្ថថា ហេតុ ព្រោះអ្នករមែងយល់បញ្ចក្ខន្ធ ថាជាខ្លួន ដូច្នោះ ។ បទថា **សកស្មឹ វិជិតេ** គឺ ក្នុងព្រំដែនរបស់ព្រះអង្គ ។ បទថា **ឃាតេតាយំ វា ឃាតេតុំ** បានដល់ ដើម្បីឲ្យសម្លាប់អ្នកដែលគួរសម្លាប់ គឺ អ្នកសមគួរត្រូវសម្លាប់ ។

បទថា **ជាបេតាយំ វា ជាបេតុំ** សេចក្តីថា ដើម្បីរឹបក្នុងទីគួររឹប គឺ អ្នកដែលគួរត្រូវរឹបយក បានដល់ ដើម្បីឲ្យវិនាសទ្រព្យ ។

បទថា **បព្វាជេតាយំ វា បព្វាជេតុំ** សេចក្តីថា ដើម្បីនិរទេស គឺ នាំអ្នកដែលគួរនិរទេសចេញទៅអំពីព្រំដែនរបស់ព្រះអង្គ ។ បទថា **វត្តិតុញ្ច អរហតិ** លោកសម្តែងថា រមែងប្រព្រឹត្តទៅ គឺ គួរដើម្បីប្រព្រឹត្តទៅ និគ្រន្ថ

សម្តែងហេតុដែលនាំមក ដើម្បីទម្លាយវាទៈរបស់ខ្លួនឯងឲ្យពិសេស ដូចអ្នកធ្វើអាវុធឲ្យមុតដើម្បីសម្លាប់មនុស្សដូចជាជនពាល ។ បទថា **ឯវំ មេ រូបំ ហោតុ** សេចក្តីថា សូមរូបរបស់យើងចូរមានយ៉ាងនេះ គឺ មានរូបគួរជ្រះថ្លា មានរូបស្អាត ឃើញក៏ពេញចិត្ត ដូចសសរខឿនមាស ដែលប្រដាប់ហើយ គាក់តែងហើយ និងសំពត់វិចិត្រ ដែលចាត់ចែងទុកយ៉ាងល្អ ។ បទថា **ឯវំ មេ រូបំ មា អហោសិ** សេចក្តីថា សូមរូបរបស់យើងចូរកុំមានយ៉ាងនេះ គឺ ពណ៌សម្បុរអាក្រក់ ទ្រង់ទ្រាយមិនល្អ ស្បែកជ្រួញ សក់ស្កូវ ខ្លួនរឹងគគ្រើម ។ បទថា **តុណ្ហី អហោសិ** សេចក្តីថា និគ្រន្ថដឹងសេចក្តីដែលខ្លួនភ្លាត់ក្នុងវាទៈនេះ ទើបគិតថា ព្រះសមណគោតមនាំហេតុមកដើម្បីត្រូវការទម្លាយវាទៈរបស់យើង យើងសម្តែងហេតុនោះភ្លាត់ទៅព្រោះល្ងង់ បើនឹងនិយាយថា ប្រព្រឹត្តទៅដូច្នេះ គ្រានេះយើងវិនាសហើយ អគ្គិវេស្សនៈលោកបានក្រោកឡើងពោលនឹងស្តេចទាំងនេះថា អំណាច រមែងប្រព្រឹត្តទៅក្នុងរូបរបស់យើង បើអំណាចប្រព្រឹត្តទៅក្នុងរូបរបស់លោក ព្រោះហេតុអ្វី លោកទើបមិនរុងរឿង ដូចស្តេចលិច្ឆវីទាំងនេះ មានរូបស្អាត គួរជ្រះថ្លា រមែងរុងរឿងដោយអត្តភាពដូចទេវតាជាន់តាវត្តឹង្ស បើយើងនឹងពោលថា ប្រព្រឹត្តទៅមិនបាន ព្រះសមណគោតមស្តេចក្រោកឡើងលើកវាទៈថា អគ្គិវេស្សនៈ ក្នុងកាលមុនអ្នកពោលថា អំណាច

ប្រព្រឹត្តទៅក្នុងរូបរបស់ខ្លួន មកថ្ងៃនេះក៏ប្រែជាជំទាស់វិញ កាលគេពោលថា ប្រព្រឹត្តទៅក៏មានទោសម្យ៉ាង ពោលប្រព្រឹត្តទៅមិនបាន ក៏មានទោសម្យ៉ាង ដោយប្រការដូច្នេះ ក៏អង្គុយនៅស្ងៀម ដូច្នេះឯង ។ ព្រះមានព្រះភាគ ត្រាស់សួរជាលើកទីពីរ សច្ចកនិគ្រន្ថក៏អង្គុយនៅស្ងៀម ទាំងពីរលើក ។ ក៏សិរសៈរបស់អ្នកមិនឆ្លើយ កាលបញ្ហាដែលព្រះមានព្រះភាគត្រាស់សួរហើយដល់បីដងរមែងបែកជា ៧ ចំណែក ។ ក៏ធម្មតាថា ព្រះពុទ្ធទាំងឡាយ មានសេចក្តីករុណាជាកម្លាំងក្នុងពួកសត្វ ព្រោះបំពេញព្រះបារមីរហូតអស់ ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប ដើម្បីប្រយោជន៍ដល់ពួកសត្វទាំងនោះ ដូច្នោះ ត្រាស់សួរដោយបដល់ពីរដងហើយ ទើបបានត្រាស់ពាក្យជាដើមថា គ្រានោះឯង ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះ ចំពោះសច្ចកនិគ្រន្ថបុត្រថា ថ្ងៃនេះអ្នកចូរឆ្លើយប្រាប់ ដូច្នេះជាដើម ។

ក្នុងបទនោះ បទថា **សហធម្មិកំ** គឺ មានហេតុ មានផល ។ ឈ្មោះថា **វជិរបាណី** ព្រោះអត្ថថា មានវជិរៈក្នុងបាតដៃ បទថា **យក្ខោ** សេចក្តីថា គប្បីជ្រាបថា អ្នកនោះមិនមែនយក្ខ ជាស្តេចសក្កទេវរាជ ។ បទថា **អាទិត្តំ** គឺ មានពណ៌ដូចភ្លើង ។ បទថា **សម្បជ្ជលិតំ** គឺ ឆេះសន្ធោសន្ធៅដោយល្អ ។

បទថា **សំជោតិភូតំ** គឺ ភ្លឺសព្វអន្លើ អធិប្បាយថា ជាអណ្តាតភ្លើង

តែម្យ៉ាង ។ បទថា **ឋិតោ ហោតិ** សេចក្តីថា យក្ខនិម្មិតឈរឯរូបគួរខ្លាចបែប
នេះ គឺ សិរសៈធំ ចង្កូមដូចជាត្រយូងចេក ភ្នែក និងច្រមុះជាដើមគួរខ្លាច ។
សួរថា ក៏ព្រោះហេតុអ្វី យក្ខនោះទើបមក ។ ឆ្លើយថា មកដើម្បីឲ្យនិគ្រន្ថ
ឆ្លើយ តាមសេចក្តីយល់ឃើញ ។ ម្យ៉ាងទៀត ស្តេចសក្កៈ និងស្តេចមហា-
ព្រហ្មស្តេចមកហើយ កាលព្រះមានព្រះភាគ ដល់សេចក្តីខ្វល់ខ្វាយតិច ក្នុង
ការសម្តែងធម៌ យ៉ាងនេះថា តថាគតគប្បីសម្តែងធម៌ ពួកអ្នកដទៃក៏គប្បីដឹង
ទូទៅដល់ធម៌របស់តថាគតមិនបាន ទ្រង់បានធ្វើបដិញ្ញាថា បពិត្រព្រះមាន-
ព្រះភាគ សូមព្រះអង្គចូរទ្រង់សម្តែងធម៌ចុះ កាលអាណាចក្រមិនប្រព្រឹត្តទៅ
ចំពោះព្រះអង្គ ប្រព្រឹត្តទៅដល់ខ្ញុំព្រះអង្គ ពួកខ្ញុំព្រះអង្គនឹងឲ្យប្រព្រឹត្តទៅ
ធម្មចក្រចូរជារបស់ព្រះអង្គ អាណាចក្រជារបស់ខ្ញុំព្រះអង្គ ដូច្នេះ ។ ព្រោះ
ដូច្នោះ ស្តេចមកហើយដោយទ្រង់ត្រិះរិះថា ក្នុងថ្ងៃនេះ យើងនឹងឲ្យសច្ចកនិគ្រន្ថ
ភ័យខ្លាច ហើយឲ្យឆ្លើយបញ្ហា ដូច្នេះ ។ បទថា **ព្រះមានព្រះភាគ និងសច្ចក-
និគន្ថបុត្រប៉ុណ្ណោះ បានឃើញ** សេចក្តីថា បើបុគ្គលពួកដទៃគប្បីឃើញហេតុ
នោះ ហេតុនោះក៏មិនគប្បីធ្ងន់ ។ ជនទាំងឡាយ គប្បីនិយាយថា ព្រះសមណ-
គោតមទ្រង់ដឹងហើយ ដែលសច្ចកនិគ្រន្ថមិនជាក់ចុះក្នុងវាទៈរបស់ខ្លួន ទ្រង់ប្រើ
យក្ខឲ្យនាំមកសម្តែង អំពីនោះសច្ចកនិគ្រន្ថនឹងក្រាបទូល ព្រោះខ្លាច ដូច្នេះ ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ និងសច្ចកនិគ្រន្ថប៉ុណ្ណោះ បានឃើញ ។ ព្រោះឃើញយក្ខនោះ ញើសក៏ហូរពេញទាំងខ្លួនរបស់សច្ចកនិគ្រន្ថនោះ ខាងក្នុងពោះរំជើបរំជួលយ៉ាងខ្លាំង គេគិតថា បុគ្គលពួកដទៃឃើញឬទេហ្ន៎ កាលក្រឡេកមើល ក៏មិនឃើញអ្នកណាស្ទូមស្ទើរព្រឺរោម តពីនោះសេចក្តីខ្លាចនេះ កើតដល់យើងប៉ុណ្ណោះ ទើបគិតថា បើយើងនឹងពោលថា យក្ខ ពួកមហាជនគប្បីនិយាយថា មានតែក្អែករបស់លោកនោះឬ លោកប៉ុណ្ណោះឬឃើញយក្ខ លោកមិនឃើញយក្ខ មុនត្រូវព្រះសមណគោតមបោះទៅក្នុងការបន្តនៃវាទៈ ទើបឃើញយក្ខ សម្គាល់ថា ឥឡូវនេះក្នុងទីនេះ យើងមិនមានទីពឹងដទៃក្រៅពីព្រះសមណ-គោតម គ្រានោះឯងសច្ចកនិគន្ថបុត្រ ។បេ។ ទើបបានក្រាបទូលពាក្យនោះព្រះមានព្រះភាគ ។ បទថា ***តាណំ គវេសី*** គឺ ស្វែងរកទីពឹង ។ បទថា ***លេណំ គវេសី*** គឺ ស្វែងរកទីការពារ ។ បទថា ***សរណំ គវេសី*** គឺ ស្វែងរកទីរលឹក ។ ក៏ក្នុងបទនេះ ឈ្មោះថា ***តាណា*** ព្រោះអត្ថថា ***ទីពឹង*** គឺ រក្សា ។ ឈ្មោះថា ***លេណា*** ព្រោះអត្ថថា ជាទីបិទបាំងនៃជន ។ ឈ្មោះថា ***សរណា*** ព្រោះអត្ថថា រលឹកបាន អធិប្បាយថា រមែងបៀតបៀន គឺ កម្ចាត់សេចក្តីខ្លាច ។

[៣៨] បទថា ***មនសិករិត្វា*** សេចក្តីថា ធ្វើទុកក្នុងចិត្ត គឺ ពិនិត្យពិចារណា ។ បទថា ***ឯវំ មេ វេទនា ហោតុ*** គឺ សូមវេទនាជាកុសល ជា

សុខ ។ បទថា **ឯវំ មេ សញ្ញា ហោតុ** គឺ សូមសញ្ញាជាកុសល ជាសុខ គឺ ចូរប្រកបដោយសោមនស្ស ។ សូម្បីក្នុងសង្ខារ និងវិញ្ញាណ ក៏មានន័យនេះឯង ។ ចំណែកក្នុងបទថា **មា អហោសិ** នេះ គប្បីជ្រាបដោយពោលផ្ទុយគ្នា ។

បទថា **កល្លំ នុ** ប្រែថា សមគួរឬហ្ន៎ ។ បទថា **សមនុបស្សិតុំ** សេចក្តីថា ពិចារណាឃើញដោយតណ្ហា មានះ ទិដ្ឋិ យ៉ាងនេះថា នុ៎ះរបស់យើង នុ៎ះជាយើង នុ៎ះជាខ្លួនរបស់យើង ។ បទថា **នោ ហេតំ ភោ គោតម** បានដល់សេចក្តីនោះ មិនគួរដល់ព្រះសមណគោតមដ៏ចម្រើន ។

គ្រូពស់អ្នកឆ្លាត ឲ្យពស់នោះខាំហើយ ដកពិសដែលត្រូវពស់ខាំ យ៉ាងណា ព្រះមានព្រះភាគទ្រង់ឲ្យសច្ចកនិគន្ថបុត្រពោលក្នុងបរិស័ទនោះ ដោយមាត់នោះឯងថា ខន្ធ ៥ មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នោះ ដោយប្រការដូច្នេះ ។ បទថា **ទុក្ខំ អល្លីនោ** សេចក្តីថា ជាប់ គឺ ចូលដល់ទុក្ខក្នុងបញ្ចក្ខន្ធនេះដោយតណ្ហា និងទិដ្ឋិ ។ បទថា **អជ្ឈោសិតោ** សេចក្តីថា គប្បីជ្រាបដោយអំណាចតណ្ហា និងទិដ្ឋិប៉ុណ្ណោះ ។ ក្នុងបទជាដើមថា **ទុក្ខំ ឯតំ មម** មានអធិប្បាយថា រមែងពិចារណាឃើញទុក្ខក្នុងបញ្ចក្ខន្ធ ដោយអំណាចតណ្ហា មានះ និងទិដ្ឋិ ។ បទថា **បរិជានេយ្យ** សេចក្តីថា គប្បីកំណត់ដឹងដោយតីរណ-បរិញ្ញាថា មិនទៀង ជាទុក្ខ ជាអនត្តា បទថា **បរិក្ខេបេត្វា** សេចក្តីថា នាំការ

អស់ សេចក្ដីសាបសូន្យ មិនឲ្យកើត ។

[៣៩] បទថា **នវំ** ប្រែថា ជំទង់ ។ បទថា **អកុក្កុជជាតំ** សេចក្ដីថា ស្នូលស្នូងមួយ ប្រមាណមួយធ្នាប់ រមែងកើតក្នុងខាងក្នុង វេលាចេញត្រយូង អធិប្បាយថា វៀរស្នូលស្នូងនោះចេញ ។ បទថា **រិត្តោ** គឺ ទទេ គឺ វៀរចាក ខ្លឹមខាងក្នុង ឈ្មោះថា ទទេ ព្រោះសោះសូន្យទទេ ។ បទថា **អបរទ្ធោ** គឺ ចាលចាញ់ ។ ព្រះមានព្រះភាគ ទ្រង់ប្រកាសសេចក្ដីដែលសច្ចកនិគន្ថបុត្រ នោះមានមាត់រឹង កាលនឹងទ្រង់គ្របសង្កត់ ទើបត្រាស់ព្រះតម្រាស់នេះថា **ភាសិតា ខោបន តេ** ដូច្នេះ ។ បានឮថា កាលមុនសច្ចកនិគ្រន្ថនោះចូលទៅ រកគ្រូទាំង ៦ មានបូរណៈ ជាដើម រមែងសួរបញ្ហា ។ ពួកគ្រូទាំងនោះ មិន អាចនឹងឆ្លើយបាន ។ គ្រានោះ គេលើកទោសធំត្រង់កណ្ដាលបរិស័ទនៃគ្រូ ទាំងនោះ ហើយក្រោកចេញទៅប្រកាសការឈ្នះ ចូលទៅដោយសេចក្ដីសម្គាល់ ថា យើងនឹងបៀតបៀន សូម្បីព្រះសម្មាសម្ពុទ្ធយ៉ាងនោះ ប្រកាសថា កំពូល ផ្សាយទៅដោយការប្រហារគ្រាតែមួយ ក្នុងដើមឈើឈ្មោះអ្វី ដែលដាច់ស្លឹក មានតែបន្ទា សច្ចកនិគន្ថបុត្រនេះ ទល់នឹងសារៈ គឺ សព្វញ្ញុតញ្ញាណ សម្រេច ប្រភេទ គឺ ព្រះញាណ ទើបបានដឹងសេចក្ដីដែលព្រះសព្វញ្ញុតញ្ញាណរឹងមាំ ដូចសត្វមានចំពុះទន់ ធ្លាប់ចោះឈើដែលមិនមានខ្លឹម ក៏ចោះឈើចូលបាន ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្តីនោះ ត្រង់កណ្តាលបរិស័ទរបស់សច្ចកនិគ្រន្ថនោះ ទើបត្រាស់ពាក្យជាដើមថា **ភាសិតា ខោ បន តេ** ដូច្នេះ ។ ក្នុងបទថា **នត្ថិ ឯតរហិ** នេះ មិនគួរពោលថា ឈ្មោះថា ញើសក្នុងឧបាទិន្នកសន្តានទើងមិនមាន គេនឹងពោលថា ក៏ក្នុងពេលឥឡូវនេះ មិនមាន ។ បទថា **សុវណ្ណវណ្ណំ កាយំ វិវរិ** គឺ ព្រះមានព្រះភាគ ទ្រង់មិនបើកព្រះកាយទាំងអស់ ។ ធម្មតាព្រះពុទ្ធ ពាក់ក្តុំ ទ្រង់បិទព្រះកាយ ទ្រង់សម្តែងធម៌នៅក្នុងបរិស័ទ ។ គ្រានោះព្រះមានព្រះភាគ ទ្រង់ចាប់ (ផ្នត់) ចីវរ ត្រង់បំពង់ព្រះសូរង់ខាងមុខទម្លាក់ចុះត្រឹម ៤ ធ្នាប់ កាលចីវរនោះធ្លាក់ចុះហើយ រស្មីមានពណ៌ដូចមាសជាក្រុមៗ ភ្លឺជះចេញមក ដូចរសធាតុមាសក្រហម ហូរចេញពីផ្ទាំងមាស និងដូចផ្លេកបន្ទោពណ៌ក្រហម ចេញចាកផ្ទៃពពក ធ្វើចីវរមហាខន្ធដូចជាស្គរមាស ឲ្យជាប្រទក្សិណ ស្ទុះទៅក្នុងអាកាស ។ សួរថា ក៏ព្រោះហេតុអ្វីទើបព្រះមានព្រះភាគ ទ្រង់ធ្វើយ៉ាងនេះ ។ ឆ្លើយថា ដើម្បីបន្ទោបង់សេចក្តីសង្ស័យរបស់មហាជន ។ ក៏មហាជនគប្បីសង្ស័យថា ព្រះសមណគោតមត្រាស់ថា ញើសរបស់តថាគតមិនមាន ។ ញើសរបស់សច្ចកនិគន្ថបុត្រ ហូរហៀត ដូចញើសរបស់អ្នកឡើងគ្រឿងយន្ត ព្រះសមណគោតមគង់ប្រថាប់ដណ្តប់សំពត់ចីវរក្រាស់ អ្នកណានឹងដឹងបានយ៉ាងណាថា ញើសខាងក្នុងនឹងមាន ឬមិន

មាន ដូច្នេះ ទើបទ្រង់ធ្វើយ៉ាងនោះ ដើម្បីបន្ទោបង់សេចក្តីសង្ស័យរបស់មហាជននោះ ។ បទថា **មង្កុភូតោ** គឺ អស់អំណាច ។ បទថា **បត្តក្ខន្ធោ** គឺ ជាក់ក សំយុង ។ បទថា **អប្បដិភាណោ** គឺ មិនជួបវត្ថុដ៏ក្រៃលែងជាង ។ បទថា **និសីទិ** គឺ អង្គុយយក ម្រាមជើងកូតផែនដី ។

[៤០] បទថា **ទុម្មុខោ** សេចក្តីថា មានមុខមិនគួរស្អប់ ពិតហើយ បុត្រលិច្ឆវីនោះ មានរូបស្អាត គួរជ្រះថ្លា ក៏ឈ្មោះរបស់គេយ៉ាងនោះ ។ បទថា **អកត្វា តំ បោក្ខរណឹ បុន ឱតរិតុំ** លោកសម្តែងថា ក្តាម ឈ្មោះថា ដើរមិនបាន ព្រោះកាច់ដង្កៀបបាក់អស់ មិនអាចចុះកាន់ស្រះបោក្ខរណីនោះបាន ទើបជាចំណីរបស់ក្អែក និងសត្វស្មាំងជាដើមក្នុងទីនោះឯង ។ បទថា **វិសូកាយិកានិ** គឺ ទិដ្ឋិដែលជាចម្រូងបន្លា ។ បទថា **វិសេវិតានិ** គឺ ប្រព្រឹត្តដោយទិដ្ឋិ ។ បទថា **វិប្ផន្ទិតានិ** គឺ សេចក្តីក្តៅក្រហាយដោយទិដ្ឋិ ។ បទថា **យទិទំ** ក្នុងបទថា **យទិទំ វាទាធិប្បាយោ** នេះ ត្រឹមតែជានិបាត ។ លោកសម្តែងថា ជាការបង្អួលបង្ហាញវាទៈ មិនគួរចូលទៅគាល់តាមអធ្យាស្រ័យថា យើងនឹងតទល់វាទៈ តែគួរចូលទៅគាល់ដើម្បីស្តាប់ធម៌ ។ សួរថា បទថា **ទុម្មុខំ លិច្ឆវិបុត្តំ ឯតទវោច** សច្ចកនិគន្ថបុត្របានពោលហើយ ព្រោះហេតុអ្វី ឆ្លើយថា បានឮថា ក្នុងវេលាបុត្រលិច្ឆវីឈ្មោះទុម្មុខនោះ នាំយកឧបមាមក សូម្បីលិច្ឆវីកុមារដ៏សេស

គិតហើយថា និគ្រន្ថនេះធ្វើការមើលងាយពួកយើងក្នុងកន្លែងរៀនសិល្បៈរបស់ពួកយើងមកយូរហើយ ឥឡូវនេះដល់វេលាដែលនឹងឃើញខ្នងសត្រូវ សូម្បីយើងនាំឧបមាប្រការមួយមក ម្នាក់មួយៗ នឹងធ្វើសច្ចកនិគ្រន្ថនោះ ឲ្យធ្លាក់ទៅដោយទះបាតដៃ ដូចវាយដំដោយអន្ទូង ដោយប្រការដែលសច្ចកនិគ្រន្ថ នឹងមិនអាចងើបសិរសៈឡើងក្នុងកណ្ដាលបរិស័ទបានទៀត ។ លិច្ឆវីទាំងនោះធ្វើឧបមាទាំងឡាយហើយ អង្គុយចាំទុម្ពុខៈនិយាយចប់ ។ សច្ចកនិគ្រន្ថដឹងសេចក្ដីប្រាថ្នារបស់លិច្ឆវីទាំងនោះ ទើបគិតថា លិច្ឆវីទាំងអស់នេះ មានមាត់រឹង បើពួកលច្ឆវីនឹងបាននាំឧបមាមកតែម្យ៉ាង យើងនឹងមិនអាចងើយក្បាលឡើងត្រង់កណ្ដាលបរិស័ទទៀតឬ ចុះយើងរុករកទុម្មុខៈហើយ កាត់វារៈនៃពាក្យដោយប្រការដែលអ្នកដទៃមិនមានឱកាស នឹងទូលសួរបញ្ហាចំពោះព្រះ-សមណគោតម ព្រោះដូច្នោះ ទើបបានពោលពាក្យនោះ ។ ក្នុងបទទាំងនោះបទថា **អាគមេហិ** ប្រែថា ឈប់ចុះ អធិប្បាយថា កុំកាន់យកទៀត ។ បទថា **តិដ្ឋតេសា ភោ គោតម** សេចក្ដីថា ព្រះគោតមដ៏ចម្រើន វាចារបស់ខ្ញុំព្រះអង្គនេះ នឹងរបស់សមណព្រាហ្មណ៍ជាច្រើនពួកដទៃ ចូរលើកទុកចុះ ។ បទថា **វិលាបំ វិលបិតំ មញ្ញេ** សេចក្ដីថា ពាក្យនេះដូចជារអ៊ូរៀបរាប់ អធិប្បាយថា ត្រឹមតែជាពាក្យនិយាយរអ៊ូរទាំ ។ ម្យ៉ាងទៀត គួរនាំបទថា កថាមកពោលក្នុង

បទនេះថា **តិដ្ឋតេសា** ។ ចំណែកក្នុងបទថា **វាចាវិលាបំ វិលបិតំ មាញ្ញេ** នេះ មានអធិប្បាយថា ការបញ្ចេញវាចានេះ ត្រឹមតែជាការនិយាយទៅទេ ។

[៤១] ឥឡូវនេះ សច្ចកនិគន្ថបុត្រ កាលទូលសួរបញ្ហា ទើបពោលពាក្យជាដើមថា **កិត្តាវតា** ។ បណ្តាបទទាំងនោះ បទថា **វេសារជ្ជប្បត្តោ** គឺ សម្រេចញាណ ។

បទថា **អបរប្បច្ចយោ** គឺ មិនត្រូវជឿអ្នកដទៃ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ឆ្លើយបញ្ហាដល់សច្ចកនិគន្ថបុត្រនោះ ទើបត្រាស់ពាក្យជាដើមថា **ឥធ អគ្គិវេស្សន** ដូច្នេះ ។ ពាក្យនោះ មានសេចក្តីងាយទាំងនោះ ។

ក៏ព្រោះសេក្ខភូមិទ្រង់សម្តែងហើយ ព្រោះត្រាស់ថា **បស្សតិ** ក្នុងបទនេះ ដូច្នោះ កាលទូលសេក្ខភូមិឲ្យក្រៃលែងឡើងទៅ ទើបទូលសួរបញ្ហាទីពីរទៀត ។ ព្រះមានព្រះភាគ ទ្រង់ឆ្លើយប្រាប់បញ្ហាសួរនោះដល់គេ ។ បណ្តាបទទាំងនោះ បទថា **ទស្សនានុត្តរិយំ** ក្នុងបទជាដើមថា **ទស្សនានុត្តរិយំ** បានដល់ បញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ បទថា **បដិបទានុត្តរិយំ** បានដល់វត្តបដិបត្តិដែលជាលោកិយៈ និងលោកុត្តរៈ ។ បទថា **វិមុត្តានុត្តរិយំ** គឺ លោកុត្តរវិមុត្តិ ។ មួយវិញទៀតបទថា **ទស្សនានុត្តរិយំ** គឺ សម្មាទិដ្ឋិ ដែលជាអរហត្តមគ្គ ព្រោះបំណងដល់លោកុត្តរធម៌សុទ្ធ ។ បទថា **បដិបទានុត្តរិយំ** គឺ

អគ្គមគ្គដ៏សេស ។ បទថា **វិមុត្តានុត្តរិយំ** គឺ វិមុត្តិ ជាមគ្គផល ។ ការឃើញនិព្វានរបស់ព្រះខីណាស្រព ឈ្មោះថា **ទស្សនានុត្តរិយ** ។ អគ្គមគ្គ ៨ ជាបដិបទានុត្តរិយៈ ។ មគ្គផល គប្បីជ្រាបថា ជាវិមុត្តានុត្តរិយៈ ។ បទថា **ពុទ្ធោ សោភគវា** សេចក្តីថា ព្រះមានព្រះភាគអង្គនោះ ត្រាស់ដឹងហើយនូវសច្ចៈ ៤ ដោយព្រះអង្គឯង ។ បទថា **ពោធាយ** សេចក្តីថា ទ្រង់សម្តែងធម៌ដល់សត្វសូម្បីពួកដទៃ ដើម្បីឲ្យត្រាស់ដឹងសច្ចៈ ៤ ។ បទថា **ទន្តោ** ក្នុងបទជាដើមថា **ទន្តោ** គឺ ទូន្មាន ។ បទថា **ទមថាយ** គឺ ដើម្បីត្រូវការទូន្មាន ។ បទថា **សន្តោ** គឺ ទ្រង់ស្ងប់ហើយ ដោយសេចក្តីចូលទៅស្ងប់កិលេសទាំងពួង ។ បទថា **សមថាយ** គឺ ដើម្បីសេចក្តីស្ងប់កិលេស ។ បទថា **តិណ្ណោ** គឺ ឆ្លងឱឃៈ ៤ ។ បទថា **តរណាយ** គឺ ដើម្បីឆ្លងឱឃៈ ៤ ។ បទថា **បរិនិព្វុតោ** សេចក្តីថា ទ្រង់រលត់ស្និទ្ធហើយដោយសេចក្តីរលត់ស្និទ្ធនៃកិលេស ។ បទថា **បរិនិព្វានាយ** សេចក្តីថា ទ្រង់សម្តែងធម៌ដើម្បីសេចក្តីរលត់ស្និទ្ធនៃកិលេស ។

[៤៣] បទថា **ធំសី** គឺ ជាអ្នកកម្ចាត់នូវគុណ ។ បទថា **បគព្ភា** គឺ ប្រកបដោយសេចក្តីឃ្នើសឃ្នងវាចា ។ បទថា **អាសាទេតព្វំ** គឺ គប្បីចាក់ដោត ។ បទថា **អាសជ្ជ** គឺ សង្កត់សង្កិន ។ បទថា **ន ត្វេវ ភវន្តំ គោតមំ** លោកសម្តែងថា អស់កម្លាំង ដើម្បីនឹងកាន់យកវាទៈរបស់ខ្លួនទៅសង្កត់សង្កិនចំពោះ

អ្នកណាៗ ទាំងអស់ ។ ព្រះមានព្រះភាគ ទ្រង់នឹងធ្វើអន្តរាយជីវិតអ្នកណាៗ ដូចដំរីជាដើម ក៏មិនមែន ។ តែនិគ្រន្ថនេះ នាំឧបមាបីប្រការទាំងនេះមកហើយ ដើម្បីនឹងលើកព្រះមានព្រះភាគ ក៏មិនមែនឡើយ គឺ នាំមកដើម្បីលើកខ្លួនឯង ប៉ុណ្ណោះ ដូចសេចក្ដីថា ព្រះរាជាទ្រង់បង្ក្រាបសត្រូវពួកខ្លះបានហើយ កាល នឹងទ្រង់សរសើរសត្រូវថា អ្នកខ្លាំងយ៉ាងនេះ នឹងជាអ្នកដល់ព្រមដោយកម្លាំង យ៉ាងនេះ ។ ក៏សរសើរខ្លួននោះឯង យ៉ាងណា សច្ចកនិគន្ថបុត្រនេះ ក៏យ៉ាង នោះ កាលនឹងលើកវាទៈព្រះមានព្រះភាគដោយពាក្យជាដើមថា **សិយា ហិ ភោ គោតម ហត្ថិបភិន្នំ** រមែងលើកខ្លួនឯងប៉ុណ្ណោះថា យើងជាអ្នកខ្លាំងក្លា យើងជាបណ្ឌិត យើងជាពហុស្សូត ជាអ្នកត្រូវការតទល់វាទៈ ចូលទៅគាល់ ព្រះសម្មាសម្ពុទ្ធ ដូចដំរីចុះប្រេង ដូចគំនរភ្លើងឆេះសន្ធោសន្ធៅ និងដូចអាសិរពិស បើកពពារ ដូច្នេះ ។

កាលលើកខ្លួនយ៉ាងនេះហើយ កាលនឹងនិមន្តព្រះមានព្រះភាគ ទើប ក្រាបទូលពាក្យជាដើមថា **អធិវាសេតុ មេ** ។ បណ្ដាបទទាំងនោះ បទថា **អធិវាសេតុ** គឺ សូមព្រះអង្គចូរទ្រង់ទទួលចុះ ។ បទថា **ស្វាតនាយ** សេចក្ដីថា ដើម្បីប្រយោជន៍ដល់បុណ្យ និងបីតិបាមោជ្ជ ដែលនឹងមានក្នុងថ្ងៃស្អែកនេះដល់ ខ្ញុំព្រះអង្គអ្នកធ្វើនូវសក្ការៈក្នុងព្រះអង្គ ។ បទថា **អធិវាសេសិ ភគវា តុណ្ហី-**

**ភាវេន** មានអធិប្បាយថា ព្រះមានព្រះភាគ ទ្រង់មិនញាំងអវយវៈចំណែកព្រះកាយ និងព្រះវាចាឲ្យញាប់ញ័រ ទ្រង់ឃាត់ទុកចំពោះខាងក្នុង ទ្រង់ទទួលហើយដោយតុណ្ហីភាព ។ គឺ ទ្រង់ទទួលដោយព្រះទ័យ ដើម្បីធ្វើការអនុគ្រោះដល់សច្ចកនិគន្ថបុត្រនោះឯង ដូច្នេះ ។

បទថា **យមស្ស បដិរូបំ មញ្ញេយ្យាថ** សេចក្តីថា បានឮថា ស្តេចលិច្ឆវីពួកនោះនាំថាស ៥០០ សម្រាប់ ទៅឲ្យដល់សច្ចកនិគន្ថបុត្រនោះ ជានិច្ចកត្តសច្ចកនិគន្ថបុត្រសំដៅយកកត្តនោះឯង ទើបពោលថា ថ្ងៃស្អែកនេះ ពួកលោកគួរសម្គាល់ថា វត្ថុដែលសមគួរទើបជារបស់គួរថ្វាយចំពោះព្រះសមណគោតម គួរនាំរបស់ដែលសមគួរនោះមក ពួកលោកជាអ្នកប្រណិបត្តិ រមែងយល់ដល់វត្ថុដែលគួរមិនគួរ សមគួរមិនសមគួរ ចំពោះព្រះសមណគោតម ។ បទថា **កត្តាភិហារំ អភិហរឹសុ** សេចក្តីថា នាំកត្តដែលគួរទៅ ។

[៤៤] បទថា **បណីតេន** គឺ ប្រសើរ ។ បទថា **សហត្ថា** គឺ ដោយដៃរបស់ខ្លួន ។

បទថា **សន្តប្បេត្វា** សេចក្តីថា ឆ្អែតល្អ គឺ អង្គាសឲ្យឆ្អែតគ្រប់គ្រាន់បរិបូណ៌តាមសេចក្តីត្រូវការ ។ បទថា **សម្បវារេត្វា** គឺ បវារណាល្អ គឺ ហាមដោយហត្ថសញ្ញាថា ល្មមហើយ ល្មមហើយ ដូច្នេះ ។ បទថា **ភុត្តាវី** គឺ

សោយ ។ បទថា **ឱនីតបត្តបាណឹ** គឺ នាំព្រះហស្តចេញពីបាត្រ អធិប្បាយថា គឺ នាំព្រះហស្តចេញហើយ ។ បាលីថា **ឱនិត្តបត្តបាណឹ** ដូច្នេះក៏មាន ។ បទនោះមានសេចក្តីថា ឈ្មោះថា **ឱនិត្តបត្តបាណឹ** ព្រោះអត្ថថា មានបាត្រផ្សេងនាំចេញហើយពីព្រះហស្ត អធិប្បាយថា ព្រះមានព្រះភាគអង្គនោះ មានបាត្រដែលនាំចេញហើយពីព្រះហស្ត គឺ ទ្រង់ជម្រះព្រះហស្ត និងបាត្រ ទ្រង់រក្សាបាត្រទុកត្រង់ទីសមគួរម្ខាង ហើយប្រថាប់អង្គុយ ។ បទថា **ឯកមន្តំ និសីទិ** សេចក្តីថា សច្ចកនិគ្រន្ថ ដឹងដល់ព្រះមានព្រះភាគសោយយ៉ាងនេះ ទើបអង្គុយក្នុងទីកន្លែងមួយ ។ បទថា **បុញ្ញញ្ច** គឺ បុណ្យក្នុងទាននេះ អធិប្បាយថា ជាវិបាកក្ខន្ធតទៅ ។ បទថា **បញ្ញាមហិ** សេចក្តីថា ជាបរិវារចំពោះវិបាកក្ខន្ធ ។ បទថា **តំ ទាយកានំ សុខាយ ហោតុ** សេចក្តីថា បុណ្យនោះ ចូរមានដើម្បីប្រយោជន៍សុខដល់លិច្ឆវីទាំងនេះ ។

បានឮថា និគ្រន្ថនោះ កាលនឹងប្រគល់ទាននេះដល់ស្តេចលិច្ឆវីទាំងនោះ ទើបពោលយ៉ាងនេះថា យើងជាបព្វជិត មិនគួរឲ្យទានរបស់ខ្លួន ។ លំដាប់នោះ ព្រះមានព្រះភាគ ព្រោះបុណ្យស្តេចលិច្ឆវីឲ្យដល់សច្ចកនិគ្រន្ថ មិនឲ្យព្រះមានព្រះភាគ ចំណែកសច្ចកនិគ្រន្ថថ្វាយចំពោះព្រះមានព្រះភាគ ដូច្នោះ កាលទ្រង់សម្តែងអត្ថន័យនោះ ទើបត្រាស់ពាក្យជាដើមថា **យំ ខោ អគ្គិវេស្សន**

ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ប្រគល់ទក្ខិណា ដែលគេថ្វាយចំពោះព្រះអង្គ ដល់និគ្រន្ថដើម្បីរក្សាទឹកចិត្ត ទក្ខិណានោះ ក៏ទឹងជាវាសនាក្នុងអនាគត ដោយប្រការដូច្នេះឯង ។

( ចប់ អដ្ឋកថា ចូឡសច្ចកសូត្រ ទី ៥ )

# អ ដ្ឋ ក ថា

## មហាសច្ចកសូត្រ ទី ៦

[៤៥] *មហាសច្ចកសូត្រ មានបទផ្ដើមថា* ***ឯវម្មេ សុតំ*** *។*

*បណ្ដាបទទាំងនោះ ដោយ ៣ បទថា* ***ឯកំ សមយំ ១ តេន ខោ បន សមយេន ១ បុព្វណ្ហសមយំ ១*** *លោកពោលជាសម័យមួយ ។ ក៏វេលាពួកភិក្ខុធ្វើការបដិបត្តិខ្លួន លុបលាងមុខ កាន់បាត្រ និងចីវរ ថ្វាយបង្គំព្រះចេតិយ ហើយឈរក្នុងរោង រិតក្កថា យើងនឹងចូលទៅស្រុកណា ។ សម័យបែបនេះ ព្រះមានព្រះភាគ ទ្រង់សំពត់ក្រហម ២ ជាន់ ក្រវាត់វត្ថព័ន្ធចង្កេះ ទ្រង់ចីវរបង្សុកូលចៀនស្មា ស្ដេចចេញពីព្រះគន្ធកុដិ ដែលពួកភិក្ខុហែហម ប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ ។ សច្ចកនិគន្ថបុត្រ សំដៅយកប្រការនោះហើយ ទើបពោលថា* ***ឯកំ សមយំ តេន ខោ បន សមយេន បុព្វណ្ហសមយំ*** *ដូច្នេះ ។ បទថា* ***បវិសិតុកាមោ*** *បានដល់ ដាក់ព្រះទ័យយ៉ាងនេះថា តថាគតនឹងចូលទៅបិណ្ឌបាត ។*

*បទថា* ***តេនុបសង្កមិ*** *សួរថា សច្ចកនិគន្ថបុត្រចូលទៅរកព្រោះហេតុអ្វី ។ តបថា ដោយអធ្យាស្រ័យដើម្បីតទល់វាទៈ បានឮថា និគ្រន្ថនោះ បានមានគំនិតយ៉ាងនេះថា គ្រាមុនយើងព្រោះមិនបានជាបណ្ឌិត ទើបនាំយកវេសាលី*

បរិស័ទទាំងអស់ ទៅកាន់សម្នាក់របស់ព្រះសមណគោតម ទើបជាអ្នកទ្រមឹង នាកណ្តាលបរិស័ទ តែគ្រានេះ យើងមិនធ្វើយ៉ាងនោះ ទៅតែម្នាក់ឯង នឹងតទល់វាទៈ បើយើងនឹងអាចឲ្យព្រះសមណគោតមបរាជ័យបាន នឹងសម្តែងលទ្ធិរបស់ខ្លួន ហើយធ្វើការឈ្នះ បើព្រះសមណគោតមនឹងឈ្នះ អ្នកណាៗ ក៏មិនដឹង ដូចរបាំ វាំក្នុងទីងងឹត ទើបកាន់យកបញ្ហាអ្នកអាក្រាតចូលទៅរក ដោយអធ្យាស្រ័យនៃវាទៈនេះ ។

បទថា **អនុកម្បំ ឧបាទាយ** សេចក្តីថា អាស្រ័យសេចក្តីករុណាដល់សច្ចកនិគន្ថបុត្រ ។ បានឮថា ព្រះថេរៈបានមានគំនិតយ៉ាងនេះថា កាលព្រះមានព្រះភាគប្រថាប់អង្គុយសម្រាកត្រឹមតែមួយរយៈ គេនឹងបានគាល់ព្រះពុទ្ធ និងបានការស្តាប់ធម៌ ការគាល់ព្រះពុទ្ធ និងការស្តាប់ធម៌ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់គេរហូតអស់កាលយូរ ព្រោះដូច្នោះ ព្រះថេរៈទូលអារាធនាព្រះមានព្រះភាគហើយ បត់ចីវរបង្សុកូលជា ៤ ជាន់ក្រាល ទើបបានក្រាបទូលថា សូមព្រះមានព្រះភាគចូរប្រថាប់គង់ចុះ ។ ព្រះមានព្រះភាគទ្រង់កំណត់ថា អានន្ទពោលហេតុ ទើបប្រថាប់គង់លើអាសនៈដែលក្រាលថ្វាយ ។

[៤៦] បទថា **ភគវន្តំ ឯតទវោច** សេចក្តីថា និគ្រន្ថខ្ចប់បញ្ហាដែលជា

សារៈ កាន់យកមកដាក់ទុកនៅខាងៗ ។ ក្រាបទូលពាក្យជាដើមនោះថា **ភោ គោតម** ។

បទថា **ផុសន្តិ ហិ ភោ គោតម** សេចក្ដីថា សមណព្រាហ្មណ៍ទាំងនោះ រមែងពាល់ត្រូវ គឺ រមែងបាន គឺ ប្រសព្វទុក្ខវេទនា ដែលកើតក្នុងសរីរកាយ ។ បទថា **ឩរុក្ខម្ភោ** សេចក្ដីថា រឹងភ្លៅ អធិប្បាយថា ភ្លៅរឹងត្អឹះ តែក្នុងទីនេះដោយអត្ថថា ធ្វើឲ្យកាំងស្មារតី ទើបធ្វើជាពាក្យអនាគតថា **ភវិស្សតិ** ។ បទថា **កាយន្វយំ ហោតិ** គឺ ចិត្តទៅតាមកាយ គឺ ប្រព្រឹត្តទៅតាមអំណាចកាយ ។ ចំណែកវិបស្សនា ហៅថា **កាយភាវនា** អ្នកដល់សេចក្ដីរេរាំយទាំងកាយ និងចិត្ត រមែងមិនមាន និគ្គហពោលដល់ទីដែល មិនមានមិនកើតប៉ុណ្ណោះ ដោយប្រការដូច្នេះ សមថៈហៅថា ចិត្តភាវនាដូច្នេះក៏មានសេចក្ដីថា ការរឹងភ្លៅជាដើម របស់បុគ្គលដែលប្រកបដោយសមាធិ រមែងមិនមាន និគ្គហពោលចំពោះវត្ថុដែលមិនមាននេះ ដោយប្រការនេះ ។ ចំណែកក្នុងអដ្ឋកថា លោកពោលថា កាលបុគ្គលពោលថា រឿងធ្លាប់មានមកហើយនៅពោលពាក្យជាដើមថា ឈ្មោះការរឹងភ្លៅក៏នឹងមាន ដែលជាពាក្យអនាគតមិនត្រូវយ៉ាងណា អត្ថន័យក៏មិនត្រូវដូច្នោះ និគ្គហពោលដល់វត្ថុដែលមិនមានមិនកើត ។ បទថា **នោ កាយភាវនំ** គេពោលសំដៅយកការបដិបត្តិខ្លួនឲ្យ

លំបាក មានការធ្វើសេចក្តីព្យាយាម ៥ ប្រការជាដើម ។ នេះឈ្មោះកាយ-ភាវនា របស់សមណព្រាហ្មណ៍ទាំងនោះ ។ សួរថា ក៏និគ្រន្ថនោះឃើញអ្វីទើបបានពោលយ៉ាងនេះ ។ ឆ្លើយថា បានឮថា និគ្រន្ថនោះ មកកាន់ទីសម្រាកពេលថ្ងៃ ក៏ឯសម័យនោះ ពួកភិក្ខុរក្សាបាត្រ និងចីវរហើយ ចូលទៅដើម្បីពួនសម្ងំក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃរៀងៗ ខ្លួន គេឃើញពួកភិក្ខុទាំងនោះពួនសម្ងំ សម្គាល់ថា ពួកភិក្ខុទាំងនោះប្រឹងប្រែង ប្រកបត្រឹមតែចិត្ត-ភាវនា តែកាយភាវនាមិនមានដល់ភិក្ខុទាំងនោះ ទើបពោលយ៉ាងនេះ ។

[៤៧] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សាកសួរនិគ្រន្ថនោះទើបត្រាស់សួរថា ម្នាលអគ្គិវេស្សនៈ ចុះកាយភាវនា អ្នកបានឮមកដូចម្តេចនិគ្រន្ថនោះ កាលទឹងពោលកាយភាវនានោះឲ្យពិស្តារ ទើបទូលពាក្យជាដើមថា គឺ នន្ទៈ ដែលជាវច្ឆគោត្រ ។ បណ្តាបទទាំងនោះ បទថា **នន្ទោ** ជាឈ្មោះបទថា **វច្ឆោ** ជាគោត្រ ។ បទថា **កីសោ** ជាឈ្មោះ បទថា **សង្កិច្ចោ** ជាគោត្រ ។ មក្ខលិគោសាល មកក្នុងកាលមុនហើយនោះឯង ។ បទថា **ឯតេ** បានដល់ជនទាំង ៣ នាក់នោះ បានឮថា ជនទាំងនោះបានសម្រេចទីបំផុតនៃតបៈដែលសៅហ្មង បទថា **ឧឡារានិ** គឺ ភោជនដែលប្រណីតៗ ។ បទថា **គាហេន្តិ** នាមឈ្មោះថា រមែងឲ្យរាងកាយមានកម្លាំង ។ បទថា **ព្រូហេន្តិ** គឺ ឲ្យចម្រើន ។

បទថា **មោទេន្តិ** គឺ ធ្វើឲ្យកើតខ្វាញ់ខាប់ ។ បទថា **បុរិមំ បហាយ** បានដល់លើកការធ្វើសេចក្តីលំបាកឡើងមុន ។ បទថា **បុប្ផាឧបចិនន្តិ** សេចក្តីថា ឲ្យឆ្អែតគ្រប់គ្រាន់ គឺ ឲ្យចម្រើនដោយរបស់គួរទំពារ ដែលប្រណីត ជាដើម ។ បទថា **អាចយាបចយោ ហោតិ** គឺ សេចក្តីចម្រើន និងសេចក្តីសាបសូន្យរមែងប្រាកដត្រឹមតែសេចក្តីចម្រើន និងសេចក្តីសាបសូន្យ កាយនេះក៏មានសេចក្តីចម្រើនតាមកាល សេចក្តីសាបសូន្យតាមកាល ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា កាយភាវនាមិនប្រាកដ ត្រាស់សួរចិត្តភាវនា ត្រាស់សួរថា ម្នាលអគ្គិវេស្សនៈ ចិត្តភាវនា អ្នកស្តាប់មកហើយយ៉ាងណា ។ បទថា **ន សម្បាយាសិ** សេចក្តីថា មិនអាចទូលឲ្យបរិបូរណ៍បាន ដូចពាលបុថុជ្ជន ។

[៤៨] បទថា **កុតោ បន ត្វំ** សេចក្តីថា អ្នកណាមិនដឹងសេចក្តីចម្រើនរបស់រាងកាយ ដែលទន់ខ្សោយ ជាចំណែកគ្រោតគ្រាតយ៉ាងនេះ បុគ្គលនោះ នឹងដឹងចិត្តភាវនាដែលល្អិតល្អន់សុខុមបានពីទីណាហ្ន៎ ។ ចំណែកក្នុងទីនេះ ព្រះបោទនាលយត្ថេរគិតថា បទនោះ ឈ្មោះព្រះពុទ្ធវចនៈ ក៏មិនមែនជាក់ផ្ចិតវិជនីក៏ចៀសចេញទៅ ។ តមកព្រះមហាសិវត្ថេរ អាងព្រះពុទ្ធវចនៈនោះថា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនខ្លះ សេចក្តីវិនាសខ្លះ បដិសន្ធិខ្លះ ចុតិខ្លះ របស់កាយដែលជាមហាភូត ៤ នេះ នឹងប្រាកដ ព្រះថេរៈស្តាប់ពាក្យ

នោះហើយ កំណត់ថា គួរពោលថា កាលកំណត់កាយជាចំណែកគ្រោតគ្រាត វិបស្សនាដែលកើត ក៏ជាចំណែកគ្រោតគ្រាត ដូច្នេះ ។

[៤៩] បទថា **សុខសារាគី** គឺ អ្នកប្រកបដោយសេចក្ដីត្រេកអរដោយសេចក្ដីសុខ បទថា **សុខាយ វេទនាយ និរោធា ឧប្បជ្ជតិ ទុក្ខាវេទនា** គឺ រមែងកើតក្នុងលំដាប់ សម្រេចហើយក្នុងគម្ពីរបដ្ឋាន ព្រោះទុក្ខវេទនានោះ ជាអនន្តរប្បច្ច័យដល់សុខ និងទុក្ខ តែព្រោះកាលសុខវេទនាមិនទាន់រលត់ ទុក្ខវេទនាក៏មិនកើត ដូច្នោះ លោកទើបពោលទុក្ខក្នុងទីនេះ ។ បទថា **បរិយាទាយ តិដ្ឋតិ** សេចក្ដីថា ឲ្យវេទនាអស់ទៅហើយ ប្រកាន់ទុក ។ បទថា **ឧភតោ បក្ខំ** សេចក្ដីថា ជា ២ ចំណែកយ៉ាងនេះ គឺ សុខមួយចំណែក ទុក្ខមួយចំណែក ។

វិនិច្ឆ័យក្នុងបទនេះថា **ឧប្បន្នាបិ ។បេ។ ចិត្តស្ស** ដូចតទៅនេះ ៖

កាយភាវនាជាវិបស្សនា ចិត្តភាវនាជាសមាធិ ចំណែកវិបស្សនាជាសត្រូវចំពោះសុខ តែជិតចំពោះទុក្ខ សមាធិជាសត្រូវចំពោះទុក្ខ តែជិតចំពោះសុខ ។ យ៉ាងណា ពិតណាស់ កាលព្រះយោគាវចរអង្គុយផ្ដើមវិបស្សនា ឲ្យវេលាកន្លងទៅយូរ ចិត្តរបស់លោករមែងក្ដៅក្រហាយ រមែងប្រាកដដូចភ្លើងដែលឆេះក្នុងទីនោះ ញើសហូរចេញចាកក្លៀក អាការក្ដៅ តាំងឡើងដល់សិរសៈ ដោយហេតុត្រឹមតែប៉ុណ្ណេះ វិបស្សនាជាសត្រូវចំពោះសុខ តែជិតចំពោះទុក្ខ ។ ក៏កាល

ទុក្ខផ្លូវកាយ ឬផ្លូវចិត្តកើតហើយ ទុក្ខក្នុងខណៈសមាបត្តិរបស់អ្នកគ្របសង្កត់ នោះចូលសមាបត្តិ រមែងប្រាសចាកទុក្ខ ធ្លាក់ចុះកាន់សុខមិនតិច កាលបើយ៉ាងនេះ សមាធិទើបជាសត្រូវចំពោះទុក្ខ តែជិតចំពោះសុខ ។ វិបស្សនាជាសត្រូវចំពោះសុខ ជិតចំពោះទុក្ខ យ៉ាងណា សមាធិមិនដូច្នោះទេ ។ សមាធិជាសត្រូវចំពោះទុក្ខ តែជិតចំពោះសុខ យ៉ាងណា ចំណែកវិបស្សនា មិនដូច្នោះទេ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា **ឧប្បន្នាបិ ។បេ។ ចិត្តស្ស** ។

[៥០] បទថា **អាសជ្ជ ឧបនីយ** បានដល់ ទាក់ទងនឹងការនាំចូលទៅកាន់គុណ ។ បទថា **តំ វត មេ** បានដល់ ចិត្តរបស់យើងនោះហ្ន៎ ។

[៥១-៥៣] បទថា **កិញ្ចិ នោ សិយា អគ្គិវេស្សន** សេចក្តីថា ម្នាលអគ្គិវេស្សនៈ អ្វីមិនមាន អ្វីមាន លោកកុំសម្គាល់យ៉ាងនេះ សុខវេទនាក្តី ទុក្ខវេទនាក្តី រមែងកើតដល់យើង តែកាលកើតឡើងហើយ យើងនឹងមិនឲ្យគ្របសង្កត់ចិត្ត ។

ឥឡូវនេះ ព្រះមានព្រះភាគ មានបំណងនឹងទ្រង់សម្តែងព្រះធម៌ទេសនាជាទីមកនៃសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង ដើម្បីប្រកាសសេចក្តីនោះ និគ្រន្ថនោះទើបទ្រង់ប្រារព្ធមហាភិនេស្រ្កមន៍តាំងអំពីដើម ក្នុងបទថា **ឥធ ។បេ។ បធានាយ** នោះ នេះទាំងអស់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងបាសរាសិសូត្រក្នុង

កាលមុននោះឯង ។

ចំណែកសេចក្តីផ្សេងគ្នាដូច្នេះ គឺ ការគង់លើពោធិបល្ល័ង្កនោះ ជាការធ្វើ ដែលធ្វើបានលំបាកក្នុងសេចក្តីនេះ ។

[៥៤] បទថា **អល្លកដ្ឋំ** គឺ ដើមឈើស្រស់ ។ បទថា **សស្នេហំ** គឺ មានជ័រដូចទឹកដោះ ។ បទថា **កាមេហិ** គឺ ចាកវត្ថុកាម ។ បទថា **អវូប កដ្ឋា** គឺ មិនចៀសចេញ ។ កិលេសកាម ក្នុងបទជាដើមថា **កាមឆន្ទោ** គប្បីជ្រាបថា ឆន្ទៈដោយអំណាចធ្វើសេចក្តីពេញចិត្ត សិនេហៈ ដោយអំណាចធ្វើសេចក្តីហួងហែង **មុច្ឆា** ដោយអំណាចធ្វើសេចក្តីស្លប់ **បិបាសា** ដោយអំណាចធ្វើសេចក្តីក្តៅក្រហាយ **បរិឡាហ** ដោយអំណាចការតាមដុត ។ បទថា **ឱបក្កមិកា** គឺ កើត ព្រោះសេចក្តីព្យាយាម ។ បទថា **ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ** ទាំងអស់ ជាវេវចនៈនឹងលោកុត្តរមគ្គ ។

ក៏មានឧបមាប្រៀបធៀបក្នុងសេចក្តីនេះដូច្នេះ គឺ បុគ្គលនៅមានកិលេស-កាម មិនទាន់ចេញចាកវត្ថុកាម ដូចដើមឈើស្រស់មានជ័រ សើមជោកដោយកិលេសកាម ដូចឈើដែលត្រាំទុកក្នុងទឹក ការមិនសម្រេចលោកុត្តរមគ្គដោយវេទនាដែលកើតព្រោះសេចក្តីព្យាយាម របស់បុគ្គលដែលមានកិលេសកាម មិនទាន់ចេញចាកវត្ថុកាម ដូចពួតឈើពួតភ្លើង ភ្លើងក៏មិនកើត ។ ការមិនសម្រេច

លោកុត្តរមគ្គរបស់បុគ្គលទាំងនោះ វៀរចាកវេទនាដែលកើត ព្រោះសេចក្តីព្យាយាម ដូចមិនពួតឈើពួតភ្លើង ភ្លើងក៏មិនកើត សូម្បីឧបមាប្រការទី ២ គប្បីជ្រាបដោយន័យនេះឯង ។ ចំណែកសេចក្តីផ្សេងគ្នាដូច្នេះ គឺ ប្រការដំបូងជាឧបមានៃការបួសព្រមទាំងបុត្រ និងភរិយា ប្រការក្រោយជាឧបមានៃការបួសរបស់ព្រាហ្មណ៍អ្នកទ្រទ្រង់ធម៌ ។

[៥៦] បទថា **កោឡាបំ** ក្នុងឧបមាប្រការទីបី បានដល់ ឈើដែលមិនមានជ័រ បទថា **ថលេនិក្ខិត្តំ** គឺ ដែលគេដាក់លើភ្នំ ឬលើផែនដី ក៏មានឧបមាប្រៀបធៀបក្នុងសេចក្តីនេះដូច្នេះ គឺ ក៏បុគ្គលមានកិលេសកាម ចេញចាកវត្ថុកាម ដូចឈើស្ងួត មិនសើមជោកដោយកិលេសកាម ដូចឈើដែលគេដាក់លើគោក ឆ្ងាយពីទឹក ការសម្រេចលោកុត្តរមគ្គដោយវេទនា សូម្បីកើតព្រោះសេចក្តីព្យាយាម មានការអង្គុយក្នុងទីវាលជាដើម របស់បុគ្គលមានកិលេសកាម ចេញចាកវត្ថុកាម ដូចពួតឈើពួតភ្លើង ភ្លើងក៏កើត ការសម្រេចលោកុត្តរមគ្គដោយសុខាបដិបទា វៀរចាកវេទនាដែលកើត ព្រោះសេចក្តីព្យាយាម ដូចកើតភ្លើង ដោយត្រឹមតែការពួតភ្លើងនឹងមែកឈើដទៃ ។ ឧបមានេះ ព្រះមានព្រះភាគទ្រង់នាំមកដើម្បីប្រយោជន៍ដល់ព្រះអង្គ ។

[៥៧] ឥឡូវនេះ កាលនឹងទ្រង់សម្តែងទុក្ករកិរិយារបស់ព្រះអង្គ ទើប

ត្រាស់ថា **តស្ស មយ្ហ** ជាដើម ។ ក៏ព្រះមានព្រះភាគ ទ្រង់មិនធ្វើទុក្ករកិរិយា មិនអាចជាព្រះពុទ្ធបានឬ ទ្រង់ធ្វើក៏ដោយ មិនធ្វើក៏ដោយ ក៏ជាព្រះពុទ្ធបាន ។ សួរថា កាលបើដូច្នោះ ទ្រង់ធ្វើព្រោះហេតុអ្វី ឆ្លើយថា យើងនឹងសម្តែងសេចក្តីព្យាយាមរបស់ខ្លួនដល់លោក ព្រមទាំងទេវលោក និងគុណ គឺ សេចក្តីញាំញីដោយសេចក្តីព្យាយាមនោះ នឹងឲ្យយើងត្រេកអរបាន ។ ពិតណាស់ ក្សត្រិយ៍ប្រថាប់អង្គុយលើប្រាសាទ សូម្បីទ្រង់បានទទួលរាជសម្បត្តិបន្តមកពីព្រះរាជ-ប្រពៃណី ទ្រង់មិនត្រេកអរយ៉ាងនោះ តែរាជសម្បត្តិដែលនាំយកពួកពលទៅប្រហារសត្រូវ ២-៣ នាក់ កម្ចាត់សត្រូវបានមក សោមនស្សដែលមានកម្លាំងរមែងកើតដល់ព្រះអង្គដែលបានសោយសិរីរាជសម្បត្តិយ៉ាងនោះ ទ្រង់ក្រឡេកមើលបរិស័ទ ទ្រង់រំលឹកដល់សេចក្តីព្យាយាមរបស់ខ្លួនហើយ ទ្រង់ត្រិះរិះថា យើងធ្វើកម្មនោះ ក្នុងទីឯណោះ សម្រេចយ៉ាងនេះ ប្រហារយ៉ាងនេះ ដល់សត្រូវឯណោះ និងឯណោះ ទើបបានសោយសិរីរាជសម្បត្តិនេះ យ៉ាងណា សូម្បីព្រះមានព្រះភាគក៏យ៉ាងនោះដែរ ទ្រង់ត្រិះរិះថា តថាគតនឹងសម្តែងសេចក្តីព្យាយាមដល់លោក ព្រមទាំងទេវលោក ក៏សេចក្តីព្យាយាមនោះនឹងឲ្យតថាគតរីករាយឲ្យកើតសោមនស្សាយ៉ាងក្រៃលែង ទើបបានធ្វើទុក្ករកិរិយា ម្យ៉ាងទៀត សូម្បីនឹងទ្រង់អនុគ្រោះពួកជនអ្នកកើតក្នុងខាងក្រោយ ក៏ទ្រង់បានធ្វើដូចគ្នា ពួកជន

អ្នកកើតក្នុងខាងក្រោយនឹងសម្គាល់សេចក្តីព្យាយាមដែលគួរធ្វើថា ព្រះសម្មាសម្ពុទ្ធទ្រង់បំពេញព្រះបារមីរហូត ៤ អសង្ខេយ្យ ក្រៃលែងដោយសែនកប្ប ទ្រង់តាំងសេចក្តីព្យាយាម សម្រេចព្រះសព្វញ្ញុតញ្ញាណ នឹងពោលទៅថ្វីដល់ពួកយើងហ្ន៎ កាលបើដូច្នោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា ពួកជននឹងធ្វើទីបំផុតនៃជាតិជរា និងមរណៈ បានឆាប់រហ័ស ព្រោះដូច្នោះ កាលទ្រង់នឹងអនុគ្រោះពួកជនអ្នកកើតខាងក្រោយ ទើបបានទ្រង់ធ្វើដូចគ្នា ។ បទថា **ទន្តេហិ ទន្តមាធាយ** បានដល់ សង្កត់ព្រះទន្តលើដោយព្រះទន្តក្រោម បទថា **ចេតសា ចិត្តំ** បានដល់ គ្របសង្កត់អកុសលចិត្តដោយកុសលចិត្ត ។ បទថា **អភិនិគ្គណ្ហេយ្យំ** គឺ គប្បីគ្របសង្កត់ ។ បទថា **អភិនិប្បីឡេយ្យំ** គឺ គប្បីបៀតបៀន ។ បទថា **អភិនិសន្តាបេយ្យំ** សេចក្តីថា គប្បីដុតកំដៅ ហើយទម្លាយ ញាំញីដោយសេចក្តីព្យាយាម ។ បទថា **សា រទ្ធោ** គឺ មានកាយរសាប់រសល់ ។ បទថា **បធានាភិតុន្នស្ស** សេចក្តីថា មានសតិដែលសេចក្តីព្យាយាមចាក់ដោតគឺ មុតហើយ ។

[៥៨] បទថា **អប្បាណកំ** គឺ មិនមានខ្យល់ដកដង្ហើម ។ បទថា **កម្មារគគ្គរិយា** បានដល់ ស្នប់ជាងមាស ។ បទថា **សីសវេទនា ហោន្តិ** សេចក្តីថា វេទនាកើតពីសិរសៈមានកម្លាំង ត្រូវខ្យល់ចេញទៅណាមិនបាន ។

បទថា *សីសាបេឡំ ទទេយ្យ* បានដល់ គប្បីរឹតត្រង់សិរសៈ ។ បទថា *ទេវតា* សេចក្តីថា ទេវតាស្ថិតនៅក្នុងខាងចុងទីចង្ក្រមរបស់ព្រះពោធិសត្វ និងជិតបរិវេណបណ្ណសាលា ។ បានឮថា ក្នុងកាលនោះ កាលសេចក្តីក្តៅផ្សាក្នុងព្រះវរកាយដែលមានប្រមាណក្រៃលែងរបស់ព្រះពោធិសត្វកើតឡើង បាត់បង់សតិ ព្រះអង្គប្រថាប់គង់ដួលលើទីចង្ក្រម ។ ទេវតាឃើញព្រះពោធិសត្វនោះ ទើបពោលថា ព្រះពោធិសត្វអស់ព្រះជន្មហើយ ពួកទេវតាទាំងនោះ ទើបទៅក្រាបទូលចំពោះព្រះបាទសុទ្ធោទនមហារាជថា ព្រះរាជឱរសរបស់ព្រះអង្គ អស់ព្រះជន្មហើយ ។ ព្រះបាទសុទ្ធោទនមហារាជ ត្រាស់ថា បុត្ររបស់យើង ជាព្រះពុទ្ធ ទើបធ្វើកាលៈ បើមិនទាន់សម្រេចជាព្រះពុទ្ធ នឹងមិនធ្វើកាលៈឡើយទេវតា ។ នឹងជាព្រះពុទ្ធមិនបាន ទ្រង់ដួលនៅលើផែនដី ដោយធ្វើសេចក្តីព្យាយាម អស់ព្រះជន្មហើយព្រះបាទសុទ្ធោទនមហារាជ ។ យើងមិនជឿការអស់ព្រះជន្ម នឹងមិនមានដល់ឱរសរបស់យើង ព្រោះមិនទាន់សម្រេចពោធិញ្ញាណ ។ ក្នុងវេលាតមក កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ស្តេចទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ស្តេចដល់ក្រុងកបិលពស្តុ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ទទួលបាត្រនាំស្តេចឡើងកាន់ប្រាសាទ ថ្វាយបបរ និងរបស់ទំពារ ទូលរឿងនោះក្នុងវេលាចន្លោះភត្តថា បពិត្រព្រះមានព្រះភាគ ក្នុងវេលាព្រះអង្គទ្រង់ធ្វើសេចក្តីព្យាយាម

ទេវតាមកប្រាប់ថា ម្នាលមហារាជ ឱរសរបស់ព្រះអង្គអស់ព្រះជន្មទៅហើយ ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ ព្រះអង្គទ្រង់ជឿឬ ព្រះបាទសុទ្ធោទនមហារាជ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនជឿ ។ ព្រះមានព្រះភាគ មហាបពិត្រ ឥឡូវនេះ ព្រះអង្គទ្រង់ឃើញអស្ចារ្យតាំងពីទ្រង់ព្រះសុបិន្ត ក៏នឹងជឿឬ សូម្បីតថាគតជាព្រះពុទ្ធ សូម្បីមហាបពិត្រក៏ទ្រង់ជាព្រះពុទ្ធបិតា ចំណែកក្នុងកាលមុន កាលញាណរបស់តថាគតនៅមិនទាន់ចាស់ក្លា បំពេញពោធិចរិយានៅឡើយ ដើម្បីសិក្សាសិល្បៈ សូម្បីក្នុងវេលាជាធម្មបាលកុមារ ព្រះមានព្រះភាគ ត្រាស់មហាធម្មបាលជាតក ព្រោះសេចក្តីឧប្បត្តិឡើងនៃរឿងនេះថា ជនទាំងឡាយនាំឆ្អឹងពពែមកសម្តែងថា ធម្មបាលកុមារបុត្ររបស់លោកធ្វើកាលៈហើយ នេះឆ្អឹងរបស់គេ ដូច្នេះ ។ មហាបពិត្រ សូម្បីក្នុងកាលនោះ ព្រះអង្គបានត្រាស់ថា ឈ្មោះថា សេចក្តីស្លាប់ក្នុងចន្លោះរបស់បុត្រយើង រមែងមិនមាន យើងមិនជឿ ដូច្នេះ ។

[៦៣] បទថា **មា ខោ តុំ មារិស** បានដល់ ពួកទេវតាអ្នកស្រឡាញ់មកក្រាបទូល ។

បានឮថា រោហារគួរស្រឡាញ់ គួរពេញចិត្តរបស់ពួកទេវតា គឺ មារិស ។ បទថា **អជ្ជិតំ** គឺ មិនមែនភោជន ។ បទថា **ហលន្តិ វទាមិ** គឺ យើងពោលថា

ល្អមហើយ អធិប្បាយថា យើងហាមយ៉ាងនេះថា លោកកុំធ្វើយ៉ាងនេះ ដោយបទនេះ យើងនឹងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។

[៦៤] បទថា **អគ្គុវច្ឆរី** គឺ មានព្រះធរីពពាល ។

[៦៥] បទថា **ឯតាវបរមំ** សេចក្តីថា ប្រមាណនោះ ជាយ៉ាងក្រៃលែង គឺ ខ្ពស់បំផុតនៃវេទនាទាំងនោះ ។ បទថា **បិតុសក្កស្ស កម្មន្តេ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតា** សេចក្តីថា បានឮថា ក្នុងថ្ងៃនោះ ឈ្មោះថា ជាថ្ងៃវប្បមង្គលរបស់ព្រះរាជា ព្រះរាជាទាំងឡាយ ចាត់របស់គួរទំពាររបស់ស៊ីច្រើនប្រការ សម្អាតថ្នល់ព្រះនគរឲ្យស្អាត តាំងឆ្នាំងពេញដោយទឹក ឲ្យលើកទង់សំពត់ជាដើមឡើង ប្រដាប់ទូទៅទាំងព្រះនគរ ដូចទេវវិមាន ទាសៈ និងកម្មករជាដើមទាំងពួង ស្លៀកដណ្តប់សំពត់ថ្មី ប្រដាប់ដោយរបស់ក្រអូប និងផ្កាឈើជាដើម ប្រជុំគ្នាក្នុងរាជត្រកូល ក្នុងរាជពិធី គេប្រកបដងនង្គ័លមួយពាន់ តែក្នុងថ្ងៃនោះ រាជបុរសប្រកបដងនង្គ័ល ៨០០ ខ្វះមួយ ដងនង្គ័លទាំងអស់ព្រមទាំងខ្សែចងគោកម្ទោះ ដណ្តប់ដោយប្រាក់ ដូចរថរបស់ជានុសោណិព្រាហ្មណ៍ ដងនង្គ័លរបស់ព្រះរាជា មានព្យួរដណ្តប់ដោយមាសឆ្អិន ស្នែងរបស់គោកម្ទោះក្តី ខ្សែ និងជន្ទួញក្តី រុំដោយមាស ព្រះរាជស្តេចចេញទៅដោយបរិវារធំ ទទួលយកឱរសទៅផង ក្នុងទីប្រកបព្រះរាជពិធីច្រតព្រះនង្គ័ល មានដើមព្រីងមួយដើម

មានស្លឹកក្រាស់ មានម្លប់ខាងក្រោមដើមព្រីងនោះ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យក្រាលទីផ្ទំរបស់កុមារ ខាងលើពិតាន ក្ជាប់ដោយផ្កាយមាស ហោមព័ទ្ធដោយកំពែងវាំងននតាំងរក្សា ទ្រង់គ្រឿងសព្វាលង្ការ ហែហមដោយពួកអមាត្យ ស្ដេចទៅកាន់ព្រះរាជពិធីប្រតព្រះនង្គ័លក្នុងទីនោះ ព្រះរាជាទ្រង់កាន់ដងនង្គ័លមាស ពួកអមាត្យកាន់ដងនង្គ័លប្រាក់ ៨០០ ខ្វះមួយ អ្នកស្រែកាន់ដងនង្គ័លដ៏សេស ពួកគេនោះ កាន់ដងនង្គ័លទាំងនោះទៅផ្លូវនោះផ្លូវនេះ ៗ ចំណែកព្រះរាជាស្ដេចយាងពីខាងនេះទៅខាងនោះ ឬពីខាងនោះមកកាន់ខាងនេះ ៗ ក្នុងទីនេះជាមហាសម្បត្តិ គីលៀងអង្គុយព័ទ្ធជុំវិញព្រះពោធិសត្វគិតថា យើងនឹងឃើញសម្បត្តិរបស់ព្រះរាជា ទើបនាំគ្នាចេញទៅក្រៅវាំងនន ព្រះពោធិសត្វទ្រង់ក្រឡេកមើលខាងនោះខាងនេះ មិនឃើញអ្នកណាៗ ទើបប្រញាប់ក្រោកឡើងអង្គុយពែនភ្នែនសមាធិ កំណត់ខ្យល់ដកដង្ហើមចូលចេញ ញ៉ាំងបឋមឈានឲ្យកើត ។ គីលៀងរវល់តែទៅក្នុងចន្លោះរោងអាហារឃឹតបន្តិច ស្រមោលរបស់ដើមឈើដទៃ ក៏ជះទិតវិកិលទៅ តែស្រមោលរបស់ដើមឈើនោះ តាំងនៅជាបរិមណ្ឌល ។ គីលៀងគិតថា ព្រះរាជបុត្រនៅមួយព្រះអង្គឯង ប្រញាប់លើកវាំងននឡើង ចូលទៅខាងក្នុង ឃើញព្រះពោធិសត្វប្រថាប់អង្គុយពែនភ្នែនសមាធិលើទីផ្ទំ និងឃើញបាដិហារ្យនោះហើយ ទើបទៅក្រាបទូលព្រះរាជាថា បពិត្រព្រះរាជា ព្រះកុមារ

ប្រថាប់យ៉ាងនេះ ម្លប់របស់ដើមឈើដទៃ វិតរំកិលទៅ តែម្លប់ដើមព្រីងតាំង នៅជាបរិមណ្ឌល ព្រះរាជាស្តេចទៅដោយរហ័ស ទ្រង់ឃើញបាដិហារ្យ ទ្រង់សំពះព្រះឱរសដោយព្រះតម្រាស់ថា នេះជាការសំពះកូនជាលើកទីពីរ ។ បទថា **បិតុ សក្កស្ស កម្មន្តេ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតា** នេះ លោកពោលសំដៅយកពាក្យនេះ ។ បទថា **សិយា នុ ខោ ឯសោ មគ្គោ ពោធាយ** សេចក្តីថា អានាបានស្សតិបឋមឈាននេះ នឹងជាផ្លូវដើម្បីប្រយោជន៍នៃការត្រាស់ដឹងហ្ន៎ ។ បទថា **សតានុសារិវិញ្ញាណំ** សេចក្តីថា វិញ្ញាណដែលកើតឡើងក្នុងលំដាប់នៃសតិ ដែលកើត ១-២ ដង យ៉ាងនេះថា ការធ្វើវត្តដែលធ្វើបានលំបាកនេះ នឹងមិនជាផ្លូវដើម្បីការត្រាស់ដឹង តែអានាបានស្សតិបឋមជ្ឈាននឹងជាការពិត ឈ្មោះថា **សតានុសារិវិញ្ញាណ** ។ បទថា **យំ តំ សុខំ** បានដល់ សេចក្តីសុខក្នុងអានាបានស្សតិបឋមជ្ឈាន ។

[៦៦] បទថា **បច្ចុបដ្ឋិតា ហោន្តិ** សេចក្តីថា បម្រុងដោយការធ្វើវត្តមានការបោសបរិវេណបណ្ណសាលាជាដើម ។ បទថា **ពាហុល្លិកោ** គឺ ប្រាថ្នាច្រើនក្នុងបច្ច័យ ។ បទថា **អាវត្តោ ពាហុល្លាយ** សេចក្តីថា ជាអ្នកជាប់ក្នុងរស វិលមកដើម្បីត្រូវការអាហារដែលប្រណីតជាដើម ។ បទថា **និព្វិជ្ជ បក្កមឹសុ** ពួកបញ្ចវគ្គិយនឿយណាយចៀសទៅ ដោយធម្មនិយាម អធិប្បាយថា

ទៅតាមធម្មតា ដើម្បីឲ្យឱកាសដល់ព្រះពោធិសត្វបានកាយវិវេក ក្នុងកាលសម្រេចព្រះសម្ពោធិញ្ញាណ នឹងកាលទៅ ក៏មិនទៅកាន់ទីដទៃ បានទៅក្រុងពារាណសីនោះឯង ។ កាលបញ្ចវគ្គិយទៅហើយ ព្រះពោធិសត្វបានកាយវិវេករហូតអស់កន្លះខែ ប្រថាប់គង់លើអបរាជិតបល្ល័ង្កក្នុងពោធិមណ្ឌល ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ។

[៦៧] បទមានពាក្យជាដើមថា ***វិវិច្ចេវ កាមេហិ*** គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងភយភេរវសូត្រ ។

[៧០] បទថា ***អភិជានាមិ ខោ បនាហំ*** គឺ នេះជាអនុសន្ធិមួយផ្នែក ។ បានឮថា និគ្រន្ថ គិតថា យើងទូលសួរបញ្ហាមួយប្រការចំពោះសមណគោតម ព្រះសមណគោតមត្រាស់ថា ម្នាលអគ្គិវេស្សនៈ ទេវតាសូម្បីដទៃទៀត សួរតថាគត ម្នាលអគ្គិវេស្សនៈ ទេវតាសូម្បីដទៃទៀតសួរតថាគត កាលទ្រង់មិនឃើញទីបំផុតត្រាស់យ៉ាងនោះ ព្រះអង្គមានសេចក្ដីក្រេវក្រោធឬ លំដាប់នោះព្រះមានព្រះភាគត្រាស់ថា អគ្គិវេស្សនៈ កាលតថាគតសម្ដែងធម៌នៅក្នុងពួកបរិស័ទច្រើនរយ សូម្បីតែម្នាក់ដែលនឹងពោលថា ព្រះសមណគោតមក្រេវក្រោធហើយមិនមាន ម្យ៉ាងទៀត តថាគតសម្ដែងធម៌ដល់ជនពួកដទៃ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង ដើម្បីប្រយោជន៍ដល់ការចាក់ធ្លុះ កាលទ្រង់សម្ដែងធម៌ ទើប

ផ្តើមព្រះធម៌ទេសនានេះ ។ បណ្តាបទទាំងនោះ បទថា **អារព្ភ** គឺ ប្រារព្ធយក ។ បទថា **យាវទេវ** គឺ ជាពាក្យកំណត់វិធីប្រើ មានអធិប្បាយថា ការញុំាងបុគ្គលពួកដទៃឲ្យដឹងនោះឯង ជាការប្រកបព្រះធម៌ទេសនារបស់ព្រះតថាគត ព្រោះដូច្នោះ ទើបព្រះតថាគតមិនបានសម្តែងធម៌ដល់បុគ្គលតែមួយនាក់ ទ្រង់សម្តែងធម៌ដល់បុគ្គលដែលដឹង ដែលនៅទាំងអស់ ព្រះមានព្រះភាគទ្រង់សម្តែងដោយបទថា **តស្មឹ យេវបុរិមស្មឹ** នេះ ទុកយ៉ាងណា បានឮថា សច្ចកនិគ្រន្ថ គិតថា ព្រះសមណគោតម មានព្រះរូបកាយស្អាត គួរស្រឡាញ់ ព្រះទន្តរាបស្មើស្និទ្ធ ព្រះជិវ្ហាទន់ ការសន្ទនាក៏ពីរោះ ឃើញហើយ ក៏ញុំាងបរិស័ទឲ្យត្រេកអរ ។ ចំណែកព្រះឯកគ្គតាចិត្ត របស់ព្រះសមណគោតមនោះ មិនមានដល់ព្រះអង្គលំដាប់នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដើម្បីទ្រង់សម្តែងថា ម្នាលអគ្គិវេស្សនៈ ព្រះតថាគតនឹងញុំាងបរិស័ទឲ្យត្រេកអរ ព្រះតថាគតទ្រង់សម្តែងធម៌ដល់បរិស័ទទូទៅទាំងចក្រវាឡ ព្រះតថាគតមានព្រះទ័យមិនរួញរា មិនប្រលាក់ប្រកបរឿយៗ នូវផលសមាបត្តិជាសុញ្ញតៈ ជាធម៌ជាគ្រឿងនៅតែម្យ៉ាង ប្រមាណប៉ុណ្ណោះ ដូច្នេះ ។ បទថា **អជ្ឈត្តំ** បានដល់ អារម្មណ៍ដែលជាខាងក្នុងប៉ុណ្ណោះ បទថា **សន្និសីទាមិ** គឺ ញុំាងចិត្តឲ្យស្ងប់ ។ ពិតណាស់ ក្នុងខណៈណា បរិស័ទរមែងឲ្យសាធុការ ក្នុងខណៈនោះ ព្រះតថាគតទ្រង់កំណត់ចំណែកខាង

ដើម ទ្រង់ចូលផលសមាបត្តិ កាលសំឡេងគឹកកងនៃសាធុការមិនទាន់បាត់ ក៏ចេញចាកសមាបត្តិ សម្ដែងធម៌តាំងពីដែលព្រះអង្គទ្រង់តាំងទុកហើយ ។ ដោយសេចក្ដីថា ការនៅក្នុងភវង្គរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រព្រឹត្តទៅឆាប់រហ័ស រមែងចូលផលសមាបត្តិបានក្នុងពេលដកដង្ហើមចូល ក្នុងពេលដកដង្ហើមចេញ ។ បទថា **យេន សុទំ និច្ចកប្បំ** សេចក្ដីថា តថាគតនៅដោយផលសមាធិដែលជាសុញ្ញតៈ បានរហូតអស់កាលជានិច្ច គឺ សម្ដែងថា តថាគតតម្កល់ចិត្ត តាំងមាំក្នុងសមាធិនិមិត្តនោះ ។ បទថា **ឱកប្បនិយមេតំ** នោះជាទីតាំងនៃការជឿ ។

សច្ចកៈនោះទូលថា ព្រះមានព្រះភាគ ជាអ្នកមានឯកគ្គតាចិត្ត ឥឡូវនេះ កាលនឹងនាំបញ្ហាដែលខ្ញុំលាក់ទុកមកទូលសួរ ទើបពោលថា **អភិជានាតិ បន ភវំ គោតមោ ទិវា សុបិតា** ។ ដូចសេចក្ដីថា ដែលឈ្មោះថា សុនខសូម្បីស៊ីអាហារបាយបាយាស ដែលជាំដោយទឹកដោះ ផ្សំដោយទឹកដោះថ្លាដរាបពេញពោះ ឃើញលាមកហើយ ស៊ីមិនបាន ក៏មិនអាចដើម្បីនឹងទៅ កាលទំពារស៊ីមិនបាន ក៏នឹងហិតក្លិនមុនទើបទៅ បានឮថា កាលវាមិនបានហិតក្លិនហើយទៅ ក៏ឈឺចុកចាប់ក្បាល យ៉ាងណា ព្រះសាស្ដាក៏យ៉ាងនោះដែរ ទ្រង់សម្ដែងធម៌ជាទីតាំងនៃសេចក្ដីជ្រះថ្លា តាំងពីការស្ដេចចេញមហាភិនេស្រ្កមន៍

រហូតដល់ការអស់ទៅនៃអាសវៈ ដូចទឹងសុនខឃើញបាយាស ដែលគេដាំដោយទឹកដោះសុទ្ធ ចំណែកសច្ចកៈនោះ ស្តាប់ព្រះធម៌ទេសនាបែបនេះ ក៏មិនកើតសូម្បីត្រឹមតែសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ព្រោះដូច្នោះ កាលគេមិនទូលសួរបញ្ហាដែលខ្លួនលាក់ទុកនាំមក ក៏មិនអាចដើម្បីទឹងទៅ ទើបបានពោលយ៉ាងនោះ ។ កាលដូច្នោះ ព្រោះបីនមិទ្ធៈ ដែលព្រះទីណាស្រពទាំងពួង លះបានដោយអរហត្តមគ្គ ។ ក៏សេចក្តីខ្វល់ខ្វាយផ្លូវកាយ រមែងមានក្នុងឧបាទិន្នករូបខ្លះ ក្នុងអនុបាទិន្នករូបខ្លះ ។ ពិតហើយ ផ្កាឈូកសជាដើម រីកក្នុងវេលាមួយក្តោបក្នុងវេលាមួយ ក្នុងវេលាល្ងាចក្តោប ក្នុងវេលាព្រឹកក៏រីក ។ ឧបាទិន្នករូបប៉ុណ្ណោះ មានសេចក្តីក្រវល់ក្រវាយ ក៏ភវង្គសោត ដែលប្រព្រឹត្តទៅដោយសេចក្តីខ្វល់ខ្វាយ លោកបំណងថា លក់ក្នុងទីនេះ ។ ភវង្គនោះសោត មានដល់ព្រះទីណាស្រព សំដៅយកការដេកលក់នោះ ទើបពោលពាក្យជាដើមថា **អភិជានាមហំ** ។ បទថា **សម្មោហវិហារស្មឹ វទន្តិ** អាចារ្យពួកខ្លះពោលថា **សម្មោហវិហារោ** ប្រែថា នៅដោយសេចក្តីវង្វេង ។

[៧២] បទថា **អាសជ្ជ អាសជ្ជ** គឺ ចាក់ដោតៗ បទថា **ឧបនីតេហិ** គឺ ដែលខ្លួននាំមកពោល បទថា **វចនបថេហិ** ប្រែថា ពាក្យ ។ បទថា **អភិនន្ទិត្វា** សេចក្តីថា ត្រេកអរទទួលដោយចិត្ត អនុមោទនាសរសើរដោយពាក្យ ។

ព្រះមានព្រះភាគត្រាស់ ២ ព្រះសូត្រនេះ ដល់និគ្រន្ថនេះ ។ ព្រះសូត្រដើម មានភាណវារៈតែមួយ ព្រះសូត្រនេះ មានភាណវារៈកន្លះ សួរថា និគ្រន្ថនេះ សូម្បីស្តាប់ ២ ភាណវារៈកន្លះហើយ មិនទាន់សម្រេចធម្មាភិសម័យ នៅមិនបួស មិនទាន់តាំងនៅក្នុងសរណៈ ដូច្នេះហើយ ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់សម្តែងធម៌ដល់គេទៀត ឆ្លើយថា ដើម្បីជាវាសនាក្នុងអនាគត ។ ពិតណាស់ ព្រះមានព្រះភាគទ្រង់ឃើញថា ឥឡូវនេះ ឧបនិស្ស័យរបស់និគ្រន្ថនេះ មិនទាន់មាន តែកាលតថាគតបរិនិព្វានកន្លងទៅបាន ២០០ ឆ្នាំសេស សាសនានឹងប្រតិស្ឋានទៅតម្ពបណ្ណិទ្វីប និគ្រន្ថនេះ នឹងកើតក្នុងផ្ទះមានត្រកូលក្នុងតម្ព-បណ្ណិទ្វីបនោះ បួសក្នុងវេលាដល់ព្រមហើយ រៀនព្រះត្រៃបិដក ចម្រើនវិបស្សនា សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ជាព្រះមហាខីណាស្រព ឈ្មោះថា **កាលពុទ្ធរក្ខិត** ព្រះមានព្រះភាគទ្រង់ឃើញហេតុនេះ ទើបទ្រង់សម្តែងធម៌ដើម្បីជាវាសនាក្នុងអនាគត ។

កាលព្រះសាសនាប្រតិស្ឋានក្នុងតម្ពបណ្ណិទ្វីបនោះ សច្ចកៈនោះ ឃ្លាតចាកទេវលោកកើតក្នុងត្រកូលនៃអមាត្យមួយ ។ ក្នុងស្រុកសម្រាប់ភិក្ខាចារនៃទក្ខិណាគិរិវិហារ បព្វជ្ជាក្នុងវេលាជាកម្លោះ បានរៀនព្រះត្រៃបិដក គឺ ព្រះពុទ្ធវចនៈ បរិហារគណៈ ពួកភិក្ខុជាច្រើនហែហមទៅ ដើម្បីនឹងសួរសុខទុក្ខ

ព្រះឧបជ្ឈាយ៍ លំដាប់នោះ ឧបជ្ឈាយ៍របស់លោកគិតថា យើងនឹងសួរសិទ្ធិ-វិហារិក ទើបបបួញមាត់នឹងភិក្ខុនោះ អ្នករៀនព្រះត្រៃបិដក គឺ ព្រះពុទ្ធវចនៈមកហើយ មិនបានសួម្បីត្រឹមតែការនិយាយ ភិក្ខុនោះក្រោកឡើងក្នុងវេលាជិតភ្លឺ ទៅសម្នាក់ព្រះថេរៈ សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំធ្វើគន្ថកម្មមកក្នុងសម្នាក់របស់លោកម្ចាស់ ហេតុអ្វីលោកទើបបបួញមាត់មិននិយាយខ្ញុំមានទោសអ្វីឬ ។ ព្រះថេរៈពោលថា លោកម្ចាស់ពុទ្ធរក្ខិត លោកធ្វើសេចក្តីសម្គាល់ថា ឈ្មោះថា បព្វជ្ជាកិច្ចរបស់យើងដល់ទីបំផុតហើយ ដោយគន្ថកម្មប្រមាណប៉ុណ្ណេះឬ ពុទ្ធរក្ខិត ។ ខ្ញុំករុណានឹងធ្វើអ្វីហ្ន៎ លោកម្ចាស់ ។ ព្រះថេរៈពោលថា លោកចូរលះបង់គណៈ កាត់បបញ្ចធម៌ ទៅកាន់ចេតិយបព៌តវិហារធ្វើសមណធម៌ចុះ ។ លោកតាំងនៅ ក្នុងឱវាទរបស់ព្រះឧបជ្ឈាយ៍ ធ្វើដូច្នោះទើបសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ជាអ្នកមានបុណ្យ ព្រះរាជាទ្រង់បូជា មានពួកភិក្ខុជាច្រើនជាបរិវារ នៅក្នុងចេតិយបព៌តវិហារ ។

ក៏ក្នុងកាលនោះ ព្រះបាទតិស្សមហារាជ ទ្រង់រក្សាឧបោសថកម្ម រមែងនៅក្នុងទីពួនសម្ងំរបស់ព្រះរាជា ក្នុងចេតិយបព៌ត លោកបានឲ្យសញ្ញាដល់ភិក្ខុជាឧបដ្ឋាករបស់ព្រះថេរៈថា កាលណាលោកម្ចាស់របស់យើង បំណងនឹងដោះស្រាយបញ្ហា ឬពោលធម៌ កាលនោះលោកគប្បីឲ្យសញ្ញាដល់យើងផង ។

ក្នុងថ្ងៃធម្មស្សវនៈមួយ សូម្បីព្រះថេរៈ ដែលពួកភិក្ខុហែហម ឡើងកាន់លានកណ្តកចេតិយ៍ ថ្វាយបង្គំព្រះចេតិយហើយ ទើបឈរជិតគល់ដើមទន្ទាប់ខ្មៅ ។ គ្រានោះ ព្រះថេរៈសមាទានបិណ្ឌបាតជាវត្តមួយរូប សួរបញ្ហានឹងព្រះពុទ្ធរក្ខិត ក្នុងកាលាមសូត្រ ។ ព្រះថេរៈពោលថា ម្នាលអ្នកដ៏មានអាយុ ថ្ងៃនេះជាថ្ងៃធម្មស្សវនៈ មិនមែនឬ ។ ភិក្ខុនោះ ឆ្លើយប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះជាថ្ងៃធម្មស្សវនៈ ព្រះករុណា ។ ព្រះថេរៈពោលថា បើដូច្នោះលោកចូរនាំយកតាំងមក យើងនឹងអង្គុយក្នុងទីនេះ ហើយនឹងធ្វើការស្តាប់ធម៌ ។ លំដាប់នោះ ពួកភិក្ខុទើបក្រាលអាសនៈត្រង់គល់ឈើ ថ្វាយព្រះថេរៈនោះ ។ ព្រះថេរៈពោលគាថាខាងដើមហើយ ទើបផ្តើមកាលាមសូត្រ ។ ភិក្ខុកម្លោះជាឧបដ្ឋាកព្រះថេរៈនោះ ទើបឲ្យសញ្ញាដល់ព្រះរាជា ព្រះរាជាស្តេចទៅដល់ ក្នុងកាលគាថាខាងដើមមិនទាន់ចប់ ក៏កាលស្តេចយាងដល់ ប្រថាប់ឈរខាងក្រោយបរិស័ទដោយភេទដែលមិនមានអ្នកណាស្គាល់ឡើយ ទ្រង់ប្រថាប់ឈរស្តាប់ធម៌រហូតអស់ ៣ យាម បានប្រទានសាធុការ ក្នុងវេលាព្រះថេរៈពោលថាព្រះមានព្រះភាគ បានត្រាស់ពាក្យនេះ ដូច្នេះ ។ ព្រះថេរៈជ្រាបហើយ ទើបសួរថា មហាបពិត្រ ព្រះអង្គស្តេចមកពីពេលណា ។ ព្រះរាជា, បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងវេលាជិតនឹងចប់គាថាខាងដើមនុ៎ះឯង ។ ព្រះថេរៈ, មហា-

បពិត្រ ព្រះអង្គទ្រង់ធ្វើកម្មដែលធ្វើបានលំបាក ។ ព្រះរាជា, បពិត្រលោកម្ចាស់ដ៏ចម្រើន នេះមិនឈ្មោះថា ធ្វើវត្តដែលធ្វើបានលំបាកទេ សេចក្តីដែលខ្ញុំព្រះករុណាមិនបញ្ជូនចិត្តទៅក្នុងទីដទៃ សូម្បីក្នុងមួយបទ តាំងពីវេលាដែលលោកម្ចាស់ផ្តើមធម្មកថា បានធ្វើបដិញ្ញាណថា ឈ្មោះថា ភាពជាម្ចាស់របស់របស់យើងចូរកុំមានដល់តម្ពបណ្ណិទ្វីប ក្នុងទីសូម្បីត្រឹមតែការចាក់ដោយឈើជន្លួញ ដូច្នេះ ។

ក៏ក្នុងព្រះសូត្រនេះ ភិក្ខុកាលពុទ្ធរក្ខិតៈ បានសម្តែងព្រះពុទ្ធគុណទាំងឡាយ ព្រោះដូច្នោះ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះពុទ្ធគុណមានប្រមាណប៉ុណ្ណេះឬ ឬថាយ៉ាងដទៃនៅមាននៅទៀត ។ ព្រះថេរៈ, មហាបពិត្រ ព្រះពុទ្ធគុណដែលមិនទាន់បានពោល មានច្រើនជាងដែលអាត្មាពោល ប្រមាណមិនបាន ។ ព្រះរាជា, បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ឧបមា ។ ព្រះថេរៈ, មហាបពិត្រ ស្រូវសាលីដ៏សេសមានច្រើនជាងក្អួរស្រូវសាលីមួយក្អួរ ក្នុងស្រែស្រូវសាលី ប្រមាណពាន់ករីសៈ យ៉ាងណា ព្រះគុណដែលអាត្មាពោលហើយ តិចណាស់ ដ៏សេសមានច្រើន ដូច្នោះ ។ ព្រះរាជា, បពិត្រលោកម្ចាស់ដ៏ចម្រើន សូមធ្វើឧបមាទៀត ។ ព្រះថេរៈ, មហាបពិត្រ មហាគង្គាពេញដោយអន្លង់ទឹក បុគ្គលគប្បីចាក់ដាក់ក្នុងវន្ធម្ជុល ទឹក

ដែលចូលទៅក្នុងរន្ធម្ជុលមានតិច ទឹកដ៏សេសមានច្រើន យ៉ាងណា ព្រះគុណដែលអាត្មាពោលហើយតិច ដ៏សេសច្រើន ដូច្នោះ ។ ព្រះរាជា, បពិត្រលោកម្ចាស់ដ៏ចម្រើន ចូរធ្វើឧបមាទៀត ។ ព្រះថេរៈ, មហាបពិត្រ ធម្មតាថា សត្វលេងខ្យល់ ត្រាច់ហើរលេងក្នុងអាកាសក្នុងលោកនេះ សកុណជាតិខ្លួនតូចៗ ទឹកន្លែងដែលទទះស្លាបរបស់សត្វនោះ ក្នុងអាកាសមានច្រើន ឬអាកាសដ៏សេសមានច្រើន ។ ព្រះរាជា, បពិត្រលោកម្ចាស់ដ៏ចម្រើន លោកពោលអ្វី ឱកាសជាទីទទះស្លាបរបស់សត្វនោះតិច ដ៏សេសមានច្រើន ព្រះថេរៈ, មហាបពិត្រ យ៉ាងនោះឯង ព្រះពុទ្ធគុណដែលអាត្មាពោលហើយតិច ដ៏សេសច្រើនមិនមានទីបំផុត ប្រមាណមិនបាន ។ ព្រះរាជា, បពិត្រលោកម្ចាស់ដ៏ចម្រើន លោកពោលល្អហើយ ព្រះពុទ្ធគុណមិនមានទីបំផុត លោកឧបមាដោយអាកាស មិនមានទីបំផុតនុ៎ះឯង ពួកខ្ញុំព្រះករុណាជ្រះថ្លា តែមិនអាចនឹងធ្វើសក្ការៈដ៏សមគួរដល់លោកម្ចាស់បាន ។ ខ្ញុំព្រះករុណា សូមថ្វាយរាជសម្បត្តិ ប្រកបដោយរយោជន៍ក្នុងតម្ពបណ្ណិទីបនេះ ដល់លោកម្ចាស់ នេះជាទុគតបណ្ណាការរបស់ខ្ញុំ ។ ព្រះថេរៈ, មហាបពិត្រ បណ្ណាការដែលមហាបពិត្រទ្រង់ជ្រះថ្លាធ្វើហើយ អាត្មាសូមថ្វាយរាជសម្បត្តិ ដែលទ្រង់ថ្វាយដល់អាត្មា គឺ ដល់មហាបពិត្រទាំងអស់របស់មហាបពិត្រ ចូរទ្រង់គ្រប់គ្រងព្រំដែនដោយធម៌ ដោយស្មើចុះ ដូច្នេះ

ឯង ៗ

( ចប់ អដ្ឋកថា មហាសច្ចកសូត្រទី ៦ )

# អ ដ្ឋ ក ថា

## ចូឡតណ្ហាសង្ខយសូត្រ ទី ៧

[៧៣] *ចូឡតណ្ហាសង្ខយសូត្រ មានបទផ្តើមថា* ***ឯវម្មេ សុតំ*** *។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ ក្នុងប្រការថា* ***បុព្វារាមេ មិគារ-មាតុបាសាទេ*** *បានដល់ ប្រាសាទរបស់មិគារមាតាក្នុងវិហារ ឈ្មោះថា* ***បុព្វារាម*** *។ ក្នុងសេចក្តីនោះ មានការពណ៌នាសេចក្តីតាមលំដាប់ដូចតទៅនេះ ៖*

*គ្រាអតីតកាល ក្នុងទីបំផុតនៃសែនកប្ប មានឧបាសិកាម្នាក់ និមន្តព្រះមានព្រះភាគ ព្រះនាមថា* ***បទុមុត្តរៈ*** *ហើយថ្វាយទានដល់ភិក្ខុសង្ឃមួយសែន មានព្រះពុទ្ធជាប្រធាន ហើយក្រាបចុះជិតព្រះយុគលបាទព្រះមានព្រះភាគ ធ្វើការប្រាថ្នាថា ក្នុងអនាគតកាល សូមឲ្យខ្ញុំជាអគ្គឧបដ្ឋាយិការបស់ព្រះពុទ្ធ ដូចនឹងព្រះអង្គ ដូច្នេះ ។ គេអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយអស់សែននៃកប្ប ហើយបានបដិសន្ធិក្នុងគភ៌របស់នាងសុមនទេវី ក្នុងផ្ទះសេដ្ឋីដែលជាបុត្ររបស់មេណ្ឌកៈ ក្នុងភទ្ទិយនគរ ក្នុងកាលនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ ។ ក្នុងវេលាប្រសូត ពួកញាតិបានតាំងឈ្មោះគេថា* ***វិសាខា*** *។ កាលព្រះមានព្រះភាគ ស្តេចបានទៅកាន់ភទ្ទិយនគរ នាងវិសាខានោះព្រមដោយពួក*

ទារិកា ៥០០ បានធ្វើការទទួលព្រះមានព្រះភាគ ហើយបានជាព្រះសោតាបន្ន ក្នុងការឃើញគ្រាដំបូងនោះឯង ។ ក្នុងកាលដទៃទៀត នាងទៅកាន់ផ្ទះរបស់ បុណ្ណវឌ្ឍនកុមារ បុត្រមិគារសេដ្ឋីក្នុងនគរសាវត្ថី ក្នុងទីនោះមិគារសេដ្ឋីបាន តាំងនាងទុកក្នុងតំណែងនៃមាតា ព្រោះដូច្នោះ ទើបហៅថា **មិគារមាតា** ។ ក៏ កាលនាងនឹងទៅកាន់ត្រកូលស្វាមី បិតារបស់នាង បានឲ្យធ្វើគ្រឿងប្រដាប់ ឈ្មោះថា មហាលតាឲ្យ ។ គ្រឿងប្រដាប់នោះប្រកបទុកដោយពេជ្រ ៤ នាឡិ កែវមុក្តា ១១ នាឡិ កែវប្រវាឡ ២២ នាឡិ កែវមណី ៣៣ នាឡិ គ្រឿង ប្រដាប់នោះសម្រេចហើយដោយរតនៈទាំងនេះ និងដោយរតនៈដទៃមានវណ្ណៈ ៧ ដោយប្រការដូច្នេះ ។ គ្រឿងប្រដាប់នោះ ពាក់សិរសៈវែងហៀរធ្លាក់ទៅ ដល់ខ្នងជើង ។ ក៏ស្រីអ្នកមានកម្លាំងស្មើដំរី ៥ ទើបអាចប្រដាប់បាន គ្រាតមក នាងបានជាអគ្គឧបដ្ឋាយិការបស់ព្រះទសពល លះបង់គ្រឿងប្រដាប់នោះ សាងវិហារថ្វាយព្រះមានព្រះភាគ ដោយទ្រព្យ ៩ កោដិ ឲ្យធ្វើប្រាសាទផ្ទៃដី ប្រមាណមួយករីសៈ ។ ប្រដាប់ដោយបន្ទប់មួយពាន់ គឺ ជាន់លើរបស់ប្រាសាទ នោះ មាន ៥០០ បន្ទប់ ជាន់ក្រោមមាន ៥០០ បន្ទប់ ។ នាងវិសាខានោះគិត ថា ប្រាសាទសុទ្ធៗ តែម្យ៉ាង រមែងមិនល្អ ទើបសាងផ្ទះទ្វិកូដៈ ៥០០ ចូឡ ប្រាសាទ ៥០០ បន្ទប់ ។ សាលាទីឃរៈ ៥០០ ហែហមប្រាសាទធំនោះ បាន

ធ្វើការឆ្លងវិហារ ៤ ខែ ។

ឈ្មោះថា ការបរិច្ចាគទ្រព្យ ក្នុងព្រះពុទ្ធសាសនារបស់ស្ត្រីដទៃដូចនាង វិសាខា អ្នកតាំងនៅក្នុងអត្តភាពនៃមាតុគ្រាម មិនមាន ។ ឈ្មោះថា ការបរិច្ចាគទ្រព្យទុកក្នុងព្រះពុទ្ធសាសនារបស់បុគ្គលដទៃដូចអនាថបិណ្ឌិកសេដ្ឋី ដែលតាំងនៅក្នុងអត្តភាពនៃបុរស ក៏មិនមាន ។ ពិតណាស់ អនាថបិណ្ឌិកសេដ្ឋីនោះលះបង់ទ្រព្យ ៥៤ កោដិ សាងមហាវិហារឈ្មោះថា **ជេតពន** ដូចនឹងមហាវិហាររបស់អនុរាធបុរី ក្នុងទីចំណែកដែលមានក្នុងទិសទក្សិណនៃព្រះនគរសាវត្ថី ។ នាងវិសាខា សាងវិហារឈ្មោះថា **បុព្វារាម** ក្នុងទីដូចនឹងទេវវិមាន ដ៏ប្រសើរក្នុងចំណែកនៃទិសបស្ចឹមនៃព្រះនគរសាវត្ថី ។ ព្រះមានព្រះភាគ អាស្រ័យព្រះនគរសាវត្ថី ប្រថាប់នៅដើម្បីអនុគ្រោះត្រកូលទាំងពីរនេះ ទើបបានប្រថាប់នៅក្នុងប្រាសាទទាំងពីរនេះជាប់ជានិច្ច គឺ ខាងក្នុងវស្សាមួយ ប្រថាប់នៅក្នុងវត្តជេតពន វស្សាមួយប្រថាប់នៅក្នុងបុព្វារាម ។ តែក្នុងសម័យនោះ ប្រថាប់នៅក្នុងបុព្វារាម ។ ព្រោះហេតុនោះ លោកទើបពោលថា **បុព្វា រាមេ មិគារមាតុ បាសាទេ** ដូច្នេះ ។

បទថា **កិត្តាវតា នុខោ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ដោយវត្តបដិបត្តិត្រឹមតែប៉ុនណា ។ បទថា **សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ**

**ហោតិ** សេចក្តីថា ពោលសង្ខេបដោយវត្តបដិបត្តិត្រឹមតែប៉ុនណា ឈ្មោះថាបង្អោនទៅក្នុងធម៌ជាទីអស់តណ្ហា ព្រោះសេចក្តីដែលភិក្ខុនោះមានចិត្តបង្អោនទៅ ធ្វើវត្តបដិបត្តិនោះឲ្យប្រព្រឹត្តទៅក្នុងអារម្មណ៍និព្វាន ដែលជាទីអស់ទៅនៃតណ្ហានោះ គឺថា ស្តេចសក្កទេវរាជទូលថា សូមព្រះអង្គសម្តែងបដិបទា ដែលជាចំណែកខាងដើមរបស់ភិក្ខុដែលមានអាសវៈនោះឯង ដោយវត្តបដិបត្តិដោយសង្ខេប ដែលបង្អោនទៅដើម្បីការអស់តណ្ហា ។ បទថា **អច្ចន្តនិដ្ឋោ** សេចក្តីថា ឈានកន្លង ពោលគឺ ការអស់ និងការវិនាស ឈ្មោះថា **អច្ចន្តនិដ្ឋ** ព្រោះមានសេចក្តីសម្រេចដោយការឈានកន្លងចំណែកៗ អធិប្បាយថា សម្រេចការឈានកន្លងចំណែក គឺ សម្រេចរឿយៗ ។

បទថា **អច្ចន្តយោគក្ខេមី** សេចក្តីថា មានការរួចផុតចាកកិលេសជាគ្រឿងប្រកបកន្លងចំណែករឿយៗ ។ បទថា **អច្ចន្តព្រហ្មចារី** បានដល់ ជាព្រហ្មចារីជានិច្ច ។

ឈ្មោះថា **អច្ចន្តបរិយោសាន** ដោយន័យមុន ព្រោះបញ្ចប់នូវការឈានកន្លងចំណែក ។ បទថា **សេដ្ឋោ ទេវមនុស្សានំ** បានដល់ ប្រសើរបំផុត គឺខ្ពស់បំផុតជាងទេវតា និងមនុស្សទាំងឡាយ ។ អធិប្បាយថា ស្តេចសក្កទេវរាជរមែងទូលសូមព្រះមានព្រះភាគថា ភិក្ខុបែបនេះ រមែងជាអ្នកមានវត្តបដិបត្តិ

ដោយវត្តបដិបត្តិដូចម្ដេច ។ សូមព្រះអង្គត្រាស់ប្រាប់វត្តបដិបត្តិដោយសង្ខេប របស់ភិក្ខុនោះ ដោយឆាប់រហ័សចុះ ។ សួរថា ក៏ព្រោះហេតុអ្វី ស្ដេចសក្ក- ទេវរាជនោះ ទើបប្រាថ្នាសេចក្ដីប្រញាប់ប្រញាល់យ៉ាងនោះ ។ ឆ្លើយថា ព្រោះ ទ្រង់ប្រាថ្នានឹងទៅលេងកីឡា ។ បានឮថា ស្ដេចសក្កទេវរាជនោះ ត្រាស់បង្គាប់ ការលេងកីឡាក្នុងឧទ្យានហើយ ឲ្យមហារាជទាំង ៤ រក្សាក្នុង ៤ ទិស អ្នក ដែលពួកទេវហែហមហើយ ទេវលោកទាំងពីរ ទ្រង់ប្រថាប់លើដំរីឰរាវណ នឹងនាងទេពអប្សរ ២ កោដិ កន្លះ ប្រថាប់នៅត្រង់ទ្វារឧទ្យាន កំណត់បញ្ហា នេះថា បដិបទាដែលជាចំណែកខាងដើមដែលបុគ្គលគប្បីសម្រេច របស់ព្រះ ខីណាស្រពអ្នកបង្អោនទៅក្នុងធម៌ជាទីអស់តណ្ហា ដោយសង្ខេបមានដូចម្ដេច ហ្ន៎ ។ ពេលនោះ ស្ដេច បានមានសេចក្ដីត្រិះរិះថា បញ្ហានេះប្រព្រឹត្តទៅមួយ អន្លើដោយសិរីក្រៃលែងណាស់ បើយើងមិនបានរៀនយកបញ្ហានេះហើយ ។ នឹងចូលទៅកាន់ឧទ្យានសោត ត្រូវអារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ញាំញី ហើយ នឹងកំណត់បញ្ហានេះទៀតមិនបាន ការលេងកីឡាក្នុងឧទ្យានរៀវទុកសិន ចុះ យើងនឹងទៅកាន់សម្នាក់របស់ព្រះសាស្ដា ទូលសួរបញ្ហានេះ យើងរៀន បញ្ហានេះហើយ នឹងលេងកីឡាក្នុងឧទ្យាន ដូច្នេះ ហើយបាត់ពីទីប្រថាប់ត្រង់ កនៃដំរី បានប្រាកដក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។ ស្ដេចមហារាជទាំង

៤ នោះ ក៏ឈរវេរក្សាក្នុងទីប្រថាប់ត្រង់នោះឯង ពួកទេវអ្នកបម្រើក្ដី នាងទេពអប្សរទាំងឡាយក្ដី ដំរីឰរាវណក្ដី នាគរាជក្ដី បានឈរត្រង់ទ្វារនោះឯង ស្ដេចសក្កទេវរាជនោះ កាលមានសេចក្ដីប្រាថ្នាដោយរហ័ស ដើម្បីប្រាថ្នានឹងលេងកីឡាដោយអាការយ៉ាងនេះ ទើបត្រាស់ហើយយ៉ាងនោះ ។

[៧៤] បទថា ***សព្វេ ធម្មា នាលំ អភិនិវេសាយ*** នេះ អធិប្បាយថា ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឈ្មោះថា ធម៌ទាំងពួង ធម៌សូម្បីទាំងអស់នោះ មិនគួរ គឺ មិនវៀន មិនប្រាថ្នា មិនប្រកបទុកដោយសេចក្ដីប្រកាន់មាំ ដោយអំណាចនៃតណ្ហា និងទិដ្ឋិ ព្រោះហេតុអ្វី ព្រោះមិនតាំងនៅក្នុងអាការដែលបុគ្គលនឹងកាន់យកបាន ។ ពិតណាស់ ធម៌ទាំងឡាយមានខន្ធ ៥ ជាដើមនោះ សូម្បីនឹងសម្គាល់ថា ជារបស់ទៀង សេចក្ដីមិនទៀងប៉ុណ្ណោះ រមែងកើតឡើង សូម្បីនឹងសម្គាល់ថា ជាសុខ សេចក្ដីទុក្ខប៉ុណ្ណោះ រមែងដល់ព្រម សូម្បីនឹងសម្គាល់ថា ជាអត្តា ជាអនត្តាប៉ុណ្ណោះ រមែងប្រាកដ ព្រោះដូច្នោះ បុគ្គលទើបមិនគួរប្រកាន់មាំ ។ បទថា ***អភិជានាតិ*** បានដល់ រមែងជ្រាបច្បាស់ដោយញាតបរិញ្ញាថា មិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា ***បរិជានាតិ*** បានដល់ រមែងកំណត់ដឹងដោយតីរណបរិញ្ញា ដូចយ៉ាងនោះឯង ។ បទថា ***យំ កិញ្ចិ វេទនំ*** បានដល់ សោយវេទនាយ៉ាងណាមួយ សូម្បីមានប្រមាណតិចតួច ដោយទី

បំផុតសូម្បីសម្បយុត្តដោយបញ្ចវិញ្ញាណ ។ ព្រះមានព្រះភាគ រមែងសម្ដែង ការកំណត់អរូបធម៌ ដែលកើតឡើងដោយអំណាចនៃវេទនាដល់ស្ដេចសក្កទេវរាជ ដោយបទនេះ ។ ប្រសិនបើថា វេទនាកម្មដ្ឋាន ជាធម៌ដែលព្រះមានព្រះភាគ មិនបានត្រាស់ទុកក្នុងកាលមុននោះទេ ក៏មិនគួរពោលទុកក្នុងទីនេះ ។ ប៉ុន្តែថា កម្មដ្ឋាននោះ ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងកាលមុន ដូច្នោះ គប្បីជ្រាប វេទនាកម្មដ្ឋាន ដោយន័យដែលពោលទុកហើយក្នុងសតិប្បដ្ឋាន ។

ក្នុងបទថា **អនិច្ចានុបស្សី** នេះ គប្បីជ្រាបថាជា **អនិច្ចំ** ជាអនិច្ចានុបស្សនា និង **អនិច្ចានុបស្សី** ។ ក្នុងទីនេះមានអធិប្បាយថា ក្នុងបណ្ដាបទទាំងនោះ បានដល់ បញ្ចក្ខន្ធ ឈ្មោះថា **អនិច្ចំ** ពិតណាស់ បញ្ចក្ខន្ធទាំងនោះ ឈ្មោះថា ជារបស់មិនទៀង ព្រោះអត្ថថា មានការកើតឡើង និងមានការវិនាសទៅ ។ ការឃើញ ការដឹងបញ្ចក្ខន្ធទាំងឡាយ ដោយការអស់ទៅ សាបសូន្យទៅ ឈ្មោះថា **អនិច្ចានុបស្សនា** ។ បុគ្គលដែលប្រកបដោយញាណនោះ ឈ្មោះថា **អនិច្ចានុបស្សី** ព្រោះដូច្នោះ បទថា **អនិច្ចានុបស្សី វិហរតិ** បានដល់ កាលបុគ្គល តាមឃើញ ដោយសេចក្ដីជារបស់មិនទៀង ។

ក្នុងបទថា **វិរាគានុបស្សី** បានដល់ វិរាគៈ ២ យ៉ាង គឺ **ខយវិរាគ អច្ចន្តវិរាគ** ។ ក្នុងពីរបទនោះ វិបស្សនា ជាគ្រឿងឃើញសង្ខារទាំងឡាយ

ដោយការអស់ទៅ សូន្យទៅ ឈ្មោះថា **ខយវិរាគ** ។ ចំណែកមគ្គញ្ញាណ ជាគ្រឿងឃើញព្រះនិព្វានដែលជាអច្ចន្តវិរាគៈ ដោយវិរាគៈ ឈ្មោះថា **វិរាគានុ-បស្សនា** បុគ្គលដែលប្រកបព្រមដោយវិរាគៈទាំងពីរនោះ ឈ្មោះថា **វិរាគា-នុបស្សី** ។ បទថា **វិរាគានុបស្សី** លោកពោលសំដៅដល់បុគ្គលនោះ អធិប្បាយថា បុគ្គលដែលតាមឃើញហើយដោយសេចក្តីជាវិរាគៈ ។ សូម្បីក្នុងបទថា **និរោធានុបស្សី** ក៏មានន័យនេះដូចគ្នា ។ ពិតណាស់ សូម្បីនិរោធ ក៏មាន ២ យ៉ាងដូចគ្នា គឺ **ខយនិរោធ** និង **អច្ចន្តនិរោធ** ។

**វោសសគ្គ** (ការលះបង់ហើយ) លោកហៅថា ការលះបង់ស្អិទ្ធ ក្នុងបទថា **បដិនិស្សគ្គានុបស្សី** នេះ ។ ក៏វោសសគ្គៈ មាន ២ គឺ បរិច្ចាគវោស-សគ្គៈ បក្ខន្ទនវោសសគ្គៈ ។ ក្នុងពីរយ៉ាងនោះ វិបស្សនា ឈ្មោះថា បរិច្ចាគ-វោសសគ្គៈ ព្រោះថា វិបស្សនានោះ រមែងលះបង់កិលេស និងខន្ធទាំងឡាយដោយអំណាចនៃតទង្គៈ ។ មគ្គ ឈ្មោះថា **បក្ខន្ទនវោសសគ្គ** ព្រោះមគ្គនោះរមែងត្រាច់ទៅកាន់និព្វានដោយអារម្មណ៍ ។ ម្យ៉ាងទៀត ការលះបង់ដោយហេតុសូម្បីទាំងពីរ គឺ ព្រោះការលះខន្ធទាំងឡាយ កិលេសទាំងឡាយដោយអំណាចនៃសមុច្ឆេទ និងព្រោះការស្ទុះទៅក្នុងនិព្វាន ដូច្នោះ ឈ្មោះថា **បរិច្ចាគវោ-សសគ្គ** ព្រោះអត្ថថា លះបង់កិលេសទាំងឡាយ និងខន្ធទាំងឡាយ និរោធ

ឈ្មោះថា **បក្ខន្ទនវោសគ្គ** ព្រោះអត្ថថា ចិត្តរមែងស្ទុះទៅក្នុងនិព្វានធាតុ ។ ទាំងពីរនោះ រមែងស្មើគ្នាក្នុងមគ្គ បុគ្គលដែលប្រកបព្រមដោយវោសសគ្គៈសូម្បីទាំងពីរនោះ ឈ្មោះថា **បដិនិស្សគ្គានុបស្សី** ព្រោះបុគ្គលនោះជាអ្នកប្រកបដោយការឃើញ ដោយការលះបង់ស្និទ្ធនេះ ។ ព្រះមានព្រះភាគ ត្រាស់សំដៅយកពាក្យដែលពោលនោះ ទើបត្រាស់ថា **បដិនិស្សគ្គានុបស្សី** ។

បទថា **ន កិញ្ចិ លោកេ ឧបាទិយតិ** បានដល់ រមែងមិនប្រកាន់មាំ មិនប្រកាន់ មិនស្ទាបអង្អែលធម៌សូម្បីយ៉ាងណាមួយ ដែលដល់ភាពជាសង្ខារដោយអំណាចនៃតណ្ហា រមែងមិនតក់ស្លុត ព្រោះសេចក្តីមិនប្រកាន់មាំ កាលមិនប្រកាន់ ទើបមិនតក់ស្លុត ព្រោះសេចក្តីតក់ស្លុតដោយតណ្ហាទាំងឡាយ រមែងរលត់ទៅចំពោះខ្លួនប៉ុណ្ណោះ ដូច្នោះទើបឈ្មោះថា រមែងរលត់ ដោយការរលត់កិលេសនោះឯង ។ បច្ចវេក្ខណៈរបស់ព្រះខីណាស្រពនោះឯង លោកសម្តែងទុកដោយបទថា **ខីណា ជាតិ** ជាដើម ។ ព្រះមានព្រះភាគ ដែលស្តេចសក្កៈទូលសួរវត្តបដិបត្តិ ដែលជាចំណែកខាងដើមរបស់ព្រះខីណាស្រព ដោយសង្ខេបទ្រង់ធ្វើឲ្យជូរស្រោលព្រះទ័យ ព្រមត្រាស់ឆ្លើយបញ្ហាដោយសង្ខេប ដោយឆាប់រហ័ស ដោយប្រការដូច្នេះ ។

[៧៥] បទថា **អវិទូរេ និសិន្នោ ហោតិ** សេចក្តីថា ព្រះមហាមោគ្គ-

ល្ហានអង្គុយនៅក្នុងកូដាគារបន្ទាប់ទៅ ។ បទថា អភិសមេច្ច បានដល់ មក ដល់ព្រមដោយញាណ អធិប្បាយថា ដឹងហើយ ។ មានអធិប្បាយថា ស្តេច សក្កទេវរាជនោះដឹងបញ្ហាហើយ ទើបត្រេកអរឬ ឬថា មិនដឹងទើបក្រញៀង សិរសៈ ព្រោះហេតុអ្វី ព្រះថេរៈទើបមានការគិតយ៉ាងនេះ បានឮថា ព្រះថេរៈ មិនបានឮសំឡេងដោះស្រាយបញ្ហារបស់ព្រះមានព្រះភាគ តែបានឮសំឡេង អនុមោទនារបស់ស្តេចសក្កទេវរាជថា បពិត្រព្រះមានព្រះភាគ សេចក្តីនោះ ជាយ៉ាងនោះឯង ដូច្នេះ ។ ន័យថា ស្តេចសក្កទេវរាជទ្រង់អនុមោទនា ដោយ សំឡេងដ៏ខ្លាំង ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបមិនបានឮសំឡេង ព្រះមានព្រះភាគ ។ ឆ្លើយថា ព្រោះញុំាងបរិស័ទឲ្យដឹង ។ ពិតណាស់ កាល ព្រះពុទ្ធទាំងឡាយទ្រង់សម្តែងធម៌ហើយ បរិស័ទសូម្បីក្នុងទីបំផុតនៃចក្រវាឡ រមែងបានឮព្រះសូរសេងតែម្យ៉ាង ។ តែហួសពីទីបំផុតនៃបរិស័ទហើយ ព្រះ សូរសេងនឹងមិនផ្សាយទៅក្នុងខាងក្រៅសូម្បីត្រឹមតែមួយអង្គុលី ព្រោះហេតុអ្វី មធុរកថាបែបនេះ មិនមានប្រយោជន៍ ។

គ្រានោះ ព្រះមានព្រះភាគ ប្រថាប់គង់ក្នុងបន្ទប់ដ៏មានសិរី ក្នុងកូដាគារ ដែលសម្រេចហើយដោយកែវ ៧ ប្រការ លើប្រាសាទរបស់មិគារមាតា កូដាគារ ដែលជាទីនៅរបស់ព្រះសារីបុត្តត្ថេរនៅខាងស្តាំ របស់ព្រះមហាមោគ្គល្លានត្ថេរ

នៅខាងក្រៅ មិនមានប្រយោជន៍ជាប់តក្នុងខាងក្នុង ព្រោះហេតុនោះ ព្រះថេរៈទើបមិនបានឮសំឡេងរបស់ព្រះមានព្រះភាគ បានឮតែសំឡេងរបស់ស្តេចសក្កទេវរាជប៉ុណ្ណោះ ។

បទថា **បញ្ចហិ តុរិយសតេហិ** បានដល់ តន្ត្រីប្រកបដោយអង្គ ៥ មានប្រមាណ៥រយ ។ គ្រឿងតន្ត្រីប្រកបដោយអង្គ ៥ ទាំងនេះគឺ **អាតតំ** ស្គរពាសស្បែកតែម្ខាង , **វិតតំ** គឺ សម្ភោរ , **អាតតវិតតំ** គឺ បណ្ឌោះវ៍ , **សុសិរំ** គឺ ប៉ី ឬស័ង្ខជាដើម និង **ឃនំ** គឺ ឆាងជាដើម ឈ្មោះថា តន្ត្រីប្រកបដោយអង្គ ៥ ។ ក្នុងគ្រឿងតន្ត្រីទាំងនោះ ក្នុងបណ្តាស្គរទាំងឡាយ មានស្គរពាសស្បែកតែម្ខាង ឈ្មោះថា អាតតៈ ។ ស្គរដែលពាសស្បែកទាំងពីរខាង ឈ្មោះថា វិតតៈ ។ ស្គដែលពាសដោយស្បែកទាំងអស់ មានបណ្ឌោះវ៍ជាដើម ឈ្មោះថា អាតតវិតតៈ ។ គ្រឿងផ្លុំ មានប៉ីជាដើម ឈ្មោះថា សុសិរៈ ។ ឆាងជាដើម ឈ្មោះថា ឃនៈ ។

បទថា **សមប្បិតោ** បានដល់ ចូលដល់ហើយ ។ បទថា **សមង្គីភូតោ** ជាពាក្យវេវចនៈរបស់ **សមប្បិតោ** នោះឯង ។ បទថា **បរិចារេតិ** បានដល់ សោយហើយនូវសម្បត្តិ ឲ្យបម្រើឥន្ទ្រិយទាំងឡាយ ចាកសមាបត្តិនោះៗ អធិប្បាយថា ការប្រកបដោយតន្ត្រី ៥០០ បម្រើហើយ សោយហើយនូវទិព្វ-

សម្បត្តិ ។ បទថា **បដិបណាមេត្វា** បានដល់ ឲ្យឈប់សិន គឺ ធ្វើមិនឲ្យមានសំឡេងតន្ត្រី ។ ដូចសេចក្ដីថា ក្នុងពេលឥឡូវនេះ ព្រះរាជាទាំងឡាយដែលមានសទ្ធា ទតឃើញភិក្ខុដែលគួរដល់ការគោរព គួរលើកតម្កើង ទើបត្រាស់ថា នុ៎ះ លោកម្ចាស់មកហើយ ពួកអ្នកទាំងឡាយកុំច្រៀង កុំប្រគំតន្ត្រី កុំរាំ ហើយឲ្យវៀរការសម្ដែងចេញ យ៉ាងណា សូម្បីស្ដេចសក្កៈទតឃើញព្រះថេរៈក៏បានធ្វើ ដូច្នោះ ។

បទយ៉ាងនេះថា **ចិរស្សំ ខោ មារិស មោគ្គល្លាន ឥមំ បរិយាយមកាសិ** ជាពាក្យហៅដោយវាចាជាទីស្រឡាញ់ ដោយប្រក្រតីក្នុងលោក ។ ពិតណាស់ មនុស្សលោកឃើញ អ្នកដែលមកយូរហើយខ្លះ មិនធ្លាប់មកខ្លះ មកក្នុងជាតិរបស់អ្នកជាទីស្រឡាញ់ ជាទីពេញចិត្ត នាំគ្នាសួរជាដើមថា លោកមកពីណា លោកមកយូរហើយឬ លោកដឹងផ្លូវមកទីនេះបានយ៉ាងណា លោកវង្វេងផ្លូវមកឬ ។ តែស្ដេចសក្កៈ ក៏ត្រាស់យ៉ាងនេះចំពោះព្រះមហាមោគ្គល្លានត្ថេរ ព្រោះធ្លាប់មកហើយ ។ ពិតហើយ ព្រះថេរៈ រមែងត្រាច់ចារិកទៅក្នុងទេវលោករហូតអស់កាលជានិច្ច ។ បណ្ដាបទទាំងនោះ បទថា **បរិយាយមកាសី** ប្រែថា បានធ្វើវារៈ ។ បទថា **យទិទំ ឥធាគមនាយ** មានអធិប្បាយថា វារៈដើម្បីមកក្នុងទីនេះ យ៉ាងណា បានធ្វើវារៈនោះអស់កាលយូរ ។ បទថា

**តទមាសនំ បញ្ញត្តំ** សេចក្តីថា ស្តេចសក្កៈ ក្រាលបល្ល័ង្កកែវមណីមួយយោជន៍ ទើបត្រាស់យ៉ាងនេះ ដូច្នេះ ។

[៧៦] បទក្នុង **ពហុកិច្ចា ពហុករណីយា** នេះ សេចក្តីថា កិច្ចទាំងឡាយរបស់ជនពួកណាច្រើន ជនពួកនោះ ឈ្មោះថា មានកិច្ចច្រើន ។ បទថា **ពហុករណីយា** នេះ ជាពាក្យវេវចនៈរបស់បទថា **ពហុកិច្ចា** នោះឯង ។ បទថា **អប្បេវ សកេន ករណីយេន** បានដល់ ករណីយកិច្ចរបស់ខ្លួនទុំឯង ។ ក៏ករណីយកិច្ចរបស់ស្តេចសក្កៈនោះតិច មិនច្រើន តែករណីយកិច្ចរបស់ទេវតាទាំងឡាយមានច្រើន ពិតហើយ រឿងក្តីតាំងពីផែនដីទៅ ដើម្បីត្រូវការដើមកល្បព្រឹក្ស និងមាតុគ្រាមជាដើម រមែងកាត់ក្តីក្នុងសម្នាក់របស់ស្តេចសក្កៈ ព្រោះដូច្នោះ កាលស្តេចលោកកំណត់ហើយ ទើបត្រាស់ថា មានករណីយកិច្ចរបស់ទេវតាទាំងឡាយជាន់តាវត្តឹង្សទៀត ដូច្នេះ ។ ពិតហើយ ធីតា និងបុត្ររមែងកើតឡើងដល់ពួកទេវតាទាំងឡាយ ស្រ្តីជាបាទបរិចារិកា រមែងកើតឡើងក្នុងទីដេក ដែលប្រដាប់តាក់តែងទេវតាពួកនោះ ក៏កើតហែហមទីដេករបស់ទេពធីតា ជាអ្នកជួយបំពេញកិច្ចការងារទាំងឡាយ កើតឡើងក្នុងខាងក្នុងវិមាន ទើបមិនមានរឿងក្តី ដើម្បីត្រូវការកាត់ក្តីនោះ ប៉ុន្តែថា មាតុគ្រាមពួកណារមែងកើតឡើងក្នុងចន្លោះព្រំប្រទល់ គេមិនអាចកាត់ក្តីថា មាតុគ្រាមទាំងនោះ

ជាសម្បត្តិរបស់យើង ឬជារបស់លោក កាលនឹងមានរឿងក្តី ទើបទូលសួរស្តេចសក្កទេវរាជ ។ ស្តេចសក្កទេវរាជនោះ រមែងត្រាស់ថា វិមានរបស់អ្នកណានៅជិតជាង ក៏ជាសម្បត្តិរបស់អ្នកនោះ ។ បើថា វិមានសូម្បីទាំងពីរមាននៅក្នុងចន្លោះស្មើគ្នា ស្តេចសក្កៈក៏នឹងត្រាស់ថា អ្នកដែលកើតមកនោះឈរក្រឡេកមើលវិមានរបស់អ្នកណា ក៏ជាសម្បត្តិរបស់អ្នកនោះ ។ បើមិនក្រឡេកមើលសូម្បីត្រឹមតែវិមានណាមួយ ដើម្បីត្រូវការកាត់ការវិវាទរបស់ទេវតាទាំងឡាយនោះ ក៏ធ្វើមាតុគ្រាមនោះ ឲ្យជាសម្បត្តិរបស់ព្រះអង្គឯង ។ ស្តេចសក្កទេវរាជត្រាស់ពាក្យថា មានករណីយកិច្ចរបស់ពួកទេវតាទាំងឡាយជាន់តាវត្តឹង្សដូច្នេះ សំដៅយកពាក្យដែលពោលហើយនោះ ។ម្យ៉ាងទៀត សូម្បីកិច្ច គឺការលេងក្នុងឧទ្យានបែបនេះ ក៏ជាករណីយកិច្ចរបស់ស្តេចសក្កៈដូចគ្នា ។

បទថា **យន្នោ ខិប្បមេវ អន្តរធាយតិ** សេចក្តីថា ពាក្យណាដែលខ្ញុំស្តាប់ហើយ ពាក្យនោះបាត់ទៅហើយឆាប់រហ័ស ដូចរូបមិនប្រាកដក្នុងទីងងឹតគឺថា ស្តេចសក្កទេវរាជនោះ រមែងសម្តែងថា បពិត្រលោកដ៏ចម្រើន ខ្ញុំរមែងកំណត់មិនបានដល់ការដោះស្រាយបញ្ហានោះ ដោយបទថា **យន្នោ ខិប្បមេវ អន្តរធាយតិ** នេះ ។ ព្រះថេរៈពិចារណាថា ព្រោះហេតុអ្វីហ្ន៎ ស្តេចសក្កៈនេះនឹងសម្តែងដល់សេចក្តីដែលខ្លួនជាអ្នកកំណត់មិនបាន ជ្រាបថា នឹងរក្សាប្រយោជន៍

ដែលជាចំណែកខាងខ្លួនទុក ដែលឈ្មោះថា ពួកទេព រមែងជាអ្នកវង្វេងភ្លេច ត្រូវអារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ បៀតបៀន រមែងមិនដឹងសូម្បី សេចក្តីដែលខ្លួនជាអ្នកបរិភោគហើយ ឬមិនទាន់បរិភោគ រមែងមិនដឹងសូម្បី សេចក្តីដែលខ្លួនជាអ្នកផឹកហើយ ឬមិនទាន់បានផឹក នឹងវង្វេងភ្លេចកិច្ចដែលខ្លួន ធ្វើហើយក្នុងទីនេះ ដូច្នេះ ។

ក៏អាចារ្យពួកខ្លះពោលថា ព្រះថេរៈជាអ្នកគួរគោរព គួរលើកតម្កើងរបស់ ស្តេចសក្កៈ ព្រោះដូច្នោះ ស្តេចទើបត្រាស់យ៉ាងនោះ ដោយខ្លាចក្រែងព្រះថេរៈ នឹងគប្បីគម្រាមយើងយ៉ាងនេះថា ឥឡូវនេះ ស្តេចសក្កៈរៀនបញ្ហាក្នុងសម្នាក់ របស់បុគ្គលដ៏កំពូលលើសលោកមកហើយ ឥឡូវនេះ ក៏ចូលទៅកាន់ចន្លោះ នាងទេពអប្សរទាំងឡាយ ដូច្នេះ ។ ក៏ឈ្មោះថា សេចក្តីកាន់កាំងយ៉ាងនេះ នៅមាន ។ ឈ្មោះថា សេចក្តីកាន់កាំងបែបនេះ របស់ព្រះអរិយសាវក រមែង មិនមាន ។ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ស្តេចសក្កទេវរាជនោះ កំណត់ មិនបានដោយភាពជាអ្នកវង្វេងភ្លេច ។ សួរថា ព្រោះហេតុអ្វី ក្នុងខាងក្រោយ ទើបកំណត់បានហ្ន៎ ។ ឆ្លើយថា ព្រោះព្រះថេរៈបានញ៉ាំងសេចក្តីសោមនស្ស និងសេចក្តីសង្វេគឲ្យកើតដល់ស្តេច ហើយនាំសេចក្តីងងឹតចេញទៅ ទើបកំណត់ បាន ។

ឥឡូវនេះ ស្តេចសក្កៈ ដើម្បីនឹងប្រាប់ហេតុដែលគប្បីកាន់កាំងណាមួយរបស់ខ្លួនក្នុងកាលមុនដល់ព្រះថេរៈ ទើបត្រាស់ពាក្យថា **ភូតបុព្វំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សមុបព្យុឡ្ហោ** ប្រែថា ប្រកៀកគ្នាហើយ គឺ ជាកងទ័ព ។ បទថា **អសុរា បរាយឹសុ** បានដល់ ពួកអសុរដល់ការបរាជ័យ ។ សួរថា ក៏ពួកអសុរទាំងនោះ ដល់ការបរាជ័យក្នុងកាលណា ។ ឆ្លើយថា ក្នុងកាលដែលស្តេចសក្កៈទ្រង់ឧប្បត្តិឡើង ។

បានឮថា ស្តេចសក្កៈបានជាមាណព ជាបណ្ឌិត ជាអ្នកវាងវៃឈ្មោះថា មាឃៈ ក្នុងស្រុកអចលគ្រាម ក្នុងមគធរដ្ឋ ក្នុងអត្តភាពបន្ទាប់ទៅ ការប្រព្រឹត្តរបស់គេ បានដូចជាការប្រព្រឹត្តរបស់ព្រះពោធិសត្វ ។ នាយមឃមាណពនោះនាំយកបុរស ៣៣ នាក់ ឲ្យសាងសេចក្តីល្អ ។ ថ្ងៃមួយ គេពិចារណាដោយបញ្ញារបស់ខ្លួនហើយ ជញ្ជូនសម្រាមទាំងពីរខាងក្នុងទីមហាជនប្រជុំគ្នា ត្រង់កណ្តាលស្រុកចេញទៅ បានធ្វើទីនោះឲ្យជាទីរីករាយ បានសាងមណ្ឌបក្នុងទីនោះៗ ឯងទៀត កាលកន្លងទៅ ក៏បានសាងសាលាទៀត គេចេញចាកស្រុកត្រាច់ទៅព្រមនឹងសម្លាញ់ទាំងនោះ បានធ្វើកន្លែងដែលមិនរាបស្មើ ឲ្យរាបស្មើ មានប្រមាណមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ បីគាវុតខ្លះ មួយយោជន៍ខ្លះ ជនទាំងអស់នោះ មានឆន្ទៈតែមួយ កាលនឹងសាងស្ពានក្នុងទីគួរសាងស្ពាន សាង

មណ្ឌបជាដើមក្នុងទីគួរដល់មណ្ឌប សាលា ស្រះបោក្ខរណី និងដាំឈើផ្កា គុម្ព ឈើជាដើម បានធ្វើបុណ្យជាច្រើន ។ នាយមឃៈមាណព បានបំពេញវត្តបទ ៧ ប្រការ លុះដល់កម្ម (ស្លាប់) ក៏ទៅកើតក្នុងភពតាវត្តឹង្ស ព្រមទាំងសម្លាញ់ ។ ក្នុងកាលនោះ ពួកអសុរអាស្រ័យនៅក្នុងតាវត្តឹង្សទេវលោក ។ ពួកអសុរទាំង អស់នោះ មានអាយុ និងវណ្ណៈដូចទេវតាទាំងឡាយ ពួកគេឃើញស្តេចសក្កៈ ព្រមទាំងបរិស័ទទើបតែកើតឡើង ទើបគិតថា ពួកទេវបុត្រថ្មីមកហើយ ទើប ចាត់ចែងទឹកមហាបានៈមកទទួល ។ ស្តេចសក្កៈបានឲ្យសញ្ញា គឺ ប្រាប់ឧបាយ ដល់ទេវបុត្រទាំងឡាយថា ពួកយើងធ្វើកុសល តែមិនបានធ្វើកុសលទូទៅរួម នឹងជនពួកដទៃ ពួកលោកកុំផឹកទឹកគណ្ឌបាន ចូរធ្វើត្រឹមតែផឹកប៉ុណ្ណោះ ដូច្នេះ ។ ពួកគេបានធ្វើដូចយ៉ាងនោះ ពួកអសុរល្ងង់នាំគ្នាផឹកទឹកគណ្ឌបានស្រវឹង ហើយ ដេកលក់ទៅ ។ ស្តេចសក្កៈឲ្យសញ្ញាដល់ពួកទេវ ហើយនាំគ្នាចាប់ជើងពួក អសុរ គ្រវែងទៅកាន់ជើងភ្នំសិនេរុ ។ ព្រោះថា ពិភពរបស់អសុរ មាននៅក្នុង ផែនដីខាងក្រោមនៃភ្នំសិនេរុ មានប្រមាណប៉ុនតាវត្តឹង្សទេវលោកនោះឯង ។ ពួកអសុរនៅក្នុងទីនោះ មានដើមឈើរបស់ពួកអសុរ ឈ្មោះថា ចិត្តបាដលិ (ដើមឈើប្រចាំអសុរពិភព) ។ ពួកអសុរទាំងនោះ រមែងដឹងបានក្នុងវេលា ដែលដើមចិត្តបាដលិមានផ្ការីក ថា ដើមឈើនេះ មិនមែនដើមឈើប្រចាំភព

តាវត្តិង្ស ពួកយើងត្រូវស្តេចសក្កៈលួងលោមហើយ ។ ពួកគេពោលថា ពួកអ្នកចូរចាប់ស្តេចសក្កៈនោះ ដូច្នេះ ហើយគ្រប់គ្រងរក្សាភ្នំសិនេរុ កាលភ្លៀងធ្លាក់ហើយ ក៏នាំគ្នាឡើងទៅដូចកណ្តៀរចេញទៅពីជំបូក ។ ក្នុងការច្បាំងគ្នានោះ ពេលខ្លះពួកទេវឈ្នះ ពេលខ្លះពួកអសុរឈ្នះ ។ កាលណាពួកទេវឈ្នះ ពួកគេក៏នឹងជាប់តាមពួកអសុរទៅដរាបដល់ផ្ទៃសមុទ្រ ។ កាលណា ពួកអសុរឈ្នះ ពួកគេក៏នឹងដេញតាមពួកទេវទៅដរាបដល់ក្រៅកំពែងក្រុង ។ ប៉ុន្តែថាក្នុងការច្បាំងនោះ ពួកទេវឈ្នះ ។ ពួកទេវទើបជាប់តាមពួកអសុរទៅ ដរាបដល់ផ្ទៃសមុទ្រ ។ ស្តេចសក្កៈញុំាង ពួកអសុរឲ្យចៀសចេញទៅហើយ ទើបតាំងរក្សាទុកក្នុងទី ៥ កន្លែង ។ បានឲ្យរក្សាយ៉ាងនេះ ទ្រង់តាំងរូបដូចព្រះឥន្ទ្រមានដៃកាន់វជិរៈក្រៅកំពែងក្រុង ។ អសុរទាំងឡាយលើកគ្នាមកពេលណា ក៏ឃើញរូបដូចព្រះឥន្ទ្រនោះ ទើបនាំគ្នាត្រឡប់អំពីទីនោះឯង ដោយសម្គាល់ថាស្តេចសក្កៈមិនប្រមាទប្រថាប់ឈរ ដូច្នេះ ។

បទថា **តតោ បដិនិវត្តិត្វា** បានដល់ ត្រឡប់ចាកទីដែលស្តេចសក្កៈនោះឈ្នះហើយ ។ បទថា **បរិចារិកាយោ** ប្រែថា នាងអប្សរទាំងឡាយ បានដល់នាងអប្សរដែលធ្វើកិច្ចការងារទាំងឡាយ មានការធ្វើកម្រងផ្កាឈើ និងគ្រឿងក្រអូបជាដើម ។

[៧៧] បទថា **វេស្សវណោ ច មហារាជា** សេចក្ដីថា បានឮថា ស្ដេចវេស្សវណនោះ ជាទីស្រឡាញ់ ជាអ្នកស្និទ្ធស្នាលច្រើននឹងស្ដេចសក្កៈ ព្រោះដូច្នោះ ទើបបានទៅជាមួយស្ដេចសក្កៈ ។

បទថា **បុរក្ខត្វា** គឺ ធ្វើទុកខាងមុខ ។ បទថា **បវិសិំសុ** សេចក្ដីថា ក៏ទេពធីតាអ្នកបម្រើស្ដេចសក្កៈទាំងនោះ ចូលទៅកាន់បន្ទប់ ហើយបិទទ្វារទុកដោយកន្លះមួយ ឈរក្រឡេកមើលទៅ ។ បទថា **ឥទម្បិ មារិស មោគ្គល្លាន បស្ស វេជយន្តបាសាទស្ស រាមណេយ្យកំ** សេចក្ដីថា បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សូមលោកចូរមើលស្ថានទី ជាទីគួររីករាយនៃវេជយន្តប្រាសាទសូម្បីនេះ គឺថា ចូរមើលរូបសត្វកាច ត្រង់សសរមាស សសរប្រាក់ សសរកែវមណី សសរកែវប្រវាឡ សសរកែវទទឹម សសរកែវលាយ សសរកែវមុក្ដាសសររតនៈ ៧ ប្រការ ដែលសម្រេចហើយដោយមាសជាដើម នៃសសរទាំងឡាយនោះ ព្រោះដូច្នោះ ស្ដេចសក្កទេវរាជ កាលនឹងសម្ដែងស្ថានទីដែលជាទីគួររីករាយ ធ្វើជួរនៃសសរ ដោយអាការយ៉ាងនេះជាដើម ទើបត្រាស់យ៉ាងនោះ ។

បទថា **យថាតំ បុព្វេ កតបុញ្ញស្ស** អធិប្បាយថា ស្ថានទីរបស់បុគ្គលអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន គប្បីស្អាតដោយការតាំងទុកនូវគ្រឿងឧបភោគ

យ៉ាងណា របស់ស្តេចសក្កៈក៏រមែងស្អាតដូច្នោះដូចគ្នា ។ បទថា **អតិពាឡ្ហំ ខោ អយំ យក្ខោ បមត្តោ វិហរតិ** សេចក្តីថា ស្តេចសក្កៈនេះ ស្រវឹងក្រៃ-លែងណាស់ ដោយប្រាសាទ ដោយនាងទេពអប្សរជាបរិវារ ដោយសម្បត្តិ ដោយយសរបស់ខ្លួន ។ បទថា **ឥទ្ធាភិសង្ខារំ អភិសង្ខារេតិ** គឺថា បានធ្វើឫទ្ធិ ។ អធិប្បាយថា ព្រះមហាមោគ្គល្លានត្ថេរ ចូលអាបោកសិណហើយ អធិដ្ឋានថា សូមឱកាសដែលជាទីតាំងនៃប្រាសាទ ចូរជាទឹក ហើយយកមេជើងសន្កត់ចុះត្រង់ជហ្វាប្រាសាទ ។ ប្រាសាទនោះញាប់ញ័រ យោងយោងទៅមក ដូចបាត្រតាំងទុកលើទឹក យកម្រាមគោះត្រង់កណ្តាប់មាត់បាត្រ ក៏កម្រើកទៅមក តាំងនៅមិនបាន ដូច្នោះ ។ វត្ថុទាំងឡាយ មានសសរ ជហ្វា បន្ទន់ជាដើម បញ្ចេញសំឡេងក្រៈក្រៈ ហាក់បីដូចចាប់ផ្តើមដើម្បីនឹងធ្លាក់ទៅ ។ ដោយហេតុនោះ លោកទើបពោលថា **សំកម្បេសិ សម្បកម្បេសិ សម្បវេធេសិ** ដូច្នេះ ។

បទថា **អច្ឆរិយព្ភុតចិត្តជាតា** បានដល់ មានសេចក្តីអស្ចារ្យមិនធ្លាប់មាន កើតឡើងយ៉ាងនេះថា ឱហ្ន៎ គួរអស្ចារ្យណាស់ មិនធ្លាប់មានមក និងមានសេចក្តីត្រេកអរ គឺ មានសោមនស្ស ដែលមានកម្លាំងកើតឡើងហើយ ។ បទថា **សំវិគ្គំ** បានដល់ ភ័យខ្លាចហើយ គឺ ញាប់ញ័រហើយ ។ បទថា **លោ-**

**មហគ្គជាតំ** បានដល់ ពេមបះឡើង គឺ មានសរីរៈព្រឺព្រួច ដោយរោមទាំងឡាយបះឡើងទៅខាងលើ ដូចព្រួសកែវមណី ដែលគេដាក់តាំងទុកត្រង់ជញ្ជាំងផ្ទះមាស ។ ម្យ៉ាងទៀត ឈ្មោះថា រោមបះឡើងនេះ រមែងកើតឡើងដោយសោមនស្សខ្លះ ដោយទោមនស្សខ្លះ ។ តែក្នុងទីនេះ កើតឡើងដោយសេចក្តីសោមនស្ស ។ ន័យថា ព្រះថេរៈបានធ្វើបាដិហារិយនោះ ដើម្បីឲ្យស្តេចសក្កៈកើតសេចក្តីសង្វេគដោយសេចក្តីសោមនស្ស និងសេចក្តីតក់ស្លុត ។ ព្រោះដូច្នោះគប្បីជ្រាបអត្ថថា ព្រះមហាមោគ្គល្លានត្ថេរនោះដឹងថា ស្តេចសក្កទេវរាជនោះមានសេចក្តីតក់ស្លុតរោមបះឡើងហើយ ដោយសេចក្តីសោមនស្ស និងសេចក្តីតក់ស្លុត ដូច្នេះ ។

[៧៨-៧៩] បទថា **ឥធាហំ មារិស** សេចក្តីថា ឥឡូវនេះ ព្រះថេរៈញុំាងសោមនស្ស និងសេចក្តីតក់ស្លុតរបស់ស្តេចសក្កៈឲ្យកើតឡើង ទម្លាយភាពងងឹតហើយ ព្រោះដូច្នោះ ក៏កំណត់បានហើយ ទើបពោលយ៉ាងនេះ ។

បទថា **ឯសោ នុ តេ មារិស សោ ភគវា សត្ថា** សេចក្តីថា កាលនាងទេពអប្សរទូលសួរថា បពិត្រព្រះអង្គអ្នកនិរទុក្ខ ព្រះអង្គស្តេចទៅណា ស្តេចសក្កៈត្រាស់ឆ្លើយថា ទៅសម្នាក់ព្រះសាស្តារបស់យើង ព្រះអង្គត្រាស់យ៉ាងនេះ ហាក់បីដូចទីនោះតាំងនៅក្នុងផែនដីតែមួយគ្នានឹងទេវលោកនេះ ។ ទូល

សួរទៀតថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ព្រះសមណៈនុ៎ះ ជាព្រះមានព្រះភាគ ជាសាស្តារបស់ព្រះអង្គឬហ្ន៎ ។ ក្នុងបទថា **សព្រហ្មចារី មេ ឯសោ** នេះ សេចក្តីថា ព្រះថេរៈជាបព្វជិត ជាអ្នកដល់ព្រមដោយអភិនិហារ ជាព្រះអគ្គ-សាវក តែស្តេចសក្កៈជាអ្នកគ្រប់គ្រងផ្ទះ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា លោកទាំងពីរ ក៏ជាព្រហ្មចារីដោយអំណាចនៃមគ្គព្រហ្មចរិយ ព្រោះដូច្នោះ ស្តេចសក្កៈទើបត្រាស់យ៉ាងនោះ ។ បទថា **អហោ នូន តេ សោ ភគវា សត្ថា** សេចក្តីថា សព្រហ្មចារីរបស់ព្រះអង្គមានឫទ្ធិច្រើនដល់យ៉ាងនេះ ។ ពួកនាងបរិចារិកាបានពោលដល់ការកើតឡើង ក្នុងការឃើញឥទ្ធិបាដិហារ្យរបស់ព្រះសាស្តា ទើបពោលយ៉ាងនេះថា ក៏ព្រះថេរៈនោះ ជាព្រះមានព្រះភាគដែលសាស្តារបស់ព្រះអង្គ គួរនឹងមានឫទ្ធិច្រើនពិត ។ បទថា **ញាតញ្ញតរស្ស** សេចក្តីថា អ្នកណាម្នាក់ដែលប្រាកដ ពិតហើយ បណ្តាអ្នកដែលប្រាកដមានឈ្មោះបោះសំឡេងទាំងឡាយ ស្តេចសក្កៈក៏ជាបុគ្គលម្នាក់ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ប្រាកដច្បាស់ហើយ ព្រះមានព្រះភាគទ្រង់ញ៉ាំងទេសនាឲ្យចប់ស្រេចតាមអនុសន្ធិ ដូច្នេះឯង ។

( ចប់ អដ្ឋកថា ចូឡតណ្ហាសង្ខយសូត្រ ទី ៧ )

# អ ដ្ឋ ក ថា

## មហាតណ្ហាសង្ខយសូត្រទី ៨

[៨០] មហាតណ្ហាសង្ខយសូត្រ មានបទផ្ដើមថា ឯវម្មេ សុតំ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ បទថា **ទិដ្ឋិគតំ** នេះ ក្នុងអលគទ្ទូ-មមសូត្រ ពោលបទថា ទិដ្ឋិថា ជាលទ្ធិ ។ ក្នុងទីនេះ លោកពោលថា ជាសស្សត-ទិដ្ឋិ ។ ក៏ភិក្ខុនោះ ជាអ្នកស្ដាប់ច្រើន តែភិក្ខុដែលស្ដាប់តិចពោលជាតក ស្ដាប់ព្រះមានព្រះភាគត្រាស់ប្រជុំរឿងជាតកថា ម្នាលភិក្ខុទាំងឡាយ គ្រានោះតថាគតបានជាវេស្សន្តរ បានជាមហោសថ បានជាវិធុរបណ្ឌិត បានជាសេនកបណ្ឌិត បានជាព្រះបាទមហាជនក ដូច្នេះ ។ ពេលនោះ លោកមានការគិតថា រូប វេទនា សញ្ញា សង្ខារទាំងនេះ រមែងរលត់ទៅក្នុងទីនោះៗ ទុំះឯង តែវិញ្ញាណរមែងស្ទុះទៅ អន្ទោលទៅអំពីលោកនេះកាន់លោកដទៃ អំពីលោកដទៃមកកាន់លោកនេះ ដូច្នេះ ទើបកើតសស្សតទិដ្ឋិ ។ ព្រោះហេតុនោះ លោកទើបពោលថា វិញ្ញាណនេះទុំះឯង រមែងស្ទុះទៅ រមែងអន្ទោលទៅ មិនមែនយ៉ាងដទៃដូច្នេះ ។ ក៏ព្រះសម្មាសម្ពុទ្ធត្រាស់ទុកថា កាលបច្ច័យមានហើយ ការកើតឡើងនៃវិញ្ញាណទើបមាន វៀរចាកបច្ច័យ ការកើតឡើងនៃវិញ្ញាណ រមែងមិន

ដូច្នេះ ។ ព្រោះដូច្នោះ ភិក្ខុនេះឈ្មោះថា រមែងពោលពាក្យដែលព្រះពុទ្ធមិនបានត្រាស់ទុក រមែងប្រហារព្រះជិនចក្រ រមែងជំទាស់វេសារជ្ជញ្ញាណ រមែងពោលនឹងជនអ្នកប្រាថ្នាដើម្បីនឹងស្តាប់ឲ្យឃៀងឃ្លាត ទាំងទទឹងទាស់ផ្លូវអរិយៈ ជាអ្នកបដិបត្តិដើម្បីវត្ថុមិនមែនប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់មហាជន មហាចោរកាលកើតក្នុងរាជសម្បត្តិរបស់ព្រះរាជា រមែងកើតឡើងមិនមែនដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់មហាជន យ៉ាងណា បណ្ឌិតគប្បីជ្រាបថា ចោរក្នុងសាសនារបស់ព្រះជិនស្រី កើតឡើងហើយ មិនដើម្បីប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់មហាជន ដូច្នោះ ។

បទថា **សម្ពហុលា ភិក្ខូ** បានដល់ ភិក្ខុអ្នកបិណ្ឌបាតជាវត្ត អ្នកមានប្រក្រតីនៅក្នុងជនបទ ។ បទថា **តេនុបសង្កមឹសុ** សេចក្តីថា ភិក្ខុទាំងនោះគិតថា សាតិភិក្ខុនេះ បានពួកហើយ នឹងគប្បីញាំងព្រះសាសនាឲ្យអន្តរធានទៅ លោកមិនទាន់បានពួកត្រឹមណា ពួកយើងនឹងដោះលោកឲ្យចាកពីសេចក្តីឃើញខុសត្រឹមនោះ ដូច្នេះ ទើបមិនឈរ មិនអង្គុយ ចូលទៅរកពីទីដែលខ្លួនស្តាប់ហើយនុ៎ះឯង ។

[៨២] បទថា **យំ កតមន្តំ សាតិ វិញ្ញាណំ** សេចក្តីថា ព្រះមានព្រះ-ភាគត្រាស់សួរថា ម្នាលសាតិ អ្នកពោលសំដៅយកវិញ្ញាណណា វិញ្ញាណនោះ

តើដូចម្តេច ? ។ ប្រការថា **យ្វាយំ ភន្តេ វទោ វេទេយ្យោ តត្រ តត្រ កល្យាណបាបកានំ កម្មានំ វិបាកំ បដិសំវេទេតិ** សេចក្តីថា សាតិភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សភាវៈណារមែងនិយាយបាន រមែងសោយអារម្មណ៍បាន ក៏សភាវៈនោះ រមែងសោយវិបាករបស់កុសលកម្ម និងអកុសល-កម្មក្នុងទីនោះៗ បាន ខ្ញុំព្រះអង្គពោលសំដៅដល់វិញ្ញាណណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាវិញ្ញាណនោះ ដូច្នេះ ។ បទថា **កស្ស នុ ខោ នាម** សេចក្តីថា ដល់អ្នកណា គឺថា ដល់ក្សត្រ ឬថា ព្រាហ្មណ៍ ឬថា ដល់វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្សទាំងឡាយ បុគ្គលណាមួយ ។

[៨៣] បទថា **អថខោ ភគវា ភិក្ខូ អាមន្តេសិ** សួរថា ព្រោះហេតុអ្វីទើបត្រាស់ហៅភិក្ខុទាំងឡាយ ។ ឆ្លើយថា បានឮថា សាតិភិក្ខុបានគិតយ៉ាងនេះថា ព្រះសាស្តាត្រាស់ហៅយើងថា មោឃបុរស ដូច្នេះ នឹងមិនមានឧប-និស្ស័យនៃមគ្គ និងផលទាំងឡាយ ដោយត្រឹមតែពាក្យដែលពោលហើយថា មោឃបុរសនេះប៉ុណ្ណោះក៏មិនមែន ព្រោះថា សូម្បីព្រះឧបសេនត្ថេរ ព្រះមាន-ព្រះភាគក៏ត្រាស់យ៉ាងនេះថា ម្នាលមោឃបុរស អ្នកវិលមកដើម្បីភាពជាអ្នកប្រាជ្ញាច្រើនហើយ ដូច្នេះ ខាងក្រោយមក ព្យាយាមហើយ ក៏បានធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ សូម្បីយើងផ្គងសេចក្តីព្យាយាមហើយ ក៏នឹងធ្វើឲ្យជាក់ច្បាស់

នូវមគ្គ និងផលទាំងឡាយ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងសម្ដែងដល់លោកថា សាតិភិក្ខុនេះ មានបច្ច័យដែលដាច់ហើយ ជាអ្នកមានធម៌ដែលមិនដុះលូតក្នុងសាសនា ដូច្នេះ ទើបត្រាស់ហៅភិក្ខុទាំងឡាយ ។ បទថា **ឧស្មីកតោ** ជាដើម បណ្ឌិត គប្បីជ្រាបអធិប្បាយតាមដែលបានពោលហើយក្នុងកាលមុននុ៎ះឯង ។

បទថា **អថខោ ភគវា** សេចក្ដីថា អនុសន្ធិសូម្បីនេះ ជារបស់ចំពោះបុគ្គល ។

បានឮថា សាតិភិក្ខុបានគិតថា ព្រះមានព្រះភាគ ត្រាស់ថា ធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផលទាំងឡាយរបស់យើងមិនមាន ដូច្នេះ កាលធម៌ដែលជាឧបនិស្ស័យមិនមានហើយ យើងអាចនឹងកែខែធម៌ដែលជាឧបនិស្ស័យបានឬ ព្រោះថា ព្រះតថាគតទាំងឡាយ រមែងសម្ដែងធម៌ដល់បុគ្គលដែលមានឧបនិស្ស័យប៉ុណ្ណោះ សម្ដែងដល់អ្នកណាៗ នុ៎ះឯង យើងបានឱវាទរបស់ព្រះសុគតពីសម្នាក់របស់ព្រះពុទ្ធហើយ នឹងធ្វើកុសល ដើម្បីសួគ៌សម្បត្តិ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ដល់សាតិភិក្ខុនោះថា ម្នាលមោឃបុរស តថាគតមិនឲ្យឱវាទ ឬអនុសាសនីដល់អ្នក ដូច្នេះ កាលនឹងទ្រង់រម្ងាប់ឱវាទរបស់ព្រះសុគត ទើបផ្ដើមទេសនានេះ ។ សេចក្ដីនៃព្រះតម្រាស់នោះ គប្បី

ជ្រាបដោយន័យដែលពោលហើយក្នុងកាលមុនទុំះឯង ។ ឥឡូវនេះ ព្រះមាន-ព្រះភាគ កាលនឹងទ្រង់ជម្រះលទ្ធិក្នុងបរិស័ទ ទើបត្រាស់ពាក្យថា **ឥធាហំ ភិក្ខុ បដិបុច្ឆិស្សាមិ** ជាដើម ។ ពាក្យសូម្បីទាំងអស់ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយក្នុងកាលមុនទុំះឯង ។

( ចប់ សាតិកណ្ឌ )

[៨៤] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីនឹងទ្រង់សម្តែងនូវសេចក្តីដែលវិញ្ញាណមានបច្ច័យ ទើបត្រាស់ពាក្យថា **យញ្ញទេវ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **មនញ្ច បដិច្ច ធម្មេ ច** បានដល់ វិញ្ញាណអាស្រ័យភវង្គចិត្ត ព្រមទាំងអាវជ្ជនៈ និងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិបី ។ បទថា **កដ្ឋញ្ច បដិច្ច** ជាដើម ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីសម្តែងចន្លុលបង្ហាញដោយឧបមា ។ ព្រះមានព្រះភាគ ទ្រង់សម្តែងទុកយ៉ាងណា ដោយឧបមានោះ ។ ទ្រង់សម្តែងដល់ការមិនមានសេចក្តីពេញចិត្តក្នុងទ្វារ ។ ដូចសេចក្តីថា ភ្លើងអាស្រ័យឈើទើបឆេះបាន កាលបច្ច័យ គឺ គ្រឿងឆេះនៅមានហើយទុំះឯងក៏នៅឆេះ កាលបច្ច័យ គឺ គ្រឿងឆេះមិនមាន ក៏រមែងរលត់ទៅក្នុងទីនោះឯងព្រោះការមិនមានបច្ច័យ រមែងមិនដល់ការរាប់ជាដើមថា ភ្លើងក្រមរឈើជាដើម

ព្រោះឈានកន្ទងវត្ថុទាំងឡាយ មានក្រមរឈើជាដើម យ៉ាងណា វិញ្ញាណកើត ឡើង ព្រោះអាស្រ័យចក្ខុ និងរូប ដូច្នោះដែរ កាលបច្ច័យ ពោលគឺ ចក្ខុ-បសាទ រូបារម្មណ៍ អាលោកៈ និងមនសិការ ក្នុងទ្វារនោះមាន ក៏រមែងកើតឡើង កាលបច្ច័យនោះមិនមានហើយ រមែងរលត់ទៅក្នុងទីនោះឯង ។ ដោយការមិន មាននៃបច្ច័យ រមែងមិនដល់ការរាប់ជាដើមថា សោតវិញ្ញាណជាដើម ព្រោះ ឈានកន្ទងសោតបសាទជាដើម ។ ក្នុងវារៈទាំងពួង ក៏មានន័យនេះឯង ។ ដោយ ហេតុនេះ ព្រះមានព្រះភាគ ទើបទ្រង់តិះដៀលសាតិភិក្ខុ ដោយព្រះតម្រាស់ថា តថាគត រមែងមិនពោលហេតុសូម្បីត្រឹមតែថា សេចក្តីពេញចិត្តក្នុងទ្វារ ក្នុងការ ប្រព្រឹត្តទៅនៃវិញ្ញាណ ក៏សាតិភិក្ខុមោឃបុរសនេះ រមែងពោលដល់ការពេញចិត្ត ក្នុងភព ដូច្នេះ ។

[៨៥] ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងសេចក្តីដែលវិញ្ញាណ មាន បច្ច័យហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងដល់ខន្ធសូម្បីទាំង ៥ មានបច្ច័យ ទើបត្រាស់ពាក្យថា **ភូតមិទំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ភូតមិទំ** នេះ បានដល់ ខន្ធបញ្ចកៈ ដែលកើតហើយ មានហើយ កើតឡើងហើយ ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឃើញថា ខន្ធ-បញ្ចកៈដែលកើតហើយឬ ។ បទថា **តទាហារសម្ភវំ** សេចក្តីថា ក៏ខន្ធបញ្ចកៈ

នោះ កើតឡើងព្រោះអាហារ កើតឡើងព្រោះបច្ច័យ ព្រះមានព្រះភាគត្រាស់សួរថា ពួកអ្នកឃើញយ៉ាងនេះថា កាលបច្ច័យមាន ខន្ធបញ្ចកៈរមែងកើតឡើងឬ ដូច្នេះ ។ បទថា **តទាហារនិរោធា** បានដល់ ព្រោះការរលត់នៃបច្ច័យនោះ ។ បទថា **ភូតមិទំ នោសុ** បានដល់ ខន្ធបញ្ចកៈនេះកើតឡើងហើយ ។ គឺ កើតហើយ ឬមិនកើតទេ ។ បទថា **តទាហារសម្ភវំ នោសុ** សេចក្ដីថា ព្រះមាន-ព្រះភាគត្រាស់សួរថា ក៏ខន្ធបញ្ចកៈដែលមានហើយនេះ កើតឡើងព្រោះបច្ច័យឬមិនមានបច្ច័យទេ ។ បទថា **តទាហារនិរោធា** បានដល់ ព្រោះការរលត់នៃបច្ច័យនោះ ។ បទថា **និរោធធម្មំ នោសុ** សេចក្ដីថា ព្រះមានព្រះភាគសួរថា ខន្ធបញ្ចកៈ មានការរលត់ទៅជាធម្មតាឬទេ ។ បទថា **សម្មប្បញ្ញាយ បស្សតោ** សេចក្ដីថា កាលបុគ្គលឃើញដោយប្រពៃ ដោយវិបស្សនាបញ្ញា ដោយលក្ខណៈដោយកិច្ច តាមសេចក្ដីពិតថា ខន្ធបញ្ចកៈនេះ កើតហើយ មានហើយ កើតឡើងហើយ ដូច្នេះ ។ បទថា **បញ្ញាយ សុទិដ្ឋំ** បានដល់ ឃើញហើយដោយប្រពៃ ដោយវិបស្សនាបញ្ញា ដោយន័យដែលពោលហើយនុ៎ះឯង ។ បុគ្គលពួកណាៗ កំណត់ពាក្យសួរនោះ ដោយអាការយ៉ាងនេះ ព្រះមានព្រះភាគកាលទ្រង់ទទួលបដិញ្ញារបស់បុគ្គលទាំងនោះ ក៏ទ្រង់សម្ដែងដល់ខន្ធប្រាំមានបច្ច័យ ដូច្នេះ ។

ឥឡូវនេះ ពួកភិក្ខុមានសេចក្ដីឃើញខន្ធបញ្ចកៈនោះ មានបច្ច័យ និង

មាននិរោធយ៉ាងល្អ ដោយបញ្ញាណា ព្រះមានព្រះភាគ កាលនឹងត្រាស់សួរដល់ខន្ធបញ្ចកៈនោះ មិនមានតណ្ហាក្នុងទីនោះ ទើបត្រាស់ពាក្យថា **ឥមំ ចេ តុម្ហេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ទិដ្ឋិ** បានដល់ វិបស្សនាសម្មាទិដ្ឋិ ។ ឈ្មោះថា **បរិសុទ្ធ** ព្រោះឃើញដល់សភាវៈ ឈ្មោះថា ផូរផង់ ព្រោះឃើញបច្ច័យ ។ បទថា **អល្លីយេថ** បានដល់ គប្បីជាប់ដោយតណ្ហា និងទិដ្ឋិទាំងឡាយ ។ បទថា **កេឡាយេថ** បានដល់ គប្បីក្រើតក្រើនដោយតណ្ហា និងទិដ្ឋិ ។ បទថា **ធនេយ្យាថ** បានដល់ គប្បីដល់សេចក្តីចង់បាន ដូចអ្នកប្រាថ្នាទ្រព្យ ។ បទថា **មមាយេថ** បានដល់ គប្បីញ៉ាំងហេតុត្រឹមតែថា តណ្ហា និងទិដ្ឋិ ឲ្យកើតឡើង ។ បទថា **និត្ថរណត្ថាយ នោ គហណត្ថាយ** សេចក្តីថា ព្រះមាន-ព្រះភាគត្រាស់ថា ធម៌ណាប្រៀបធៀបដោយគ្រឿងបណ្តែត (ផែមួយប្រភេទ) ដែលតថាគតសម្តែងហើយ ដើម្បីប្រយោជន៍ក្នុងការរលាស់ចេញចាកឱឃៈ ៤ ពួកអ្នកគប្បីដឹងធម៌នោះ មិនមែនដើម្បីប្រយោជន៍ក្នុងការកាន់យក ដោយអំណាចនៃសេចក្តីប្រាថ្នាខ្ះឬទេ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបធម៌ចំណែកស ដោយន័យផ្សេងគ្នា ។

[៨៦] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងបច្ច័យនៃខន្ធពួកនោះ ទើបត្រាស់ពាក្យថា **ចត្តារោ មេ ភិក្ខវេ អាហារា** ជាដើម ។ ពាក្យ

នោះ មានអត្ថតាមដែលពោលទុកហើយនុ៎ះឯង ។ មានអធិប្បាយថា ដូចសេចក្ដីថា ធម៌ណាមួយ ដែលព្រះមានព្រះភាគត្រាស់ទុកថា អ្នករមែងដឹងធម៌នេះ គឺថា បុគ្គលកាលដឹងដោយអំណាចនៃប្រពៃណីដែលមានមកយ៉ាងនេះថា យើងរមែងមិនដឹងមាតារបស់បុគ្គលនេះតែម្យ៉ាង រមែងដឹងសូម្បីដល់មាតារបស់មាតា ដូច្នេះ ឈ្មោះថា រមែងដឹងយ៉ាងល្អ យ៉ាងណា ព្រះមានព្រះភាគ ក៏យ៉ាងនោះដែរ រមែងទ្រង់ជ្រាបច្បាស់ត្រឹមតែខន្ធតែម្យ៉ាងប៉ុណ្ណោះក៏ទេ ទ្រង់ជ្រាបសេចក្ដីបន្តជាប់ៗ គ្នាមកនៃធម៌ដែលជាបច្ច័យទាំងពួង យ៉ាងនេះថា រមែងទ្រង់ជ្រាបច្បាស់សូម្បីបច្ច័យនៃខន្ធទាំងឡាយ រមែងទ្រង់ជ្រាបសូម្បីបច្ច័យនៃបច្ច័យទាំងឡាយនោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងកម្លាំងរបស់ព្រះពុទ្ធ ដើម្បីទ្រង់សម្ដែងសេចក្ដីបន្តជាប់គ្នាមកនៃបច្ច័យក្នុងពេលឥឡូវនេះ ទើបត្រាស់ពាក្យថា **ឥមេ ច ភិក្ខវេ ចត្តារោ អាហារា** ជាដើម ។ សូម្បីពាក្យនោះ ក៏មានអត្ថដូចដែលពោលហើយ ។ កថាពោលអំពីបដិច្ចសមុប្បាទក្នុងព្រះបាលីនោះថា ម្នាលភិក្ខុទាំងឡាយសង្ខារទាំងឡាយមាន ព្រោះអវិជ្ជាជាបច្ច័យ ។ល។ ដោយប្រការដូច្នេះឯង ការកើតឡើងនៃកងទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះ ដូច្នេះ គប្បីឲ្យពិស្ដារ ក៏កថានោះពោលពិស្ដារទុកហើយក្នុងវិសុទ្ធិមគ្គ ។

[៨៨] បទថា **ឥមស្មឹ សតិ ឥទំ ហោតិ** បានដល់ កាលបច្ច័យ មានអវិជ្ជាជាដើមនេះមាន ផលមានសង្ខារជាដើមនេះ ក៏មាន ។ បទថា **ឥមស្សុ-ប្បាទា ឥទំ ឧប្បជ្ជតិ** បានដល់ ព្រោះបច្ច័យមានអវិជ្ជាជាដើមនេះ កើតឡើង ផលមានសង្ខារជាដើមនេះ ក៏កើតឡើង ។ ដោយហេតុនោះឯង ទើបព្រះមាន-ព្រះភាគត្រាស់ថា ព្រោះអវិជ្ជាជាបច្ច័យ សង្ខារទាំងឡាយទើបមាន ។ល។ ការកើតឡើងនៃកងទុក្ខទាំងមូលនោះ រមែងមានយ៉ាងនេះ ដូច្នេះ ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងវដ្តៈយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងដល់វិវដ្តៈ ទើបត្រាស់ពាក្យថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អវិជ្ជាយ ត្វេវ** គឺ អវិជ្ជានុ៎ះឯង ។ បទថា **អសេស វិរាគនិរោធា** ពាក្យនេះ ព្រះមានព្រះភាគត្រាស់ថា ព្រោះសង្ខាររលត់ទៅ វិញ្ញាណទើបរលត់ ដូច្នេះជាដើម ដើម្បីសម្តែងថា ក៏ព្រោះការរលត់ទៅនៃសង្ខារទាំងឡាយ ដែលរលត់ទៅហើយ យ៉ាងនេះថា ព្រោះការរលត់ដោយមិនមានសេសសល់ដោយមគ្គ ពោលគឺ វិរាគៈ ការរលត់មិនកើតឡើងនៃសង្ខារទាំងឡាយ ទើបមាន ដូច្នេះ វិញ្ញាណក៏រលត់ និងព្រោះការរលត់នៃធម៌ទាំងឡាយ មានវិញ្ញាណជាដើម ឈ្មោះថា ធម៌ទាំងឡាយមានរូបជាដើម ក៏រមែងរលត់ទៅដូចគ្នា ដូច្នេះ ហើយទើបត្រាស់ថា ការរលត់នៃកង

ទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះ ។ បណ្តាបទទាំងនោះ បទថា **កេវលស្ស** បានដល់ ទាំងអស់ អធិប្បាយថា កងទុក្ខសុទ្ធៗ វៀរចាកភាពជាសត្វ បទថា **ទុក្ខក្ខន្ធស្ស** ប្រែថា កងទុក្ខ ។ បទថា **និរោធោ ហោតិ** បានដល់ ការមិនកើតឡើង ។

[៩០] បទថា **ឥមស្មឹ អសតិ** ជាដើម បណ្ឌិតគប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

[៩១] ព្រះមានព្រះភាគ លុះត្រាស់បដិច្ចសមុប្បាទទាំងវដ្ដៈ និងវិវដ្ដៈ ដោយអាការយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងត្រាស់សួរដល់ការមិនមាននៃការត្រាច់អន្ទោលទៅ ដែលបុគ្គលដឹងនូវការវិលទៅនៃបច្ច័យ ១២ នេះ ព្រមដោយមគ្គ ក្នុងវិបស្សនាញាណ ដែលលះបានហើយនោះ ទើបត្រាស់ពាក្យថា **អបិនុ តុម្ហេ ភិក្ខវេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯវំ ជានន្តា** បានដល់ ដឹងហើយយ៉ាងនេះ ព្រមដោយវិបស្សនា និងមគ្គ ។ បទថា **ឯវំ បស្សន្តា** ជាវេវចនៈរបស់ពាក្យនោះឯង បទថា **បុព្វន្តំ** អធិប្បាយថា ខន្ធ ធាតុ និងអាយតនៈទាំងឡាយក្នុងអតីត ។ បទថា **បដិធាវេយ្យាថ** គឺថា គប្បីស្ទុះទៅដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ ពាក្យដ៏សេសពិស្តារមានហើយក្នុងសព្វាសវសូត្រ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងត្រាស់សួរដល់ការមិនញាប់ញ័ររបស់ភិក្ខុទាំងនោះ ក្នុងទីនោះ ទើបត្រាស់ពាក្យថា **អបិនុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា ឯវំ វទេយ្យាថ សត្ថា នោ គរុ** ដូច្នេះជាដើម ។ ប្រែថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកដឹងហើយយ៉ាងនេះ ឃើញហើយយ៉ាងនេះ គប្បីពោលយ៉ាងនេះថា ព្រះសាស្តាជាគ្រូរបស់ពួកយើង ។

បណ្តាបទទាំងនោះ បទថា **គរុ** បានដល់ អ្នកពេញទៅដោយភារៈ ជាអ្នកបណ្តោយតាមសេចក្តីប្រាថ្នាក៏មិនមែន ។ បទថា **សមណោ** បានដល់ សមណៈអ្នកត្រាស់ដឹងហើយ ។ បទថា **អញ្ញំ សត្ថារំ ឧទ្ទិសេយ្យាថ** សេចក្តីថា ពួកអ្នកគប្បីជាអ្នកសម្គាល់យ៉ាងនេះថា ព្រះសាស្តានេះ មិនអាចញាំងកិច្ចរបស់ពួកយើងឲ្យសម្រេច ដូច្នេះ ហើយគប្បីលើកតម្កើងសាស្តាដទៃ គឺ ខាងក្រៅព្រះសាសនាខ្លះឬ ។ បទថា **បុថុសមណព្រាហ្មណានំ** គឺ សមណតិរ្ថិយ និងព្រាហ្មណ៍ជាច្រើន ។ បទថា **វតកុតុហលមង្គលានិ** បានដល់ សមាទានវត្ត-បដិបត្តិណាមួយ ភ្ញាក់ពីការឃើញណាមួយ និងទិដ្ឋមង្គល សុតមង្គល មុត្ត-មង្គលណាមួយ ។ បទថា **តានិ សារតោ បច្ចាគច្ឆេយ្យាថ** សេចក្តីថា គប្បីជាអ្នកសម្គាល់សេចក្តីនោះយ៉ាងនេះថា ជាសារៈ ដូច្នេះ ប្រកាន់យក អធិប្បាយថា សូម្បីលះបង់ចេញហើយយ៉ាងនេះ ហើយក៏ប្រកាន់យកទៀត ។ បទថា **សាមំ**

ញាតំ បានដល់ ដឹងខ្លួនឯងដោយញាណ ។ បទថា **សាមំ ទិដ្ឋំ** បានដល់ឃើញខ្លួនឯងដោយបញ្ញាចក្ខុ ។

បទថា **សាមំ វិទិតំ** បានដល់ ធ្វើឲ្យច្បាស់ គឺ ធ្វើឲ្យប្រាកដដោយខ្លួនឯង ។ បទថា **ឧបនីតា ខោ មេ តុម្ហេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នក ដែលតថាគតនាំចូលទៅកាន់និព្វាន ដោយធម៌ដែលមានសភាវៈដែលខ្លួនគប្បីឃើញជាដើមនេះ ។ អធិប្បាយថា ដែលតថាគតឲ្យដល់ហើយ សេចក្តីនៃធម៌ទាំងឡាយ មាន **សន្ទិដ្ឋិកោ** ជាដើម មកពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **ឥទមេតំ បដិច្ច វុត្តំ** សេចក្តីថា ពាក្យនេះយ៉ាងនេះ តថាគតសម្តែងហើយព្រោះអាស្រ័យសេចក្តីដែលពួកអ្នកដឹងដោយខ្លួនឯងជាដើម ។

[៩២] សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ផ្តើមពាក្យថា ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះការប្រជុំព្រមនៃបច្ច័យ ៣ ប្រការ ដូច្នេះ ? ។ ព្រះអង្គទ្រង់ញ៉ាំងទេសនាឲ្យដល់ទីបំផុតហើយ ដោយអំណាចនៃវដ្តៈក្នុងកាលខាងក្រោយមិនមែនឬ ។ ឆ្លើយថា មែន ឲ្យដល់ទីបំផុតហើយ ។ ប៉ុន្តែថា អនុសន្ធិនេះជារបស់ចំពោះបុគ្គល ។ ពិតហើយ លោកសន្និវាសនេះ វង្វេងហើយក្នុងបដិសន្ធិ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបផ្តើមទេសនានេះថា តថាគតនឹងកម្ចាត់ឋានៈដែលជាទីតាំង នៃសេចក្តីវង្វេងរបស់លោកសន្និវាសនោះ ធ្វើឲ្យ

ប្រាកដ ។ម្យ៉ាងទៀត អវិជ្ជា មានវដ្ដៈជាមូល ការកើតឡើងនៃព្រះពុទ្ធ មាន
វិវដ្ដៈជាមូល ព្រោះហេតុនោះ ព្រះមានព្រះភាគ សូម្បីទ្រង់សម្ដែងអវិជ្ជាដែល
មានវដ្ដៈជាមូល និងពុទ្ធុប្បាទ ដែលមានវិវដ្ដៈជាមូលហើយ ទ្រង់ត្រិះរិះថា
តថាគតនឹងញ៉ាំងទេសនាឲ្យដល់ទីបំផុតទៀតក្នុងគ្រាតែមួយ ដោយអំណាចនៃ
វដ្ដៈ និងវិវដ្ដៈដូច្នេះ ទើបផ្ដើមទេសនានេះ ។

បណ្ដាបទទាំងនោះ បទថា **សន្និបាតា** បានដល់ ព្រោះការប្រជុំ គឺថា
ព្រោះប្រមូលមក ។ បទថា **គព្ភស្ស** បានដល់ សត្វអ្នកកើតឡើងក្នុងគភ៌ ។

បទថា **អវក្កន្តិ ហោតិ** បានដល់ ការកើតរមែងមាន ។ ពិតហើយ
ក្នុងទីកន្លែងខ្លះ ផ្ទៃនៃមាតាលោកហៅថា **គភ៌** ។ ដូចដែលពោលទុកថា ៖

**យមេករត្តឹ បឋមំ គព្ភេ វសតិ មាណវោ**

**អព្ភុដ្ឋិតោវ សយតិ ស គច្ឆំ ន និវត្តតិ ។**

ប្រែថា សត្វនៅក្នុងផ្ទៃម្ដាយ រហូតអស់រាត្រីមួយមុន គេក្រោកឡើង
ហើយក៏ដេក គេទៅមិនត្រឡប់ ។ ក្នុងទីកន្លែងខ្លះ លោកហៅសត្វអ្នកកើតក្នុង
គភ៌ថា **គភ៌** ។

ដូចដែលពោលទុកថា **យថា ខោ បនានន្ទ ឥត្ថិយោ អញ្ញា នវ វា
ទស វ វា មាសេ គព្ភំ កុច្ឆិនា បរិហរិត្វា វិជាយន្តិ** ប្រែថា ម្នាលអានន្ទ

ស្ត្រីដទៃៗ រមែងរក្សាទារកអ្នកកើតក្នុងគភ៌ដោយផ្ទៃ ៩ ខែ ឬថា ១០ ខែហើយ ទើបប្រសូត ។ ក្នុងទីនេះ លោកប្រាថ្នាយកសត្វ ។ តម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា **គព្ភស្ស អវក្កន្តិ ហោតិ** ដូច្នេះ សំដៅដល់សត្វនោះ ។ បទថា **ឥធ** បានដល់ ក្នុងសត្វលោកនេះ ។ បទថា **មាតា ច ឧតុនី ហោតិ** នេះ ត្រាស់សំដៅយកវេលាមានរដូវ ។ បានឮថា ទារករមែងកើតដល់មាតុគ្រាមក្នុងឱកាសណា ក្នុងឱកាសនោះ គ្រាប់លោហិតជំតាំងនៅហើយ បែកហូរទៅជាវត្ថុបរិសុទ្ធិ កាលវត្ថុបរិសុទ្ធិ មាតាបិតានៅរួមគ្នាតែមួយគ្រា មានខេត្តប្រាំពីរថ្ងៃតែម្តង ក្នុងសម័យនោះ ទារករមែងកើតឡើងបាន សូម្បីដោយការស្ទាបអង្អែលអវយវៈ មានការចាប់ដៃ ចាប់ផ្នួងសក់ជាដើម ។ បទថា **គន្ធព្វោ** បានដល់ សត្វអ្នកចូលដល់ក្នុងទីនោះ ។ បទថា **បច្ចុបដ្ឋិតោ ហោតិ** នេះ អធិប្បាយថា ឈ្មោះថា សត្វអ្នកសម្លឹងមើលការនៅរួមមាតា និងបិតា ដែលឈរក្នុងទីជិត រមែងមិនមាន ប៉ុន្តែថា សត្វមួយ ដែលកម្មបោះបញ្ជូនទៅហើយ ដែលនឹងកើតឡើងក្នុងឱកាសនោះ មានហើយ ដូច្នេះ ។ បទថា **សំសយេន** សេចក្តីថា ដោយការសង្ស័យក្នុងជីវិតយ៉ាងធំ យ៉ាងនេះថា យើង ឬថា បុត្ររបស់យើង នឹងប្រាសចាកគេទេហ្ន៍ ដូច្នេះ ។

[៩៣] បទថា **លោហិតមេ្ហតំ ភិក្ខវេ** សេចក្តីថា បានឮថា លោហិត

របស់ម្តាយក្នុងគ្រានោះ ដល់ព្រមហើយ និងដល់ព្រមហើយនូវឋានៈនោះ គឺថា រមែងជារបស់ស ដោយសេចក្តីស្នេហាក្នុងបុត្រ ព្រោះដូច្នោះ ទើបព្រះមាន-ព្រះភាគត្រាស់យ៉ាងនោះ ។ បទថា **វង្កំ** បានដល់ កូននង្គ័លរបស់ទារកក្នុងស្រុកសម្រាប់លេង ។ ការលេងវាយឈើខ្លីដោយឈើវែង លោកហៅថា **ឃដិកា** ។ បទថា **មោក្ខចិកំ** បានដល់ ការលេងបង្វិល ។ មានអធិប្បាយថា ការលេងចាប់កំណាត់ឈើក្នុងអាកាស ឬថា លេងយកក្បាលដាក់លើផែនដី ហើយត្រឡប់ទៅមកខាងក្រោមខាងលើ ។ ចក្រវិលទៅដោយការប៉ះខ្យល់ដែលធ្វើដោយវត្ថុទាំងឡាយ មានស្លឹកត្នោតជាដើម លោកហៅថា **បិង្គុលិកៈ** ។ នាឡិធ្វើដោយស្លឹកឈើ លោកហៅថា **បត្តាឡ្ហក** បានដល់ ការលេងវាល់វត្ថុទាំងឡាយ មានខ្សាច់ជាដើម ដោយនាឡិស្លឹកឈើនោះ ។ បទថា **រថកំ** បានដល់ រថតូច ។ **សូម្បីធ្នូ** ក៏បានដល់ ធ្នូតូចទុំះឯង ។ បទថា **សារជ្ជតិ** កើតតម្រេក បានដល់ រមែងញ៉ាំងរាគៈឲ្យកើតឡើង ។ បទថា **ព្យាបជ្ជតិ** បានដល់ រមែងញ៉ាំងសេចក្តីព្យាបាទឲ្យកើតឡើង ។ បទថា **អនុបដ្ឋិតកាយសតិ** សេចក្តីថា សតិក្នុងកាយ ហៅថា កាយសតិ អធិប្បាយថា តាំងកាយសតិនោះ ។ បទថា **បរិត្តចេតសោ** បានដល់ អកុសលចិត្ត ។ បទថា **យត្ថស្ស តេ បាបកា** សេចក្តីថា អកុសលធម៌ដ៏លាមកទាំងនោះ រមែងរលត់ទៅក្នុងផលសមាបត្តិណា រមែង

មិនដឹង រមែងមិនសម្រេចសមាបត្តិនោះ ។ បទថា **អនុរោធវិរោធំ** បានដល់ រាគៈ និងទោសៈ ។ បទថា **អភិនន្ទតិ** បានដល់ រមែងត្រេកត្រអាលដោយអំណាចនៃតណ្ហា កាលបុគ្គលពោលដោយអំណាចនៃតណ្ហាថា ឱសុខហ្ន៎ជាដើម ឈ្មោះថា រមែងរអ៊ូរទាំ ។ បទថា **អជ្ឈោសាយ តិដ្ឋតិ** បានដល់ ទំពារស៊ី គឺ ញ៉ាំងកិច្ចឲ្យសម្រេច ហើយកាន់យកដោយសេចក្ដីជាប់ចិត្តក្នុងតណ្ហា ។ អធិប្បាយថា ចូរត្រេកអរក្រៃលែងចំពោះសុខ ឬចំពោះអទុក្ខមសុខមុន ឬថា រមែងត្រេកអរក្រៃលែងចំពោះទុក្ខយ៉ាងណា ។ កាលបុគ្គលប្រកាន់ថា យើងមានទុក្ខ ទុក្ខជារបស់យើង ដូច្នេះ ឈ្មោះថា រមែងត្រេកអរក្រៃលែងក្នុងទុក្ខ ។ បទថា **ឧប្បជ្ជតិ នន្ទិ** បានដល់ តណ្ហារមែងកើតឡើង ។ បទថា **តទុបាទានំ** សេចក្ដីថា តណ្ហានោះឯង ឈ្មោះថា ឧបាទាន ព្រោះអត្ថថា ប្រកាន់ ។ ក៏បច្ចយាការដែលជាវដ្ដៈ មានសន្ធិបី និងសង្ខេបនេះថា **តស្ស ឧបាទានបច្ចយា ភវោ ។បេ។ សមុទយោ ហោតិ** ដូច្នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ម្ដងទៀត ។

[៩៤-៩៨] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែងការបែកវិវដ្ដៈ ទើបត្រាស់ថា **ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អប្បមាណចេតសោ** សេចក្ដីថា ឈ្មោះថា មានចិត្តរកប្រមាណមិនបាន ព្រោះមានចិត្តជាលោកុត្តរៈដែលប្រមាណមិនបាន អធិប្បាយថា ជាអ្នក

ប្រកបព្រមដោយមគ្គចិត្ត ។

បទថា *ឥមំ ខោ មេ តុម្ហេ ភិក្ខវេ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តឹ ធារេថ* សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរទ្រទ្រង់ចាំ ទេសនាតណ្ហាសង្ខយវិមុត្តិរបស់តថាគត ដែលតថាគតសម្តែងដោយសង្ខេបនេះ រហូតអស់កាលជានិច្ចចុះ កុំវង្វេងភ្លេចឡើយ ។ ពិតណាស់ទេសនាក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ថា *វិមុត្តិ* ព្រោះជាហេតុបានវិមុត្តិ ។ បទថា *មហាតណ្ហាជាលតណ្ហាសង្ឃាដបដិមុក្កំ* សេចក្តីថា តណ្ហា ព្រះមានព្រះភាគត្រាស់ហៅថា សំណាញ់តណ្ហាធំ ព្រោះអត្ថថា ចងរឹតទុក ត្រាស់ថា *សង្ឃាដ* ព្រោះអត្ថថា ចង្អៀតចង្អល់ អធិប្បាយថា អ្នកទាំងឡាយចូរចាំទុកនូវសាតិ-ភិក្ខុកេវដ្តបុត្តនេះថា ជាអ្នកជំពាក់ក្នុងសំណាញ់នៃតណ្ហាធំ និងក្នុងតណ្ហានេះគប្បីចងចាំភិក្ខុនោះថា ជាអ្នកចូលទៅហើយ ប្រាជ្ញានៅចំណែកខាងក្នុង ដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយហើយ ។

( ចប់ អដ្ឋកថា មហាតណ្ហាសង្ខយសូត្រ ទី ៨ )

# អ ដ្ឋ ក ថា

## មហាអស្សបុរសូត្រ ទី ៩

[៨៨] *មហាអស្សបុរសូត្រ មានបទផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងមហាអស្សបុរសូត្រនោះ ។ បទថា* ***អង្គេសុ*** *បានដល់ ពួកអ្នកជនបទឈ្មោះថា* ***អង្គ*** *។ ទីប្រថាប់នៅនៃស្ដេចអង្គៈទាំងនោះ សូម្បីជាជនបទតែមួយ ក៏ហៅថា* ***អង្គា*** *ដូច្នេះ ព្រោះស័ព្ទពង្រីកសេចក្ដីសូម្បីក្នុងអង្គជនបទនោះ ។*

*បទថា* ***អស្សបុរំ នាម អង្គានំ និគមោ*** *សេចក្ដីថា និគមមួយនៃអង្គជនបទ មាននោហារដែលបានហើយដោយឈ្មោះក្រុងថា* ***អស្សបុរ*** *អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ធ្វើនិគមនោះឲ្យជាគោចរគ្រាម ហើយប្រថាប់នៅ បទថា* ***ភគវា ឯតទវោច*** *សេចក្ដីថា ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធវចនៈថា ម្នាលភិក្ខុទាំងឡាយ ប្រជុំជនរមែងស្គាល់ពួកអ្នកថា ជាសមណៈៗ ដូច្នេះជាដើម ។*

*ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគបានត្រាស់យ៉ាងនេះ ។ បានឮថា*

ក្នុងនិគមនោះ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លា មានសេចក្តីរាប់អានព្រះពុទ្ធជាជារបស់យើង រាប់អានព្រះធម៌ជាជារបស់យើង រាប់អានព្រះសង្ឃជាជារបស់យើង ឃើញសូម្បីសាមណេរអ្នកបួសក្នុងថ្ងៃនោះ ក៏ធ្វើឲ្យដូចជាព្រះថេរៈមានវស្សារយវស្សា ។ ពួកគេឃើញភិក្ខុសង្ឃចូលទៅបិណ្ឌបាតក្នុងវេលាព្រឹកសូម្បីកាន់ពូជស្រូវ និងនង្គ័លជាដើម ទៅកាន់ស្រែ សូម្បីកាន់វត្ថុ មានពូថៅជាដើម ចូលទៅកាន់ព្រៃ ក៏នឹងដាក់ឧបករណ៍ទាំងនោះ ហើយបោសសម្អាតទីសម្រាប់អង្គុយរបស់ភិក្ខុសង្ឃ ឬអាសនៈសាលា ឬមណ្ឌប ឬជាគល់ឈើហើយក្រាលអាសនៈទាំងឡាយ តាំងជើងទ្របាត្រ និងទឹកផឹក ហើយនិមន្តឲ្យភិក្ខុសង្ឃអង្គុយ ថ្វាយបាយយាគូ និងរបស់ដែលគួរទំពារជាដើម បញ្ចូនភិក្ខុ-សង្ឃអ្នកធ្វើភត្តកិច្ចស្រេចហើយ ទើបកាន់ឧបករណ៍ទាំងឡាយនោះ ចេញពីទីនោះទៅកាន់ស្រែ ឬព្រៃ ធ្វើការងារទាំងឡាយរបស់ខ្លួន ។ ក្នុងកន្លែងធ្វើការងារ គេក៏មិននិយាយគ្នារឿងដទៃ ពួកគេទាំងនោះ រមែងពោលគុណ សេចក្តីល្អរបស់ភិក្ខុសង្ឃនុ៎ះឯង ដោយពាក្យថា បុគ្គល ៨ គឺ អ្នកតាំងនៅក្នុងមគ្គ ៤ឈ្មោះថា អរិយសង្ឃ ព្រះអរិយសង្ឃទាំងនោះ ប្រកបដោយសីលបែបនេះដោយអាចារៈបែបនេះ ដោយវត្តបដិបត្តិបែបនេះ ជាអ្នកខ្មាសបាប ជាអ្នកមានសីលជាទីស្រឡាញ់ ជាអ្នកមានគុណដ៏ឧឡារដូច្នេះ មកពីកន្លែងប្រកបការងារ

បរិភោគអាហារត្រជាក់ ហើយអង្គុយនៅត្រង់ទ្វារផ្ទះក្តី ចូលទៅបន្ទប់ដេកអង្គុយហើយក្តី ក៏រមែងពោលគុណ គឺ សេចក្តីល្អរបស់ព្រះភិក្ខុសង្ឃទាំងឡាយ ។ ព្រះមានព្រះភាគ ទ្រង់ឃើញសេចក្តីរាប់អានរបស់ពួកមនុស្សទាំងនោះហើយ ទ្រង់ប្រកបភិក្ខុសង្ឃទុកក្នុងសេចក្តីគោរពក្នុងបិណ្ឌបាត ទើបបានត្រាស់ព្រះតម្រាស់នោះ ។

បទថា **យេ ធម្មា សមណករណា ច ព្រាហ្មណករណា ច** សេចក្តីថា ធម៌ពួកណា ដែលបុគ្គលសមាទានឲ្យបរិបូរណ៍ហើយ រមែងធ្វើឲ្យជាសមណៈមានបាបដែលស្ងប់ និងឲ្យជាព្រាហ្មណ៍ មានបាបដែលបន្សាត់ហើយ ដូច្នេះ ។ ក៏ព្រះមានព្រះភាគ ត្រាស់ធម៌ដែលសមណៈគួរធ្វើទុកក្នុងសេចក្តីនេះថា ម្នាលភិក្ខុទាំងឡាយ កិច្ចរបស់សមណៈ ដែលសមណៈគប្បីធ្វើទាំងនេះ មាន ៣ យ៉ាង ៣ យ៉ាងតើដូចម្តេច ? គឺ ការសមាទានអធិសីលសិក្ខា ១ ។ ការសមាទានអធិចិត្តសិក្ខា ១ ការសមាទានអធិប្បញ្ញាសិក្ខា ១ ដូច្នេះ ។ សូម្បីធម៌ទាំងនោះក៏ឈ្មោះថា ជាធម៌ធ្វើឲ្យជាសមណៈដូចគ្នា ។ តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ទេសនាពិស្តារហើយ ដោយអំណាចនៃហិរិឱត្តប្បៈជាដើម ។

ក្នុងបទថា **ឯវំ នោ អយំ អម្ហាកំ** នេះ បទថា **នោ** ត្រឹមតែជានិបាត អធិប្បាយថា ធម៌នេះ នឹងមានដល់ពួកយើង ដោយអាការយ៉ាងនេះ ។ សូម្បី

បទទាំងពីរ គឺ **មហប្ផលា** និង **មហានិសំសា** ពោលដោយអត្ថដូចគ្នាតែម្យ៉ាង ។ បទថា **អវញ្ឈា** បានដល់ មិនជាមោឃៈ ។ បទថា **សផលា** នេះ ក៏មានអត្ថនៃអមោឃៈនុ៎ះឯង ។

ពិតណាស់ ផលនៃសេចក្តីមិនមាន ជារបស់មិនមានផលនោះ ឈ្មោះថា មានទោស ។ បទថា **សឧទ្រយា** ប្រែថា មានផល ពាក្យនេះជាវេវចនៈគ្នា ព្រោះមានផល ។ បទថា **ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីសិក្សាយ៉ាងនេះ ។

ព្រះមានព្រះភាគត្រាស់សរសើរធម៌ មានហិរិ និងឱត្តប្បៈជាដើម ដោយឋានៈនេះ មានប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះ ។ ព្រោះហេតុអ្វី ព្រោះដើម្បីកាត់គន្លងនៃពាក្យនិយាយ ។ ពិតហើយ បើអ្នកណាៗ បួសមិនយូរជាភិក្ខុល្ងង់ គប្បីពោលយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកសមាទានធម៌ មានហិរិ និងឱត្តប្បៈជាដើម ហើយប្រព្រឹត្តចុះ ដូច្នេះ ក៏អ្វីហ្ន៎ ជាអានិសង្ស ក្នុងការសមាទានធម៌ទាំងនោះ ប្រព្រឹត្តដើម្បីកាត់គន្លងនៃពាក្យនិយាយរបស់ភិក្ខុនោះ ។ ព្រះមានព្រះភាគទ្រង់សរសើរថា ធម៌ទាំងនេះ បុគ្គលសមាទាន ធ្វើឲ្យបរិបូរណ៍ហើយ រមែងធ្វើឲ្យមានឈ្មោះថា សមណៈ អ្នកមានបាបស្ងប់ហើយ ឲ្យមានឈ្មោះថា ព្រាហ្មណ៍អ្នកបន្សាត់បាបហើយ ទាំងឲ្យកើតលាភ គឺ

បច្ច័យបួន រមែងញុាំងសេចក្តីមានផលច្រើនឲ្យដល់ព្រម ដល់អ្នកឲ្យបច្ច័យ រមែងធ្វើការបញ្ជាមិនឲ្យមានផល ឲ្យមានផល នេះជាអានិសង្ស ដូច្នេះ ។ គប្បីជ្រាបសេចក្តីដោយសង្ខេបក្នុងទីនេះត្រឹមប៉ុណ្ណេះ តែដោយពិស្តារ គប្បីជ្រាបការពោលសរសើរ ដោយន័យដែលពោលទុកក្នុងសតិប្បដ្ឋាន ។

[១០០] បទថា ***ហិរោត្តប្បេន*** បានដល់ ដោយហិរិ និងឱត្តប្បៈដែលលោកពង្រីកចេញទៅយ៉ាងនេះថា វត្ថុណាដែលបុគ្គលគួរខ្មាស់ រមែងខ្មាស់វត្ថុណា ដែលបុគ្គលគួរខ្លាច រមែងខ្លាច ដូច្នេះ មួយ៉ាងទៀតក្នុងសេចក្តីនេះ ហិរិមានវត្ថុខាងក្នុងជាសមុដ្ឋាន ឱត្តប្បៈមានវត្ថុខាងក្រៅជាសមុដ្ឋាន ហិរិជាអត្តាធិបតេយ្យ ឱត្តប្បៈជាលោកាធិបតេយ្យ ។ ហិរិតាំងនៅក្នុងសភាពនៃសេចក្តីខ្មាស ឱត្តប្បៈតាំងនៅក្នុងសភាពនៃសេចក្តីខ្លាច ។ ក៏កថាពិស្តារក្នុងធម៌ទាំងពីរនេះ ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ដោយអាការទាំងពួង ។

ម៉្យាងទៀត ធម៌ទាំងពីរទាំងនេះ ព្រះមានព្រះភាគត្រាស់ថា ឈ្មោះថាធម៌ជាគ្រឿងគ្រប់គ្រងលោក ព្រោះរក្សាលោក ។ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សុក្កធម៌ទាំង ២ នេះ រមែងគ្រប់គ្រងលោក ២ យ៉ាងតើដូចម្តេច ? គឺ ហិរិ និងឱត្តប្បៈ ម្នាលភិក្ខុទាំងឡាយ សុក្កធម៌ ២ ទាំងនេះ មិនគប្បីគ្រប់គ្រងលោក មិនគប្បីប្រាកដក្នុងទីនេះសោត លោកមិនថា មាតា

ឬអ៊ុំស្រី ម្ដាយមីង ភរិយារបស់អាចារ្យ ឬថា ភរិយារបស់គ្រូ ក៏នឹងដល់ការលាយគ្នាដូចពពែ កែះ មាន់ ជ្រូក ឆ្កែស្រុក ឆ្កែព្រៃ ។ ធម៌ទាំងនេះឯង ព្រះមានព្រះភាគត្រាស់ទុកក្នុងជាតកថា ជាទេវធម៌ ។ ដូចដែលត្រាស់ទុកថា ៖

ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា សន្តោ

សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ ។

ប្រែថា សប្បុរសទាំងឡាយអ្នកស្ងប់ហើយក្នុងលោក អ្នកដល់ព្រមដោយហិរិ និងឱត្តប្បៈ ប្រកបដោយសុក្កធម៌ លោកពោលថា ជាអ្នកមានទេវធម៌ដូច្នេះ ។

ហិរិ និងឱត្តប្បៈ ធម៌ទាំងនេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់ព្រះមហាចុន្ទត្ថេរ ថា ជាបដិបទាគ្រឿងជុសខាត់កិលេស ។ ដូចដែលត្រាស់ទុកថា អ្នកគប្បីធ្វើការជុសខាត់ថា ជនពួកដទៃ នឹងជាអ្នកមិនមានឱត្តប្បៈ យើងនឹងជាអ្នកមានឱត្តប្បៈក្នុងទីនេះ ដូច្នេះ ។ ក៏ហិរិ និងឱត្តប្បៈ ធម៌ទាំងនេះ ព្រះមានព្រះភាគទ្រង់សម្ដែងសម្រាប់ធ្វើឲ្យជាឱវាទូបសម្បទា ពិតណាស់ ព្រះមានព្រះភាគត្រាស់ថា ម្នាលកស្សបៈ ព្រោះហេតុនោះឯង អ្នកគប្បីសិក្សាយ៉ាងនេះថា យើងនឹងចូលទៅតាំងហិរិ និងឱត្តប្បៈយ៉ាងខ្លាំងក្លា ក្នុងព្រះថេរៈ ក្នុងព្រះនវកៈ ក្នុងព្រះមជ្ឈិមៈទាំងឡាយ ដូច្នេះ ម្នាលកស្សបៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ។

តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់សម្តែងហិរិ និងឱត្តប្បៈធម៌ទាំងនេះថា ឈ្មោះថា សមណធម៌ ។ ក៏ព្រោះប្រយោជន៍នៃភាពជាសមណ រមែងមិនដល់ទីបំផុតដោយធម៌មានប្រមាណប៉ុណ្ណោះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ដើម្បីនឹងទ្រង់សម្តែងធម៌ ដែលធ្វើភាពជាសមណៈសូម្បីដទៃៗ ទើបត្រាស់ពាក្យថា **សិយា ខោ បន ភិក្ខវេ តុម្ហាកំ** ជាដើម ។ បណ្តាបទទាំងនោះ ក្នុងបទថា **សាមញ្ញត្ថោ** មុនដំបូងក្នុងគម្ពីរសំយុត្តនិកាយ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ **សាមញ្ញ** ភាពជាសមណៈ តើដូចម្តេច ? អរិយមគ្គ ប្រកបដោយអង្គ ៨ គឺ សម្មាទិដ្ឋិ ។លៗ សម្មាសមាធិ នេះឯង តថាគតហៅថា **សាមញ្ញ** ម្នាលភិក្ខុទាំងឡាយ ក៏ប្រយោជន៍នៃភាពជាសមណៈតើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃរាគៈ ទោសៈ មោហៈណា នេះ តថាគតហៅថា ប្រយោជន៍នៃភាពជាសមណៈ ។ **មគ្គ** លោកហៅថា សាមញ្ញៈ , **ផល** និង **និព្វាន** លោកហៅថា ប្រយោជន៍នៃភាពជាសមណៈ ។ តែក្នុងទីនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមាន-ព្រះភាគត្រាស់ថា ប្រយោជន៍នៃភាពជាសមណៈ ព្រោះរួមទាំងមគ្គ និងផលចូលជាមួយគ្នា ។ បទថា **អារោចយាមិ** ប្រែថា រមែងប្រាប់ ។

បទថា **បដិវេទយាមិ** បានដល់ ដាស់តឿនឲ្យដឹង ។

[១០១] ក្នុងបទថា **បរិសុទ្ធោ នោ កាយសមាចារោ** នេះ បានដល់

កាយសមាចារ ២ យ៉ាង គឺ បរិសុទ្ធិ និងមិនបរិសុទ្ធិ ។ ពិតណាស់ ភិក្ខុណា សម្លាប់សត្វ កាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាម កាយសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ ក៏កាយសមាចារនេះ លោកហាមទុកដោយភាពជាកម្មបថ ។

ក៏ភិក្ខុណា រមែងវាយ រមែងបៀតបៀនអ្នកដទៃ ដោយបាតដៃ ឬដោយដុំដី ដោយកំណាត់ឈើ ឬសស្ត្រា កាយសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ កាយសមាចារសូម្បីនេះ លោកក៏ហាមទុកជាប់ទាក់ទងដោយសិក្ខាបទតែម្យ៉ាង ក្នុងសូត្រនេះ ព្រះមានព្រះភាគ មិនត្រាស់សេចក្តីទាំងពីរនោះ ត្រាស់តែឈ្មោះជាធម៌ដុសខាត់យ៉ាងក្រៃលែង ។

ពិតណាស់ ភិក្ខុណា ឆាដុំដី ឬកំណាត់ឈើ ដោយការដេញក្អែកទាំងឡាយដែលកំពុងផឹកទឹកក្នុងថ្នាំងទឹក ឬចឹកបាយស៊ីក្នុងបាត្រ កាយសមាចាររបស់ភិក្ខុនោះ មិនបរិសុទ្ធិ ។ ផ្ទុយគ្នាឈ្មោះថា សមាចារបរិសុទ្ធិ ។ បទថា **ឧត្តានោ** បានដល់ ឡើងទៅហើយ គឺ ប្រាកដហើយ ។ បទថា **វិវដោ** បានដល់ បើកបង្ហាញ គឺ មិនបិទបាំង រមែងសម្តែងសេចក្តីបរិសុទ្ធិដោយធម៌សូម្បីទាំងពីរនុ៎ះឯង ។ បទថា **ន ច ឆិទ្ទវា** បានដល់ ដូចគ្នាក្នុងកាលគ្រប់កាល គឺ មិនមានប្រហោងក្នុងរវាងចន្លោះ ។ បទថា **សំវុតោ** បានដល់ បិទហើយដោយ

គ្រឿងបិទទ្វារនៃកិលេសទាំងឡាយ មិនមែនដើម្បីត្រូវការបិទបាំងទោស ។

[១០២] សួម្បីក្នុងវចីសមាចារ ភិក្ខុណា និយាយកុហក និយាយសើក សៀត និយាយពាក្យគ្រោតគ្រាត និយាយផ្ដេសផ្ដាស វចីសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ ក៏វចីសមាចារនេះ លោកហាមទុកដោយភាពជាកម្មបថ ហើយ ។ ក៏ភិក្ខុណា កាលពោលមើលងាយដោយពាក្យទាំងឡាយ មានពាក្យ ថា គហបតី ឬថា ទាសៈ ឬថា អ្នកនៅបម្រើជាដើម វចីសមាចាររបស់ភិក្ខុ នោះ ក៏ឈ្មោះថា មិនបរិសុទ្ធិ ។ វចីសមាចារនេះ លោកហាមទុកដោយ សិក្ខាបទ ក្នុងសូត្រនេះ ព្រះមានព្រះភាគ មិនត្រាស់វចីសមាចារទាំងពីរនោះ ត្រាស់តែពាក្យជាធម៌ជុសខាត់កិលេសយ៉ាងក្រៃលែង ។

ក៏កាលភិក្ខុកម្លោះ ឬសាមណេរ ពោលថា បពិត្រលោកដ៏ចម្រើន លោកទាំងឡាយឃើញព្រះឧបជ្ឈាយ៍ របស់ពួកខ្ញុំខ្លះឬ ដូច្នេះ ភិក្ខុណា សូម្បី មានបំណងត្រឹមតែសើច ពោលពាក្យបែបនេះហើយដោយន័យជាដើមថា លោក ដ៏មានអាយុទាំងឡាយ ភិក្ខុនីច្រើនរូបនៅក្នុងអាវាសនេះ ព្រះឧបជ្ឈាយ៍របស់ ពួកលោក នឹងទៅជួយរៀបចំទុកដាក់បន្ទៃលក់ ដូច្នេះ វចីសមាចាររបស់ភិក្ខុ នោះ រមែងមិនបរិសុទ្ធិ ។ វចីសមាចារផ្ទុយគ្នា ឈ្មោះថា បរិសុទ្ធិ ។

[១០៣] ក្នុងមនោសមាចារ ភិក្ខុណាជាអ្នកមានអភិជ្ឈា មានចិត្តព្យាបាទ

ជាអ្នកមានការឃើញខុស មនោសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ ក៏មនោសមាចារទាំងនេះ លោកហាមទុកហើយដោយភាពជាកម្មបថ ។ ក៏ភិក្ខុណាត្រេកអរជាមួយមាស និងប្រាក់ ដែលគេរក្សាទុកដើម្បីខ្លួន មនោសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ មនោសមាចារសូម្បីនេះ ក៏ហាមទុកហើយដោយសិក្ខាបទ ក្នុងសូត្រនេះ មិនត្រាស់ដល់មនោសមាចារទាំងពីរនោះ ដោយត្រាស់តែធម៌ជាគ្រឿងជុសខាត់កិលេសយ៉ាងក្រៃលែង ។ ភិក្ខុណា រមែងត្រិះរិះដល់កាមវិតក្ក ឬព្យាបាទវិតក្ក ឬវិហិង្សាវិតក្ក មនោសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ មនោសមាចារដែលផ្ទុយគ្នា ឈ្មោះថា បរិសុទ្ធិ ។

[១០៤-១០៥] ក្នុងអាជីវៈ ភិក្ខុណា ព្រោះអាជីវៈជាហេតុ រមែងចិញ្ចឹមជីវិតដោយអំណាចអនេសនា ២១ យ៉ាង ដូចធ្វើវេជ្ជកម្ម ទទួលនាំកាត់បួសការឲ្យប្រេងលាបជើង រមែងស្វែងរកប្រេងជាដើម ឬថា ភិក្ខុណាធ្វើវិញ្ញត្តិបរិភោគអាជីវៈរបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ ក៏អាជីវៈដែលមិនបរិសុទ្ធិនេះ ត្រាស់ហាមទុកដោយសិក្ខាបទ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ មិនត្រាស់ដល់អាជីវៈដែលមិនបរិសុទ្ធិទាំងពីរ បានត្រាស់តែធម៌ជាគ្រឿងជុសខាត់កិលេសយ៉ាងក្រៃលែង ។

ពិតណាស់ ភិក្ខុណាបានបច្ច័យ មានទឹកដោះថ្លា ទឹកដោះខាប់ ប្រេង

ទឹកឃ្មុំ និងទឹកអំពៅជាដើម ហើយគិតថា នឹងឆាន់ក្នុងថ្ងៃស្អែកនេះ ថ្ងៃខានស្អែកនេះ ហើយឆាន់វត្ថុដែលខ្លួនសន្សំទុក ។ ឬថា ភិក្ខុណាឃើញផ្កាស្ដៅជាដើមហើយ ពោលនឹងពួកសាមណេរថា ពួកអ្នកចូរទំពារស៊ីស្ដៅ ដូច្នេះ ។ ពួកសាមណេរគិតថា ព្រះថេរៈចង់នឹងទំពារស៊ី ទើបធ្វើឲ្យជាកប្បិយហើយថ្វាយ ។ ភិក្ខុពោលនឹងភិក្ខុកម្លោះ ឬសាមណេរថា ម្នាលអ្នកមានអាយុ ពួកលោកចូរផឹកទឹក ដូច្នេះ ។ ភិក្ខុកម្លោះ ឬសាមណេរទាំងនោះ គិតថា ព្រះថេរៈត្រូវការនឹងផឹកទឹក ទើបធ្វើទឹកនោះឲ្យស្អាត ហើយថ្វាយ ។ អាជីវៈរបស់ភិក្ខុដែលបរិភោគទឹកនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ អាជីវៈផ្ទុយគ្នា ឈ្មោះថា បរិសុទ្ធិ ។

[១០៦] បទថា **មត្តញ្ញូ** បានដល់ អ្នកដឹងប្រមាណ ស្គាល់ប្រមាណ ស្គាល់ល្មមប្រមាណ ក្នុងការស្វែងរក ការទទួល និងបរិភោគ ។

[១០៧] បទថា **ជាគរិយមនុយុត្តា** បានដល់ ធ្វើការបែងចែកពេលយប់ពេលថ្ងៃ ចេញជា ៦ ចំណែក ហើយធ្វើឱកាសដើម្បីការដេកមួយចំណែកប្រកបសេចក្ដីខ្វល់ខ្វាយក្នុងធម៌ជាគ្រឿងភ្ញាក់ ៥ ចំណែក ។

ក្នុងបទថា **សីហសេយ្យំ** នេះ បានដល់ ការដេក ៤ គឺ **កាមភោគិសេយ្យា បេតសេយ្យា សីហសេយ្យា តថាគតសេយ្យា** ។ ក្នុងបណ្ដាការដេកទាំងនោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយដែល

បរិភោគកាមដោយច្រើន រមែងដេកផ្អៀងខាងឆ្វេង ព្រោះដូច្នោះ ការដេកនេះ ទើបឈ្មោះថា **កាមភោគិសេយ្យា** ពិតហើយ ក្នុងបណ្ដាសត្វអ្នកបរិភោគកាមទាំងនោះ ដោយច្រើនមិនដេកផ្អៀងខាងស្ដាំ ។ ម្នាលភិក្ខុទាំងឡាយ ប្រេតដោយច្រើន រមែងដេកផ្ងារ ព្រោះដូច្នោះ ការដេកនេះ ទើបហៅថា **បេតសេយ្យា** ។ ពិតណាស់ ព្រោះមានសាច់ និងឈាមតិច ប្រេតមានឆ្អឹងរគីមរគាម រមែងមិនអាចដេកផ្អៀងម្ខាងបាន ទើបដេកផ្ងារប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ ដោយច្រើនដាក់កន្ទុយចូលទៅក្នុងចន្លោះជើង ហើយដេកផ្អៀងខាងស្ដាំ ព្រោះដូច្នោះ ការដេកនេះ ទើបហៅថា **សីហសេយ្យា** ។ ពិតណាស់ សីហមិគរាជ ព្រោះច្រើនដោយអំណាច ដាក់ជើងទាំងពីរខាងមុខទុកក្នុងទីមួយ ដាក់ជើងទាំងពីរខាងក្រោយទុកក្នុងទីមួយ យកកន្ទុយស៊កចូលក្នុងចន្លោះជើងក្រោយ កំណត់ឱកាសដែលតាំងនៅនៃជើងមុខ ជើងក្រោយ និងកន្ទុយ ហើយទើបដេកដាក់សិរសះលើជើងមុខទាំងពីរ ដេកសូម្បីរហូតអស់មួយថ្ងៃ កាលភ្ញាក់ ក៏មិនមានការខ្វាចរញ្ជើត លើកសិរសះឡើង ហើយកំណត់មើលឱកាសដែលជាទីតាំងនៃជើងមុខជាដើម បើឋានៈអ្វីៗ ដែលខ្លួនតាំងទុកហើយ ខុសប្រក្រតីក៏ជាអ្នកមិនពេញចិត្តថា ឋានៈនេះមិនសមគួរដល់ជាតិ និងភាពជាអ្នកក្លាហានរបស់ខ្លួន ដូច្នេះ ក៏នឹងដេកក្នុងទីនោះឯង មិនចេញទៅរកអាហារ ។ ក៏កាលឋានៈដែល

ខ្លួនតាំងទុកមិនខុសប្រក្រតី ក៏នឹងជាអ្នករីករាយពេញចិត្តថា ឋានៈនេះ សមគួរដល់ជាតិ និងដល់កាលជាអ្នកក្លាហានរបស់ខ្លួន ដូច្នេះ ក្រោកឡើងហើយ ក៏រលាស់ខ្លួនបន្លឺសីហនាទ ៣ ដង ទើបចេញទៅរកអាហារ ។ ក៏ការដេកដោយឈានទាំងបួន ព្រះមានព្រះភាគ ត្រាស់ហៅថា **តថាគតសេយ្យា** ក្នុងបណ្តាការដេកទាំងបួននោះ ការដេកដូចសីហៈ មកហើយក្នុងទីនេះ ព្រោះថា ការដេកនេះឈ្មោះថា ការដេកដ៏ប្រសើរ ព្រោះជាឥរិយាបថរបស់អ្នកច្រើនដោយអំណាច ។

បទថា **បាទេន បាទំ** បានដល់ យកជើងឆ្វេងត្រួតជើងស្តាំ ។ បទថា **ឧច្ចាធាយ** បានដល់ ដាក់ទុកអន្លេញខុសគ្នាបន្តិច ។ ព្រោះថា កជើងខ្ទប់នឹងកជើង ជង្គង់ប៉ះខ្ទប់នឹងជង្គង់ វេទនារមែងកើតជាប់ៗ ចិត្តរមែងមិនស្ងប់ ការដេកក៏មិនសុខស្រួល ឯកជើងនិងកជើង ជង្គង់និងជង្គង់ រមែងមិនប៉ះទង្គិចគ្នាដោយប្រការណា កាលដាក់ទុកដោយប្រការនោះ វេទនារមែងមិនកើតឡើង ចិត្តរមែងស្ងប់ ការដេករមែងសុខស្រួល ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនោះ ។

[១០៩] បទថា **អភិជ្ឈំ លោកេ** ជាដើម ពោលពិស្តារហើយក្នុងចូឡហត្ថិបទោបមសូត្រ ។

[១១០] បទថា **សេយ្យថាបិ ភិក្ខវេ** ជាឧបមា បណ្តាបទទាំងនោះ

បទថា **ឥណមាទាយ** បានដល់ កាន់យកទ្រព្យដោយចេញការប្រាក់ (ទូំ) ។ បទថា **ព្យន្តីករេយ្យ** បានដល់ គប្បីធ្វើឲ្យអស់ទៅ អធិប្បាយថា គប្បីសងទៅវិញទាំងអស់ ។ បទថា **តតោនិទានំ** បានដល់ ហេតុនៃការៈមិនមានបំណុលពិតណាស់ បុរសនោះ កាលរលឹកថា យើងជាអ្នកមិនមានបំណុល ដូច្នេះ ក៏នឹងបានបាមោជ្ជៈ ដល់សេចក្តីសោមនស្ស ដោយហេតុនោះ ទើបព្រះមាន-ព្រះភាគត្រាស់ថា គេគប្បីបាននូវបាមោជ្ជៈ គប្បីដល់ភាពសោមនស្ស ដូច្នេះ ។ ឈ្មោះថា **អាពាធ** ព្រោះកើតវេទនាដែលជាសត្រូវ ព្រោះកម្ចាត់នៅឥរិយាបថដូចត្រូវកាត់ដោយរណា បៀតបៀន អាពាធនោះ មានដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបឈ្មោះថា អ្នកមានអាពាធ ។ ឈ្មោះថា មានទុក្ខ ព្រោះទុក្ខដែលមានអាពាធនោះជាសមុដ្ឋាន ។ ឈ្មោះថា ឈឺធ្ងន់ ព្រោះជម្ងឺមានប្រមាណក្រៃលែង ។ បទថា **នច្ឆាទេយ្យ** បានដល់ មិនគប្បីពេញចិត្ត ព្រោះមានព្យាធិធ្ងន់ជាងមុន ។ បទថា **ពលមត្តា** បានដល់ កម្លាំងនុ៎ះឯង អធិប្បាយថា គេគប្បីមានកម្លាំងកាយ ។ បទថា **តតោនិទានំ** បានដល់ ហេតុនៃការមិនមានរោគ ។ ពិតណាស់ កាលគេរលឹកថា យើងជាអ្នកមិនមានរោគ ដូច្នេះ ហេតុទាំងពីរនោះ រមែងកើតឡើង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **លភេថ បាមោជ្ជំ អធិគច្ឆេយ្យ សោមនស្សំ** ដូច្នេះ ។

បទថា **ន ចស្ស កិញ្ចិ ភោគានំ វយោ** សេចក្តីថា មិនគប្បីវិនាសភោគៈទាំងឡាយ សូម្បីត្រឹមតែមួយកាកណិកៈ ។ បទថា **តតោនិទានំ** បានដល់ហេតុផុតចាកការឃុំឃាំង ។ ពាក្យដ៏សេសក្នុងបទទាំងពួង គប្បីប្រកបដោយន័យដែលពោលហើយ ។ បទថា **អនត្តាធីនោ** បានដល់ ខ្លួនឯងមិនបានជាធំ គឺថា រមែងធ្វើអ្វីៗ មិនបានតាមសេចក្តីពេញចិត្តរបស់ខ្លួន ។

បទថា **បរាធីនោ** បានដល់ អ្នកដទៃជាធំ គឺថា ប្រព្រឹត្តទៅតាមសេចក្តីពេញចិត្តរបស់អ្នកដទៃ ។

បទថា **ន យេនកាមង្គមោ** សេចក្តីថា គេប្រាថ្នានឹងទៅ ត្រូវការទៅដោយទិសាភាគណា រមែងមិនបានដោយទិសាភាគនោះ ។ បទថា **ទាសព្យា** បានដល់ ភាពជាទាសៈ ។ បទថា **ភុជិស្សោ** បានដល់ ជាអ្នកគ្មានបំណុលដល់ខ្លួន ។ បទថា **តតោនិទានំ** បានដល់ ភាពជាអ្នកគ្មានបំណុល ។ បទថា **កន្តារទ្ធានមគ្គំ** បានដល់ ផ្លូវឆ្ងាយកន្តារ អធិប្បាយថា ផ្លូវឆ្ងាយប្រាសចាកទឹក ។ បទថា **តតោនិទានំ** បានដល់ ហេតុជាដែនដ៏ក្សេម ។

ក្នុងបទថា **ឥមេ បញ្ច នីវរណេ អប្បហីនេ** នេះ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់រមែងសម្តែងកាមច្ឆន្ទនីវរណៈ ដែលនៅលះមិនបាន ដូចជាបំណុលនីវរណៈដ៏សេស ដូចជារោគជាដើម ។ ក្នុងសេចក្តីនោះ គប្បីជ្រាបសេចក្តីដូច

គ្នា ដូចតទៅនេះ ៖

ពិតណាស់ បុគ្គលណា ខ្ចីបំណុលគេទៅហើយមិនប្រើ បុគ្គលនោះត្រូវម្ចាស់បំណុលទារថា អ្នកឯងចូរសងបំណុល ដូច្នេះក្តី ត្រូវគេនិយាយពាក្យគ្រោតគ្រាតក្តី ត្រូវគេចាប់ទៅក្តី ត្រូវគេប្រហារក្តី រមែងមិនអាចឆ្លើយឆ្លងអ្វីបាន រមែងអត់ទ្រាំគ្រប់យ៉ាង ព្រោះថា បំណុលនោះ មានការអត់ទ្រាំជាហេតុ យ៉ាងណា បុគ្គលណារមែងត្រេកអរវត្ថុណា ដោយកាមឆន្ទៈ រមែងកាន់យកនូវវត្ថុនោះ ដោយការកាន់យកដោយតណ្ហា ដូច្នោះដែរ បុគ្គលនោះ ត្រូវគេពោលពាក្យគ្រោតគ្រាតក្តី ត្រូវគេចាប់ទៅក្តី ត្រូវគេប្រហារក្តី រមែងអត់ធន់គ្រប់យ៉ាង ព្រោះថា កាមឆន្ទៈនោះ មានការអត់ទ្រាំជាហេតុ ដូចសេចក្តីពេញចិត្តក្នុងកាមរបស់ស្រីទាំងឡាយ ដែលត្រូវស្វាមីក្នុងផ្ទះសម្លាប់ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាប កាមឆន្ទៈប្រៀបបីដូចជាបំណុលយ៉ាងនេះ ។

ដូចបុគ្គលដែលរសាប់រសល់ ព្រោះរោគប្រម៉ាត់ កាលអ្នកណាៗ ឲ្យវត្ថុទាំងឡាយ មានទឹកឃ្មុំ និងដុំស្ករត្នោតជាដើម ក៏រមែងមិនបានរសនៃវត្ថុទាំងនោះ ព្រោះខ្លួនរសាប់រសល់ដោយរោគប្រម៉ាត់ រមែងក្អួតចេញនោះឯង ដោយសម្គាល់ថា រសល្វីងដូច្នេះ យ៉ាងណា បុគ្គលដែលមានចិត្តព្យាបាទ ក៏យ៉ាងនោះដែរ កាលត្រូវអាចារ្យ ឬឧបជ្ឈាយ៍ ដែលប្រាថ្នាប្រយោជន៍ ពោលទូន្មានត្រឹម

តែបន្តិចបន្តួច ក៏មិនទទួលឱវាទ នឹងពោលថា ពួកលោករមែងទាស់ចិត្តជាមួយយើងហួសប្រមាណ ហើយក៏សឹកចេញទៅ គេរមែងមិនប្រសព្វនឹងរសនៃព្រះសាសនា មានសេចក្តីសុខក្នុងឈានជាដើម ព្រោះសេចក្តីរសាប់រសល់ដោយសេចក្តីក្រោធ ដូចបុគ្គលនោះ ដែលមិនបានប្រសព្វនូវរសទឹកឃ្មុំ និងជុំស្ករត្នោតជាដើម ព្រោះសេចក្តីរសាប់រសល់ដោយរោគប្រម៉ាត់ ។ បណ្ឌិតគប្បីយើញព្យាបាទ ដូចរោគយ៉ាងនេះ ។

ភិក្ខុដែលត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ កាលធម្មស្សវនៈការស្តាប់ធម៌សូម្បីមានន័យដ៏វិចិត្រកំពុងប្រព្រឹត្តទៅ ក៏រមែងមិនដឹងខាងដើម កណ្តាល និងទីខាងចុងនៃធម្មស្សវនៈនោះ ដូចបុរសអ្នកត្រូវឃុំឃាំងក្នុងគុក ក្នុងថ្ងៃនក្ខត្តឫក្ស រមែងមិនឃើញខាងដើម កណ្តាល និងខាងចុងនៃការងារនក្ខត្តឫក្ស គេផុតពីគុកក្នុងថ្ងៃទីពីរហើយ សូម្បីបានស្តាប់ពាក្យថា ឱ! កាលថ្ងៃម្សិលមិញមានការងាររីករាយ សប្បាយ មានរបាំ រាំច្រៀង ជាដើម ក៏មិនពោលតប ។ ព្រោះហេតុអ្វី ព្រោះខ្លួនមិនបានជួបប្រសព្វការងារនក្ខត្តឫក្ស ដូច្នោះ ភិក្ខុនោះកាលធម្មស្សវនៈតាំងឡើងហើយ សូម្បីស្តាប់អ្នកដទៃពោលសរសើរធម្មស្សវនៈថា ឱ! ស្តាប់ធម៌ ឱ! ការណៈ ឱ! ឧបមាជាដើម ក៏មិនពោលតប ។ ព្រោះហេតុអ្វី ។ ព្រោះខ្លួនមិនប្រសព្វធម្មកថា ដោយអំណាចនៃថីនមិទ្ធៈ ។ ថីនមិទ្ធៈ បណ្ឌិតគប្បី

ជ្រាប ដូចគុកយ៉ាងនេះ ។

ដូចសេចក្តីថា ទាសៈសូម្បីទឹងកំពុងលេងនក្ខត្តឫក្ស ត្រូវចៅហ្វាយនាយបង្គាប់ថា មានការងារដែលត្រូវធ្វើប្រញាប់បន្ទាន់ឈ្មោះនេះ អ្នកឯងចូរប្រញាប់ទៅទីនោះ បើមិនទៅ យើងនឹងកាត់ដៃ និងជើង ឬត្រចៀក និងច្រមុះរបស់អ្នកឯង ដូច្នេះ គេក៏រមែងប្រញាប់ទៅ រមែងមិនបានដើម្បីប្រសព្វខាងដើម កណ្តាលនិងខាងចុងនៃនក្ខត្តឫក្សនោះ ។ ព្រោះហេតុអ្វី ព្រោះខ្លួន មានអ្នកដទៃជាធំយ៉ាងណា ភិក្ខុដែលមិនដឹងវត្តបដិបត្តិក្នុងព្រះវិន័យ សូម្បីចូលទៅកាន់ទីដទៃដោយវិវេកកថា "រឿងវិវេក" កាលមានការសម្គាល់ក្នុងអកប្បិយៈយ៉ាងណាមួយកើតឡើងហើយ ដោយទីបំផុតសូម្បីក្នុងកប្បិយមំសៈ ក៏លះវិវេក ទៅក្នុងសម្នាក់ព្រះវិន័យធរដើម្បីជម្រះសីល ព្រោះដូច្នោះ លោករមែងមិនបានសោយសេចក្តីសុខ ដែលកើតពីវិវេក ។ ព្រោះហេតុណា ព្រោះត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ក៏យ៉ាងនោះ បណ្ឌិតគប្បីជ្រាបឧទ្ធច្ចកុក្កុច្ចៈ ដូចទាសៈយ៉ាងនេះ ។

ដូចបុរសដើរផ្លូវឆ្ងាយកន្តារ ឃើញឱកាសដែលពួកមនុស្សត្រូវចោរប្លន់ហើយ ក៏រន្ធៀសសង្ស័យថា ពួកចោរមកហើយ ដោយសំឡេងរបស់កំណាត់ឈើខ្លះ ដោយសំឡេងរបស់ព្រានសត្វខ្លះ ដូច្នេះ រមែងដើរទៅខ្លះ ឈប់ខ្លះ រមែងត្រឡប់ខ្លះ កន្លែងដែលមកច្រើនជាងកន្លែងទៅ បុគ្គលនោះ រមែងទៅដល់

កន្លែងដែលជាដែនក្សេមបានដោយលំបាក ឬមិនដល់ យ៉ាងណា វិចិកិច្ឆា គឺសេចក្តីសង្ស័យរបស់បុគ្គលណា ក្នុងឋានៈ ៨ យ៉ាង កើតឡើងហើយ ក៏យ៉ាងនោះដែរ កាលគេសង្ស័យថា **ពុទ្ធោ នុខោ ននុខោ ពុទ្ធោ** ព្រះពុទ្ធមែន ឬមិនមែនព្រះពុទ្ធហ្ន៎ ជាដើម មិនអាចបង្អោនដើម្បីនឹងកាន់យកដោយសទ្ធា កាលមិនអាច ក៏រមែងមិនសម្រេចមគ្គផល ។ កាលបុគ្គលញុំាងសេចក្តីងឿងឆ្ងល់ សង្ស័យ សេចក្តីមិនជឿមាំ ភាពជាអ្នកញុំាងសេចក្តីតក់ស្លុតឲ្យកើតដល់ចិត្តរឿយៗ ថា ពួកចោរមាននៅក្នុងផ្លូវឆ្ងាយកន្តារឬទេហ្ន៎ ដូច្នេះ រមែងធ្វើអន្តរាយសូម្បីដល់ការរួចផុតភ័យ យ៉ាងណា សូម្បីវិចិកិច្ឆាក៏យ៉ាងនោះ ញុំាងសេចក្តីងឿងឆ្ងល់ សង្ស័យ សេចក្តីមិនជឿមាំ ញុំាងសេចក្តីតក់ស្លុតឲ្យកើតដល់ចិត្តរឿយៗ ដោយន័យថា **ពុទ្ធោ** ជាដើម រមែងធ្វើអន្តរាយដល់ការសម្រេចអរិយមគ្គ បណ្ឌិតគប្បីជ្រាប ដូចបុគ្គលដែលដើរផ្លូវកន្តារ ។

ឥឡូវនេះ ក្នុងបទថា **សេយ្យថាបិ ភិក្ខវេ អានណ្យំ** នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងកាមច្ឆន្ទៈដែលលះបង់បានហើយ ឲ្យដូចជាការមិនមានបំណុល និងនីវរណៈដ៏សេសដែលកិក្ខុលះបានហើយ ឲ្យដូចជាការមិនមានរោគជាដើម ។ ក្នុងប្រការនោះ សេចក្តីដូចគ្នា គប្បីជ្រាបដូចតទៅនេះ ៖

ដូចបុរសខ្ចីបំណុលមកហើយប្រកបការងារ សម្រេចការងារហើយ គិតថា

ដែលឈ្មោះថា បំណុលហើយ រមែងជាហេតុឲ្យកង្វល់ចិត្ត ដូច្នេះ ទើបសង បំណុលព្រមទាំងការប្រាក់ ហើយហែកសំបុត្រចោល ។ ចាប់ពីពេលនោះ ក៏ មិនមានអ្នកណាៗ មកទារបំណុល ឬបញ្ជូនសំបុត្រមកទារគេ ។ គេឃើញ ម្ចាស់បំណុលហើយ បើប្រាថ្នានឹងអង្គុយ ឬនឹងក្រោកឡើងពីទីអង្គុយ ឬមិន ប្រាថ្នានឹងអង្គុយ មិនត្រូវការនឹងក្រោកឡើងក៏បាន ។ ព្រោះហេតុអ្វី ព្រោះគេ អស់បំណុលហើយ មិនជាប់ជំពាក់នឹងម្ចាស់បំណុលនោះ យ៉ាងណា ភិក្ខុនេះ គិតថា ឈ្មោះថា កាមច្ឆន្ទៈ មានសេចក្ដីកង្វល់ចិត្តជាហេតុដូច្នេះ ការចម្រើនធម៌ ទាំង ៦ យ៉ាង ដោយន័យដូចពោលទុកក្នុងសតិប្បដ្ឋានហើយ លះកាមច្ឆន្ទនីវ-រណៈ ដូច្នោះដូចគ្នា ។ សេចក្ដីខ្លាច សេចក្ដីតក់ស្លុត រមែងមិនមានដល់បុរស ដែលរួចពីបំណុលហើយ ព្រោះឃើញម្ចាស់បំណុល យ៉ាងណា ការជាប់ជំពាក់ ការពាក់ព័ន្ធរបស់ភិក្ខុដែលមានកាមច្ឆន្ទៈលះបានហើយ រមែងមិនមានក្នុងវត្ថុដទៃ ដូច្នោះដែរ ។ កាលឃើញរូបទាំងឡាយសូម្បីជាទិព្វ កិលេសក៏មិនកើតឡើង ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ការលះកាមច្ឆន្ទៈដូចអ្នកអស់បំណុល ។

ដូចបុរសអ្នកសោះរោស ដោយរោគប្រម៉ាត់ ធ្វើរោគនោះឲ្យស្ងប់រម្ងាប់ ដោយការធ្វើភេសជ្ជៈ ចាប់តាំងពីនោះ រមែងដឹងរសនៃដុំស្ករត្នោតជាដើម យ៉ាងណា ភិក្ខុនោះក៏យ៉ាងនោះដែរ គិតថា ដែលឈ្មោះថា ព្យាបាទៈនេះ ធ្វើ

សេចក្ដីវិនាស មិនមែនជាប្រយោជន៍ ដូច្នេះ ហើយចម្រើនធម៌ ៦ យ៉ាង លះព្យាបាទនីវរណៈបាន ។ ភិក្ខុនោះ ឈ្មោះថា លះសេចក្ដីព្យាបាទបានយ៉ាងនេះ ។ បុរសអ្នកបានជាពីរោគប្រម៉ាត់ហើយ បរិភោគរបស់ផ្អែម មានដុំស្ករត្នោតជាដើម យ៉ាងណា ភិក្ខុនោះ ដែលអាចារ្យឲ្យសិក្សានូវអាចារៈ និងព្រះវិនយបញ្ញត្តិជាដើម ទទួលដោយសិរសៈដោយប្រតិពហើយសិក្សា ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ការលះព្យាបាទ ដូចការមិនមានរោគ ។

បុរស ដែលត្រូវចាប់បញ្ជូនទៅកាន់គុកក្នុងថ្ងៃនក្ខត្តឫក្ស សូម្បីក្នុងថ្ងៃនក្ខត្តឫក្សដទៃទៀត គេគិតថា យើងធ្លាប់ត្រូវឃុំឃាំងដោយទោសនៃសេចក្ដីប្រមាទ ទើបមិនបានលេងក្នុងថ្ងៃនក្ខតឫក្ស ព្រោះទោសនោះ ឥឡូវនេះយើងនឹងជាអ្នកមិនប្រមាទ ដូច្នេះ យ៉ាងណា សត្រូវរបស់គេរមែងមិនបានឱកាស គេជាអ្នកមិនប្រមាទ ទើបបានលេងនក្ខតឫក្ស ហើយថ្លែងឧទានថា **អហោ** ថ្ងៃនក្ខតឫក្ស ដូច្នេះ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដូចគ្នា គិតថា ដែលឈ្មោះថា ថីនមិទ្ធៈនេះ ធ្វើសេចក្ដីវិនាសធំ ដូច្នេះ ទើបចម្រើនធម៌ ៦ យ៉ាង លះបង់ថីនមិទ្ធៈបាន ភិក្ខុនោះឈ្មោះថា លះថីនមិទ្ធៈហើយយ៉ាងនេះ បុរសអ្នករួចអំពីគុក បានលេងនក្ខតឫក្សរហូតអស់ខាងដើម កណ្ដាល និងរហូតចប់បាន សូម្បីទាំង ៧ ថ្ងៃ ក៏បានសោយទាំងខាងដើម កណ្ដាល និងខាងចុងនៃធម្មនក្ខត្ត យ៉ាង

ណា សម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា យ៉ាងនោះដែរ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ការលះថីនមិទ្ធៈ ដូចការរួចពីទីឃុំឃាំង ។

ដូចទាសៈចូលទៅអាស្រ័យមិត្តណាម្នាក់ ឲ្យទ្រព្យដល់នាយចៅហ្វាយ ធ្វើខ្លួនឲ្យជាអ្នកគ្មានបំណុលបានហើយ ចាប់តាំងពីនោះមក គប្បីធ្វើវត្ថុដែលខ្លួនប្រាថ្នាបាន យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ គិតថា ដែលឈ្មោះថា ឧទ្ធច្ចកុក្កុច្ចៈធ្វើសេចក្តីវិនាសធំ ដូច្នេះ ទើបចម្រើនធម៌ ៦ យ៉ាង ហើយលះឧទ្ធច្ចកុក្កុច្ចៈបាន ។ ភិក្ខុនោះឈ្មោះថា លះឧទ្ធច្ចកុក្កុច្ចៈហើយ ដោយអាការយ៉ាងនេះ បុរសជាអ្នកគ្មានបំណុលដល់ខ្លួន ប្រាថ្នានឹងធ្វើវត្ថុណា ក៏ធ្វើវត្ថុនោះបាន អ្នកណានឹងយកគេពីការធ្វើនោះ ដោយកម្លាំងមិនបាន យ៉ាងណា ភិក្ខុរមែងបដិបត្តិនេក្ខម្មប្បដិបទាតាមសប្បាយ ដូច្នោះដែរ ឧទ្ធច្ចកុក្កុច្ចៈអ្នកណាៗ នឹងញ៉ាំងលោកឲ្យត្រឡប់ចាកនេក្ខម្មប្បដិបទានោះ មកកាន់ឧទ្ធច្ចកុក្កុច្ចៈដោយកម្លាំងមិនបាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ការលះឧទ្ធច្ចកុក្កុច្ចៈបាន ដូចភាពជាអ្នកគ្មានបំណុល ។

ដូចបុរសអ្នកមានកម្លាំង កាន់ស្បៀង ត្រៀមអាវុធព្រមទាំងបរិវារ ដើរទៅកាន់ផ្លូវកន្តារ ពួកចោរឃើញគេពីចម្ងាយ គប្បីចៀសចេញទៅ បុរសនោះក៏ឆ្លងផ្លូវកន្តារនោះ ដល់នូវការរួចផុតភ័យបានដោយសេចក្តីសួស្តី គប្បីជាអ្នក

រីកពាយគ្រោកអរហើយ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ គិតថា ឈ្មោះថា វិចិកិច្ឆា នេះ រមែងធ្វើសេចក្ដីវិនាស មិនមែនប្រយោជន៍ ដូច្នេះ ទើបចម្រើនធម៌ ៦ យ៉ាង ហើយលះវិចិកិច្ឆាបាន ភិក្ខុនោះឈ្មោះថា លះវិចិកិច្ឆាហើយ ដោយអាការយ៉ាង នេះ បុរសអ្នកមានកម្លាំង មានអាវុធដែលត្រៀមទុកហើយ ព្រមទាំងបរិវារ ឃើញចោរហើយ មិនខ្លាច មិនញញើតពួកចោរប៉ុនសរសៃសក់ ចេញទៅដល់ ស្ថានទីដែលរួចផុតភ័យដោយសេចក្ដីសួស្ដី យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ កន្លង ផុតផ្លូវកន្តារ គឺ ទុច្ចរិតហើយ ដល់អមតនិព្វាន ជាទីក្សេមយ៉ាងក្រៃលែង ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ការលះវិចិកិច្ឆា ដូចអ្នកដែលដល់ ស្ថានទីរួចផុតភ័យ ។

[១១១] បទថា **ឥមមេវ កាយំ** បានដល់ ករជកាយនេះ ។ បទថា **អភិសន្ទេតិ** បានដល់ ធ្វើឲ្យជោក ធ្វើឲ្យស្នេហា គឺថា រមែងធ្វើបីតិ និងសុខ ប្រព្រឹត្តទៅក្នុងករជកាយទាំងពួង ។ បទថា **បរិសន្ទេតិ** បានដល់ រមែងស្កប់-ស្កល់ដោយជុំវិញ ។ បទថា **បរិបូរេតិ** បានដល់ រមែងពេញ ដូចត្រូវខ្យល់បក់ ។ បទថា **បរិប្ផរតិ** បានដល់ រមែងផ្សព្វផ្សាយដោយជុំវិញ ។ បទថា **សព្វាវតោ កាយស្ស** សេចក្ដីថា កន្លែងសូម្បីបន្តិចបន្តួចតាមស្បែក សាច់ លោហិត ក្នុង ទីបន្តទៅនៃឧបាទិន្នករូបណាមួយ នៃកាយគ្រប់ចំណែករបស់ភិក្ខុនោះ ឈ្មោះថា

មិនពាល់ត្រូវដោយសេចក្ដីសុខក្នុងបឋមឈាន រមែងមិនមាន ។ បទថា **ទក្ខោ** បានដល់ អ្នកឆ្លាតអាចដើម្បីធ្វើ ដើម្បីប្រកប ដើម្បីផ្សំនូវលំអិត សម្រាប់ងូត ។ បទថា **កំសថាលេ** បានដល់ កាជនៈដែលធ្វើដោយលោហៈណាមួយ ។ ក៏កាជនៈដែលធ្វើដោយដីស្អិត ជាភាជនៈមិនរឹងមាំ កាលបុគ្គលជំហើយ រមែងបែកបាន ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបមិនសម្ដែងភាជនៈដែលធ្វើដោយដីស្អិតនោះ ។ បទថា **បរិប្ផោសកំ បរិប្ផោសកំ** ប្រែថា ស្រោចស្រព ។ បទថា **សន្នេយ្យ** សេចក្ដីថា កាន់ថាសសំរឹទ្ធិដោយដៃឆ្វេង ស្រោចស្រពហើយស្រោចស្រពទៀតនូវទឹក ល្មមប្រមាណដោយដៃស្ដាំ ហើយធ្វើឲ្យជាដុំ ។ បទថា **ស្នេហានុគតា** បានដល់ ជាប់គ្នាដោយជ័រស្អិត គឺ ទឹក ។ បទថា **សិនេហបរេតា** បានដល់ ជ្រាបទៅដោយជ័រស្អិត គឺ ទឹក ។ បទថា **សន្តរពាហិរា** សេចក្ដីថា ព្រមទាំងចំណែកខាងក្នុងខាងក្រៅ ។ រមែងពាល់ត្រូវចំណែកទាំងអស់ដោយជ័រស្អិត គឺ ទឹក ។ បទថា **ន ច បគ្ឃរណី** សេចក្ដីថា ទឹករមែងមិនហូរទៅជាតំណក់ៗ អធិប្បាយថា អាចកាន់យកសូម្បីដោយដៃ សូម្បីដោយម្រាមត្រឹមតែពីរម្រាម ដើម្បីធ្វើឲ្យវិលវល់បាន ។

[១១២] គប្បីជ្រាបពាក្យឧបមាសេចក្ដីសុខក្នុងទុតិយជ្ឈាន ។

បទថា **ឧព្ភិតោទកោ** បានដល់ ទឹកដែលមិនហូរទៅ គឺ មិនហូរទៅ

ខាងក្រោម មិនហូរទៅខាងលើ អធិប្បាយថា ជាទឹកកើតនៅក្នុងខាងក្នុងទុំះ ឯង ។ បទថា **អាយមុខំ** បានដល់ ផ្លូវមក ។ បទថា **ទេវោ** បានដល់ ពពក ។ បទថា **កាលេន កាលំ** បានដល់ រាល់កន្លះខែ ឬគ្រប់ ១០ ថ្ងៃ ។ បទថា **ធារំ** ប្រែថា ភ្លៀង ។ បទថា **អានុបវេច្ឆេយ្យ** បានដល់ មិនគប្បីចូលទៅ គឺថា មិនគប្បីធ្លាក់ចុះទៅ ។ អធិប្បាយថា ធ្លារទឹកត្រជាក់ផោរឡើង គឺ ធ្វើអន្លង់ទឹកត្រជាក់ដែលយាំងនៅ ឲ្យពេញហើយ ។

ពិតណាស់ ទឹកដែលផោរឡើងពីខាងក្រោម ធ្វើទឹកដែលផោរឡើងមិនឲ្យហៀរចេញទៅ ទឹកដែលហូរចូលទៅពីទិសទាំងបួន រមែងហូរនាំស្លឹកឈើស្មៅ សំណល់ឈើ កំណាត់ឈើចាស់ជាដើម ទឹករមែងហូរ ព្រោះទឹកភ្លៀងធ្លារទឹកដែលធ្លាក់ចុះមក តែទឹកស្ងប់ស្ងៀមកើតឡើងហើយ រមែងផ្សាយទៅកាន់ប្រទេសនេះ រមែងមិនផ្សាយទៅកាន់ប្រទេសនេះ ដូចនិម្មិតទុកដោយឫទ្ធិ ព្រោះដូច្នោះ ឱកាសដែលទឹកនោះមិនពាល់ត្រូវហើយ រមែងមិនមាន ។ ក្នុងសេចក្តីនោះ ករជកាយប្រៀបដូចអន្លង់ទឹក សេចក្តីសុខក្នុងទុតិយជ្ឈានដូចជាទឹក ។ ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យមុន ។

[១១៣] គប្បីជ្រាបពាក្យឧបមាសេចក្តីសុខក្នុងតតិយជ្ឈាន ផ្កាឧប្បលទាំងឡាយមានហើយក្នុងទីនេះ ព្រោះហេតុនោះ ទីនេះទើបឈ្មោះថា គុម្ពឧប្បល ។

សូម្បីពីរបទដ៏សេសក៏ន័យនេះដូចគ្នា ។ ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីនេះថា ក្នុងពាក្យនេះ បណ្តាផ្កាឧប្បល មានពណ៌ស ពណ៌ក្រហម ពណ៌ខៀវ ផ្កាឧប្បលណាមួយ ក៏ចាត់ជាឧប្បល ឧប្បលដែលមានត្របក ៩៩ សន្លឹក ហៅថា បុណ្ឌរិក មានត្របកមួយរយសន្លឹក ហៅថា បទុម ម្យ៉ាងទៀត ផ្កាឧប្បលពណ៌ស សូម្បីមិនកំណត់ស្លឹក ក៏ហៅថា បទុម ផ្កាឧប្បលពណ៌ក្រហម ហៅថា បុណ្ឌរិក ។

បទថា **ឧទកានុគ្គតានិ** បានដល់ មិនលូតផុតពីទឹក ។ បទថា **អន្តោនិមុគ្គបោសិតានិ** សេចក្តីថា លិចនៅខាងក្នុងទឹកប៉ុណ្ណោះ រមែងពាល់ត្រូវ គឺរមែងចម្រើន ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុនឯង ។

[១១៤] គប្បីជ្រាបពាក្យឧបមាសេចក្តីសុខក្នុងចតុត្ថជ្ឈានតទៅ ក្នុងបទថា **បរិសុទ្ធេន ចេតសា បរិយោទាតេន** នេះ គប្បីជ្រាប ឈ្មោះថា បរិសុទ្ធិ ហើយ ព្រោះអត្ថថា អស់ឧបក្កិលេស ឈ្មោះថា ផូរផង់ហើយ ព្រោះអត្ថថា ត្រចះត្រចង់ ។ បទថា **ឱទាតេន វត្ថេន** នេះ លោកពោលដើម្បីការផ្សាយទៅនៃឱកាស ។ គប្បីជ្រាបសេចក្តីក្នុងសេចក្តីនេះ យ៉ាងនេះថា សំពត់ដែលសៅហ្មង ការអប់កំដៅមិនអាចផ្សាយទៅ ។ ពេលណាដែលសំពត់ស បរិសុទ្ធិស្អាត ការអប់កំដៅ រមែងមានកម្លាំងផ្សាយទៅ ។ ពិតហើយ សម្រាប់ឧបមានេះ

ករជកាយប្រៀបដូចសំពត់ សេចក្តីសុខក្នុងចតុត្ថជ្ឈាន ប្រៀបដូចការផ្សាយទៅនៃឱកាស ព្រោះដូច្នោះ កាលបុរសងូតទឹកជម្រះល្អហើយ អង្គុយដណ្តប់សំពត់សគ្របសិរសៈ ឧតុកើតពីសរីរៈរមែងផ្សាយទូទៅក្នុងសំពត់ទាំងអស់នោះឯង ឱកាសអ្វីៗ មិនជាឱកាសដែលនឹងត្រូវសំពត់ មិនមាន យ៉ាងណា ឱកាសអ្វីៗ ដែលសេចក្តីសុខក្នុងចតុត្ថជ្ឈានទុំះឯង មិនពាល់ត្រូវករជកាយរបស់ភិក្ខុ រមែងមិនមាន ដូច្នោះ ។ មួយវិញទៀត ចិត្តក្នុងចតុត្ថជ្ឈាននោះឯង ប្រៀបដូចសំពត់ដែលដណ្តប់ហើយ រូបដែលមានចិត្តនោះជាសមុដ្ឋាន ប្រៀបដូចការផ្សាយទៅនៃឱកាស ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងទីនេះ យ៉ាងនេះថា ដូចកាលសំពត់សក្នុងទីកន្លែងខ្លះសូម្បីមិនពាល់ត្រូវកាយ កាយក៏ជាចំណែកឱកាស ដែលមានកាយនោះជាសមុដ្ឋាន ពាល់ត្រូវហើយទាំងអស់តែម្យ៉ាង យ៉ាងណា កាយរបស់ភិក្ខុក៏ជាសុខុមរូប ដែលចតុត្ថជ្ឈានឲ្យកើតឡើង ពាល់ត្រូវទូទៅ ក៏ដូច្នោះ ។

[១១៥] គប្បីជ្រាបឧបមាក្នុងបុព្វេនិវាសញ្ញាណ កិរិយាដែលភិក្ខុនោះធ្វើហើយក្នុងថ្ងៃនោះ រមែងប្រាកដច្បាស់ ព្រោះដូច្នោះ ក្នុងថ្ងៃនោះលោកកាន់យកផ្ទះបីខ្នង ក្នុងសេចក្តីនោះបណ្ឌិតគប្បីជ្រាបថា ភិក្ខុដែលបានបុព្វេនិវាសញ្ញាណ ដូចបុរសទៅកាន់ផ្ទះបីខ្នង ។ ភពបី បណ្ឌិតគប្បីឃើញដូចផ្ទះបីខ្នង ។ សេចក្តីជាក់ច្បាស់នៃកិរិយា ដែលភិក្ខុប្រាថ្នាទៅក្នុងបុព្វេនិវាសញ្ញាណ អង្គុយ

ធ្វើហើយក្នុងកពបី បណ្ឌិតគប្បីជ្រាបដូចសេចក្ដីជាក់ច្បាស់នៃកិរិយា ដែលបុរសនោះធ្វើហើយក្នុងថ្ងៃនោះ ក្នុងផ្ទះបីខ្នង ។

[១១៦] គប្បីជ្រាបឧបមាក្នុងទិព្វចក្ខុ បទថា **ទ្វេ អគារា** បានដល់ផ្ទះពីរខ្នង ។ បទថា **សទ្វារា** បានដល់ មានទ្វារខាងមុខ ។ បទថា **អនុចង្កមន្តេ** បានដល់ ដើរទៅមក ។ បទថា **អនុវិចរន្តេ** បានដល់ ត្រាច់ទៅខាងណោះខាងនេះ អធិប្បាយថា គប្បីជ្រាបដោយអំណាចនៃការចេញពីផ្ទះខ្នងនេះ ហើយចូលទៅកាន់ផ្ទះខ្នងនោះ ឬចេញពីផ្ទះខ្នងក្រោយនោះ ហើយចូលទៅកាន់ផ្ទះខ្នងនេះ ។

ក្នុងសេចក្ដីនោះ ចុតិ និងបដិសន្ធិ ប្រៀបដូចផ្ទះពីរខ្នង មានទ្វាររួមគ្នា ភិក្ខុណាមានទិព្វចក្ខុញ្ញាណ ប្រៀបដូចបុរសមានចក្ខុ វេលាដែលសត្វកំពុងនឹងបដិសន្ធិ ប្រាកដដល់ភិក្ខុដែលបានទិព្វចក្ខុ អ្នកចម្រើនអាលោកកសិណ ពិចារណាមើល ប្រៀបដូចវេលាដែលបុរសដើរចូល និងដើរចេញក្នុងផ្ទះទាំងពីរខ្នង ប្រាកដដល់បុរសអ្នកមានចក្ខុឈរសម្លឹងមើលនៅក្នុងរវាងផ្ទះទាំពីរខ្នង ។ សួរថា ក៏កាលនោះប្រាកដដល់ញាណ ឬដល់បុគ្គល ឆ្លើយថា ដល់ញាណ ។ ប៉ុន្តែថា ព្រោះប្រាកដដល់ញាណនោះ ទើបប្រាកដ ដល់បុគ្គលដូចគ្នា ។

[១១៧] គប្បីជ្រាបឧបមានៃអាសវក្ខយញ្ញាណ ដូច្នេះ បទថា **បព្វត-**

**សាន្ទូបេ** បានដល់ កំពូលភ្នំ ។ បទថា **អនាវិលោ** បានដល់ មិនមានកក់ល្បប ។ ខ្យងផង គ្រំផង ឈ្មោះថា ខ្យង និងគ្រុំ ដុំគ្រួសផង ក្បឿងផង ឈ្មោះថា ដុំគ្រួស និងក្បឿង ។ ឈ្មោះថា ហ្វូងត្រី ព្រោះត្រីជាពួក ជាហ្វូង ។ ក្នុងបទថា **តិដ្ឋន្តម្បិ រន្តំបិ** នេះ បានដល់ ដុំគ្រួស និងក្បឿងឈប់ស្ងៀមតែក្រៅពីនេះ មានខ្យងជាដើម ដើរទៅខ្លះ ឈប់ខ្លះ ។ ដូចកាលមេគោឈរខ្លះ ក្រាបខ្លះ ដេកខ្លះ ក្នុងចន្លោះៗ ហ្វូងគោទាំងនេះ រមែងត្រាច់ទៅ ព្រះ-មានព្រះភាគទ្រង់សំដៅយកគោដែលត្រាច់ទៅ ទើបត្រាស់ថា គោក្រៅពីនេះរមែងត្រាច់ទៅ យ៉ាងណា ព្រះមានព្រះភាគទ្រង់សំដៅយកដុំគ្រួស និងក្បឿងដែលនៅស្ងៀមទុំឯង ទើបត្រាស់ថា ពីរពួកក្រៅអំពីនេះស្ងៀម ។ ទ្រង់សំដៅយកពីរពួកនេះឃ្លាតទៅ ទើបត្រាស់ថា សូម្បីដុំគ្រួស និងក្បឿងក៏ឃ្លាតទៅ ដូច្នេះ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបកាលសច្ចៈ ៤ ជាក់ច្បាស់ហើយដល់ភិក្ខុ ដែលអង្គុយបង្អោនចិត្តទៅ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ដូចកាលដែល ខ្យង និងគ្រំជាដើម ប្រាកដច្បាស់ហើយដល់បុរសដែលមានចក្ខុឈរមើល នៅត្រង់មាត់ប្រាំង ដូច្នោះ ។

[១១៨] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់កាន់យកឈ្មោះព្រះខីណាស្រព ទាំងភេទ ទាំងគុណ ដោយអាការ ៧ យ៉ាង ទើបត្រាស់បទថា

**អយំ វុច្ចតិ ភិក្ខវេ ភិក្ខុសមណោ ឥតិបិ** ជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ ក្នុងបទថា **ឯវំ ខោ ភិក្ខវេ ភិក្ខុ សមណោ ហោតិ** ជាដើម អធិប្បាយថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថាសមណៈ ព្រោះមានបាបស្ងប់ហើយ ដោយអាការយ៉ាងនេះ ។ ឈ្មោះថា **ព្រាហ្មណ៍** ព្រោះមានបាបបន្សាត់ហើយ ។ ឈ្មោះថា **ន្ហាតក** (អ្នកងូត) ព្រោះមានកិលេសលាងជម្រះហើយ គឺ មានកិលេសដែលកម្ចាត់ចេញហើយ ។ ឈ្មោះថា **វេទគូ** ព្រោះអកុសលធម៌ទាំងឡាយអស់ហើយ ដោយវេទទាំងឡាយ គឺ មគ្គញាណ ៤ អធិប្បាយថា ព្រោះដឹងហើយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **វិទិតស្ស ហោន្តិ** ជាដើម ។ ឈ្មោះថា **សោត្តិយ** ព្រោះកិលេសទាំងឡាយរលត់ហើយ គឺថា ព្រោះកិលេសទាំងឡាយមិនមិនកម្រើកចេញទៅមក ។ ឈ្មោះថា **អរិយ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ អធិប្បាយថា ព្រោះកិលេសទាំងឡាយត្រូវកម្ចាត់ហើយ ។ ឈ្មោះថា **អរហន្ត** ព្រោះឆ្ងាយ គឺថា ជាអ្នកឆ្ងាយហើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ប្រាកដច្បាស់ហើយនោះឯង ។

( ចប់ អដ្ឋកថា មហាអស្សបុរសូត្រ ទី ៩ )

# អ ដ្ឋ ក ថា

## ចូឡអស្សបុរសូត្រ ទី ១០

[១១៩] *ចូឡអស្សបុរសូត្រមានបទផ្ដើមថា* **ឯវម្មេ សុតំ** *ហេតុនៃការសម្ដែងព្រះសូត្រនោះ ដូចគ្នានឹងព្រះសូត្រមុនទាំងឯង ។ បទថា* **សមណសាមីចិប្បដិបទា** *បានដល់ បដិបទាដែលសមគួរដល់សមណៈទាំងឡាយ គឺ បដិបទាដែលអនុគ្រោះដល់សមណៈទាំងឡាយ ។*

[១២០] *ក្នុងបទថា* **សមណមលានំ** *ជាដើម សេចក្ដីថា ធម៌ទាំងឡាយនេះ កាលកើតឡើង រមែងធ្វើសមណៈទាំងឡាយឲ្យមានមន្ទិល គឺ ប្រឡាក់មន្ទិល ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ជាមន្ទិលរបស់សមណៈ ។ សមណៈទាំងឡាយ រមែងវិនាស រមែងប្រទូសរ៉ាយ ដោយមន្ទិលទាំងនោះ ព្រោះដូច្នោះ ទើបត្រាស់ថា ជាទោសរបស់សមណៈ ។ និងធម៌ទាំងនេះ កើតឡើងហើយ រមែងធ្វើសមណៈទាំងឡាយឲ្យដូចជាសម្រាម អស់ឱជៈ ឲ្យស្ងួត ព្រោះដូច្នោះ ទើបត្រាស់ថា ដូចជាទឹកអម្ចត់របស់សមណៈ ដូច្នេះ ។ បទថា* **អាបាយិកានំឋានានំ** *សេចក្ដីថា ហេតុឲ្យកើតក្នុងអបាយ ។ បទថា* **ទុគ្គតិវេទនីយានំ** *សេចក្ដីថា ជាបច្ច័យនៃការសោយវិបាកក្នុងទុគ្គតិ ។*

បទថា **មតជន្នាម** សេចក្តីថា ពួកមនុស្សគោសដែកដោយដែកហើយ យកកម្ទេចផង់ដែកនោះ លាយនឹងសាច់ឲ្យសត្វក្រៀលស៊ី សត្វក្រៀលទាំងនោះ មិនអាចបន្ទោបង់ឧច្ចារៈ ក៏ស្លាប់ បើមិនស្លាប់ ក៏នឹងប្រហារឲ្យស្លាប់ ។ កាល បើដូច្នោះ ក៏នឹងវះពោះរបស់សត្វក្រៀលទាំងនោះ យកទឹកលាងកម្ទេចដែកទាំង នោះ កាន់យកកម្ទេចល្អិតលាយនឹងសាច់ ឲ្យសត្វក្រៀលទាំងឡាយស៊ី ដូច្នោះ ទើបឲ្យសត្វក្រៀលស៊ីយ៉ាងនេះ ៧ ដង ហើយធ្វើអាវុធដោយកម្ទេចដែកដែល កាន់យកហើយ ជាងដែកសិក្សាល្អហើយ បានមូលហេតុហត្ថកម្មជាច្រើន រមែង ធ្វើអាវុធនោះ គេទើបហៅអាវុធនោះថា **មតជ** ព្រោះកើតពីសត្វដែលស្លាប់ ហើយ ។ អាវុធនោះ ជាអាវុធមុតក្រៃលែងណាស់ ។ បទថា **បីតិនិសិតំ** បានដល់ ជោគដោយទឹក និងសំលៀងដោយថ្ម ។ បទថា **សន្ធាជិយា** បាន ដល់ ស្រោម ។ បទថា **សំបារុត** បានដល់ ដណ្តប់ទុកហើយ ។ បទថា **សម្បលិវេដ្ឋិតំ** បានដល់ ព័ទ្ធទុកដោយជុំវិញ ។

[១២១] បទថា **រជោជល្លិកស្ស** បានដល់ អ្នកប្រឡាក់ប្រឡូសដោយ ធូលី ។ បទថា **ឧទកោរោហកស្ស** បានដល់ ចុះងូតទឹកមួយថ្ងៃបីដង ។ បទថា **រុក្ខមូលិកស្ស** បានដល់ នៅត្រង់គល់ឈើ ។ បទថា **អព្ភោកាសិកស្ស** បាន ដល់ នៅត្រង់ទីវាល ។ បទថា **ឧព្ភដ្ឋកស្ស** បានដល់ ការអេប់កាយ ។ បទថា

**បរិយាយកត្តិកស្ស** បានដល់ ការបរិភោគអាហារមួយខែម្តង ឬថា កន្លះខែម្តង ។ ពាក្យទាំងអស់នោះ ត្រាស់ដល់លទ្ធិខាងក្រៅ ។ ព្រោះក្នុងព្រះសាសនានេះ ភិក្ខុអ្នកទ្រទ្រង់ចីវរ មិនហៅថា គ្រងសង្ឃាដិ ។ ម្យ៉ាងទៀត វត្ត មានការប្រឡាក់ប្រឡូសដោយធូលីជាដើម ក្នុងព្រះសាសនានេះក៏មិនមាន ព្រះតម្រាស់របស់ព្រះពុទ្ធប៉ុណ្ណោះ ជាឈ្មោះរបស់ព្រះពុទ្ធវចនៈ មិនមែនមន្ត ព្រោះដូច្នោះ ក៏បទថា **រុក្ខមូលិកោអព្ភោកាសិកោ** រមែងបានត្រឹមនេះប៉ុណ្ណោះ ។ សូម្បីពាក្យដែលពោលនោះ ក៏ត្រាស់ទុកដោយលទ្ធិខាងក្រៅ ។ បទថា **ជាតមេវនំ** បានដល់ ត្រឹមតែថា កើតហើយក្នុងថ្ងៃនោះឯង ។

បទថា **សង្ឃាដិកំ ករេយ្យុំ** សេចក្តីថា ស្លៀកហើយ ដណ្តប់ហើយនូវសំពត់សង្ឃាដិ គប្បីធ្វើឲ្យជាសង្ឃាដិ ។ ក្នុងពាក្យទាំងពួងក៏ន័យនេះ ។

[១២២] បទថា **វិសុទ្ធិមត្តានំ សមនុបស្សតិ** សេចក្តីថា ភិក្ខុនោះរមែងឃើញខ្លួនថា បរិសុទ្ធិ ។ ប៉ុន្តែថា បទថា **បរិសុទ្ធិ** ដូច្នេះ មិនគប្បីពោលមុន ។ បទថា **បាមោជ្ជំ ជាយតិ** បានដល់ អាការនៃសេចក្តីត្រេកអរ រមែងកើតឡើង ។ អធិប្បាយថា បីតិដែលញ៉ាំងសរីរៈទាំងអស់របស់អ្នករីករាយហើយ រីករាយហើយដោយបីតិ ឲ្យញាប់ញ័រកើតឡើង ។ បទថា **បីតិមនស្ស កាយោ** បានដល់ នាមកាយរបស់បុគ្គលដែលប្រកបហើយដោយបីតិ ។ បទថា **បស្សម្ភតិ**

បានដល់ ប្រាសចាកសេចក្ដីខ្វល់ខ្វាយ ។ បទថា **សុខំ វេទេតិ** សេចក្ដីថា រមែងសោយសេចក្ដីសុខតាមផ្លូវកាយខ្លះ ផ្លូវចិត្តខ្លះ ។ បទថា **ចិត្តំ សមាធិយតិ** សេចក្ដីថា ចិត្តរបស់បុគ្គលដែលមានសេចក្ដីសុខ ដោយនេក្ខម្មសុខនេះ រមែងតាំងមាំ រមែងដូចជាសម្រេចអប្បនា ។ បទថា **សោ មេត្តាសហគតេន ចេតសា** សេចក្ដីថា ទេសនាដែលព្រះមានព្រះភាគទ្រង់ផ្ដើមហើយ ដោយអំណាចនៃកិលេសក្នុងកាលក្រោយ ធ្លាក់ចុះហើយកាន់ការចម្រើនព្រហ្មវិហារ តាមអនុសន្ធិ ដូចភ្លៀងដែលធ្លាក់ហើយធ្លាក់ទៀតលើភ្នំ ហូរចុះកាន់ទន្លេ ដូច្នោះ ។ បណ្ដាបទទាំងនោះ បទដែលគួរពោលទាំងអស់ បានពោលទុកក្នុងវិសុទ្ធិមគ្គ ។ បទថា **សេយ្យថាបិ ភិក្ខវេ បោក្ខរណី** នេះ គប្បីជ្រាបថា ក្នុងមហាសីហនាទសូត្រ មគ្គ ព្រះមានព្រះភាគ ទ្រង់ប្រៀបដោយស្រះបោក្ខរណីធំ ព្រះសាស្ដាក៏ទ្រង់ប្រៀបធៀបទុកក្នុងទីនេះ ។ បទថា **អាសវានំ ខយា សមណោ ហោតិ** សេចក្ដីថា ឈ្មោះថា ជាសមណៈយ៉ាងក្រៃលែង ព្រោះកិលេសទាំងអស់ស្ងប់ហើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានសេចក្ដីងាយនោះឯង ។

( ចប់អដ្ឋកថា ចូឡអស្សបុរសូត្រ ទី ១០ )

# " ចូឡយមកវគ្គ "

# អ ដ្ឋ ក ថា

## សាលេយ្យកសូត្រ ទី ១

[១២៣] សាលេយ្យកសូត្រ មានពាក្យផ្ដើមឡើងថា ខ្ញុំបានស្ដាប់មក ហើយយ៉ាងនេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ក្នុងដែនកោសល** សេចក្ដីថា ក្នុងដែនរបស់អ្នកកោសលទាំងឡាយ គឺ ពួកអ្នកខេត្ត ឬពួករាជកុមារ ឈ្មោះកោសល ។ ខេត្តដែលជាអាវាស ទីអាស្រ័យរបស់អ្នកទាំងនោះ សូម្បីត្រឹមតែខេត្តមួយ ក៏ហៅដោយសំឡេងរត់មាត់ថា "កោសលទាំងឡាយ" បាន ។ ក្នុងខេត្តរបស់ពួកអ្នកស្រុកកោសលនោះ ។ ចំណែកពួកអ្នកជំនាន់មុន លោកថា ព្រោះពីមុនព្រះរាជាបានទ្រង់ស្ដាប់ថា មហាបនាទរាជកុមារ ទតព្រះនេត្រមើលអ្វីៗ សូម្បីតែញញឹមក៏ទ្រង់មិនធ្វើ ទើបត្រាស់ថា អ្នកណាធ្វើឲ្យកូនយើងសើចបាន យើងនឹងយកគ្រឿងស្អិតស្អាងគ្រប់យ៉ាងមកប្រគល់ឲ្យអ្នកនោះ ។

កាលក្រុមមហាជនបោល សូម្បីតែនង្គ័លមកប្រជុំគ្នា ពួកមនុស្សក៏នាំគ្នា

សម្តែងការលេងផ្សេងៗ រយៈកាលជាង ៧ ឆ្នាំ ក៏មិនអាចធ្វើឲ្យព្រះរាជកុមារនោះ ទ្រង់សើចសប្បាយបាន ។ លំដាប់នោះ ព្រះឥន្ទ្រទ្រង់បញ្ជូនទេវតាកំប្លែងទៅ ទេវអង្គនោះសម្តែងអាកប្បកិរិយាកំប្លែងប្រភេទជាទិព្វ ដរាបធ្វើឲ្យទ្រង់សើចសប្បាយបាន ។ លំដាប់នោះ មនុស្សទាំងនោះ ក៏នាំគ្នាចៀសចេញទៅកាន់ទីលំនៅរៀងៗ ខ្លួន កាលជួបពួកសម្លាញ់តាមផ្លូវមក ពួកនោះក៏រាក់ទាក់ប្រាស្រ័យគ្នាថា ល្អទេ ដូច្នោះ ព្រោះអាស្រ័យពាក្យថា ប្រពៃៗ នោះ ប្រទេសនោះទើបហៅថា **កោសល** ។

ពាក្យថា **ស្តេចត្រាច់ចារិក** គឺ ស្តេចកំពុងត្រាច់ចារិកបែបមិនប្រញាប់ ។ ពាក្យថា **ជាមួយពួកភិក្ខុចំនួនច្រើន** គឺ ជាមួយពួកភិក្ខុចំនួនច្រើន ដែលមិនបានកំណត់ច្បាស់យ៉ាងនេះថា រយ ពាន់ ឬសែន ។ ពាក្យថា **ស្រុករបស់ព្រាហ្មណ៍** បានដល់ ប្រជុំជនពួកព្រាហ្មណ៍ ហៅថា ស្រុករបស់ព្រាហ្មណ៍ ។ សូម្បីឃ្លាំងគោគរបស់ពួកព្រាហ្មណ៍ ក៏ជាទីប្រជុំជនក្នុងទីនេះ មិនមែនបំណងយកទីលំនៅរបស់ពួកព្រាហ្មណ៍ ។ ពាក្យថា **រលឹកដល់ទីនោះ** គឺ រលឹកទៅកាន់ទីនោះ សំដៅដល់សេចក្តី **ព្រមហើយ** ។ ចំណែកវិហារ មិនបានកំណត់ពិតប្រាកដទៅក្នុងទីនោះ ។ ដូច្នោះ ទើបក៏នៅជាព្រៃក្រាស់មួយកន្លែង ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយ ដែលនៅជិតៗ នឹងស្រុករបស់ពួកព្រាហ្មណ៍នោះ ។

គប្បីជ្រាបថា ព្រះសាស្តា ស្តេចបានព្រះពុទ្ធដំណើរទៅដល់ព្រៃនោះ ។ ពាក្យថា **បានឮហើយ** ប្រែថា ស្តាប់ហើយ គឺ ចូលទៅបាន បានដល់ ជ្រាបដោយទំនង សំឡេងរំពងនៃពាក្យដែលដល់សោតទ្វារ ។ **ខោ** ជានិបាតចុះក្នុងអត្ថអវធារណៈ គឺ ត្រឹមតែជាធ្វើបទឲ្យពេញ ។ គប្បីជ្រាបអធិប្បាយក្នុងសេចក្តីនេះ យ៉ាងនេះថា បានស្តាប់ហើយដោយអវធារណៈអត្ថក្នុងទីនេះប៉ុណ្ណោះ អន្តរាយនៃការស្តាប់ណាៗ មិនមានដល់ពួកគេ ។ ដោយការធ្វើឲ្យពេញបទ ក៏ត្រឹមតែឲ្យព្យញ្ជនៈមានភាពងាយស្រួលប៉ុណ្ណោះ ។

ឥឡូវនេះ កាលនឹងប្រកាសសេចក្តីដែលបានស្តាប់នោះ ។ លោកទើបបានពោលថា អើនេះនែ៎ គេថា ព្រះសមណគោតម ដូច្នេះជាដើម ។ គប្បីជ្រាបថា ឈ្មោះថា សមណៈ ព្រោះរម្ងាប់បាប ។ ក្នុងបទទាំងនោះ ។ **ខលុ** ជានិបាតចុះក្នុងអត្ថថា **ស្តាប់តាម** ។ **ភោ** ជាពាក្យហៅគ្នានិងគ្នារបស់អ្នកទាំងនោះ ។ **គោតម** ជាពាក្យសម្តែងដោយព្រះគោត្រ របស់ព្រះមានព្រះភាគដូច្នោះ ក្នុងពាក្យទាំងនេះថា នេះនែ៎គេថា ព្រះសមណៈគោតម ទើបគប្បីឃើញអត្ថន័យយ៉ាងនេះថា នេះនែ៎ លោក គេបានឮមកថា ព្រះសមណៈដែលជាគោ-គោត្រ ចំណែកពាក្យថា **ឱរសសក្យ** នេះ ជាពាក្យសម្តែងត្រកូលដែលខ្ពង់ខ្ពស់របស់ព្រះមានព្រះភាគ ។ ពាក្យថា **បួសចេញពីត្រកូលសក្យ** ជាពាក្យសម្តែង

ភាពជាអ្នកបួសដោយសទ្ធា ។ មានពាក្យដែលពោលទុកថា អ្នកដែលមិនត្រូវសេចក្តីវិនាសណាមួយគ្របសង្កត់ មកលះបង់ត្រកូលដែលមិនទាន់អស់ (អ្វីៗទៅឡើយ) ឈ្មោះថា បួសដោយសទ្ធា ។ ពាក្យបន្ទាប់ពីនោះទៅ ក៏មានសេចក្តីដូចបានពោលទុកហើយនោះឯង ។ ពាក្យថា **ក៏ទុះឯង** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថ ប្រាប់ឥត្ថម្ភូតៈ សេចក្តីក៏គឺ របស់ព្រះគោតមដ៏ចម្រើន ។ ពាក្យថា **ដ៏ប្រសើរ** បានដល់ អ្នកប្រកបដោយព្រះគុណដ៏ប្រសើរ មានអធិប្បាយថា អ្នកប្រសើរបំផុត ។ កិត្តិទុះឯង ឬសំឡេងសរសើរ ឈ្មោះថា **កិត្តិស័ព្ទ** ។ ពាក្យថា **ផ្សាយឡើង** គឺ ខ្ចរខ្ចាយឡើងដល់លោក រួមទាំង (លោករបស់ពួក)ទេវតា ។ ពោលដូចម្តេច ? ពោលសូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគនោះ ។ល។ ទ្រង់ជាអ្នកភ្ញាក់ (អ្នកក្រោក អ្នករីកសាយដោយព្រះគុណ) ទ្រង់ជាអ្នកមានជោគល្អ (ទ្រង់មានចំណែកនៃការចែកធម៌ , ទ្រង់ចែកធម៌) ។ តទៅនេះ គប្បីជ្រាបសេចក្តីទំនាក់ទំនងនៃបទក្នុងពាក្យទាំងនោះ ។

ព្រះមានព្រះភាគទ្រង់ជាអរហន្ត សូម្បីព្រោះហេតុនេះ ទ្រង់ជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង សូម្បីព្រោះហេតុនេះ ។ល។ ទ្រង់ជាអ្នកមានជោគល្អ សូម្បីព្រោះហេតុនេះ ។ មានពាក្យអធិប្បាយថា ព្រោះហេតុនេះ ។ល។ ទ្រង់ជាអ្នកមានជោគល្អ សូម្បីព្រោះហេតុនេះ ។ មានពាក្យអធិប្បាយ

ថា ព្រោះហេតុនេះឯង ៗ បទទាំងអស់នេះឯងដែលលោកលើកឡើងជាមាតិកា ដោយទំនងជាដើមថា គប្បីយល់ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាព្រះអរហន្ត ដោយហេតុទាំងនេះមុន គឺ ទ្រង់ឆ្ងាយចាកសឹកសត្រូវ ព្រោះទ្រង់កាច់បំបាក់កាំ (នៃភព) ព្រោះគួរដល់បច្ច័យជាដើម ព្រោះមិនមានសេចក្តីកំបាំងក្នុងការធ្វើអាក្រក់ បានឲ្យពិស្តារហើយក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ៗ គប្បីកាន់យកសេចក្តីពិស្តារនៃបទទាំងនោះ ពីទីនោះចុះ ៗ

ពាក្យថា **ក៏ជាការល្អ** គឺ ក៏ជាសេចក្តីល្អ ៗ មានពាក្យអធិប្បាយថា ជាការនាំយកប្រយោជន៍មកឲ្យ ជាការនាំយកសេចក្តីសុខមកឲ្យ ៗ ពាក្យថា **ពួកព្រះអរហន្តទាំងនោះ** គឺ ព្រះអរហន្តទាំងឡាយ អ្នកបានសេចក្តីជឿតាមថា អ្នកដែលជាព្រះអរហន្តទាំងឡាយក្នុងលោក ក៏ព្រោះការសម្រេចគុណពិសេសតាមសេចក្តីពិតរបស់ពួកព្រះអរហន្ត ដែលឃើញបានលំបាកដោយសែនកោដិ-កប្ប សូម្បីមិនមែនតិច មានរាងកាយជាទីមនោរម្យ ដែលពាសពេញដោយរស្មីនៃមហាបុរិសលក្ខណៈ ៣២ ប្រការ ប្រដាប់ដោយកែវ គឺ អនុព្យញ្ជនៈ ៨០ យ៉ាង ព័ទ្ធព័ទ្ធដោយរស្មីមួយព្យាម មានការឃើញដែលមិនក្តៅ មានសំឡេងនៃធម៌ដ៏ពីរោះក្រៃលែង ដូចដែលព្រះគោតមដ៏ចម្រើននោះ ព្រះអង្គមាន ៗ ពាក្យថា **រមែងជាការឃើញ** គឺ ធ្វើអធ្យាស្រ័យយ៉ាងនេះថា ការបើកភ្នែកដែលមាន

ប្រសាទថ្លាល្អ ហើយមើលក៏ជាការល្អ (ញុំាងប្រយោជន៍ឲ្យសម្រេច) និងបើកាលព្រះអង្គកំពុងសម្តែងធម៌ដោយសំឡេង ដូចសំឡេងព្រហ្ម ដែលប្រកបព្រមទៅដោយអង្គ ៨ បានស្តាប់សូម្បីតែមួយបទ ក៏នឹងជាការល្អផង ។ ពាក្យថា **ចូលទៅគាល់ដល់កន្លែងដែលព្រះមានព្រះភាគប្រថាប់** បានដល់ លះបង់កិច្ចគ្រប់យ៉ាង មានចិត្តត្រេកអរមកហើយ ។

ពាក្យថា **បានពោលពាក្យនេះ** បានដល់ ក៏ការសួរមានពីរយ៉ាង គឺការសួរបែបអ្នកស្រុក ១ ការសួរបែបអ្នកបួស ១ ក្នុងការសួរទាំងពីរយ៉ាងនោះ ការសួរបែបអ្នកស្រុក មកហើយដោយបែបនេះថា លោកម្ចាស់ អ្វីជាកុសល អ្វីជាអកុសល , ការសួរបែបអ្នកបួសមកហើយយ៉ាងនេះថា លោកដ៏ចម្រើន ទាំងនេះឬហ្ន៎ ជាឧបាទានខន្ធ ៥ ចំណែកព្រាហ្មណ៍ និងគហបតីទាំងនេះ កាលនឹងទូលសួរ បែបការសួររបស់អ្នកស្រុកដែលសមគួរដល់ខ្លួន ទើបបានពោលពាក្យជាដើមថា ព្រះគោតមដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីជាបច្ច័យ ? ចំពោះព្រះមានព្រះភាគនោះ ។ ព្រះមានព្រះភាគ កាលទ្រង់ដោះស្រាយបញ្ហាដោយសង្ខេបជាមុនដល់ពួកគេ ប្រភេទដែលពួកគេមិនទាន់អាចកំណត់បាន ទើបត្រាស់ពាក្យជាដើមថា ព្រាហ្មណ៍ និងគហបតីទាំងឡាយ ព្រោះការប្រព្រឹត្តដែលមិនត្រឹមត្រូវ និងការប្រព្រឹត្តដែលមិនសមគួរជាហេតុ សួរថា ហេតុដូចម្តេច

ហ្ន៎ ទើបព្រះមានព្រះភាគ ទ្រង់ដោះស្រាយប្រភេទដែលអ្នកទាំងនោះមិនអាចកំណត់បាន ឆ្លើយថា មានអ្នកពោលថា ព្រោះអ្នកទាំងនោះប្រកាន់ខ្លួនថា ជាបណ្ឌិត រមែងតាំងប្រធានបទហើយ កំណត់ទុកតាំងពីដើមតែម្ដងដោយប្រការណា កាលព្រះអង្គទ្រង់អធិប្បាយសេចក្ដីឲ្យពិស្ដារដោយប្រការនោះ ក៏នាំគ្នាសម្គាល់ទេសនាថា ងាយៗ នាំគ្នាមើលងាយថា សូម្បីកាលពួកយើងនឹងពោលក៏គប្បីពោលយ៉ាងនេះដូចគ្នា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ដោះស្រាយបញ្ហាដោយសង្ខេបៗ មុន ជាប្រភេទដែលពួកអ្នកទាំងនោះមិនអាចនឹងកំណត់បាន បន្ទាប់ពីនោះ កាលពួកអ្នកទាំងនោះមិនអាចនឹងកំណត់បាន ទើបអង្វរសូមឲ្យទ្រង់សម្ដែងពិស្ដារ កាលទ្រង់សម្ដែងដោយពិស្ដារ ទើបត្រាស់ពាក្យជាដើមថា បើយ៉ាងនោះ ព្រាហ្មណ៍ និងគហបតីទាំងឡាយ ក្នុងពាក្យទាំងនោះ ពាក្យថា **បើយ៉ាងនោះ** ជានិបាតចុះក្នុងហេតុ មានសេចក្ដីថា ព្រោះហេតុដែលពួកអ្នកសូមអង្វរតថាគត ។

[១២៤] ពាក្យថា **បីយ៉ាង** គឺ បីចំណែក ។ ពាក្យថា **ដោយកាយ** គឺ ដោយកាយទ្វារ ។ ពាក្យថា **ការប្រព្រឹត្តមិនត្រឹមត្រូវ និងការប្រព្រឹត្តមិនសមគួរ** គឺ ការប្រព្រឹត្តដែលមិនសមគួរ បានដល់ ការប្រព្រឹត្តមិនត្រឹមត្រូវ ។ និងតទៅនេះ ជាអត្ថន័យរបស់បទក្នុងពាក្យទាំងនេះ ។ ការប្រព្រឹត្តអធម៌ ឈ្មោះថា

**អធម្មចរិយា** , មានន័យថា ការធ្វើដែលមិនមែនជាធម៌ ដែលឈ្មោះថា **វិសមចរិយា** ព្រោះប្រព្រឹត្តវេជវេជុប ឬប្រព្រឹត្តជុំៗ ទួលៗ ការប្រព្រឹត្តមិនជាធម៌ និងការប្រព្រឹត្តដែលមិនស្មើនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ការប្រព្រឹត្តមិនមែនជាធម៌ និងការប្រព្រឹត្តដែលមិនស្មើ គប្បីជ្រាបអត្ថន័យក្នុងបទចំណែកខ្មៅ និងចំណែកសគ្រប់បទ ដោយឧបាយនេះ ។

ពាក្យថា **ប្រទូស្ត** បានដល់ គ្រោតគ្រាត ឃោឃៅ អន្ទះអន្ទែង ស្លុះមួយរំពេច ។ ពាក្យថា **មានដៃប្រលាក់ឈាម** បានដល់ ប្រលាក់ដោយឈាមដែលដៃរបស់អ្នកដែលកំពុងសម្លាប់សត្វដទៃចាកជីវិត សូម្បីនឹងមិនប្រលាក់បុគ្គលបែបនោះ លោកក៏នៅតែហៅថា មានដៃប្រលាក់ឈាមទុំះឯង ពាក្យថា **តាំងមាំនៅក្នុងការសម្លាប់ ការប្រហារ** បានដល់ តាំងមាំក្នុងការសម្លាប់ ការឲ្យប្រហារសត្វដទៃ និងក្នុងការសម្លាប់ គឺ ការធ្វើឲ្យសត្វដទៃស្លាប់ ។ ពាក្យថា **មិនប្រកបដោយសេចក្តីអាណិត** គឺ មកដល់ភាពជាអ្នកមិនមានសេចក្តីអាណិត ។ ពាក្យថា **របស់អ្នកដទៃនោះ** គឺ វត្ថុដែលមាននៅក្នុងរបស់អ្នកដទៃនោះឯង ។ ពាក្យថា **ឧបករណ៍ជាគ្រឿងរីករាយចិត្ត** បានដល់ ឧបករណ៍ជាគ្រឿងរីករាយចិត្តរបស់អ្នកដទៃទុំះឯង គឺ គ្រឿងបរិក្ខារដែលធ្វើឲ្យកើតសេចក្តីត្រេកអរដល់អ្នកដទៃនោះ ។ ពាក្យថា **ឬនៅក្នុងពួកអ្នកស្រុក** គឺ ឬទីតាំងទុកខាងក្នុង ពួកអ្នក

ស្រុក ។ ពាក្យថា **ឬនៅក្នុងព្រៃ** គឺ តាំងទុកក្នុងព្រៃ ឬលើចុងឈើ នាកំពូលភ្នំជាដើម ។ ពាក្យថា **ដែលមិនឲ្យ** គឺ ពួកគេមិនបានឲ្យដោយកាយ ឬដោយវាចា ។ អ្នកលួច ឈ្មោះថា **លួច** ក្នុងទីនេះ ។ **ភាវៈនៃចោរ** ឈ្មោះថា ភាពជាចោរ ។ ពាក្យនេះជាឈ្មោះនៃចិត្តគិតនឹងលួច ។ ពាក្យថា **ចំណែកនេះ** ជាឈ្មោះនៃចំណែកមួយដោយសេចក្តី ។ ដូចក្នុងពាក្យជាដើមថា **ក៏ចំណែកនៃធម៌ជាគ្រឿងយឺតយូរ ដែលមានសញ្ញាជាមូល** ចំណែកនោះផង ភាពជាចោរផងហេតុនោះ ឈ្មោះថា ចំណែកនៃភាពជាចោរ មានសេចក្តីថា ចំណែកនៃចិត្តមួយពោលគឺ ចិត្តគិតនឹងលួច ។ និងពាក្យថា ចំណែកនៃភាពជាចោរនេះ ជាបឋមាវិភត្តិចុះក្នុងអត្ថតតិយាវិភត្តិ ដូច្នោះ ទើបគួរឃើញដោយសេចក្តីថា **ដោយចំណែកនៃភាពជាចោរ** ដូច្នេះ ។

ក្នុងពាក្យថា **ដែលមាតាគ្រប់គ្រង** ជាដើម មានអធិប្បាយថា កាលបាត់បង់ ឬស្លាប់ទៅហើយ មាតាថែរក្សាដោយអាហារ និងគ្រឿងស្លៀកដណ្តប់ជាដើម គិតថា នឹងឲ្យមានការគ្រប់គ្រងផ្ទះ កាលធំឡើងហើយ រមែងគ្រប់គ្រងកូនស្រីណាទុក បុគ្គលនេះឈ្មោះថា មាតាគ្រប់គ្រង ។ សូម្បីបិតាគ្រប់គ្រងជាដើម ក៏គប្បីជ្រាបដោយឧបាយនេះ ។ ចំណែកត្រកូលដែលស្រឡាញ់ពេញចិត្តគ្នា ធ្វើការព្រមព្រៀងគ្នា តាំងពីកូននៅក្នុងផ្ទៃថា បើចំណែកខ្ញុំមានកូនប្រុស

ឯអ្នកមានកូនស្រី ឲ្យទៅទីដទៃមិនបាន ត្រូវជារបស់កូនប្រុសខ្ញុំប៉ុណ្ណោះ ស្រីដែលមានចំណងតាំងពីនៅក្នុងផ្ទៃដូច្នេះ ឈ្មោះថា **មានប្ដី** ។ ចំណែកស្ត្រីដែលត្រូវទោសគេបណ្ដើរតាមស្រុក ផ្ទះ ឬថ្នល់ ហើយដាក់ទោសយ៉ាងនេះថា អ្នកណាទៅរកស្ត្រីឈ្មោះនេះ និងត្រូវពិន័យទោសប៉ុណ្ណេះ ឈ្មោះថា មានទណ្ឌដោយជុំវិញ ។ ពាក្យថា **ដោយទីបំផុតសូម្បីតែស្ត្រីដែលបោះកម្រងផ្កាទៅ** គឺដោយកំណត់យ៉ាងទាបបំផុតជាងគេ ស្ត្រីដែលបុរសណាមួយកំពុងបោះកម្រងផ្កាទៅលើនាង ដោយសម្គាល់ថា នាងនេះនឹងជាភរិយារបស់យើង ហើយក៏ត្រូវយកត្រឹមតែកម្រងផ្កាប៉ុណ្ណោះ បោះទៅ ។ ពាក្យថា **រមែងជាអ្នកល្មើសចារិតក្នុងពួកស្ត្រីបែបនោះ** បានដល់ រមែងជាអ្នកធ្វើការឈានកន្លងក្នុងស្ត្រីបែបនោះ ដោយអំណាចលក្ខណៈការប្រព្រឹត្តខុស ដែលពោលហើយក្នុងសម្មាទិដ្ឋិសូត្រ ។

ពាក្យថា **នៅក្នុងទីប្រជុំ** គឺ ឈរក្នុងសភា ។ ពាក្យថា **នៅក្នុងបរិស័ទ** គឺ ឈរក្នុងបរិស័ទ ។ ពាក្យថា **នៅកណ្ដាលញាតិ** គឺ នៅកណ្ដាលពួកទាយាទ ។ ពាក្យថា **នៅកណ្ដាលបក្ខពួក** គឺ នៅកណ្ដាលកងទាហាន ។ ពាក្យថា **នៅកណ្ដាលរាជត្រកូល** គឺ នៅក្នុងកណ្ដាលព្រះរោងធំក្នុងរាជត្រកូល ។

ពាក្យថា **ត្រូវនាំទៅ** គឺ ត្រូវនាំទៅដើម្បីត្រូវការនាំ ។ ពាក្យថា **ត្រូវ**

**នាំសាក្សី** គឺ ត្រូវធ្វើជាសាក្សីហើយនាំ ។ ពាក្យថា **នែ៎នាយមកនេះ** នេះជាពាក្យសម្រាប់ស្រែកហៅ ។ ពាក្យថា **ព្រោះខ្លួនជាហេតុ ឬព្រោះអ្នកដទៃជាហេតុ** គឺ ព្រោះហេតុនៃដៃ និងជើងជាដើមរបស់ខ្លួន ឬរបស់អ្នកដទៃ ឬព្រោះហេតុនៃទ្រព្យ ។

ពាក្យថា **លាភ** លោកបំណងថា អាមិស ក្នុងបទថា **ឬព្រោះឃើញដល់អាមិសបន្តិចបន្តួចជាហេតុ** នេះ ព្រោះដូច្នោះ ពាក្យថា **បន្តិចបន្តួច** ទើបសំដៅសេចក្ដីដល់របស់មិនសំខាន់ គឺ តិចតួច អធិប្បាយពោលដោយទីបំផុតព្រោះហេតុនៃទ្រព្យដែលមាន គ្រាន់តែសត្វទទា សត្វក្រួច ដុំទឹកដោះថ្លា និងដុំខ្លាញ់ខាប់ជាដើម ។

ពាក្យថា **រមែងជាអ្នកនិយាយកុហកទាំងដែលដឹងខ្លួន** គឺ ទាំងដែលដឹងខ្លួនពិតៗ ក៏នៅជាអ្នកធ្វើឲ្យជាពាក្យកុហក ។ ពាក្យថា **ដើម្បីទម្លាយពួកនេះ** គឺ បានឮក្នុងសម្នាក់របស់បុគ្គលណាមួយ ដែលលោកហៅថា ក្រៅពីនេះ ដើម្បីទម្លាយជនទាំងនោះ ។ ពាក្យថា **ដើម្បីទម្លាយជនឯណោះ** គឺ បានស្ដាប់ពាក្យរបស់បុគ្គលពួកណា ដែលលោកពោលថា ឯណោះ ដើម្បីទម្លាយពួកជននោះ ។ ពាក្យថា **ឬជាអ្នកទម្លាយ អ្នកដែលព្រមព្រៀងគ្នាហើយយ៉ាងនេះ** បានដល់ ឬជាអ្នកធ្វើឲ្យសម្លាញ់ពីរចំណែក ដែលស្មោះស្ម័គ្រគ្នាយ៉ាងនេះ ឲ្យបែក

គ្នា ។ ពាក្យថា **ឬសរសើរអ្នកដែលបែកគ្នាហើយ** គឺ ជាអ្នកសរសើរ គាំទ្រ ដើម្បីឲ្យអ្នកដែលបែកគ្នាហើយ ព្រមព្រៀងគ្នាទៀតមិនបាន យ៉ាងនេះថា លោកធ្វើល្អហើយគេនឹងលះបង់បាន ពីរបីទៀតថ្ងៃប៉ុណ្ណោះ គេនឹងធ្វើឲ្យលោកវិនាសធំ អធិប្បាយថា ជាអ្នកបន្ទុលហេតុឲ្យ ។ **ពួកអ្នកដែលមកត្រេកអរ** គឺ ជាទីតាំងនៃសេចក្តីត្រេកអរក្រៃលែងរបស់គេ ហេតុនោះ គេទើបឈ្មោះថា មានពួកជាអ្នកមកត្រេកអរ ។ ពាក្យថា **អ្នកត្រេកអរហើយក្នុងពួក** គឺ ត្រេកអរហើយក្នុងពួកទាំងឡាយ ។ ឈ្មោះថា រីករាយក្នុងពួក ព្រោះឃើញ បានឮថា ពួកក៏រមែងរីករាយ ។ ពាក្យថា **វាចាធ្វើឲ្យជាពួក** គឺ វាចាណាធ្វើសត្វឲ្យជាពួក គឺ ទម្លាយសត្វសូម្បីដែលព្រមព្រៀងគ្នាហើយ ជាអ្នកនិយាយវាចាដែលបន្តការឈ្មោះនោះ ។

ពាក្យថា **អាក្រក់** គឺ ឈ្មោះថា ទ្រគោះដោយពាក្យគម្រាម និងពាក្យគ្របសង្កត់ជាដើម ព្រោះជាវាចាដែលមានទោស ដូចប៉មដែលតាំងឡើងត្រង់ដើមឈើងាប់ ដូច្នោះ ។ ពាក្យថា **គ្រោតគ្រាត** គឺ វិនាស ជាវាចាដែលគ្រោត-គ្រាត ដូចដើមឈើងាប់ ជាដើមឈើពុក មានខ្ទុតស៊ី ដូច្នោះ ។ វាចានោះរមែងដូចគ្នានឹងកោសត្រចៀក ដូច្នោះ លោកទើបហៅថា គ្រោតគ្រាត ។ ពាក្យថា **ដុតកម្តៅដល់អ្នកដទៃ** គឺ ជាវាចាដែលដុតកម្តៅ មិនគួររីករាយចិត្តនៃអ្នក

ដទៃ គឺ ជាវាចាដែលធ្វើឲ្យកើតជម្លោះ ។ ពាក្យថា **ចាក់រុកអ្នកដទៃ** គឺ បានដល់ វាចាដែលចាក់ទៅក្នុងរបស់ស្រឡាញ់ ដូចជាមែកឈើមានបន្លាប៉ះត្រូវធ្វើឲ្យកើតការមុត ព្រោះមិនឲ្យទៅសូម្បីដល់អ្នកដែលចង់ទៅ ។ ពាក្យថា **ជិតចំពោះសេចក្ដីក្រោធ** គឺ ជិតចំពោះសេចក្ដីក្រោធ ។ ពាក្យថា **មិនប្រព្រឹត្តទៅដើម្បីសមាធិ** គឺ ជាវាចាដែលមិនប្រព្រឹត្តទៅដើម្បីអប្បនាសមាធិ ឬឧបចារ-សមាធិ ។ ដូចដែលពោលមកទាំងអស់នេះ សុទ្ធតែជាពាក្យប្រើជំនួសវាចាដែលមានទោសទាំងនោះឯង ។

ពាក្យថា **មានប្រក្រតីនិយាយខុសកាល** គឺ ជាអ្នកនិយាយដោយមិនមានវេលា ។ ពាក្យថា **មានប្រក្រតីនិយាយមិនពិត** គឺ ជាអ្នកនិយាយវត្ថុដែលមិនមាន ។ ពាក្យថា **មានប្រក្រតីនិយាយមិនជាផលប្រយោជន៍** គឺ ជាអ្នកនិយាយពាក្យមិនអាស្រ័យហេតុ ។ ពាក្យថា **មានប្រក្រតីនិយាយមិនជាធម៌** គឺ ជាអ្នកនិយាយពាក្យដែលមិនជាសភាវៈ ។ (មិនមានផល?) ។ ពាក្យថា **មានប្រក្រតីនិយាយមិនជាវិន័យ** គឺ ជាអ្នកនិយាយពាក្យដែលមិនប្រកបដោយសំវរៈវិន័យជាដើម ។ ពាក្យថា **មិនមានគោលឋាន** គឺ រមែងជាអ្នកនិយាយវាចាដែលមិនសមគួរ និងរក្សាទុកក្នុងទូ គឺ បេះដូង ។ ពាក្យថា **ដោយមិនជ្រើសរើសវេលា** គឺ រមែងជាអ្នកនិយាយក្នុងវេលាដែលមិនសមគួរមុន ឬក្រោយ

វេលាដែលត្រូវនិយាយ ។ ពាក្យថា **មិនមានទីអាង** គឺ វៀរចាកទីអាង គឺសូត្រ ។ ពាក្យថា **មិនមានទីបញ្ចប់** គឺ លើកយកព្រះសូត្រ ឬជាតកដែលមិនមានលំដាប់មកហើយ នាំយករឿងដែលល្មមនឹងចូលគ្នានឹងព្រះសូត្រ ឬជាតកនោះ បានប្រការប្រៀបផ្ទឹម ឬវត្ថុមកហើយត្រឡប់ទៅពោលពាក្យដែលក្រៅរឿងទៅវិញ ។ ពាក្យដែលលើកមកហើយ ក៏ត្រឹមតែថា លើកឡើងមកប៉ុណ្ណោះឯង ។ គេរមែងដល់ភាពជាអ្នកដែលអ្នកដទៃគប្បីដឹងថា គេរមែងពោលសូត្រឬហ្ន៎ ? ឬជាតក ។ ពួកយើងមិនឃើញការបញ្ចប់ ឬទីបំផុតរបស់សូត្រ ឬជាតកនោះសូម្បីអ្នកនេះ ក៏រមែងឈ្មោះថា ជាធម្មកថិកពួរជ្រៃ រមែងធ្វើបទដែលលើកឡើងមកតាំង ឲ្យត្រឹមតែលើកមកតាំងទុកប៉ុណ្ណោះ ហើយក៏ពោលទៅរឿយៗបែបខាងៗ យ៉ាងនោះឯង ដូចជាឫសរបស់មែកជ្រៃដែលធ្លាក់ ធ្លាក់ចុះទៅក្នុងទីដែលវាធ្លាក់ទៅហើយ សូម្បីទីដែលវាធ្លាក់ចុះហើយ ក៏រមែងចម្រើនទៀតនោះឯង វាទៅបានបែបនេះឯង ប្រមាណកន្លះយោជន៍ខ្លះ មួយយោជន៍ខ្លះ តាំងនៅជាជួរតែមួយនោះឯង យ៉ាងណា ក៏ដូច្នោះ ។ ចំណែកអ្នកណាសូម្បីនឹងនិយាយច្រើន ក៏នៅតែអាចដើម្បីឲ្យនាំយកមក ហើយដឹងបានថា លោកនិយាយពាក្យនេះដើម្បីវត្ថុនេះ អ្នកនោះនឹងពោលក៏គួរ ។ ពាក្យថា **មិនប្រកបដោយប្រយោជន៍** គឺ មិនប្រកបដោយប្រយោជន៍នោះឯង ។

ពាក្យថា **រមែងជាអ្នកសម្លឹងរំពៃ** បានដល់ រមែងជាអ្នកក្រឡេកមើលដោយការសម្លឹងរំពៃ ។ ពាក្យថា **ឱហ្ន៎** ជានិបាតចុះក្នុងអត្ថថា ប្រាថ្នា ។ ក៏ក្នុងសេចក្ដីនេះ ដោយអាការត្រឹមតែក្រឡេកមើលដោយការសម្លឹងរំពៃប៉ុណ្ណោះ ការបែកធ្លាយកម្មបថមិនទាន់មាន , កាលបង្អោនមកជារបស់ខ្លួនថា ធ្វើយ៉ាងណាហ្ន៎ វត្ថុនេះនឹងគប្បីជារបស់ខ្ញុំ ខ្ញុំគប្បីដាក់អំណាចឲ្យប្រព្រឹត្តទៅក្នុងវត្ថុនេះ ដូច្នេះ កម្មបថទើបបែកធ្លាយ ។ លោកសំដៅការសម្លឹងរំពៃបែបនេះ ក្នុងទីនេះ ។

ពាក្យថា **មានចិត្តព្យាបាទ** គឺ មានចិត្តខូច បានដល់ មានចិត្តផ្អូមស្អុយ ។ ពាក្យថា **មានសេចក្ដីត្រិះរិះដោយចិត្តប្រទុស្ត** បានដល់ មានសេចក្ដីត្រិះរិះដោយចិត្ត ដែលត្រូវទោសៈប្រទូសរ៉ាយ ។ ពាក្យថា **ចូរត្រូវសម្លាប់** គឺ ចូរត្រូវធ្វើឲ្យស្លាប់ ។ ពាក្យថា **ចូរត្រូវធ្វើឲ្យស្លាប់** គឺ ចូលដល់ការសម្លាប់ ។ ពាក្យថា **ឬកុំបានមានឡើយ** គឺ សូម្បីតែអ្វីៗ ក៏កុំបានមានឡើយ ។ សូម្បីក្នុងសេចក្ដីនេះ ដោយហេតុត្រឹមតែសេចក្ដីកម្រើក (ក្រោធ) កម្មបថក៏មិនបែកធ្លាយ ។ នឹងបែកធ្លាយ ក៏ព្រោះគិតជាដើមថា ចូរត្រូវសម្លាប់ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។

ពាក្យថា **អ្នកមានការឃើញខុស** គឺ អ្នកមានសេចក្ដីឃើញដោយអកុសល ។ ពាក្យថា **មានការឃើញវិបរិត** គឺ មានការឃើញក្នុងចិត្តឃ្លៀង

ឃ្លាតទៅ ។ ពាក្យថា **ទានដែលឲ្យហើយមិនមានផល** គឺ ព្រះមានព្រះភាគ ត្រាស់សំដៅយកការមិនមានផលរបស់ទានដែលឲ្យហើយ ។ **ការបូជាធំ** លោក ហៅថា **យិដ្ឋ** ការបូជា សក្ការៈដែលត្រឹមតែល្មមទ្រង់បំណាច់ថា **ហុត** ការសែន ប្រួនស្រួន គេសំដៅយកការមិនមានផលប៉ុណ្ណោះ ទើបហាមវត្ថុទាំងពីរសូម្បីនោះ ។ ពាក្យថា **នៃកម្មដែលធ្វើល្អ និងធ្វើអាក្រក់** មានសេចក្តីថា នៃកុសល និង អកុសល ដែលធ្វើល្អ និងធ្វើមិនល្អ ។ ពាក្យដែលថា **ផលវិបាក** នោះ នឹង ហៅថា ផល ឬហៅថា វិបាកក៏បាន ។ គេនិយាយថា **ផល** (ឬវិបាក) នុ៎ះ មិន មាន ។ ពាក្យថា **លោកនេះមិនមាន** គឺ មិនមានលោកនេះសម្រាប់អ្នករស់ នៅក្នុងលោកដទៃ ។ ពាក្យថា **លោកដទៃមិនមាន** គឺ មិនមានលោកដទៃ សូម្បីសម្រាប់អ្នករស់នៅក្នុងលោកនេះ ។ គេចង្អុលបង្ហាញថា ទាំងអស់រមែង ដាច់សូន្យក្នុងទីនោះឯង ។ ពាក្យថា **មាតាមិនមាន បិតាមិនមាន** សំដៅដល់ថា គេរមែងនិយាយដោយអំណាចការមិនមានផលនៃការបដិបត្តិប្រពៃ និងបដិបត្តិ ខុសក្នុងលោកទាំងនោះ ។ ពាក្យថា **មិនមានសត្វដែលឱបបាតិកកំណើត** នុ៎ះ គឺ គេនិយាយថា ដែលឈ្មោះថា សត្វដែលចុតិហើយ កើតមិនមាន ។ ពាក្យ ថា **ធ្វើឲ្យច្បាស់នូវសេចក្តីដឹងក្រៃលែងដោយខ្លួនឯង ហើយប្រកាស** គឺ គេ សម្តែងដល់ការមិនមាននៃពួកព្រះសព្វញ្ញុពុទ្ធថា អ្នកដែលធ្វើឲ្យជាក់ច្បាស់ដោយ

ខ្លួនឯងដោយបញ្ញាដ៏ពិសេសក្រៃលែង ហើយប្រកាសលោកនេះ និងលោកខាងមុខនោះមិនមាន ដូច្នេះ ដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណេះ ការឃើញខុសដែលមានទាំង ១០ យ៉ាង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។

[១២៥] កម្មបថ ៧ ប្រការ ជាដើមថា លះបង់ការសម្លាប់សត្វ បានពោលពិស្តារក្នុងចូឡហត្ថិបទោបមសូត្រហើយ ។ ការមិនសម្លឹងរំពៃជាដើម ក៏មានសេចក្តីងាយហើយនោះឯង ។

[១២៦] ពាក្យថា **សូមឲ្យយើងចូលដល់ភាវៈតែមួយ** គឺ សូមឲ្យយើងចូលដល់សហភាព (ភាពជាពួក ជាសម្លាញ់ ដោយចំណែកតែមួយជាមួយគ្នា) ពាក្យថា **នៃពួកទេពដែលជាពួកព្រហ្ម** បានដល់ នៃពួកទេពជាន់បឋមជ្ឈាន ។ ពាក្យថា **នៃពួកទេពជាន់អាភា** គឺ ឈ្មោះ **អាភា** ដែលជាផ្នែកមួយផ្សេងដទៃមិនមាន , ពាក្យនេះ ជាឈ្មោះនៃពួកទេពជាន់ **បរិត្តាភា** **អប្បមាណាភា** និង **អាភស្សរា** ។ តែពាក្យ **បរិត្តាភា** ជាដើម ជាការមិនកាន់យករួមគ្នា តែកាន់ដោយការបែកពួកទេពទាំងអស់នោះឯង ។

សូម្បីក្នុងបទជាដើមថា **ជាន់សុភា** **ជាន់បរិត្តសុភា** ក៏ទំនងដូចគ្នានេះឯង ។

ព្រះមានព្រះភាគ ទ្រង់សម្តែងការអស់អាសវៈដោយប្រការដូច្នេះហើយ

ក៏ទ្រង់បញ្ចប់ទេសនាដល់កំពូល គឺ ព្រះអរហត្តផល ។

ចំពោះក្នុងទីនេះ គួររួមយកទេវលោកមកតាំងទុកផង គឺ ៖

ក. ព្រហ្មលោក ១៨ ជាន់ គឺ ៖

ព្រហ្មលោកដោយអំណាចឈានភូមិ ៣ ជាន់ដំបូង (ភូមិនីមួយៗ មាន ៣) រួមជា ៩ ។

សុទ្ធាវាស ៥ រួមនឹងអរូបភូមិ ៤ ទៀត រួមជា ៩ ។

( រួមទាំងអស់ ១៨ ជាន់ )

ខ. ព្រហ្មលោក ២០ ជាន់ គឺ ៖

យកព្រហ្មលោកក្នុងចំណុច"ក" ១៨

ព្រមទាំងជាន់វេហប្ផលា ១ ទៀត ១ + ១៨ = ១៩

បន្ថែមអសញ្ញីកពចូលមកក្នុង ១៩ នោះ ទើបជា ១ + ១៩ = ២០

គ. ទេវលោក ២៦ ជាន់ គឺ ៖

យកព្រហ្មលោកក្នុង ២០ នោះឯង រួមនឹងកាមាវចរ ៦ ទៀត ។

( ទេវលោកទាំងអស់ ២៦ ជាន់ )

ព្រះមានព្រះភាគ ទ្រង់សម្តែងការកើតរបស់ពួកទេព សូម្បីទាំងអស់នោះ ដោយកុសលកម្មបថ ១០ ប្រការ ។ ក្នុង ២៦ ជាន់ ការកើតក្នុងកាមាវចរ ៦

ជាន់ រមែងមានដោយវិបាកនៃសុចរិតទាំងបីយ៉ាងនុ៎ះឯង ។ ចំណែកកម្មបថទាំងនេះ ត្រាស់ដោយអំណាចជាឧបនិស្ស័យនៃទេវលោកជាន់លើ ។ ពិតណាស់ កុសលកម្មបថទាំង ១០ ប្រការ ក៏គឺ សីល , ការបរិកម្មកសិណ រមែងសម្រេចដល់អ្នកមានសីលប៉ុណ្ណោះ ដូច្នោះ កាលតាំងនៅក្នុងសីលហើយ ក៏ធ្វើការបរិកម្មកសិណ កាលញុំាងបឋមជ្ឈានឲ្យកើតហើយ ក៏រមែងកើតក្នុងបឋមជ្ឈានភូមិ ។ អប់រំទុតិយជ្ឈានជាដើមហើយ ក៏រមែងកើតក្នុងទុតិយជ្ឈានភូមិជាដើម លុះធ្វើរូបាវចរឈានឲ្យជាបាទ ហើយចម្រើនវិបស្សនា តាំងនៅក្នុងអនាគាមិផល ក៏រមែងកើតក្នុងសុទ្ធាវាសទាំង ៥ ជាន់ កាលបានធ្វើរូបាវចរជ្ឈានឲ្យជាបាទហើយ ញុំាងអរូបាវចរសមាបត្តិឲ្យកើតឡើង ក៏រមែងកើតក្នុងអរូបភព ៤ ជាន់ លុះធ្វើរូបឈាន និងអរូបឈានឲ្យជាបាទហើយ ចម្រើនវិបស្សនា រមែងសម្រេចអរហត្តផល ។

ចំណែកអសញ្ញភព ពួកតាបស និងបរិព្វាជកខាងក្រៅនោះ ទ្រង់ទើបមិនសម្តែងក្នុងទីនេះ ។ ដ៏សេសក្នុងទីគ្រប់កន្លែង រាក់ហើយនោះឯង ។

( ចប់ អដ្ឋកថា សាលេយ្យកសូត្រ ទី ១ )

# អ ដ្ឋ ក ថា

## វេរញ្ជកសូត្រ ទី ២

[១២៨] *វេរញ្ជកសូត្រ ផ្ដើមឡើងថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ* ក្នុងបណ្ដាបទទាំងនោះ បទថា **អ្នកស្រុកវេរញ្ជា** បានដល់ ពួកអ្នកនៅស្រុកវេរញ្ជា ។ ពាក្យថា **ដោយករណីយ៍ខ្លះយ៉ាងណាមួយ** បានដល់ ដោយកិច្ចដែលមិនកំណត់ឲ្យបានពិតប្រាកដនុ៎ះឯង ។ ពាក្យដ៏សេសទាំងអស់ គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងសូត្រមុន ។ ក៏ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ទ្រង់បានសម្ដែងប្រភេទលើកយកបុគ្គលមកជាទីតាំង យ៉ាងនេះថា បុគ្គលដែលមានប្រក្រតីមិនប្រព្រឹត្តធម៌ មានប្រក្រតីប្រព្រឹត្តមិនរៀបរយ តែក្នុងព្រះសូត្រមុន ជាប្រភេទលើកយកធម៌មកជាទីតាំងប៉ុណ្ណោះ ។ សេចក្ដីមានផ្សេងគ្នាប៉ុណ្ណោះ ដ៏សេសដូចគ្នាទាំងអស់នោះឯង ។

ចប់ អដ្ឋកថា វេរញ្ជកសូត្រ ទី ២

# អ ដ្ឋ ក ថា

## មហាវេទល្លសូត្រ ទី ៣

[១៣៣] *មហាវេទល្លសូត្រ ផ្ដើមឡើងថា ខ្ញុំបានស្ដាប់មកហើយយ៉ាង នេះ ។*

*ក្នុងពាក្យទាំងនោះ ពាក្យថា* **អ្នកមានអាយុ** *នេះ ជាពាក្យសម្ដែង សេចក្ដីគោរព និងសេចក្ដីកោតក្រែង ។ ពាក្យថា* **មហាកោដ្ឋិកៈ** *ជាឈ្មោះ របស់ព្រះថេរៈនោះ ។ ពាក្យថា* **ចេញចាកទីពួនសម្ងំ** *គឺ ចេញចាកផល-សមាបត្តិ ។*

[១៣៤] *ក្នុងពាក្យថា* **មានបញ្ញាថោកទាប** *នេះ គឺ ដែលឈ្មោះថា បញ្ញាអាក្រក់ថោកទាប មានសេចក្ដីថា មិនមានបញ្ញា គឺ គ្មានប្រាជ្ញា ។ ពាក្យ ថា* **ដោយហេតុមានប្រមាណត្រឹមណាហ្ន៎ !** *គឺ ពាក្យសួរកំណត់ហេតុ ។ មាន សេចក្ដីថា ដែលហៅយ៉ាងនោះ ដោយហេតុដូចម្ដេចហ្ន៎ ។ ក៏ឯឈ្មោះថា ការ សួរនេះ មាន ៥ យ៉ាង គឺ ៖*

១-**អទិដ្ឋជោតនាបុច្ឆា** *សួរដើម្បីបញ្ជាក់លក្ខណៈដែលមិនទាន់ឃើញ ឲ្យជាក់ច្បាស់ ។*

២-**ទិដ្ឋសំសន្ទនាបុច្ឆា** សួរដើម្បីប្រៀបធៀបលក្ខណៈដែលឃើញហើយ ។

៣-**វិមតិច្ឆេទនាបុច្ឆា** សួរដើម្បីកាត់សេចក្ដីសង្ស័យ ។

៤-**អនុមតិបុច្ឆា** សួរដើម្បីបញ្ជាក់ដល់ការយល់ស្រប ។

៥-**កថេតុកម្យតាបុច្ឆា** សួរដើម្បីឆ្លើយខ្លួនឯង ។

តទៅនេះជាហេតុដែលធ្វើឲ្យការសួរទាំងនោះផ្សេងគ្នា ។

ការសួរដើម្បីបំភ្លឺវត្ថុដែលមិនទាន់ឃើញតើដូចម្ដេច

ដោយប្រក្រតី អ្នកដែលមិនទាន់យល់ មិនទាន់ឃើញ មិនទាន់បានថ្លឹងថ្លែង មិនទាន់ពិចារណា មិនទាន់ជាក់ច្បាស់ មិនទាន់អប់រំលក្ខណៈ ក៏សួរបញ្ហាដើម្បីយល់ ដើម្បីឃើញ ដើម្បីថ្លឹងថ្លែង (ប្រៀបធៀប) ដើម្បីពិចារណា ដើម្បីជាក់ច្បាស់ ដើម្បីអប់រំលក្ខណៈនោះ នេះគឺ **អទិដ្ឋជោតនាបុច្ឆា** ។

ការសួរដើម្បីប្រៀបផ្ទឹមវត្ថុដែលឃើញហើយ តើដូចម្ដេច

ដោយប្រក្រតី អ្នកដែលយល់ បានឃើញ បានថ្លឹងថ្លែង បានពិចារណា បានជ្រាប បានជាក់ច្បាស់ បានអប់រំលក្ខណៈទុកហើយ ក៏នៅសួរបញ្ហាដើម្បីត្រូវការប្រៀបធៀបនឹងពួកអ្នកប្រាជ្ញដទៃ នេះគឺ **ទិដ្ឋសំសន្ទនាបុច្ឆា** ។

ការសួរដើម្បីកាត់សេចក្ដីសង្ស័យ តើដូចម្ដេច

ដោយប្រក្រតី អ្នកដែលស្ទុះទៅក្នុងសេចក្ដីសង្ស័យ ស្ទុះទៅក្នុងសេចក្ដី

ងឿងឆ្ងល់ កើតគិតពីរយ៉ាងនៃចិត្តថា យ៉ាងនេះឬហ្ន៎ ជាអ្វី យ៉ាងណាហ្ន៎ ក៏សួរបញ្ហាដើម្បីត្រូវការកាត់សេចក្ដីសង្ស័យ នេះគឺ **វិមតិច្ឆេទនាបុច្ឆា** ។

ចំណែកការកាន់យកសេចក្ដីយល់ព្រមតាម ហើយសួរក្នុងវេលាសម្ដែងធម៌យ៉ាងនេះថា ភិក្ខុទាំងឡាយ ពួកអ្នកយល់សេចក្ដីនោះយ៉ាងណា រូបទៀងឬមិនទៀង , មិនទៀងទេព្រះអង្គ ដូច្នេះជាដើម ឈ្មោះថា **អនុមតិបុច្ឆា** ។

ការសួររបស់ព្រះមានព្រះភាគ ដែលទ្រង់សួរភិក្ខុសង្ឃដោយព្រះអង្គឯង ហើយទ្រង់ត្រូវការឆ្លើយដោយព្រះអង្គឯង បែបនេះថា ភិក្ខុទាំងឡាយ ទីតាំងមាំនៃសេចក្ដីរលឹកទាំងនេះ មានបួនយ៉ាង បួនយ៉ាងតើដូចម្ដេច ? ដូច្នេះជាដើម ឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។

ក្នុងការសួរ ៥ យ៉ាងនោះ ក្នុងទីនេះ ប្រាថ្នាយកការសួរដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ ។

ពិតហើយ ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួន ហើយតាំងបញ្ហាឡើងនោះឯង កាលនឹងកាត់ក្ដីដោយខ្លួនឯង ក៏ធ្វើព្រះសូត្រនេះ តាំងពីខាងដើមរហូតចប់បាន ក៏បុគ្គលខ្លះអាចតាំងបញ្ហាឡើងបាន តែកាត់ក្ដីមិនបាន បុគ្គលខ្លះកាត់ក្ដីបាន តែតាំងបញ្ហាមិនបាន បុគ្គលខ្លះមិនបានទាំងពីរយ៉ាង បុគ្គលខ្លះក៏បានទាំងពីរយ៉ាង ក្នុងបុគ្គលទាំងនោះ ព្រះថេរៈជាអ្នកបានទាំងពីរយ៉ាង

ព្រោះហេតុអ្វី ព្រោះមានបញ្ញាច្រើន ក៏ព្រោះអាស្រ័យបញ្ញាច្រើន ទើបបាន ព្រះថេរៈច្រើនរូប ដែលសម្រេចឋានៈពិសេសក្នុងសាសនានេះ គឺ ព្រះសារីបុត្តត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះបុណ្ណត្ថេរ ព្រះកុមារកស្សបត្ថេរ ព្រះអានន្ទត្ថេរ និងព្រះកោដ្ឋិកៈ នេះឯង ។

ពិតណាស់ ភិក្ខុដែលមានបញ្ញាតិច នឹងអាចដល់ទីបំផុតសាវកបារមីញាណមិនបាន តែអ្នកមានបញ្ញាច្រើន នឹងអាចដល់បាន ព្រោះមានបញ្ញាច្រើន ដូចដែលពោលមកនេះ ព្រះសារីបុត្តត្ថេរ ទើបបានសម្រេចតំណែងនោះ ។ អ្នកមានបញ្ញាដូចព្រះថេរៈមិនមានឡើយ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ ទ្រង់តាំងលោកទុកក្នុងតំណែងដ៏កំពូលថា ភិក្ខុទាំងឡាយអ្នកប្រសើរជាងពួកភិក្ខុដែលមានបញ្ញាច្រើន ដែលជាសាវករបស់តថាគតនោះ គឺ សារីបុត្រ ។

ភិក្ខុដែលមានបញ្ញាតិច ថ្នាក់តូចទាបនោះ នឹងអាចរួបរួមយកមកប្រៀបផ្ទឹមនឹងព្រះសព្វញ្ញុតញ្ញាណ ហើយចែកអត្ថន័យនៃព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកដោយសង្ខេបៗ ឲ្យពិស្ដារមិនបាន តែអ្នកមានបញ្ញាច្រើន អាចធ្វើបាន ។ ព្រោះភាពជាអ្នកមានបញ្ញាច្រើន ដូចដែលពោលមកនេះ ព្រះមហាកច្ចាយនត្ថេរ ទើបជាអ្នកអាចក្នុងរឿងនោះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ ទ្រង់តាំងលោកទុកក្នុងតំណែងដ៏កំពូលថា ភិក្ខុទាំងឡាយ អ្នក

ដ៏ប្រសើរជាងពួកភិក្ខុដែលចែកសេចក្ដីនៃពាក្យ ដែលតថាគតពោលទុកដោយសង្ខេបៗ ឲ្យពិស្ដារបាន ដែលជាសាវករបស់តថាគតនោះ គឺ មហាកច្ចាយនៈ ។

ភិក្ខុដែលមានបញ្ញាតិច ក៏យ៉ាងនោះ នឹងពោលធម្មកថា ប្រារព្ធរឿងដែលគប្បីពោល ១០ ប្រការ ហើយចែកវិសុទ្ធិ ៧ ប្រការ នឹងមិនអាចពោលធម្មកថាបាន តែអ្នកមានបញ្ញាច្រើនធ្វើបាន ព្រោះភាពជាអ្នកមានបញ្ញាច្រើនដូចពោលមកនេះ ព្រះបុណ្ណត្ថេរ ទើបសម្ដែងធម៌លីលាដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី អន្ទយចាប់ផ្ដិតដ៏វិចិត្រលើទីអន្ទយ សម្ដែងធម៌ដែលតាក់តែងហើយពោលធម្មកថាកណ្ដាលបរិស័ទទាំងបួន ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទើបទ្រង់តាំងលោកទុកក្នុងតំណែងដ៏កំពូលថា ភិក្ខុទាំងឡាយ អ្នកដ៏ប្រសើរជាងពួកភិក្ខុអ្នកសម្ដែងធម៌ដែលជាសាវករបស់តថាគតនោះ គឺ បុណ្ណៈ កូនប្រុសនាងព្រាហ្មណីមន្តានី ។

ភិក្ខុដែលមានបញ្ញាតិច ក៏យ៉ាងនោះ កាលនឹងពោលធម្មកថា ក៏ដំណើរទៅតេះតះដូចអ្នកខ្វាក់ក្អែកកាន់ឈើច្រត់ដើរបានដោយលំបាក និងដូចអ្នកធ្វងស្ពានឈើ ដែលដើរទៅបានត្រឹមតែម្នាក់ ។ តែអ្នកមានបញ្ញាច្រើន លើកយកគាថាត្រឹមតែបួនបាទមកតាំង ហើយនាំយកការប្រៀបធៀប និងហេតុផលមករួមធ្វើឲ្យព្រះត្រៃបិដកដែលជាព្រះពុទ្ធតម្រាស់ ដែលមានទាំងបែបទាប និង

បែបខ្ពស់ហើយសម្តែង ។ ក៏ព្រោះភាពជាអ្នកមានបញ្ញាច្រើន ព្រះកុមារកស្សបត្ថេរ ទើបលើកយកគាថា ត្រឹមតែបួនបាទមកតាំង ហើយនាំយកការប្រៀបធៀប និងហេតុផលមកប្រកបចូលនឹងបទទាំងនោះ ធ្វើឲ្យព្រះត្រៃបិដកដែលជាព្រះពុទ្ធតម្រាស់ មានទាំងបែបទាប និងបែបខ្ពស់ហើយសម្តែង ដូចធ្វើឲ្យផ្កាឈើ ៥ ពណ៌ រីកនៅក្នុងស្រះធម្មជាតិ ឬដូចអុជចង្កៀងប្រេង រុំប្រេះឲ្យឆេះសន្ធោសន្ធៅនៅលើកំពូលភ្នំសិនេរុ ដូច្នោះ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់តាំងលោកទុកក្នុងតំណែងដ៏កំពូលថា ភិក្ខុទាំងឡាយ អ្នកជាកំពូលលើសពួកភិក្ខុដែលពោលធម៌យ៉ាងវិចិត្រ ជាសាវករបស់តថាគតនោះ គឺកុមារកស្សបៈ ។

ភិក្ខុដែលមានបញ្ញាតិច ក៏យ៉ាងនោះ សូម្បីប្រើវេលាអស់បួនខែ ក៏មិនអាចរៀនគាថាត្រឹមតែបួនបទបាន ។ ចំណែកអ្នកមានបញ្ញាច្រើនឈរលើជំហានតែមួយ ក៏រៀនបានទាំងរយទាំងពាន់បទ ក៏ព្រះអានន្ទត្ថេរ លោកឈរលើជំហានដែលកំពុងលើកឈាន បានស្តាប់តែម្តងប៉ុណ្ណោះ មិនសួរជាដែលទៀត ក៏ទទួលយកបានទាំង ៦ ម៉ឺនបទ ទាំងមួយម៉ឺន ៥ ពាន់គាថា ក្នុងខណៈតែមួយនុ៎ះឯង , ដូចយកវល្លិចងផ្កាឈើទុក , និងដែលលោកបានរៀនមកហើយ ក៏តាំងនៅដោយអាការដែលបានទទួលទុក ដូចស្នាមគំនូសលើផ្ទាំងថ្ម និងដូចខ្លាញ់រាជសីហ៍ដែល

ដាក់ក្នុងឆ្នាំងមាស ព្រោះហេតុដែលលោកមានបញ្ញាច្រើន ។ ហេតុនោះឯង ទើបព្រះមានព្រះភាគ ទ្រង់តាំងលោកទុកក្នុងតំណែងដ៏កំពូលថា ភិក្ខុទាំងឡាយ អ្នកដែលប្រសើរជាងពួកភិក្ខុដែលមានគតិជាសាវករបស់តថាគតនោះ គឺ អានន្ទ អ្នកមានសតិ , អ្នកមានធិតិ (បញ្ញាគ្រឿងចងចាំ) , អ្នកបានស្តាប់ច្រើន , អ្នកជាឧបដ្ឋាក (អ្នកបម្រើ) នោះគឺ អានន្ទ ។

ភិក្ខុដែលមានបញ្ញាតិច មិនអាចនឹងដល់កំពូល ប្រភេទបញ្ញាដែលបែកធ្លាយទាំងបួនយ៉ាងបានឡើយ ចំពោះអ្នកមានបញ្ញាច្រើនទើបនឹងអាច ។ ព្រោះភាពជាអ្នកមានបញ្ញាច្រើន ដូចដែលពោលមកនេះ ព្រះមហាកោដ្ឋិកត្ថេរ ទើបដល់បញ្ញាដែលបែកធ្លាយទាំងបួនប្រភេទ ដែលសូម្បីក្រាស់ទៅដោយន័យ មិនមានទីបំផុត ដោយអំណាចការប្រកបទុកក្នុងខាងដើមដោយការសម្រេច ការសាកសួរ និងការស្តាប់ ។ ហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់តាំងលោកទុកក្នុងតំណែងដ៏កំពូលថា ភិក្ខុទាំងឡាយ តំណែងដ៏ប្រសើរនៃពួកភិក្ខុ ដែលសម្រេចបញ្ញាដែលបែកធ្លាយ ជាសាវករបស់តថាគតនោះ គឺ មហាកោដ្ឋិកៈ ដូច្នេះ ។

ដោយភាពជាអ្នកមានបញ្ញាច្រើនដូចពោលមកនេះ ព្រះថេរៈ ទើបតាំងបញ្ហាឡើងក៏បាន ឆ្លើយក៏បាន ទាំងពីរយ៉ាងក៏បាន ។ ខណៈដែលលោកអង្គុយ

ក្នុងទីសម្រាកពេលថ្ងៃ លោកបានតាំងបញ្ហាគ្រប់ប្រការឡើងមកហើយ លោកនឹងវិនិច្ឆ័យព្រះសូត្រនេះ តាំងពីដើមដរាបដល់ចប់ (ប៉ុន្តែបាន) គិតថា ធម្មទេសនានេះល្អហួសប្រមាណ ចាំបាច់យើងនឹងត្រូវផ្ទៀងផ្ទាត់ជាមួយមេទ័ពធម៌ជាបងប្រុសធំ តពីនោះ ព្រះធម៌ទេសនាដែលយើងទាំងពីរនាក់ប្រើមតិដូចគ្នាតែមួយ ប្រើអធ្យាស្រ័យដូចគ្នាតែម្យ៉ាងតាំងទុកនេះ នឹងក្លាយជាធម្មទេសនាដ៏ជ្រាលជ្រៅ ដូចឆត្រថ្ម ហើយនឹងក្លាយជាធម្មទេសនា ដែលមានឧបការៈច្រើន ដូចទូកដែលចតទុកត្រង់កំពង់ សម្រាប់អ្នកត្រូវការឆ្លងអន្លង់ទឹកទាំងបួនកន្លែង (មហាសមុទ្រទាំងបួន) និងដូចរថទឹមដោយសេះអាជានេយ្យមួយពាន់សម្រាប់អ្នកត្រូវការទៅសួគ៌ ។ ដូច្នេះហើយ ទើបសួរបញ្ហាដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ ។ ហេតុនោះទើបថា ក្នុងបណ្ដាការសួរទាំងនោះ ក្នុងទីនេះប្រាថ្នាយកការសួរ ដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ ។

ក្នុងបទថា **មិនដឹងច្បាស់** នេះ មានសេចក្ដីថា អ្នកដែលត្រូវហៅថា **មិនមានបញ្ញា** ក៏ព្រោះមិនដឹងច្បាស់ ។ គ្រប់កន្លែងមានន័យដូចគ្នានេះ ។ ពាក្យថា **មិនទាន់ដឹងច្បាស់ថា នេះជាទុក្ខ** គឺ មិនដឹងច្បាស់នូវសេចក្ដីពិត ជាប់ទាក់ទងនឹងទុក្ខថា នេះជាទុក្ខ ទុក្ខមានត្រឹមតែប៉ុណ្ណេះ មិនមានទុក្ខដែលក្រៅអំពីនេះ ដោយលក្ខណៈព្រមទាំងកិច្ច តាមសេចក្ដីពិត ។ ពាក្យថា **នេះហេតុ**

**ឲ្យទុក្ខកើតឡើង** គឺ មិនដឹងច្បាស់ដោយលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្តីពិតថា សេចក្តីប្រាថ្នាដែលជាហេតុឲ្យកើតទុក្ខ ដែលប្រព្រឹត្តទៅថា ទុក្ខរមែងកើតឡើងមកពីសេចក្តីប្រាថ្នានេះ ជាសេចក្តីពិត ជាប់ទាក់ទងជាមួយហេតុកើតឡើង ។ ពាក្យថា **នេះជាសេចក្តីរលត់ទុក្ខដោយមិនមានសល់** គឺ មិនដឹងច្បាស់ដោយលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្តីពិតថា សេចក្តីពិតជាប់ទាក់ទងនឹងសេចក្តីរលត់ដោយមិនមានសល់ គឺ ការរលត់ទុក្ខ និងហេតុកើតឡើងនៃទុក្ខទាំងពីរថា នេះទុក្ខ និងនេះគឺហេតុឲ្យទុក្ខកើតឡើង កាលដល់ដំណែងនេះហើយរមែងរលត់ទៅមិនមានសេសសល់ ។ ពាក្យថា **នេះវត្តបដិបត្តិឲ្យដល់សេចក្តីរលត់ទុក្ខបានដោយមិនមានសល់** គឺ មិនដឹងច្បាស់តាមសេចក្តីពិត ដែលជាប់ទាក់ទងនឹងផ្លូវថា វត្តបដិបត្តិនេះ រមែងទៅដល់សេចក្តីរលត់ទុក្ខដោយមិនមានសេសសល់ ដោយលក្ខណៈ ព្រមនឹងកិច្ច តាមសេចក្តីពិត ។ សូម្បីក្នុងអនន្តរវារៈ (វារៈនៃអនន្តរបច្ច័យ) ក៏គប្បីជ្រាបខ្លឹមសារដោយន័យនេះ ។ តែក្នុងទីនេះ គប្បីជ្រាបថា លោកពោលដល់បុគ្គលដែលធ្វើកម្មដ្ឋាន ដែលកាន់យកសេចក្តីពិតបួនយ៉ាងមកជាអារម្មណ៍ដោយសង្ខេប ។

ពិតហើយ បុគ្គលនេះ រៀនសច្ចៈបួនប្រការក្នុងសម្នាក់អាចារ្យដោយការស្តាប់ កាលរៀនរួចហើយ ក៏ប្រកាន់មាំយ៉ាងនេះថា ឿរលែងតែសេចក្តីបាថ្នា

ចេញហើយ វត្ថុដែលជាប់ទាក់ទងនឹងភូមិបី ឈ្មោះថា សេចក្តីពិត ជាប់ទាក់ទង ជាមួយនឹងទុក្ខ , ដែលឈ្មោះថា សេចក្តីពិតជាប់នឹងហេតុឲ្យទុក្ខកើតឡើង គឺ សេចក្តីប្រាថ្នា , ការរលត់ គឺ ការមិនប្រព្រឹត្តទៅនៃទុក្ខ និងហេតុកើតឡើង នៃទុក្ខ ឈ្មោះថា សេចក្តីពិតជាប់ទាក់ទងជាមួយការរលត់ទុក្ខបានដោយមិន មានសេសសល់ , កាលកំណត់ដឹងសេចក្តីពិតជាប់ទាក់ទងនឹងទុក្ខ និងសេចក្តី ពិតជាប់ទាក់ទងនឹងហេតុកើតឡើងនៃទុក្ខ ក៏ចាត់ជាផ្លូវ ដែលសេចក្តីរលត់ដោយ មិនសេសសល់នៃទុក្ខឲ្យសម្រេច ក៏ឈ្មោះថា ជាសេចក្តីពិត គឺ ផ្លូវ (ឲ្យដល់ សេចក្តីរលត់ទុក្ខបាន ដោយមិនមានសេសសល់) ក្នុងសច្ចៈទាំងបួនប្រការនោះ សច្ចៈពីរប្រការដំបូង ជាវដ្តៈ , ពីរប្រការក្រោយ ជាវិវដ្តៈ សេចក្តីប្រកាន់មាំ ក្នុងវដ្តៈក៏មាន មិនមែនសេចក្តីប្រកាន់មាំក្នុងវិវដ្តៈ ។ ដូច្នោះ កាល ប្រកាន់មាំ ក៏ឈ្មោះថា ប្រកាន់មាំក្នុងសច្ចៈជាប់ទាក់ទងជាមួយទុក្ខ ដោយប្រការដូច្នេះ ។ ដែលឈ្មោះថា សច្ចៈដែលជាប់ទាក់ទងនឹងទុក្ខ ក៏គឺ ខន្ធទាំងប្រាំ មានរូបជាដើម ។ ដើម្បីនឹងកំណត់ខន្ធ ៥ នោះ ក៏ឈានចុះដោយអំណាចកម្មដ្ឋាន ដែលមានធាតុ បួនជាអារម្មណ៍ ហើយទើបកំណត់មហាភូតបួនយ៉ាង និងរូបដែលអាស្រ័យ មហាភូតទាំងបួនថា រូប ។ កាលកំណត់យ៉ាងនេះថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលមានធាតុបួននោះជាអារម្មណ៍ ជានាម ទើបឈ្មោះថា កំណត់ថា

វត្ថុពីរនេះឯង គឺ នាមរូប ដូចជាកាត់ដើមត្នោតគូ កាលបានកំណត់បច្ច័យ និង វត្ថុដែលកើតឡើងព្រោះបច្ច័យថា **ក៏វត្ថុនេះមិនមែនមិនមានហេតុ** គឺ មានហេតុ មានបច្ច័យ , ក៏អ្វីហ្ន៎ ជាបច្ច័យ វត្ថុទាំងឡាយមានសេចក្តីមិនដឹងជាដើម (ជាបច្ច័យ) យ៉ាងនេះហើយ ក៏លើកឡើងកាន់លក្ខណៈ ដែលមិនទៀងថា វត្ថុទាំងអស់នេះ ជារបស់មិនទៀង ព្រោះអត្ថថា មិនមាន ។ តពីនោះក៏លើកឡើងកាន់លក្ខណៈ ៣ យ៉ាងថា ជាទុក្ខ ព្រោះអាការកើតឡើង វិនាសទៅ និង បៀតបៀន , ថាជារបស់មិនមានខ្លួន ព្រោះអាការមិនប្រព្រឹត្តទៅក្នុងអំណាច , ហើយពិចារណាទៅតាមលំដាប់វិបស្សនា ក៏រមែងសម្រេចផ្លូវដែលផុតចាកលោកបាន ក្នុងខណៈនៃផ្លូវ (មគ្គខណៈ) ក៏រមែងចាក់ធ្លុះសច្ចៈទាំងបួនប្រការ ដោយការចាក់ធ្លុះក្នុងខណៈតែមួយ ។ រមែងត្រាស់ដឹង ដោយការត្រាស់ដឹងក្នុងខណៈតែមួយ រមែងចាក់ធ្លុះទុក្ខ ដោយការចាក់ធ្លុះ ដោយអំណាចការកំណត់ដឹង , រមែងចាក់ធ្លុះហេតុកើតឡើង ដោយការចាក់ធ្លុះ គឺ ការលះ , រមែងចាក់ធ្លុះសេចក្តីរលត់ដោយមិនមានសល់ដោយធ្វើជាក់ច្បាស់ , រមែងចាក់ធ្លុះផ្លូវដោយការចាក់ធ្លុះព្រោះការអប់រំ ។ រមែងត្រាស់ដឹងទុក្ខ ដោយការត្រាស់ដឹង ព្រោះការកំណត់ដឹង ។ រមែងត្រាស់ដឹងហេតុឲ្យទុក្ខកើត ដោយការត្រាស់ដឹងការលះ , រមែងត្រាស់ដឹងការរលត់ដោយមិនមានសល់ ដោយការត្រាស់ដឹងការធ្វើឲ្យជាក់ច្បាស់ ,

រមែងត្រាស់ដឹងផ្លូវ ដោយការត្រាស់ដឹងការអប់រំ ។ គេចាក់ធ្លុះសច្ចៈទាំងបីយ៉ាងដោយកិច្ច ចាក់ធ្លុះសេចក្ដីរលត់ដោយមិនមានសេសសល់ដោយអារម្មណ៍ ។ ចំណែកក្នុងខណៈនៃផលរបស់គេនោះ មិនមានការគិត ការប្រមូលចិត្ត ការយកចិត្តទុកដាក់ និងការពិចារណាថា " យើងកំណត់ដឹងទុក្ខ កំពុងលះហេតុឲ្យកើតទុក្ខ កំពុងធ្វើឲ្យជាក់ច្បាស់ការរលត់ដោយមិនសេសសល់ កំពុងអប់រំផ្លូវ " ។ តែចំពោះអ្នកដែលកំពុងកំណត់កាន់យកនោះ ផ្លូវរបស់អ្នកដែលកំពុងកំណត់កាន់យកនោះឯង ធ្វើកិច្ច មានការកំណត់ដឹងជាដើម ក្នុងសច្ចៈបីប្រការឲ្យសម្រេចតែម្យ៉ាង ចាក់ធ្លុះសេចក្ដីរលត់ដោយមិនមានសេសសល់ដោយអារម្មណ៍ ។

ក្នុងពាក្យថា **ព្រោះដូច្នោះ ទើបហៅថា អ្នកមានបញ្ញា** នេះ ដោយទាបបំផុតព្រះសោតាបន្ន , ខ្ពស់ទីបំផុតព្រះខីណាស្រព លោកសម្ដែងថា ជាអ្នកមានបញ្ញា ចំណែកអ្នកដែលរៀនសូត្រពាក្យរបស់ព្រះពុទ្ធ (ចប់) បិដកទាំងបីដោយបាលីខ្លះ ដោយអដ្ឋកថាខ្លះ ដោយអនុសន្ធិខ្លះ ដោយមុនក្រោយខ្លះ ហើយធ្វើឲ្យជាថ្នាក់ទាប និងថ្នាក់ខ្ពស់ តែមិនមានសូម្បីតែការកំណត់យកដោយអំណាចនៃការមិនទៀង ជាទុក្ខ និងមិនមានខ្លួនទេនោះ មិនបានឈ្មោះថា អ្នកមានបញ្ញាទេ នៅតែឈ្មោះថា អ្នកមិនមានបញ្ញា (ដូចដើម) ចាំបាច់ពោលថ្វីដល់អ្នកដែលកាន់យកតែសេចក្ដីដឹងច្បាស់ (វិញ្ញាណចរិត) នោះថា ជាអ្នកមានបញ្ញាចូលផង

ហ្នឹ ។ គ្រានេះ អ្នកដែលបានលើកឡើងកាន់លក្ខណៈបីយ៉ាង ហើយពិចារណាតាមលំដាប់វិបស្សនា នឹងគិតថា ថ្ងៃនេះ ថ្ងៃនេះឯង អរហត្តនេះ ឈ្មោះថា ជាអ្នកមានបញ្ញា មិនមែនមិនមានបញ្ញា ។ អ្នកមានបញ្ញា កាលអ្នកណាព្រមឲ្យជួបជាមួយក៏ជួប (តែ) ចំណែក (ដែលមានបញ្ញាដូចគ្នា) ចំណែកក្នុងព្រះសូត្រ លោកពោលដល់ការចាក់ធ្លុះប៉ុណ្ណោះ ។

ក្នុងពាក្យថា **សេចក្ដីដឹងច្បាស់** នេះ ព្រះមហាកោដ្ឋិកត្ថេរ រមែងសួរដល់អ្វី អ្នកដែលយកសេចក្ដីដឹងច្បាស់ណាមកពិចារណាសង្ខារនោះ ក៏ជាអ្នកមានបញ្ញា ព្រះមហាកោដ្ឋិកត្ថេរ ទើបសួរថា ខ្ញុំព្រះករុណាសូមសួរវិបស្សនាដែលត្រូវមកសេចក្ដីដឹងច្បាស់ និងចិត្តអ្នកធ្វើការងាររបស់ការពិចារណាសង្ខារនោះជាមួយលោកម្ចាស់ ។ ពាក្យថា **រមែងដឹងច្បាស់សុខខ្លះ** គឺ រមែងដឹងច្បាស់វេទនាជាសុខខ្លះ ។ សូម្បីក្នុងពីរបទខាងលើ ក៏ទំនងដូចគ្នាតែមួយនុ៎ះឯង ។ ដោយបទថា **រមែងដឹងច្បាស់សុខខ្លះនេះ** សម្ដែងដល់កម្មដ្ឋានដែលមិនបានប្រើរូបជាអារម្មណ៍ ដោយអំណាចវេទនា ដែលមកដោយន័យជាដើមថា កាលយើងសោយនូវវេទនាជាសុខ ក៏ដឹងច្បាស់ថា យើងសោយនូវវេទនាជាសុខ គួរជ្រាបខ្លឹមសារនៃបទនោះ តាមន័យដែលពោលទុកក្នុងសូត្រ ដែលពោលអំពីការតាំងសតិ (សតិប្បដ្ឋានសូត្រ) នុ៎ះឯង ។

ពាក្យថា **ដូចគ្នា**(១) គឺ ព្រះថេរៈរមែងសួរថា ដែលឈ្មោះដូចគ្នា ព្រោះអត្ថថា ប្រកបព្រមដោយលក្ខណៈ មានការកើតឡើងព្រមគ្នាជាដើម ឬផ្សេងគ្នា ចំពោះប្រការនេះមិនគប្បីយល់ថា ព្រះថេរៈយកវត្ថុដែលជារបស់លោក និងដែលនៅលើលោកទាំងពីរ គឺ បញ្ញាក្នុងមគ្គ និងសេចក្ដីដឹងច្បាស់នៃវិបស្សនានេះ មកលាយឡំគ្នា ហើយបំបែកចេញជាថ្នាក់ និងសួរដូចអ្នកមិនស្គាល់សម័យ តែគប្បីជ្រាបថា លោកសួរដល់ការលាយគ្នា ព្រមនឹងសេចក្ដីដឹងច្បាស់ លំនាំផ្លូវក្នុងសេចក្ដីដឹងច្បាស់ផ្លូវ និងជាមួយសេចក្ដីដឹងច្បាស់នៃវិបស្សនា ក្នុងសេចក្ដីដឹងច្បាស់ដោយវិបស្សនាប៉ុណ្ណោះ សូម្បីព្រះថេរៈ កាលនឹងឆ្លើយសេចក្ដីនោះដល់ព្រះមហាកោដ្ឋិកៈនោះ ក៏ពោលពាក្យជាដើមថា **វត្ថុទាំងនេះដូចគ្នា** ពាក្យថា **ក្នុងករណីនោះ** បុគ្គលមិនគប្បីបាននូវវត្ថុទាំងនេះ គឺ នៃវត្ថុពីរយ៉ាង ដែលកើតឡើងព្រមគ្នា ទាំងក្នុងខណៈលោកិយមគ្គ ទាំងក្នុងខណៈលោកុត្តរមគ្គ ។ ពាក្យថា **បែករំលែក** មានសេចក្ដីថា មិនមានអ្នកណាអាចនឹងបែកជាផ្នែក និងមកសម្ដែងឲ្យឃើញសូម្បីសេចក្ដីផ្សេងគ្នាដោយអារម្មណ៍ ដោយទីតាំង ដោយការកើតឡើង ឬដោយការរលត់ទៅបាន ។

ក៏ធម្មតាថា អារម្មណ៍របស់វត្ថុនោះៗ មានហើយ ។ ពិតណាស់ កាល

---

(១) **សំសដ្ឋា** = ក្នុងបិដកប្រែថា ដូចគ្នា , លាយគ្នា , ច្រឡំគ្នា ។

សម្រេចវត្ថុដែលជារបស់បែបលោកៗ ចិត្តរមែងជាធំ ជាប្រធាន កាលសម្រេចវត្ថុដែលនៅលើលោក[១] បញ្ញារមែងជាធំ ជាប្រធាន ។ ពិតណាស់ សូម្បីព្រះសម្មាសម្ពុទ្ធ កាលត្រាស់សួរដល់វត្ថុដែលជារបស់បែបលោកៗ ក៏មិនត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុ អ្នកសម្រេចសេចក្ដីដឹងច្បាស់ប្រភេទណា ជាសេចក្ដីដឹងច្បាស់ក្នុងផ្លូវជាខាងដើម ឬជាសេចក្ដីដឹងច្បាស់ក្នុងផ្លូវទីពីរ ទីបី និងទីបួន តែនឹងត្រាស់សួរដោយអំណាចចិត្តថា ម្នាលភិក្ខុ អ្នកមានចិត្តយ៉ាងណា និងមិនត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានផស្សៈយ៉ាងណា ? មានវេទនាយ៉ាងណា មានសញ្ញាយ៉ាងណា មានចេតនាយ៉ាងណា សូម្បីកាលនឹងទ្រង់បញ្ញត្តិកុសល និងអកុសល ក៏ទ្រង់បញ្ញត្តិដោយអំណាចចិត្តយ៉ាងនេះថា វត្ថុទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចដោយចិត្ត និងត្រាស់ថា វត្ថុដែលជាកុសលតើដូចម្ដេច ? ក្នុងសម័យណា ចិត្តជាកុសលដែលត្រាច់ទៅក្នុងភូមិកាមរមែងជារបស់កើតឡើងហើយ តែកាលនឹងទ្រង់សួរដល់វត្ថុដែលនៅលើលោក ទ្រង់មិនសួរថា ម្នាលភិក្ខុ អ្នកមានវត្ថុដែលធ្វើមុខនាទីឲ្យប៉ះខ្ទប់យ៉ាងណា មានវេទនាយ៉ាងណា មានសញ្ញាយ៉ាងណា មានចេតនាយ៉ាងណា ទ្រង់នឹងសួរដោយអំណាចការដឹងច្បាស់យ៉ាងនេះថា ភិក្ខុ ការដឹងច្បាស់ដែលអ្នកសម្រេចហើយ

---

(១) ក្នុងអដ្ឋកថាបាលី : ពាក្យថា បែបលោក គឺ សំដៅយកលោកិយៈ , បែបលើលោក គឺ សំដៅយកលោកុត្តរៈ ។

ដូចម្តេច ជាការដឹងច្បាស់ក្នុងផ្លូវខាងដើម ឬជាសេចក្តីដឹងច្បាស់ក្នុងផ្លូវទីពីរ ទីបី និងទីបួន សូម្បីក្នុងឥន្ទ្រិយសំយុត្ត ក៏ត្រាស់តែវត្ថុបែបលោក និងដែលនៅលើលោក ក្នុងអារម្មណ៍ប៉ុណ្ណោះ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ ទាំងនេះ ។ ៥ អ្វីខ្លះ ? គឺ ឥន្ទ្រិយ គឺ សេចក្តីជឿ , ឥន្ទ្រិយ គឺ សេចក្តីព្យាយាម , ឥន្ទ្រិយ គឺ សេចក្តីរលឹក , ឥន្ទ្រិយ គឺ សេចក្តីតម្កល់ចិត្តមាំ , ឥន្ទ្រិយ គឺ សេចក្តីដឹងច្បាស់ , ម្នាលភិក្ខុទាំងឡាយ ក៏ឥន្ទ្រិយ គឺ សេចក្តីជឿ ដែលបុគ្គលគប្បីឃើញបានពីទីណា គប្បីឃើញឥន្ទ្រិយ គឺ សេចក្តីជឿក្នុងសោតាបត្តិយង្គៈ ៤ យ៉ាងនេះ ។ ក៏ភិក្ខុទាំងឡាយ ឥន្ទ្រិយ គឺ សេចក្តីព្យាយាម ដែលបុគ្គលគប្បីបានពីទីណា គប្បីឃើញឥន្ទ្រិយ គឺ សេចក្តីព្យាយាមក្នុងសេចក្តីព្យាយាមត្រូវ ៤ យ៉ាងនេះ ។ ភិក្ខុទាំងឡាយ ឥន្ទ្រិយ គឺ សេចក្តីរលឹក ដែលបុគ្គលគប្បីឃើញបានពីទីណា គប្បីឃើញឥន្ទ្រិយ គឺ សតិ ក្នុងសតិដ្ឋាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ គឺ ការតម្កល់ចិត្តមាំ ដែលបុគ្គលគប្បីបានពីទីណា គប្បីឃើញឥន្ទ្រិយ គឺ សមាធិក្នុងឈាន ៤ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ គឺ បញ្ញាដែលបុគ្គលគប្បីឃើញបានក្នុងទីណា គប្បីឃើញឥន្ទ្រិយ គឺ បញ្ញាបានអំពីសេចក្តីពិតដ៏ប្រសើរ ៤ នេះ ដូច្នេះ ។

ដូចកាលពួកសម្លាញ់ ដែលមានព្រះរាជាជាគម្រប់ ៥ គឺ កូនប្រុសសេដ្ឋី

៤ នាក់ និងព្រះរាជា ១ អង្គ គិតថា ពួកយើងនឹងលេងនក្ខត្តឫក្ស ហើយនាំគ្នាដើរទៅតាមផ្លូវ កាលដល់ផ្ទះកូនប្រុសសេដ្ឋីម្នាក់ ៤ នាក់ទៀតក៏នាំគ្នាអង្គុយស្ងៀម ។ អ្នកដែលជាម្ចាស់ផ្ទះប៉ុណ្ណោះ ដែលបង្គាប់ថា ពួកអ្នកចូរឲ្យរបស់ទំពារ របស់ស៊ីដល់អ្នកទាំងនេះ ចូរឲ្យរបស់ក្រអូប កម្រងផ្កា និងគ្រឿងស្អិតស្អាងជាដើម ដល់អ្នកទាំងនេះ ។ កាលទៅដល់ផ្ទះអ្នកទីពីរ... ទីបី... ទីបួនបួននាក់ទៀត ក៏នាំគ្នាអង្គុយស្ងៀម អ្នកជាម្ចាស់ផ្ទះប៉ុណ្ណោះ ដែលអាចបានបង្គាប់ថា ពួកអ្នកចូរឲ្យរបស់ទំពារ របស់ស៊ី ដល់អ្នកទាំងនេះ ចូរឲ្យរបស់ក្រអូបកម្រងផ្កា និងគ្រឿងស្អិតស្អាងជាដើម ដល់អ្នកទាំងនេះ ។ ក្នុងគ្រាក្រោយគេទៅដល់ព្រះរាជវាំង ព្រះរាជាប៉ុណ្ណោះ ទ្រង់ជាអ្នកធំក្នុងទីទាំងពួង ក៏ក្នុងវេលានៃព្រះរាជានេះ ទ្រង់ត្រាស់បង្គាប់ថា ពួកអ្នកចូរឲ្យរបស់ទំពារ របស់ស៊ី ដល់អ្នកទាំងនេះ ចូរឲ្យរបស់ក្រអូប និងកម្រងផ្កា និងគ្រឿងស្អិតស្អាងជាដើម ដល់អ្នកទាំងនេះ ។ ក្នុងព្រះរាជវាំងរបស់ព្រះអង្គទ្រង់ឯង យ៉ាងណា សេចក្តីនេះក៏ដូច្នោះឯង កាលឥន្ទ្រិយដែលមានសេចក្តីជឿជាគម្រប់ ៥ សូម្បី កំពុងកើតឡើងនៅក្នុងអារម្មណ៍តែមួយជាមួយគ្នា ដូចកាលសម្លាញ់ទាំងនោះ ដើរតាមផ្លូវជាមួយគ្នា ក្នុងផ្ទះដំបូង ៤ នាក់ទៀត នាំគ្នាអង្គុយស្ងៀម អ្នកដែលជាម្ចាស់ផ្ទះប៉ុណ្ណោះអាចបង្គាប់ការងារបាន យ៉ាងណា , សេចក្តីនេះក៏ដូច្នោះ កាលចំណែកប្រកប

ដល់ក្រសែ , ឥន្ទ្រិយ គឺ សេចក្ដីជឿ ដែលមានលក្ខណៈកាត់ក្ដីអារម្មណ៍បានដាច់ខាតប៉ុណ្ណោះ រមែងជាធំ ជាប្រធាន , ឥន្ទ្រិយដ៏សេសក៏ស្រេបទៅតាមឥន្ទ្រិយ គឺ សេចក្ដីជឿនោះ ។ កាលដល់សម្មប្បធាន ឥន្ទ្រិយ គឺ សេចក្ដីព្យាយាម ដែលមានការផ្គងឡើងជាលក្ខណៈប៉ុណ្ណោះ រមែងជាធំ ជាប្រធាន ធម៌ដ៏សេសក៏ស្រេបទៅតាមឥន្ទ្រិយ គឺ សេចក្ដីព្យាយាមនោះ , ដូចក្នុងផ្ទះរបស់អ្នកទី ២ , ៤ នាក់ទៀតក្រៅពីនេះ ក៏អង្គុយស្ងៀម ទុកឲ្យម្ចាស់ផ្ទះប៉ុណ្ណោះ ជាអ្នកបង្គាប់ការងារ ដូច្នោះ ។

កាលដល់ការតាំងក្នុងសេចក្ដីរលឹក ឥន្ទ្រិយ គឺ សេចក្ដីរលឹក ដែលមានការប្រាកដជាលក្ខណៈប៉ុណ្ណោះ ដែលជាធំ ជាប្រធាន ធម៌ដ៏សេសក៏ស្រេបទៅតាមឥន្ទ្រិយ គឺ សេចក្ដីរលឹកនោះ ដូចក្នុងផ្ទះរបស់អ្នកទី ៣ , ៤ នាក់ទៀតអង្គុយស្ងៀម ទុកឲ្យម្ចាស់ផ្ទះប៉ុណ្ណោះ ជាធុរៈក្នុងការបង្គាប់ការងារ ដូច្នោះ ។

កាលដល់ការរួចផុត ព្រោះអំណាចឈាន ឥន្ទ្រិយ គឺ ការតម្កល់ចិត្តមាំ ដែលមានសេចក្ដីមិនរាយមាយជាលក្ខណៈប៉ុណ្ណោះ ដែលជាធំ ជាប្រធាន ធម៌ដ៏សេស ក៏ស្រេបទៅតាមឥន្ទ្រិយ គឺ ការតម្កល់ចិត្តមាំនោះ , ដូចក្នុងផ្ទះរបស់អ្នកទី ៤ , ៤ នាក់ទៀតអង្គុយស្ងៀម ទុកឲ្យម្ចាស់ផ្ទះប៉ុណ្ណោះជាធុរៈ ក្នុងការបង្គាប់ការ ដូច្នោះ ។

កាលមកដល់សេចក្តីពិតដ៏ប្រសើរ ឥន្ទ្រិយ គឺ សេចក្តីដឹងច្បាស់ ដែលមានសេចក្តីដឹងច្បាស់ជាលក្ខណៈប៉ុណ្ណោះ ដែលជាធំ ជាប្រធាន ធម៌ដ៏សេសក៏ស្របទៅតាមឥន្ទ្រិយ គឺ សេចក្តីដឹងច្បាស់ប៉ុណ្ណោះ , ដូចកាលចូលដល់ព្រះរាជវាំងក្នុងពេលចុងក្រោយ , ៤ នាក់ទៀត ក៏អង្គុយស្ងៀម ព្រះរាជាប៉ុណ្ណោះ ដែលទ្រង់ត្រាស់បង្គាប់ការងារក្នុងព្រះរាជវាំង ដូច្នោះ ។

ព្រះមហាកោដ្ឋិកត្ថេរ ជាអ្នកបានទទួលការតែងតាំងក្នុងតំណែងដ៏កំពូលលើសភិក្ខុសាវក ដល់សេចក្តីបែកធ្លាយ កាលទឹងសួររឿងបែបលោក លោកក៏ធ្វើចិត្តឲ្យជាធំ ជាប្រធាន ហើយទើបសួរ កាលទឹងសួរដល់រឿងដែលនៅលើលោក ក៏លើកយកសេចក្តីដឹងច្បាស់មកឲ្យជាធំ ជាប្រធាន ហើយទើបសួរ ។ ចំណែកព្រះសារីបុត្តត្ថេរ ជាមេទ័ពធម៌ ក៏ដោះស្រាយយ៉ាងនោះដូចគ្នា ដោយប្រការដូច្នេះឯង ។

ពាក្យថា **រមែងដឹងនូវទៅដូចម្តេច លោកដ៏មានអាយុ ?** គឺ បញ្ញាដឹងច្បាស់នូវផ្លូវ រមែងដឹងច្បាស់នូវធម៌ដែលជាសេចក្តីពិតបួនប្រការយ៉ាងណា ដោយទំនងជាដើមថា នេះទុក្ខ ។ ពាក្យថា **រមែងដឹងច្បាស់នោះ** គឺ សម្បយុត្តវិញ្ញាណ ដឹងច្បាស់ក្នុងផ្លូវ ក៏រមែងដឹងច្បាស់យ៉ាងនោះដូចគ្នា ។ ពាក្យថា **វិញ្ញាណ ដូចម្តេច** គឺ សេចក្តីដឹងច្បាស់ក្នុងវិបស្សនា ដោយទំនងជាដើមថា

ដើមថា វត្ថុណាដែលជាអ្នកតាក់តែង អ្នកត្រូវតាក់តែង (វត្ថុនោះ) មិនទៀង ពាក្យថា **វិញ្ញាណដឹងច្បាស់វត្ថុនោះ** គឺ សូម្បីវិញ្ញាណដឹងច្បាស់ដោយវិបស្សនា ក៏រមែងដឹងច្បាស់វត្ថុនោះ ដូច្នោះដូចគ្នា ។ ពាក្យថា **ព្រោះដូច្នោះធម៌ទាំងនេះ** គឺ ព្រោះហេតុនោះ ធម៌ទាំងនេះ ។ ពាក្យថា **ដូចគ្នា** គឺ លាយគ្នា ព្រោះការកើតព្រមគ្នា រលត់ព្រមគ្នា មានទីអាស្រ័យដូចគ្នា និងមានអារម្មណ៍ដូចគ្នា ។ ពាក្យថា **គប្បីអប់រំបញ្ញា** នេះ លោកបំណងយកបញ្ញាក្នុងមគ្គ ចំណែកវិញ្ញាណដែលប្រកបព្រមនឹងបញ្ញានោះ ក៏ត្រូវអប់រំឲ្យព្រមគ្នានឹងបញ្ញានោះផង ។ ពាក្យថា **វិញ្ញាណ ជាវត្ថុដែលត្រូវកំណត់ដឹង** នេះ លោកពោលសំដៅយកវិញ្ញាណក្នុងវិបស្សនា ចំណែកបញ្ញាដែលប្រកបនឹងវិញ្ញាណក្នុងវិបស្សនានោះ ក៏គប្បីកំណត់ព្រមនឹងវិញ្ញាណនោះផង ។

[១៣៥] ហេតុដូចម្ដេច លោកទើបសួរពាក្យថា **វេទនា វេទនា ?** សូម្បីដូច្នេះ ក៏ត្រូវកំណត់ថា លោកសំដៅយកតែវេទនាដែលសម្រាប់ពិចារណា ត្រិះរិះដែលប្រព្រឹត្តទៅក្នុងភូមិបីប៉ុណ្ណោះ ។ ពាក្យថា **រមែងសោយសុខខ្លះ** គឺ រមែងសោយ គឺ តាមសោយអារម្មណ៍ដែលជាសុខ ។ ទំនងដូចគ្នាតែយ៉ាងនេះឯងរមែងប្រើបានសូម្បីក្នុងពីរបទមុខផង ។

ពិតណាស់ លោកពោលដល់អារម្មណ៍ដែលជាសុខ មិនមែនទុក្ខមិនមែន

សុខក្នុងទីនេះ តាមមហាលិសូត្រនេះថា មហាលិ ប្រសិនបើរូបនេះនឹងជាទុក្ខតែម្យ៉ាង ត្រូវទុក្ខពាល់ត្រូវ ត្រូវទុក្ខគ្របសង្កត់ សុខចូលមកមិនបាន ប្រសិនបើយ៉ាងនេះ ពួកសត្វក៏មិនគប្បីងប់ជ្រប់ក្នុងរូប ។ មហាលិ ព្រោះហេតុដែលរូបនេះឯង ជាសុខ ត្រូវសុខពាល់ត្រូវ ត្រូវសុខគ្របសង្កត់ចូលមក ទុក្ខចូលមកមិនបាន ដូច្នោះ ពួកសត្វទើបងប់ជ្រប់ក្នុងរូប ព្រោះងប់ជ្រប់ ទើបជាប់ , ព្រោះជាប់ ទើបមិនរួចផុត ។ ប្រសិនបើវេទនានេះ ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ មហាលិ ប្រសិនបើវិញ្ញាណនេះ នឹងជាទុក្ខតែម្យ៉ាង ។បេ។ ទើបមិនរួចផុត ។ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងរឿងវេទនានេះ យ៉ាងនេះថា វេទនាដែលជាសុខមួយទៀត ក៏រមែងធ្វើវេទនាមុនឲ្យជាអារម្មណ៍ហើយ ទើបសោយ ។ វេទនាដែលជាទុក្ខជាខាងក្រោយ ក៏រមែងធ្វើវេទនាដែលជាទុក្ខមុនឲ្យជាអារម្មណ៍ហើយ ទើបសោយ ។ វេទនាដែលមិនមែនទុក្ខមិនមែនសុខជាខាងក្រោយ ក៏រមែងធ្វើវេទនាដែលជាអទុក្ខមសុខមុនឲ្យជាអារម្មណ៍ហើយ ទើបសោយ ។ មានពាក្យដែលលោកពោលទុកយ៉ាងនេះថា វេទនាទុំះឯង រមែងសោយ មិនមានអ្នកដទៃណា ដែលឈ្មោះថា ជាអ្នកសោយ ។

ព្រះមហាកោដ្ឋិកត្ថេរ សួរដល់អ្វី ក្នុងបទនេះថា សញ្ញា សញ្ញា ពាក្យថា

លក្ខណៈនៃសញ្ញាថា លក្ខណៈនៃសញ្ញាក្នុងទីគ្រប់កន្លែង ក្នុងគ្រប់កាលក្តី នៃបញ្ញាថា អ្វីជាលក្ខណៈនៃសញ្ញា អ្វីជាលក្ខណៈនៃសញ្ញាក្នុងទីគ្រប់កន្លែង ក្នុងកាលគ្រប់កាលនេះ តែម្យ៉ាងដូចគ្នាទុំះឯង ។ សូម្បីដូច្នេះ ក៏គប្បីកំណត់ទុកថា លោកសំដៅយកតែសញ្ញា ដែលកើតព្រមជាមួយសេចក្តីពិចារណា ត្រិះរិះ ដែលប្រព្រឹត្តទៅក្នុងភូមិបីប៉ុណ្ណោះ ពាក្យថា **រមែងចាំពណ៌ខៀវខ្លះ** គឺ កាលធ្វើបរិកម្មក្នុងផ្កាឈើពណ៌ខៀវ ឬក្នុងសំពត់ហើយ ឲ្យដល់ឧបចារៈ ឬអប្បនា ឈ្មោះថារមែងចាំបាន ក៏ក្នុងអត្ថនេះ ប្រើបានទាំងសញ្ញាក្នុងបរិកម្ម ទាំងសញ្ញាក្នុងឧបចារៈ ទាំងសញ្ញាក្នុងអប្បនា សូម្បីសញ្ញាដែលកើតឡើងក្នុងពណ៌ខៀវថា **ពណ៌ខៀវ** ក៏ប្រើបានដូចគ្នា ។ ក្នុងពណ៌លឿងជាដើម ក៏ទំនងនេះឯង ។

ហេតុដូចម្តេច លោកទើបមិនកាន់យកបញ្ញា តែកាន់យកវត្ថុទាំងបីនេះ គឺ វេទនា សញ្ញា វិញ្ញាណ ក្នុងបទទាំងនេះថា **អ្នកមានអាយុ ក៏វេទនា សញ្ញា វិញ្ញាណ** យ៉ាងណា ព្រោះមិនមែនជាការរួមយកមកទាំងអស់ ។ ពិតហើយ កាលកាន់យកដោយបញ្ញា វេទនាជាដើម ដែលប្រកបជាមួយបញ្ញាក៏បាន ដែលមិនប្រកបមិនមាន ។ តែកាលមិនកាន់យកបញ្ញានោះ , កាលធម៌ទាំងនោះបានទទួលការកាន់យកហើយ ។ វេទនាជាដើម ទាំងដែលប្រកបជាមួយបញ្ញាក្តី មិនប្រកបក្តី ទីបំផុតសូម្បីតែធម៌ គឺ ទ្វិបញ្ចវិញ្ញាណទាំង ១០ ដួង ក៏ជាការ

បានផង ។ ដូចសេចក្តីថា បុរស ៣ នាក់ គប្បីពោលថា **អំបោះ អំបោះ** អ្នកទី ៤ ថា **អំបោះក្រងកែវ** ក្នុងអ្នកទាំងនោះ , ៣ នាក់ដំបូង រមែងមានការស្មានខ្លះ ការគិតស្មានជាដើមខ្លះ និងអំបោះចំនួនច្រើនណាមួយ ដោយទីបំផុតកាលស្វែងរកសូម្បីតែសរសៃសូត្រ ឬអំបោះក្រងកែវ ក៏រមែងបានបន្តិចបន្តួច យ៉ាងណា , គប្បីជ្រាបប្រការប្រៀបធៀប ដូច្នោះ ។ម្យ៉ាងទៀត លោកខ្លះក៏ពោលថា លោកដោះស្រាយទុកហើយ ព្រោះបានការប្រកបទៅព្រមៗ គ្នាជាមួយវិញ្ញាណ និងបញ្ញាមកពីខាងក្រោមហើយ ព្រោះដូច្នោះ ទើបមិនចាត់ចូលក្នុងទីនេះ ព្រោះលោកបានដោះស្រាយទុកហើយ ។ ពាក្យថា **អ្នកមានអាយុ វេទនា គឺ ការសោយណា** គឺ វេទនារមែងសោយអារម្មណ៍ណា សូម្បីសញ្ញា ក៏រមែងចាំអារម្មណ៍នោះដូចគ្នា ។ ពាក្យថា **រមែងចាំអារម្មណ៍ណា** មានន័យថា សញ្ញារមែងចាំអារម្មណ៍ណា សូម្បីវិញ្ញាណ ក៏រមែងដឹងច្បាស់អារម្មណ៍នោះដូចគ្នា ។

ឥឡូវនេះ គប្បីជ្រាបសេចក្តីផ្សេងគ្នា និងសេចក្តីមិនផ្សេងគ្នាក្នុងពាក្យទាំងនេះ គឺ **សញ្ញា វិញ្ញាណ បញ្ញា** ក្នុងពាក្យទាំង ៣ នោះ ផ្សេងគ្នាត្រឹមតែពាក្យនាំមុខ (ឧបសគ្គ) ប៉ុណ្ណោះ ។ ចំណែកបទថា **រមែងដឹង** មិនមានសេចក្តីផ្សេងគ្នា ។ សូម្បីក្នុងអត្ថថា **ដឹង** របស់បទនោះ ក៏គប្បីជ្រាបសេចក្តីផ្សេងគ្នា ។ ពិតណាស់ **សញ្ញា** ត្រឹមតែចាំអារម្មណ៍ ដោយអំណាចពណ៌ខៀវជាដើមប៉ុណ្ណោះ

មិនអាចឲ្យដល់ការចាក់ធ្លុះលក្ខណៈទាំងបី គឺ មិនទៀង ជាទុក្ខ ជាអនត្តាបាន ។ វិញ្ញាណ រមែងដឹងច្បាស់អារម្មណ៍ដោយអំណាចពណ៌ខៀវជាដើម និងឲ្យដល់ការចាក់ធ្លុះលក្ខណៈ មានមិនទៀងជាដើមក៏បាន តែនឹងឲ្យខ្វល់ខ្វាយដល់ការប្រាកដនៃមគ្គមិនបាន ។ បញ្ញា រមែងដឹងអារម្មណ៍ដោយអំណាចពណ៌ខៀវជាដើម ក៏បាន ឲ្យដល់ការចាក់ធ្លុះលក្ខណៈ ដោយអំណាចសេចក្តីមិនទៀងជាដើមក៏បាន និងខ្វល់ខ្វាយហើយ អាចឲ្យសម្រេចដល់ការប្រាកដនៃមគ្គបានផង ។ ដូចសេចក្តីថា យើងយកកហាបណៈមកគរទុកលើបន្ទះក្តារបស់ហិរញ្ញិក កាលបុគ្គល ៣ នាក់ គឺ កុមារតូចមិនទាន់ដឹងក្តី បុរសអ្នកស្រុក និងហិរញ្ញិក មកឈរមើល ។ កុមារតូចដែលមិនទាន់ដឹងក្តី រមែងដឹងបានត្រឹមតែការវិចិត្រស្អាតល្អ និងប្រភេទបួនជ្រុង ឬមូលរបស់កហាបណៈប៉ុណ្ណោះ មិនដឹងថា វត្ថុនេះ ដែលគេគ្រប់គ្នាដឹងថាជាកែវ គ្រឿងឧបភោគបរិភោគ របស់មនុស្សទាំងឡាយ ។ បុរសអ្នកស្រុក រមែងដឹងដល់ការវិចិត្រជាដើមផង ដឹងទូទៅដូចអ្នកគ្រប់គ្នាថា ជាកែវ សម្រាប់ប្រើជាគ្រឿងឧបភោគបរិភោគរបស់អ្នកទាំងឡាយផង តែមិនដឹងថា ក៏កហាបណៈនេះក្លែងក្លាយ ឬមិនក្លែងក្លាយ នេះគ្រោតគ្រាត នេះល្អិត , ហិរញ្ញិក រមែងដឹងដល់សេចក្តីវិចិត្រជាដើមផង ដឹងទូទៅថាជាកែវផង ដឹងដល់សេចក្តីក្លែងក្លាយជាដើមផង និងក៏កាលដឹងហើយ ក៏មើលរូបនោះខ្លះ ស្តាប់សំឡេងខ្លះ ហិតក្លិន

ខ្លះ លិទ្ធរសខ្លះ យកដៃចាប់មើលសេចក្ដីធ្ងន់ និងស្រាលខ្លះ ហើយក៏ដឹងថា ផលិតនៅស្រុកឯណោះខ្លះ ដឹងថា ផលិតក្នុងខេត្តឯណោះ ក្នុងក្រុងឯណោះ ជិតស្រះធម្មជាតិឯណោះ ក្រោមស្រមោលភ្នំឯណោះ ត្រង់ច្រាំងទន្លេឯណោះ ផលិតដោយអាចារ្យឯណោះខ្លះ យ៉ាងណា , **សញ្ញា** ក៏ដូចកុមារតូចដែលមិនទាន់ដឹងក្ដី មើលកហាបណៈ រមែងចាំអារម្មណ៍ដោយអំណាចពណ៌ខៀវជាដើមប៉ុណ្ណោះ ។ **វិញ្ញាណ** ក៏ដូចបុរសអ្នកស្រុកមើលកហាបណៈ រមែងដឹងអារម្មណ៍ដោយអំណាចពណ៌ខៀវជាដើមផង ឲ្យដល់ការចាក់ធ្លុះលក្ខណៈ ដោយអំណាចមិនទៀងជាដើមផង ។ **បញ្ញា** ដូចហិរញ្ញិកមើលកហាបណៈ រមែងដឹងអារម្មណ៍ដោយអំណាចពណ៌ខៀវជាដើមផង ដល់នូវការចាក់ធ្លុះលក្ខណៈ ដោយអំណាចមិនទៀងជាដើមផង ឲ្យខ្វល់ខ្វាយហើយដល់សេចក្ដីប្រាកដនូវផ្លូវ (មគ្គ) ផង យ៉ាងនោះឯង ។ ចំណែកសេចក្ដីផ្សេងគ្នានៃវត្ថុទាំងនោះ ចាក់ធ្លុះបានលំបាក ។

ព្រោះហេតុនោះ ព្រះនាគសេន ទើបពោលថា មហាបពិត្រ ព្រះមានព្រះភាគ ទ្រង់បានធ្វើវត្ថុដែលធ្វើបានលំបាកហើយ លោកម្ចាស់នាគសេនដ៏ចម្រើន វត្ថុដែលធ្វើបានលំបាក អ្វីដែលព្រះមានព្រះភាគទ្រង់បានធ្វើហើយ មហាបពិត្រ វត្ថុដែលធ្វើបានលំបាក ដែលព្រះមានព្រះភាគទ្រង់បានធ្វើហើយ គឺ សេចក្ដីដែលទ្រង់ប្រាប់ការកំណត់វត្ថុដែលជាចិត្ត និងវត្ថុដែលកើតជាមួយចិត្ត ដែលមិន

មានរូបរាង ប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយជាមួយគ្នាថា នេះគឺ វត្ថុដែលធ្វើនាទីប៉ះខ្ទប់ នេះគឺ វត្ថុដែលធ្វើនាទីសោយ នេះគឺ វត្ថុដែលធ្វើនាទីចាំ នេះគឺ វត្ថុដែលធ្វើនាទីចូរចិត្ត នេះគឺ វត្ថុដែលធ្វើនាទីគិត ។ ដូចបុគ្គលដែលយកប្រេង ៥ ប្រភេទនេះ គឺ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុង ប្រេងរាវ មកដាក់ចូលក្នុងភាជនៈតែមួយ ហើយយកឈើមកកូរទាំងថ្ងៃ ហើយក៏ដួសចែកចេញពីគ្នា ថា នេះប្រេងល្ង នេះប្រេងស្ពៃ នេះក៏រាប់ថា ធ្វើបានលំបាកទៅហើយ ក្រៃលែងធ្វើឲ្យលំបាកក្រៃលែងជាងនោះទៀត ព្រោះព្រះមានព្រះភាគ ព្រះអង្គជាធម្មរាជា ព្រះធម្មិស្សរោ ព្រោះសេចក្តីដែលទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណដ៏ប្រសើរហើយ ត្រាស់សម្តែងការកំណត់ធម៌ ដែលមិនមានរូបរាងមិនបាន ដែលកំពុងប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយដូចគ្នាទាំងនេះ ។ គប្បីជ្រាបសេចក្តីនេះថា ដូចគ្នានឹងដងទឹកមកចែកជាចំណែកៗ យ៉ាងនេះថា នេះជាទឹករបស់ទន្លេគង្គា នេះរបស់ទន្លេយមុនា ក្នុងទន្លេធំទាំង ៥ ខ្សែ ហូរចូលកាន់សមុទ្រហើយដូច្នោះ ។

[១៣៦] ពាក្យថា *ដែលលះបង់ចេញហើយ* គឺ រលាស់ចេញទៅហើយ ឬដែលត្រូវលះបង់ហើយ ។ កាលក្នុងពាក្យថា *ដែលលះបង់ចេញហើយ* នោះទាំង ៥ កាលមានសេចក្តីថា *ដែលត្រូវលះបង់ហើយ* ក៏គប្បីជ្រាបថា ជាតតិ-

យាវិកត្តិ ។ មានពាក្យដែលលោកអធិប្បាយទុកថា ដែលវិញ្ញាណត្រូវលោស់ចេញពីឥន្ទ្រិយទាំង ៥ ហើយប្រព្រឹត្តទៅក្នុងទ្វារចិត្ត ឬដែលត្រូវឥន្ទ្រិយទាំង ៥ លះបង់ចោលទៅហើយ ព្រោះសេចក្តីដែលវិញ្ញាណនោះ មិនចូលដល់សភាពជាទីតាំងបាន ។ ពាក្យថា **បរិសុទ្ធិ** គឺ មិនមានអ្វីចូលទៅធ្វើឲ្យសៅហ្មង ។ ពាក្យថា **មនោវិញ្ញាណ** គឺ ដោយរូបាវចរចតុត្ថជ្ឈានចិត្ត ។ ពាក្យថា **គប្បីណែនាំអ្វី** គឺ គប្បីដឹងអ្វី ព្រោះវត្ថុដែលគប្បីដឹង ក្នុងពាក្យជាដើមថា ធម្មតាវត្ថុដែលគប្បីណែនាំខ្លះ វត្ថុខ្លះនៅមាន... **ធម៌** លោកហៅថា **នេយ្យ** គប្បីណែនាំ គប្បីដឹង គប្បីដឹងអាកាសានញ្ចាយតនៈ យ៉ាងណា អរូបាវចរសមាបត្តិ ដែលបុគ្គលគប្បីដឹងបានដោយចិត្ត ដែលមានឈានទីបួន ដែលត្រាច់ទៅក្នុងរូបជាអារម្មណ៍ ព្រោះដូច្នោះ អ្នកដែលនៅក្នុងឈានទីបួន ដែលត្រាច់ទៅក្នុងរូប រមែងអាចធ្វើឲ្យអរូបាវចរសមាបត្តិ (ការចូលដល់ឈាន ដែលមិនត្រាច់ទៅក្នុងរូប ឬត្រាច់ទៅក្នុងវត្ថុដែលមិនមែនរូប) កើតឡើងបាន ។ ព្រោះអរូបាវចរសមាបត្តិ រមែងសម្រេចដល់អ្នកដែលនៅក្នុងឈានទីបួន ដែលត្រាច់ទៅក្នុងរូបបាន ។ ដូច្នោះ ព្រះសារីបុត្តត្ថេរ ទើបឆ្លើយថា គប្បីដឹង (ឬណែនាំ) អាកាសានញ្ចាយតនៈ ដូច្នេះ ។ កាលបើដូច្នោះ ហេតុដូចម្តេច ទើបមិនពោលដល់នេវសញ្ញានាសញ្ញាយតនៈផងហ្ន៎ ព្រោះមិនមានការចាត់ទុកមួយផ្នែកផ្សេងទៀត ក្នុងជួរនេវសញ្ញា-

នាសញ្ញាយតនៈនោះ បុគ្គលនឹងពិចារណាដោយភាពជាពួកៗ (និង) ដោយភាពជានយ័ៗ ក៏បាន ។ ការចាត់ទុកជាផ្នែកៗ រមែងមិនកើតដល់ភិក្ខុ សូម្បីថ្នាក់ព្រះធម្មសេនាបតីក៏ដោយ ។ ព្រោះដូច្នោះ សូម្បីព្រះថេរៈក៏ពិចារណាដោយភាពជាពួកៗ (និង) ដោយភាពជានយ័ៗ ហើយក៏ឆ្លើយថា បានឮគេពោលមកថា វត្ថុទាំងនេះមិនមានហើយ រមែងមាន ព្រមទាំងមានហើយ រមែងវិនាសទៅយ៉ាងនេះ ដោយប្រការដូច្នេះ ។ ចំណែកព្រះមានព្រះភាគ ព្រោះព្រះសព្វញ្ញុតញ្ញាណនៅក្នុងកណ្តាប់ព្រះហស្ត ទ្រង់លើកវត្ថុច្រើនជាង ៥០ យ៉ាង សូម្បីក្នុងនេវសញ្ញានាសញ្ញាយតនៈ ដោយការលើកឡើងជាអង្គ ចាត់ទុកជាផ្នែកៗ ហើយត្រាស់ថា ការសម្រេចអរហត្តផល មានប្រមាណប៉ុណ្ណេះ និងការចូលដល់សេចក្តីចាំ (សញ្ញាសមាបត្តិ) ដូច្នេះ ។

ពាក្យថា **រមែងដឹងច្បាស់ដោយបញ្ញាចក្ខុ** គឺ រមែងដឹងដោយបញ្ញា ដែលឈ្មោះថា ជាកែវភ្នែក ព្រោះអត្ថថា ជាអ្នកនាំឲ្យឃើញគ្រប់ផ្លូវ ។ ក្នុងពាក្យថា **រមែងដឹងច្បាស់ដោយបញ្ញាចក្ខុ** នោះ បញ្ញាមាន ២ យ៉ាង គឺ បញ្ញាក្នុងសមាធិ និងបញ្ញាក្នុងវិបស្សនា ។ រមែងដឹងច្បាស់ទាំងដោយកិច្ច ទាំងដោយការមិនវង្វេងដោយបញ្ញាក្នុងសមាធិ ។ លោកពោលការដឹងអារម្មណ៍ដោយការចាក់ធ្លុះលក្ខណៈបាន គឺ ចាក់ធ្លុះដោយបញ្ញាក្នុងវិបស្សនា ។ ពាក្យថា **ដើម្បីត្រូវការអ្វី** គឺ អ្វីជា

សេចក្ដីត្រូវការនៃបញ្ញានេះ ។ ក្នុងពាក្យជាដើមថា **មានសេចក្ដីដឹងក្រៃលែងជាទីត្រូវការ** គឺ ឈ្មោះថា មានសេចក្ដីដឹងក្រៃលែងជាទីត្រូវការ ព្រោះរមែងដឹងក្រៃលែងនូវវត្ថុដែលនឹងគប្បីដឹងដ៏យ៉ាងក្រៃលែង ។ ដែលឈ្មោះថា មានការកំណត់ដឹងជាទីត្រូវការ ព្រោះរមែងកំណត់ដឹងវត្ថុដែលនឹងត្រូវកំណត់ឲ្យដឹង ។ ឈ្មោះថា មានការលះជាទិសដៅ ក៏ព្រោះលះវត្ថុដែលត្រូវលះ ។ បញ្ញានេះសូម្បីដែលជាលោកិយបញ្ញា ក៏មានសេចក្ដីដឹងក្រៃលែងជាទីត្រូវការ មានសេចក្ដីកំណត់ដឹងជាទីប្រាថ្នា និងមានការលះដោយការគ្របសង្កត់ជាទិសដៅ ។ ដែលជាលោកុត្តរបញ្ញា ក៏មានសេចក្ដីដឹងក្រៃលែងជាទីត្រូវការ មានការកំណត់ដឹងជាសេចក្ដីប្រាថ្នា និងមានការលះដោយការកាត់ផ្ដាច់ជាទិសដៅ ។ ក្នុងបញ្ញាទាំងពីរនោះ លោកិយបញ្ញា រមែងដឹងច្បាស់ទាំងដោយកិច្ច ទាំងដោយការមិនវង្វេង , លោកុត្តបញ្ញា រមែងដឹងច្បាស់ដោយការមិនវង្វេង ។

[១៣៧] ពាក្យថា ***អាស្រ័យការឃើញដ៏ត្រឹមត្រូវ*** គឺ អាស្រ័យការឃើញដ៏ត្រឹមត្រូវក្នុងវិបស្សនា និងការឃើញដ៏ត្រឹមត្រូវក្នុងមគ្គ ។

ពាក្យថា **បរតោឃោសៈ** គឺ ការស្ដាប់សំឡេងដែលជាទីសប្បាយ ។

ពាក្យថា **យោនិសោមនសិការៈ** គឺ ធ្វើទុកក្នុងចិត្តដោយឧបាយ (វិធីការ) របស់ខ្លួន ។ សូម្បីក្នុងពួកព្រះសាវកទាំងនោះ បច្ច័យទាំងពីររមែងគួរ បានដល់

ព្រះថេរៈជាមេទ័ពធម៌ (ព្រះសារីបុត្រ) ប៉ុណ្ណោះ ។ ព្រោះព្រះថេរៈសូម្បីបាន បំពេញបារមីមកមួយអសង្ខេយ្យ កម្រៃមួយសែនកប្ប ក៏មិនទាន់អាចលះកិលេស សូម្បីតែបន្តិចដោយធម្មតារបស់ខ្លួនបាន ។ តែកាលបានស្ដាប់គាថានេះ អំពី ព្រះអស្សជិត្ថេរ ដែលមានជាដើមថា វត្ថុពួកណា មានហេតុជាដែនកើត (កើត មកពីហេតុ) ទើបចាក់ធ្លុះបាន ។ សម្រាប់ព្រះបច្ចេកពោធិញ្ញាណ និងសព្វញ្ញុតញ្ញ មិនមានការជាប់ទាក់ទងនឹងបរតោឃោសៈ ។ អ្នកដែលតាំងនៅក្នុងយោនិសោ-មនសិការៈប៉ុណ្ណោះ ទើបនឹងឲ្យកើតបច្ចេកពោធិញ្ញាណ និងសព្វញ្ញុគុណទាំង ឡាយបាន ។ ពាក្យថា ដែល... **ជួយផ្គត់ផ្គង់** គឺ បានទទួលឧបការៈហើយ ។ ពាក្យថា **សេចក្ដីឃើញត្រូវ** គឺ សេចក្ដីឃើញត្រូវក្នុងអរហត្តមគ្គ (ផ្លូវនៃការ បានជាព្រះអរហន្ត) សេចក្ដីឃើញត្រូវក្នុងអរហត្តមគ្គនោះ កើតក្នុងខណៈនៃ ផល ។ ដែលឈ្មោះថា មានសេចក្ដីឃើញការរួចផុត ព្រោះចិត្តជាផល ព្រោះ ការរួចផុត ព្រោះបដិបត្តិផ្លូវចិត្តជាផលរបស់លោក ។ ដែលឈ្មោះថា **មានផល** គឺ វត្ថុដែលហូរចេញមកពីការរួចផុតក្នុងផ្លូវចិត្ត ព្រោះផល គឺ វត្ថុដែលហូរ ចេញមក ពោលគឺ ការរួចផុតក្នុងផ្លូវចិត្តរបស់លោក ។ សូម្បីក្នុងបទទីពីរ ក៏មានទំនងតែមួយនេះឯង ។ និងគប្បីជ្រាបថា ក្នុងផលទាំងនេះ ផលទី ៤ ឈ្មោះថា ការរួចផុត ព្រោះសេចក្ដីដឹងច្បាស់ វត្ថុដ៏សេសជាការរួចផុត ព្រោះ

ចិត្ត ។ ក្នុងពាក្យជាដើមថា **ដែលសីលជួយទំនុកបម្រុងហើយ** សីលដែលមានសេចក្តីបរិសុទ្ធិ ៤ យ៉ាង ឈ្មោះថា សីល ។ ពាក្យថា **ការស្តាប់** គឺ ការស្តាប់រឿងរ៉ាវដែលជាទីសប្បាយ ។ ពាក្យថា **សាកច្ឆា** បានដល់ ពាក្យដែលកាត់សេចក្តីខុស ឃ្លៀងឃ្លាតក្នុងកម្មដ្ឋាន ។ ពាក្យថា **សមថ:** (សេចក្តីស្ងប់) បានដល់ សមាបត្តិ ៨ ដែលមានវិបស្សនាជាបាទ ។ ពាក្យថា វិបស្សនា (សេចក្តីឃើញច្បាស់) គឺ ការតាមឃើញ (អនុបស្សនា) ៧ យ៉ាង ។

ក៏ឯព្រះអរហត្តមគ្គ រមែងកើតឡើងហើយ ឲ្យផលដល់អ្នកដែលកំពុងបំពេញសីលដែលមានសេចក្តីបរិសុទ្ធិបួនយ៉ាង ស្តាប់រឿងរ៉ាវដែលជាសប្បាយ កាត់សេចក្តីខុស ឃ្លៀងឃ្លាតក្នុងកម្មដ្ឋាន ធ្វើការងារក្នុងសមាបត្តិ ៨ ដែលមានវិបស្សនាជាបាទ អប់រំការតាមពិចារណាឃើញ ៧ យ៉ាងហើយ ។ គប្បីជ្រាបសេចក្តីប្រៀបធៀបដូចអ្នកចង់បរិភោគស្វាយទុំផ្អែម ជាប់មាត់ទឹក ធ្វើរបងជុំវិញកូនដើមស្វាយយ៉ាងរឹងមាំ , កាន់ធ្នាំងទឹកស្រោចទឹកក្នុងគ្រាខ្លះៗ , ធ្វើទំនប់យ៉ាងមាំដើម្បីការពារទឹកមិនឲ្យហូរចេញ , យកវល្លិ៍ដែលនៅជិតៗ កំណាត់ឈើស្ងួតៗ សំបុកស្រមោចក្រហម ឬសរសៃពីងពាងចោលចេញ , យកចប (ឬចបជីក) ទៅជ្រំជុំវិញគល់ក្នុងវេលាខ្លះ , កាលគេប្រុងប្រយ័ត្នធ្វើហេតុគ្រប់ ៥ យ៉ាង ដូចដែលពោលមកនេះហើយ ស្វាយក៏ចម្រើន ហើយឲ្យផល ។ គប្បី

ឃើញសីលដែលមានសេចក្ដីបរិសុទ្ធបួនយ៉ាង ដូចការធ្វើរបងជុំវិញដើមឈើ, ការស្ដាប់រឿងរ៉ាវ (ធម្មៈ) ដូចការស្រោចទឹកក្នុងវេលាខ្លះៗ , សមថៈ ដូចការធ្វើសេចក្ដីរឹងមាំដោយទំនប់ , ការកាត់សេចក្ដីខុសឃ្លៀងឃ្លាតក្នុងកម្មដ្ឋាន ដូចការយកវល្លិ៍ដែលនៅជិតៗ ចេញ , ការអប់រំបញ្ញាគ្រឿងតាមពិចារណាឃើញ ៧ យ៉ាង ដូចការយកចបមកជ្រុំជុំវិញគល់ក្នុងវេលាខ្លះ , គប្បីជ្រាបការឲ្យផល គឺ ភាពជាព្រះអរហន្ត ព្រោះសេចក្ដីឃើញត្រូវនូវវត្ថុ ៥ យ៉ាង ទាំងនេះ របស់ភិក្ខុនេះ តាមទំនុកបម្រុងហើយ ដូចវេលាដើមស្វាយ ដែលហេតុទាំង ៥ យ៉ាង នោះ តាមទំនុកបម្រុង ហើយឲ្យផលផ្អែមឆ្ងាញ់ ដូច្នោះ ។

[១៣៨] ព្រះមហាកោដ្ឋិកត្ថេរ រមែងសួរដល់អ្វីក្នុងពាក្យនេះថា **អ្នកមានអាយុ ភពមានប៉ុន្មាន** ព្រះថេរៈរមែងសួរថា សេចក្ដីបន្តទៅដល់ឫសគល់តែម្ដង បុគ្គលល្ងង់ពួកណារមែងមិនរួចចាកភព ខ្ញុំនឹងសូមសួរដល់ភពទាំងនោះក្នុងភពទាំងនោះ ពាក្យថា **កាមភព** ព្រោះព្រះថេរៈរួមយកវត្ថុទាំងពីរ គឺ ការធ្វើដែលឲ្យចូលដល់កាមភព និងខន្ធ ដែលតណ្ហា មានៈ និងទិដ្ឋិប្រកាន់ទុកដែលកើតឡើងមកព្រោះការធ្វើតែម្យ៉ាង ហើយទើបពោលថា **កាមភព** សូម្បីក្នុងរូបភព និងអរូបភព ក៏មានទំនងដូចគ្នានេះឯង ។ ពាក្យថា **តទៅ** បានដល់ក្នុងអនាគត ។ ការកើតឡើងក្នុងភពថ្មីទៀត ឈ្មោះថា **ការកើតឡើងយ៉ាង**

ក្រៃលែងក្នុងភពថ្មីទៀត ក្នុងទីនេះ លោកសួរដល់ការវិលវល់ ស្លាប់កើត ។ សេចក្តីត្រេកអរយ៉ាងក្រៃលែងក្នុងវត្ថុនោះៗ យ៉ាងនេះ គឺ សេចក្តីត្រេកអរយ៉ាងក្រៃលែងក្នុងរូប សេចក្តីត្រេកអរយ៉ាងក្រៃលែងក្នុងសំឡេងជាដើម ឈ្មោះថា សេចក្តីត្រេកអរយ៉ាងក្រៃលែងក្នុងវត្ថុនោះៗ ពាក្យនេះជាបឋមាវិភត្តចុះក្នុងតតិយាវិភត្តិនោះឯង ទើបមានអធិប្បាយថា ការកើតឡើងក្នុងភពថ្មីទៀត រមែងមានព្រោះសេចក្តីត្រេកអរយ៉ាងក្រៃលែងក្នុងវត្ថុនោះៗ ។ ក៏ឯពាក្យមានប្រមាណប៉ុណ្ណោះ គឺ ព្រះថេរៈធ្វើឲ្យសេចក្តីវិលវល់ (នៃជីវិត) ដល់ទីបំផុត ហើយសម្តែងថា ការទៅមាន , ការមកក៏មាន ការទៅ និងការមកក៏មាន សេចក្តីវិល ក៏រមែងវិលទៅ ដូច្នេះ ។

ឥឡូវនេះ លុះសួរដល់ការឈប់វិលវល់ ព្រះមហាកោដ្ឋិកត្ថេរ ទើបបានពោលពាក្យជាដើមថា **ក៏យ៉ាងណា លោកអ្នកមានអាយុ** ក្នុងការឆ្លើយពាក្យសួរនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា **ព្រោះប្រាសចាកសេចក្តីមិនដឹង** បានដល់ ព្រោះការអស់ទៅនិងសាបសូន្យនៃសេចក្តីមិនដឹង ។ ពាក្យថា **ព្រោះកើតសេចក្តីដឹងឡើង** បានដល់ ព្រោះកើតសេចក្តីដឹងក្នុងព្រះអរហត្តមគ្គ ។ កុំគប្បីពោលពាក្យទាំងពីរនេះថា សេចក្តីមិនដឹងរលត់មុន ឬសេចក្តីដឹងកើតមុន ព្រោះកើតសេចក្តីដឹងឡើង

សេចក្តីមិនដឹង ទើបជាការរលត់ទៅដោយពិត ដូចសេចក្តីងងឹតបាត់ទៅព្រោះពន្លឺរបស់ចង្កៀង ។ ពាក្យថា ព្រោះចំណង់រលត់ទៅដោយមិនមានសេសសល់បានដល់ ព្រោះសេចក្តីរលត់ទៅដោយមិនមានសេសសល់ គឺ ការអស់ទៅនៃចំណង់ ។ ពាក្យថា **មិនមានការកើតឡើងក្នុងភពថ្មីទៀត** គឺ ការកើតឡើងនៃភពថ្មីទៀតតទៅយ៉ាងនេះ រមែងមិនមាន , ការទៅ ការមក ទាំងការទៅនិងការមក ក៏រមែងមិនមាន ។ ចក្កវដ្ដ (របស់ជីវិត) ក៏ឈប់វិលទៅដោយប្រការដូច្នេះ ។ ក៏ជាការដែលព្រះថេរៈធ្វើឲ្យចក្កវដ្ដ (របស់ជីវិត) ដល់ទីបំផុតហើយសម្តែង ។

[១៣៩] ព្រះថេរៈ រមែងសួរដល់អ្វី ក្នុងពាក្យនេះថា **លោកអ្នកមានអាយុ ក៏ដូចម្តេចហ្ន៎ ? ភិក្ខុដែលរួចផុតទាំងពីរចំណែក** (គឺទាំងចេតោវិមុត្តិនិងបញ្ញាវិមុត្តិ) រមែងចូលនិរោធក្នុងគ្រាខ្លះ ។ ព្រះថេរៈរមែងសួរថា ខ្ញុំសូមសួរឈានទីមួយ ដែលមាននិរោធជាគ្រឿងឧបការៈរបស់ភិក្ខុនោះ ក្នុងពាក្យនេះថា **អ្នកមានអាយុ ក៏ឯឈានទីមួយនេះ** ព្រះថេរៈរមែងសួរដល់អ្វី ? ធម្មតាភិក្ខុដែលចូលនិរោធត្រូវចូលដល់ព្រំដែនកំណត់អង្គថា ឈាននេះ មានអង្គ ៥ នេះមានអង្គបួន នេះមានអង្គបី នេះមានអង្គពីរ ។ ព្រះថេរៈទើបសួរថា ខ្ញុំនឹងសូមសួរដល់ព្រំដែនសម្រាប់កំណត់អង្គ ។ ក្នុងអង្គជាដើមថា វិតក្កៈ (នេះ)

វិតក្កៈមានការលើកឡើង (គឺ លើកអារម្មណ៍ឡើងកាន់ចិត្ត ឬលើកចិត្តឡើងកាន់អារម្មណ៍) ជាលក្ខណៈ វិចារៈមានការស្ទាបអង្អែល (អារម្មណ៍) ជាលក្ខណៈ , បីតិ មានការផ្សាយទៅជាលក្ខណៈ ។ សុខ មានសេចក្តីរីករាយជាលក្ខណៈ ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ មានសេចក្តីមិនរវើរវាយជាលក្ខណៈ វត្ថុទាំង ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដោយប្រការដូច្នេះ ។

ក្នុងពាក្យថា **ដែលអង្គនោះលះបានហើយ** នេះ ព្រះថេរៈរមែងសួរដល់អ្វី ? លោកសួរថា ធម្មតាភិក្ខុដែលចូលនិរោធ ត្រូវយល់អង្គដែលជាឧបការៈនិងដែលមិនមែនជាឧបការៈ ខ្ញុំសូមសួរអង្គទាំងនោះ ។ ចំណែកពាក្យឆ្លើយក្នុងពាក្យសួរនេះ ប្រាកដហើយ ។ ដោយប្រការដូច្នេះ ក៏ជាចំណែកដែលលោកបានកាន់យកឈានទីមួយ ដែលមាននិរោធជាគ្រឿងឧបការៈទុកក្នុងថ្នាក់ក្រោមហើយ ព្រះថេរៈទើបសួរការចូលនេវសញ្ញានាសញ្ញាយតនៈ ដែលជាអនន្តរប្បច្ច័យនៃឈានទីមួយនោះក្នុងថ្នាក់លើទៀត ។ ឯសមាបត្តិទាំង ៦ ក្នុងចន្លោះនៃនេវសញ្ញានាសញ្ញាយតនៈនោះ គប្បីជ្រាបថា លោកបានសង្ខេបទុក ឬលោកចង្អុលន័យដោះស្រាយទុកហើយ ។

[១៤០] ឥឡូវនេះ កាលទីងសួរបសាទទាំង ៥ ដែលជាទីអាស្រ័យនៃវិញ្ញាណ ព្រះមហាកោដ្ឋិកត្ថេរ ទើបពោលថា **អ្នកមានអាយុ ទាំង ៥ នេះជាដើម** ។

ក្នុងពាក្យទាំងនោះ ពាក្យថា **គោចរវិស័យ** គឺ វិស័យដែលជាគោចរ ។ ពាក្យថា **ដល់គ្នានិងគ្នា** បានដល់ រមែងមិនព្រមសោយចំពោះគោចរវិស័យ (អារម្មណ៍ជាទីត្រាច់ទៅ) ក្នុងវត្ថុនីមួយៗ យ៉ាងនេះ គឺ ត្រចៀក (ទទួលអារម្មណ៍បានទាំង) របស់ភ្នែក និងរបស់ត្រចៀក ឬ (ទទួលអារម្មណ៍) របស់ភ្នែក ។ ប្រសិនបើរួមយកអារម្មណ៍ដែលជារូប ផ្សេងដោយពណ៌ខៀវជាដើម ហើយបង្អោនទៅឲ្យឥន្ទ្រិយ គឺ ត្រចៀក ហើយនិយាយថា អើ! ធ្វើដូចជាមិនដឹងរបស់នោះ សាក-ល្បងថាឲ្យច្បាស់មកមើល៍ នេះវាឈ្មោះអារម្មណ៍អ្វី សូម្បីវិញ្ញាណផ្លូវភ្នែកហាមាត់ហើយ ក៏នឹងគប្បីនិយាយតាមធម្មតារបស់ខ្លួនយ៉ាងនេះថា នែអាខ្វាក់ហើយល្ងង់ផង ឲ្យឯងរត់ទៅមកអស់ទាំងរយឆ្នាំ ទាំងពាន់ឆ្នាំក៏ដោយចុះ ក្រៅពីយើងហើយ ឯងនឹងបានអ្នកស្គាល់វត្ថុនេះអំពីណា យកវាមកបង្អោនដាក់ក្នុងបសាទភ្នែកចុះ យើងនឹងស្គាល់អារម្មណ៍នោះ មិនថា វាជាពណ៌ខៀវ ឬលឿងនោះទេ ព្រោះវាមិនមែនវិស័យរបស់អ្នកដទៃឡើយ វាត្រូវជាវិស័យរបស់យើងប៉ុណ្ណោះ សូម្បីក្នុងទ្វារដ៏សេស ក៏មានន័យដូចគ្នានេះឯង ។ យ៉ាងនេះឈ្មោះថាឥន្ទ្រិយ ទាំងនេះមិនព្រមទទួលសោយគោចរវិស័យរបស់គ្នានិងគ្នា ។ ពាក្យថា **អ្វីជាទីអាស្រ័យ** បានដល់ លោកសួរថា អ្វីជាទីអាស្រ័យរបស់ឥន្ទ្រិយទាំងនេះ គឺ ឥន្ទ្រិយទាំងនេះ អាស្រ័យអ្វី? ពាក្យថា **មានចិត្តជាទីអាស្រ័យ** បានដល់

មានចិត្តជាទីត្រាច់ទៅ (សេពអារម្មណ៍ ឬធ្វើកម្ម) ជាទីអាស្រ័យ ។ ពាក្យថា **ចិត្តនុ៎ះឯង... របស់... ទាំងនោះ** បានដល់ ចិត្តដែលត្រាច់ទៅតាមមនោទ្វារ ឬចិត្តដែលត្រាច់ទៅផ្លូវទ្វារទាំង ៥ រមែងសោយគោចរវិស័យនៃឥន្ទ្រិយទាំងនោះ ដោយអំណាចសេចក្តីពេញចិត្តជាដើម ។ ពិតហើយ វិញ្ញាណក្នុងផ្លូវភ្នែក រមែងឃើញត្រឹមតែរូបប៉ុណ្ណោះ មិនមានសេចក្តីពេញចិត្ត ការគិតប្រទូសរ៉ាយ ឬសេចក្តីវង្វេងក្នុងការឃើញរូបជាដើម តែចិត្តដែលត្រាច់ទៅក្នុងមនោទ្វារ រមែងពេញចិត្ត រមែងប្រទូសរ៉ាយ ឬរមែងវង្វេង ។ សូម្បីក្នុងវិញ្ញាណផ្លូវត្រចៀកជាដើម ក៏ទំនងដូចគ្នានេះឯង ។

តទៅនេះ ជាការប្រៀបធៀបក្នុងរឿងឥន្ទ្រិយទាំងនោះ គឺ មានរឿងដំណាលថា មានម្ចាញ់តូចទាប ៥ នាក់ នាំគ្នាសេពគប់ព្រះរាជា ហើយក៏បានផលបន្តិចបន្តួចក្នុងពួកអ្នកស្រុក ៥ ត្រកូលមួយកន្លែង ដោយសេចក្តីលំបាក ។ របស់ត្រឹមតែប៉ុណ្ណោះឯង គឺ ពិន័យជាត្រីមួយចំណែក សាច់មួយចំណែក កហាបណៈល្មមទិញខ្សែបាទមួយសរសៃ កហាបណៈល្មមទិញខ្សែបចង់ជើបាទ ១ សរសៃ បួនកហាបណៈ ៨ កហាបណៈ ១៦ កហាបណៈ ៣២ កហាបណៈ ឬ ៦៤ កហាបណៈ ក្នុងពួកអ្នកស្រុកនោះ រមែងមានដល់ពួកសម្ចាញ់ទាំងនោះ ។ ព្រះរាជាប៉ុណ្ណោះទ្រង់ទទួលពលីដ៏ធំ មានមួយរយវត្ថុ ៥ រយវត្ថុ ពាន់វត្ថុ ។

គប្បីជ្រាបថា ប្រសាទទាំង ៥ ដូចពួកអ្នកស្រុក ៥ ត្រកូល ក្នុងទីនោះ, សេចក្តីដឹងច្បាស់ (វិញ្ញាណ) ទាំង ៥ ដូចសម្លាញ់ទន់ខ្សោយ ៥ នាក់ ការត្រាច់ទៅសេពអារម្មណ៍ (ជវនៈ) ដូចព្រះរាជា នាទីគ្រាន់តែការឃើញរូបជាដើម នៃវិញ្ញាណក្នុងផ្លូវភ្នែកជាដើម ដូចសម្លាញ់ទន់ខ្សោយ បានទទួលផលបន្តិចបន្តួច ។ ចំណែកសេចក្តីពេញចិត្តជាដើម មិនមានក្នុងបសាទទាំងនេះ ។ គប្បីជ្រាបសេចក្តីពេញចិត្តជាដើមរបស់ចិត្ត ដែលធ្វើកិច្ចត្រាច់ទៅសេពអារម្មណ៍ក្នុងទ្វារទាំងនោះ ដូចការទទួលពលីចំនួនច្រើនរបស់ព្រះរាជា ។

[១៤១] ក្នុងពាក្យថា **ទាំង ៥ នេះ អ្នកមានអាយុ** នេះ ព្រះថេរៈរមែងសួរដល់អ្វី លោកសួរដល់បសាទទាំង ៥ ខាងក្នុងនិរោធថា ចំណែកពួកវត្ថុដែលមិនមានរូបរាង (នោះ) កាលប្រព្រឹត្តទៅ ដែលសម្រេចមកពីកិរិយា (ចិត្ត) កំពុងប្រព្រឹត្តទៅហើយ ក៏ជាបច្ច័យដែលមាំមួនដល់បសាទទាំងឡាយ ចំណែកបុគ្គលណារំលត់បសាទដែលប្រព្រឹត្តទៅហើយនោះ ហើយចូលនិរោធសមាបត្តិ បសាទទាំង ៥ ខាងក្នុងនិរោធរបស់បុគ្គលនោះ អាស្រ័យអ្វី ទើបតាំងនៅបាន ខ្ញុំសូមសួរវត្ថុនេះ ដោយប្រការដូច្នេះ ។ ពាក្យថា **អាស្រ័យអាយុ** បានដល់ អាស្រ័យធម្មជាតិដែលជាធំធ្វើកិច្ចដែលរស់នៅ (ជីវិតិន្ទ្រិយ) តាំងនៅ ។ ពាក្យថា **អាស្រ័យចំហាយក្តៅ** បានដល់ វត្ថុដែលជាធំក្នុងការរស់នៅអាស្រ័យភ្លើង

ដែលកើតពីកម្មតាំងនៅ ។ ក៏ព្រោះសូម្បីភ្លើងដែលកើតមកពីកម្ម វៀរវត្ថុដែលជាជំក្នុងការរស់នៅ រមែងតាំងនៅមិនបាន ដូច្នោះ លោកទើបពោលថា អាស្រ័យអាយុតាំងនៅ ។ ពាក្យថា **ជុតឆេះហើយ** បានដល់ ឆេះសន្ធោសន្ធៅ ។ ពាក្យថា **អាស្រ័យអណ្តាតភ្លើង** បានដល់ អាស្រ័យអណ្តាតភ្លើង ។ ពាក្យថា **ពន្លឺរមែងប្រាកដ** បានដល់ ពន្លឺរមែងប្រាកដ ។ ពាក្យថា **អណ្តាតភ្លើងអាស្រ័យពន្លឺ** បានដល់ អណ្តាតភ្លើងអាស្រ័យពន្លឺទើបប្រាកដ ។ ក្នុងពាក្យថា **ដូច្នោះនុ៎ះឯង លោកអ្នកមានអាយុ អាយុរមែងអាស្រ័យកម្តៅតាំងនៅ** នេះ គឺ ភ្លើងដែលកើតពីកម្មដូចអណ្តាតភ្លើង , វត្ថុដែលជាជំក្នុងការរស់នៅ ដូចពន្លឺ , ពិតហើយ អណ្តាតភ្លើងកាលនឹងកើត ក៏កាន់យកពន្លឺនុ៎ះឯង ប្រាកដឡើង ។ សូម្បីអណ្តាតភ្លើងនោះឯង ក៏រមែងប្រាកដជារបស់តូច ធំ វែង ខ្លី តាមពន្លឺខ្ទនោះ ឲ្យកើតនុ៎ះឯង ការប្រើវត្ថុដែលជាជំក្នុងការរស់នៅ ដែលកើតព្រមនឹងមហាភូតរូបដែលកើតពីកម្ម ដែលអាស្រ័យកម្តៅ តាមរក្សាកម្តៅ ក៏ដូចសេចក្តីប្រាកដនៃការប្រព្រឹត្តទៅរបស់អណ្តាតភ្លើងនោះឯង ព្រោះពន្លឺដែលប្រព្រឹត្តទៅបានអាស្រ័យអណ្តាតភ្លើងនោះឲ្យកើត ពិតហើយ វត្ថុដែលជាជំក្នុងការរស់នៅ រមែងរក្សាកម្តៅឲ្យប្រព្រឹត្តទៅដែលកើតពីកម្ម ទុក ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ។ល។ មួយរយឆ្នាំខ្លះ ។ ដោយប្រការដូច្នេះ មហាភូតរូប ទើបជាបច្ច័យដោយអំណាចនិស្ស័យប្បច្ច័យជាដើម

នៃរូបអាស្រ័យ ។ ដូច្នោះ ទើបជាការពោលថា អាយុរមែងអាស្រ័យកម្តៅ ហើយតាំងនៅ ។ ភាពជាធំក្នុងការរស់នៅ រមែងរក្សាមហាភូតរូបទាំងឡាយទុក ដោយហេតុនេះ ទើបគប្បីយល់ថា កម្តៅ រមែងអាស្រ័យអាយុតាំងនៅ ។

ពាក្យថា **អាយុសង្ខារ** គឺ អាយុនុ៎ះឯង ។ ពាក្យថា **ធម៌ទាំងឡាយមានវេទនា** គឺ ធម៌ដែលជាវេទនា ។ ពាក្យថា **ការចេញរមែងប្រាកដ** គឺ ការចេញចាកសមាបត្តិក៏ប្រាកដ ។ ពិតហើយ ភិក្ខុណាកើតការពេញចិត្តក្នុងអរូប ដែលប្រព្រឹត្តទៅហើយ ទើបរលត់សញ្ញា និងវេទនា ហើយចូលកាន់និរោធ ធម៌ដែលមិនមានរូបរាង ទើបមានវត្ថុដែលជាធំក្នុងការរស់នៅរបស់រូបជាបច្ច័យ ក៏កើតដល់ភិក្ខុនោះ តាមអំណាចវេលាតាមដែលកំណត់ទុក ចំណែកធម៌ទាំងមានរូបនិងមិនមានរូប ដែលប្រព្រឹត្តទៅហើយយ៉ាងនោះ ក៏នៅប្រព្រឹត្តទៅ ។ ដូចអ្វី ? ដូចបុរសម្នាក់កើតទុក្ខហើយ ព្រោះអណ្តាតភ្លើងដែលប្រព្រឹត្តទៅ ទើបយកទឹកមកលត់ធ្វើឲ្យអណ្តាតភ្លើងរលត់ទៅ យកផេះមកលុបរងើកទុក ហើយក៏អង្គុយស្ងៀម ។ កាលគេចង់ឲ្យមានអណ្តាតភ្លើងទៀត ក៏គៀរផេះចេញ ហើយត្រឡប់រងើកភ្លើងចុះឡើង ថែមគ្រឿងឆេះ ហើយផ្លុំខ្យល់ដោយមាត់ ឬបក់ដោយផ្លិតស្លឹកត្នោត ក្លាមនោះ អណ្តាតភ្លើងដែលប្រព្រឹត្តទៅ ក៏ប្រព្រឹត្តទៅបាន យ៉ាងណា , ដូច្នោះនុ៎ះឯង ធម៌ដែលមិនមានរូប ក៏ដូចអណ្តាតភ្លើងដែលប្រព្រឹត្តទៅ , ការដែល

ភិក្ខុកើតសេចក្តីខ្វល់ខ្វាយ ក្នុងអរូប (ឈាន) ដែលប្រព្រឹត្តទៅហើយ ទើបរលត់សញ្ញា និងវេទនា ចូលនិរោធ ក៏ដូចបុគ្គលកើតសេចក្តីរំខានព្រោះអណ្តាតភ្លើងដែលប្រព្រឹត្តទៅហើយ ទើបយកទឹកមកលត់ធ្វើឲ្យអណ្តាតភ្លើងរលត់ យកផេះច្រើនលុបរងើក ហើយអង្គុយស្ងៀម , វត្ថុដែលជាធំក្នុងការរស់នៅរបស់រូប គឺ ធាតុភ្លើងដែលកើតពីកម្ម ក៏គង់ប្រព្រឹត្តទៅដូចគ្នានឹងរងើកដែលយកផេះលុបទុក , ការទៅតាមវេលាដែលភិក្ខុកំណត់ទុក ដូចគ្នានឹងការដែលបុគ្គលត្រូវការអណ្តាតភ្លើងទៀត ហើយកៀរផេះជាដើមចេញទៅ , ការប្រព្រឹត្តទៅរបស់ធម៌ដែលមានរូប និងមិនមានរូប ក្នុងកាលធម៌ដែលមិនមានរូបកើតឡើងទៀត គប្បីជ្រាបថា ដូចការប្រព្រឹត្តទៅរបស់ពន្លឺភ្លើង ។

[១៤២] ពាក្យថា ***អាយុ ភ្លើងធាតុ និងវិញ្ញាណ*** មានសេចក្តីថា វត្ថុបីយ៉ាងទាំងនេះ គឺ វត្ថុដែលជាធំក្នុងការរស់នៅរបស់រូប ១ ភ្លើងធាតុដែលកើតពីកម្ម ១ ចិត្ត ១ លះបង់ចោលរូបកាយនេះកាលណា កាលនោះក៏ត្រូវលះបង់កាយនេះឲ្យដេកលើផែនដីដូចកំណាត់ឈើរកប្រយោជន៍គ្មាន ដូច្នោះ ។ សមដូចពាក្យដែលលោកពោលទុកយ៉ាងនេះថា

*អាយុ ភ្លើងធាតុ និងវិញ្ញាណ លះបង់រាងកាយនេះទៅកាលណា*

*កាលនោះ ក៏ត្រូវចោលឲ្យដេកដោយគ្មានចិត្ត ក្លាយជាអាហារ*

របស់សត្វដទៃទៅ ។

ការដកដង្ហើមចូល និងការដកដង្ហើមចេញ ឈ្មោះថា **កាយសង្ខារ** ការត្រិះរិះ និងការពិចារណា ឈ្មោះថា **វចីសង្ខារ** សញ្ញា និងវេទនា ឈ្មោះថា **ចិត្តសង្ខារ** ជីវិតរូប ឈ្មោះថា **អាយុ** ពាក្យថា **បែកធ្លាយទៅដោយជុំវិញ** បានដល់ ត្រូវវិនាសហើយ ក្នុងរឿងរបស់និរោធ (សេចក្តីរលត់) នោះ ជួនកាលលោកពោលថា ចិត្តនៅមិនទាន់រលត់ ព្រោះពាក្យ (បាលី) ថា ចិត្តសង្ខាររបស់អ្នកចូលនិរោធប៉ុណ្ណោះ ដែលរលត់ទៅ , ដូច្នោះទើបជាការចូលដល់កាយ ព្រមនឹងចិត្ត គប្បីពោល (ជំទាស់) លោកទាំងនោះថា ពាក្យនិយាយ ក៏មិនរលត់ឬ ព្រោះពាក្យ (បាលី) ថា សូម្បីវចីសង្ខាររបស់លោក ក៏រលត់ទៅដែរ ដូច្នោះ បុគ្គលអ្នកចូលនិរោធសមាបត្តិ គប្បីអង្គុយពោលធម៌ក៏បាន គប្បីអង្គុយធ្វើការទន្ទេញធម៌ក៏បាន និងចិត្តរបស់បុគ្គលអ្នកដែលធ្វើកាលៈស្លាប់ទៅហើយ ក៏មិនគប្បីរលត់ ព្រោះពាក្យ (បាលី) ថា សូម្បីចិត្តសង្ខាររបស់លោកក៏រលត់ទៅហើយ ដូច្នោះ អ្នកជុតឱពុកម្តាយ ឬព្រះអរហន្ត ដែលស្លាប់ទៅហើយ ក៏នឹងគប្បីជាអ្នកធ្វើអនន្តរិយកម្មឬហ្ន៎ ព្រោះដូច្នោះ កុំទៅធ្វើការចាប់កាន់ក្នុងព្យញ្ជនៈ គប្បីតាំងនៅក្នុងបែបផែន (ន័យ) ហើយពិចារណាសេចក្តីឲ្យល្អិតល្អន់ ពិតណាស់សេចក្តីជាគោលដែលគប្បីអាស្រ័យ មិនមែនព្យញ្ជនៈ ។ ពាក្យថា **ឥន្ទ្រិយទាំង**

**ឡាយផូរផង់ហើយ** សេចក្តីថា ពិតហើយ កាលការប្រព្រឹត្តទៅដែលសម្រេចមកពីកិរិយាចិត្តកំពុងប្រព្រឹត្តទៅ កាលអារម្មណ៍ខាងក្រៅកំពុងប៉ះខ្ទប់បសាទ ឥន្ទ្រិយទាំងឡាយរមែងនៀយហត់ដូចជាត្រូវប៉ះទង្គិច ដូចគ្នានឹងកញ្ចក់ដែលតាំងទុកក្នុងផ្លូវធំបែកជាបួន ត្រូវល្អងធូលីដែលហុយឡើងព្រោះខ្យល់ជាដើម ធ្វើឲ្យប្រលាក់ដូច្នោះ ។ បសាទទាំង ៥ នៅខាងក្នុងនិរោធរបស់ភិក្ខុដែលចូលនិរោធ រមែងរុងរឿង ដែលនឹងប្រៀបដូចកញ្ចក់ដែលដាក់ទុកក្នុងថង់ ហើយរក្សាទុកជាដើម រមែងរុងរឿងក្នុងខាងក្នុងនុ៎ះឯងយ៉ាងណា ក៏ដូច្នោះ ។ ព្រោះដូច្នោះ ព្រះសារីបុត្តត្ថេរ ទើបបានពោលថា **ឥន្ទ្រិយទាំងឡាយផូរផង់ហើយ** ។

[១៤៣] ក្នុងពាក្យថា **អ្នកមានអាយុ ក៏បច្ច័យមានប៉ុន្មាន** ព្រះមហាកោដ្ឋិកត្ថេរ រមែងសួរដល់អ្វី លោករមែងសួរថា **ខ្ញុំនឹងសូមសួរដល់នេវសញ្ញានាសញ្ញាយតនៈ ដែលជាអនន្តរប្បច្ច័យរបស់និរោធ** ។ ក្នុងការដោះស្រាយបញ្ហានោះ ព្រះសារីបុត្តត្ថេរ បានពោលដល់បច្ច័យដែលទៅប្រាសហើយទុកបួនយ៉ាងថា **និងព្រោះលះសុខចេញបាន** ជាដើម ។

ក្នុងពាក្យថា **មិនមានគ្រឿងសម្គាល់** នេះ លោករមែងសួរដល់អ្វី លោកសួរថា ខ្ញុំនឹងសូមសួរដល់ផលសមាបត្តិរបស់អ្នកចេញចាកនិរោធ ។ ឯការចេញចាកពីសមាបត្តិដ៏សេសរមែងមាន ព្រោះភវង្គ ។ ចំណែកការចេញចាកនិរោធ

រមែងមានព្រោះផលសមាបត្តិដែលហូរមកពីវិបស្សនា ។ ដូច្នោះ ព្រះថេរៈទើបសួរដល់ការចេញចាកនិរោធនោះឯង ។ ពាក្យថា **មានគ្រឿងសម្គាល់គ្រប់យ៉ាង** បានដល់ អារម្មណ៍ទាំងអស់ មានរូបជាដើម ។ ពាក្យថា **និងការធ្វើទុកក្នុងចិត្តក្នុងធាតុដែលមិនមានគ្រឿងសម្គាល់** បានដល់ ការធ្វើទុកក្នុងចិត្តក្នុងនិព្វានធាតុដែលប្រាសចាកគ្រឿងសម្គាល់គ្រប់ប្រភេទ ។ ព្រះថេរៈពោលសំដៅយកមនសិការដែលកើតព្រមនឹងផលសមាបត្តិ ដោយប្រការដូច្នេះ ។ ជាការពោលថា លោកកាន់យកឈានទីមួយ ដែលមាននិរោធជាបាទក្នុងជាន់ក្រោមហើយ , នេវសញ្ញា-នាសញ្ញាយតនៈដែលជាអនន្តរប្បច្ច័យរបស់និរោធ លោកក៏កាន់យកហើយ , ផលសមាបត្តិរបស់អ្នកចេញចាកនិរោធ លោកក៏កាន់យកក្នុងបទនេះដែរ ។ ក្នុងទីនេះគប្បីពោលដល់និរោធកថា (ពាក្យថាដោយសេចក្ដីរលត់) និរោធកថានោះមកហើយក្នុងបដិសម្ភិទាមគ្គយ៉ាងនេះថា បញ្ញាអប់រំចម្រើននូវភាពស្ទាត់ជំនាញរមែងមានបានដោយសេចក្ដីស្ងប់រម្ងាប់គ្រឿងតាក់តែងទាំងបីយ៉ាង ព្រោះបុគ្គលអ្នកប្រកបដោយផលពីរយ៉ាង ដោយការប្រព្រឹត្តទៅក្នុងញាណទាំង ១៦ យ៉ាង និងក្នុងសមាធិចរិយា ៩ យ៉ាង ញាណរមែងមានដោយការចូលនិរោធ ចំណែកពាក្យវិនិច្ឆ័យគ្រប់កន្លែងនៃនិរោធកថានោះ លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

ឥឡូវនេះ កាលនឹងសួរដល់សមាបត្តិ ព្រះថេរៈទើបពោលពាក្យជាដើមថា

**អ្នកមានអាយុ កី៏ឯបច្ច័យមានប៉ុន្មាន** ក៏ធម្មតាការតាំងនៅនៃផលសមាបត្តិរបស់អ្នកចេញចាកនិរោធមិនមាន ។ ការតាំងនៅ (ឋិតិ បានដល់ ឋិតិខណៈ) ប្រព្រឹត្តទៅមួយ ឬពីរវារៈចិត្តប៉ុណ្ណោះ ហើយក៏ធ្លាក់ចុះកាន់ភវង្គ សម្រាប់ភិក្ខុដែលអង្គុយរំលត់វត្ថុដែលមិនមានរូបឲ្យប្រព្រឹត្តទៅហើយរហូតអស់ ៧ ថ្ងៃនេះ នឹងតាំងនៅក្នុងផលសមាបត្តិរបស់អ្នកចេញចាកនិរោធបានមិនយូរ ។ តែក្នុងសមាបត្តិ ការកំណត់វេលាជារឿងសំខាន់ , ដូច្នោះ ឈ្មោះថា ការតាំងនៅ ទើបរមែងមាន ។ ព្រោះហេតុនោះ ព្រះមហាកោដ្ឋិកត្ថេរ ទើបពោលថា **ដោយការតាំងនៅ (ឋិតិ) នៃផលសមាបត្តិដែលមិនមានគ្រឿងសម្គាល់** មានន័យថា បច្ច័យដើម្បីសេចក្តីតាំងនៅបានយូរនៃផលសមាបត្តិនោះ មានប៉ុន្មាន ចំណែកក្នុងការដោះស្រាយបញ្ហានោះ លោកពោលដល់វេលាថា **និងការតាក់តែងយ៉ាងក្រៃលែងក្នុងកាលមុន** ព្រះមហាកោដ្ឋិកត្ថេរសួរដល់ការចេញចាកភវង្គ ក្នុងពាក្យថា **នៃការចេញ** នេះ ។ សូម្បីក្នុងការដោះស្រាយបញ្ហានោះ លោកក៏បានពោលដល់ការធ្វើទុកក្នុងចិត្តដែលកើតឡើងព្រមនឹងភវង្គ ដោយអំណាចគ្រឿងនិមិត្ត មានរូបជាដើមថា **និងការធ្វើទុកក្នុងចិត្តនូវគ្រឿងនិមិត្តគ្រប់ប្រភេទ** ។

[១៤៤] ក្នុងពាក្យថា **អ្នកមានអាយុ... កី៏ដូច្នេះឯង** នេះ ព្រះមហាកោដ្ឋិកត្ថេរសួរដល់អ្វី លោកសួរថា ក្នុងទីនេះមិនមានប្រការថ្មីយ៉ាងដទៃ ខ្ញុំនឹង

សូមយកវត្ថុដែលពោលរួចហើយក្នុងកាលក្រោយនុ៎ះឯង មករួមតែមួយ ហើយទើបសួរ ។

ក៏ឯវត្ថុទាំងនេះ លោកពោលទុកទីណា លោកពោលដល់ចេតោវិមុត្តិដែលមិនមានព្រំដែនកំណត់ទុកក្នុងទីនេះឯងថា **រមែងចាំពណ៌ខៀវក៏បាន រមែងចាំពណ៌លឿង ពណ៌ក្រហម ពណ៌សក៏បាន** ។ លោកពោលដល់សភាពជារបស់ទទេក្នុងសូត្រនេះថា **រមែងដឹងច្បាស់អាកិញ្ចញ្ញា** ក្នុងទីនេះថា គប្បីដឹងអាកិញ្ចញ្ញាយតនៈ ដែលបរិកម្មថា **មិនមានអ្វីៗ** (ឬអ្វីតិចតួចក៏មិនមាន) ដោយភ្នែក គឺបញ្ញា ។ លោកពោលដល់ចេតោវិមុត្តិដែលមិនមានគ្រឿងសម្គាល់ ក្នុងព្រះសូត្រនេះថា **អ្នកមានអាយុ ក៏បច្ច័យរបស់ការតាំងនៅ របស់ការចេញនៃចេតោវិមុត្តិដែលមិនមានគ្រឿងសម្គាល់ មានប៉ុន្មាន** លោករមែងយកវត្ថុដែលពោលរួចហើយក្នុងខាងក្រោយនុ៎ះឯង មករួមចូលតែមួយក្នុងទីនេះ ហើយទើបសួរយ៉ាងនេះ ។ ព្រោះពោលថា ក៏លោកដាក់ការរួចផុតនោះហើយ ទើបសម្តែងការរួចផុតនេះទុកក្នុងទីនោះៗ ឬ ទើបនៅមានវត្ថុពួកដទៃទៀតបួនយ៉ាង ដែលមានឈ្មោះតែម្យ៉ាងដូចគ្នា ។ វត្ថុដូចគ្នាតែម្យ៉ាង មានឈ្មោះ ៤ យ៉ាងក៏មាន ។ លោកទើបសួរដើម្បីឲ្យអ្នកឆ្លើយ ធ្វើវត្ថុមួយឲ្យជាក់ច្បាស់ ហើយប្រាប់ក្នុងទីនេះ ។ ក្នុងអដ្ឋកថាលោកធ្វើសេចក្តីយល់ព្រម ដូច្នេះ ។ ពាក្យក្នុងការឆ្លើយតបពាក្យ

សួរនោះថា **អ្នកមានអាយុ... នេះហៅថា អប្បមាណាចេតោវិមុត្តិ** (មិនមានព្រំដែនកំណត់) គឺ នេះឈ្មោះថា ការរួចផុតដោយចិត្តដែលមិនមានប្រមាណ ព្រោះមិនមានប្រមាណនៃការផ្សាយទៅ ។ ពិតហើយ ការរួចផុតដោយចិត្តដែលមិនមានប្រមាណនេះ រមែងផ្សាយទៅក្នុងសត្វមិនកំណត់ចំនួន ឬផ្សាយទៅក្នុងសត្វមួយដរាបដល់មិនមានសត្វនៅសល់ ។

ពាក្យថា **អ្នកមានអាយុ... នេះហៅថា អាកិញ្ចញ្ញា** គឺ ដែលឈ្មោះថា អាកិញ្ចញ្ញា ព្រោះមិនមានសេចក្តីកង្វល់ក្នុងអារម្មណ៍ ។ ពាក្យថា **ឬក្រៅពីខ្លួន** គឺ សូន្យចាកខ្លួន ពោលគឺ អត្តភាពបុរស និងបុគ្គលជាដើម ។ ពាក្យថា **ឬក្រៅពីរបស់ខ្លួន** បានដល់ សូន្យចាករបស់ខ្លួន ពោលគឺ គ្រឿងបរិក្ខារ មានចីវរជាដើម ។ ពាក្យថា **មិនមាននិមិត្ត** បានដល់ ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមាននិមិត្ត មានរាគៈជាដើម ។ ព្រះថេរៈពោលសំដៅយកការចូលដល់អរហត្តផល ។ ពាក្យថា **អត្ថក៏ផ្សេងគ្នា និងព្យញ្ជនៈក៏ផ្សេងគ្នា** បានដល់ ទាំងព្យញ្ជនៈ ទាំងអត្ថនៃវត្ថុទាំងនោះផ្សេងគ្នា ។ ក្នុងសេចក្តីផ្សេងគ្នាទាំងនោះ សេចក្តីផ្សេងគ្នានៃព្យញ្ជនៈ ជាក់ច្បាស់ហើយ ។ ចំណែកអត្ថ គឺ ការរួចផុតដោយចិត្តដែលមិនកំណត់ចំនួន (**អប្បមាណាចេតោវិមុត្តិ**) ជាមហគ្គតៈ ។ ជារូបាវចរៈដោយភូមិ ជាអរូបាវចរ ប៉ុន្តែដោយអារម្មណ៍ មានសត្វបញ្ញត្តិជាអារម្មណ៍ ។

អាកិញ្ចញ្ញា ដោយភូមិ ជាអរូបាវចរភូមិ ដោយអារម្មណ៍ មាននវត្តព្វារម្មណ៍ ។ សេចក្តីជារបស់សូន្យ (**សុញ្ញតា**) ដោយភូមិជាកាមាវចរៈ ដោយអារម្មណ៍ មានសង្ខារជាអារម្មណ៍ ។ សម្រាប់ក្នុងទីនេះ លោកសំដៅយកវិបស្សនាថា ជាសុញ្ញតា ។ សេចក្តីមិនមាននិមិត្ត (**អនិមិត្តា**) ដោយភូមិជាលោកុត្តរភូមិ ដោយអារម្មណ៍ មានព្រះនិព្វានជាអារម្មណ៍ ។ ក្នុងពាក្យជាដើមថា **អ្នកមានអាយុរាគៈនេះឯង ជាវត្ថុធ្វើសេចក្តីប្រមាណ** លោកពោលវត្ថុដែលធ្វើសេចក្តីប្រមាណទុកថា ដូចសេចក្តីថា ក្បែរជើងភ្នំ មានទឹកស្អុយ ១៥ ប្រភេទ ជាទឹកមានពណ៌ខ្មៅ ប្រាកដដូចជាជ្រៅតាំងរយព្យាមដល់អ្នកសម្លឹងមើល មិនមានសូម្បីគ្រាន់តែលិចខ្នងជើងរបស់អ្នកយកឈើច្រត់ ឬខ្សែវាស់យ៉ាងណា , យ៉ាងនោះដូចគ្នា កិលេសមានរាគៈជាដើម មិនទាន់កើតឡើងដរាបណា ដរាបនោះ ក៏មិនមានអ្នកណាអាចស្គាល់បុគ្គលបាន ម្នាក់ៗ ក៏ប្រាកដដូចព្រះសោតាបន្ន ដូចព្រះ-សកទាគាមី និងដូចព្រះអនាគាមី ។ តែកាលរាគៈជាដើម កើតឡើងដល់គេទើបប្រាកដចេញមកថា ជាអ្នកពេញចិត្ត អ្នកប្រទុស្តរ៉ាយ អ្នកវង្វេង ។ រាគៈជាដើមទាំងនោះ រមែងកើតឡើង សម្តែងប្រមាណរបស់បុគ្គលថា **បុគ្គលនេះត្រឹមតែប៉ុណ្ណោះ** ដូចដែលពោលមកនេះ ។

ពាក្យថា **អ្នកមានអាយុ ការរួចផុតដោយចិត្ត មានសត្វដែលបុគ្គលគប្បី**

ប្រមាណមិនបាន **មានប្រមាណប៉ុន្មាន** គឺ ការរួចផុតដោយចិត្ត ដែលមិនមានប្រមាណ មានប្រមាណត្រឹមណា ក៏ការរួចផុតដោយចិត្តដែលមិនមានប្រមាណទាំងនោះមានប៉ុន្មាន មាន ១២ យ៉ាង គឺ ព្រហ្មវិហារ ៤ មគ្គ ៤ ផល ៤ ។ ក្នុង ១២ យ៉ាងនោះ **ព្រហ្មវិហារ** ឈ្មោះថា មិនមានប្រមាណ ព្រោះការដែលផ្សាយទៅមិនមានប្រមាណ ដ៏សេសឈ្មោះថា មិនមានប្រមាណ ព្រោះមិនមានកិលេសជាគ្រឿងប្រមាណ ។ សូម្បីព្រះនិព្វានក៏ប្រមាណមិនបានដូចគ្នា ។ ចំណែកការរួចផុតដោយចិត្តមិនមាន (ក្នុងព្រះនិព្វាននោះ) ដូច្នោះលោកទើបមិនចាត់ចូល ។ ពាក្យថា **មិនកម្រើក** សំដៅយកការរួចផុតដោយចិត្ត គឺ ព្រះអរហត្តផល ។ ឯការរួចផុតដោយចិត្ត គឺ ព្រះអរហត្តផលនោះ ជាធំជាងអ្វីៗ ទាំងអស់ ។ ដូច្នោះលោកទើបពោលថា **ដែលលោករមែងពោលថា ដ៏ប្រសើរ** ។ ពាក្យថា **អ្នកមានអាយុ រាគៈនោះឯង ជាតួបៀតបៀន** គឺ រាគៈ សូម្បីកាលកើតឡើងហើយរមែងបៀតបៀន ញាំញី រុក្កុនបុគ្គល ដូច្នោះ លោកទើបពោលថា ជាតួបៀត-បៀន (តួបង្កឲ្យកើតសេចក្ដីកង្វល់ , សេចក្ដីវល់ខ្វល់ខ្វាយ) ។ ដំណាលមកថា ពួកមនុស្សកំពុងនាំគ្នាយកគោបញ្ជាន់ស្រូវក្នុងលាន ហើយម្នាក់ៗ នាំគ្នានិយាយថា អាខ្មៅ...បៀតបៀនចូលទៅ បៀតបៀនអាក្រហមចូលទៅ គប្បីជ្រាបអត្ថថា **ញាំញី** អត្ថថា **បៀតបៀន** ដូចដែលពោលមកនេះ ។ សូម្បីក្នុងសេចក្ដី

ប្រទូសរ៉ាយ និងសេចក្តីវង្វេង ក៏មានទំនងនេះដូចគ្នា ។ វត្ថុ ៩ យ៉ាង គឺ អាកិញ្ចញ្ញាយតនៈ ១ មគ្គ និងផល ១ មួយៗ (រួមជា ៨ ) ឈ្មោះ **អាកិញ្ច-ញ្ញាចេតោវិមុត្តិ** ។ ក្នុង ៩ យ៉ាងនោះ អាកិញ្ចញ្ញាយតនៈ ឈ្មោះអាកិញ្ចញ្ញា ព្រោះមិនមានអារម្មណ៍ ដែលធ្វើឲ្យកើតសេចក្តីកង្វល់ សេចក្តីបៀតបៀន , សេចក្តីញាំញី , សេចក្តីរុកកួន , សេចក្តីរវល់ខ្វល់ខ្វាយលំបាក , ឬតិចតួច , អ្វីៗតិចតួចដល់ចិត្ត , មគ្គ ៤ និងផល ៤ ឈ្មោះអាកិញ្ចញ្ញា ព្រោះមិនមានសេចក្តីបៀតបៀន គឺ ព្រោះមិនមានកិលេសជាគ្រឿងញាំញី និងគ្រឿងធ្វើឲ្យកើតសេចក្តីកង្វល់ , សូម្បីព្រះនិព្វាន ក៏ជាអាកិញ្ចញ្ញា ។ តែមិនមានការរួចផុតនៃចិត្ត (ព្រោះចិត្តមិនមានក្នុងព្រះនិព្វាន ព្រះនិព្វានមិនមានចិត្ត) ព្រោះដូច្នោះទើបមិនចាត់ចូល ។ ក្នុងពាក្យថា **អ្នកមានអាយុ រាគៈនោះឯងជាគ្រឿងធ្វើនូវគ្រឿងសម្គាល់** ជាដើម សេចក្តីថា កាលរាគៈមិនទាន់កើតដរាបណា ដរាបនោះមិនមានអ្នកណាអាចដឹងបានថា ជាអរិយៈ ឬជាបុថុជ្ជន ។ កាលរាគៈកើតឡើង ក៏កើតឡើងដូចកំពុងធ្វើគ្រឿងសម្គាល់សម្រាប់ចាំបានថា "បុគ្គលនេះ ឈ្មោះថាអ្នកមានរាគៈ" ព្រោះដូច្នោះ លោកទើបពោលថា **ជាគ្រឿងធ្វើគ្រឿងសម្គាល់** ដូចកូនគោ ២ ក្បាលដែលដូចគ្នា របស់ត្រកូល ២ កាលមិនទាន់បានធ្វើគ្រឿងសម្គាល់ដល់កូនគោទាំង ២ នោះ ក៏រមែងមិនមានអ្នកណាដែលអាចដឹងបានថា

នេះជាកូនគោរបស់ត្រកូលឯណោះ នេះរបស់ត្រកូលឯណោះ តែកាលណាយក ដែកស្រួច មានលំពែងជាដើម មកធ្វើគ្រឿងសម្គាល់យ៉ាងណាមួយ ក៏មានអ្នកអាចដឹងបាន យ៉ាងណា ក៏យ៉ាងនោះដែរ ។ សូម្បីក្នុងសេចក្តីប្រទូសរ៉ាយ និងសេចក្តីវង្វេង ក៏មានទំនងនេះដូចគ្នា ។

វិបស្សនា ១ អរូប ៤ មគ្គ ៤ និងផល ៤ រួមជា ១៣ វត្ថុ (នេះ) ឈ្មោះថា **ការរួចផុតនៃចិត្តដែលមិនមានអ្វីជាគ្រឿងសម្គាល់** ក្នុងវត្ថុ ១៣ នោះ វិបស្សនា ឈ្មោះថា មិនមានអ្វីជាគ្រឿងសម្គាល់ ក៏ព្រោះដកគ្រឿងសម្គាល់ជាទៀង គ្រឿងសម្គាល់ជាសុខ គ្រឿងសម្គាល់ជាតួខ្លួនចេញបាន ។ អរូប ៤ ឈ្មោះថា មិនមានអ្វីជាគ្រឿងសម្គាល់ ព្រោះមិនមានរូបជាគ្រឿងសម្គាល់ ។ មគ្គផល ឈ្មោះថា មិនមានអ្វីជាគ្រឿងសម្គាល់ ក៏ព្រោះមិនមានកិលេសដែលជាគ្រឿងសម្គាល់ ។ ព្រះនិព្វាន ក៏មិនមានអ្វីជាគ្រឿងសម្គាល់ដូចគ្នា តែព្រះនិព្វាននោះ មិនមែនជាការរួចផុតនៃចិត្ត ព្រោះដូច្នោះ លោកទើបមិនបានចាត់ចូល ។ ហេតុអ្វីទើបមិនចាត់ចូល ការរួចផុតនៃចិត្ត ដែលជារបស់សូន្យទុកផង ការរួចផុតនៃចិត្តដែលជារបស់សូន្យនោះ ឈ្មោះថា មិនចូលទៅក្នុងកិលេសគ្រប់ប្រភេទឡើយ ព្រោះពាក្យ (បាលី) ជាដើមថា **សូន្យចាករាគៈ** ព្រោះដូច្នោះទើបមិនចាត់ចូលក្នុងផ្នែកណាមួយ ។ ពាក្យថា **មានអត្ថតែម្យ៉ាង** បានដល់ និង

ដោយអំណាចអារម្មណ៍ ក៏មានអត្ថជាតែមួយដូចគ្នា ។ ក៏ពាក្យទាំងអស់នេះ គឺ មិនមានប្រមាណ , ភាពជារបស់មិនមានគ្រឿងកង្វល់ , ភាពជារបស់សូន្យ , មិនមានអ្វីជាគ្រឿងសម្គាល់ ជាឈ្មោះរបស់ព្រះនិព្វាននោះឯង ។

ទើបជាការសរុបបានថា តាមសភាពបែបនេះ ការរួចផុតនៃចិត្តដែលមិនមានប្រមាណក្នុងទីដទៃ ភាពជារបស់មិនមានគ្រឿងកង្វល់ក្នុងទីដទៃ ការរួចផុតនៃចិត្ត ដែលមិនមានអ្វីជាគ្រឿងសម្គាល់ក្នុងទីដទៃ (ទាំងអស់នោះសុទ្ធតែ) មានអត្ថតែមួយដូចគ្នា , តាមសភាពបែបនេះ ផ្សេងគ្នាតែព្យញ្ជនៈ (ប៉ុណ្ណោះ) ។ ព្រះថេរៈបញ្ចប់ទេសនាតាមអនុសន្ធិ ដូចដែលបានសម្ដែងមក ដោយប្រការដូច្នេះ ឯង ។

" ចប់អដ្ឋកថា មហាវេទល្លសូត្រ ទី ៣ "

# អ ដ្ឋ ក ថា

## ចូឡវេទល្លសូត្រ ទី ៤

[១៤៥] ចូឡវេទល្លសូត្រ ឡើងដើមថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **វិសាខឧបាសក** បានដល់ ឧបាសកអ្នកមានឈ្មោះយ៉ាងនោះថា **វិសាខ** ។ ពាក្យថា **ទីណាព្រះនាងធម្មទិន្នា** គឺ ចូលទៅរកដល់កន្លែងដែលភិក្ខុនីឈ្មោះធម្មទិន្នានៅ ។

វិសាខៈនេះ គឺ អ្នកណាហ្ន៎

នាងធម្មទិន្នាជាអ្នកណា

ហេតុដូចម្តេច ទើបចូលទៅរក

កាលនាងធម្មទិន្នានៅជាគ្រហស្ថ វិសាខៈជាម្ចាស់របស់ផ្ទះ (ជាស្វាមី) កាលព្រះមានព្រះភាគអង្គនោះ បានត្រាស់ដឹង ព្រះសម្មាសម្ពោធិញ្ញាណហើយ ទ្រង់បន្ទិលចក្កព្រះធម៌ដ៏ប្រសើរ ទ្រង់បានណែនាំកុលបុត្រ មានយសជាដើម ស្តេចសម្រេចដល់តំបន់ឧរុវេលា ។ ក្នុងទីនោះ ទ្រង់បានណែនាំជដិលមួយពាន់នាក់ ហើយស្តេចពុទ្ធដំណើរទៅកាន់ក្រុងរាជគ្រឹះជាមួយពួកភិក្ខុដែលជាទីណា-

ស្រេពជាជដិលចាស់ ហើយទ្រង់សម្តែងធម៌ថ្វាយព្រះបាទពិម្ពិសារមហារាជ ដែលស្តេចដំណើរមកព្រមទាំងបរិស័ទមួយសែនពីរម៉ឺននាក់ ដើម្បីគាល់ព្រះពុទ្ធ ។ ក្នុងមួយសែនពីរម៉ឺននាក់ដែលមកព្រមជាមួយព្រះរាជា ក្នុងគ្រានោះ មួយម៉ឺននាក់ប្រកាសខ្លួនជាឧបាសក ។ មួយទៀត មួយសែនមួយម៉ឺននាក់ព្រមទាំងព្រះបាទពិម្ពិសារតាំងនៅក្នុងសោតាបត្តិផល ។ ឧបាសកនេះ ជាមនុស្សម្នាក់ក្នុងចំនួននោះ កាលតាំងនៅក្នុងសោតាបត្តិផល ក្នុងការគាល់គ្រាដំបូងនុ៎ះឯង ព្រមជាមួយអ្នកទាំងនោះហើយ ក្នុងថ្ងៃមួយក៏បានស្តាប់ធម៌សម្រេចសកទាគាមិផល តពីនោះ ក្នុងថ្ងៃខាងក្រោយ ថ្ងៃមួយបានស្តាប់ធម៌ ទើបបានតាំងនៅក្នុងអនាគាមិផល កាលបានជាព្រះអនាគាមីហើយ មកកាន់ផ្ទះ មិនបានមកដូចថ្ងៃដទៃ មើលនោះមើលនេះ សើចញញឹមរីករាយបណ្តើរ ដើរចូលមក , ជាអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ដើរចូលទៅ ។ នាងធម្មទិន្នាបើកបង្អួចមើលទៅត្រង់ថ្នល់ ឃើញហេតុការណ៍ក្នុងការមករបស់គេ ហើយគិតថា នេះយ៉ាងណាហ្ន៎ កាលឈរត្រង់ក្បាលជណ្តើរបានធ្វើការទទួល គេក៏គៀសដៃចេញ ។ ឧបាសកត្រឡប់វាសដៃរបស់ខ្លួនចេញ ។ នាងគិតថា យើងនឹងដឹងក្នុងវេលាទទួលទានអាហារពេលព្រឹក ពីមុនមក ឧបាសករមែងទទួលទានជាមួយគ្នានឹងនាង តែថ្ងៃនេះ មិនព្រមមើលនាងធ្វើហាក់បីដូចជាយោគាវចរភិក្ខុ ទទួលទានម្នាក់ប៉ុណ្ណោះ ។ នាងគិតថា វេលា

ដេកយើងនឹងដឹង ឧបាសកមិនព្រមចូលបន្ទប់សរីនោះ , បង្គាប់ឲ្យរៀបបន្ទប់ដទៃ ឲ្យតាំងគ្រែតូចដែលសមគួរ ហើយដេក ។ ឧបាសិកាមកគិតថា អ្វីហ្ន៎ គេមានសេចក្ដីប្រាថ្នាខាងក្រៅ ឬត្រូវអ្នកពេញចិត្តញុះញង់អ្នកណាម្នាក់ឲ្យបែក ? ឬថា យើងនេះឯងមានកំហុសអ្វីៗ ហើយក៏តូចចិត្តយ៉ាងខ្លាំង សម្រេចចិត្តថា រហូតអស់វេលាមួយថ្ងៃ ពីរថ្ងៃ ដែលគេនៅនេះឯងនឹងអាចដឹងបាន ហើយទើបទៅកាន់ទីទំនុកបម្រុងគេ សំពះហើយក៏ឈរនៅ ។ ឧបាសកសួរថា ធម្មទិន្នា ហេតុដូចម្ដេច ទើបមកខុសវេលាយ៉ាងនេះ ។

ធម្មទិន្នា. ចា៎ អយ្យបុត្រ. ខ្ញុំមក , លោកមិនដូចមនុស្សមុនទេ , សូមសួរបន្តិចចុះថា លោកមានសេចក្ដីប្រាថ្នាខាងក្រៅឬ ?

វិសាខ. មិនមានទេ ធម្មទិន្នា

ធម្មទិន្នា. មានអ្នកណាដទៃជាអ្នកញុះញង់មែនឬ

វិសាខ. ដូច្នេះ ក៏មិនមែន

ធម្មទិន្នា. បើដូច្នោះ ខ្ញុំគង់នឹងមានកំហុសណាៗ ដែរឬ ?

វិសាខ. សូម្បីនាងខ្លួនឯង ក៏មិនមានកំហុស

ធម្មទិន្នា. ចុះហេតុដូចម្ដេច លោកទើបមិនធ្វើសូម្បីត្រឹមតែការនិយាយចរចាប្រាស្រ័យតាមប្រក្រតីនឹងខ្ញុំហ្ន៎ គេគិតថា ឈ្មោះថា លោកុត្តរធម៌នេះជា

ការៈធ្ងន់ មិនគប្បីប្រាប់ តែបើខ្លួនមិនប្រាប់ , ធម្មទិន្នានេះនឹងគប្បីបែកទ្រូង ស្លាប់ក្នុងទីនេះឯង ដើម្បីអនុគ្រោះនាង ទើបប្រាប់ថា ធម្មទិន្នា ខ្ញុំស្តាប់ធម៌-ទេសនារបស់ព្រះសាស្តា ហើយបានសម្រេចលោកុត្តរធម៌ , អ្នកបានសម្រេចលោកុត្តរធម៌នោះហើយ ការធ្វើបែបលោកិយៈយ៉ាងនេះ រមែងមិនប្រព្រឹត្តទៅ , បើនាងត្រូវការ , ទ្រព្យចំណែករបស់នាង ៤០០ លាន ចំណែករបស់ខ្ញុំ ៤០០ លានទៀត រួមទាំងអស់ក៏មានទ្រព្យនៅ ៨០០ លាន , នាងជាធំក្នុងទីនេះហើយ ចូរតាំងនៅក្នុងតំណែងជាម្តាយ ឬតំណែងប្អូនស្រីរបស់ខ្ញុំក៏បាន ខ្ញុំនឹងសូមចិញ្ចឹមជីវិតដោយត្រឹមតែដុំបាយដែលនាងឲ្យ , បើនាងមិនធ្វើដូចដែលពោលមកនេះក៏ចូរយកកោគៈទាំងនេះទៅផ្ទះត្រកូលក៏បាន , ហើយបើនាងមានសេចក្តីត្រូវការបុរសដទៃ ខ្ញុំក៏នឹងតាំងនាងទុកក្នុងតំណែងប្អូនស្រី ឬតំណែងកូនស្រី ហើយចិញ្ចឹមរក្សា ។

នាងគិតថា មនុស្សប្រុសប្រក្រតី នឹងមិនមានអ្នកណានិយាយយ៉ាងនេះ , គេគង់ចាក់ធ្លុះលោកុត្តរធម៌ដោយពិត ក៏មនុស្សប្រុសប៉ុណ្ណោះឬ ដែលគប្បីសម្រេចធម៌នោះបាន ឬសូម្បីជាមនុស្សស្រី ក៏អាចសម្រេចបាន ទើបនិយាយនឹងវិសាខៈថា ធម៌នោះ មនុស្សប្រុសប៉ុណ្ណោះឬ ដែលគប្បីបាន ឬសូម្បីមនុស្សស្រី ក៏អាចបានផង ។

វិសាខ. និយាយអ្វីធម្មទិន្នា បុគ្គលដែលជាអ្នកបដិបត្តិនោះ រមែងជាទាយាទរបស់ធម៌នោះ អ្នកដែលមានឧបនិស្ស័យក៏រមែងបានទទួលធម៌នោះ

ធម្មទិន្នា. បើដូច្នោះ សូមលោកព្រមឲ្យខ្ញុំបួសផង ។

វិសាខ. ល្អហើយនាងជាទីស្រឡាញ់ ខ្ញុំក៏ចង់នឹងណែនាំក្នុងផ្លូវនេះដូចគ្នាតែមិនទាន់ដឹងចិត្តនាង ទើបមិននិយាយ ហើយក៏ទៅគាល់ព្រះបាទពិម្ពិសារក្នុងគ្រានោះឯង ថ្វាយបង្គំហើយ ក៏បានឈរ ព្រះរាជាត្រាស់សួរថា គហបតី ហេតុដូចម្តេច ទើបបានមកខុសវេលា ដូច្នេះ ។

វិសាខ. មហាបពិត្រ នាងធម្មទិន្នានិយាយថា ខ្ញុំម្ចាស់នឹងបួស ។

ព្រះរាជា. នាងសមគួរនឹងបានអ្វីហ្ន៎ ។

វិសាខ. មិនមានអ្វីដទៃ , បានអង្រឹងមាស និងទទួលបង្គាប់ឲ្យតាក់តែងព្រះនគរក៏សមគួរ ព្រះអង្គ ។ ព្រះរាជាប្រទានអង្រឹងមាស ហើយត្រាស់បង្គាប់ឲ្យតាក់តែងព្រះនគរ ។

វិសាខ: ឲ្យនាងធម្មទិន្នាងូតទឹកក្រអូប ឲ្យប្រដាប់ដោយគ្រឿងស្អិតស្អាងគ្រប់យ៉ាង ឲ្យអង្គុយលើអង្រឹងមាស ហែហមដោយពួកញាតិ បូជាដោយផ្កាឈើក្រអូបជាដើម បណ្តើរដូចធ្វើដល់ពួកអ្នកក្រុង ទៅកាន់សម្នាក់ភិក្ខុនី ហើយប្រាប់ថា សូមឲ្យនាងធម្មទិន្នាបួសចុះ ម៉ែម្ចាស់ ពួកភិក្ខុនីនិយាយថា គហបតី

ចំពោះសេចក្តីខុសមួយ ឬពីរយ៉ាង ក៏គួរនឹងអត់ធន់បាន ។

វិសាខៈទើបទូលថា មិនមានសេចក្តីខុសអ្វីទេ ម៉ែម្ចាស់ នាងបួសដោយសទ្ធា លំដាប់នោះ ភិក្ខុនីមួយរូប ទើបប្រាប់កម្មដ្ឋាន មានស្បែកជាតម្រប់ប្រាំឲ្យកោរសក់ហើយឲ្យបួស ។ វិសាខៈនិយាយថា ម៉ែម្ចាស់ ព្រះមានព្រះភាគត្រាស់ព្រះធម៌ទុកល្អហើយ , ព្រះនាងចូរត្រេកអរចុះ សំពះហើយចៀសទៅ ។

តាំងពីថ្ងៃដែលនាងបួសហើយ លាភសក្ការៈក៏កើតឡើង ព្រោះហេតុនោះ នាងទើបរវល់ខ្វល់ខ្វាយជាបរកឱកាសធ្វើសមណធម៌មិនបាន ។ ពេលនោះ ពួកព្រះថេរីដែលជាអាចារ្យ និងឧបជ្ឈាយ៍ ទើបនាំនាងទៅស្រុកជនបទហើយក៏ឲ្យរៀនកម្មដ្ឋានតាមពេញចិត្ត ក្នុងអារម្មណ៍ ៣៨ យ៉ាង ផ្តើមធ្វើសមណ-ធម៌ ចំពោះនាងមិនលំបាកយូរ ព្រោះជាអ្នកមានសម្បូរណ៍អភិនិហារ ។

សេចក្តីសង្ខេបមកថា ក្នុងទីបំផុតនៃសែនកប្បពីកទូកប្បនេះទៅ ព្រះសាស្តាទ្រង់ព្រះនាមថា **បទុមុត្តរៈ** ទ្រង់ឧប្បត្តិក្នុងលោក ។ គ្រានោះ នាងធម្ម-ទិន្នានេះ ជាស្រីបម្រើក្នុងត្រកូលមួយ លក់សក់របស់ខ្លួនដើម្បីថ្វាយទានចំពោះព្រះអគ្គសាវក ឈ្មោះសុជាតត្ថេរ ហើយបានធ្វើសេចក្តីប្រាថ្នាទុក ។ ព្រោះដល់ព្រមដោយអភិនិហារនៃសេចក្តីប្រាថ្នានោះ នាងទើបមិនទៀយហត់ច្រើនពីរបីថ្ងៃប៉ុណ្ណោះឯង ក៏បានសម្រេចជាព្រះអរហន្ត ហើយបានគិតថា យើងបាន

បួសក្នុងសាសនា ព្រោះប្រយោជន៍ណា យើងដល់ទីបំផុតនៃប្រយោជន៍នោះហើយ , យើងនៅជមបទដើម្បីប្រយោជន៍អ្វី ? ពួកញាតិយើងនឹងធ្វើបុណ្យ , ដល់ភិក្ខុនីសង្ឃ ក៏នឹងមិនលំបាកដោយបច្ច័យ យើងនឹងទៅក្រុងរាជគ្រឹះ ហើយក៏បានពួកភិក្ខុនីសង្ឃ ទៅក្រុងរាជគ្រឹះនុ៎ះឯង ។

វិសាខៈបានស្តាប់ថា គេថា នាងធម្មទិន្នាមក ទើបគិតថា នាងបួសហើយទៅជនបទមិនទាន់បានយូរឡើយ ក៏ត្រឡប់មកអស់កាលមិនយូរនេះឯងនឹងមានហេតុអ្វីហ្ន៎ ? ហើយក៏បានទៅសម្នាក់នាងភិក្ខុនី ដោយការទៅជាលើកទីពីរ ។ ព្រោះហេតុនោះ ព្រះអានន្ទទើបពោលថា គ្រានោះឯងវិសាខឧបាសកបានចូលទៅរកនាងធម្មទិន្នាដល់ទីនៅ ដូច្នេះ ។

[១៤៦] ពាក្យថា បានពោលពាក្យនេះហើយ គឺ បានពោលពាក្យជាដើមថា **កាយរបស់ខ្លួន** នេះ ។ ហេតុដូចម្តេចទើបបានពោល បានឮមកថា គេមានគំនិតយ៉ាងនេះថា ការនឹងសួរយ៉ាងនេះថា ម៉ែម្ចាស់ នៅត្រេកអរឬ ឬមិនត្រេកអរ មិនមែននាទីរបស់បណ្ឌិត យើងនឹងបង្អោនចូលទៅក្នុងឧបាទានក្ខន្ធ ៥ ហើយសួរបញ្ហា , ដោយការដោះស្រាយបញ្ហានុ៎ះឯង យើងក៏នឹងជ្រាបថានាងមានសេចក្តីត្រេកអរ ឬមិនត្រេកអរ , ដូច្នោះ ទើបបានពោល ។ ពេលនាងធម្មទិន្នាបានស្តាប់ពាក្យនោះ មិនពោលថា អាវុសោវិសាខៈ ! អាត្មាកាត

ទើបតែបួសមកមិនយូរ នឹងជ្រាបកាយខ្លួន ឬកាយអ្នកដទៃអំពីណា ឬថា លោកចូរទៅរក ហើយសួរព្រះថេរីរូបដទៃចុះ កាលតាំងនៅក្នុងវិស័យនៃបញ្ញាគ្រឿងបែកធ្លាយដោះស្រាយបញ្ហា ដូចទទួលរបស់ដែលគេផ្ញើ , ដូចស្រាយកំនួចអន្ទាក់ម្ខាង , ដូចត្រាយផ្លូវដំរីក្នុងទីស្តុក ដូចជម្រះដោយចុងដាវ ទើបពោលថា អាវុសោវិសាខ ឧបាទានក្ខន្ធ ៥ ទាំងនេះឯង ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ **ពាក្យថា ៥ ជាពាក្យកំណត់រាប់** ពាក្យថា **ឧបាទានក្ខន្ធ** បានដល់ គប្បីធ្វើឲ្យអដ្ឋកថាឧបាទានក្ខន្ធពិស្តារហើយពោលក្នុងទីនេះ ដោយន័យជាដើមយ៉ាងនេះថា ខន្ធដែលមានឧបាទានជាបច្ច័យ ក៏ឯអដ្ឋកថានៃឧបាទានក្ខន្ធនោះ លោកពង្រីកទុកយ៉ាងពិស្តារក្នុងវិសុទ្ធិមគ្គនុ៎ះឯង ព្រោះដូច្នោះ គប្បីជ្រាបដោយន័យដែលលោកធ្វើឲ្យពិស្តារហើយ ក្នុងវិសុទ្ធិមគ្គនោះចុះ ។ ពាក្យដែលនឹងគប្បីពោលសូម្បីក្នុង **សក្កាយសមុទយ** ជាដើមនោះ ក៏បានពោលទុកហើយក្នុងទីនោះៗ ក្នុងខាងក្រោយដូចគ្នា ។ កាលវិសាខៈបានស្តាប់ការដោះស្រាយសច្ចៈបួននេះហើយ ក៏ជ្រាបថា ព្រះថេរីត្រេកអរហើយ ព្រោះថា អ្នកដែលអផ្សុកមិនត្រេកអរក្នុងព្រះពុទ្ធសាសនានោះ មិនអាចនឹងដោះស្រាយបញ្ហាដែលសួរហើយសួរទៀតបាន ដូចយកជន្ទាស មកដកសក់ស្កូវម្តងមួយសរសៃៗ ដូចរោមទ្រាយចេញចាកជើងភ្នំសិនេរុ ។ ក៏ព្រោះសច្ចៈបួនយ៉ាងនេះ

ប្រាកដហើយក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទ និងព្រះអាទិត្យប្រាកដក្នុងលោក ដោយសេចក្ដីថា ព្រះមានព្រះភាគក្ដី ព្រះមហាថេរៈទាំងឡាយក្ដី ដែលនៅត្រង់កណ្ដាលបរិស័ទ រមែងប្រកាសតែសច្ចៈប៉ុណ្ណោះ , ភិក្ខុសង្ឃក៏ឲ្យពួកកុលបុត្ររៀនបញ្ហាថា អ្វីឈ្មោះថា បួន ? អរិយសច្ចបួន តាំងពីថ្ងៃដែលបួស ។ វិសាខៈគិតថា នាងធម្មទិន្នានេះ ក៏ជាបណ្ឌិតដែលឆ្លាត តាំងនៅក្នុងភាពជាអ្នកឆ្លាតក្នុងឧបាយ បាននាំយកន័យមកហើយ ក៏អាចពោលសូម្បីដោយន័យដែលបានស្ដាប់មកហើយ ដូច្នោះអ្នកណាៗ ទើបមិនអាចនឹងដឹងសេចក្ដី ចាក់ធ្លុះសច្ចៈរបស់នាង ដោយហេតុមានប្រមាណប៉ុណ្ណេះ , ទាំងយើងក៏អាចដឹងបានដោយការដោះស្រាយបញ្ហា ជាប់ទាក់ទងនឹងការបែកសច្ចៈ កាលនឹងវិលត្រឡប់ទៅកាន់សច្ចៈទាំងពីរ ដែលពោលទុកក្នុងខាងក្រោយធ្វើឲ្យកំបាំង ហើយសួរថា ខ្ញុំនឹងសូមសួរបញ្ហាដែលមានកំនួច ទើបពោលពាក្យថា **ម៉ែម្ចាស់ ! ឧបាទាននោះឯង** ដូច្នេះជាដើម ។

ក្នុងការដោះស្រាយបញ្ហានោះថា អាវុសោវិសាខៈ ! នោះឯង មិនមែនឧបាទានឡើយ មានពាក្យអធិប្បាយថា នោះមិនមែនជាឧបាទានឡើយ តែជាខន្ធ ៥ ដទៃផ្សេង ព្រោះជាសភាពដែលជាឯកទេសចាកកងសន្ធាររបស់ឧបាទាននិងឧបាទាន ក៏មិនមែនក្រៅទៅពីឧបាទានក្ខន្ធទាំង ៥ ។ ព្រោះបើវត្ថុនោះឯង

គប្បីជាឧបាទានសោត សភាពមានរូបជាដើម ក៏គប្បីជាឧបាទានផងដែរ ។ បើឧបាទាន គប្បីជាវត្ថុខាងក្រៅ (ពីរូបជាដើម) សោត ក៏នឹងជាខន្ធវិមុត្តិ (រួចចាកខន្ធ) ដូចអនុស័យ ដូចបញ្ញត្តិ និងដូចនិព្វាន ដែលមិនប្រកបជាមួយចិត្តក្នុងសម័យដទៃ , ឬក៏នឹងមិនត្រូវបញ្ញត្តិខន្ធទី ៦ បន្ថែមទៀត , ព្រោះដូច្នោះនាងធម្មទិន្នា ទើបដោះស្រាយយ៉ាងនេះ ។

កាលបានស្តាប់ពាក្យព្យាករណ៍របស់នាង , វិសាខៈគិតថា នាងនេះបានសម្រេចការចាក់ធ្លុះហើយ ហើយគិតថា អ្នកដែលមិនមែនជាវិណាស្រេតមិនឃើញ មិនជាអ្នកដឹង នឹងធ្វើឲ្យពិស្តារ ប្រៀបដូចអ្នកកាន់ប្រទីបមួយពាន់ដួងឲ្យញ៉ែរ នឹងមិនអាចដោះស្រាយបញ្ហាដ៏អាថ៌កំបាំងទុកដោយត្រៃលក្ខណ៍ នាំមកជ្រាលជ្រៅបែបនេះបានឡើយ , តែនាងធម្មទិន្នានេះ ដល់ទីបំផុត (គឺព្រះនិព្វាន) បានទីពឹងក្នុងសាសនា សម្រេចបញ្ញាបែកធ្លាយ ដល់សេចក្តីក្លាហានកម្ចាត់កត ជាវិណាស្រេតដ៏ធំក្រៃលែង អាចដោះស្រាយបញ្ហាដែលសាកសួរ ទើបគិតថា ឥឡូវនេះ យើងនឹងសួរបញ្ហាដែលជ្រាលជ្រៅ និងអាថ៌កំបាំងចំពោះនាងទៀត កាលនឹងសួរបញ្ហានោះ ទើបពោលពាក្យថា **ដូចម្តេចហ្ន៎ ម៉ែម្ចាស់** ដូច្នេះជាដើម ។

[១៨៧] ក្នុងការដោះស្រាយបញ្ហានោះ ពាក្យជាដើមថា **អ្នកមិនបាន**

ស្តាប់ហើយ លោកបានឲ្យពិស្តារហើយក្នុងមូលបរិយាយសូត្រនុ៎ះឯង ។ ពាក្យថា រមែងពិចារណាឃើញរូប ដោយសេចក្តីប្រកាន់ថាជាខ្លួន គឺ បុគ្គលខ្លះក្នុងលោកនេះ រមែងពិចារណាឃើញរូបដោយសេចក្តីប្រកាន់ថាជាខ្លួន រមែងពិចារណាឃើញរូប និងខ្លួន ជាវត្ថុមិនមែនពីរថា រូបយ៉ាងណា ខ្លួនក៏ដូច្នោះ ខ្លួនយ៉ាងណា រូបក៏យ៉ាងនោះ ។ ប្រៀបដូចកាលចង្កៀងប្រេងកំពុងឆេះ អណ្តាតយ៉ាងណា ពន្លឺក៏យ៉ាងនោះ ពន្លឺយ៉ាងណា អណ្តាតក៏យ៉ាងនោះ សូម្បីយ៉ាងណា , យ៉ាងនោះនុ៎ះឯង បុគ្គលខ្លះក្នុងលោកនេះ រមែងពិចារណាឃើញរូបថាជាខ្លួន ពិចារណាឃើញ... មិនមែនពីរយ៉ាង យ៉ាងនេះ ដូច្នោះ ទើបឈ្មោះថារមែងឃើញដោយវិបស្សនាក្នុងទិដ្ឋិថា រូបជាខ្លួន យ៉ាងនេះ ។ ឬរមែងពិចារណាឃើញថា ខ្លួនមានរូប ទើបកាន់យករូបថា ជារបស់ខ្លួន ហើយរមែងពិចារណាឃើញខ្លួនមានរូប ដូចឃើញដើមឈើមានម្លប់ ឬឃើញថា រូបក្នុងខ្លួន ទើបកាន់យកអរូបនុ៎ះឯងថាជាខ្លួន ទើបឈ្មោះថា រមែងពិចារណាឃើញរូបក្នុងខ្លួនដូចឃើញក្លិនក្នុងផ្កាឈើ ឬឃើញខ្លួននោះក្នុងរូប ដូចឃើញកែវមណីក្នុងជបសូម្បីក្នុងការពិចារណាថា វេទនាដោយសេចក្តីជាខ្លួនជាដើម ក៏មានទំនងដូចគ្នានោះឯង ក្នុងពាក្យទាំងនោះ ពាក្យថា រមែងពិចារណាឃើញរូបដោយសេចក្តីថាជាខ្លួន លោកពោលដល់រូបសុទ្ធៗ ប៉ុណ្ណោះថា ជាខ្លួន ។ លោកពោលដល់

អរូបថាជាខ្លួនក្នុងទី ៧ ទាំងនេះ គឺ រមែងពិចារណាឃើញខ្លួនមានរូប , ឬ រូបមានក្នុងខ្លួន , ឬខ្លួនមានក្នុងរូប , វេទនាដោយសេចក្តីថាជាខ្លួន , សញ្ញា សង្ខារ វិញ្ញាណដោយសេចក្តីថាជាខ្លួន លោកពោលដល់រូប និងអរូបដែល លាយគ្នាថាជាខ្លួនក្នុងទី ១២ ដោយអំណាចនៃខន្ធទាំងបី ក្នុងចំនួនខន្ធទាំងបួន យ៉ាងនេះ គឺ ខ្លួនមានវេទនា វេទនាមានក្នុងខ្លួន ខ្លួនមានក្នុងវេទនា ដូច្នេះ ។

ក្នុងពាក្យថា រមែងពិចារណាឃើញរូបដោយសេចក្តីថាជាខ្លួន រមែង ពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសេចក្តីថាជាខ្លួននោះ លោកសម្តែងសេចក្តីឲ្យឃើញថា ដាច់សូន្យក្នុងឋានៈ ៥ , ក្នុងន័យដ៏សេស លោកសម្តែងសេចក្តីឃើញថា ទៀង ។ ដោយប្រការដូច្នេះ ក្នុងទីនេះទើប មានភវទិដ្ឋិ ( សេចក្តីឃើញថាមាន ) ១៥ យ៉ាង , វិភវទិដ្ឋិ (សេចក្តីឃើញ ថាមិនមាន) ៥ យ៉ាង ។ ក្នុងបទថា មិនពិចារណាឃើញរូបដោយសេចក្តីថា ជាខ្លួននេះ , បានដល់ រមែងពិចារណាឃើញថា មិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយអាការគ្រប់យ៉ាង គឺ រមែងមិនពិចារណាឃើញ ៥ យ៉ាងទាំងនេះ ដោយ បែបយ៉ាងណាមួយ ដែលបានដល់ មិនពិចារណាឃើញរូបថាជាខ្លួន តែពិចា- រណាឃើញថា មិនទៀង ជាទុក្ខ មិនមែនខ្លួន មិនពិចារណាឃើញខ្លួនមានរូប ។ល។ មិនពិចារណាឃើញខ្លួនក្នុងវិញ្ញាណ ដូច្នេះ ។ កាលព្រះថេរី ដោះស្រាយ

បញ្ហាជំបូងយ៉ាងនេះថា អាវុសោវិសាខ ! សេចក្តីឃើញថា កាយរបស់ខ្លួន រមែងមានដោយអាការយ៉ាងនេះឯង ដូច្នេះ ដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណេះ , ពាក្យថា **ដោយហេតុត្រឹមតែប៉ុណ្ណេះ** ការទៅក៏មាន ការមកក៏មាន ការទៅ និងការមកក៏មាន វដ្ដៈ ក៏រមែងវិលទៅ ក៏ជាការដែលនាងបានធ្វើវដ្ដៈឲ្យដល់ទីបំផុតហើយសម្ដែងទុក ។ កាលដោះស្រាយបញ្ហាចុងក្រោយថា ពោលថា អាវុសោវិសាខៈ ការឃើញថា កាយខ្លួន រមែងមិនមានដោយអាការយ៉ាងនេះឯង ដូច្នេះ , ពាក្យថា **ដោយហេតុត្រឹមតែប៉ុណ្ណេះ ការទៅក៏មិនមាន ការមកក៏មិនមាន** ការទៅ និងការមកក៏មិនមាន វដ្ដៈក៏ឈប់វិល ក៏ជាការដែលនាងបានធ្វើវិវដ្ដៈឲ្យដល់ទីបំផុត សម្ដែងទុកហើយ ។

[១៤៨] បញ្ហាថា *ម៉ែម្ចាស់ ក៏ផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្ដេច ?* ជាការដែលព្រះថេរីគប្បីសួរត្រឡប់ហើយ ទើបឆ្លើយថា ឧបាសកលោកសួរដល់ផ្លូវខាងក្រោមហើយ ហេតុដូចម្ដេចក្នុងទីនេះ ទើបមកសួរដល់ផ្លូវនេះទៀត ក៏ព្រះថេរីនោះ កំណត់សេចក្ដីបំណងរបស់ឧបាសកនោះបាន ក៏ព្រោះភាពដែលខ្លួនឆ្លាតជាបណ្ឌិត ។ ព្រះនាងគិតថា ឧបាសកនេះ គង់នឹងសួរដល់ផ្លូវជាន់ក្រោមដោយអំណាចបដិបត្តិ តែក្នុងទីនេះ គង់ចង់នឹងសួរដល់ផ្លូវនោះនៃសង្ខតៈ (ត្រូវតាក់តែង) អសង្ខតៈ (មិនត្រូវតាក់តែង) លោកិយៈ (បែប

លោក) លោកុត្តរៈ (ផុតចាកលោក , ឆ្លងចាកលោក) ដែលលោករួមចូលទុក (សង្គ្រោះ) និងមិនរួមចូលទុក (មិនសង្គ្រោះ) ដូច្នោះ ឧបាសកសួរប្រការណាៗច្រើន ក៏ដោះស្រាយប្រការនោះៗ ដោយមិនសួរត្រឡប់ឡើយ ។

ក្នុងពាក្យទាំងនោះ ពាក្យថា "**សង្ខតៈ**" សេចក្តីថា ត្រូវគិត ត្រូវត្រិះរិះ ត្រូវសញ្ចឹងគិត ត្រូវរួបរួមទុក ត្រូវឲ្យកើត ដែលអ្នកចូលដល់ គប្បីចូលដល់ ។ ក្នុងពាក្យថា **ក៏អាវុសោវិសាខៈ ផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរ លោកសង្គ្រោះចូលទុកដោយខន្ធ ៣** នេះ មានពាក្យអធិប្បាយថា ព្រោះផ្លូវមានប្រទេស ខន្ធទាំង ៣ មិនមានប្រទេស ដូច្នោះ លោកទើបយកផ្លូវនេះមករួមចូលដោយខន្ធ ៣ ដែលមិនមានប្រទេស ដូចយកក្រុងមករួមចូលនឹងរាជ្យ ព្រោះសេចក្តីដែលផ្លូវមានប្រទេស ។ ក្នុងអង្គមគ្គពួកនោះ អង្គមគ្គ ៣ មានសម្មាវាចា ជាដើម ជាសីល ដូច្នោះ ទើបលើកយកអង្គមគ្គទាំងនោះមករួមចូលនឹងកងសីល ព្រោះមានជាតិស្មើគ្នា ។ សូម្បីក្នុងបាលីលោកលើកយកមកសម្តែង ធ្វើដូចជាសត្តមីវិភត្តិថា **ក្នុងកងសីល** ដូច្នេះក៏ពិត តែក៏គប្បីជ្រាបសេចក្តីដោយអំណាចតតិយាវិភត្តិ ។ ចំណែកសមាធិ ក្នុងអង្គមគ្គ ៣ ទៀត មានសម្មាវាយាមៈ ជាដើម ដោយធម្មតារបស់ខ្លួនហើយ រមែងមិនអាចនឹងតម្កល់មាំបាន ព្រោះជាភាវៈដែលមានអារម្មណ៍តែមួយ តែកាលសេចក្តីព្យាយាម កំពុងញ៉ាំងកិច្ចឲ្យសម្រេច

ការលើកក៏កំពុងធ្វើកិច្ចឲ្យសម្រេច , សមាធិក៏ក្លាយជាធម្មជាតិដែលបានឧបការៈ ទើបនឹងអាចឲ្យតម្កល់មាំបាន ។

ក្នុងរឿងអង្គមគ្គនោះ មានពាក្យប្រៀបធៀបដូចតទៅនេះ ៖

ដូចក្នុងមិត្តបីនាក់ ដែលបបួលគ្នាចូលទៅកាន់ឧទ្យានដោយតាំងចិត្តថា ពួកយើងនឹងលេងនក្ខត្តឫក្ស (ការងារប្រចាំឆ្នាំ) ម្នាក់ជួបដើមចម្បាមានផ្ការីកល្អ លើកដៃឡើងទៅក៏មិនអាចបេះបាន ពេលនោះ អ្នកទីពីរទើបឱនខ្នងឲ្យគេ សូម្បីគេបានឈរលើខ្នងរបស់អ្នកទីពីរនោះ ក៏នៅតែបេះមិនបាន , ពេលនោះ ម្នាក់ទៀត ក៏ហុចចង្កួយស្មាឲ្យគេ ។ កាលគេបានឈរលើខ្នងរបស់ម្នាក់ហើយ តោងចង្កួយស្មារបស់ម្នាក់ទៀត ទើបបេះយកផ្កាឈើមកប្រដាប់តាមពេញចិត្ត ហើយលេងនក្ខត្តឫក្ស យ៉ាងណា , គប្បីឃើញពាក្យដែលនាំមកប្រៀបនេះ ដូច្នោះ គឺ ធម៌ទាំងបី មានសេចក្តីព្យាយាមប្រពៃជាដើម ដែលកើតរួមគ្នា ដូចមិត្តបីនាក់ ដែលចូលសួនជាមួយគ្នា , អារម្មណ៍ដូចដើមចម្បាមានផ្ការីកស្គុះស្គាយ សមាធិ មិនអាចនឹងដល់ភាវៈដែលមានអារម្មណ៍តែមួយដោយធម្មតារបស់ខ្លួន ដូចអ្នកដែលបានលើកដៃឡើង ហើយក៏មិនទាន់អាចបេះផ្កាបាន , សេចក្តីព្យាយាមប្រពៃ ដូចមិត្តដែលបន្អោនខ្នងឲ្យ , ការលើកប្រពៃ ដូចមិត្តដែលឈរឲ្យចាប់ចង្កួយស្មា , សមាធិ កាលវីរិយៈកំពុងធ្វើនាទីផ្គងឲ្យសម្រេច (និង) សតិ

ក៏កំពុងធ្វើនាទីស្ទាបអង្អែលឲ្យសម្រេចហើយយ៉ាងនេះ , បានឧបការៈហើយ ក៏រមែងអាចសម្រេចបាននូវការៈដែលមានអារម្មណ៍តែមួយ ដូចមិត្តម្នាក់ទៀត ដែលឈរលើខ្នងរបស់មិត្តម្នាក់ ក្នុងបីនាក់នោះ និងចាប់ចង្កេះស្មារបស់មិត្តម្នាក់ទៀត ទើបអាចបេះផ្កាឈើបានតាមពេញចិត្ត យ៉ាងណា ក៏យ៉ាងនោះ ។ ព្រោះដូច្នោះ លោកទើបយកសមាធិមករួមចូលនឹងកងសមាធិ តាមកំណើតរបស់ខ្លួន ។ ចំណែកសេចក្ដីព្យាយាមប្រពៃ និងសេចក្ដីរលឹកប្រពៃ លោកក៏យកមករួមចូលនឹងកិរិយា ។

សូម្បីបញ្ញាក្នុងសេចក្ដីឃើញប្រពៃ និងសេចក្ដីត្រិះរិះប្រពៃ ក៏មិនអាចកាត់ក្ដីអារម្មណ៍ថា មិនទៀង ជាទុក្ខ មិនមែនខ្លួន តាមសភាពខ្លួនឯងបាន ។ តែកាលវិតក្កៈ ត្រិះរិះរឿយៗ លើកឡើងបញ្ជូនឲ្យ ក៏អាច យ៉ាងណា ? ដូចសេចក្ដីថា ហិរញ្ញិក យកកហាបណៈមកដាក់លើដៃ សូម្បីចង់ពិនិត្យមើលគ្រប់ចំណែក ក៏មិនអាចនឹងត្រឡប់ដោយភ្នែកបានឡើយ ក៏កាលប្រើម្រាមដៃត្រឡប់ហើយ ទើបនឹងអាចពិនិត្យមើលបានគ្រប់ផ្នែក យ៉ាងណា , បញ្ញាក៏យ៉ាងនោះដែរ មិនអាចកំណត់អារម្មណ៍ដោយអំណាចនៃភាពមិនទៀងជាដើម តែឯកឯងរបស់ខ្លួនបាន តែនឹងអាចកំណត់អារម្មណ៍ ដែលវិតក្កមានការលើកឡើងជាលក្ខណៈ មានការសម្លឹង និងប្រតចំពោះអារម្មណ៍ជាកិច្ច ដូចកំពុងចាប់កាន់

និងកំពុងចាប់ត្រឡប់ហើយបញ្ជូនមកឲ្យនោះឯង ព្រោះដូច្នោះ លោកទើបចាត់យកតែសម្មាទិដ្ឋិប៉ុណ្ណោះ មករួមទុកនឹងកងបញ្ញា ព្រោះមានកំណើតស្មើគ្នាសូម្បីក្នុងទីនេះ ។ ចំណែកសម្មាសង្កប្បៈ ក៏ត្រូវយកមករួមចូល ព្រោះការធ្វើ ។ មគ្គរមែងដល់ការរួមចូលជាមួយរបស់ទាំងបីនេះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ព្រះនាងធម្មទិន្នាទើបបានពោលថា **វិសាខៈ ក៏ផ្លូវដែលមានអង្គ ៨ ដ៏ប្រសើរ លោកសង្គ្រោះដោយខន្ធទាំង ៣ ដូច្នេះ ។**

ឥឡូវនេះ កាលនឹងសួរដល់សមាធិក្នុងមគ្គ ដែលប្រព្រឹត្តទៅត្រឹមតែមួយខណៈចិត្ត ព្រមទាំងគ្រឿងសម្គាល់ រួមទាំងបរិក្ខារ ទើបពោលពាក្យជាដើមថា **តើដូចម្តេចហ្ន៎ ម៉ែម្ចាស់ ?**

ក្នុងការដោះស្រាយបញ្ហានោះ លោកថា សតិប្បដ្ឋាន ៤ គឺ សម្មាសតិកើតឡើងហើយដោយអំណាចញ៉ាំងកិច្ចបួនយ៉ាង ក្នុងខណៈមគ្គឲ្យសម្រេច ។ សម្មាសតិនោះ ក្លាយជាគ្រឿងសម្គាល់ ព្រោះអត្ថថា ជាបច្ច័យនៃសម្មាសមាធិ ។ សម្មប្បធាន ៤ គឺ ជាវីរិយៈ កើតឡើងហើយដោយអំណាចការធ្វើកិច្ចបួនយ៉ាងឲ្យសម្រេច , វីរិយៈនោះក្លាយជាបរិក្ខារ ព្រោះអត្ថថា ហែហម ។ ពាក្យថា **នៃធម៌ទាំងនោះឯង** គឺ នៃធម៌ដែលប្រកបព្រមដោយមគ្គទាំងនោះ ក្នុងពាក្យជាដើមថា **ការសេព** គឺ លោកពោលការសេព ដែលប្រព្រឹត្តទៅត្រឹមតែមួយខណៈ

ចិត្ត ។ ចំណែក អ្នកចូលចិត្តនិយាយលេង ក៏និយាយថា **ឈ្មោះថា មគ្គដែលប្រព្រឹត្តទៅត្រឹមតែមួយខណៈចិត្តមិនមាន** ។ បើដូច្នោះ នឹងមានការអប់រំមគ្គអស់ ៧ ឆ្នាំ ព្រោះពាក្យថា "៧ ឆ្នាំ" ចំណែកពួកកិលេសកាលនឹងដាច់ ក៏រមែងដាច់ទៅដោយញាណទាំង ៧ ដោយឆាប់រហ័ស ។ គប្បីនិយាយចំពោះគេថា "នាំព្រះសូត្រមក" ពិតណាស់ កាលគេមើលមិនឃើញផ្សេងដទៃ ក៏នឹងនាំសេចក្តីថា "ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវធម៌ទាំងនោះឯង យ៉ាងណា" នេះឯងមកពោលថា "រមែងសេពដោយចិត្តដូងដទៃ អប់រំដោយចិត្តដូងដទៃ ធ្វើឲ្យច្រើនក៏ដោយចិត្តដូងដទៃ ។ តពីនោះ គេគប្បីពោលថា "ក៏សូត្រនេះ មានសេចក្តីដែលគប្បីដឹង មានសេចក្តីដែលនាំទៅយ៉ាងណា ?" គេក៏នឹងពោលបន្ថែមទៀតថា "សូត្រមានសេចក្តីដូចដែលនាំទៅនុ៎ះឯង" យ៉ាងច្រើនរបស់គេ ក៏ប៉ុណ្ណេះ ។ កាលបើដូច្នេះ ក៏នឹងមានតែការសេពប៉ុណ្ណោះ សូម្បីទាំងថ្ងៃ យ៉ាងនេះ គឺ ចិត្តដួងមួយកើតឡើងហើយសេព ចិត្តដួងមួយទៀតកើតឡើងហើយសេព សូម្បីដួងមួយទៀត ក៏កើតឡើងហើយសេព , នឹងមានការអប់រំអំពីទីណា ? នឹងមានការធ្វើឲ្យច្រើនអំពីទីណា ? ឬកាលដួងមួយកើតឡើងអប់រំហើយ ដួងដទៃទៀតក៏កើតឡើងអប់រំហើយ ដួងមួយទៀតក៏កើតឡើងអប់រំ ដូច្នេះ បែបនេះទាំងថ្ងៃ ក៏នឹងមានតែការអប់រំប៉ុណ្ណោះ ។ ការសេពនឹងមានអំពីទីណា ? ការធ្វើ

ឲ្យច្រើននឹងមានអំពីទីណា ? ឬដួងមួយក៏កើតឡើងធ្វើឲ្យច្រើនហើយ ដួងដទៃក៏កើតឡើធ្វើឲ្យច្រើន មួយដួងទៀតក៏កើតឡើងធ្វើឲ្យច្រើនឡើង ដូច្នេះ បែបនេះទាំងថ្ងៃ ក៏នឹងមានតែការធ្វើឲ្យច្រើនប៉ុណ្ណោះ នឹងមានការសេពអំពីទីណា ? នឹងមានការអប់រំអំពីទីណា ? ម្យ៉ាងទៀត គេអាចនឹងពោលយ៉ាងនេះថា " រមែងសេពដោយចិត្តដួងមួយ រមែងអប់រំដោយចិត្តពីរដួង រមែងធ្វើឲ្យច្រើនដោយចិត្តបីដួង ឬរមែងសេពដោយចិត្តពីរដួង រមែងអប់រំដោយចិត្តបីដួង រមែងធ្វើឲ្យច្រើនដោយចិត្តមួយដួង ឬរមែងសេពដោយចិត្តបីដួង រមែងអប់រំដោយចិត្តមួយដួង រមែងធ្វើឲ្យច្រើនដោយចិត្តពីរដួង" ។ គេគប្បីត្រូវពោលថា "លោកកុំពោលអះអាងថា "ខ្ញុំក៏បានសូត្រនេះ" ធម្មតាអ្នកនឹងដោះស្រាយបញ្ហា ត្រូវនៅក្នុងសំណាក់អាចារ្យ រៀនព្រះពុទ្ធវចនៈឲ្យជ្រាបអត្ថរសហើយ ទើបសន្សឹមនិយាយ ក៏ការសេពនេះ ប្រកបដោយខណៈចិត្តតែមួយ ការអប់រំ ក៏ប្រកបដោយខណៈចិត្តតែមួយ និងការធ្វើឲ្យច្រើន ក៏ប្រកបដោយខណៈចិត្តតែមួយ ធម្មតាលោកុត្តរមគ្គ ដែលឲ្យដល់ការអស់ទៅ ដែលមានច្រើនខណៈចិត្តមិនមាន មានតែប្រកបដោយខណៈចិត្តតែមួយប៉ុណ្ណោះ" គប្បីធ្វើឲ្យគេព្រមទទួលដូចដែលពោលមកនេះ ។ បើគេព្រមទទួល ក៏ព្រមទទួលទៅ , បើមិនព្រមទទួល ក៏គប្បីបញ្ជូនទៅថា "ចូរទៅចូលវត្តពីព្រឹក ហើយឆាន់បបរចុះ" ។

[១៤៩] ក្នុងពាក្យថា " សង្ខារមានប៉ុន្មានយ៉ាង ម៉ែម្ចាស់ ? " នេះ វិសាខៈឧបាសក សួរដល់អ្វី ?

សួរថា បុគ្គលរលត់សង្ខារពួកណា ទើបចូលនិរោធ ខ្ញុំសូមសួរសង្ខារពួកនោះ កាលព្រះថេរីបានជ្រាបសេចក្តីបំណងរបស់គេ ដោយប្រការនោះឯង ប្រាប់កាយសង្ខារជាដើម ក្នុងសង្ខារចំនួនច្រើនមានបុញ្ញាភិសង្ខារជាដើម ដែលមានហើយ ទើបពោលពាក្យជាដើមថា "ឧបាសក សង្ខារទាំងនេះមានបីយ៉ាង" ។

ក្នុងសង្ខារទាំងនោះ ឈ្មោះកាយសង្ខារ ព្រោះតាក់តែងកាយ គឺ រមែងឲ្យកើត ព្រោះមានសភាពដែលជាប់ទាក់ទងនឹងកាយ , ឈ្មោះវចីសង្ខារ ព្រោះត្រូវតាក់តែង គឺ ត្រូវឲ្យកើតដោយវាចា ព្រោះជាវត្ថុដែលជាប់ទាក់ទងនឹងវាចា , ឈ្មោះថា ចិត្តសង្ខារ ព្រោះត្រូវតាក់តែង គឺ ត្រូវឲ្យកើតដោយចិត្ត ព្រោះជារបស់ដែលជាប់ទាក់ទងនឹងចិត្ត ។ វិសាខឧបាសក រមែងសួរដល់អ្វី ក្នុងពាក្យថា "**តើដូចម្តេច ម៉ែម្ចាស់**" នេះ រមែងសួរថា "សង្ខារទាំងនេះលាយគ្នានិងគ្នា មិនប្រាកដ ប្រាកដដោយលំបាក" ។ ពិតហើយ ដែលហៅចេតនា ២០ យ៉ាង ដែលជាកុសលាកុសល យ៉ាងនេះគឺ ចេតនាក្នុងកាមាវចរកុសល ៨ យ៉ាង ចេតនាក្នុងអកុសល ១២ យ៉ាង ដែលញុំាងបុគ្គល ឲ្យដល់ការតោង ការកាន់ ការរបូត ការបញ្ចេញ ក្នុងកាយទ្វារខ្វះ ខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើម

ចូលខ្លះ ថាជាកាយសង្ខារ ។ លោកហៅចេតនា ២០ យ៉ាង មានប្រការដូចបាន ពោលហើយ ដែលញុំាងការញ៉រនៃចង្កាឲ្យដល់វចីភេទក្នុងវចីទ្វារខ្លះ វិតក្កវិចារៈ ខ្លះថា ជាវចីសង្ខារ , លោកហៅចេតនា ២០ យ៉ាងនោះ កុសល និងអកុសល ដែលកើតដល់អ្នកមិនទាន់ដល់ការកម្រើកញ៉រក្នុងកាយទ្វារ និងវចីទ្វារ ហើយ អង្គុយគិតនៅក្នុងទីស្ងាត់ ធម៌ពីរយ៉ាង គឺ សញ្ញា និងវេទនា ខ្លះថា ជាចិត្ត-សង្ខារតែម្យ៉ាង ធម៌ទាំងនេះលាយឡំគ្នា មិនប្រាកដ ប្រាកដដោយលំបាក , ខ្ញុំ សូមឲ្យធ្វើធម៌ទាំងនោះឲ្យជាក់ច្បាស់ ហើយប្រាប់" ។

ក្នុងបទថា "*កំហេតុដូចម្តេចហ្ន៎ ម៉ែម្ចាស់*" នេះ វិសាខឧបាសក រមែង សួរដល់សេចក្តីរបស់បទនៃឈ្មោះ កាយសង្ខារជាដើម ។ ក្នុងការដោះស្រាយ បញ្ហានោះ អ្នកសិក្សាគប្បីជ្រាបអត្ថន័យនេះថា កាយសង្ខារ ឈ្មោះថា អាស្រ័យ កាយ ព្រោះជាប់ទាក់ទងនឹងកាយ កាលមានកាយ ក៏មានកាយសង្ខារ កាល កាយមិនមាន កាយសង្ខារក៏មានមិនបាន ចិត្តសង្ខារ ឈ្មោះថា អាស្រ័យចិត្ត ព្រោះជាប់ទាក់ទងជាមួយចិត្ត កាលមានចិត្ត ក៏មានចិត្តសង្ខារ កាលចិត្តមិន មាន ចិត្តសង្ខារក៏មានមិនបាន ។

[១៥០] ឥឡូវនេះ កាលវិសាខឧបាសកនឹងសួរ ដើម្បីសេចក្តីដឹងថា "សមាបត្តិនេះ រមែងប្រើសញ្ញាវេទយិតនិរោធឬ មិនមែនហ្ន៎ ឬជាអ្នកសន្សំកាត

ស្ទាត់ជំនាញក្នុងសញ្ញាវេទយិតនិរោធនោះ ឬមិនជាអ្នកសន្សំភាពស្ទាត់ជំនាញ?” ទើបពោលពាក្យជាដើមថា **“ម៉ែម្ចាស់ ធ្វើយ៉ាងណាទើបនឹងជាសញ្ញាវេទយិតនិរោធសមាបត្តិបាន ?”** ក្នុងការឆ្លើយបញ្ហានោះ មានសេចក្តីថា លោកបានពោលដល់វេលានៃនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដោយបទទាំង ២ ថា **“យើងនឹងចូល”** ឬ **“យើងកំពុងចូល”** ។ លោកពោលនិរោធខាងក្នុង ដោយបទថា **“ចូលហើយ”** ។ វេលាដែលមានចិត្ត លោកក៏ពោលដោយបទមុន ទាំងពីរដូចគ្នានោះ វេលាដែលមិនមានចិត្ត លោកពោលដោយបទក្រោយ ។ ពាក្យថា **“ចិត្ត ក៏ជាការអប់រំទុកហើយយ៉ាងនោះមកពីមុនតែម្យ៉ាង”** បានដល់ ចិត្តដែលមានកាលវេលាជាគ្រឿងកំណត់ ជាការបានអប់រំហើយថា “រហូតអស់វេលាប៉ុណ្ណេះ យើងនឹងជាអ្នកមិនមានចិត្ត ក្នុងកាលដែលមានរយៈពេលជាគ្រឿងកំណត់មុននិរោធសមាបត្តិ ។ ពាក្យថា **“រមែងបង្អោន បុគ្គលនោះបានចូលទៅដើម្បីភាពជាយ៉ាងនោះ”** គឺ រមែងបង្អោន បុគ្គលដែលអប់រំចិត្តទុកហើយយ៉ាងនេះ ចូលទៅដើម្បីសភាពជាយ៉ាងនោះ បានដល់ ដើម្បីភាពជាអ្នកមិនមានចិត្ត ។ ពាក្យថា **“វចីសង្ខាររមែងរលត់ទៅមុន”** គឺ វចីសង្ខារ រមែងរលត់ចាកសង្ខារដ៏សេសក្នុងឈានទីពីរមុន ។ ពាក្យថា **“តពីនោះកាយសង្ខារ”** គឺ តពីនោះ កាយសង្ខារក៏រលត់ទៅក្នុងឈានទីបួន ។ ពាក្យថា **“តពីនោះចិត្តសង្ខារ”**

គឺ តពីនោះចិត្តសង្ខារ ទើបរលត់ទៅខាងក្នុងនិរោធ ។ លោកពោលវេលាខាងក្នុងនិរោធ ដោយពីរបទថា “**យើងនឹងចេញ**” ឬ “**យើងកំពុងចេញ**” វេលានៃផលសមាបត្តិ លោកពោលដោយបទថា “**ចេញហើយ**” វេលាជាអ្នកគ្មានចិត្ត លោកពោលដោយពីរបទមុនដូចគ្នានោះ ។ ដោយបទក្រោយ លោកពោលវេលាដែលមានចិត្ត ។ ពាក្យថា “**ចិត្តក៏ជាការបានអប់រំមកហើយយ៉ាងនោះមុន**” គឺ ចិត្តដែលមានវេលាជាគ្រឿងកំណត់ ជាការបានអប់រំហើយថា រហូតអស់វេលាប៉ុណ្ណេះ យើងនឹងជាអ្នកគ្មានចិត្ត ក្នុងកាលដែលមានរយះពេលជាគ្រឿងកំណត់ទុក មុនចូលដល់និរោធសមាបត្តិហើយ តពីនោះទើបនឹងជាអ្នកមានចិត្ត ។ ពាក្យថា “**រមែងបង្អោនបុគ្គលនោះបានចូលទៅ ដើម្បីភាពជាយ៉ាងនោះ**” គឺ រមែងបង្អោនបុគ្គលដែលអប់រំចិត្តទុកហើយយ៉ាងនេះ ចូលទៅដើម្បីភាពជាយ៉ាងនោះ គឺ ដើម្បីភាពជាអ្នកមានចិត្ត ។ វេលានៃការចូលនិរោធលោកពោលទុកក្នុងកាលមុនហើយ ក្នុងទីនេះ លោកពោលវេលានៃការចេញចាកនិរោធ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ជាភារៈដើម្បីនឹងពោលនិរោធកថា ដូច្នោះ និរោធកថា ទើបជារឿងដែលត្រូវពោល ក៏ឯនិរោធកថានោះ លោកបានតាំងមាតិកាពោលទុកក្នុងវិសុទ្ធិមគ្គហើយថា “**បញ្ញាដែលសេចក្តីស្ទាត់ជំនាញអប់រំទុក ដោយការរម្ងាប់**

សង្ខារបើ ព្រោះភាពជាអ្នកប្រកបដោយកម្លាំងពីរ , ដោយការប្រព្រឹត្តទៅក្នុងញាណ ១៦ , ដោយការប្រព្រឹត្តក្នុងសមាធិ ៩ បញ្ញាដែលសេចក្ដីស្ទាត់ជំនាញអប់រំហើយ និងញាណក្នុងការចូលដល់និរោធ” ។ ព្រោះដូច្នោះ អ្នកត្រូវការប្រាជ្ញាបគប្បីកាន់យកតាមន័យដែលពោលទុកក្នុងវិសុទ្ធិមគ្គនោះចុះ ។ ដែលឈ្មោះថា **និរោធនេះ បានដល់អ្វីហ្ន៎** ? បានដល់ ការមិនប្រព្រឹត្តទៅនៃការពិចារណាខន្ធទាំងបួន ។ បើនឹងមានការសួរថា កាលបើដូច្នោះ ចូលសមាបត្តិដើម្បីអ្វី ? ក៏ឆ្លើយថា ចូលសមាបត្តិដើម្បីវត្ថុនេះគឺ “យើងកើតទុក្ខក្នុងការប្រព្រឹត្តទៅហើយក្នុងសង្ខារ នឹងជាអ្នកមិនមានចិត្តត្រឹមតែប្រាំពីរថ្ងៃនៅសប្បាយ និរោធនេះ ឈ្មោះថា ជានិព្វានក្នុងបច្ចុប្បន្ន” ។ ពាក្យថា “**ចិត្តសង្ខារ រមែងកើតឡើងមុន**” គឺពិតហើយ កាលនឹងចេញចាកនិរោធ ចិត្តក្នុងផលសមាបត្តិរមែងកើតឡើងមុន ។ លោកសំដៅយកសញ្ញា និងវេទនា ដែលប្រកបដោយផលសមាបត្តិនោះ ទើបពោលថា “ចិត្តសង្ខារ រមែងកើតឡើងមុន” ពាក្យថា “**តពីនោះកាយសង្ខារ**” គឺ តពីចិត្តសង្ខារនោះទៅ កាយសង្ខាររមែងកើតឡើងក្នុងសម័យនៃភវង្គ ។ សួរថា “ក៏ផលសមាបត្តិ មិនញ៉ាំងខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលឲ្យតាំងឡើងឬ ? ឆ្លើយថា ឲ្យតាំងឡើង តែផលសមាបត្តិរបស់អ្នកនេះ ប្រកបដោយឈានទីបួន ផលសមាបត្តិនោះ ទើបធ្វើឲ្យខ្យល់ដកដង្ហើមចេញ និងខ្យល់

ដកដង្ហើមចូល តាំងឡើងមិនបាន ។ ឬព្រោះហេតុនេះឬ ? ផលសមាបត្តិនឹងប្រកបដោយឈានទីមួយ ឬប្រកបដោយឈានទីពីរ ទីបី ឬទីបួនក៏ដោយចុះ ខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូលរបស់ភិក្ខុដែលចេញចាកសមាបត្តិដែលស្ងប់ រមែងជាវត្ថុដែលនិយាយមិនបាន (គឺមានដូចមិនមាន) ឬ? សេចក្តីដែលខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលនោះ ជាវត្ថុដែលនិយាយមិនបាន គប្បីជ្រាបដោយរឿងព្រះសញ្ជីវត្ថេរៈ ៖

សេចក្តីសង្ខេបមានថា កាលព្រះសញ្ជីវត្ថេរៈចេញចាកសមាបត្តិហើយ ក៏ដើរលុយកាត់លើរងើកភ្លើងដែលគេពង្រាយទុកដូចផ្កាមាស សូម្បីត្រឹមតែក្នុងចីវរក៏មិនឆេះឡើង សូម្បីត្រឹមតែអាការនៃចំហាយក្តៅ ក៏មិនបានមាន ។ ពួកគេក៏ពោលថា នេះឯងផលរបស់សមាបត្តិ ។ ខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលរបស់ភិក្ខុ ចេញចាកសមាបត្តិដែលស្ងប់ រមែងជាវត្ថុដែលនិយាយមិនបាន ដូចដែលពោលមកនេះឯង ដូច្នោះគប្បីជ្រាបថា ពាក្យនេះលោកពោលក្នុងសម័យនៃកវគ្គប៉ុណ្ណោះ ។

ពាក្យថា **“តពីនោះ ក៏វចីសង្ខារ”** គឺ បន្ទាប់ពីកាយសង្ខារនោះ មកវចីសង្ខារ ក៏រមែងកើតឡើងក្នុងវេលានៃការប្រើដែលសម្រេចមកពីកិរិយាចិត្តប្រព្រឹត្តទៅ សួរថា កវគ្គនឹងឲ្យវិតក្កវិចារតាំងឡើងមិនបានឬ ? ឆ្លើយថា ឲ្យតាំង

ឡើងបាន , តែវិតក្ក និងវិចារដែលប្រកបដោយកវង្គនោះ តាក់តែងវាចាមិនបាន ព្រោះដូច្នោះ ពាក្យនោះ លោកពោលតាមវេលាប្រើដែលសម្រេចមកពីកិរិយាចិត្តដែលប្រព្រឹត្តទៅហើយប៉ុណ្ណោះ ។ សមាបត្តិជាដើមថា **"ផស្សៈជារបស់សូន្យ"** ក៏គប្បីពោលអំពីផស្សៈដែលមានគុណ និងដោយអារម្មណ៍ ។ ផលសមាបត្តិឈ្មោះថា ជារបស់សូន្យដោយផស្សៈដែលមានគុណមុន ព្រោះលោកបំណងយកផស្សៈដែលកើតព្រមនឹងសុញ្ញតផលសមាបត្តិនោះ ទើបពោលពាក្យថា "ផស្សៈជារបស់សូន្យ" សូម្បីក្នុងអនិមិត្តផលសមាបត្តិ និងអប្បណិហិតផលសមាបត្តិ ក៏មានទំនងយ៉ាងនេះដូចគ្នា ក៏ដោយអារម្មណ៍ ព្រះនិព្វានដែលឈ្មោះថា សូន្យ ក៏ព្រោះសូន្យចាករាគៈជាដើម ។ ឈ្មោះថា មិនមានគ្រឿងសម្គាល់ ព្រោះមិនមានគ្រឿងសម្គាល់នៃរាគៈជាដើម ព្រោះមិនមានទីតាំងនៃរាគៈជាដើម ទើបឈ្មោះថា មិនមានទីតាំង ។ ផស្សៈក្នុងផលសមាបត្តិ ធ្វើព្រះនិព្វានដែលជារបស់សូន្យឲ្យកើតជាអារម្មណ៍ ឈ្មោះថា ជារបស់សូន្យ ។ សូម្បីក្នុងអនិមិត្តផលសមាបត្តិ និងអប្បណិហិតផលសមាបត្តិ ក៏មានទំនងយ៉ាងនេះដូចគ្នា ។ នៅមានពាក្យដែលនឹងត្រូវបន្ថែមយ៉ាងដទៃទៀត គឺ សូម្បីវិបស្សនា លោកក៏ហៅថា **សុញ្ញតា អនិមិត្តតា អប្បណិហិតា** ក្នុងប្រការទាំងនោះ ភិក្ខុណា កំណត់សង្ខារដោយសេចក្ដីមិនទៀងឃើញដោយសេចក្ដីមិនទៀងហើយ រមែងចេញដោយសេចក្ដីមិនទៀង ។ វិបស្សនា

ដែលនាំទៅដល់ការចេញរបស់ភិក្ខុនោះ រមែងឈ្មោះថា **អនិមិត្តាវិបស្សនា** ។ ភិក្ខុណាកំណត់សង្ខារដោយភាពជាទុក្ខ ឃើញដោយសភាពជាទុក្ខហើយ រមែងចេញដោយសភាពជាទុក្ខ វិបស្សនាដែលនាំទៅដល់ការចេញរបស់ភិក្ខុនោះ រមែងឈ្មោះថា **អប្បណិហិតាវិបស្សនា** ។ ភិក្ខុណាកំណត់សង្ខារដោយសេចក្ដីជារបស់មិនមែនខ្លួន ឃើញដោយសេចក្ដីជារបស់មិនមែនខ្លួនហើយ រមែងចេញដោយសេចក្ដីជារបស់មិនមែនខ្លួន ។ វិបស្សនាដែលនាំទៅដល់ការចេញរបស់ភិក្ខុនោះ រមែងឈ្មោះថា **សុញ្ញតាវិបស្សនា** ។ មគ្គក្នុងអនិមិត្តវិបស្សនារបស់ភិក្ខុនោះ ឈ្មោះ អនិមិត្តមគ្គ ។ ផលរបស់អនិមិត្តមគ្គ ឈ្មោះ អនិមិត្តផល កាលពាល់ត្រូវផស្សៈ ដែលកើតព្រមនឹងអនិមិត្តផលសមាបត្តិ ក៏ហៅថា **អនិមិត្ត** រមែងពាល់ត្រូវ សូម្បីក្នុងអប្បណិហិតៈ និងសុញ្ញតៈ ក៏មានទំនងនេះដូចគ្នា ។ ដោយពាក្យនឹងត្រូវបន្ថែមដែលបានពោលទុកហើយ ផស្សៈក៏គប្បីមកដល់ការជ្រើសរើសយកយ៉ាងណាមួយថា “សុញ្ញតផស្សៈក៏បាន អនិមិត្តផស្សៈក៏បាន ឬអប្បណិហិតផស្សៈក៏បាន , ព្រោះដូច្នោះ ទើបគួរពោលសមាបត្តិជាដើម ដោយផស្សៈដែលមានគុណ និងដោយអារម្មណ៍ ។ ព្រោះកាលពោលយ៉ាងនេះ ពាក្យក៏នឹងចូលគ្នាបានថា “ផស្សៈបីយ៉ាង រមែងពាល់ត្រូវ” ។ ព្រះនិព្វាន ឈ្មោះ វិវេក ក្នុងពាក្យជាដើមថា “ផស្សៈបីយ៉ាងរមែងពាល់ត្រូវ” ។ ព្រះនិព្វាន ឈ្មោះ វិវេក

ក្នុងពាក្យជាដើមថា *"**បង្អោនទៅក្នុងវិវេក**"* ដែលថាបង្អោនទៅក្នុងវិវេក ក៏ព្រោះបង្អោន គឺ ឱនទៅក្នុងវិវេកនោះ ។ ដែលឈ្មោះថា ទៅក្នុងវិវេក ។ ក្នុងពាក្យថា *"**សុះទៅក្នុងវិវេក**"* ក៏ព្រោះមកពីទីដទៃហើយ ក៏តាំងនៅ ដូចគ្នានឹងចូលទៅរកវិវេកនោះ ។ ដែលឈ្មោះថា ***មានវិវេក*** ក៏ព្រោះថា តាំងនៅដូចនឹងធ្លាក់ទៅរកវិវេកនោះ ។

[១៥១] ឥឡូវនេះ កាលវិសាខៈនឹងសួរថា *"**ខ្ញុំនឹងសូមសួរវេទនាដែលភិក្ខុរំលត់បានហើយ ទើបចូលនិរោធសមាបត្តិបាន**"* ទើបពោលពាក្យជាដើមថា *"**ម៉ែម្ចាស់ ក៏វេទនាមានប៉ុន្មាន ?**"* សេចក្ដីសុខដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ក្នុងពាក្យជាដើមថា *"ឬប្រព្រឹត្តទៅក្នុងផ្លូវកាយ"* ឈ្មោះ កាយិកសុខ , ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ គប្បីជ្រាបថា ឈ្មោះ ចេតសិកសុខ ។ ក្នុងរឿងរបស់វេទនានោះ ពាក្យថា *"**សុខ**"* ជាពាក្យចង្អុលបង្ហាញដល់សភាវៈ ។ ពាក្យថា *"**សេចក្ដីរីករាយ**"* ជាពាក្យសម្រាប់ប្រើជំនួសគ្នា សម្ដែងដល់សេចក្ដីឆ្ងាញ់នៃសុខនោះឯង ។ ពាក្យថា *"**ការសោយ**"* ជាពាក្យទូទៅដល់វេទនាគ្រប់យ៉ាងដែលសម្ដែងសេចក្ដី គឺ ការសោយ សូម្បីក្នុងបទដ៏សេស ក៏មានទំនងតែមួយដូចគ្នានេះឯង ។ ក្នុងពាក្យជាដើមថា *"សេចក្ដីតាំងនៅជាសុខ សេចក្ដីប្រែប្រួលជាទុក្ខ"* មានអត្ថន័យថា សេចក្ដីមាននៃសុខវេទនា ឈ្មោះថា សុខ , សេចក្ដី

មិនមាន ឈ្មោះថា ទុក្ខ , សេចក្ដីមាននៃទុក្ខវេទនា ឈ្មោះថា ទុក្ខ , សេចក្ដីមិនមាន ឈ្មោះថា សុខ , សេចក្ដីដឹងអទុក្ខមសុខវេទនា ឈ្មោះថា សុខ , សេចក្ដីមិនដឹង ឈ្មោះថា ទុក្ខ ។

ក្នុងពាក្យថា "**អនុស័យអ្វី រមែងដេកត្រាំ**" នេះ វិសាខៈ រមែងសួរដល់អនុស័យថា អនុស័យតើដូចម្ដេច ? រមែងដេកត្រាំ គឺ ដូចជាអ្នកដេក ព្រោះអត្ថថា លះមិនបាន ។ ពាក្យថា "**វិសាខៈ កាមរាគានុស័យ មិនមែនដេកត្រាំក្នុងសុខវេទនាទាំងអស់ទេ**" សេចក្ដីថា រាគានុស័យ មិនមែនដេកជាប់ក្នុងសុខវេទនាទាំងអស់ រាគានុស័យនោះ ដែលលះមិនបានក្នុងសុខវេទនាគ្រប់យ៉ាង ក៏រមែងមិនប្រារព្ធសុខវេទនាគ្រប់ប្រភេទ ហើយកើតឡើង ។ ក្នុងទីគ្រប់កន្លែង ក៏មានទំនងដូចគ្នាយ៉ាងនេះ ។ ពាក្យថា "**គប្បីលះអ្វី ?**" នេះជាពាក្យសួរដល់ការលះ ព្រះនាងធម្មទិន្នាដោះស្រាយពាក្យសួរពីរប្រការ ដោយពាក្យឆ្លើយនេះឯង ក្នុងបទថា "**រមែងលះរាគៈដោយឈានទីមួយនោះ**" នេះ ។ ភិក្ខុក្នុងព្រះធម៌វិន័យនេះ គ្របសង្កត់កាមរាគានុស័យបានហើយ រមែងចូលដល់ឈានទីមួយ ធ្វើរាគានុស័យដែលឈានគ្របសង្កត់ទុក ឲ្យជាការគ្របសង្កត់ហើយ យ៉ាងនុ៎ះឯង ហើយចម្រើនវិបស្សនា ទើបដកបាន កាត់ផ្ដាច់ដោយអនាគាមិមគ្គ ។ រាគានុស័យនោះ សូម្បីនឹងត្រូវលះ បានដោយអនាគាមិមគ្គហើយ ក៏ឈ្មោះថា

រមែងដេកត្រាំក្នុងឈានទីមួយ ព្រោះត្រូវឈានទីមួយនោះ គ្របសង្កត់យ៉ាងនោះ ។ ព្រោះដូច្នោះ ព្រះនាងធម្មទិន្នាទើបពោលថា "រាគានុស័យ រមែងមិនដេកត្រាំក្នុងសុខវេទនានោះ" ។

បទថា **តទាយតនំ** កាត់ជា **តំ អាយតនំ** សេចក្តីថា ព្រះអរហត្តផលដែលឈ្មោះថា ជាទីពឹង ព្រោះការៈនៃចិត្តដែលរួចស្រឡះដ៏ក្រៃលែង ។ ពាក្យថា "**ដ៏ប្រសើរដោយប្រការដូច្នេះ**" គឺ អ្នកតាំងសេចក្តីប្រាថ្នាក្នុងព្រះអរហត្តផលដែលបានឈ្មោះថា "វិមោក្ខដ៏ប្រសើរដោយប្រការដូច្នេះ" ។ ពាក្យថា "**ទោមនស្ស រមែងកើតឡើង ព្រោះការប្រាថ្នាជាបច្ច័យ**" គឺ ទោមនស្សរមែងកើត ដែលជាមូលឲ្យសេចក្តីប្រាថ្នាតាំងឡើង តែទោមនស្សដែលជាមូលឲ្យសេចក្តីប្រាថ្នាតាំងឡើងនោះ នឹងមិនកើតឡើងឡើយ , តែលោកពោលថា ទោមនស្សដែលមានសេចក្តីមិនបានជាមូល កាលនឹងកើតដល់អ្នកប្រាថ្នាហើយមិនបាន ក៏រមែងកើតឡើង ព្រោះភាពជាបច្ច័យ ។ អាចារ្យខ្លះពោលថា "សូម្បីថា ឈ្មោះថា ទោមនស្សក្នុងសេចក្តីប្រាថ្នាហើយមិនបាននោះ ជាអកុសលដោយចំណែកតែមួយក៏ពិតមែនហើយ ប៉ុន្តែថា ក៏គប្បីសេពទោមនស្សនេះ ។ ទោមនស្ស (នេះ) គួរ" ពិតមែន ពួកយោគី (ភិក្ខុអ្នកបដិបត្តិ) រមែងទទួលយកវត្តបដិបត្តិរយៈ ៣ ខែខ្លះ រយៈ ៦ ខែខ្លះ រយៈ ៩ ខែខ្លះ ។ ក្នុងយោគីទាំងនោះ អ្នកដែលទទួលយក

វត្តបដិបត្តិនោះៗ ទៅហើយ ក៏បន្តព្យាយាម ដោយគិតថា "ខាងក្នុងវេលាដែលកំណត់ទុកនេះឯង យើងគង់នឹងសម្រេចព្រះអរហត្តផល (តែ) ក៏មិនអាចសម្រេចតាមវេលាដែលកំណត់ទុក ទើបកើតទោមនស្សដ៏ខ្លាំង មានទឹកភ្នែកហូរ ដូចជាព្រះមហាបុស្សត្ថេរៈ អ្នកស្រុកអាឡិន្ទកវាសី ។

មានរឿងដំណាលមកថា ព្រះថេរៈបំពេញវត្តដើរទៅដើរមកអស់ ១៩ ឆ្នាំ កាលលោកគិតថា "គ្រានេះយើងនឹងកាន់យកព្រះអរហត្តផលឲ្យបាន" ថា "គ្រានេះ យើងនឹងបវារណាប្រភេទវិសុទ្ធិបវារណា" ហើយធ្វើសមណធម៌ទុំះឯង ១៩ ឆ្នាំកន្លងទៅ លុះមកដល់ថ្ងៃបវារណា ក៏មិនបានរួចផុត ព្រោះតំណក់ទឹកភ្នែករបស់ព្រះថេរៈ តែក្នុងឆ្នាំទី ២០ ទើបបានសម្រេចព្រះអរហត្តផល ។

ក្នុងពាក្យថា **"រមែងលះបដិឃៈដោយទោមនស្សនោះ"** នេះ មានសេចក្តីថា នឹងយកទោមនស្សទៅលះបដិឃៈមិនបាន នឹងយកបដិឃៈនុំះឯង ទៅលះបដិឃៈក៏មិនបាន ឬការយកទោមនស្សទៅលះទោមនស្ស ក៏រមែងមិនបាន ។ តែភិក្ខុនេះ ទទួលយកវត្តបដិបត្តិយ៉ាងណាមួយក្នុងវត្តបដិបត្តិ មានរយៈ ៣ ខែជាដើម ហើយពិចារណាយ៉ាងនេះថា "ភិក្ខុមើលលោកមានឋានៈអាក្រក់ដោយសីល ដោយវីរិយៈ ឬដោយបញ្ញា ? សីលរបស់លោកហ្មត់ចត់ល្អហើយ មិនមែនឬ ? លោកផ្គងវីរិយៈល្អហើយមិនមែនឬ ? ឬបញ្ញាជាធម្មជាតិដែលខ្លាំង

ក្មារមែងនាំទៅ ?" កាលលោកពិចារណាយ៉ាងនេះ ក៏ឃើញថា "ឥឡូវនេះ យើងនឹងមិនព្រមឲ្យទោមនស្សនេះកើតឡើងទៀត ទើបធ្វើសេចក្ដីព្យាយាមដ៏ធ្ងន់ខាងក្នុង ៣ ខែ ខាងក្នុង ៦ ខែ ឬខាងក្នុង ៩ ខែ ក៏រមែងដកបដិឃៈដោយ អនាគមិមគ្គបាន តាមន័យនេះ ឈ្មោះថា លោករមែងប្រើបដិឃៈនុ៎ះឯង លះបដិឃៈ (និង) ប្រើទោមនស្សនុ៎ះឯង លះទោមនស្ស ។ ក្នុងពាក្យថា "**បដិឃានុស័យរមែងមិនដេកក្នុងទោមនស្សនោះ**" នុ៎ះ មានសេចក្ដីថា ក្នុងទោមនស្សបែបនោះ បដិឃានុស័យរមែងមិនដេកត្រាំ បដិឃានុស័យ ក៏មិនប្រារព្ធទោមនស្សនោះកើតឡើង , បដិឃានុស័យ ដែលត្រូវលះបានក្នុងទោមនស្សនោះ ។ ពាក្យថា "**រមែងលះអវិជ្ជាបានដោយអរហត្តមគ្គនោះ**" គឺ ភិក្ខុក្នុងព្រះធម៌វិន័យនេះ គ្រប់សង្កត់អវិជ្ជានុស័យបានហើយ ក៏ចូលកាន់ឈានទីបួន ធ្វើអវិជ្ជានុស័យដែលត្រូវឈានគ្រប់សង្កត់ហើយឲ្យជាការត្រូវគ្រប់សង្កត់យ៉ាងនោះឯង ទើបចម្រើនវិបស្សនានឹងដកបានដោយអរហត្តមគ្គ ។ សូម្បីអវិជ្ជានុស័យនោះ ត្រូវអរហត្តមគ្គលះបានហើយក៏ដោយ ក៏ឈ្មោះថា ដេកជាប់ដោយឈានទីបួន ព្រោះត្រូវឈានទីបួននោះ គ្រប់សង្កត់បានហើយ ព្រោះហេតុនោះ ព្រះនាងធម្មទិន្នា ទើបពោលថា "អវិជ្ជានុស័យ រមែងមិនដេកត្រាំក្នុងអរហត្តមគ្គនោះ" ដូច្នេះ ។

[១៥២] ឥឡូវនេះ កាលនឹងសួរពាក្យសួរដែលជាបដិភាគ , (ចំណែក

ប្រាប់គ្នា ) វិសាខៈ ទើបពោលពាក្យជាដើមថា **ម៉ែម្ចាស់ ! ក៏សុខវេទនា** “ក្នុងការដោះស្រាយបញ្ហានោះ (គប្បីជ្រាបគោលសេចក្តីដូចតទៅនេះ) ព្រោះទុក្ខជាសត្រូវរបស់សុខ និងសុខជាសត្រូវរបស់ទុក្ខ , ដូច្នោះលោកទើបពោលវិសភាគបដិភាគទុកក្នុងវេទនាទាំងពីរ ចំណែកឧបេក្ខាជាធម្មជាតិដែលត្រូវសេចក្តីងងឹតគ្របសង្កត់ លំបាកនឹងបង្ហាញប្រាប់ ព្រោះដូច្នោះ លោកទើបពោលទាំងសភាគ និងបដិភាគក្នុងទីនេះថា សូម្បីអវិជ្ជាក៏យ៉ាងនោះឯង ។ ក៏បុគ្គលរមែងធ្វើសេចក្តីងងឹត គឺ អវិជ្ជាក្នុងទីមានប្រមាណប៉ុនណា ក៏រមែងបន្ទោបង់សេចក្តីងងឹត គឺ អវិជ្ជាក្នុងទីមានប្រមាណប៉ុណ្ណោះ ដូច្នោះទើបពោលទាំងវិសភាគនិងបដិភាគទុកក្នុងទីនេះ ។ ក្នុងពាក្យថា “**អវិជ្ជានេះ**” នេះ គឺ លោកពោលទាំងសភាគ និងបដិភាគថា “ធម៌ទាំងពីរនេះ មិនមានអាសវៈ ជាលោកុត្តរៈ” លោកពោលទាំងសភាគ និងបដិភាគ ព្រោះអត្ថថា មិនមានអាសវៈ ព្រោះអត្ថថា ជាលោកុត្តរៈ និងព្រោះអត្ថថា ជាអព្យាក្រិត ក្នុងបទនេះថា “**អាវុសោ វិមុត្តិនេះឯង**” ក្នុងពាក្យថា “**វិមុត្តិ**” នេះ មានសេចក្តីថា អាវុសោ អ្នកឆ្លងបញ្ហាទៅ ពាក្យថា “**អ្នកមិនអាចកាន់យកទីបំផុតនៃបញ្ហាបាន**” ទើបសួរបដិភាគ នៃអប្បដិភាគធម៌ ព្រះនិព្វាននេះ ជាអប្បដិភាគធម៌ ដែលមិនមានអ្នកណាប្រាថ្នាដើម្បីនឹងធ្វើបដិភាគព្រមនឹងធម៌ពួកខ្លះ គឺ ពណ៌ខៀវ ពណ៌លឿង ឬពណ៌ក្រហម

ហើយសម្តែងបាន និងអ្នកក៏រមែងសួរព្រះនិព្វាននោះ ដោយសេចក្តីប្រាថ្នានេះទៀតផង ក៏ដោយពាក្យត្រឹមតែប៉ុណ្ណោះ ឧបាសកអ្នកនឹងសួរបដិភាគ នៃអប្បដិភាគធម៌នេះ ទើបជាការដែលបុគ្គលគប្បីជ្រាបថា រមែងជាអ្នកផ្តើមខុសក្នុងពាក្យសួរ ដែលមានចំណែកប្រាប់សូម្បីគ្រប់ប្រការ ដូចកិត្តុដែលបានស្ទាកកត្តក្នុងផ្ទះទី ៧ ហើយដើរហួសទៅអស់ផ្ទះ ៧ ខ្នង មកឈរត្រង់ទ្វារផ្ទះទី ៨ ផ្តើមខុសទៅតាំងពីក្ទះ ៧ ខ្នង មិនដឹង ( អ្វីឡើយ ) យ៉ាងណា ក៏យ៉ាងនោះ ។ ពាក្យថា *"ធ្លាក់ចុះកាន់ព្រះនិព្វាន"* គឺ ចូលទៅខាងក្នុងព្រះនិព្វាន គឺ ចូលទៅកាន់ព្រះនិព្វាន ។ ពាក្យថា *"មានព្រះនិព្វានជាខាងមុខ"* គឺ ព្រះនិព្វានជាទីមកខាងមុខ គឺ ជាទីទៅខាងមុខរបស់គេ អធិប្បាយថា គេមិនទៅកាន់ទីដទៃអំពីព្រះនិព្វាននោះ ។ ឈ្មោះថា *"មានព្រះនិព្វានជាទីបំផុត"* ព្រោះព្រះនិព្វាន ជាទីបំផុតរបស់គេ ។

[១៥៣] អ្នកដែលដល់ព្រមដោយភាពជាបណ្ឌិត ឈ្មោះថា *"បណ្ឌិត"* មានសេចក្តីថា អ្នកឆ្លាតក្នុងធាតុ ឆ្លាតក្នុងអាយតនៈ ឆ្លាតក្នុងបដិច្ចសមុប្បាទ ឆ្លាតក្នុងឋានៈ និងអឋានៈ ពាក្យថា *"អ្នកមានបញ្ញាធំក្រៃលែង"* បានដល់ អ្នកប្រាស់ក្លាព្រមដោយបញ្ញា ដែលអាចកំណត់កាន់យកអត្ថដ៏ធំក្រៃលែង ធម៌ដែលធំក្រៃលែង និរុត្តិដែលធំក្រៃលែង បដិភាណដែលធំក្រៃលែង ។ ពាក្យថា "ដូច

សេចក្តីដែលព្រះនាងធម្មទិន្នានោះ” គឺ សូម្បីតថាគតក៏នឹងគប្បីព្យាករណ៍ដូចធម្មទិន្នាភិក្ខុនីព្យាករណ៍ហើយនុ៎ះឯង ។

ក៏ព្រោះព្រះតម្រាស់ត្រឹមតែប៉ុណ្ណេះ ព្រះសូត្រនេះ ក៏ក្លាយជាភាសិតរបស់ព្រះជិនស្រីទៅ ។ មិនមែនភាសិតរបស់សាវក ដូចសំបុត្រដែលរាជលេខានុការសរសេរហើយ មិនទាន់នឹងជាព្រះរាជសាសន៍ រហូតវេលាដែលមិនទាន់បានប្រថាប់ព្រះរាជលញ្ចករ ពេលប្រថាប់ព្រះរាជលញ្ចកររបស់ព្រះរាជាហើយសំបុត្ររមែងឈ្មោះថា ជាព្រះរាជសាសន៍ យ៉ាងណា , ព្រះសូត្រនេះបានក្លាយជាភាសិតរបស់ព្រះជិនស្រី ដោយការត្រាស់ហើយ ព្រោះសេចក្តីដែលព្រះត្រា គឺ ព្រះតម្រាស់របស់ព្រះជិនស្រី ដោយការត្រាស់ហើយ ព្រោះសេចក្តីដែលព្រះត្រា គឺ ព្រះតម្រាស់របស់ព្រះជិនស្រីអង្គនេះ បានប្រថាប់ហើយ ថា “**តថាគតក៏នឹងព្យាករណ៍យ៉ាងនោះដូចគ្នា សូម្បីដូច្នោះដែរ**” ។ ពាក្យដ៏សេសគ្រប់កន្លែងងាយស្រួលយល់ហើយ ដោយប្រការដូច្នេះ ។

“ ចប់ អដ្ឋកថា ចូឡវេទល្លសូត្រទី ៤ ”

# អ ដ្ឋ ក ថា

## ចូឡធម្មសមាទានសូត្រទី ៥

[១៥៤] *ចូឡធម្មសមាទានសូត្រ មានពាក្យផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

[១៥៥] *បណ្ដាបទទាំងនោះ បទថា* **ធម្មសមាទានំ** *បានដល់ ការកាន់យក ដែលលោកកាន់យកដោយបទថា* **ធម៌** *ដូច្នេះ ។*

*បទថា* **សេចក្ដីសុខដែលកើតក្នុងបច្ចុប្បន្ន** *បានដល់ សេចក្ដីសុខក្នុងបច្ចុប្បន្ន ។ សេចក្ដីសុខក្នុងការប្រមូលមកធ្វើបានងាយ គឺ អាចឲ្យពេញបានដោយងាយ ។*

*បទថា* **ផលដែលជាទុក្ខខាងមុខ** *បានដល់ ផលដែលជាទុក្ខក្នុងកាលឲ្យផលក្នុងអនាគត ។ គប្បីជ្រាបអធិប្បាយក្នុងបទទាំងពួងដោយឧបាយនេះ ។*

[១៥៦] *បទថា* **មិនមានទោសក្នុងកាមទាំងឡាយ** *សេចក្ដីថា មិនមានទោសក្នុងវត្ថុកាមខ្លះ កិលេសកាមខ្លះ ។*

*បទថា* **ដល់ភាពជាអ្នកគប្បីផឹក** *សេចក្ដីថា សមណព្រាហ្មណ៍ពួកនោះគប្បីផឹក គឺ ការៈជាវត្ថុដែលខ្លួនគប្បីផឹក បានដល់ ភាពជាវត្ថុដែលខ្លួនគប្បីបរិ-*

ភោគតាមសេចក្តីពេញចិត្ត ដោយកិលេសកាមក្នុងវត្ថុកាម ។

បទថា **ចងឲ្យជាផ្នួង** បានដល់ ពួកតាបស និងបរិព្វាជកអ្នកបួសក់ធ្វើឲ្យជាផ្នួង ។

បទថា **ពោលយ៉ាងនេះ** គឺ រមែងពោលយ៉ាងនេះ ។

បទថា **រមែងបញ្ញត្តិការកំណត់ដឹង** បានដល់ រមែងបញ្ញត្តិការលះ គឺការឈានកន្លង ។ បទថា **ផ្លែជ្រៃ** បានដល់ ផ្លែជ្រៃដែលទុំហើយ នឹងមានសណ្ឋានវែង ។ បទថា **គប្បីបែក** សេចក្តីថា ស្ងួតដោយកំដៅថ្ងៃហើយបែក ។

បទថា **គល់ដើមរាំងភ្នំ** បានដល់ ជិតដើមរាំងភ្នំ ។

បទថា **គប្បីដល់សេចក្តីតក់ស្លុត** សេចក្តីថា រមែងដល់ (សេចក្តីតក់ស្លុត) ព្រោះហេតុអ្វី ? ព្រោះខ្លាចសេចក្តីវិនាសទៅនៃលំនៅ ព្រោះថា ផ្លែជ្រៃដែលធ្លាក់ទៅត្រង់ដើមឈើ កើតឡើងហើយពីពូជ រមែងវារឡើងដើមឈើ ។ ជ្រៃនោះ មានស្លឹកធំ និងក្រាស់ ប្រកបដោយស្លឹក ដូចជាស្លឹករលួស លំដាប់នោះ ដើមជ្រៃ កាលកម្ចាត់ដើមឈើនោះ តាំងពីគល់ទៅធ្លុះប្រគាបទាំងពួងឲ្យកើតទម្ងន់យ៉ាងច្រើនតាំងនៅ ដើមជ្រៃនោះ កាលខ្យល់បក់មក ឬកាលភ្លៀងធ្លាក់ ក៏ដុះលូតលាស់ឡើង កាច់បំបាក់មែកតូចធំទាំងពួងរបស់ដើមឈើនោះឲ្យធ្លាក់ទៅលើផែនដី បន្ទាប់ពីនោះ កាលដើមឈើនោះដួលទៅ វិមានរមែង

បែកបាក់វិនាសទៅ ទេវតានោះ រមែងដល់សេចក្ដីតក់ស្លុត ព្រោះខ្លាចសេចក្ដីវិនាសទៅនៃវិមាន ដោយប្រការដូច្នេះ ។

បទថា **ទេវតាដែលស្ថិតនៅក្នុងសួន** សេចក្ដីថា ទេវតាអ្នកស្ថិតនៅតាមសួនផ្កាឈើ និងសួនផ្លែឈើនោះ ៗ ។

បទថា **ទេវតាដែលស្ថិតនៅក្នុងព្រៃ** បានដល់ ទេវតាអ្នកស្ថិតនៅក្នុងព្រៃអន្ធវ័ន និងសុកគវ័នជាដើម ។

បទថា **រុក្ខទេវតា** បានដល់ ទេវតាដែលស្ថិតនៅត្រង់ដើមស្ដៅជាដើមដែលហួងហែងទុក ។

បទថា **ដើមឈើជាថ្នាំ ស្មៅ និងឈើធំក្នុងព្រៃជាដើម** សេចក្ដីថា ទេវតាបានស្ថិតនៅត្រង់ដើមឈើជាថ្នាំ មានដើមសម៉ និងកន្ទួតព្រៃជាដើម ត្រង់ស្មៅមានដើមត្នោត និងដូងជាដើម និងឈើធំក្នុងព្រៃ ដែលជាដើមឈើធំបំផុតក្នុងព្រៃ ។

បទថា **មនុស្សធ្វើការងារក្នុងព្រៃ** សេចក្ដីថា ពួកមនុស្សដែលត្រាច់ទៅធ្វើការងារណាមួយ បណ្ដាការងារ មានការរកឬស ប្រេត ជញ្ជូនឈើ និងឃ្វាលគោជាដើមក្នុងព្រៃ ។ បទថា **គប្បីក្រោកឡើង** បានដល់ គប្បីទំពារស៊ី ។ បទថា **វិលម្ពិនី** បានដល់ សំយុងចុះ ដូចកង់លេងក្នុងទីដែលត្រូវខ្យល់បក់ ។

បទថា **ជ្រៃនេះមានសម្ផស្សជាសុខ** សេចក្តីថា ដើមជ្រៃយ៉ាងនេះ សូម្បីពាល់ត្រូវក៏ជាសុខ សូម្បីសម្លឹងមើលក៏ឲ្យកើតសេចក្តីសុខ រមែងឲ្យកើតសេចក្តីពេញចិត្តសូម្បីព្រោះការមើល និងការពាល់ត្រូវវល្លិ៍ ថា ពួកក្មេងៗ របស់យើងនឹងមានរោងផឹក នឹងមានទីលេង យើងបានវិមានទីពីរហើយ ព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ។

បទថា **ធ្វើឲ្យជាប្រគាប** សេចក្តីថា គប្បីតាំងនៅដោយអាការស្រដៀងឆ័ត្រខាងលើមែកទាំងឡាយ ។

បទថា **សំយ៉ុងចួរ** សេចក្តីថា ឲ្យសំយ៉ុងចុះខាងក្រោម ។ ដើមជ្រៃនោះ កាលវារឡើងខាងលើ ក៏រុំដើមឈើទាំងអស់ទុកខាងក្រោមទៀត ។

បទថា **ទម្លាយ** សេចក្តីថា ព្រោះធ្វើឲ្យយ៉ាងនេះ បន្ទាប់ពីនោះដើមជ្រៃនេះក៏នឹងវារស្ទួរឡើងទៅតាំងពីគល់ តាមមែកដែលដុះឡើងទៅ ហើយរុំព័ទ្ធគ្រប់មែកទុក លុះដល់ចុងហើយ ក៏នឹងសំយុងចុះដោយទំនងនោះឯងទៀត និងវារឡើងទៅរួបដើមឈើទាំងអស់ទុក ឲ្យមែកទាំងអស់នៅខាងក្រោម ខ្លួនឯងនៅខាងលើ កាលខ្យល់បក់ ឬភ្លៀងធ្លាក់ ក៏នឹងទម្លាយខ្ទាត់ខ្ទាយទៅ វិមាននោះគប្បីតាំងនៅត្រឹមជន្លង់ប៉ុណ្ណោះ ត្រង់គល់ឈើនោះ រមែងមានវិមានដែលនៅលើមែកឈើ កាលមែកបាក់ហើយ បានទម្លាយត្រង់មែកនោះៗ កាលគ្រប់មែកបាក់

អស់ វិមានទាំងពួងក៏រមែងវិនាស ក៏វិមានដែលតាំងនៅលើដើមឈើ ក៏នឹងតាំងនៅត្រឹមតែគល់ឈើ ដរាបដែលនៅមិនទាន់វិនាសនេះ ជាវិមានដែលនៅលើមែកឈើ ។ ព្រោះដូច្នោះ កាលមែកទាំងពួងបាក់អស់ហើយ ទេវតាបានពកូនតូចឈរត្រង់ជន្ទត់ឈើ ហើយផ្ដើមទួញយំ ។

[១៥៨] បទថា **អ្នកមានជាតិប្រកបដោយរាគៈខ្លាំងក្លា** បានដល់ អ្នកមានរាគៈក្រាស់ជាសភាវៈ ។ បទថា **សោយទុក្ខ និងទោមនស្សដែលកើតពីរាគៈ** សេចក្ដីថា ព្រោះភាពជាអ្នកមានជាតិប្រកបដោយរាគៈខ្លាំងក្លា រមែងកាន់យកនិមិត្តក្នុងអារម្មណ៍ដែលឃើញហើយៗ ។ គ្រានោះ ពួកអាចារ្យ និងឧបជ្ឈាយ៍របស់លោក ដាក់ទណ្ឌកម្ម ភិក្ខុនោះ កាលធ្វើទណ្ឌកម្មរឿយៗ ក៏រមែងសោយទុក្ខទោមនស្ស ទើបមិនធ្វើការឈានកន្លងទៀតនោះឯង ។ សម្រាប់អ្នកមានជាតិប្រកបដោយទោសៈខ្លាំងក្លា រមែងកម្រើក ក៏ដោយហេតុត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ និងកាលគេចាប់ដៃជាដើម ស្និទ្ធស្នាលនឹងភិក្ខុកម្លោះ និងសាមណេរទាំងឡាយ ក៏រមែងសោយទុក្ខទោមនស្ស ព្រោះទណ្ឌកម្មជាបច្ច័យ ។

ចំណែកបុគ្គលដែលមានជាតិប្រកបដោយមោហៈ មិនកំណត់កិច្ចដែលធ្វើហើយ តាមដែលធ្វើហើយ ឬកិច្ចដែលមិនទាន់បានធ្វើ ដោយកិច្ចដែលនៅមិនទាន់បានធ្វើក្នុងព្រះសាសនានេះ រមែងឲ្យកិច្ចឃ្លៀងឃ្លាត សូម្បីគេក៏រមែង

សោយទុក្ខទោមនស្ស ព្រោះទណ្ឌកម្មជាបច្ច័យ ។

[១៥៩] ពាក្យថា **ជាអ្នកមិនមានជាតិប្រកបដោយរាគៈខ្លាំងក្លាជាដើម** គប្បីជ្រាបតាមន័យផ្ទុយគ្នាដែលពោលហើយ ។

សួរថា ក៏ព្រោះហេតុអ្វី ក្នុងលោកនេះបុគ្គលខ្លះ ទើបជាអ្នកមានរាគៈខ្លាំងក្លា បុគ្គលខ្លះទើបមិនមែនជាអ្នកមានរាគៈជាដើមខ្លាំងក្លា ? ឆ្លើយថា ព្រោះថា ក្នុងខណៈសន្សំកម្ម តាមច្បាប់របស់កម្ម សេចក្ដីលោភមានកម្លាំង សេចក្ដីមិនលោភមានកម្លាំងខ្សោយ សេចក្ដីមិនប្រទូសរ៉ាយ និងសេចក្ដីមិនវង្វេងមានកម្លាំង សេចក្ដីប្រទូសរ៉ាយ និងសេចក្ដីវង្វេងមានកម្លាំងខ្សោយ សេចក្ដីមិនលោភរបស់អ្នកនោះមានកម្លាំងខ្សោយ មិនអាចនឹងគ្របសង្កត់សេចក្ដីលោភបាន តែជាការមិនប្រទូសរ៉ាយ និងការមិនវង្វេងមានកម្លាំង អាចគ្របសង្កត់សេចក្ដីប្រទូសរ៉ាយ និងសេចក្ដីវង្វេងបាន ។ ព្រោះដូច្នោះ បុគ្គលនោះកើតដោយអំណាចបដិសន្ធិដែលកម្មនោះឲ្យផលហើយ រមែងជាអ្នកលោភ មានប្រក្រតីជាសុខ មិនក្រោធ មានបញ្ញា មានសេចក្ដីដឹងប្រៀបដោយពេជ្រ ។

ក៏ក្នុងខណៈសន្សំកម្ម សេចក្ដីលោភ និងសេចក្ដីប្រទូសរ៉ាយមានកម្លាំង សេចក្ដីមិនលោភ និងសេចក្ដីមិនប្រទូសរ៉ាយមានកម្លាំងខ្សោយ សេចក្ដីមិនវង្វេងមានកម្លាំង សេចក្ដីវង្វេងមានកម្លាំងខ្សោយ បុគ្គលនោះរមែងជាអ្នកលោភ និង

ជាអ្នកប្រទូសរ៉ាយ តាមន័យមុនទុំះឯង តែជាអ្នកមានបញ្ញា មានសេចក្ដីដឹង ដោយពេជ្រ ដូចព្រះទន្ដាភយត្ថេរៈ ។

ក្នុងខណៈសន្សំកម្ម សេចក្ដីលោភ សេចក្ដីមិនប្រទូសរ៉ាយ សេចក្ដីវង្វេង មានកម្លាំង ក្រៅពីនេះមានកម្លាំងខ្សោយ បុគ្គលនោះរមែងជាអ្នកលោភ និងល្ងង់ ខ្លៅ តាមន័យមុននោះឯង ជាអ្នកមានប្រក្រតីជាសុខ មិនក្រោធ ។

ក៏ក្នុងខណៈសន្សំកម្ម សេចក្ដីលោភ សេចក្ដីក្រោធ និងសេចក្ដីវង្វេង ទាំង ៣ មានកម្លាំង សេចក្ដីមិនលោភជាដើម មានកម្លាំងខ្សោយ បុគ្គលនោះ រមែងលោភ ប្រទូសរ៉ាយ និងវង្វេងតាមន័យមុននោះឯង ។

ក្នុងខណៈសន្សំកម្ម សេចក្ដីមិនលោភ សេចក្ដីប្រទូសរ៉ាយ និងសេចក្ដី វង្វេងមានកម្លាំង ក្រៅពីនេះមានកម្លាំងខ្សោយ បុគ្គលនោះ រមែងជាអ្នកមាន កិលេសតិច លុះឃើញអារម្មណ៍ជាទិព្វក៏មិនញាប់ញ័រ តាមន័យមុនទុំះឯង តែ ជាអ្នកប្រទូសរ៉ាយ និងមានបញ្ញាទន់ខ្សោយ ។

ក្នុងខណៈសន្សំកម្ម សេចក្ដីមិនលោភ មិនប្រទូសរ៉ាយ និងសេចក្ដី វង្វេងមានកម្លាំង ក្រៅពីនេះមានកម្លាំងខ្សោយ បុគ្គលនោះរមែងជាអ្នកមិនលោភ មានប្រក្រតីជាសុខ មិនក្រោធ តែជាអ្នកល្ងង់ខ្លៅ តាមន័យមុននោះឯង ។

ក្នុងខណៈសន្សំកម្ម សេចក្ដីមិនលោភ សេចក្ដីប្រទូសរ៉ាយ និងសេចក្ដី

មិនវាងវៃមានកម្លាំង ក្រៅពីនេះមានកម្លាំងខ្សោយ បុគ្គលនោះរមែងជាអ្នកមិនលោភ មានបញ្ញា តែជាអ្នកប្រទូសរ៉ាយ និងក្រោធ តាមន័យមុនទុំ៎ះឯង ។

ក្នុងខណៈសន្សំកម្មសូម្បីទាំង ៣ មានសេចក្តីមិនលោភជាដើម មានកម្លាំង សេចក្តីលោភជាដើម មានកម្លាំងខ្សោយ បុគ្គលនោះរមែងជាអ្នកមិនលោភ មិនប្រទូសរ៉ាយ និងមានបញ្ញា ដូចព្រះមហាសង្ឃរក្ខិតត្ថេរៈ សេចក្តីគ្រប់បទនៃបទទាំងពួង ងាយយល់នោះឯង ។

" ចប់អដ្ឋកថា ចូឡធម្មសមាទានសូត្រទី ៥ "

# អ ដ្ឋ ក ថា

## មហាធម្មសមាទានសូត្រទី ៦

[១៦០] មហាធម្មសមាទានសូត្រ មានបទផ្តើមថា **ឯវំមេ សុតំ** ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។

[១៦១] ក្នុងបទទាំងនោះ បទថា **ឯវំ កាមា** គឺ មានសេចក្តីត្រូវការយ៉ាងនេះ ។ បទថា **ឯវំ ឆន្ទា** គឺ មានសេចក្តីបង្អោនទៅយ៉ាងនេះ ។ បទថា **មានសេចក្តីប្រាថ្នាយ៉ាងនេះ** គឺ មានលទ្ធិយ៉ាងនេះ ។ បទថា **តត្រ** គឺ ក្នុងសេចក្តីចម្រើននៃអារម្មណ៍ដែលមិនគួរពេញចិត្ត និងក្នុងសេចក្តីសាបសូន្យទៅនៃអារម្មណ៍ដែលគួរពេញចិត្តនោះ ។ ពាក្យថា **មានព្រះមានព្រះភាគជាមូល** គឺ ឈ្មោះថា មានព្រះមានព្រះភាគជាឫសគល់ ព្រោះព្រះមានព្រះភាគទ្រង់ជាមូលនៃវត្ថុទាំងនេះ ។ មានពាក្យដែលពោលទុកថា បពិត្រព្រះអង្គ ! វត្ថុទាំងឡាយនេះ របស់ពួកខ្ញុំព្រះករុណាគ្រាដំបូង ព្រះកស្សបសម្មាសម្ពុទ្ធ ទ្រង់បានឲ្យកើតឡើងកាលព្រះអង្គបរិនិព្វានហើយ មិនមានសមណៈ ឬព្រាហ្មណ៍ដែលឈ្មោះថា ជាអ្នកអាចឲ្យធម៌ទាំងនេះកើតឡើងទៀតឡើយ អស់មួយចន្លោះព្រះពុទ្ធ តែព្រះមានព្រះភាគ ទ្រង់បានឲ្យធម៌ទាំងនេះរបស់ពួកខ្ញុំព្រះអង្គកើតឡើងហើយ ពួក

ខ្ញុំព្រះអង្គបានអាស្រ័យព្រះមានព្រះភាគដោយពិត ទើបយល់ទូទៅដល់ធម៌ គឺដឹងចំពោះធម៌ទាំងនេះបាន ព្រះអង្គ ! ព្រោះហេតុនេះ ធម៌របស់ពួកខ្ញុំព្រះអង្គទើបឈ្មោះថា មានព្រះមានព្រះភាគជាមូល ដោយប្រការដូច្នេះ ។ ពាក្យថា **មានព្រះមានព្រះភាគទ្រង់ជាអ្នកណែនាំ** គឺ ព្រះមានព្រះភាគទ្រង់ជាអ្នកណែនាំ អ្នកដឹកនាំ អ្នកបង្ហាញ ទាក់ទងនឹងរឿងរបស់ធម្មៈដោយពិត ។ ធម្មៈទាំងឡាយដែលព្រះអង្គទ្រង់តាំងឈ្មោះជាពួកៗ តាមសេចក្ដីពិត ទើបឈ្មោះថា មានព្រះមានព្រះភាគទ្រង់ជាអ្នកណែនាំ ។ ពាក្យថា **មានព្រះមានព្រះភាគជាទីពឹងអាស្រ័យ** បានដល់ ធម៌ទាំង ៤ ប្រការ មកកាន់គន្លងព្រះសព្វញ្ញុតញ្ញាណ រមែងចាត់ជាក្រុមរួមប្រជុំចុះព្រមក្នុងព្រះមានព្រះភាគ ម្យ៉ាងទៀត កាលដែលព្រះមានព្រះ-ភាគប្រថាប់អង្គុយជិតគល់មហាពោធិព្រឹក្ស កាលទឹងទ្រង់កាន់យកឈ្មោះជាពួកៗ តាមសេចក្ដីពិតរបស់ធម៌ទាំង ៤ ប្រការយ៉ាងនេះ គឺ ផស្សៈ មកដោយអំណាចបដិវេធ (ក៏ទ្រង់គិតថា) តថាគតជាអ្នកចែកធម៌ឈ្មោះណា (ហើយទ្រង់តាំងឈ្មោះថា) នោះឈ្មោះផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណមក (ក៏ទ្រង់គិតថា) តថាគតជាអ្នកចែកធម៌នោះឈ្មោះអ្វី (ហើយក៏ទ្រង់តាំងឈ្មោះថា) នោះឈ្មោះ វេទនា សញ្ញា សង្ខារ (ព្រោះអត្ថថា សោយអារម្មណ៍... ចាំអារម្មណ៍)... តាក់តែងអារម្មណ៍) នោះឈ្មោះវិញ្ញាណ ព្រោះអត្ថថា

ដឹងច្បាស់ ព្រះមានព្រះភាគ ទ្រង់យកធម៌មកចាត់ជាក្រុម ព្រោះដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា មានព្រះមានព្រះភាគជាទីពឹងអាស្រ័យ (គឺរួមជាពួកៗ បាន ដោយព្រះមានព្រះភាគ) ។ ពាក្យថា **ចូរជាក់ច្បាស់ចំពោះព្រះមានព្រះ-ភាគប៉ុណ្ណោះចុះ** បានដល់ សូមឲ្យសេចក្ដីរបស់បទភាសិតនេះ ចូរប្រាកដចំពោះព្រះមានព្រះភាគប៉ុណ្ណោះចុះ គឺ សូមឲ្យព្រះអង្គទ្រង់ឯង មេត្តាទ្រង់ប្រទានសម្ដែងឲ្យដល់ពួកខ្ញុំព្រះអង្គផងចុះ ។

[១៦២] ពាក្យថា **គប្បីសេព** គឺ គប្បីអាស្រ័យ ពាក្យថា **គប្បីសេពគប់** គឺ គប្បីចូលជិត ពាក្យថា **ដូចអ្នកមិនដឹងច្បាស់** គឺ ដូចបុថុជ្ជនដែលល្ងង់ខ្លៅ ។ ពាក្យថា **ដូចអ្នកដឹងច្បាស់** គឺ ដូចបណ្ឌិតដែលដឹង ។

[១៦៣] ព្រះមានព្រះភាគទ្រង់តាំងមាតិកា តាមបែបផែនខ្ពស់ឡើងសន្សើមៗ តាមលំដាប់ក្នុងសូត្រមុនថា **ភិក្ខុទាំងឡាយ មានការកាន់យកធម៌** តែក្នុងព្រះសូត្រនេះ ព្រះសាស្ដាទ្រង់តាំងមាតិកាតាមកិច្ចនៃធម៌ប៉ុណ្ណោះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ការប្រកាន់ធម៌** បានដល់ ការកាន់យកធម៌ មានការសម្លាប់សត្វជាដើម ។

[១៦៤] ពាក្យថា **អ្នកនៅក្នុងសេចក្ដីមិនដឹង** បានដល់ អ្នកប្រកបព្រមដោយសេចក្ដីមិនដឹង ។

[១៦៥] ពាក្យថា **អ្នកនៅក្នុងសេចក្ដីជីង** បានដល់ អ្នកប្រកបព្រម ដោយសេចក្ដីជីង គឺ អ្នកមានបញ្ញា ។

[១៦៦] វត្ថុទាំងបីនេះ គឺ មិច្ឆាចារ អភិជ្ឈា មិច្ឆាទិដ្ឋិ ក្នុងពាក្យ ទាំងនេះ គឺ ព្រមដោយទុក្ខខ្លះ ជាទុក្ខវេទនាដោយអំណាចចេតនាទាំងពីរ គឺ បុព្វចេតនា និងអបរចេតនា ។ ចំណែកចេតនាដែលឲ្យសម្រេចវៀបរយ ជា ចេតនាដែលប្រកបដោយសុខ ឬប្រកបដោយឧបេក្ខា ។ ចំណែកចេតនាដ៏សេស មានការសម្លាប់សត្វជាដើម ៧ ប្រការទៀត ជាទុក្ខវេទនា ដោយអំណាចវេទនា ទាំងបី ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីនេះ ទើបត្រាស់ថា ព្រមដោយ ទុក្ខខ្លះ ព្រមដោយទោមនស្សខ្លះ ដូច្នេះ ។ ក៏ឯទោមនស្សក្នុងព្រះពុទ្ធតម្រាស់ នេះ គប្បីយល់ថា ជាទុក្ខ ។

កាលអ្នកមកដល់ការស្វែងរក សុម្បីទុក្ខក្នុងផ្លូវកាយ ក៏រមែងត្រូវទាំង ក្នុងចំណែកខាងដើម និងខាងចុងដោយពិត ។

[១៦៧] វត្ថុបីយ៉ាងនេះ គឺ ការសម្លាប់សត្វ ការនិយាយពាក្យគ្រោត គ្រាត ព្យាបាទ ក្នុងបទនេះ គឺ ព្រមដោយសុខខ្លះ ជាសុខវេទនា ដោយ អំណាចចេតនាពីរយ៉ាង គឺ បុព្វចេតនា និងអបរចេតនា ចំណែកចេតនាដែល ឲ្យសម្រេចវៀបរយ ជាចេតនាដែលប្រកបដោយទុក្ខ ដ៏សេស ៧ យ៉ាងទៀត

រមែងជាសុខវេទនា ដោយអំណាចចេតនាគ្រប់ទាំង ៣ ។ ក៏ឯសោមនស្សនុ៎ះឯង ក៏គប្បីយល់ថា សុខក្នុងទីនេះ ។ ឬចំពោះអ្នកដែលប្រកបព្រមដោយផោដ្ឋព្វារម្មណ៍ដែលគួរពេញចិត្ត សុម្បីសុខតាមផ្លូវកាយ ក៏រមែងមានក្នុងចំណែកខាងដើម និងចំណែកខាងចុងដោយពិត ។

[១៦៨] ក្នុងការកាន់យកធម៌ទីបីនេះឯង បុគ្គលខ្លះក្នុងលោកនេះ ជាអ្នករកត្រី (អ្នកប្រមង់) ឬជាព្រានម្រឹគ អាស្រ័យការសម្លាប់សត្វប៉ុណ្ណោះ ចិញ្ចឹមជីវិត ភិក្ខុដែលនៅក្នុងតំណែងជាទីគោរពរបស់គេ សម្តែងទោសការសម្លាប់សត្វ និងអានិសង្សការវៀរចាកការសម្លាប់សត្វហើយ ឲ្យសិក្ខាបទដល់គេ ដែលជាអ្នកមិនត្រូវការឡើយ កាលគេនឹងទទួល គេក៏រមែងទទួលទាំងដែលជាទុក្ខទោមនស្សតែម្យ៉ាង ។ កាលកន្លងមកពីរបីថ្ងៃ កាលគេមិនអាចរក្សាបាន ក៏ជាទុក្ខទៀត បុព្វចេតនា និងអបរចេតនារបស់គេ រមែងជាគូគ្នាប្រកបដោយទុក្ខតែម្យ៉ាង ។ ចំណែកចេតនាដែលឲ្យសម្រេចរៀបរយ ទៅជាមួយគ្នានឹងសុខខ្លះ ទៅជាមួយគ្នានឹងឧបេក្ខាខ្លះ ។ ក្នុងទីគ្រប់កន្លែងគប្បីយល់សេចក្តីយ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់សំដៅយកចេតនា ទាំងដែលជាចំណែកខាងដើម និងចំណែកខាងចុងនេះឯង ដោយប្រការដូច្នេះហើយ ទើបត្រាស់ថា ព្រមជាមួយទុក្ខខ្លះ ជាមួយទោមនស្សខ្លះ ដូច្នេះ ។ គប្បីជ្រាបថា ទោមនស្សនុ៎ះឯងជាទុក្ខ ។

[១៦៩] ក្នុងការកាន់យកធម៌ប្រការទីបួន ចេតនាដែលជាចំណែកខាងដើម ចំណែកខាងចុង និងចេតនាដែលឲ្យសម្រេចរៀបរយគ្រប់ទាំងបី ក្នុងបទគ្រប់ទាំង ១០ រមែងប្រកបដោយសុខដោយពិត , ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីនោះ ទើបបានត្រាស់ថា ព្រមដោយសុខខ្លះ ព្រមដោយសោមនស្សខ្លះ ក៏សោមនស្សនុ៎ះឯង គប្បីជ្រាបថា សុខក្នុងទីនេះ ។

[១៧០] ពាក្យថា **តិត្តកាលាពុ** ប្រែថា ននោងព្រៃ ។ ពាក្យថា **លាយដោយថ្នាំពិស** បានដល់ លាយជាមួយនឹងថ្នាំពិសដែលមានកម្លាំង ។ ពាក្យថា **មិនគាប់ចិត្ត** គឺ មិនពេញចិត្ត មិនធ្វើសេចក្ដីត្រេកអរ ។ ពាក្យថា **នឹងដល់** គឺ នឹងសម្រេច ។ ពាក្យថា **មិនពិចារណាហើយគប្បីផឹក** គឺ ផឹកមិនពិចារណា ។

[១៧១] ពាក្យថា **ភាជន៍ទឹកផឹក** គឺ ភាជនៈពេញប្រៀបទៅដោយគ្រឿងផឹកដ៏ឆ្ងាញ់គួរផឹក ។ ពាក្យថា **សម្បូរណ៍ដោយពណ៌** គឺ ជាភាជនៈប្រកបដោយពណ៌នៃគ្រឿងផឹកជាដើម ដែលអ្នកនិយាយយ៉ាងនេះថា ភាជនៈដែលសម្បូរណ៍ដោយគ្រឿងផ្សំដែលដាក់ទុកហើយ ។ ពាក្យថា **នឹងពេញចិត្ត** បានដល់ ថ្នាំពិសដែលមានកម្លាំងនោះ រមែងជាការដាក់ទុកហើយក្នុងគ្រឿងផឹកណាៗ រមែងញ៉ាំងរសនៃគ្រឿងផឹកនោះៗ ឯង ព្រោះហេតុនោះទើបពោលថា នឹងពេញចិត្ត ។

[១៧២] ពាក្យថា **ទឹកមូត្រស្អុយ** ក៏គឺ ទឹកមូត្រនុ៎ះឯង ។ ដូចសេចក្ដីថា រាងកាយរបស់មនុស្សយើងសូម្បីមានពណ៌ដូចមាស ក៏នៅតែត្រូវហៅថា កាយស្អុយនុ៎ះឯង និងវល្លិ៍ផោម សូម្បីទើបតែកើតក្នុងថ្ងៃនោះ ក៏រមែងហៅថា វល្លិ៍ផោមនុ៎ះឯង យ៉ាងណា , ទឹកមូត្រថ្មីៗ ដែលត្រងយកទុក ក្នុងពេលក្លាម នោះ ក៏ជាទឹកមូត្រនុ៎ះឯង យ៉ាងនោះ ។ ពាក្យថា **ចូរជាសុខ** គឺ ចូរជាអ្នក មានសេចក្ដីសុខ គ្មានរោគ មានសម្បុរដូចមាស ។

[១៧៣] ពាក្យថា **ទឹកដោះជូរ ទឹកឃ្មុំ** គឺ ទឹកដោះជូរដែលបរិសុទ្ធិ និងទឹកឃ្មុំដែលផ្អែមឆ្ងាញ់ ។ ពាក្យថា **លាយឡំជាមួយគ្នា** បានដល់ លាយចូល ជាមួយគ្នា ។ ពាក្យថា **ដល់គេនោះ** គឺ គប្បីពេញចិត្តដល់គេ អ្នកផឹកភេសជ្ជៈ ដែលមានរសផ្អែមប្អូនយ៉ាង យ៉ាងណា ការផឹកដែលលាយដោយរោគយ៉ាងនេះ គប្បី (ធ្វើឲ្យ) កើតរោគមួល ថ្នាំរបស់គេធ្វើឲ្យអាហាររឹង បន្ទោបង់មិនចេញ ។ (ឬទ្ធិថ្នាំធ្វើឲ្យចុកពោះ បន្ទោបង់មិនចេញ) ចំណែកថ្នាំដែលផ្សំដោយល្អ ថ្នាំរបស់ គេនេះ ខាងក្រោយមកក៏ធ្វើឲ្យរាងកាយត្រជាក់ស្រួល ។

[១៧៤] ពាក្យថា **អណ្ដែតទៅ** គឺ អណ្ដែតខ្ពស់ឡើង គឺ មិនមាន ពពក សំដៅសេចក្ដីថា ពពកនៅឆ្ងាយ ។ ពាក្យថា **ប្រាសចាកវលាហកៈ** គឺ ពពករសាត់ទៅហើយ ។ ពាក្យថា **ទេវៈ** បានដល់ អាកាស ។ ពាក្យថា

សេចក្ដីងងឹតទៅក្នុងអាកាស គឺ សេចក្ដីងងឹតក្នុងអាកាស ។ ពាក្យថា **បរប្បវាទរបស់សមណព្រាហ្មណ៍ចំណែកច្រើន** បានដល់ វាទៈរបស់បុគ្គលពួកដទៃដែលបានដល់ សមណព្រាហ្មណ៍ចំណែកធំ ។ ពាក្យថា **បៀតបៀនក្រៃលែង** បានដល់ សម្លាប់ ។ ពាក្យថា **បំភ្លឺ បញ្ចេញពន្លឺ និងរុងរឿង** បានដល់ ពេលថ្ងៃក្នុងសរទៈរដូវ ព្រះអាទិត្យរមែងបញ្ចេញពន្លឺ គឺ បញ្ចេញពន្លឺក្ដៅថែស ស្វាងស្វៃ ។ ក៏ឯសូត្រនេះ ពួកទេវតាស្រឡាញ់ ប្រាថ្នាពេញចិត្តហួសប្រមាណ ។

ដូចមានរឿងតទៅនេះ ៖

មានដំណាលមកថា ទិសខាងត្បូង ក្នុងហត្ថិកោគជនបទ មានវត្តសង្គរត្រង់ទ្វាររោងអាហាររបស់វត្តនោះ មានទេវតាស្ថិតនៅត្រង់ដើមសង្ឃរ ពេលយប់បានស្ដាប់ភិក្ខុកម្លោះមួយរូបកំពុងស្វាធ្យាយព្រះសូត្រនេះ ដោយទំនងសូត្រជាបទ ទើបឲ្យសាធុការ ។

ភិក្ខុកម្លោះ. នុ៎ះជាអ្នកណា

ទេវតា. ខ្ញុំជាទេពធីតាស្ថិតនៅត្រង់ដើមឈើនេះឯង លោកម្ចាស់

ភិក្ខុកម្លោះ. ចុះទេពធីតាជ្រះថ្លាក្នុងអ្វី គឺ ក្នុងសំឡេង ឬក្នុងសូត្រ?

ទេវតា. លោកម្ចាស់ដ៏ចម្រើន អ្នកណាៗ ក៏មានសំឡេង ខ្ញុំជ្រះថ្លាក្នុងសូត្រ , ក្នុងថ្ងៃដែលព្រះសាស្ដាទ្រង់ប្រថាប់ក្នុងកណ្ដាលវត្តជេតពន និង

ក្នុងថ្ងៃនេះ មិនមានសេចក្តីប្លែកគ្នា សូម្បីតែព្យញ្ជនៈមួយ ។

ភិក្ខុកម្ពោះ. ទេពធីតា ចុះក្នុងថ្ងៃដែលព្រះសាស្តាត្រាស់ ទេពធីតាបាន ឮឬ ។

ទេវតា. ករុណាលោកម្ចាស់

ភិក្ខុកម្ពោះ. តើទេពធីតាឈរស្តាប់នៅទីណា

ទេវតា. លោកម្ចាស់ ខ្ញុំទៅវត្តជេតពន តែកាលពួកទេវតាជាអ្នកបុណ្យ ច្រើន សក្តិធំនាំគ្នាមក , ខ្ញុំមិនបានឱកាស ទើបឈរស្តាប់ក្នុងទីនេះឯង ។

ភិក្ខុកម្ពោះ. ឈរទីនេះ នឹងបានឮសំឡេងព្រះសាស្តាឬ ទេពធីតា ។

ទេវតា. ចុះលោកម្ចាស់ ឮសំឡេងខ្ញុំព្រះករុណាទេ

ភិក្ខុកម្ពោះ. អាត្មាឮ ទេពធីតា

ទេវតា. ដូចគ្នានឹងវេលាអន្ទ័យនិយាយខាងត្រចៀកស្តាំ ករុណាលោក ម្ចាស់ ។

ភិក្ខុកម្ពោះ. ទេពធីតា ! ចុះនាងឃើញរូបព្រះសាស្តាទេ

ទេវតា. ខ្ញុំយល់ថា ព្រះសាស្តាទតព្រះនេត្រមើលខ្ញុំកំពង់ស្តាប់នោះឯង សឹងតែតាំងខ្លួនមិនជាប់ លោកម្ចាស់ ។

ភិក្ខុកម្ពោះ. ចុះទេពធីតាមានគុណពិសេសកើតឡើងខ្លះទេ ។

ទេពធីតា ក៏បាត់ទៅក្នុងទីនោះឯង បានឮថា ថ្ងៃនោះទេវអង្គនេះ តាំងនៅក្នុងសោតាបត្តិផល ។ ទេវតាទាំងឡាយស្រឡាញ់ពេញចិត្តព្រះសូត្រនេះ ដូចដែលពោលមកនេះគ្រប់ៗ គ្នា ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

" ចប់អដ្ឋកថា មហាធម្មសមាទានសូត្រ ទី ៦ "

# អ ដ្ឋ ក ថា

## វីមំសកសូត្រទី ៧

[១៧៥] *វីមំសកសូត្រ មានពាក្យចាប់ផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

[១៧៦] *បណ្ដាបទទាំងនោះ បទថា* ***អ្នកសាកសួរហើយ*** *សេចក្ដីថា អ្នកសាកសួរមាន ៣ គឺ អ្នកសាកសួរក្នុងអត្ថ អ្នកសាកសួរក្នុងសង្ខារ អ្នកសាកសួរក្នុងព្រះសាស្ដា ។ ក្នុងអ្នកសាកសួរទាំងនោះ អ្នកសាកសួរអត្ថ មកហើយក្នុងបទនេះថា លោកដ៏មានអាយុ មនុស្សទាំងឡាយអ្នកឆ្លាត រមែងជាអ្នកសាកសួរ ។ អ្នកសាកសួរក្នុងសង្ខារ មកហើយក្នុងបទនេះថា ត្រូវហើយ ដោយពាក្យថា អានន្ទ កាលណាភិក្ខុជាអ្នកឆ្លាតក្នុងធាតុ ឆ្លាតក្នុងអាយតនៈ ឆ្លាតក្នុងបដិ-ច្ចសមុប្បាទ និងជាអ្នកឆ្លាតក្នុងឋានៈ និងមិនមែនឋានៈ អានន្ទ ដោយហេតុប៉ុណ្ណោះឯង ជាភិក្ខុអ្នកឆ្លាត រមែងជាអ្នកសាកសួរ ។ ចំណែកអ្នកឆ្លាតក្នុងព្រះសាស្ដា លោកបំណងយកក្នុងព្រះសូត្រនេះ ។*

*បទថា* ***ទំនាមនៃចិត្ត*** *សេចក្ដីថា វារៈនៃចិត្ត គឺ ការកំណត់ចិត្ត បទថា* ***តាមស្វែងរក*** *សេចក្ដីថា ស្វែងរក គឺ សម្លឹងរក បានដល់ ពិចារណារក ។*

បទថា ដើម្បីដឹងច្បាស់ដោយប្រការដូច្នេះ សេចក្តីថា ដើម្បីប្រយោជន៍ដឹងច្បាស់យ៉ាងនេះ ។

[១៧៧] ព្រះមានព្រះភាគ ទ្រង់សម្តែងការចូលទៅអាស្រ័យកល្យាណមិត្ត ក្នុងពាក្យនេះថា ភិក្ខុគប្បីស្វែងរកព្រះតថាគតក្នុងហេតុទាំង ២ ព្រោះថា ព្រះតថាគតនេះ ឈ្មោះថា ជាទីពឹង គឺ កល្យាណមិត្តដ៏ធំ គប្បីជ្រាបសេចក្តីដែលព្រះតថាគតនោះ ជាកល្យាណមិត្តយ៉ាងធំក្រៃលែងនេះ ។ សម័យមួយ ព្រះអានន្ទគិតថា ព្រហ្មចរិយពាក់កណ្តាលមានដោយអានុភាពខ្លួន ពាក់កណ្តាលមានបានដោយអានុភាពកល្យាណមិត្ត ហើយមិនអាចនឹងវិនិច្ឆ័យតាមធម្មតារបស់ខ្លួនបាន ទើបចូលទៅគាល់ព្រះមានព្រះភាគទូលសួរថា ព្រះអង្គ ពាក់កណ្តាលនៃព្រហ្មចរិយៈនេះ គឺ ភាពជាអ្នកមានមិត្តល្អ ១ ភាពជាអ្នកមានសម្លាញ់ល្អ ១ ភាពជាអ្នកបង្អោនចូលទៅក្នុងមិត្តដែលល្អ ១ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ! អ្នកកុំពោលយ៉ាងនេះឡើយៗ អានន្ទ ព្រហ្មចរិយៈទាំងអស់នេះ គឺ ភាពជាអ្នកមានមិត្តល្អ ១ ភាពជាអ្នកមានសម្លាញ់ល្អ ១ ភាពជាអ្នកបង្អោនទៅក្នុងមិត្តល្អ ១ អានន្ទ ហេតុនោះ ភិក្ខុអ្នកមានមិត្តល្អ ១ ភាពជាអ្នកបង្អោនទៅក្នុងមិត្តល្អ គប្បីប្រាថ្នាបានចំពោះ អ្នកនឹងចម្រើនធ្វើឲ្យច្រើននូវមគ្គមានអង្គ ៨ ដែលជារបស់ព្រះអរិយៈ យ៉ាងណា អានន្ទ ក៏ភិក្ខុដែលមានកល្យាណមិត្ត

។ល។ ចម្រើន ធ្វើឲ្យច្រើននូវមគ្គមានអង្គ ៨ ដែលជារបស់ព្រះអរិយៈ ។ អានន្ទ ភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនសម្មាទិដ្ឋិ ។ល។ ចម្រើនសម្មាសមាធិ ដែលអាស្រ័យវិវេក ។ អានន្ទ យ៉ាងនេះឯង ភិក្ខុដែលមានកល្យាណមិត្ត ។ល។ ធ្វើឲ្យច្រើន អានន្ទ ហេតុនេះ គប្បីជ្រាបដោយទំនងនេះ ដូចជាព្រហ្មចរិយៈនេះទាំងអស់ គឺ ភាពជាអ្នកមានមិត្តល្អ ១ ភាពជាអ្នកមានសម្លាញ់ល្អ ១ ភាពជាអ្នកបង្អោនទៅក្នុងមិត្តល្អ ១ អានន្ទ ក៏សត្វទាំងឡាយ អ្នកមានការកើតជាធម្មតា អាស្រ័យតថាគតដែលជាកល្យាណមិត្ត រមែងរួចផុតពីជាតិ ។ សត្វទាំងឡាយអ្នកមានសេចក្តីចាស់ជាធម្មតា ។ល។ មានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា រមែងរួចផុតពីសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ សេចក្តីទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ។

ព្រះមានព្រះភាគ សូម្បីកាលនឹងត្រាស់សេចក្តីដល់ព្រមដោយអង្គក្នុងខាងក្រៅដល់ភិក្ខុទាំងឡាយ ទើបត្រាស់ថា "ភិក្ខុទាំងឡាយ កាលធ្វើវត្ថុក្នុងខាងក្រៅថាជាអង្គហើយ យើងមិនពិចារណាឃើញអង្គដទៃ សូម្បីត្រឹមតែមួយដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំក្រៃលែងយ៉ាងនេះ ដូចភាពជាអ្នកមានមិត្តល្អនេះ ភិក្ខុទាំងឡាយ ភាពជាអ្នកមានមិត្តល្អ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏

ធំ ។ សូម្បីកាលនឹងត្រាស់វត្តបដិបត្តិជាគ្រឿងជុសខាត់កិលេស ដល់ព្រះមហា-ចុន្ទៈ ទើបត្រាស់ថា ភិក្ខុទាំងឡាយ គួរធ្វើសេចក្តីជុសខាត់ថា បុគ្គលពួកដទៃនឹងមានអ្នកអាក្រក់ជាមិត្ត ពួកយើងនឹងមានមិត្តដែលល្អ ។

សូម្បីកាលនឹងត្រាស់ធម៌ សម្រាប់អប់រំបន្ទំវិមុត្តិដល់ព្រះមេឃិយត្ថេរ ទើបត្រាស់ធម៌ជាគ្រឿងចូលទៅអាស្រ័យកល្យាណមិត្ត ឲ្យវិសេសនោះឯងថា មេឃិយៈ ធម៌ទាំង ៥ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចាស់ក្លានៃចេតោវិមុត្តិដែលមិនទាន់ចាស់ក្លា ៥ យ៉ាង តើដូចម្តេច ? គឺ ម្នាលមេឃិយៈ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកមានកល្យាណមិត្ត ។

សូម្បីកាលនឹងប្រទានឱវាទជាគ្រឿងពិចារណារឿយៗ ដល់ព្រះរាហុល-ត្ថេរបិយបុត្រ ទើបត្រាស់ធម៌ជាគ្រឿងចូលទៅអាស្រ័យកល្យាណមិត្តនុ៎ះឯង មុនធម៌ទាំងអស់ថា ។ អ្នកចូរសេពគប់កល្យាណមិត្ត ទីដេក ទីអង្គុយ ទីស្ងាត់កន្លែងដែលស្ងាត់ប្រាសចាកសំឡេងគឹកកង អ្នកចូរជាអ្នកដឹងប្រមាណក្នុងការបរិភោគ ។ អ្នកកុំមានធ្វើសេចក្តីប្រាថ្នាក្នុងបច្ច័យទាំងនេះ គឺ ចីវរ បិណ្ឌបាត បច្ច័យ គឺ ទីដេក និងទីអង្គុយ អ្នកចូរកុំមកកាន់លោកនេះទៀត ។ ដែលឈ្មោះថា ធម៌ជាគ្រឿងចូលទៅអាស្រ័យកល្យាណមិត្តនេះ ជាធម៌មានគុណច្រើន យ៉ាងនេះ ។

កាលទ្រង់សម្ដែងធម៌សូម្បីក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ទើបទ្រង់ប្រារព្ធទេសនាថា ភិក្ខុទាំងឡាយគប្បីស្វែងរកព្រះតថាគតក្នុងវត្ថុទាំង ២ អធិប្បាយថា ភិក្ខុដែលឆ្លាត ចូរសម្លឹងរក គឺ ស្វែងរកព្រះតថាគតក្នុងវត្ថុទាំងពីរ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់បន្លឺសីហនាទថា កិច្ចដោយការគិតយ៉ាងនេះថា ព្រះពុទ្ធទ្រង់មានជាតិជាធំ ដល់ព្រមដោយលក្ខណៈ ព្រះរូបល្អគួរសរសើរ មានព្រះកិត្តិយស ដែលគេដឹងថា សំខាន់យ៉ាងក្រៃលែង ឬយើងអាស្រ័យអ្នកនេះហើយ នឹងបានបច្ច័យ មានចីវរជាដើម ហើយនៅអាស្រ័យយើងមិនមាន ចំណែកបុគ្គលណាមកកំណត់យ៉ាងនេះថា ព្រះពុទ្ធនេះសមជាជាសាស្ដា ដែលធ្វើនាទីសាស្ដាឲ្យសម្រេចដល់យើងបាន បុគ្គលនោះចូរសេពគប់នឹងតថាគតចុះ ។ ឈ្មោះថា ការបន្លឺសីហនាទរបស់ព្រះពុទ្ធ ក្លាយជាព្រះសូត្រ ។

ឥឡូវនេះ កាលនឹងទ្រង់សម្ដែងវត្ថុទាំងពីរនោះ ព្រះមានព្រះភាគទើបត្រាស់ថា ដែលគប្បីដឹងច្បាស់ដោយភ្នែក និងត្រចៀកក្នុងធម៌នោះ មារយាទដែលប្រព្រឹត្តទៅផ្លូវកាយរបស់ព្រះសាស្ដា ឈ្មោះថា ធម៌ដែលគប្បីដឹងច្បាស់ដោយភ្នែករបស់អ្នកសាកសួរ មារយាទដែលប្រព្រឹត្តទៅផ្លូវវាចា ឈ្មោះថា ធម៌ដែលគប្បីដឹងច្បាស់ដោយត្រចៀក ។ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងអាការ

ដែលទីងគប្បីសាកសួរក្នុងធម៌ទាំងនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា វត្ថុពួកណាសៅហ្មងព្រមហើយជាដើម ។ បណ្ដាបទទាំងនោះ បទថា សៅហ្មងព្រមហើយ បានដល់ ប្រកបដោយកិលេស និងវត្ថុទាំងនោះ នឹងគប្បីដឹងច្បាស់ដោយភ្នែក និងត្រចៀកមិនបាន ។ ដូចកាលទឹករំជើបរំជួល ពពុះទឹកផុសឡើង បុគ្គលរមែងដឹងថា ខាងក្នុងមានត្រី យ៉ាងណា បុគ្គលឃើញ និងបានដឹងមារយាទផ្លូវកាយ និងផ្លូវវាចា របស់អ្នកធ្វើការសម្លាប់សត្វ ឬពោលកុហកជាដើម ក៏រមែងដឹងថា ចិត្តដែលញ៉ាំងអកុសលធម៌ មានការសម្លាប់ជាដើម តាំងឡើងសៅហ្មងព្រមហើយ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះថា ចំពោះអ្នកដែលមានចិត្តសៅហ្មង សូម្បីមារយាទផ្លូវកាយ និងផ្លូវវាចា ក៏ឈ្មោះថា សៅហ្មងតាមទៅផង ។

បទថា **វត្ថុទាំងនោះមិនមានដល់ព្រះតថាគត** សេចក្ដីថា គេរមែងដឹងយ៉ាងនេះថា វត្ថុទាំងនោះរបស់ព្រះតថាគតមិនមាន គឺ រកមិនបាន ។ ក៏ព្រោះវត្ថុទាំងនោះមិនមានពិតប្រាកដមែន គឺ ព្រោះមិនបានបិទបាំងទុក ទើបរកវត្ថុទាំងនោះមិនបាន ។ ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់បវារណាពួកភិក្ខុក្នុងវត្ថុពួកនេះ ក្នុងថ្ងៃមួយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះឥឡូវនេះ តថាគតនឹងបវារណាចំពោះពួកអ្នកថា ពួកអ្នក រមែងមិនតិះដៀល

មារយាទផ្លូវកាយ និងផ្លូវវាចារបស់តថាគតខ្វះឬទេ កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្រ បានក្រោកឡើងចាកអាសនៈ ធ្វើសំពត់ចីវរឆៀងស្មាម្ខាង ផ្គងអញ្ជលីទៅកាន់ទិសព្រះមានព្រះភាគប្រថាប់ បានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គនឹងមិនតិះដៀលកម្មណាៗ ដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវវាចារបស់ព្រះ-មានព្រះភាគទេ ព្រះអង្គ , ព្រះមានព្រះភាគ ទ្រង់ឲ្យមគ្គដែលមិនទាន់កើតឡើងឲ្យកើតឡើង ទ្រង់ឲ្យដឹងមគ្គដែលពួកបុគ្គលណាៗ មិនដឹង ទ្រង់ប្រាប់មគ្គដែលបុគ្គលណាៗ ប្រាប់មិនបាន ទ្រង់ជាអ្នកដឹងផ្លូវ ទ្រង់ជាអ្នកដឹងច្បាស់នូវផ្លូវ ទ្រង់ជាអ្នកឆ្លាតក្នុងផ្លូវ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ពួកសាវកជាអ្នកដំណើរទៅតាមមគ្គ ខាងក្រោយមកតាមព្រមហើយ ។

ព្រះមានព្រះភាគទ្រង់មានមារយាទផ្លូវកាយ និងផ្លូវវាចាហ្មត់ចត់យ៉ាងនេះ ។ បានឮថា សូម្បីឧត្តរមាណពគិតថា យើងនឹងឃើញទោសណាៗ ដែលមិនគួរគ្រេកអរក្នុងកាយទ្វារ និងវចីទ្វាររបស់ព្រះតថាគត ។ ហើយជាប់តាមនៅ ៧ ខែ ក៏មិនបានឃើញសូម្បីបន្តិចបន្តួច ឬថា ឧត្តរមាណពនេះជាមនុស្សនឹងឃើញទោសអ្វីដែលមិនគួរគ្រេកអរក្នុងកាយទ្វារ និងវចីទ្វាររបស់ព្រះតថាគតដែលជាព្រះពុទ្ធ សូម្បីទេវបុត្តមារ ក៏ជាប់តាមតាំងពីព្រះមានព្រះភាគ កាលនៅ

ជាព្រះពោធិសត្វស្តេចចេញមហាភិនេស្រ្កមណ៍ ស្វែងរកហើយរហូតអស់ ៦ ឆ្នាំ ក៏មិនបានឃើញទោសណាៗ ដែលមិនគួរព្រួ ដោយទីបំផុតសូម្បីត្រឹមតែសេចក្តីបរិវិតក្កផ្លូវចិត្ត ។ មារគិតហើយថា បើយើងនឹងឃើញអកុសលសូម្បីត្រឹមតែហេតុដែលព្រះពោធិសត្វនោះត្រិះរិះហើយ ព្រោះទោសនោះឯង យើងនឹងវាយព្រះពោធិសត្វនោះត្រង់សិរសៈ ហើយចៀសចេញទៅ ។ មារនោះមិនបានឃើញឡើយរហូតអស់ ៦ ឆ្នាំ ជាប់តាមព្រះមានព្រះភាគអស់ ១ ឆ្នាំ ទៀត ក៏មិនបានឃើញទោសណាៗ ទើបថ្វាយបង្គំក្នុងវេលាជាទីទៅ ទើបពោលគាថានេះថា បពិត្រព្រះគោតមអ្នកជាមហាវីរៈ មានបញ្ញាច្រើន អ្នករុងរឿងដោយព្រះឫទ្ធិ ដោយយស អ្នកទ្រង់ឈានកន្លងពៀរវេរភ័យទាំងពួង ខ្ញុំព្រះអង្គសូមថ្វាយបង្គំព្រះបាទ ដូច្នេះ ហើយចៀសចេញទៅ ។

បទថា **ប្រឡូកប្រឡំគ្នា** សេចក្តីថា លាយគ្នាយ៉ាងនេះ គឺ វេលាខ្លះក៏ខ្មៅ វេលាខ្លះក៏ស ។ បទថា **ស** បានដល់ បរិសុទ្ធិមិនមានកិលេស ។ បទថា **មាននៅ** សេចក្តីថា ធម៌ដែលផ្លូវផង់មានហើយ គឺ មិនបាននៅ ពិតហើយព្រះតថាគត រមែងមានមារយាទផ្លូវកាយជាដើមបរិសុទ្ធិ ។ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុទាំងឡាយ ៤ យ៉ាង ទាំងនេះ ដែលតថាគតមិនត្រូវការប្រយ័ត្នប្រយែងចំពោះ ៤ យ៉ាង អ្វីខ្លះ គឺ ភិក្ខុទាំងឡាយ ព្រះតថា-

គតជាអ្នកមានមារយាទផ្លូវកាយបរិសុទ្ធិ ។ ព្រះតថាគតទ្រង់មិនមានកាយទុច្ចរិត ដែលតថាគតត្រូវប្រយ័ត្នប្រយែងចំពោះថា ភិក្ខុទាំងឡាយ តថាគតទ្រង់មាន មារយាទផ្លូវវាចាបរិសុទ្ធិ មានមារយាទផ្លូវចិត្តបរិសុទ្ធិ មានអាជីវបរិសុទ្ធិ តថា-គតមិនមានមិច្ឆាជីវៈ ដែលតថាគតនឹងត្រូវប្រយ័ត្នប្រយែងចំពោះថា សូមឲ្យ អ្នកដទៃកុំបានដឹងមិច្ឆាជីវៈរបស់យើងឡើយ ។ ប្រការថា ធម៌ដែលជាកុសលនេះ បានដល់ សីលមានអាជីវៈជាទី ៨ ។ អធិប្បាយថា លោកដ៏មានអាយុ ចូរស្វែង រកយ៉ាងនេះថា ព្រះសាស្តាទ្រង់ចូលរហូតអស់វេលាយូរ ទ្រង់សម្បូរណ៍ដោយ សីលនេះ តាំងពីកាលដ៏យូរក្រៃលែង ឬថា ទ្រង់ចូលវេលាតិចតួច ទើបទ្រង់ ចូលកាលថ្ងៃម្សិលមិញ ស្អែកនេះ ឬថ្ងៃខានស្អែកនេះ ។ ព្រោះថា ពួកអ្នកខ្លះ នៅក្នុងទីមួយ បានធ្វើកម្មជាគ្រឿងចិញ្ចឹមជីវិតដែលខុសយ៉ាងច្រើន កម្មនោះ រមែងប្រាកដក្នុងការកន្លងវេលានោះ រមែងប្រាកដហើយ លោកកាលទៅ ពួក អ្នកស្រុកជាយដែន ឬត្រើយមហាសមុទ្រកន្លែងណាមួយ ហើយឲ្យធ្វើបណ្ណសាលា នៅដូចអ្នកនៅព្រៃ ។ ពួកមនុស្សកើតការលើកតម្កើង ហើយថ្វាយបច្ច័យដល់ លោក ។ ពួកភិក្ខុដែលនៅស្រុកក្រៅ ឃើញការរស់នៅរបស់លោក ទើប កំណត់ថា បុគ្គលនេះរីករាយហួសប្រមាណ នេះជាអ្នកណាហ្ន៎ ។ បានដឹងហើយ ថា ពួកភិក្ខុដែលធ្វើមិច្ឆាជីវឈ្មោះឯណោះ ក្នុងទីឯណោះចៀសទៅ ហើយអន្ទុយ

ប្រឹក្សាគ្នាថា ពួកយើងមិនអាចនឹងធ្វើឧបោសថ ឬបវារណារួមជាមួយភិក្ខុនេះបាន ទើបធ្វើកម្មយ៉ាងណាមួយក្នុងកម្ម មានឧក្ខេបនីយកម្មជាដើម ប្រកបដោយធម៌ ។ ព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ដើម្បីទ្រង់ឲ្យភិក្ខុទាំងនោះសាកសួរដល់វត្តបដិបត្តិដែលបិទបាំងបែបនោះថា មាន ឬមិនមាន ។

ប្រការថា **រមែងដឹងយ៉ាងនេះ** សេចក្ដីថា ដឹងថា ទ្រង់ចូលរហូតអស់វេលាយូរ មិនមែនទ្រង់ចូលក្នុងវេលាបន្តិចបន្តួច ។ ក៏សីលដែលមានអាជីវៈជាគម្រប់ ៨ របស់ព្រះតថាគត ដែលទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណក្នុងពេលឥឡូវនេះ គប្បីបរិសុទ្ធិរហូតអស់កាលយូរនេះ មិនគួរអស្ចារ្យ សូម្បីក្នុងវេលាជាព្រះពោធិសត្វ សីលរបស់ព្រះអង្គក៏បានជាយ៉ាងនេះ ។

បានជ្រាបថា ក្នុងអតីតព្រះរាជា ២ ព្រះអង្គ គឺ ព្រះរាជាក្នុងដែនគន្ធារៈនិងព្រះរាជាក្នុងដែនវិទេហៈ ទ្រង់ជាសម្លាញ់គ្នា ទ្រង់ឃើញទោសក្នុងកាមទាំងឡាយ ទើបប្រគល់រាជសម្បត្តិដល់ព្រះឱរស ទ្រង់ព្រះផ្នួសជាឥសី ហើយត្រាច់បិណ្ឌបាតក្នុងពួកអ្នកស្រុកព្រៃ ក្នុងស្រុកមួយ ។ ក៏ជាយដែនរកអំបិលបានដោយលំបាក ឥសីទាំងពីរនោះ បានបបរមិនបានដាក់អំបិល ហើយអង្គុយហុតលើសាលាមួយខ្នង ។ ពួកមនុស្សក្នុងចន្លោះនោះ បានធ្វើអំបិលម៉ត់មកថ្វាយ ។ ថ្ងៃមួយ មនុស្សម្នាក់ បានដាក់អំបិលម៉ត់លើស្លឹកឈើឲ្យដល់វេទេហឥសី ។

វេទេហឥសីទទួលហើយបែងចែកទុក ក្នុងសម្នាក់របស់គន្ធារឥសី ពាក់កណ្តាល សម្រាប់ខ្លួនពាក់កណ្តាល ។ អំពីនោះ ឥសីនោះឃើញអំបិលដែលសល់ពីការបរិភោគបន្តិច ទើបពោលថា អំបិលនេះកុំខូចឡើយ ហើយយកស្លឹកឈើខ្ចប់ទុកក្នុងព្រៃស្មៅ ក្នុងវេលាហុតបបរថ្ងៃមួយ វេទេហឥសី រលឹកបាន កាលមើលទៅក៏ឃើញអំបិលនោះ ទើបចូលទៅរកគន្ធារឥសី ពោលថា លោកអាចារ្យ ! សូមលោកចូរកាន់យកបន្តិចពីចំណែកនេះ ។

គ. វេទេហឥសី លោកបានអំបិលនេះមកពីណា

វ. អំបិលដែលសល់ពីការបរិភោគក្នុងថ្ងៃនោះ ខ្ញុំរក្សាទុកដោយគិតថា កុំវិនាសទៅឡើយ ។ គន្ធារឥសីមិនប្រាថ្នានឹងទទួល បានហុតបបរមិនមានអំបិលនោះឯង ហើយពោលនឹងវេទេហឥសីថា លោកលះបង់ពួកអ្នកស្រុក ១៦.០០០ បរិបូរដោយព្រះឃ្លាំងដែលជាមង្គល ហើយឥឡូវនេះមកធ្វើការសន្សំ (អំបិល) ។ វេទេហឥសី បានពោលថា លោកលះបង់រាជសម្បត្តិ បួសហើយ ឥឡូវនេះព្រោះហេតុអ្វី ទើបមិនធ្វើកម្មដែលសមគួរដល់ការបួស ។ ព្រោះហេតុសន្សំត្រឹមតែអំបិលម៉ត់ឬ ?

គ. ខ្ញុំបានធ្វើអ្វីទុក លោកវេទេហឥសី

លំដាប់នោះ វេទេហឥសី ទើបពោលនឹងគន្ធារឥសីថា លោកលះបង់

ដែនគន្ធារៈក្នុងក្រុងដែលមានទ្រព្យច្រើន ចេញចាកពីការគ្រប់គ្រងហើយ ឥឡូវនេះ មកគ្រប់គ្រងក្នុងទីនេះទៀត ។

គ. លោកដ៏ចម្រើន ខ្ញុំនឹងពោលធម៌ វត្ថុដែលមិនមែនធម៌ ខ្ញុំមិនពេញចិត្ត កាលខ្ញុំពោលធម៌ហើយ បាបរមែងមិនចូលទៅពាក់ព័ន្ធ ។

វ. បុគ្គលដទៃរមែងបានសេចក្តីវិនាស ព្រោះការសរសើរយ៉ាងណាមួយ បើបណ្ឌិតមិនគប្បីពោលពាក្យនោះ ដែលមានប្រយោជន៍ធំ ។

គ. សេចក្តីប្រាថ្នាចូរវិនាសទៅ ឬក៏វិនាសទៅ ចូររាត់រាយទៅ ដូចរោយអង្កាម កាលយើងពោលធម៌ហើយ បាបរមែងមិនចូលទៅពាក់ព័ន្ធ ។ លំដាប់នោះ វេទេហឥសី គិតថា អ្នកណាមិនមានសេចក្តីដឹងសូម្បីចំពោះខ្លួន មិនសិក្សារបៀបបែបផែនក្នុងសម្នាក់អាចារ្យ គេរមែងត្រាច់ទៅ ដូចក្របីខ្វាក់ត្រាច់ទៅក្នុងព្រៃ ។ ហើយពោលថា បើសេចក្តីដឹងចំពោះខ្លួនមិនគប្បីមានសោត ឬមិនបានសិក្សាវិន័យទុកឲ្យល្អ អ្នកនឹងគប្បីត្រាច់ទៅ ដូចក្របីខ្វាក់ត្រាច់ទៅក្នុងព្រៃ ។ ក៏ព្រោះបុគ្គលពួកខ្លះ សិក្សាល្អហើយក្នុងសម្នាក់អាចារ្យ ដូច្នោះ ជាអ្នកមានវិន័យដែលបុគ្គលណែនាំបានហើយ មានសតិតាំងមាំ ត្រាច់ទៅហើយ ។ ក៏គ្រាពោលហើយយ៉ាងនេះ វេទេហឥសីទើបពោលថា ហេតុនេះ យើងមិនដឹង បានធ្វើហើយ ។ ហើយឲ្យគន្ធារឥសីអត់ទោសហើយ ។

ឥសីសូម្បីទាំង ២ ប្រព្រឹត្តតបៈហើយទៅកាន់ព្រហ្មលោក ។ ដល់ក្នុងកាលដែលព្រះតថាគតជាព្រះពោធិសត្វ អាជីវដ្ឋមកសីល ក៏បានបរិសុទ្ធិរហូតអស់កាលយូរយ៉ាងនេះ ។

បទថា **ភិក្ខុដ៏មានអាយុនេះ ប្រាកដឈ្មោះបោះសំឡេង** សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងថា ភិក្ខុដ៏មានអាយុនេះ ជាគ្រូរបស់យើង ដល់ភាពជាអ្នកដែលគេដឹងហើយ គឺ មានឈ្មោះបោះសំឡេង បានដល់ ប្រាកដហើយ និងខ្លួនឯងសម្រេចបរិវារសម្បត្តិឬទេហ្ន៎ ព្រោះហេតុនោះ លោកចូរជេញដោលសួរយ៉ាងនេះថា ទោសពួកខ្លះនឹងប្រាកដ ដោយភាពដែលខ្លួនមានឈ្មោះបោះសំឡេង និងដោយភាពដែលខ្លួនអាស្រ័យយស ឬមិនប្រាកដ ។

បទថា **ភិក្ខុទាំងឡាយ ត្រឹមនោះមិនមែន** សេចក្ដីថា រហូតអស់វេលាដែលភិក្ខុជាអ្នកចាស់ មានភាពជាអ្នកមានឈ្មោះបោះសំឡេង ក្នុងព្រះរាជា និងអមាត្យរបស់ព្រះរាជាជាដើម ឬដែលមានបរិវារសម្បត្តិ ទោសខ្លះ មានមានះ និងមានះចាត់ជាដើម រមែងមិនមាន លោកដូចជាថា អ្នកចូលទៅស្ងប់រម្ងាប់ហើយ ដូចព្រះសោតាបន្ន និងដូចព្រះសកទាគាមី លោករមែងជាអ្នកដែលអ្នកណាៗ មិនអាចដើម្បីនឹងចន្ទុលច្បាស់ថា លោកជាព្រះអរិយៈ ឬជាបុថុជ្ជន ។

បទថា **ភិក្ខុទាំងឡាយ ក៏កាលណា** សេចក្ដីថា ក៏កាលណាភិក្ខុពួកខ្លះ

ក្នុងសាសនានេះ ជាអ្នកមានឈ្មោះបោះសំឡេងហើយ ឬជាអ្នកសម្បូរណ៍ដោយបរិវារ កាលនោះ លោកកាលនឹងបៀតបៀនភិក្ខុពួកដទៃក្នុងទីនោះៗ ដូចគោឈ្មោលកាច ដេញយកស្នែងដែលស្រួចវាត់ហ្វូងគោ និងដូចខ្លាដំបងញាំញីហ្វូងម្រឹគជាអ្នកមិនមានសេចក្ដីគោរព មានការប្រព្រឹត្តមិនសមរម្យ ត្រាច់ទៅដូចយកចុងជើងឆ្កឹះផែនដី ។

ក៏កុលបុត្រពួកខ្លះ ជាអ្នកមានឈ្មោះបោះសំឡេង មានយសដោយប្រការណាៗ បន្ទោនចុះដោយល្អ ដូចស្រូវសាលីដែលពេញដោយគ្រាប់ ដោយប្រការនោះៗ កាលព្រះរាជា និងមហាអាមាត្យរបស់ព្រះរាជាជាដើម ចូលទៅរកលោករមែងពិចារណាឃើញការមិនមានកិលេសជាតិ ជាគ្រឿងកន្ធល់ ចូលទៅតាំងសេចក្ដីសម្គាល់ក្នុងភាពជាសមណៈទុក ជាអ្នកស្ងប់ស្ងៀម មិនក្រអឺតក្រទម មានចិត្តទាប ដូចគោឧសភៈមានស្នែងបាក់ និងដូចក្មេងចណ្ឌាល បដិបត្តិហើយដើម្បីប្រយោជន៍ និងសេចក្ដីសុខដល់ភិក្ខុសង្ឃ និងដល់មនុស្សលោក ព្រមទាំងទេវ-លោក ព្រះមានព្រះភាគ ទ្រង់សំដៅយកការបដិបត្តិបែបនេះ ទើបត្រាស់ថា ទោសយ៉ាងណាមួយក្នុងលោកនេះ មិនមានដល់លោក ។ ក៏ព្រះតថាគត ទ្រង់ជាអ្នករឹងមាំក្នុងលោកធម៌ ៨ ព្រោះព្រះអង្គជាអ្នករឹងមាំក្នុងលាភខ្លះ ក្នុងការមិនមានលាភខ្លះ ក្នុងយសខ្លះ ក្នុងការមិនមានយសខ្លះ ក្នុងនិន្ទាខ្លះ ក្នុងសរសើរ

ខ្វះ ក្នុងសុខខ្វះ ទុក្ខខ្វះ ដូច្នោះ ទោសទាំងឡាយណាមួយក្នុងលោកនេះ ទើបមិនមានដល់ព្រះអង្គ ដោយប្រការទាំងពួង ។

បទថា **ជាអ្នកមិនមានភ័យ ចូលទៅត្រេកអរហើយ** សេចក្តីថា ជាអ្នកមិនមានភ័យ ចូលទៅត្រេកអរហើយ អធិប្បាយថា "ជាអ្នកចូលទៅត្រេកអរហើយដោយចំណែកតែមួយ គឺ ជាអ្នកចូលទៅត្រេកអររឿយៗ" ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមិនមានភ័យ ចូលទៅត្រេកអរហើយ ព្រោះភាពជាអ្នកចូលទៅត្រេកអរ ដោយសេចក្តីភ័យមិនមាន ដូច្នេះខ្វះ ។ ក៏ភ័យ មាន ៤ យ៉ាង គឺ ភ័យកើតពីកិលេស ១ ភ័យកើតពីវដ្ដៈ ១ ភ័យកើតពីទុគ្គតិ ១ ភ័យកើតពីការតិះដៀល១ សូម្បីបុថុជ្ជនរមែងខ្លាចភ័យ ៤ ប្រការ , សេក្ខបុគ្គលទាំងឡាយ រមែងខ្លាចភ័យ ៣ ប្រការ ព្រោះថា ព្រះសេក្ខបុគ្គលទាំងនោះ លះបង់ភ័យដែលកើតពីទុគ្គតិបាន ព្រះសេក្ខបុគ្គល ៧ ពួក ជាអ្នកមិនទាន់រួចផុតភ័យដូច្នេះឯង ។ ព្រះខីណាស្រពឈ្មោះថា ជាអ្នករួចផុតភ័យ ក៏ភ័យណាមួយរបស់លោករមែងមិនមាន ភ័យដែលកើតពីការតិះដៀលរបស់អ្នកដទៃ ក៏មិនមាន ។ លោករមែងអាស្រ័យសេចក្តីអាណិតអ្នកដទៃ ហើយរក្សាការចូលទៅតិះដៀលអ្នកដទៃថា សត្វទាំងឡាយ អាស្រ័យព្រះខីណាស្រពដូចជាយើង ចូរកុំវិនាសឡើយ ដូចព្រះថេរៈ អ្នកនៅក្នុងវត្តមុលុប្បលវាបីវិហារ ។

បានឮថា ព្រះថេរៈចូលទៅកាន់ស្រុកមុលុប្បលវាបី ដើម្បីបិណ្ឌបាត្រ ។ លំដាប់នោះ មនុស្សទាំងឡាយទទួលបាត្ររបស់ព្រះថេរៈ ដែលទៅដល់ទ្វារផ្ទះនៃត្រកូល ឧបដ្ឋាកហើយក្រាលអាសនៈពីងកៅអីជេក ចំណែកធីតារបស់អាមាត្យអាស្រ័យកៅអីនោះឯង ឲ្យក្រាលអាសនៈក្រោម ក្នុងចំណែកម្ខាងអង្គុយហើយ អាវាសិកភិក្ខុមួយរូប ចូលទៅបិណ្ឌបាតខាងក្រោយ ឈរក្រឡេកមើលក្បែរទ្វារផ្ទះនោះឯង កំណត់ថា ព្រះថេរៈអង្គុយលើគ្រែតែមួយជាមួយធីតាអាមាត្យ ទើបគិតថា ភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលនេះ នៅក្នុងវិហារដូចស្ងប់ស្ងៀម តែអង្គុយលើគ្រែតែមួយជាមួយនឹងធីតាអាមាត្យអ្នកឧបដ្ឋាកខាងក្នុងផ្ទះ ហើយគិតមើលដដែលហើយដដែលទៀតថា អ្វីហ្ន៎ យើងឃើញអាការវិលខូចហើយ ជាអ្នកសម្គាល់យ៉ាងនោះហើយ ក៏ចៀសចេញទៅ ។ ចំណែកព្រះថេរៈ ឆាន់ស្រេចហើយ បាននិមន្តមកវត្ត ចូលដល់ទីនៅរបស់ខ្លួន បិទទ្វារអង្គុយ ។ ចំណែកអាវាសិកភិក្ខុ ឆាន់ស្រេចហើយក៏ទៅវត្ត គិតថា យើងនឹងគ្របសង្កត់លោក ហើយដេញភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលចេញពីវត្ត ក៏បានទៅកាន់ទីនៅរបស់ព្រះថេរៈ ដោយទំនងការគ្រោចទៅដូចអ្នកមិនសង្រួម យកបោយដងទឹកពីផ្ទាំងទឹកសម្រាប់ឆាន់ ធ្វើសំឡេងខ្លាំងៗ លាងជើង ។ ព្រះថេរៈរំពឹងថា អ្នកនេះជាអ្នកណាហ្ន៎ គ្រោចទៅមិនសង្រួម ដឹងរឿងទាំងអស់ហើយគិតថា អ្នកនេះចូរ

ជាអ្នកកុំមានចិត្តប្រទូសរ៉ាយក្នុងយើង ហើយចូលដល់អបាយឡើយ ។ ហើយហោះឡើង អង្គុយពត់ភ្នែនជិតមណ្ឌលកំពូលវិហារ ។ អាវាសិកភិក្ខុទើបលើកធ្នាំងទឹកដោយអាការដែលនឹងប្រទូសរ៉ាយ បានបើកទ្វារចូលទៅខាងក្នុង មិនជួបព្រះថេរៈ គិតថា ព្រះថេរៈនឹងចូលទៅក្រោមគ្រែ ទើបពិនិត្យមើល មិនជួបព្រះថេរៈសូម្បីក្នុងទីនោះទៀត រៀបនឹងចេញទៅ ។ ព្រះថេរៈទើបគ្រហែមឡើង អាវាសិកភិក្ខុក្រៅនេះ ក្រឡេកឡើងទៅខាងលើឃើញហើយ មិនអាចនឹងអត់ធន់បាន ទើបពោលយ៉ាងនេះថា លោកម្ចាស់ទ្រទ្រង់សំពត់បង្សុកូលដ៏មានអាយុ ការអង្គុយលើគ្រែតែមួយជាមួយគ្នានឹងជីតាអាមាត្យអ្នកឧបដ្ឋាក សមគួរដល់លោកដែលដល់ព្រមហើយដោយអានុភាពយ៉ាងនេះឬ លោកដ៏ចម្រើនដែលឈ្មោះថា បព្វជិតទាំងឡាយអង្គុយលើគ្រែតែមួយរួមគ្នានឹងមាតុគ្រាម មិនបាន ក៏ហេតុនេះលោកឃើញថា មិនល្អឬ ព្រះវិណាស្រពទាំងឡាយ រមែងស្រឡាញ់ការចូលទៅតិះដៀលអ្នកដទៃយ៉ាងនេះ ។

បទថា *ព្រោះអស់រាគៈ* សេចក្តីថា ព្រោះការអស់ទៅនៃរាគៈនោះឯង រមែងមិនសេពកាមទាំងឡាយ ព្រោះប្រាសចាករាគៈ អធិប្បាយថា ហាមហើយសេពដោយការពិចារណាមិនមានទេ ។ បទថា **ប្រសិនបើថានូវភិក្ខុនោះ** សេចក្តីថា អ្នកពួកដទៃគប្បីសួរយ៉ាងនេះចំពោះភិក្ខុ ដែលនឹងសាកសួរនោះ អ្នកដឹង

ការលះកិលេសរបស់ព្រះតថាគតយ៉ាងនេះ ហើយអគ្គិយលើធម្មាសនៈដែលបាន តាក់តែងហើយកណ្តាលបរិស័ទទាំង ៤ សូម្បីក្នុងវេលាឈរ និងអគ្គិយជាដើម នោះៗ ពោលសរសើរការលះកិលេសរបស់ព្រះតថាគតយ៉ាងនេះថា សូម្បីព្រោះ យ៉ាងនេះ ព្រះសាស្តាទ្រង់ជាអ្នកប្រាសចាករាគៈ ទោសៈ មោហៈ បន្ទោបង់កិលេស លះមន្ទិលបាន ទ្រង់បរិសុទ្ធិយ៉ាងល្អ ដូចព្រះចន្ទពេញវង់ចេញចាកពពក ដូច្នោះ ។ បទថា **អាការ** បានដល់ ហេតុ ។ បទថា **ទៅតាម** បានដល់ ដឹងតាម ។ បទថា **ឬថានៅក្នុងសង្ឃ** សេចក្តីថា ពេលខ្លះនៅកណ្តាលភិក្ខុដែលកំណត់ រាប់មិនបាន ។ បទថា **ឬថាស្តេចប្រថាប់តែមួយព្រះអង្គឯង** សេចក្តីថា ព្រះអង្គ ប្រថាប់នៅក្នុងទីពួនសម្ងំ និងក្នុងព្រៃបារិលេយ្យកៈយ៉ាងនេះថា ម្នាលភិក្ខុទាំង ឡាយ ! តថាគតប្រាថ្នាដើម្បីនឹងពួនសម្ងំកន្លះខែ (ខ្វះ) ៣ ខែ (ខ្វះ) ។ បទថា **អ្នកទៅល្អហើយ** សេចក្តីថា អ្នកទៅល្អហើយ គឺ ជាអ្នកបដិបត្តិល្អ បានដល់ ជាអ្នកដែលប្រកបសមគួរដល់ហេតុ ។ ក៏ភិក្ខុពួកខ្លះ សូម្បីបែបនេះក៏មាន ។

បទថា **ទៅមិនល្អហើយ** សេចក្តីថា ឈ្មោះថា ជាអ្នកជាប់ជំពាក់ ព្រោះជាប់ធ្ងន់ច្រើន លះកម្មដ្ឋាន ភិក្ខុរូបខ្លះ សូម្បីបែបនេះក៏មាន ។ បទថា **តាមទូន្មានគណៈ** សេចក្តីថា ឈ្មោះថា ជាអ្នកជាប់ជំពាក់ ព្រោះជាប់ជំពាក់ ដោយគណៈ ជាអ្នកត្រេកអរក្នុងគណៈ ច្រើនក្នុងគណៈ បរិហារគណៈ ។ ភិក្ខុ

រូបខ្លះ សូម្បីបែបនេះក៏មាន ។ ភិក្ខុទាំងនោះ ជាបដិបក្ខចំពោះភិក្ខុទាំងនោះ ជាអ្នកត្រាច់ចេញ រលាស់ចេញចាកគណៈ មិនប្រកបជាមួយក៏មាន ។

បទថា **រមែងប្រាកដក្នុងអាមិស** សេចក្តីថា ពួកភិក្ខុដែលប្រាថ្នាក្នុងអាមិសទាំងឡាយ ជាអ្នកលោភក្នុងអាមិស មានចក្ខុសម្លឹងតែអាមិស ត្រាច់ទៅដើម្បីអាមិស គឺ បច្ច័យ ៤ ប៉ុណ្ណោះក៏មាន ។ ភិក្ខុទាំងឡាយ ត្រូវអាមិសបូកលាបហើយ មានចិត្តថ្លាផូរផង់អំពីបច្ច័យ ៤ ដូចជាព្រះចន្ទដែលចេញចាកពពកហើយក៏មាន ។

បទថា **បុគ្គលនេះ រមែងមើលងាយបុគ្គលនោះដោយអាមិស ក៏មិនមែន** សេចក្តីថា ការលើកឡើងដោយអំណាចអាស្រ័យផ្ទះ រមែងមិនមានដល់លោកយ៉ាងនេះថា លោកដ៏មានអាយុនេះជាគ្រូ រមែងមិនមើលងាយបុគ្គលនោះដោយវត្តបដិបត្តិនោះៗ អ្នកនេះជាអ្នកបដិបត្តិល្អ ជាអ្នកបដិបត្តិ នេះឈ្មោះថាជាអ្នកត្រាច់ចេញ រលាស់ចេញចាកគណៈ អ្នកនេះជាអ្នកដែលអាមិសមិនបូកលាប ជាអ្នកមានចិត្តថ្លាផូរផង់អំពីបច្ច័យទាំងឡាយ ដូចព្រះចន្ទដែលចេញចាកដូច្នោះ យ៉ាងនេះខ្លះ ។ ការគ្របសង្កត់ គម្រាមដោយអំណាចអាស្រ័យផ្ទះ រមែងមិនមានដល់លោកយ៉ាងនេះថា អ្នកនេះជាអ្នកបដិបត្តិមិនល្អ មិនមែនអ្នកបដិបត្តិ ជាអ្នកមានកាយធ្ងន់ លះបង់កម្មដ្ឋាន អ្នកនេះជាអ្នកជាប់ទាក់ទងដោយ

លោកក្នុងអាមិស ចិត្តមិននឹងនរ មានចក្ខុផ្តោតតែអាមិស ដូច្នេះខ្លះ សួរថា ពាក្យអ្វីដែលភិក្ខុនេះពោលទុក ឆ្លើយថា លោករមែងជាអ្នកពោលដល់ភាពជាអ្នកមុតមាំក្នុងសត្វទាំងឡាយរបស់ព្រះតថាគត ។ ព្រះតថាគតជាមុនីនេះ មានព្រះទ័យស្មើចំពោះពួកសត្វទាំងពួង គឺ ចំពោះភិក្ខុទេវទត្ត នាយខ្មាន់ធ្នូ ចោរអង្គុលិមាល ក្នុងដំរីធនបាល និងក្នុងព្រះរាហុល ។

[១៧៨] បទថា **ភិក្ខុទាំងឡាយ ក្នុងភិក្ខុដែលនឹងសាកសួរទាំងនោះ** សេចក្តីថា ក៏ក្នុងបណ្តាភិក្ខុដែលនឹងសាកសួរទាំងពីរនោះ ភិក្ខុនេះណា បានមកដល់ហើយ ព្រោះការសួរថា ក៏អ្វីជាអាការរបស់លោក នេះឈ្មោះថា អ្នកសាកសួរបញ្ហាបញ្ជិតបញ្ចៀង ។ មួយទៀត អ្នកណាមក ហើយដោយគិតថា បុគ្គលនេះជាអ្នកមិនមានភ័យ ចូលទៅត្រេកអរហើយ ឈ្មោះថា អ្នកសាកសួរមូលបញ្ហា ។ ក្នុងបុគ្គលទាំង ៣ អ្នកសាកសួរទាំងនោះ អ្នកសាកសួរមូលបញ្ហានឹងគប្បីត្រឡប់សួរព្រះតថាគតឲ្យធ្ងន់ឡើងទៅទៀតនោះឯង ។ អធិប្បាយថា បញ្ហាដំបូង សូម្បីលោកក៏នឹងដល់សេចក្តីអាក់អន់ចិត្ត ដោយពាក្យរបស់អ្នកដទៃ ដែលឈ្មោះថា អ្នកដទៃកាលដឹងខ្លះ មិនដឹងខ្លះ ក៏នឹងគប្បីពោល , ពាក្យរបស់លោកជាពាក្យពិតខ្លះ មិនពិតខ្លះយ៉ាងនេះ ព្រោះដូច្នោះ លោកមិនដល់ការអន់ចិត្តក្នុងពាក្យរបស់អ្នកដទៃនុ៎ះឯង នឹងគប្បីសួរព្រះតថាគតឲ្យក្រៃ-

លែងឡើងទៅជាងនោះទៀត នោះឯង ។

ក្នុងពាក្យថា **កាលព្យាករណ៍** នេះ ព្រោះដែលឈ្មោះថា ព្រះតថាគត មិនមានព្យាករណ៍ខុស ដូច្នោះ ព្រះមានព្រះភាគ ទើបមិនត្រាស់ថា ត្រូវខុស (តែ) ត្រាស់ថា ទ្រង់ព្យាករណ៍ហើយ ។ បទថា **តថាគតជាអ្នកមានអាជីវដ្ឋ-មកសីល នោះជាផ្លូវ មានអាជីវដ្ឋមកសីលនោះជាគោចរ** សេចក្តីថា តថាគត ជាអ្នកមានអាជីវដ្ឋមកសីលបរិសុទ្ធិថា នេះជាផ្លូវរបស់តថាគត នេះជាគោចរ របស់តថាគត បាលីថា **ឯត្ថាបាថោ** ដូច្នេះខ្លះ ។

បទថា **ឯត្ថាបាថោ** នោះ មានអធិប្បាយថា តថាគតជាអ្នកមានអាជី-វដ្ឋមកសីលបរិសុទ្ធិ តថាគតនោះឈ្មោះថា ជាអ្នកមានអាជីវដ្ឋមកសីលជាផ្លូវ ដោយមុខ គឺ ញាណរបស់ភិក្ខុដែលឈ្មោះថា សាកសួរនោះ ព្រោះភាពជា អ្នកបរិសុទ្ធិ មានពាក្យអធិប្បាយថា យើងមកប្រាកដខ្លួនយ៉ាងនេះ ។

ដោយបទថា **តថាគតជាអ្នកសម្រេចហើយ ដោយអាជីវដ្ឋមកសីលនោះ ដោយសីលនោះក៏ទេ** ព្រះមានដំព្រះភាគ ទ្រង់សម្តែងទុកថា ក៏តថាគតជាអ្នក សម្រេចហើយដោយអាជីវដ្ឋមកសីលនោះ ដោយសីលដែលបរិសុទ្ធិសូម្បីនោះ មិនមែន ជាអ្នកមានតណ្ហាមិនមែន ឈ្មោះថា ជាអ្នកអស់តណ្ហា ព្រោះភាពជា អ្នកមានសីលបរិសុទ្ធិនុ៎ះឯង ។

បទថា **ក្រៃលែងៗ ឡើងទៅ និងប្រណីតក្រៃលែងឡើង** សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងឲ្យក្រៃលែងឡើងទៅ និងឲ្យប្រណីតក្រៃលែងឡើងទៅ ។ បទថា **ដែលមានចំណែកប្រៀបទាំងចំណែកខ្មៅ និងស** សេចក្ដីថា ទាំងខ្មៅ និងស ។ ព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យទាំងចំណែកខ្មៅ និងសនោះមានចំណែកប្រៀបគ្នា ឲ្យមានវិបាកស្មើគ្នា ហើយទ្រង់ហាមចំណែកដែលខ្មៅ ទ្រង់សម្ដែងទាំងចំណែកខ្មៅ និងស ឲ្យមានចំណែកប្រៀបធៀបយ៉ាងនេះថា ស និងទ្រង់ហាមចំណែកដែលសហើយ សម្ដែងទាំងចំណែកខ្មៅ និងស ឲ្យមានចំណែកប្រៀបធៀបយ៉ាងនេះថា ខ្មៅ ដូច្នេះ ។ សូម្បីកាលទ្រង់សម្ដែងចំណែកដែលខ្មៅ ក៏ទ្រង់សម្ដែងព្រមទាំងឧស្សាហ៍ និងវិបាក ។ កាលទ្រង់សម្ដែងចំណែកដែលស ក៏រមែងទ្រង់សម្ដែងព្រមទាំងសេចក្ដីឧស្សាហ៍ និងវិបាក ។

បទថា **ដល់ការធ្លាក់ចុះនៃចិត្តក្នុងធម៌ទាំងឡាយ ដោយសេចក្ដីដឹងក្រៃលែងនូវធម៌ខ្លះក្នុងសាសនានេះ** សេចក្ដីថា ដល់សេចក្ដីធ្លាក់ចុះនៃចិត្តក្នុងព្រះធម៌ទេសនាដោយធម៌ គឺ ការធ្លាក់ចុះដែលដឹងដ៏ក្រៃលែងហើយនោះ ដោយសេចក្ដីដឹងក្រៃលែងនូវធម៌យ៉ាងណាមួយ ក្នុងធម៌ដែលទ្រង់សម្ដែងហើយនោះ ។ បទថា **ជ្រះថ្លាក្នុងព្រះសាស្ដា** សេចក្ដីថា ដល់សេចក្ដីធ្លាក់ចុះនៃចិត្តក្នុងធម៌យ៉ាងនេះ ហើយជ្រះថ្លាក្នុងព្រះសាស្ដា ដោយប្រមាណដ៏ក្រៃលែងថា ព្រះមាន-

ព្រះភាគត្រាស់ដឹងឯងដោយប្រពៃ រមែងជ្រះថ្លាក្នុងព្រះធម៌ សូម្បីក្នុងព្រះសង្ឃ ក៏យ៉ាងនេះថា ក៏ព្រះធម៌ណាដែលព្រះមានព្រះភាគត្រាស់ទុកហើយ ព្រះធម៌សូម្បីនោះ ឈ្មោះថា ព្រះមានព្រះភាគត្រាស់ទុកល្អហើយ ព្រោះជាគ្រឿងនាំចេញ ។ ព្រះសង្ឃណាបដិបត្តិធម៌នោះ របស់ព្រះមានព្រះភាគអង្គនោះ ព្រះសង្ឃសូម្បីនោះ ឈ្មោះថា បដិបត្តិល្អហើយ ព្រោះបដិបត្តិវត្តបដិបត្តិដែលវៀរចាកទោស មានការកោងជាដើម ។

បទថា **បើថា... ។ ដែលភិក្ខុនោះ** សេចក្តីថា ដែលភិក្ខុនោះអ្នកជ្រះថ្លាហើយយ៉ាងនេះ ពោលសរសើរគុណព្រះរតនត្រ័យក្នុងទីនោះៗ ។

[១៧៩] បទថា **អាការទាំងនេះ** សេចក្តីថា ដោយហេតុជាគ្រឿងសាកសួរព្រះសាស្តាទាំងនេះ ។ បទថា **ដោយបទទាំងនេះ** បានដល់ បទជាគ្រឿងរួបរួមអក្ខរៈពួកនេះ ។ បទថា **មានសេចក្តីជឿតាំងមាំ** បានដល់ ការតម្កល់មាំតាំងមាំហើយ ។ បទថា **មានការកើតជាមូល** បានដល់ មានមូលកើតព្រមហើយ ដោយអំណាចសោតាបត្តិមគ្គ ។ ក៏សោតាបត្តិមគ្គ ឈ្មោះថា ជាមូលនៃសទ្ធា ។

បទថា **មានអាការ** បានដល់ ឈ្មោះថា មានហេតុ ព្រោះលោកស្វែងរកហេតុហើយ ទើបកាន់យក ។

បទថា **មានការឃើញជាមូល** បានដល់ ជាមូលនៃសោតាបត្តិមគ្គ ។ ក៏សោតាបត្តិមគ្គ លោកហៅថា **ការឃើញ** ។

បទថា **តាំងមាំ** បានដល់ យូរយា ។ បទថា **ដែលអ្នកណានាំទៅមិនបាន** បានដល់ ដែលអ្នកណាៗ មិនអាចនាំទៅបាន ។ បទថា **ឬសមណៈ** បានដល់ ឬថាសមណៈអ្នកមានបាបដែលស្ងប់ហើយ ។ បទថា **ឬថាព្រាហ្មណ៍** បានដល់ ឬថាព្រាហ្មណ៍អ្នកបណ្តែតបាបហើយ ។ បទថា **ឬថាទេវ** បានដល់ ឧប្បត្តិទេព ។ បទថា **ឬថាមារ** បានដល់ ឬថាវសវត្តីមារ ។ ក៏សេចក្តីជឿរបស់ព្រះសោតាបន្ននោះ មានសភាពដែលទេវតាសូម្បីវសវត្តីមារ ក៏លួចទៅមិនបាន ដូចសេចក្តីជឿរបស់នាយសូរៈ ដែលនៅក្នុងព្រៃស្វាយ ។

ជ្រាបថា នាយសូរៈនោះ ស្តាប់ធម៌របស់ព្រះសាស្តាហើយ បានជាព្រះសោតាបន្នហើយ ទៅផ្ទះ ។ លំដាប់នោះ មារទើបនិម្មិតជារូប ប្រៀបដូចជាព្រះពុទ្ធ ដែលប្រដាប់ដោយព្រះលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ហើយឈរត្រង់ទ្វារផ្ទះរបស់សូរឧបាសក បញ្ជូនដំណឹងទៅថា ព្រះសាស្តាស្តេចមកហើយ ។ សូរឧបាសក គិតថា យើងទើបស្តាប់ធម៌ពីសម្នាក់របស់ព្រះសាស្តាឥឡូវនេះឯង នឹងមានហេតុអ្វីហ្ន៎ ទើបចូលទៅគាល់ហើយបានឈរថ្វាយបង្គំ ដោយសម្គាល់ថាជាព្រះសាស្តា ។

មារពោលថា សូរម្ពដ្ឋៈ ពាក្យណាដែលតថាគតពោលហើយជាមួយនឹងអ្នកថា រូបមិនទៀង ។ល។ វិញ្ញាណមិនទៀង ពាក្យនោះ តថាគតពោលហើយមិនត្រូវ តថាគតមិនទាន់ពិចារណា ទើបពោលយ៉ាងនេះ ដូច្នោះ អ្នកចូរកាន់យកថា រូបទៀង ។ល។ វិញ្ញាណទៀង ។ សូរឧបាសក ទើបគិតថា សេចក្តីដែលព្រះពុទ្ធទាំងឡាយទ្រង់មិនពិចារណា ហើយគប្បីត្រាស់ពាក្យណាៗ មិនឲ្យជាក់ច្បាស់នោះ ប្រព្រឹត្តទៅមិនបាន ។ បុគ្គលនេះនឹងជាមារ មកដើម្បីឲ្យយើងយល់ខុសពិតប្រាកដ ។ លំដាប់នោះ ទើបពោលនឹងមារនោះថា អ្នកជាមារឬ មារនោះ មិនអាចនឹងពោលកុហកបានទើបទទួលថា អើ!សូរៈ យើងជាមារមែន ។ ត្រូវសូរឧបាសកពោលថា មកព្រោះហេតុអ្វី មារទើបពោលថា ដើម្បីឲ្យសទ្ធារបស់អ្នកធ្លាក់ចុះ ។

សូរឧបាសក ទើបផ្ទាត់ម្រាមដៃឲ្យដឹងថា នៃមារអ្នកមានចិត្តបាប អ្នកឯងតែម្នាក់ចូរឈប់សិន មារដូចអ្នកឯងទាំងរយ ទាំងពាន់ ក៏មិនអាចឲ្យសទ្ធារបស់យើងញាប់ញ័របាន ព្រោះថា សទ្ធាដែលមកហើយដោយមគ្គ រមែងមិនញាប់ញ័រ ដូចភ្នំសិនេរុ ដែលតាំងនៅលើផែនដីដែលជាសិលា អ្នកឯងនឹងនៅក្នុងទីនេះធ្វើអ្វី មារនោះ មិនអាចតាំងនៅក្នុងទីនោះ បាតអន្តរធានទៅក្នុងទីនោះឯង ។

បទថា **ឬជាព្រហ្ម** សេចក្តីថា ឬថាបណ្តាព្រហ្ម មានព្រហ្មកាយិកៈ ជាដើម ព្រហ្មពួកណាមួយ ។ បទថា **ឬជាអ្នកណាៗ ក្នុងលោក** សេចក្តីថា វៀរសមណៈជាដើមពួកនេះ ឬថា អ្នកណាៗ សូម្បីដទៃក្នុងលោកក៏មិនអាចនាំទៅបាន ។ ការសោកស្ដាយដល់ការៈរបស់ខ្លួន ឈ្មោះថា ការសោកស្ដាយធម៌ ។

បទថា **តាំងមាំក្នុងការសោកស្ដាយយ៉ាងល្អតាមធម្មតា** បានដល់ តាំងនៅក្នុងការសោកស្ដាយយ៉ាងល្អដោយធម្មតា ។ អធិប្បាយថា ជាអ្នកត្រូវសោកស្ដាយហើយយ៉ាងល្អតាមការៈរបស់ខ្លួន ។ ពាក្យដ៏សេសក្នុងគ្រប់បទ ងាយយល់ទាំងអស់នុ៎ះឯង ។

“ ចប់អដ្ឋកថា វីមំសកសូត្រ ទី ៧ ”

# អ ដ្ឋ ក ថា

## កោសម្ពិយសូត្រទី ៨

[១៨០] *កោសម្ពិយសូត្រ មានពាក្យផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

*បណ្ដាបទទាំងនោះ បទថា* ***ជិតក្រុងកោសម្ពី*** *សេចក្ដីថា ជិតព្រះនគរមានឈ្មោះយ៉ាងនេះ ។ ជ្រាបថា មានដើមពោនស្វាដ៏ធំ ក្នុងទីមានសួន និងស្រះបោក្ខរណីជាដើមទាំងនោះៗ នៃព្រះនគរនោះ ព្រោះដូច្នោះ ព្រះនគរនោះបានដល់ការរាប់ថា* ***កោសម្ពី*** *។ អាចារ្យពួកមួយពោលថា ឈ្មោះថា* ***កោសម្ពី*** *ព្រោះឥសី ឈ្មោះកុសម្ពៈ ឲ្យសាងទុកមិនឆ្ងាយពីអាស្រម ។ បទថា* ***ឃោសិតារាម*** *បានដល់ អារាមដែលឃោសិតសេដ្ឋីឲ្យសាងទុក ។*

*បានឮថា ក្នុងកាលមុន មានព្រំដែនឈ្មោះថា* ***អទិលៈ*** *លំដាប់នោះអ្នកក្រខ្សត់ម្នាក់ ឈ្មោះ* ***កោតុហលិក*** *ព្រោះកើតគ្រោះរាំងស្ងួត ទើបព្រមទាំងបុត្រ និងភរិយាទៅព្រំដែនដែលកំណត់តាមភ្លឺស្រែ កាលមិនអាចនឹងនាំបុត្រទៅបាន ទើបចោលហើយទៅ ។*

*មាតាបានត្រឡប់មកពបុត្រនោះទៅ ។ ទាំងពីរនាក់នោះ ចូលទៅកាន់*

ផ្ទះអ្នកចិញ្ចឹមគោមួយខ្នង ។ ក៏គ្រានោះ អ្នកទាំងឡាយនោះបានចាត់ចែងបាយបាយាសយ៉ាងច្រើនទុក ដើម្បីអ្នកចិញ្ចឹមគោទាំងឡាយ ប្តីប្រពន្ធទាំងពីរនាក់នោះ បានបាយបាយាសចាកពីស្រុកនោះបរិភោគហើយ ។ ខណៈនោះ កាលបុរសនោះបរិភោគបាយបាយាសច្រើន មិនអាចនឹងឲ្យអាហាររលួយបាន ហើយស្លាប់ក្នុងពេលយប់ បានបដិសន្ធិកើតជាកូនសុនខក្នុងពោះសុនខញីក្នុងផ្ទះនោះ ។ កូនសុនខនោះ បានជាទីស្រឡាញ់ ជាទីប្រោសប្រាណរបស់អ្នកចិញ្ចឹមគោ ។ ក៏អ្នកចិញ្ចឹមគោ បានទំនុកបម្រុងព្រះបច្ចេកពុទ្ធ ។ ដល់កាលព្រះបច្ចេកពុទ្ធឆាន់ស្រេចហើយ ក៏ឲ្យដុំបាយមួយដុំដល់កូនសុនខនោះ ។ វាធ្វើសេចក្តីស្រឡាញ់ឲ្យកើតក្នុងព្រះបច្ចេកពុទ្ធ ទៅបណ្ណសាលាជាមួយនឹងអ្នកចិញ្ចឹមគោ ។ កាលអ្នកចិញ្ចឹមគោមិនបានទៅ កូនសុនខនោះ ក៏ទៅក្នុងវេលាឆាន់ដោយខ្លួនឯងហើយព្រុសជិតទ្វារបណ្ណសាលាដើម្បីនឹងប្រាប់វេលា ។ សូម្បីកាលឃើញម្រឹគកាចក្នុងចន្លោះផ្លូវ ក៏ព្រុសឲ្យចៀសចេញទៅ ។ កូនសុនខនោះ មានចិត្តទោរទន់ក្នុងព្រះបច្ចេកពុទ្ធ ស្លាប់ហើយ បានទៅកើតក្នុងទេវលោក ។ គ្រានោះទេវបុត្រនោះ មានឈ្មោះថា **ឃោសកទេវបុត្រ** ។ កាលឃ្លាតចាកទេវលោកបានកើតក្នុងផ្ទះត្រកូលមួយក្នុងក្រុងកោសម្ពី ។ សេដ្ឋីជាអ្នកមិនមានបុត្រ បានឲ្យទ្រព្យដល់បិតាមាតារបស់ក្មេងនោះ ហើយនាំយកមកជាបុត្រ ។

លំដាប់នោះ កាលបុត្ររបស់ខ្លួនកើត សេដ្ឋីនោះបានព្យាយាមដើម្បីនឹងសម្លាប់ ៧ ដង ។ ក្នុងនោះ ព្រោះខ្លួនមានបុណ្យ មិនបានស្លាប់ក្នុងទីទាំង ៧ កន្លែង គ្រាចុងក្រោយ បានជីវិតព្រោះសេចក្តីឆ្លាតរបស់ធីតាសេដ្ឋីម្នាក់ ។ តមក កាលបិតាកន្លងទៅ ទើបបានតំណែងសេដ្ឋីឈ្មោះថា **ឃោសិតសេដ្ឋី** ។ ក្នុងក្រុងកោសម្ពី មានសេដ្ឋីដទៃទៀត ២ នាក់ គឺ កុក្កុដសេដ្ឋី ១ បាវារិកសេដ្ឋី ១ រួមទាំងឃោសិតសេដ្ឋីនេះចូលផង ទើបមាន ៣ នាក់ ។

គ្រានោះ ពួកសេដ្ឋីដែលជាសម្លាញ់នឹងគ្នានោះ មានឥសី ៥០០ ជាជីតុននៅជើងភ្នំ ។ គ្រាខ្លះ ពួកឥសីនោះនឹងមកអាវាសរបស់មនុស្ស ដើម្បីត្រូវការសេពរសប្រៃ និងជូរ ។ គ្រាមួយក្នុងរដូវក្តៅ កាលទៅលំនៅរបស់មនុស្សបានដើរហួស ចូលដល់ផ្លូវឆ្ងាយ រកទឹកមិនបាន ក្នុងទីបំផុតផ្លូវឆ្ងាយនោះ ឃើញដើមជ្រៃធំមួយដើម គិតគ្នាថា ក្នុងដើមឈើនេះគួរនឹងមានទេវតាអ្នកមានសក្តិធំស្ថិតនៅដោយពិត នឹងជាការល្អហ្ន៎ បើទេវតានោះនឹងគប្បីឲ្យទឹកផឹក និងរបស់គួរបរិភោគដល់ពួកយើង ។ ទេវតា ដឹងអធ្យាស្រ័យរបស់ពួកឥសីនោះ ទើបគិតថា យើងនឹងសង្គ្រោះពួកឥសីនេះ ដោយអានុភាពខ្លួន ទើបបណ្តាលឲ្យខ្សែទឹកប្រមាណប៉ុនដងនង្គ័ល ហូរពីចន្លោះបង្គាប ។ ពួកឥសីឃើញទឹកធ្លាក់ដូចដើមផ្កាំងប្រាក់ ទើបយកភាជនៈរបស់ខ្លួនដងទឹកបរិភោគនាំគ្នាគិតថា ពួក

យើង ទេវតាឲ្យទឹកផឹក ក៏ព្រៃធំនេះមិនមានពួកអ្នកស្រុក នឹងគប្បីជាការល្អហ្ន៎ បើទេវតានឹងឲ្យអាហារសូម្បីដល់ពួកយើង ។ ទេវតាទើបឲ្យបបរ និងរបស់ទំពារស៊ីដែលជាទិព្វជាដើម ឲ្យឆ្អែតគ្រប់គ្រាន់ហើយដោយអំណាចការចូលទៅសម្រេចដល់ពួកឥសី ។ ពួកឥសីម្នាក់ៗ នាំគ្នាគិតថា ទេវតាឲ្យរបស់គ្រប់យ៉ាងដល់ពួកយើងមិនថា ជាទឹកផឹក និងអាហារ បើទេវតានឹងគប្បីសម្ដែងខ្លួនដល់ពួកយើងក៏នឹងជាការល្អ ។ ពួកឥសីនោះទើបពោលថា ទេវតា សម្បត្តិរបស់លោកច្រើន លោកធ្វើកម្មអ្វីទុក ទើបសម្រេចសម្បត្តិនេះ ។

ទ. លោកដ៏ចម្រើន ខ្ញុំធ្វើកម្មបន្តិចបន្តួចមិនធំសម្បើមអ្វីទេ ក៏ខ្ញុំអាស្រ័យឧបោសថកម្មពាក់កណ្ដាល ទើបបានសម្បត្តិនោះ ។

បានឮថា គ្រានោះ ទេវបុត្រនេះ ជាអ្នកធ្វើការងារក្នុងផ្ទះរបស់អនាថ-បិណ្ឌិកៈ ។ ព្រោះថា ក្នុងផ្ទះរបស់សេដ្ឋី រាល់ថ្ងៃឧបោសថ អ្នកទាំងអស់ដោយហោចទៅទាសៈ និងអ្នកធ្វើការងារ ក៏ជាអ្នករក្សាឧបោសថ ។ ថ្ងៃមួយបុរសម្នាក់នេះប៉ុណ្ណោះ ក្រោកឡើងពីព្រឹកព្រលឹមទៅធ្វើការងារ ។ មហាសេដ្ឋីកាលបានកំណត់មនុស្សអ្នកដែលគួរនឹងបានអាហារទាំងឡាយ បានដឹងថា គេម្នាក់ប៉ុណ្ណោះចេញទៅព្រៃហើយ ទើបបានឲ្យចាត់ចែងអាហារទុកសម្រាប់វេលាល្ងាច ។ ស្ត្រីបម្រើជាចុងភៅដាំស្លដើម្បីគេម្នាក់ប៉ុណ្ណោះ កាលគេត្រឡប់ពីព្រៃ ទើបបាន

ជូសបាយទៅឲ្យ ។ បុរសនោះពោលថា វេលានេះ ក្នុងថ្ងៃដទៃៗ ពេញទាំងផ្ទះមានសំឡេងអ៊ូអរ ថ្ងៃនេះស្ងៀមស្ងាត់ហួសប្រមាណ តើនេះហេតុអ្វីហ្ន៎ មេចុង-ភៅនោះ ប្រាប់ដល់គេថា ថ្ងៃនេះ ក្នុងផ្ទះនេះមនុស្សទាំងអស់ជាអ្នករក្សាឧបោ-សថ មហាសេដ្ឋីបានឲ្យចាត់ចែងអាហារចំពោះលោកតែម្នាក់ ។

បុរស. ពិតឬនាង ។

ចុងភៅ. ពិតមែន ។

បុរស. អ្នកសមាទានឧបោសថវេលានេះ នឹងជាឧបោសថកម្មឬទេ នាងចូរសួរមហាសេដ្ឋីយ៉ាងនេះចុះ ។

មហាសេដ្ឋីត្រូវស្ត្រីបម្រើសួរទើបពោលថា មិនជាឧបោសថទាំងអស់ទេ តែនឹងជាឧបោសថពាក់កណ្តាល គេចូររក្សាឧបោសថចុះ ។

បុរសនោះ ទើបមិនបរិភោគអាហារ ខ្ពុរមាត់ រក្សាឧបោសថ ទៅទីនៅរបស់ខ្លួនហើយដេក កាលគេអស់អាហារ ខ្យល់បានកម្រើកឡើង ក្នុងពេលយប់គេក៏ស្លាប់វេលាព្រឹកព្រលឹម កើតជាទេវបុត្រនៅនឹងដើមជ្រៃក្នុងព្រៃជ្រៃធំ ព្រោះផលជាគ្រឿងហូរនៃឧបោសថពាក់កណ្តាល ទេវបុត្រនោះប្រាប់ ការប្រព្រឹត្តនោះដល់ពួកឥសី ។

ឥសី. លោកប្រកាសប្រាប់វត្ថុដែលយើងមិនធ្លាប់បានឮថា ព្រះពុទ្ធ ព្រះ

ធម៌ និងព្រះសង្ឃឲ្យបានឮថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោកហើយឬហ្ន៎ ។

ទេវតា. ទ្រង់ឧប្បត្តិឡើងហើយ លោកដ៏ចម្រើន ។

ឥសី. ឥឡូវនេះ ប្រថាប់នៅទីណា

ទេវតា. ទ្រង់អាស្រ័យក្រុងសាវត្ថីប្រថាប់នៅក្នុងវត្តជេតព លោកដ៏ចម្រើន ។

ឥសី. លោកចូរឈប់សិនចុះ ពួកខ្ញុំនឹងគាល់ព្រះសាស្តា ម្នាក់ៗ រីករាយត្រេកអរ ចេញទៅដល់ព្រះនគរកោសម្ពីដោយលំដាប់ ។ ពួកមហាសេដ្ឋីជ្រាបថា ឥសីទាំងឡាយមកហើយ ទើបទទួលថា លោកម្ចាស់ ។ ស្អែកនេះ សូមទទួលភិក្ខារបស់ពួកខ្ញុំ លុះដល់ថ្ងៃស្អែក ក៏បានថ្វាយមហាទានដល់គណឥសី ។ ពួកឥសីឆាន់ហើយ ទើបសួរគ្នាថា ពួកយើងនឹងនាំគ្នាទៅណា ។

សេដ្ឋី. លោកដ៏ចម្រើន លោកម្ចាស់វេលាដទៃៗ ក៏នៅសម្រាក ១ ខែខ្លះ ២ ខែខ្លះ ៣ ខែខ្លះ ៤ ខែខ្លះ (ក្នុងទីនេះ) ទើបទៅ តែលើកនេះមកកាលថ្ងៃម្សិលមិញពោលថា ពួកយើងនឹងទៅថ្ងៃនេះ ហេតុអ្វី ។

ឥសី. មែនហើយ គហបតី ព្រះពុទ្ធទ្រង់ឧប្បត្តិក្នុងលោកហើយ យើងមិនអាចដឹងអន្តរាយជីវិតបាន ព្រោះហេតុនោះ ពួកយើងទើបប្រញាប់ទៅ ។

សេដ្ឋី. លោកម្ចាស់ បើដូច្នោះ សូម្បីពួកខ្ញុំក៏នឹងទៅផង សូមពួកលោកទៅរួមជាមួយពួកខ្ញុំចុះ ។

ឥសី. ពួកលោកឈ្មោះថា ជាមហាជននៅគ្រប់គ្រងផ្ទះ ចូរកុំទាន់ទៅ ពួកខ្ញុំនឹងទៅមុន ដូច្នេះ នាំគ្នាចេញទៅ មិនសម្រាកកន្លែងមួយលើស ២ ថ្ងៃ បានទៅយ៉ាងប្រញាប់នោះឯង ដល់ក្រុងសាវត្ថីហើយ ទើបមកសម្នាក់ព្រះសាស្តា ក្នុងវត្តជេតពន ។ ឥសីទាំងអស់នោះឯង ស្តាប់ធម្មីកថាយ៉ាងពីរោះក្នុងទីនោះ បួសហើយ ក៏បានសម្រេចព្រះអរហត្ត ។

ចំណែកសេដ្ឋីទាំង ៣ បររទេះទៅ ម្នាក់ៗ ៥០០ ផ្ទុកទឹកដោះថ្លា ទឹកឃ្មុំ ស្ករអំពៅ និងសំពត់សំបកឈើជាដើម ចេញចាកក្រុងកោសម្ពីដល់ក្រុងសាវត្ថីដោយលំដាប់ បានតាំងជុំវិញវត្តជេតពន នាំគ្នាទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំធ្វើបដិសណ្ឋារៈហើយអង្គុយក្នុងទីមួយសមគួរ ។ ព្រះសាស្តា បានត្រាស់ធម្មីកថាយ៉ាងពីរោះដល់សម្លាញ់ទាំង ៣ ។ ពួកសេដ្ឋីទាំងនោះ កើតសោមនស្សយ៉ាងខ្លាំង ទូលនិមន្តព្រះសាស្តា ដើម្បីថ្វាយមហាទានក្នុងថ្ងៃស្អែក ។ ពួកគេថ្វាយជារៀងរាល់ថ្ងៃ រួមសេចក្តីមក បានថ្វាយយ៉ាងនេះរហូតអស់កន្លះខែ ក្រាបទីជិតព្រះបាទ ក្រាបទូលថា សូមព្រះអង្គប្រទានបដិញ្ញាណដើម្បីស្តេចមកជនបទរបស់ពួកខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា គហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងត្រេកអរយ៉ាងក្រៃលែងក្នុងផ្ទះដែលស្ងាត់ ។ ពួកគហបតីម្នាក់ៗ កំណត់គ្នាថា ហេតុប៉ុណ្ណេះ ក៏ជាការព្រះមានព្រះភាគទ្រង់បាន

ប្រទានបដិញ្ញាណហើយ ហើយគិតថា ព្រះមានព្រះភាគទ្រង់ប្រទានបដិញ្ញាណដល់ពួកយើងហើយ ថ្វាយបង្គំព្រះទសពល ចេញទៅឲ្យសាងវិហារគ្រប់ៗ ១ យោជន៍ចន្លោះផ្លូវរហូតដល់ក្រុងកោសម្ពីដោយលំដាប់ ម្នាក់ៗ នាំគ្នាពោលថា ព្រះពុទ្ធទ្រង់ឧប្បត្តិក្នុងលោកហើយ ។ ចំណែកសេដ្ឋីទាំង ៣ បរិច្ចាគទ្រព្យចំនួនច្រើនក្នុងអារាមរៀងៗ ខ្លួន ឲ្យសាងវិហារសម្រាប់ជាទីប្រថាប់របស់ព្រះមានព្រះភាគ ។ សេដ្ឋីទាំង ៣ នោះ កុក្កុដសេដ្ឋីឲ្យសាង **កុក្កុដារាម** ។ បាវារិកសេដ្ឋីឲ្យសាង **បាវារិកម្ពវ័ន** ក្នុងព្រៃស្វាយ ។ ឃោសិតសេដ្ឋីឲ្យសាង **ឃោសិតារាម** ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកឃោសិតារាមនោះ ទើបត្រាស់ថា ក្នុងអារាមដែលឃោសិតសេដ្ឋីឲ្យសាងទុក ។

ក្នុងបទជាដើមថា **កើតការបង្កហេតុ** គួរធ្វើវិគ្រោះថា ខាងដើមនៃការឈ្លោះ ឈ្មោះថា ការបង្កហេតុ ការបង្កហេតុនោះ កើតដល់ភិក្ខុពួកនោះ ព្រោះហេតុនោះ ឈ្មោះថា មានការបង្កហេតុកើតឡើង ។ ការឈ្លោះដែលដល់ទីបំផុត ដោយអំណាចលំពែង គឺ មាត់ជាដើម កើតដល់ភិក្ខុទាំងនោះ ហេតុនោះ ឈ្មោះថា អ្នកមានជម្លោះកើតឡើងហើយ ។

ពីរបទថា **វាទៈដែលខុសគ្នា** សេចក្តីថា ភិក្ខុទាំងនោះ ដល់ការវិវាទនោះ ហេតុនោះ ឈ្មោះថា ដល់ការពោលផ្សេងគ្នា ។ បទថា **ដោយលំពែង**

គឺ មាត់ បានដល់ ដោយលំពែង គឺ វាចាទាំងឡាយ ។

បទថា **ទម្ពុះហើយ** គឺ ចាក់ហើយ ។

ប្រើនបទថា **ភិក្ខុទាំងនោះមិនញុំាងគ្នានិងគ្នាឲ្យយល់ព្រម និងមិនចូលដល់សេចក្តីយល់ព្រម** សេចក្តីថា ភិក្ខុទាំងនោះ សម្តែងហេតុផលហើយ មិនយល់ព្រមគ្នានិងគ្នា ។ អធិប្បាយថា បើប្រាជ្ញានឹងឲ្យគ្នានិងគ្នាយល់ព្រមតាមសោត ។ ពួកលោកក៏នឹងមិនចូលដល់សេចក្តីយល់ព្រម សូម្បីយ៉ាងនោះ (ទាំង) មិនប្រាជ្ញាដើម្បីនឹងយល់ព្រម ។ សូម្បីក្នុងការសម្លឹងរំពៃក៏ន័យនេះ ។ ពាក្យថា **ឃើញ** ក្នុងពាក្យថា សម្លឹងរំពៃនោះ ជាវេវចនៈរបស់ពាក្យថា "ដឹងព្រម" ជ្រាបថា ភិក្ខុ ២ រូប គឺ ភិក្ខុទ្រទ្រង់វិន័យ និងភិក្ខុទ្រទ្រង់ព្រះសូត្រ នៅវត្តជាមួយគ្នា ។ ទាំង ២ រូបនោះ ភិក្ខុទ្រទ្រង់ព្រះសូត្រ ថ្ងៃមួយចូលវេច្ចកុដិ បន្សល់ទឹកសម្រាប់លាងទុកក្នុងភាជនៈ ហើយចេញទៅ ភិក្ខុដែលទ្រទ្រង់វិន័យចូលទៅខាងក្រោយ ឃើញទឹកនោះ ចេញមកហើយសួរភិក្ខុនោះថា លោកម្ចាស់ ទឹកនេះលោកបន្សល់ទុកឬ ។

ស. ករុណា អាវុសោ ។

វ. លោកមិនដឹងថា ជាអាបត្តិព្រោះហេតុនោះទេឬ ។

ស. ករុណា មិនជ្រាប ។

វ. អាវុសោ ជាអាបត្តិក្នុងសេចក្តីនេះ ។

ស. បើមាន ខ្ញុំព្រះករុណានឹងសម្តែង ។

វ. អាវុសោ ក៏បើលោកមិនក្លែងធ្វើទេ ព្រោះភ្លេចសតិ អាវុសោ ក៏មិនជាអាបត្តិ ។

ភិក្ខុដែលទ្រទ្រង់ព្រះសូត្រ បានជាអ្នកឃើញថា មិនជាអាបត្តិក្នុងវត្ថុដែលជាអាបត្តិ ។ ភិក្ខុដែលទ្រទ្រង់វិន័យ ទើបប្រាប់ដល់ពួកសិស្សរបស់ខ្លួនថា លោកដែលទ្រទ្រង់ព្រះសូត្រនេះ សូម្បីត្រូវអាបត្តិក៏នៅតែមិនដឹង ។ ពួកភិក្ខុជាសិស្សរបស់ភិក្ខុវិន័យធរ ឃើញពួកសិស្សរបស់ភិក្ខុទ្រទ្រង់ព្រះសូត្រ ទើបពោលថា ឧបជ្ឈាយ៍របស់ពួកលោក សូម្បីត្រូវអាបត្តិហើយ ក៏មិនដឹងថាជាអាបត្តិ ។ ភិក្ខុជាសិស្សរបស់ភិក្ខុអ្នកទ្រទ្រង់ព្រះសូត្រនោះ ទើបទៅប្រាប់ដល់ឧបជ្ឈាយ៍របស់ខ្លួន ។ ភិក្ខុអ្នកទ្រទ្រង់ព្រះសូត្រ ទើបពោលយ៉ាងនេះថា ព្រះវិន័យធរនេះ កាលមុនពោលថា មិនជាអាបត្តិ ឥឡូវនេះពោលថា ជាអាបត្តិ គេជាមនុស្សពោលកុហក ។ ពួកសិស្សរបស់ភិក្ខុទ្រទ្រង់ព្រះសូត្រ ទើបទៅពោលថា ឧបជ្ឈាយ៍របស់ពួកលោកពោលកុហក ដូច្នេះ ទើបមានបែកខ្ញែកឈ្លោះទៅកាន់គ្នានិងគ្នា ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកការឈ្លោះនោះ ទើបត្រាស់ពាក្យនេះទុក ។

បទថា **បានក្រាបទូលយ៉ាងនេះចំពោះព្រះមានព្រះភាគ** សេចក្ដីថា បានក្រាបទូលពាក្យខាងដើមនោះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមប្រទានឱកាស ពួកភិក្ខុក្នុងក្រុងកោសម្ពី កើតការបង្កហេតុនឹងគ្នាហើយ ។ ក៏ភិក្ខុនោះមិនបានពោលពាក្យនោះ ព្រោះបំណងជាទីស្រឡាញ់ ទាំងមិនបានពោល ព្រោះត្រូវការបែងចែក តែការពិត ព្រោះត្រូវការប្រយោជន៍ (និង) ការជួយសង្គ្រោះ ។ ន័យថា ភិក្ខុនេះជាអ្នកធ្វើឲ្យកើតសាមគ្គីគ្នា ដូច្នោះ ទើបមានការគិតយ៉ាងនេះថា ភិក្ខុទាំងនេះប្រារព្ធការបង្កហេតុ និងវិវាទ ដូចដែលយើងនិងភិក្ខុដទៃ ក៏មិនអាចធ្វើឲ្យព្រមព្រៀងគ្នាបាន តើធ្វើដូចម្ដេចហ្ន៎ ព្រះមានព្រះភាគ ទ្រង់មិនមានអ្នកប្រៀបផ្ទឹមក្នុងលោក ព្រមទាំងទេវលោក ស្ដេចទៅដោយព្រះអង្គឯង ឬថាត្រាស់បង្គាប់ឲ្យហៅមកកាន់សម្នាក់របស់ព្រះអង្គ ត្រាស់ធម្មទេសនា ជាហេតុឲ្យរលឹកដល់គ្នា ប្រកបដោយខន្តិ និងមេត្តាដល់ភិក្ខុទាំងនោះ ក៏នឹងគប្បីធ្វើឲ្យស្ម័គ្រស្មោះគ្នាបាន ទើបបានទៅក្រាបទូល ព្រោះប្រាថ្នាប្រយោជន៍ (និង) ការជួយសង្គ្រោះ ។

[១៨២] បទថា **ភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃសេចក្ដីរលឹកដល់គ្នា ៦ ប្រការនេះ** សេចក្ដីថា ប្រារព្ធទេសនាដោយអំណាចការឈ្លោះ និងការបង្កហេតុក្នុងកាលមុន ។ ច្រើនបទថា **ធម៌ជាទីតាំងនៃសេចក្ដីរលឹកដល់ ៦ មក**

**ហើយក្នុងឋានៈនេះ** សេចក្តីថា កោសម្ពិយសូត្រនេះ ជាការមកហើយ តាមការបន្តយ៉ាងនេះ ។

ក្នុងបទនេះ បទថា **ជាទីតាំងនៃសេចក្តីរលឹកដល់** សេចក្តីថា កាលកាលកន្លងទៅយូរមិនគួរភ្លេច ព្រោះប្រកបដោយធម៌ដែលគួររលឹកដល់ អ្នកណាបំពេញធម៌ទាំងនោះ ធម៌ទាំងនោះ រមែងធ្វើអ្នកនោះឲ្យជាទីស្រឡាញ់របស់សម្មាញ់អ្នកប្រព្រឹត្តព្រហ្មចារ្យរួមគ្នា ហេតុនោះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យជាទីស្រឡាញ់ ។ ឈ្មោះថា **ជាគ្រឿងធ្វើសេចក្តីគោរព** ព្រោះធ្វើសេចក្តីគោរព ។

បទថា **ដើម្បីសង្គ្រោះ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការសង្គ្រោះ ។

បទថា **ដើម្បីមិនវិវាទ** បានដល់ ដើម្បីប្រយោជន៍ដល់សេចក្តីមិនវិវាទ ។

បទថា **ដើម្បីសេចក្តីព្រមព្រៀង** បានដល់ ដើម្បីប្រយោជន៍សាមគ្គីស្មោះគ្នា ។

បទថា **ដើម្បីមូលមិត្តគ្នា** សេចក្តីថា ដើម្បីប្រយោជន៍នៃការមូលមិត្តគ្នា គឺ ដើម្បីមិនធ្វើឲ្យផ្សេងគ្នា ។

បទថា **ប្រព្រឹត្តទៅព្រម** បានដល់ មានហើយ ។

បទថា **មេត្តាកាយកម្ម** បានដល់ កាយកម្ម ដែលគប្បីធ្វើដោយចិត្តប្រកបដោយមេត្តា ។ សូម្បីក្នុងវចីកម្ម និងមនោកម្ម ក៏ន័យនេះនោះឯង ។

មេត្តាចិត្តទាំងនេះ មកហើយដោយអំណាចភិក្ខុទាំងឡាយ រមែងមិនបានសូម្បី ក្នុងពួកគ្រហស្ថ ។ មេត្តាជាគ្រឿងបំពេញអភិសមាចារិកធម៌ដោយចិត្តប្រកប ដោយមេត្តារបស់ភិក្ខុទាំងឡាយ ឈ្មោះថា កាយកម្ម ។ កម្មជាដើមយ៉ាងនេះ គឺ ការទៅដើម្បីប្រយោជន៍សំពះចេតិយ ១ សំពះដើមពោធិព្រឹក្ស ១ និមន្ត ព្រះសង្ឃ ១ ការឃើញភិក្ខុទាំងឡាយអ្នកចូលទៅគោចរគ្រាមដើម្បីបិណ្ឌបាត ហើយទទួល ១ ការទទួលបាត្រ ១ ការក្រាលអាសនៈ ១ ការតាមបញ្ជូន ១ របស់ពួកគ្រហស្ថ ឈ្មោះថា មេត្តាកាយកម្ម ។ ឈ្មោះថា មេត្តាវចីកម្ម គឺ ការប្រាប់សិក្ខាបទ គឺ បញ្ញត្តិជាប់ទាក់ទងនឹងមារយាទ ការប្រាប់កម្មដ្ឋាន ការ សម្តែងធម៌ ការប្រាប់ពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ដោយចិត្តមេត្តារបស់ភិក្ខុ ទាំងឡាយ ។ម្យ៉ាងទៀត កម្មក្នុងកាលដែលពោលជាដើមថា យើងនឹងទៅ សំពះព្រះចេតិយ ១ សំពះដើមពោធិព្រឹក្ស ១ នឹងឲ្យធ្វើការស្តាប់ធម៌ ១ នឹង បូជាដោយប្រទីប កម្រងផ្កាឈើ ១ នឹងប្រព្រឹត្តសមាទានសុចរិតបី ១ ថ្វាយ ស្លាកភត្តជាដើម ១ ថ្វាយសំពត់ចាំវស្សា ១ ថ្វាយបច្ច័យ ៤ ដល់សង្ឃក្នុង ថ្ងៃនេះ ១ ពួកលោកចូរនិមន្តព្រះសង្ឃ ហើយចាត់ចែងរបស់ទំពាររបស់ឆាន់ជា ដើម ១ ចូរក្រាលអាសនៈ ១ ចូរតាំងទឹកឆាន់ ១ ចូរទទួលហើយនាំព្រះសង្ឃ នោះមកដោយខ្លួនឯង ១ ចូរនិមន្តព្រះសង្ឃឲ្យអង្គុយលើអាសនៈ ដែលក្រាល

ទុក កើតសេចក្ដីពេញចិត្តឲ្យខ្លាំង ហើយចូរធ្វើសេចក្ដីខ្វល់ខ្វាយ ដូច្នេះ របស់ពួកគ្រហស្ថ ឈ្មោះថា មេត្តាវចីកម្ម ។ ការក្រោកឡើងពីព្រឹក ហើយបដិបត្តិរាងកាយ ធ្វើវត្តចេតិយ និងគណៈជាដើម អង្គុយលើអាសនៈដ៏ស្ងាត់ គិតថា "សូមពួកភិក្ខុក្នុងវិហារនេះ ចូរមានសេចក្ដីសុខ ចូរកុំមានពៀរ កុំព្យាបាទគ្នា" ឈ្មោះថា មេត្តាមនោកម្ម ។

បទថា **ទីវាល និងទីកំបាំង** សេចក្ដីថា ចំពោះមុខផង កំបាំងមុខផង ។

បណ្ដាកម្មនោះ ការដល់ភាពជាសម្លាញ់ក្នុងចីវរកម្មជាដើម របស់ភិក្ខុថ្មីទាំងឡាយ ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។

មួយទៀត សាមីចិកម្មទាំងអស់ ផ្សេងដោយកម្ម មានការលាងជើង និងបក់ផ្លិតឲ្យជាដើម របស់ព្រះថេរៈ ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។

ការមិនធ្វើសេចក្ដីមើលបំណាំក្នុងគ្រឿងឈើជាដើម ដែលទាំងពីរចំណែករក្សាទុកមិនល្អ ហើយរក្សា ដូចរក្សារបស់ដែលខ្លួនរក្សាទុកមិនល្អ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។

ការពោលលើកតម្កើងយ៉ាងនេះថា ព្រះទេវត្ថេរៈ ព្រះតិស្សត្ថេរៈ ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ ។

ក៏ការដែលបុគ្គលសួរចំពោះភិក្ខុដែលមិននៅក្នុងវិហារនោះឯង ពោល

អាងថា ជារបស់ខ្លួនយ៉ាងនេះថា ព្រះទេវត្ថេរៈរបស់ពួកយើងទៅណា នឹងមក វេលាណាហ្ន៎ ព្រះតិស្សៈត្ថេរៈរបស់ពួកយើងទៅណា នឹងមកវេលាណាហ្ន៎ ដូច្នេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ។

ម្យ៉ាងទៀត ការបើកភ្នែកដែលស្និទ្ធដោយសេចក្តីស្រឡាញ់ប្រកបដោយ មេត្តាហើយមើលដោយទឹកមុខថ្លាផូរផង់ ឈ្មោះថា មេត្តាមនោកម្មចំពោះមុខ ។ ការប្រមូលមកថា ព្រះទេវត្ថេរៈ ព្រះតិស្សៈត្ថេរៈ ចូរកុំមានរោគ មានអាពាធ តិច ឈ្មោះថា មេត្តាមនោកម្មកំបាំងមុខ ។

បទថា **លាភ** បានដល់ បច្ច័យដែលបាន មានចីវរជាដើម ។

បទថា **ជាធម៌** សេចក្តីថា បច្ច័យដែលកើតឡើងដោយវត្ត គឺ វៀរចាក ការចិញ្ចឹមជីវិតខុសផ្សេងៗ មានដោយការកុហកជាដើម ហើយត្រាច់ទៅដើម្បី អាហារដោយធម៌ដែលស្មើ ។

បទថា **ដោយទីបំផុត សូម្បីត្រឹមតែជាអាហារដែលមាននៅក្នុងបាត្រ** សេចក្តីថា សូម្បីត្រឹមតែជាអាហារ ២-៣ វែក ដែលមាននៅក្នុងបាត្រ គឺ នៅ ខាងក្នុងបាត្រ ដោយចំណែកបំផុតខាងក្រោយ ។

ក្នុងបទថា **អ្នកបរិភោគ (អាហារ) ដែលមិនទាន់បានបែងចែកទុកនេះ** ឈ្មោះថា អ្នកមានអាហារដែលបែងចែកហើយមាន ២ គឺ ចែកអាមិស ១

ចែកបុគ្គល ១ ។

ក្នុងការបែងចែកចំណែកទាំង ២ នោះ ការបែងចែកដោយចិត្តយ៉ាងនេះថា យើងនឹងឲ្យប៉ុណ្ណេះ នឹងមិនឲ្យប៉ុណ្ណេះ ។ ឈ្មោះថា បែងចែកអាមិស ។

ការបែងចែកដោយចិត្តយ៉ាងនេះថា យើងនឹងឲ្យដល់អ្នកឯណោះ មិនឲ្យដល់អ្នកឯណោះ ឈ្មោះថា បែងចែកដោយចំណែកបុគ្គល ។

ការចែកដោយបុគ្គល មិនធ្វើសូម្បីទាំង ២ យ៉ាងនោះ និងបរិភោគអាហារ ដែលមិនបានបែងចែកទុកនេះ ឈ្មោះថា អ្នកមានប្រក្រតីបរិភោគអាហារដែលមិនបានបែងចែកទុក ។

ក្នុងពាក្យថា **អ្នកមានប្រក្រតីបរិភោគទូទៅ នឹងសម្មាញ់អ្នកប្រព្រឹត្តព្រហ្មចរិយៈរួមគ្នានឹងអ្នកមានសីល** មានអធិប្បាយថា ភិក្ខុដែលមានប្រក្រតីបរិភោគទូទៅ មានលក្ខណៈដូច្នេះ លោកបានវត្ថុណាៗ ប្រណីត ក៏មិនឲ្យវត្ថុនោះៗ ដោយលាភ លោកនឹងឲ្យលាភដល់គ្រហស្ថទាំងឡាយ ក៏ដោយការផ្ទោះមុខស្វែងរក ទាំងខ្លួនក៏មិនបរិភោគ កាលនឹងទទួល ក៏ទទួលយកដោយគិតថា ចូរជារបស់ទូទៅដល់សង្ឃ គោះរគាំងហើយ ក្រឡេកមើលដូចរបស់សង្ឃដែលគួរបរិភោគ ។

សួរថា ក៏អ្នកណាបំពេញធម៌ជាគ្រឿងឲ្យរលឹកដល់គ្នា ( និង ) អ្នកណា

មិនបំពេញ ?

ឆ្លើយថា អ្នកទ្រុស្តសីលមិនបំពេញ ព្រោះថា អ្នកមានសីលទាំងឡាយ រមែងមិនកាន់យកវត្ថុដែលជារបស់អ្នកនោះ ។ ចំណែកថា អ្នកមានសីលបរិសុទ្ធិ មិនធ្វើវត្តឲ្យដាច់ រមែងធ្វើឲ្យពេញ ។ ក្នុងសេចក្តីនោះ មានទំនៀមនេះ (ជាឧទាហរណ៍) ។

ក៏អ្នកដែលធ្វើចំពោះហើយ ទើបឲ្យដល់មាតាបិតា ឬថា អាចារ្យ និងឧបជ្ឈាយ៍ជាដើមនោះ ឲ្យវត្ថុដែលគួរឲ្យ ។ អ្នកនោះរមែងមិនមានធម៌ជាគ្រឿងឲ្យរលឹកដល់គ្នា ។ មានតែការរក្សាសេចក្តីកង្វល់ ព្រោះថា អ្នកផុតពីសេចក្តីកង្វល់ប៉ុណ្ណោះ ទើបនឹងសមគួរនឹងធម៌ជាទីតាំងនៃសេចក្តីរលឹកដល់គ្នា ។ អ្នកនោះ កាលនឹងឲ្យចំពោះ គួរឲ្យដល់ភិក្ខុដែលមានជម្ងឺ អ្នករក្សាភិក្ខុឈឺ អ្នកត្រាច់មក អ្នកត្រៀមនឹងទៅខ្វះ ដល់អ្នកបួសថ្មីដែលមិនដឹងវត្តសម្រាប់ទទួលសង្ឃាដិ និងបាត្រ កាលនឹងថ្វាយដល់ភិក្ខុទាំងនោះ តាំងពីអាសនៈសម្រាប់ព្រះថេរៈចុះមកមិនគួរថ្វាយឲ្យនៅសល់បន្តិចបន្តួច ថ្វាយល្មមដែលលោកកាន់យកនោះ ។ កាលមិនមានសល់ ក៏គួរត្រាច់ទៅបិណ្ឌបាត ហើយថ្វាយរបស់ដែលប្រណីតនោះៗ តាំងពីអាសនៈព្រះថេរៈចុះមក ហើយឆាន់របស់ដែលសល់ ព្រោះពោលយ៉ាងនេះថា អ្នកមានសីល ដូច្នេះ សូម្បីការមិនឲ្យដល់អ្នកមិនមាន

សីលក៏គួរ ។ ប្រសិនបើថា ធម៌ដែលជាទីតាំងនៃសេចក្ដីរលឹកដល់គ្នានិងគ្នា ដែលបរិស័ទមិនបានសិក្សាមិនបំពេញហើយ ព្រោះថា កាលបរិស័ទបានសិក្សាហើយ អ្នកដែលបាន... តែអ្នកដទៃនោះ រមែងមិនកាន់យកសូម្បីកាលមិនបានពីអ្នកដទៃ ក៏កាន់យកល្មមប្រមាណប៉ុណ្ណោះ មិនកាន់យកហួសប្រមាណ ។ ក៏ធម៌ជាទីតាំងនៃសេចក្ដីរលឹកដល់គ្នានេះ ភិក្ខុដែលកាលនឹងឲ្យវត្តុដែលខ្លួនត្រាច់ទៅបិណ្ឌបាតបានហើយបានទៀតដដែលៗ ប្រព្រឹត្តឲ្យពេញទាំង ១២ ឆ្នាំ មិនខ្វះជាងនោះ ។ ប្រសិនបើថា ភិក្ខុដែលបំពេញធម៌ជាទីតាំងនៃសេចក្ដីរលឹកដល់គ្នាដាក់បាត្រដែលពេញដោយបិណ្ឌបាត កន្លែងរោងឆាន់ ហើយទៅងូតទឹក ។ ព្រះសង្ឃត្ថេរៈ សួរថា នេះបាត្រអ្នកណា កាលគេពោលថា របស់ភិក្ខុដែលបំពេញធម៌ជាទីតាំងនៃសេចក្ដីរលឹកដល់គ្នា ទើបពោលថា ពួកលោកចូរនាំបាត្រនោះមក ហើយចាត់ចែងបិណ្ឌបាតគ្រប់យ៉ាង ឆាន់ហើយដាក់បាត្រទទេទុក ។

ភិក្ខុនោះ កើតសេចក្ដីខូចចិត្តថា ភិក្ខុទាំងឡាយឆាន់ (អាហារ) របស់យើងហើយឲ្យនៅសល់តែបាត្រទទេទុក ។ សារាណិយធម៌ រមែងបែកធ្លាយ លោកត្រូវបំពេញ ១២ ឆ្នាំទៀត ។ ក៏សារាណិយធម៌នេះ ដូចជាតិត្ថិយបរិវាសកាលដាច់តែមួយដង ក៏គប្បីប្រព្រឹត្តទៀត ។ ភិក្ខុណាកើតសេចក្ដីសប្បាយចិត្តថា ប្រការភិក្ខុដែលប្រព្រឹត្តព្រហ្មចារ្យរួមនឹងយើង មិនសួរដោយអើពើដល់អាហារ

ដែលនៅក្នុងបាត្រហើយឆាន់ នោះជាលាភរបស់យើងហ្ន៎ យើងបានល្អហើយហ្ន៎ ។ ភិក្ខុនោះឈ្មោះថា មានសាភាណិយធម៌បរិបូរហើយ ។ ចំណែកសេចក្តីឫស្យា និងសេចក្តីកំណាញ់ នឹងមិនមានដល់ភិក្ខុដែលបំពេញសាភាណិយធម៌យ៉ាងនេះដោយពិត ។ លោកជាទីស្រឡាញ់របស់ពួកមនុស្ស ទាំងបច្ច័យក៏មិនបានងាយជាងអ្នកដល់វត្ថុដែលនៅក្នុងបាត្រ ដែលគេថ្វាយដល់ លោកក៏មិនអស់ទៅ ។ រមែងបានវត្ថុល្អប្រសើរ ក្នុងចំណែកវត្ថុដែលគប្បីបែងចែក លុះដល់សេចក្តីភ័យខ្លាច ឬសេចក្តីស្រេកឃ្លាន ពួកទេវតារមែងខ្វល់ខ្វាយ ។ ក្នុងសេចក្តីនោះ មានរឿងទាំងនេះជាឧទាហរណ៍ ៖

បានស្តាប់មកថា ព្រះតិស្សត្ថេរៈអ្នកនៅក្នុងសេលាគិរីវិហារ អាស្រ័យស្រុកមហាគិរី ។ កាលព្រះមហាថេរៈ ៥០ រូប កំពុងទៅកោះនាគដើម្បីថ្វាយបង្គំព្រះចេតិយ ត្រាច់បិណ្ឌបាតក្នុងស្រុកគិរីមិនបានអ្វី ក៏និមន្តចេញទៅ ។ កាលព្រះថេរៈចូល ទៅឃើញព្រះមហាថេរៈទាំងនោះ សួរថា បានអ្វីខ្លះលោកម្ចាស់ ។ អ្នកដ៏មានអាយុ ពួកយើងបានត្រាច់ទៅហើយ ។

ព្រះថេរៈនោះដឹងថា ព្រះមហាថេរៈទាំងនោះ មិនមានអ្វី ទើបពោលថា លោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយ ចូរនៅទីនេះ ទម្រាំតែខ្ញុំព្រះករុណាមកវិញ ។ អ្នកមានអាយុ ពួកយើងទាំង ៥០ នាក់ (ទៅហើយ) ក៏នៅមិនបាន

ល្មមឲ្យសើមបាត្រ ។ លោកម្ចាស់ ធម្មតាអ្នកនៅប្រចាំជាអ្នកអាចសូម្បីកាល មិនបាន ក៏នៅជីងសភាពប្រមាណភិក្ខាចារ ។ ពួកព្រះថេរៈមកហើយ ។ ព្រះថេរៈទើបចូលទៅកាន់ស្រុក ។ មហាឧបាសិកាក្នុងផ្ទះដែលឆ្ងាយៗ បានចាត់ចែងទឹកដោះ និងបាយ ឈរចាំមើលព្រះថេរៈ កាលព្រះថេរៈដល់ទ្វារប៉ុណ្ណោះ ក៏បានដាក់បាត្រឲ្យពេញថ្វាយ ។ ព្រះថេរៈកាន់បាត្រនោះទៅកាន់សម្នាក់ព្រះថេរៈទាំងឡាយ ពោលនឹងព្រះសង្ឃត្ថេរៈថា លោកម្ចាស់ សូមលោកទទួលចុះ ។ ព្រះថេរៈសម្លឹងមើលមុខព្រះថេរៈដទៃបណ្តើរ គិតបណ្តើរថា ពួកយើងទាំងនេះមិនបានអ្វីឡើយ ភិក្ខុនេះកាន់យកមកហើយដោយរហ័សតែម្តង នេះជាអ្វីហ្ន៎ ។

ព្រះថេរៈជ្រាបដោយអាការក្រឡេកមើល ទើបពោលថា បិណ្ឌបាតខ្ញុំព្រះករុណា បានមកប្រកបដោយធម៌ សូមពួកលោកកុំរង្កៀស ទទួលយកចុះ ហើយបានប្រគេនដល់ព្រះថេរៈទាំងនោះតាមត្រូវការ ចំណែកខ្លួនក៏ឆាន់តាមត្រូវការ ។ លំដាប់នោះ កាលឆាន់ស្រេច ពួកព្រះថេរៈទើបសួរលោកថា អ្នកមានអាយុចាក់ធ្លុះលោកុត្តរធម៌កាលណា ។

ថេរ. ខ្ញុំព្រះករុណាមិនទាន់មានលោកុត្តរធម៌ទេ លោកម្ចាស់ ។

មហាថេរ. អ្នកមានអាយុ បានឈានឬ

ថេរ.សូម្បីឈានក៏មិនមាន លោកម្ចាស់ ។

មហាថេរ. អ្នកមានអាយុ បានបាដិហារ្យមិនមែនឬ ។

ថេរ. លោកម្ចាស់ ខ្ញុំព្រះករុណា បំពេញសារាណិយធម៌ តាំងពីខ្ញុំព្រះករុណាបំពេញសារាណិយធម៌មក សូម្បីមានភិក្ខុទាំង ១.០០០ រូប អាហារក្នុងបាត្រក៏មិនអស់ទៅ ។

មហាថេរ. ល្អហើយៗ លោកសប្បុរស នេះសមគួរដល់លោក ។ ក្នុងពាក្យថា **អាហារក្នុងបាត្ររបស់លោកក៏មិនអស់ទៅមុន** មានរឿងដូចតទៅនេះ ៖

ព្រះថេរៈអង្គផ្សេងទៀតនុ៎ះឯង បានទៅថ្វាយទានក្នុងទីបូជាធំនៃគិរីភណ្ឌ-វិហារ ឯចេតិយបព៌ត សួរថា ទាននេះមានអ្វីជារបស់ដ៏ប្រសើរ ។ សំពត់ ២ ផ្ទាំង លោកម្ចាស់ ។ សំពត់ទាំងពីរផ្ទាំងនោះ ត្រូវបានដល់យើងណា៎ះ អាមាត្យស្ដាប់ពាក្យនោះ ទើបក្រាបទូលព្រះរាជាថា ព្រះអង្គ ភិក្ខុកម្លោះពោលយ៉ាងនេះ ។

ព្រះរាជា. ការគិតរបស់ភិក្ខុកម្លោះសមគួរនោះឯង ប៉ុន្តែថា ព្រះមហាថេរៈទាំងឡាយ ក៏សមគួរដល់សំពត់សាច់ល្អ ហើយទ្រង់ដាក់ព្រះទ័យដោយទ្រង់ត្រិះរិះថា យើងថ្វាយព្រះមហាថេរៈទាំងឡាយ ។ កាលព្រះភិក្ខុឈរតាមលំដាប់ សំពត់ ២ ផ្ទាំងដែលទូលលើព្រះសិរសារបស់ព្រះអង្គដែលកំពុងថ្វាយមិនចុះមកកាន់ព្រះហស្តសូម្បីតែមួយផ្ទាំង (ចំណែក) សំពត់ផ្ទាំងដទៃៗ ប៉ុណ្ណោះដែលចុះមក ប៉ុន្តែថា វេលាថ្វាយភិក្ខុកម្លោះ សំពត់ទាំង ២ ផ្ទាំងនោះ ក៏ចុះមក

កាន់ព្រះហស្ថ ។ ព្រះរាជាទ្រង់ដាក់លើដៃភិក្ខុកម្លោះនោះ មើលមុខអមាត្យ ទ្រង់ឲ្យភិក្ខុកម្លោះអង្គុយ ហើយថ្វាយទាន ទ្រង់លះព្រះសង្ឃមកប្រថាប់ជិតភិក្ខុកម្លោះ ត្រាស់ថា លោកម្ចាស់ ធម៌នេះ លោកចាក់ធ្លុះក្នុងកាលណា កាលមិនពោលដោយត្រង់ៗ ទើបថ្វាយព្រះពរថា មហាបពិត្រ អាត្មាភាពមិនមានលោកុត្តរធម៌ ។

ព្រះរាជា. លោកម្ចាស់ បានពោលទុកមុនមិនមែនឬ ?

ថេរ. ថ្វាយព្រះពរ មហាបពិត្រ អាត្មាភាពបំពេញសារាណិយធម៌ តាំងពីវេលាអាត្មាភាពបំពេញធម៌នោះមក ក៏បានវត្ថុយ៉ាងល្អប្រសើរក្នុងទីដែលគប្បីបែងចែក ។

ព្រះរាជា. ល្អហើយ ល្អហើយ លោកម្ចាស់ សំពត់នេះគួរដល់លោកម្ចាស់ ទ្រង់សំពះហើយ ចៀសចេញទៅ ។ ក្នុងពាក្យថា **បានរបស់ល្អប្រសើរក្នុងទីដែលគប្បីបែងចែក** នេះ មានរឿងនេះជាឧទាហរណ៍ ។

ក៏ភិក្ខុទាំងឡាយ មានប្រក្រតីនៅក្នុងស្រុកភាតរៈក្នុងចណ្ឌាលតិស្សរភយវិហារ មិនប្រាប់ព្រះថេរី ឈ្មោះនាគា ក៏ចៀសទៅ ។ ព្រះថេរីពោលនឹងពួកភិក្ខុនីក្រមុំវេលាព្រឹកព្រលឹមថា ពួកអ្នកស្រុកស្ងាត់សំឡេងហួសប្រមាណ ពួកនាងចូរសាកសួរមើលមើល៍ ។ ភិក្ខុនីក្រមុំទាំងនោះទៅ ដឹងថា ភិក្ខុទាំងអស់ទៅហើយ ទើបត្រឡប់មកប្រាប់ព្រះថេរី ។ ព្រះថេរីនោះ បានស្តាប់ហើយ ពោល

ថា ពួកនាងកុំគិតថា ភិក្ខុទាំងនោះទៅហើយ ចូរធ្វើសេចក្ដីព្យាយាមក្នុងការរៀនបាលី សាកសួរ និងការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាចុះ កាលដល់វេលាត្រាច់ភិក្ខា ទើបដណ្ដប់សំពត់ បានជាអ្នកទី ១២ ឈរត្រង់គល់ដើមជ្រៃជិតមាត់ព្រៃ ។ ទេវតាអ្នកស្ថិតនៅត្រង់ដើមឈើ ក៏បានថ្វាយបិណ្ឌបាតដល់ភិក្ខុទី ១២ រូប ទើបពោលថា ម៉ែម្ចាស់ សូមកុំទៅកាន់ទីដទៃឡើយ មកប្រចាំទីនេះប៉ុណ្ណោះចុះ ។ ក៏ព្រះថេរី មានប្អូនប្រុសម្នាក់ ឈ្មោះថា នាគត្ថេរៈ ។ ព្រះនាគត្ថេរៈនោះគិតថា យើងមិនអាចឲ្យភ័យយ៉ាងធំប្រព្រឹត្តទៅក្នុងទីនេះ ពួកយើងនឹងទៅកាន់ត្រើយដទៃ ជារូបទី ១២ នោះឯង ចេញចាកទីនៅរបស់ខ្លួន ហើយមកស្រុកភាតរៈដោយគិតថា យើងនឹងសួរសុខទុក្ខព្រះថេរី ហើយក៏ទៅ ។

ព្រះថេរីបានស្ដាប់ថា ពួកព្រះថេរៈមក ទើបទៅសម្នាក់ព្រះថេរៈពួកនោះសួរថា មានការអ្វីលោកម្ចាស់ លោកទើបប្រាប់ការប្រព្រឹត្តទៅនោះ ។ ព្រះថេរីនោះទើបពោលថា ថ្ងៃនេះ ពួកលោកចូរសម្រាកក្នុងវិហារមួយថ្ងៃសិនចុះ ថ្ងៃស្អែកនេះសឹមទៅ ។ ពួកព្រះថេរៈមកវិហារ ។ ស្អែកឡើងព្រះថេរី ត្រាច់ទៅបិណ្ឌបាតត្រង់គល់ឈើ ហើយចូលទៅរកព្រះថេរៈពោលថា សូមលោកម្ចាស់ទាំងឡាយ ចូរឆាន់បិណ្ឌបាតនេះចុះ ។ ព្រះថេរៈពោលថា ថេរីសមគួរឬ ទើបបានឈរនៅស្ងៀម ។

ថេរី. បិណ្ឌបាតនេះប្រកបដោយធម៌ លោកម្ចាស់ទាំងឡាយកុំរង្កៀស ឆាន់ចុះ ។

ថេរៈ. ថេរីសមគួរហើយ នាងចាប់បាត្រហើយបោះទៅលើអាកាស បាត្របាន អណ្តែតនៅក្នុងអាកាស ។

ព្រះថេរៈពោលថា អាហាររបស់ភិក្ខុនីអណ្តែតទៅប្រមាណ ៧ ដូវដើម ត្នោត កាលពោលថា ដែលឈ្មោះថា ភ័យមិនមែនមាននៅគ្រប់វេលា ភ័យស្ងប់ កាលនឹងពោលអរិយវង្ស ក៏នឹងពោលថា លោកម្ចាស់ លោកឆាន់អាហាររបស់ នាងភិក្ខុនីដែលបានពីបិណ្ឌបាតហើយ បណ្តាយវេលាឲ្យកន្លងទៅ ដូច្នេះ កាល នឹងប្រព្រឹត្តតាមគំនិតក៏មិនអាចគាំទ្របាន ព្រះថេរី សូមពួកលោកកុំប្រមាទ ។ ហើយដើរឡើងផ្លូវ ។ ចំណែករុក្ខទេវតាឈរគិតថា បើព្រះថេរៈនឹងបរិភោគ បិណ្ឌបាតពីដៃព្រះថេរី យើងក៏នឹងមិនឲ្យលោកត្រឡប់ ឃើញព្រះថេរៈដើរទៅ ទើបចុះអំពីដើមឈើពោលថា លោកម្ចាស់ សូមឲ្យបាត្រ ហើយទទួលបាត្រ នាំព្រះថេរៈមកគល់ឈើទុំះឯង ក្រាលអាសនៈថ្វាយបិណ្ឌបាត ឲ្យព្រះថេរៈឆាន់ ហើយធ្វើប្តេជ្ញាទំនុកបម្រុងភិក្ខុនី ១២ រូប ភិក្ខុ ១២ រូប រហូតអស់ ៧ ឆ្នាំ ។ ក្នុងពាក្យថា **ទេវតាខ្វល់ខ្វាយ** នេះ មានរឿងនេះជាឧទាហរណ៍ ។ ក៏ក្នុងរឿង នេះ ព្រះថេរីបានជាអ្នកបំពេញសាភណិយធម៌ ។

ក្នុងបទថា **មិនដាច់** ជាដើម មានអធិប្បាយថា ភិក្ខុណាមានសិក្ខាបទដាច់ក្នុងខាងដើម និងទីបំផុត ក្នុងអាបត្តិទាំង ៧ កង ភិក្ខុនោះឈ្មោះថា មានសីលដាច់ ដូចសំពត់ដាច់ជាយ ។ មយ៉ាងទៀត ភិក្ខុណាមានសិក្ខាបទដាច់ត្រង់កណ្តាល ភិក្ខុនោះឈ្មោះថា មានសីលធ្លុះ ដូចសំពត់ធ្លុះត្រង់កណ្តាល ។ ភិក្ខុណាដាច់ ២,៣ សិក្ខាបទ តាមលំដាប់ ភិក្ខុនោះឈ្មោះថា មានសីលដាង ដូចមេគោដែលមានពណ៌ខ្មៅ ឬក្រហមជាដើមណាមួយ ដោយពណ៌ដែលកាត់គ្នាតាំងឡើងលើខ្នង ឬពោះ ។ ភិក្ខុណាមានសិក្ខាបដាច់ចន្លោះៗ ភិក្ខុនោះឈ្មោះថា មានសីលពព្រុស ដូចមេគោដែលមានអុជធូតពេញទាំងខ្លួន ។

ចំណែកភិក្ខុណា មានសិក្ខាបទមិនដាច់ ភិក្ខុនោះឈ្មោះថា មានសីលទាំងនោះមិនដាច់ មិនធ្លុះ មិនដាង មិនពព្រុស ។ ក៏សិក្ខាបទទាំងនេះនោះឈ្មោះថា ជាអ្នកគ្មានបំណុល ព្រោះផុតពីភាពជាទាសៈនៃតណ្ហា ហើយធ្វើឲ្យជាឥស្សរៈ ឈ្មោះថា វិញ្ញូជនសរសើរ ព្រោះវិញ្ញូជនទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ឈ្មោះថា អ្វីៗ ស្ទាបអង្អែលមិនបាន ព្រោះតណ្ហាជាដើមស្ទាបអង្អែលមិនបាន និងព្រោះកិលេសអ្វីៗ មិនអាចដើម្បីនឹងស្ទាបអង្អែលថា លោកធ្លាប់ត្រូវសិក្ខាបទឈ្មោះនេះ រមែងប្រព្រឹត្តទៅដើម្បីសមាធិ ឬសមាធិដែលតម្កល់មាំ ដូច្នោះ លោកទើបហៅថា ប្រព្រឹត្តទៅដើម្បីសេចក្តីតាំងមាំ ។

បទថា **ដល់ភាពជាអ្នកមានសីលស្មើគ្នា** សេចក្តីថា អ្នកមានសីលចូលដល់ភាពស្មើគ្នា នឹងភិក្ខុទាំងឡាយអ្នកនៅក្នុងចំណែកទិសទាំងនោះៗ ។ ព្រោះថា សីលរបស់ព្រះសោតាបន្នជាដើម ស្មើគ្នាដោយសីលរបស់ព្រះសោតាបន្នជាដើមពួកដទៃ ។ ដែលនៅចន្លោះសមុទ្រខ្លះ ទេវលោកខ្លះ (តែ) មិនមានសេចក្តីផ្សេងគ្នាដោយមគ្គ និងសីល ព្រះមានព្រះភាគទ្រង់សំដៅយកសីលនោះ ទើបបានត្រាស់ពាក្យនេះ ។

បទថា **ទិដ្ឋិណា** សេចក្តីថា សម្មាទិដ្ឋិដែលប្រកបព្រមដោយមគ្គ ។

បទថា **អរិយា** បានដល់ មិនមានទោស ។

បទថា **នាំចេញ** គឺ នាំចេញទៅ ។

បទថា **អ្នកធ្វើកម្មនោះ** បានដល់ អ្នកណាជាអ្នកធ្វើយ៉ាងនោះ ។

បទថា **ដើម្បីអស់ទុក្ខ** បានដល់ ដើម្បីការអស់ទុក្ខទាំងអស់ ។

បទថា **ដល់ភាពស្មើគ្នាដោយការឃើញ** សេចក្តីថា ជាអ្នកចូលដល់ភាពជាអ្នកមានការឃើញស្មើគ្នា ។

បទថា **លើស** បានដល់ ចម្រើនបំផុត ។

បទថា **រួមឈើបន្ទន់ទាំងពួង** បានដល់ ចងទុកដោយល្អ អធិប្បាយថា ធ្វើបន្ទន់គ្រប់កន្លែងឲ្យជាប់គ្នា ហេតុនោះ ឈ្មោះថា ឲ្យតៗ គ្នា ។

បទថា **កំពូលនេះណា** សេចក្តីថា ទីតចំពោះកំពូលជាមួយនឹងជហ្វា ហេតុនោះ ឈ្មោះថា កំពូល ។ ក៏ប្រាសាទ ៥ ជាន់ ជាដើម ដែលកំពូលនោះទ្រឹងទុកនោះឯង ទើបតាំងនៅបាន កាលកំពូលនោះធ្លាក់ទៅ ប្រាសាទទាំងអស់តាំងអំពីជីស្អិត ក៏ធ្លាក់ទៅ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។

បទថា **ដូច្នោះនោះឯង** សេចក្តីថា សេចក្តីឃើញដ៏ប្រសើរ និងដ៏លើសនៃសាវកណិយធម៌ទាំងនេះ គប្បីឃើញថា ជាតួរបរួម និងតួភ្ជាប់ទុក ដូចកំពូលរបស់ផ្ទះកំពូល ដូច្នោះ ។

[១៨៣] ក្នុងបទថា **ភិក្ខុទាំងឡាយ ក៏ការឃើញនេះ តើដូចម្តេច ?** អធិប្បាយថា ភិក្ខុទាំងឡាយ ទិដ្ឋិក្នុងសោតាបត្តិមគ្គ លោកពោលថា ឆ្ងាយចាកសត្រូវ គឺ មានសភាពនាំចេញ រមែងនាំចេញទៅ ដើម្បីការអស់ទុក្ខដោយប្រពៃរបស់អ្នកបដិបត្តិ ។ ទិដ្ឋិនោះនាំចេញដូចម្តេច នាំចេញព្រោះហេតុអ្វី ។

បទថា **ឬថាជាអ្នកមានចិត្តត្រូវរួបរិតហើយ** សេចក្តីថា ឈ្មោះថា ជាអ្នកមានចិត្តត្រូវរួបរិតហើយ សូម្បីដោយហេតុប៉ុណ្ណោះ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។

បទថា **ចិត្តរបស់យើងតាំងមាំល្អហើយ** សេចក្តីថា ចិត្តយើងតាំងទុក

ល្អហើយ ។

បទថា **ដើម្បីដឹងសច្ចៈទាំងឡាយ** បានដល់ ដើម្បីប្រយោជន៍ដឹងសច្ចៈ ៤ ។

ក្នុងបទជាដើមថា **ប្រសើរ** មានអធិប្បាយថា ព្រោះញាណនោះរមែងមានដល់អ្នកប្រសើរ មិនមានដល់បុថុជ្ជនទេ ដូច្នោះ លោកទើបហៅថា ប្រសើរ ។ ចំណែកថា សម្បីលោកុត្តរធម៌របស់បុគ្គលណាមានហើយ ក៏ជារបស់បុគ្គលពួកនោះប៉ុណ្ណោះ មិនមានដល់បុគ្គលពួកដទៃ ដូច្នោះ លោកទើបពោលថា កំពូលក្នុងលោក ។ មានពាក្យអធិប្បាយថា ឈ្មោះថា មិនទូទៅដល់បុថុជ្ជនទាំងឡាយ ព្រោះមិនមានដល់បុថុជ្ជន ។ ក្នុងវារៈទាំងអស់ក៏ន័យនេះ ។

[១៨៤] បទថា **យើងបានសេចក្ដីស្ងប់ចំពោះខ្លួន** សេចក្ដីថា យើងបានសេចក្ដីស្ងប់ក្នុងចិត្តរបស់ខ្លួន ។ សម្បីក្នុងសេចក្ដីរលត់ ក៏ន័យនេះ ។ ក្នុងបទថា **រលត់សម្បីនេះ** រមែងបានទាំងសេចក្ដីស្ងប់ ទាំងភាពជាអ្នកមានអារម្មណ៍តែមួយ ។

បទថា **រលត់** បានដល់ ចូលទៅស្ងប់កិលេស ។

[១៨៥] បទថា **ទិដ្ឋិបែបនោះ** បានដល់ សោតាបត្តិមគ្គ ទិដ្ឋិមានសភាពបែបនោះ ។

[១៨៦] បទថា **ដោយធម្មតា** គឺ ដោយសភាវៈ ។

សភាវៈនេះ ឈ្មោះថា ធម្មតា ។

បទថា **រមែងប្រាកដការតាំងឡើង** សេចក្ដីថា ការតាំងឡើងដោយអំណាចសង្ឃកម្ម ឬទេសនា រមែងប្រាកដ ។ ពិតហើយ អរិយសាវកកាលត្រូវអាបត្តិ ក៏ត្រូវអាបត្តិដោយមិនដឹង ដូចការសាងកុដិក្នុងគរុកាបត្តិ (និង) ដូចត្រូវអាបត្តិ ព្រោះការដេករួមក្នុងទីប្រក់ទីបាំងតែមួយជាមួយគ្នាជាដើម ក្នុងលហុកាបត្តិ ពិតណាស់ ព្រះអរិយសាវកនោះ មិនក្លែង គឺ មិនក្លែងត្រូវអាបត្តិនោះ ត្រូវហើយ ក៏មិនបិទបាំង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យ ជាដើមថា គ្រានោះឯង... នោះឆាប់រហ័សតែម្ដង ។

បទថា **កម្លោះ** បានដល់ នៅក្មេង ។

បទថា **កុមារ** បានដល់ មិនមែនមនុស្សចាស់ ។

បទថា **មន្ទ** គឺ ឈ្មោះថា នៅខ្ចី ព្រោះភ្នែក និងត្រចៀកនៅមិនទាន់ដឹងក្ដី ។

បទថា **ដេកផ្ងារ** សេចក្ដីថា ឈ្មោះថា ជាអ្នកដេកផ្ងារ ព្រោះនៅតូចណាស់ មិនអាចនឹងដេកផ្អៀងខាងស្ដាំ ឬខាងឆ្វេងបាន ។

បទថា **បានជាន់រងើក** សេចក្ដីថា យកដៃ ឬជើងដែលទម្រេតទៅត្រង់

នេះខ្លះ ត្រង់នោះខ្លះ ប៉ះត្រូវហើយ ក៏កាលពួកមនុស្សពាល់ត្រូវយ៉ាងនេះ ដៃនឹងដកចេញរហ័ស ធ្វើឲ្យឃើតមិនបាន សូម្បីគ្រានោះ មនុស្សទាំងឡាយ យកដៃខាងណាមួយ ចាប់រងើកភ្លើងផ្លាស់ទៅផ្លាស់មក រមែងទៅបានឆ្ងាយ ។ ប៉ុន្តែថា ដៃ និងជើងរបស់ក្មេងតូចនៅទន់ខ្សោយ ។ ក្មេងនោះ រមែងត្រូវភ្លើង រលាកប៉ុណ្ណោះ ក៏នឹងស្រែកទ្រហោយំ បោលភ្លើងទៅដោយរហ័ស ។ ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សម្ដែងក្មេងតូចទុកក្នុងទីនេះតែម្យ៉ាង ។ មនុស្សចាស់ កាលត្រូវភ្លើងរលាករមែងទ្រាំបាន ។ ប៉ុន្តែថា ក្មេងតូចនេះ អត់ទ្រាំមិនបាន ។ ព្រោះដូច្នោះ ទើបទ្រង់សម្ដែងក្មេងតូចនោះឯង ។

បទថា **សម្ដែង** សេចក្ដីថា កាលបុគ្គលដែលស្មើៗ គ្នា ជាអ្នកទទួល អាបត្តិ ក៏មិនរង់ចាំថា ពេលថ្ងៃ ឬពេលយប់ ទៅទីនៅរបស់ភិក្ខុដែលស្មើ ៗ គ្នានោះ សូម្បីក្នុងពេលយប់ប្រកបដោយអង្គ ៤ ហើយសម្ដែងតែម្ដង ។

[១៨៧] បទថា **ខ្ពស់ ទាប** បានដល់ ខ្ពស់ទាបៗ ។

កិច្ចដែលគួរពោលយ៉ាងនេះថា **យើងនឹងធ្វើយ៉ាងណា ហើយធ្វើ** ឈ្មោះ ថា កិច្ចដែលគួរធ្វើយ៉ាងណា ។

ក្នុងកិច្ចទាំងនោះ កិច្ចជាដើមយ៉ាងនេះ គឺ ការធ្វើ ឬជ្រលក់ចីវរ ១ ការងារត្រង់លានព្រះចេតិយ ១ ការងារដែលគួរធ្វើត្រង់រោងឧបោសថ ១ ផ្ទះ

ព្រះចេតិយ ១ ផ្ទះពោធិព្រឹក្ស ១ ឈ្មោះថា ការងារដ៏ប្រសើរ ។ ការងារបន្តិចបន្តួច មានការលាង និងលាបជើងជាដើម ឈ្មោះថា ការងារដែលទាប ។ ម្យ៉ាងទៀត ការងារទាំងនោះ មានការបោកបាយអរជាដើមត្រង់លានព្រះចេតិយ ឈ្មោះថា ការងារខ្ពស់ ។ ក្នុងការងារទាំងនោះ ការសម្អាតសំពត់កាសាវៈ ១ ការនាំទឹកមក ១ ការបុកកំបោរ (ដោយស្លាបព្រា) ១ ការធ្វើជណ្ដើរ ១ ឈ្មោះថា ការងារខាងទាប ។

បទថា **ដល់សេចក្ដីខ្វល់ខ្វាយ** សេចក្ដីថា ជាអ្នកបដិបត្តិសេចក្ដីខ្វល់ខ្វាយដែលគួរធ្វើ ។

បទថា **ជាអ្នកប្រាថ្នាក្លៀវក្លា** សេចក្ដីថា ជាអ្នកមានសេចក្ដីប្រាថ្នាយ៉ាងក្លៀវក្លា ។

បទថា **និងដកស្មៅ** បានដល់ ស្មៅទំពារស៊ី ។

បទថា **មនសិការដល់កូនគោ** សេចក្ដីថា ចាំក្រឡេកមើលកូនគោផង ។ ដូចសេចក្ដីថា មេគោកូនខ្ចី នឹងមិនចោលកូនគោដែលរួមគ្នាមកព្រៃហើយដេកក្នុងទីមួយនៅឆ្ងាយ មេគោនោះនឹងត្រាច់ទៅក្នុងទីជិតៗ កូនគោ និងទីដែលមានស្មៅហើយ ក៏អើតក.ឡើងរមិលមើលកូនគោទៅផង ។ ព្រះសោតាបន្នក៏យ៉ាងនោះដែរ ធ្វើកិច្ចដែលគួរធ្វើទាំងខ្ពស់ ទាប បង្អោនទៅក្នុងកិច្ចនោះ ជា

អ្នកបំពេញមិនធូរថយ មានសេចក្តីពេញចិត្តយ៉ាងខ្លាំងក្លា ជាអ្នកប្រារព្ធសេចក្តីប្រាថ្នាយ៉ាងក្លៀវក្លា ។ ក្នុងសេចក្តីនោះ មានរឿងនេះជាឧទាហរណ៍ ៖

បានឮមកថា កាលកំពុងបូកលាបកំបោរត្រង់មហាចេតិយ ព្រះអរិយ-សាវកមួយរូប មានដៃម្ខាងកាន់ភាជនៈដាក់កំបោរ ដៃម្ខាងកាន់ស្លាបព្រា គិតថាលាបកំបោរហើយ ឡើងកាន់ទីព្រះចេតិយ , ភិក្ខុមួយរូប មានកាយធំ ធូន់ច្រើន បានទៅឈរជិតព្រះថេរៈ ព្រះថេរៈក្នុងទីដទៃជាអ្នកឃើតយូរពេក ព្រោះហេតុនោះ ទើបចេញពីទីនោះទៅទីដទៃ ។ សូម្បីភិក្ខុនោះ ក៏បានទៅទីនោះៗឯង ។ ព្រះថេរៈបានទៅទីដទៃទៀត ដូច្នេះឯង ។ ព្រះថេរៈបានពោលចំពោះភិក្ខុដែលមកក្នុងទី ២-៣ កន្លែងយ៉ាងនេះថា អ្នកមានអាយុ ត្រង់ទួលព្រះចេតិយធំ លោកមិនបានឱកាសទីដទៃឬ ។ ព្រះថេរៈក្រៅនេះ ក៏មិនព្រមចៀសទៅ ។

[១៨៨] បទថា **ប្រកបដោយភាពជាអ្នកមានកម្លាំង** បានដល់ ប្រកបដោយកម្លាំង ។

បទថា **ធ្វើឲ្យមាន** សេចក្តីថា ធ្វើភាពជាអ្នកមានប្រយោជន៍ គឺ ជាអ្នកមានប្រយោជន៍ ។

បទថា **មនសិការ** សេចក្តីថា ធ្វើទុកក្នុងចិត្ត គឺ រួបរួមវត្ថុទាំងអស់មកដោយចិត្ត ឈ្មោះថា មិនធ្វើសេចក្តីរវើរវាយសូម្បីត្រឹមតែបន្តិចបន្តួច រួបរួម

មកដោយចិត្តទាំងអស់ ។

បទថា **ផ្ទៀងសោតៈ** សេចក្ដីថា មានសោតៈដែលតាំងទុកហើយ ។

ក៏ព្រះអរិយសាវកទាំងឡាយ ជាអ្នកស្រឡាញ់ការស្ដាប់ធម៌ កាលនឹងទៅស្ដាប់ធម៌ ក៏មិនអង្គុយលក់ សន្ទនានឹងអ្នកណាៗ ឬមានចិត្តរវើរវាយ ។ ការពិត លោកជាអ្នកមិនឆ្អែតក្នុងការស្ដាប់ធម៌ ដូចបរិភោគទឹកអម្រឹត ដរាបដល់អរុណរះក្នុងការស្ដាប់ធម៌ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះ ។

[១៩០] បទថា **ធម្មតា ជាការតាំងទុកល្អហើយ** សេចក្ដីថា សភាវៈដែលលោកស្វែងរកទុកល្អហើយ ។

ពាក្យថា **ព្រោះធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល** នេះ ជាពាក្យពោលដល់ហេតុ អធិប្បាយថា ព្រោះញាណដែលធ្វើឲ្យជាក់ច្បាស់ហើយដោយសោតា-បត្តិផល ។

បទថា **មកតាមព្រមហើយដោយអង្គ ៧ យ៉ាងនេះ** សេចក្ដីថា ប្រកបដោយញាណជាគ្រឿងពិចារណាយ៉ាងធំទាំងនេះ យ៉ាងនេះ ។ អាចារ្យទាំងឡាយមានពោលពាក្យដែលស្មើគ្នានេះមុន ។ ចំណែកលោកុត្តរមគ្គ ដែលឈ្មោះថាមានខណៈចិត្តច្រើនមិនមាន ។

ចំណែកអាចារ្យអ្នកពេញចិត្តពោលលេង រមែងពោលថា មគ្គ ដែលឈ្មោះថាមានខណៈចិត្តមួយមិនមាន ការចម្រើនមគ្គមានបានរហូតអស់ ៧ ឆ្នាំ ចំណែកកិលេសទាំងឡាយ កាលនឹងដាច់សូន្យដោយរហ័ស ក៏រមែងដាច់សូន្យដោយញាណទាំង ៧ ព្រោះពាក្យថា គប្បីឲ្យចម្រើនរហូតអស់ ៧ ឆ្នាំ ។ អាចារ្យនោះនឹងត្រូវគេពោលថា ចូរនាំព្រះសូត្រមក ។ កាលមិនឃើញសូត្រដទៃ គេក៏នឹងនាំព្រះសូត្រនេះមកសម្តែងយ៉ាងពិតប្រាកដថា ញាណដែលយើងសម្រេចនេះ ជាទីមួយនៃព្រះសូត្រនោះ ញាណដែលយើងសម្រេចហើយនេះជាទីពីរនៃព្រះសូត្រនោះ ។ល។ ញាណដែលយើងសម្រេចហើយនេះ ជាទី ៧ នៃព្រះសូត្រនោះ ។ លំដាប់នោះ អាចារ្យនោះក៏នឹងត្រូវពោលថា ក៏ព្រះសូត្រនេះ មានសេចក្តីដែលគប្បីនាំទៅ មានសេចក្តីដែលនាំទៅហើយឬ ។ តអំពីនោះក៏នឹងពោលថា មានសេចក្តីដែលនាំទៅហើយ ។ ព្រះសូត្រយ៉ាងណា សេចក្តីក៏យ៉ាងនោះ ។ អាចារ្យនោះក៏នឹងត្រូវពោលថា សភាពជាធម៌ ក៏នឹងតាំងមាំដោយល្អ ប្រយោជន៍មានប្រមាណប៉ុណ្ណេះ ដើម្បីធ្វើឲ្យច្បាស់នូវសោតាបត្តិ-ផល ។ អាចារ្យនោះ រមែងពោលថា ប្រយោជន៍នៃការធ្វើឲ្យច្បាស់សោតា-បត្តិផលមានពិតប្រាកដ ។ តអំពីនោះ ក៏នឹងត្រូវសួរថា អ្នកព្រមព្រៀងដោយមគ្គ រមែងធ្វើផលឲ្យច្បាស់ ហើយក្លាយជាអ្នកព្រមព្រៀងដោយផលឬ ។ កាល

ដឹង ក៏ឆ្លើយថា អ្នកព្រមព្រៀងដោយមគ្គ រមែងធ្វើឲ្យច្បាស់ផល ក្លាយជាព្រមព្រៀងដោយផល ។ តអំពីនោះត្រូវនាំមកទៀតថា ព្រោះលោកមិនទាន់អប់រំមគ្គក្នុងព្រះពុទ្ធតម្រាស់នេះថា ភិក្ខុទាំងឡាយ អរិយសាវកអ្នកប្រកបដោយអង្គ ៧ នេះ ជាអ្នកប្រកបដោយសោតាបត្តិផល ។ ទើបលោកទៅពោលវេវ៉ូទាំដូចគ្នាថា ខ្ញុំមិនទាន់បានព្រះសូត្រថា អរិយសាវកនឹងតោងយកផលឲ្យបាន ធម្មតាភិក្ខុដែលនឹងដោះស្រាយបញ្ហា គួរនៅក្នុងសម្នាក់អាចារ្យ រៀនយកព្រះពុទ្ធវចនៈជ្រាបអត្ថរសហើយពោល ។

ញាណ ៧ ទាំងនេះ ចាត់ថាញាណ ជាគ្រឿងពិចារណារបស់ព្រះអរិយ-សាវកតែម្យ៉ាង ។ លោកុត្តរមគ្គ ដែលឈ្មោះថា មានខណៈចិត្តច្រើន រមែងមិនមាន គប្បីឲ្យព្រមទទួលថា មានខណៈចិត្តតែមួយប៉ុណ្ណោះ បើគេនឹងដឹង ក៏ចូរដឹង បើមិនដឹង ក៏ចូរប្រាប់ទៅថា លោកចូរចូលទៅវិហារពីព្រឹកព្រលឹម ហើយហុតបបរចុះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយស្រួលយល់នោះឯង ។

" ចប់អដ្ឋកថា កោសម្ពិយសូត្រ ទី ៨ "

# អ ដ្ឋ ក ថា

## ព្រហ្មនិមន្តនិកសូត្រទី ៩

[១៩១] ព្រហ្មនិមន្តនិកសូត្រ ផ្តើមឡើងថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖

[១៩២] បណ្តាបទទាំងនោះ បទថា **ទិដ្ឋិដ៏អាក្រក់** បានដល់ ការឃើញថា ទៀងដ៏លាមក ពាក្យថា **នេះជារបស់ទៀង** គឺ និយាយថា ឋានៈរបស់ព្រហ្មព្រមទាំងឱកាសដែលជារបស់មិនទៀងនេះថា ទៀង ។ ពាក្យថា **នៅស្ថិតស្ថេរ** ជាដើម ក៏ជាពាក្យប្រើជំនួសពាក្យថា ទៀងនោះឯង ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ធុវំ** គឺ រឹងមាំ ។ ពាក្យថា **សស្សតំ** គឺ មាននៅគ្រប់កាល ។ ពាក្យថា **កេវលំ** គឺ ទាំងអស់មិនដាច់ធ្លាយ ។ ពាក្យថា **មានការមិនឃ្លៀងឃ្លាតជាធម្មតា** គឺ មានសភាពមិនឃ្លៀងឃ្លាតទៅ ។ **ដល់ឋានៈ** ក្នុងពាក្យជាដើមថា **នេះឯងរមែងមិនកើត** នេះ គឺ និយាយសំដៅយកថា អ្នកកើត អ្នកចាស់ អ្នកស្លាប់ អ្នកឃ្លៀងឃ្លាត អ្នកកើតឡើង រមែងមិនមាន ។ ពាក្យថា **និងដទៃពីនេះ** គឺ សេចក្តីឃើញថា ទៀងពិតដ៏មានកម្លាំង រមែងជារបស់ដែលកើតឡើងហើយដល់គេ យ៉ាងនេះថា ឈ្មោះថា ហេតុនៃការចេញទៅយ៉ាងដទៃ ដែលក្រៅពីឋានៈ

របស់ព្រហ្ម ព្រមទាំងឱកាសនេះ មិនមាន ។ ក៏ឯអ្នកនិយាយដូច្នេះនោះ រមែងការពារគ្រប់យ៉ាង គឺ របស់ឈានខាងលើ ៣ មគ្គ ៤ ផល ៤ និព្វាន ១ ។ ពាក្យថា **អ្នកទៅក្នុងសេចក្តីមិនដឹង** សេចក្តីថា អ្នកទៅ គឺ ប្រកបក្នុងសេចក្តីមិនដឹង ឈ្មោះថា ជាអ្នកមិនដឹង គឺ ជាអ្នកខ្វាក់ ។ ពាក្យថា **យត្រ ហិ នាម** គឺឈ្មោះណា ។

[១៩៣] មារ ក្នុងបទទាំងឡាយថា **ម្នាលភិក្ខុទាំងឡាយ! គ្រានោះ មារមានចិត្តបាប បានឃើញព្រះមានព្រះភាគ** តើដូចម្តេច ?

ដំណាលមកថា មារនោះ អង្គុយនឹករំពឹងដល់ព្រះសាស្តាក្នុងភពរបស់ខ្លួននោះឯងរហូតអស់វេលាថា ថ្ងៃនេះ ព្រះគោតមជាសមណៈនៅត្រង់តំបន់ ឬស្រុកណា ? និងពេលដែលកំពុងនឹករំពឹងនេះ ដឹងថា កំពុងអាស្រ័យក្រុងឧក្កដ្ឋៈនៅត្រង់ព្រៃសុភគៈ ទើបសម្លឹងមើល ហើយនឹងទៅណាទៀតហ្ន៎ ? ក៏ឃើញថា កំពុងទៅព្រហ្មលោក ទើបគិតថា ព្រះគោតមជាសមណៈកំពុងទៅព្រហ្មលោក យើងនឹងត្រាច់ទៅធ្វើការពេញចិត្តក្នុងធម្មទេសនាដែលខុសៗ រហូតអស់វេលាដែលមារពោលធម្មីកថាក្នុងទីនោះហើយ នៅមិនធ្វើឲ្យគណៈព្រហ្ម រួចផុតវិស័យរបស់យើង ទើបដើរតាមស្នាមព្រះសាស្តា ហើយមកឈរកំបាំងខ្លួនក្នុងចន្លោះពួកព្រហ្ម ។ មារដឹងថា ពួកព្រហ្មត្រូវព្រះសាស្តារុករាន , ទើបបានឈរធ្វើខ្លួន

ជាអ្នកជួយគ្រាំទ្រព្រហ្ម ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មារមានចិត្តបាប** ដូច្នេះ ពាក្យថា **ចូលស្ថិតព្រហ្មបារិសជ្ជៈហើយ** គឺ មារចូលកាន់រាងកាយរបស់ព្រហ្មបារិសជ្ជៈមួយអង្គ ក៏មិនទាន់អាចចូលជៀតមហាព្រហ្ម ឬពួកព្រហ្មបុរោហិតបាន ។

ពាក្យថា **កុំរុករានអ្នកនេះ** គឺ កុំរុករានពួកព្រហ្មនេះ ។ ពាក្យថា **គ្របសង្កត់ (ជាអ្នកធំក្រៃលែង)** គឺ ជាអ្នកគ្របសង្កត់ហើយតាំងនៅ គឺ ចម្រើនបំផុត (ធំបំផុត , ប្រធាន) ។ ពាក្យថា **មិនត្រូវគ្របសង្កត់** គឺ ពួកដទៃគ្របសង្កត់មិនបាន ។ ពាក្យថា **ដោយពិត** ជានិបាតចុះក្នុងពាក្យបញ្ជាក់ថា ចំណែកតែមួយ ទ្រង់សម្តែងថា អ្នកឃើញដោយអំណាចការឃើញ រមែងឃើញវត្ថុគ្រប់យ៉ាង ។ ពាក្យថា **អ្នកមានអំណាច** គឺ រមែងញុំាងជនទាំងអស់ឲ្យប្រព្រឹត្តទៅក្នុងអំណាច ។ ពាក្យថា **ជាឥស្សរៈ** គឺ ជាធំក្នុងលោក ។ ពាក្យថា **អ្នកសាង អ្នកនិមិត្ត** គឺ ជាអ្នកសាង និងអ្នកនិម្មិតលោកទុក លោកសម្តែងថា ផែនដីហិមពាន្ត ភ្នំសិនេរុ ចក្រវាឡ មហាសមុទ្រ ព្រះចន្ទ និងព្រះអាទិត្យ មហាព្រហ្មអង្គនេះ និម្មិតទុក ។ ពាក្យថា **អ្នកប្រសើរ អ្នកចាត់ចែង** គឺ មហាព្រហ្មអង្គនេះនិម្មិត ជាអ្នប្រសើរ និងជាអ្នកចាត់ចែង លោកសម្តែងថា មហាព្រហ្មអង្គនេះ បានចាត់ចែងពួកសត្វទុកយ៉ាងនេះថា លោកជាក្សត្រិយ៍ លោក

ជាព្រាហ្មណ៍ ជាវេស្ស: ជាសូទ្រ: ជាអ្នកស្រុក ជាអ្នកបួស ជាអ្នក ជាគោ លោកពោលថា មហាព្រហ្មអង្គនេះ ឈ្មោះថា ជាអ្នកមានអំណាច ព្រោះសន្សំ អំណាចទុក មហាព្រហ្មអង្គនេះ ជាព្រះបិតារបស់ពួកភូត និងពួកភព្យ ដោយ បទថា ជាអ្នកមានអំណាច ជាព្រះបិតារបស់ពួកភូត និងភព្យ ។ ក្នុងពាក្យថា ភូត និងភព្យនោះ ពួកសត្វដែលកើតក្នុងស៊ុត និងក្នុងផ្ទៃ ឈ្មោះថា ភព្យ ពេល នៅខាងក្នុងស៊ុត និងខាងក្នុងស្បូន វេលាដែលចេញមកខាងក្រៅហើយ ឈ្មោះ ថា **ភូត** ពួកសត្វអាស្រ័យកើតពីញើសក្អែល (ដូចក្នុងទឹកជ្រាំជាដើម) ក្នុងខណ: ចិត្តដំបូង ជា **ភព្យ** តាំងពីខណ:ចិត្តទីពីរទៅជាភូត ។ ពួកអ្នកឱបបាតិកកំណើត ជាភព្យក្នុងឥរិយាបថដំបូង តាំងពីឥរិយាបថទីពីរទៅ គប្បីជ្រាបថា ជាភូត ។ ព្រះមានព្រះភាគត្រាស់ថា ជាបិតារបស់ពួកភូត និងភព្យ ដោយទ្រង់សម្គាល់ថា ពួកសត្វសូម្បីទាំងអស់នោះ ជាកូនរបស់មហាព្រហ្មអង្គនេះ ។ ដោយបទថា **អ្នក តិះដៀលផែនដីនេះ** ព្រះមានព្រះភាគទ្រង់សម្ដែងថា ពួកគេជាអ្នកតិះដៀលផែន ដីមកហើយ ដូចដែលអ្នកកំពុងតិះដៀលស្អប់ខ្ពើមផែនដីថា មិនទៀង ជាទុក្ខ មិនមែនខ្លួន ក្នុងឥឡូវនេះ និងមិនមែនតែអ្នកប៉ុណ្ណោះទេ ។ សូម្បីក្នុងពាក្យជា ដើមថា អ្នកតិះដៀលទឹក ក៏ទំនងដូចគ្នានេះឯង ។

ពាក្យថា **តាំងនៅក្នុងកាយថោកទាប** បានដល់ កើតក្នុងអបាយទាំងបួន ។

ដោយបទថា **អ្នកសរសើរផែនដី** នេះ ព្រះមានព្រះភាគត្រាស់ថា ពួកគេបាន ជាអ្នកសរសើរផែនដី គឺ ជាអ្នកនិយាយសរសើរគុណផែនដីមកហើយយ៉ាងនេះ គឺ ពួកគេមិនតិះដៀល (តែសរសើរថា) ផែនដីទៀង ឋិតថេរ ទៀងទាត់ មិន ដាច់ មិនបែកធ្លាយ មិនអស់ ដូចដែលលោកកំពុងតិះដៀល ។

ពាក្យថា **អ្នកមានសេចក្ដីត្រេកត្រអាលក្នុងផែនដី** បានដល់ ជាអ្នកមានសេចក្ដី ត្រេកត្រអាលក្នុងផែនដីដោយអំណាចតណ្ហា និងទិដ្ឋិ សូម្បីក្នុងបទដ៏សេសទាំងឡាយ ក៏ទំនងនេះដូចគ្នា ។ ពាក្យថា **តាំងនៅក្នុងកាយដែលប្រណីត** បានដល់ កើត ក្នុងព្រហ្មលោក ។ ពាក្យថា **ដូច្នោះ ខ្ញុំសូមនិយាយនឹងលោក យ៉ាងនេះ** គឺ ព្រោះហេតុនោះ ខ្ញុំនិយាយចំពោះលោក ។ ពាក្យថា **ណេ្ហយចុះ** ជានិបាតចុះ ក្នុងអត្ថថា ជាស់តឿន ។ ពាក្យថា **ចូលទៅប្រព្រឹត្តទៅកន្ទួង** គឺ ឈានកន្ទួង បាឋៈថា **ឧបាតិវត្តិតោ** ចូលទៅប្រព្រឹត្តកន្ទួងខ្លះក៏មាន ។ សេចក្ដីក៏ដូចគ្នាយ៉ាង នេះឯង ពាក្យថា **ទណ្ឌេន បដិប្បនាមេយ្យ** គឺ យកដំបងវែងបួនហត្ថវាយឲ្យ ចៀសចេញទៅ ។ ពាក្យថា **ក្នុងអណ្ដូងជ្រៅ** គឺ ក្នុងអណ្ដូងជម្រៅមួយរយជួរ បុរស ។ ពាក្យថា **មិនអាច** បានដល់ មិនគប្បីអាចដើម្បីនឹងធ្វើជាទីតោងជាន់ ក្នុងទីដែលល្មមនឹងយកដៃចាប់ ឬល្មមនឹងដាក់ជើងបាន ។ ដោយពាក្យថា **ម្នាល ភិក្ខុ អ្នកឃើញមិនមែនឬ ?** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងឥទ្ធានុភាពរបស់

អ្នកដែលតាំងនៅក្នុងឱវាទរបស់ព្រហ្មថា ភិក្ខុ អ្នកក៏រមែងឃើញព្រហ្មបរិស័ទដែលប្រជុំគ្នា ភ្លឺច្បាស់ ស្វាងស្វៃ រុងរឿង បែងចាំងនេះ មិនមែនឬ ។ ពាក្យថា **ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាប បានបង្អោនយកព្រហ្មបរិស័ទ មកកាន់តថាគតយ៉ាងនេះឯង** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបពោលហើយយ៉ាងនេះថា ភិក្ខុ អ្នកក៏រមែងឃើញព្រហ្មបរិស័ទដែលស្វាងស្វៃដោយយស និងដោយសិរី មិនមែនឬ ? សូម្បីលោក បើមិនឈានកន្លងពាក្យមហាព្រហ្ម ធ្វើតាមដែលព្រហ្មពោលនឹងលោកហើយ លោកក៏នឹងត្រូវរុងរឿងដោយយស និងសិរីបែបនេះដូចគ្នា ក៏បង្អោន គឺ នាំយកព្រហ្មបរិស័ទមកកាន់តថាគត ។ ពាក្យថា **អ្នកកុំសម្គាល់** គឺ មារមានចិត្តបាប អ្នកកុំសម្គាល់ឡើយ ។ ពាក្យថា **អ្នកជាមារដ៏លាមក** គឺ មារ តថាគតស្គាល់អ្នកថា អ្នកជាមារ ព្រោះសម្លាប់មហាជន អ្នកឈ្មោះថា ជាបុគ្គលស្មោកគ្រោក ព្រោះធ្វើព្រមដោយរបស់ដ៏ស្មោកគ្រោក គឺ លាមកដល់មហាជន ។

[១៩៤] ពាក្យថា **កសិណំ អាយុំ** គឺ អាយុទាំងអស់ ។ ពាក្យថា ពួកគេទាំងនោះឯងដឹងយ៉ាងនេះ គឺ ព្រហ្មមកពោលបន្តទៅថា ពួកគេដល់ព្រមដោយការធ្វើតបៈដ៏ធំយ៉ាងនេះ ចំណែកលោកទើបតែកើតមកកាលម្សិលមិញ (ថ្ងៃមុន) នឹងដឹងអ្វី ។ សូម្បីក្នុងថ្ងៃនេះ ក្នុងមាត់របស់លោក ក៏នៅមានក្លិនទឹកដោះបក់

មក (មាត់មិនទាន់អស់ក្លិនទឹកដោះ) ។ ពាក្យថា **ប្រកាន់ផែនដី** គឺ ប្រកាន់ផែនដីដកបអស់គ្មានសល់ ហើយកាន់យកដោយតណ្ហា មានះ និងទិដ្ឋិ ។ ពាក្យថា **អ្នកនឹងជាប់តាមខ្ញុំ** គឺ អ្នកនឹងជាប់ខ្ញុំ មានន័យថា កាលខ្ញុំដើរ អ្នកក៏ដើរតាមខ្ញុំឈរអ្នកក៏ឈរជិត , អង្គុយ អ្នកអង្គុយជិត , ដេក ក៏ដេកជិត ។ ពាក្យថា **ជាអ្នកដេកត្រាំ** គឺ ជាអ្នកដេកក្នុងផ្ទះខ្ញុំ ។ ពាក្យថា **យថា កាមករណិយោ ពាហិតេយ្យោ** សេចក្តីថា អ្នកត្រូវធ្វើវត្ថុដែលត្រូវការតាមសេចក្តីពេញចិត្តរបស់ខ្ញុំ នឹងកាលឲ្យថោកទាប អ្នកក៏ត្រូវធ្វើឲ្យទាបជាង ខ្ញីជាងសូម្បីតែគុម្ពផ្ដីទៀត ។ ព្រហ្ម រមែងនិយាយអុចអាល រមែងរុកកាន ព្រះមានព្រះភាគយ៉ាងនេះ ដោយពាក្យនេះ ឈ្មោះថា រមែងនិយាយអុចអាល គឺ ព្រហ្ម ឈ្មោះថា រមែងនិយាយអុចអាលមុនយ៉ាងនេះថា ភិក្ខុ បើលោកនឹងប្រកាន់ផែនដីនោះ ដោយតណ្ហាជាដើម លោកក៏នឹងជាអ្នកដេកជិតខ្ញុំ កាលខ្ញុំដើរ លោកក៏នឹងដើរ ខ្ញុំឈរ លោកក៏នឹងឈរ ខ្ញុំអង្គុយ លោកក៏នឹងអង្គុយ ខ្ញុំដេក លោកក៏នឹងដេក ខ្ញុំនឹងផ្តល់ជម្រកឲ្យលោក ហើយធ្វើលោកឲ្យជាបុគ្គលស្និទស្នាលជាអ្នកខាងក្នុង ។ ចំណែកដោយបទដ៏សេស ឈ្មោះថា រមែងរុកកាន ។ ក្នុងបទទាំងនេះឯង មានអធិប្បាយដូចតទៅនេះ ៖

ព្រហ្ម ឈ្មោះថា រមែងរុកកានយ៉ាងនេះថា បើលោកនឹងប្រកាន់ផែនដី

នឹងក្លាយជាអ្នកដេកក្នុងផ្ទះខ្ញុំ រង់ចាំខ្ញុំដើរជាដើមហើយ ទើបនឹងដើរ នឹងឈរ នឹងអង្គុយ ឬនឹងដេក នឹងរក្សាខ្ញុំ ក្នុងផ្ទះខ្ញុំ ខ្ញុំនឹងធ្វើលោកតាមសេចក្ដីប្រាថ្នា និងធ្វើលោកឲ្យថោកទាបក្រៃលែងជាងគុម្ពផ្ទី ។ តែព្រហ្មនេះ អាស្រ័យសេចក្ដីប្រកាន់ខ្លួន ដូច្នោះ ក្នុងទីនេះទើបសំដៅយកត្រឹមតែការរុករានប៉ុណ្ណោះ ក្នុងរឿងទឹកជាដើម ក៏ទំនងនេះដូចគ្នា ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **អបិច តេ អហំ ព្រហ្មេ** ទ្រង់គិតថា ព្រហ្មនេះអាស្រ័យសេចក្ដីប្រកាន់ខ្លួន ទើបសម្គាល់ថា ខ្ញុំដឹង ជាអ្នកត្រូវសម្មតិដោយយសរបស់ខ្លួនឯង ទើបមិនឃើញអ្វីតិចតួច ដែលអាចនឹងពាល់ត្រូវរាងកាយបាន គួរគ្របសង្កត់បន្តិចទៀត ហើយទ្រង់ទើបផ្ដើមទេសនានេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **រមែងដឹងច្បាស់គតិផង** សេចក្ដីថា តថាគតរមែងដឹងច្បាស់នូវសេចក្ដីសម្រេចផង ។ ពាក្យថា **សេចក្ដីរុងរឿង** គឺ តថាគតរមែងដឹងច្បាស់នូវអានុភាពផង ។ ពាក្យថា **ជាអ្នកធំក្រៃលែងយ៉ាងនេះ** គឺ ជាអ្នកមានយសធំ មានបរិវារច្រើន ។

ពាក្យថា **ព្រះចន្ទ និងព្រះអាទិត្យ រមែងបរិហារមានប្រមាណត្រឹមណា** គឺ ព្រះចន្ទ និងព្រះអាទិត្យ រមែងត្រាច់ទៅក្នុងទីមានប្រមាណត្រឹមណា ។

ពាក្យថា **ទិសទាំងឡាយភ្លឺរុងរឿង** គឺ ភ្លឺរុងរឿងក្នុងទិសទាំងឡាយ ឬថា ទិសទាំងឡាយរមែងភ្លឺរុងរឿង ព្រោះព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ។ ពាក្យថា **តាវ សហស្សធា លោកោ** គឺ លោក (ធាតុ) មួយពាន់ដោយប្រមាណត្រឹមនោះ អធិប្បាយថា ពាន់ចក្រវាឡ រួមទាំងចក្រវាឡនេះផង ។ ពាក្យថា **អំណាចរបស់អ្នក រមែងប្រព្រឹត្តទៅក្នុងពាន់ចក្រវាឡ** គឺ អំណាចរបស់អ្នករមែងប្រព្រឹត្តទៅក្នុងពាន់ចក្រវាឡនេះ ។ ពាក្យថា **អ្នករមែងដឹងនូវសត្វដទៃដែលក្រៃលែងជាងសត្វដទៃ** (គឺ ជាន់ដោយឡែកពីគ្នា) គឺ អ្នករមែងស្គាល់សត្វដែលមានលំដាប់ផ្សេងគ្នា គឺ ខ្ពស់ ទាប អាក្រក់ ប្រណីតក្នុងពាន់ចក្រវាឡនេះ ។ ពាក្យថា **អ្នកមានរាគៈ និងអ្នកមិនមានរាគៈ** គឺ មិនមែនស្គាល់តែសត្វដែលមានលំដាប់ផ្សេងគ្នាថា បុគ្គលនេះជាអ្នកធំ បុគ្គលនេះជាមនុស្សប្រក្រតី “ មនុស្សសាមញ្ញធម្មតា ” ដូច្នេះប៉ុណ្ណោះ ប៉ុន្តែបើនៅស្គាល់មនុស្សដែលនៅមានរាគៈ និងប្រាសចាករាគៈយ៉ាងនេះថា បុគ្គលនេះនៅមានរាគៈ បុគ្គលនេះប្រាសចាករាគៈហើយ ។ ពាក្យថា **ភាវៈយ៉ាងនេះ ភាវៈយ៉ាងដទៃ** គឺ ចក្រវាឡនេះហៅថា ភាវៈយ៉ាងនេះ ចក្រវាឡ ៩៩៩ ដ៏សេសពីនេះហៅ ភាវៈយ៉ាងដទៃ ។ ពាក្យថា **ការមកការទៅរបស់ពួកសត្វនេះ** គឺ ដឹងច្បាស់ការមករបស់ពួកសត្វដោយអំណាចបដិសន្ធិ និងគតិ ដោយអំណាចចុតិក្នុងពាន់ចក្រវាឡនេះ ។ ព្រះ

មានព្រះភាគទ្រង់ត្រាស់ថា ការដឹងរបស់តថាគត រមែងដឹងធំក្រៃលែងជាង អ្នក អ្នកគ្រាន់តែជាព្រហ្មក្នុងពាន់ចក្រវាឡ ចំណែកព្រហ្មពួកដទៃទឹងដឹងក្រៃលែង ជាងអ្នក ២០០០ , ៣០០០ , ៤០០០ , ៥០០០ , ១០,០០០ និង ១០០,០០០ ក៏មិនមាន , នៅតែមកធ្វើសេចក្តីសម្គាល់ថា ខ្ញុំធំ ដូចព្យាយាមយកសំពត់ចាស់ ៤ ហត្ថ មកធ្វើជាខ្នាតសំពត់ ។ ពាក្យថា **ចូលដល់ក្នុងទីនេះ** គឺ ចូលដល់ជាន់ របស់ឈានទីមួយនេះ ។ ពាក្យថា **ព្រោះហេតុនោះ អ្នកទើបមិនស្គាល់ទីនោះ** គឺ ព្រោះហេតុនោះ អ្នកទើបមិនស្គាល់កាយនោះ ។ ពាក្យថា **អ្នកដែលស្មើៗ នឹងលោកក៏មិនមានឡើយ** គឺ សូម្បីអ្នកដល់ឋានៈដែលគប្បីដឹងស្មើនឹងលោក ក៏មិនមែនជាខ្ញុំ ។ ពាក្យថា **ដឹងក្រៃលែង** គឺ ដឹងទូទៅ ។ ពាក្យថា **គប្បីថោក ទាបពីទីណា** គឺ ឯសេចក្តីថោកទាបជាងលោកនឹងមានដល់ខ្ញុំ ពីទីណា ? បាន ឮថា ព្រហ្មអង្គនេះ ជាអ្នកកើតក្នុងគ្រាក្រោយ កាលមិនទាន់កើត ការកើតឡើង នៃព្រះពុទ្ធ បានបួសជាឥសី ធ្វើការបរិកម្មកសិណ ធ្វើឲ្យកើតសមាបត្តិ មិន វិនាសចាកឈាន ស្លាប់ហើយក៏កើតមានអាយុ ៥០០ កប្ប ក្នុងព្រហ្មលោកជាន់ វេហប្ផលា ក្នុងជាន់ឈានទីបួន តាំងនៅក្នុងទីនោះដរាបរហូតអស់អាយុហើយ ក៏ធ្វើក្នុងកំណើតខាងក្រោយ អប់រំឈានទីបីយ៉ាងប្រណីតហើយ ទើបកើតមាន អាយុ ៦៤ កប្ប ក្នុងព្រហ្មលោកជាន់សុភកិណ្ហា ។ អប់រំឈានទីពីរក្នុងជាន់

នោះ កើតមានអាយុ ៨ កប្បក្នុងជាន់អាភស្សរ ។ ក្នុងជាន់នោះ បានអប់រំឈាន ទីមួយហើយ ក៏កើតជាអ្នកមានអាយុ ១ កប្ប ក្នុងជាន់ឈានទីមួយ ។ ក្នុងពេល ដំបូងៗ គេបានដឹងទូទៅដល់កម្មដែលបានសាង ទាំងទីកន្លែងកើត ។ តែកាល វេលាកន្លងទៅ គេភ្លេចអស់ទាំងពីរយ៉ាង ទើបកើតការឃើញថា ទៀង ។ ព្រោះ ហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ចំពោះគេថា ព្រោះហេតុនោះ អ្នកទើប មិនដឹងដល់ទីនោះ ។ល។ តថាគតគប្បីថោកទាបពីទីណា ? ។

ពេលនោះ ព្រហ្មគិតថា ព្រះគោតមដែលជាសមណៈ ទ្រង់ដឹងទាំងអាយុ ទីកើត និងកម្មដែលធ្វើទុកកាលមុនរបស់ខ្ញុំ , ណ្ហើយចុះ ខ្ញុំនឹងសួរដល់កម្ម ដែលបានធ្វើទុកកាលមុនចំពោះព្រះអង្គ ដូច្នេះហើយ ទើបទូលសួរបុព្វកម្ម របស់ខ្លួនចំពោះព្រះសាស្តា ។ ព្រះសាស្តាទើបត្រាស់ថា ៖

បានឮថា កាលមុន ព្រហ្មនេះបានកើតក្នុងផ្ទះនៃត្រកូល ឃើញទោស ក្នុងកាមទាំងឡាយហើយ ទើបគិតថា យើងនឹងធ្វើទីបំផុតរបស់ការកើត ការចាស់ និងសេចក្តីស្លាប់ ហើយចេញទៅបួសជាឥសី ញុំាងសមាបត្តិឲ្យកើតឡើងហើយ ជាអ្នកបានឈាន ដែលមានអភិញ្ញាជាបាទ ឲ្យសាងរោងប្រក់ស្លឹកឈើ នាមាត់ ប្រាំងទន្លេគង្គា ញុំាងវេលាឲ្យកន្លងទៅដោយសេចក្តីត្រេកអរក្នុងឈាន ។

ក៏ក្នុងគ្រានោះ គ្រាខ្លះ ពេលខ្លះ ក៏មានពួកឈ្មួញរទេះ ៥០០ រទេះឆ្លង

កាត់សមុទ្រខ្សាច់មក ។ ក៏ក្នុងសមុទ្រខ្សាច់ (នោះ) ពេលថ្ងៃនឹងទៅមិនបាន ទៅបានតែពេលយប់ ។ គ្រានោះ គោដែលទឹមរទេះដំបូង ដើរទៅហើយក៏ត្រឡប់បែរមុខមកតាមផ្លូវដែលមកទៀត រទេះបន្ទាប់ៗ ក៏ត្រឡប់ទៅតាមគ្នា ពេលភ្លឺទើបបានដឹងថា ត្រឡប់មកវិញ ។ និងកាលនោះ ជាថ្ងៃឆ្លងផុតសមុទ្រខ្សាច់របស់ពួកគេទៀតផង ទើបគិតគ្នាថា ឧស និងទឹកអស់គ្មានសល់ទេ ព្រោះដូច្នោះ ពេលនេះ ពួកយើងនឹងស្លាប់ពិត ហើយក៏យកគោចងទុកត្រង់កង់ ពួកគេម្នាក់ៗ ក៏ចូលទៅដេកត្រង់ម្លប់រទេះ ។

ចំណែកតាបស ព្រឹកឡើង ក៏ចេញចាកបណ្ណសាលា អង្គុយសម្លឹងមើលទន្លេគង្គាត្រង់ទ្វារបណ្ណសាលានុ៎ះឯង បានឃើញ (ពួកឈ្មួញ) ហើយ លុះបានឃើញទន្លេគង្គាមានអន្លង់ទឹកជំពេញ ហូរមកដូចដងកែវមណី ទើបគិតថា ក្នុងលោកនេះមានខ្លះទេហ្ន៎ ពួកសត្វដែលកំពុងលំបាក ព្រោះមិនបានទឹកឆ្ងាញ់បែបនេះ ? ។ កាលលោកពិចារណាយ៉ាងនេះ ក៏បានឃើញក្រុមរទេះនោះ ក្នុងសមុទ្រខ្សាច់ ទើបគិតថា សូមសត្វទាំងនេះចូរកុំវិនាស , ហើយក៏អធិដ្ឋានដោយអភិញ្ញាចិត្តថា សូមឲ្យខ្សែទឹកដ៏ធំហូរកាត់ពីទីនេះ បែរមុខទៅរកក្រុមរទេះក្នុងសមុទ្រខ្សាច់ចុះ ។ ព្រមគ្នានឹងការគិត ទឹកក៏ហូរទៅសមុទ្រខ្សាច់នោះ បីដូចជាឡើងមកតាមគន្លង ។ ពួកអ្នករទេះម្នាក់ៗ ក្រោកឡើងព្រោះសំឡេងទឹក បានជួបទឹក

ម្នាក់ៗ រីករាយត្រេកអរ បានងូតផឹកហើយ ឲ្យពួកគោផឹកទឹកស្រេចហើយ ក៏នាំគ្នាទៅកាន់ទីដែលខ្លួនត្រូវការ ដោយការរួចផុតពីភ័យ ។

កាលព្រះសាស្តាទ្រង់សម្តែងបុព្វកម្មនោះ របស់ព្រហ្ម ទើបត្រាស់គាថានេះថា

លោកបានឲ្យពួកមនុស្សដែលក្តៅក្រហាយ ដែលប្រឈមមុខក្នុង
សមុទ្រខ្សាច់ក្តៅចំនួនច្រើន ផឹកទឹកណា នោះជាវត្ត និងសីលវត្ត
ចាស់របស់លោក តថាគតតាមរលឹកបាន ដូចអ្នកដេកលក់ហើយ
ភ្ញាក់ ។

ក្នុងសម័យដទៃទៀត តាបសឲ្យសាងពេងប្រក់ស្លឹកឈើដើម្បីអាស្រ័យនៅស្រុកក្នុងព្រៃមួយ ។ សម័យនោះ ពួកចោរចោមវាយពួកអ្នកស្រុកនោះ កាន់យករបស់មានតម្លៃជាប់ដៃ (ដេញដំរី) ហើយដេញគោ និងឈ្លើយទៅ ទាំងគោទាំងសេះ ទាំងមនុស្សក៏ស្រែកយំទ្រហឹង ។ តាបសបានឮសំឡេងនោះ ក៏ពិចារណាថា មានរឿងអ្វីហ្ន៎ ក៏ដឹងថា ភ័យកើតឡើងដល់ពួកមនុស្ស ទើបគិតថា កាលយើងឃើញហើយ សូមសត្វទាំងនេះកុំវិនាស ហើយក៏ចូលឈាន ដែលមានអភិញ្ញាជាបាទ ចេញហើយ ក៏និម្មិតកងទ័ពបួនពួកត្រៀបត្រាកំពុងដើរតាមផ្លូវមក ដោយអភិញ្ញាចិត្ត ។ ពួកចោរបានឃើញ ក៏នាំគ្នាសម្គាល់ឮថា ព្រះរាជា

ទើបបោលការបូន់ គេចចេញទៅ តាបសអធិដ្ឋានថា ចំណែកណា ជារបស់អ្នកណា ចំណែកនោះ ក៏ចូរជារបស់អ្នកនោះចុះ ។ របស់នោះ ក៏បានជាយ៉ាងនោះឯង ។ មហាជនក៏ដល់ការរួចផុតពីភ័យ ។ ព្រះសាស្តាកាលនឹង ទ្រង់បង្ហាញបុព្វកម្មសូម្បីនេះរបស់ព្រហ្មនោះ ទើបត្រាស់ព្រះគាថានេះថា ៖

លោកបានដោះលែងមនុស្សដែលត្រូវដេញកៀង របស់ដែលគប្បី
យក ដែលកំពុងនាំទៅនូវត្រកូលម្រឹគណា , នោះជាវត្ត និង
សីលវត្តចាស់របស់លោក , តថាគតតាមរលឹកបាន ដូចអ្នក
ដេកលក់ហើយភ្ញាក់ ។

ពាក្យដែលថា ត្រកូលម្រឹគក្នុងទីនេះ សំដៅដល់មាត់ប្រាំងទន្លេគង្គា ។ សម័យដទៃទៀត ត្រកូលដែលនៅតាមទន្លេគង្គាខាងលើ ចងមេត្រីភាពជាមួយនឹងត្រកូលដែលនៅតាមដងទន្លេគង្គាខាងក្រោម នាំគ្នាចងផែ ទូកឲ្យជាប់គ្នា ហើយជួយគ្នាជញ្ជូនយកខាទនីយៈ និងភោជនីយៈ និងគ្រឿងក្រអូបជាដើមយ៉ាងច្រើនមកដាក់ ហើយក៏មកតាមក្រសែទន្លេគង្គា ។ ពួកមនុស្សក៏នាំគ្នាទំពារស៊ី រាំច្រៀង សប្បាយទាំងអស់គ្នា ដូចជិះទេវវិមានទៅ ។ នាគដែលកើតក្នុងទន្លេគង្គា មើលឃើញ ក៏ខឹងសម្បារថា អ្នកទាំងនេះ មិនធ្វើសូម្បីតែសញ្ញាចំពោះយើង គ្រានេះ យើងនឹងឲ្យពួកនេះដល់សមុទ្រឲ្យបាន ។ ហើយក៏និម្មិតរាងកាយ

ដ៏ធំ ញែកទឹកចេញជាពីរចំណែក ផុសឡើងមក បើកពពារបញ្ចេញសំឡេងហ្វូតៗ ។ មហាជន បានឃើញក៏ខ្លាច បញ្ចេញអាការវង្វេងភាន់ភាំង ។ តាបសអគ្គិយ នៅបណ្ណសាលាបានឮ ពិចារណាថា អ្នកទាំងនេះស្រែកច្រៀង រាំ កើតសេចក្តីសប្បាយរីករាយមក តែឥឡូវនេះ ស្រែកយំដោយប្រភេទសំឡេងខ្លាចស្លាប់ , មានហេតុយ៉ាងណាហ្ន៎ ? បានឃើញស្តេចនាគ ទើបគិតថា កាលយើងឃើញហើយ សូមសត្វទាំងឡាយចូរកុំវិនាស ហើយក៏ចូលឈានដែលមានអភិញ្ញាជាបាទ លះរាងកាយហើយ ក្លែងជាភេទគ្រុឌ ហើយសម្តែងចំពោះស្តេចនាគ , ស្តេចនាគខ្លាច បិទពពារមុជទឹកទៅ ។ មហាជនក៏ដល់សេចក្តីសួស្តី ។ កាលព្រះសាស្តាទ្រង់បង្ហាញបុព្វកម្មនេះរបស់ព្រហ្មនោះ ទើបត្រាស់គាថា នេះថា ៖

អ្នកបានប្រើកម្លាំងគ្របសង្កត់ ដើម្បីដោះលែងអ្នកទូក ដែលត្រូវនាគឃោឃៅប្រទូស្តក្នុងក្រសែគង្គា ព្រោះការងាររបស់អ្នកនោះជាវត្ត និងសីលវត្តចាស់របស់លោក , តថាគតតាមរលឹកបាន ដូចអ្នកដែលដេកលក់ហើយភ្ញាក់ ។

ក្នុងសម័យដទៃទៀត ព្រហ្មអង្គនេះ បួសឥសី ជាតាបសឈ្មោះ កេសវៈ ។ ដោយសម័យនោះ ព្រះពោធិសត្វរបស់យើងជាមាណព ឈ្មោះ កប្បៈ ជាកូនសិស្សជាប់បម្រើតាមតាបសកេសវៈ ទទួលជំនួសកិច្ចការងារ ប្រព្រឹត្តត្រូវ

ចិត្ត ដល់ព្រមដោយសេចក្តីជឹងជុំវិញ ជាអ្នកប្រព្រឹត្តប្រយោជន៍ ។ វៀរនាយកប្បៈហើយ កេសវៈក៏មិនអាចនឹងប្រព្រឹត្តទៅបាន ។ ព្រោះបានអាស្រ័យនាយកប្បៈនោះឯង កេសវៈទើបចិញ្ចឹមជីវិតបាន ។ ព្រះសាស្តាកាលនឹងទ្រង់សម្តែងបុព្វកម្មសូម្បីនេះរបស់ព្រហ្មនោះ ទើបត្រាស់ព្រះគាថា នេះថា ៖

ក៏តថាគតជានាយកប្បៈ ជាប់តាមលោក លោកក៏បានយល់ថា តថាគតមានសេចក្តីជឹងជុំវិញ មានវត្ត , នោះជាវត្ត ជាសីលវត្តចាស់របស់អ្នក , តថាគត តាមរលឹកបានដូចអ្នកដេកលក់ហើយភ្ញាក់ ។

ព្រះសាស្តាទ្រង់បានប្រកាសកម្មដែលធ្វើហើយក្នុងអត្តភាពផ្សេងៗ របស់ព្រហ្មដូចដែលពោលមកនេះ ។ ខណៈដែលព្រះសាស្តាកំពុងត្រាស់ទុំះឯង ព្រហ្មក៏កំណត់ហើយ ។ កម្មគ្រប់យ៉ាងរបស់ព្រហ្មនោះ ប្រាកដដូចរូបដែលប្រាកដកាលប្រទីបមួយពាន់ឆេះសន្ធោសន្ធៅឡើង ដូច្នោះ ។ ព្រហ្មនោះ មានចិត្តជ្រះថ្លាពោលគាថានេះថា ៖

ព្រះអង្គជឹងច្បាស់អាយុរបស់ខ្ញុំនេះពិតប្រាកដ ព្រះអង្គជឹងសូម្បីវត្ថុដទៃៗ ដូចជាព្រះពុទ្ធានុភាព ដែលព្រះអង្គឲ្យឆេះសន្ធោសន្ធៅហើយនេះ ក៏យ៉ាងនោះឯង រមែងញ៉ាំងព្រហ្មលោកឲ្យភ្លឺហើយ

តាំងនៅ ។

គ្រានោះ កាលទ្រង់ប្រកាសភាពជាអ្នកប្រសើរនឹងអ្នកដែលមិនមាន អ្នកណាស្មើ សូម្បីឲ្យក្រៃលែងឡើងទៀតដល់ព្រហ្មអង្គនោះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យជាដើមថា **បឋវិយោ បឋវត្តេន អននុភូតំ** ។ ក្នុងពាក្យទាំងនោះ ពាក្យថា **មិនប្រព្រឹត្តទៅតាម ព្រោះអត្ថថា ភាវៈជាផែននៃផែនដី** សេចក្តីថា មិនប្រព្រឹត្តទៅតាម បានដល់ មិនធ្លាប់ដល់ ព្រោះភាវៈជាផែនដីនៃផែនដី ។ សួរថា នោះបានដល់អ្វីហ្ន៎ ? ឆ្លើយថា បានដល់ ព្រះនិព្វាន ។ ក៏ព្រះនិព្វាននោះ ឈ្មោះថា មិនធ្លាប់ដល់ដោយភាវៈជាផែនដី ព្រោះព្រះនិព្វាននោះ ផុតពីសភាវៈដែលត្រូវបច្ច័យគ្រប់យ៉ាងតាក់តែង ។ ពាក្យថា **ដឹងដ៏ក្រៃលែងនូវព្រះនិព្វាននុ៎ះ** សេចក្តីថា ដឹង គឺ ធ្វើព្រះនិព្វាននោះឲ្យជាក់ច្បាស់ហើយ ។ ពាក្យថា **មិនប្រកាន់ចំពោះផែនដី** សេចក្តីថា តថាគតមិនកាន់យកផែនដី ដោយការកាន់យកដោយអំណាចតណ្ហា ទិដ្ឋិ និងមានៈ ។ សូម្បីក្នុងទឹកជាដើម ក៏ទំនងដូចគ្នានេះឯង ។ ចំណែកសេចក្តីពិស្តារ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងមូលបរិយាយសូត្រនុ៎ះឯង ។

ព្រហ្មនេះ សម្គាល់អក្ខរថា **ទាំងអស់** ព្រោះខ្លួនជាអ្នកពោលពាក្យនេះថា បពិត្រព្រះអង្គអ្នកនិទុក្ខ **នៃវត្ថុទាំងពួង** ព្រោះអត្ថថា ទាំងអស់ ហើយយក

សេចក្តីខុសក្នុងអក្ខរមកពោល ។ តែព្រះសាស្តាទ្រង់ជាអ្នកអាច ទើបទ្រង់សំដៅយកវត្ថុណា មកត្រាស់ថា ទាំងអស់ ។ ព្រហ្មទើបពោលថា លោកសំដៅយកទាំងអស់ មកពោលថា ទាំងអស់ លោកនិយាយថា មិនប្រព្រឹត្តទៅតាម ព្រោះអត្ថថា ទាំងអស់ បើវត្ថុដែលមិនប្រព្រឹត្តទៅតាមទាំងអស់មិនមាន វត្ថុដែលមិនប្រព្រឹត្តទៅតាមវត្ថុនោះក៏មាន សូមឲ្យពាក្យរបស់អ្នកចូរកុំជាពាក្យដែលសោះសូន្យប៉ុណ្ណោះឡើយ កុំជាពាក្យដែលទទេៗ ប៉ុណ្ណោះឡើយ ហើយក៏គ្របសង្កត់ព្រះ-សាស្តាដោយមុសាវាទ (គឺចោទទ្រង់ថា និយាយកុហក) ថា សូមឲ្យពាក្យរបស់ព្រះអង្គ កុំជាពាក្យដែលសោះសូន្យ កុំជាពាក្យដែលទទេៗ ដូច្នេះ ។

ចំណែកព្រះសាស្តា ទ្រង់មានព្រះពុទ្ធដីកាញាប់ក្រៃលែង ជាងព្រហ្មនេះទាំងរយដង ពាន់ដង សែនដង ដូច្នោះ កាលនឹងទ្រង់នាំយកហេតុមកដើម្បីញាំញីពាក្យនិយាយរបស់ព្រហ្មនោះថា តថាគតនឹងពោលដល់សភាវៈទាំងអស់ តថាគតនឹងពោលសភាវៈដែលមិនមានអ្វីប្រព្រឹត្តទៅតាម ចូរស្តាប់តថាគត ទើបត្រាស់ពាក្យជាដើមថា **វិញ្ញាណំ** ក្នុងពាក្យទាំងនោះ ពាក្យថា **វិញ្ញាណំ** សេចក្តីថា គប្បីដឹងឲ្យជាក់ច្បាស់ ។ ពាក្យថា **អនិទស្សនំ** សេចក្តីថា ឈ្មោះថា ឃើញមិនបាន ព្រោះមិនចូលកាន់គន្លងនៃចក្ខុវិញ្ញាណ ។ សូម្បីដោយបទទាំងពីរ (នេះ) ព្រះមានព្រះភាគ ត្រាស់ដល់ព្រះនិព្វានទុំះឯង ។ ពាក្យថា **អនន្តំ** សេចក្តីថា

ឈ្មោះថា រកទីបំផុតមិនបាន ព្រោះព្រះនិព្វាននោះ វៀរចាកចន្លោះនៃការកើត និងការវិនាស ។ សមពិតដូចពាក្យដែលព្រះមានព្រះភាគ សូម្បីត្រាស់ទុកហើយថា ៖

សត្វទាំងឡាយមានទីបំផុត ព្រះនិព្វានដែលមិនកើត មិនមានទីបំផុត សត្វទាំងឡាយមិនប្រាកដក្នុងទីបំផុត តថាគតបានប្រកាសទីបំផុតនៃសត្វហើយ ។

ពាក្យថា **ចូលដល់ពន្លឺទាំងអស់** បានដល់ ដល់ព្រមដោយពន្លឺ ដោយប្រការទាំងពួង ។ ពិតហើយ ក្រៅពីព្រះនិព្វានហើយ មិនមានវត្ថុដទៃដែលមានពន្លឺជាង មានសេចក្តីរុងរឿងជាង មានទីបំផុតដែលហ្មត់ចត់ជាង ឬស្អាតជាងម្យ៉ាងទៀត ព្រះនិព្វាន ជាដែនកើតចាកទីទាំងពួងតែម្យ៉ាង ក្នុងទីកន្លែងណាមួយមិនមែនមិនមាន ព្រោះដូច្នោះ ទើបឈ្មោះថា ជាដែនកើតដោយប្រការទាំងពួងពិតហើយ ក្នុងទិសខាងកើតជាដើម ឈ្មោះថា ក្នុងទិសឯណោះមិនគប្បីពោលថា មិនមានព្រះនិព្វាន ។ ម្យ៉ាងទៀត ពាក្យថា **ពន្លឺ** ជាឈ្មោះនៃកំពង់ ។ ឈ្មោះថា **មានកំពង់គ្រប់កន្លែង** ព្រោះគ្រប់កន្លែងមានកំពង់ ។ គេពោលជាប់ទាក់ទងនឹងព្រះនិព្វានថា បុគ្គលប្រាថ្នាចូលមហាសមុទ្រត្រង់ទីណាៗ ទីនោះៗ ឯងជាកំពង់ , ឈ្មោះថា កន្លែងដែលមិនមានកំពង់ រមែងមិនមានយ៉ាងណា ក្នុង

កម្មដ្ឋាន ៣៨ យ៉ាង បុគ្គលប្រាថ្នានឹងចូលទៅព្រះនិព្វានដោយប្រការណាៗ ប្រការនោះៗ ឯង រមែងជាកំពង់ , មិនមានកម្មដ្ឋានដែលឈ្មោះថា មិនជាកំពង់របស់ព្រះនិព្វាន ដូច្នោះដែរ , ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ជាកំពង់គ្រប់កន្លែង** ។ ពាក្យថា **បឋវិយោ បឋវិត្តេន** ផែនដីនៃផែនដី សេចក្តីថា ព្រះនិព្វាននោះ ជាសភាវៈដែលមិនប្រព្រឹត្តទៅតាមផែនដី ព្រោះអត្ថថា ផែនដីនឹងមិនប្រព្រឹត្តទៅតាមទឹកជាដើម ដទៃពីផែនដីនោះ ព្រោះភាវៈនៃទឹកជាដើម ។ ព្រះមានព្រះភាគទ្រង់តាំងព្រះតម្រាស់ថា ធម្មជាតិដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ដែលជាវិស័យរបស់អ្នក យ៉ាងណា ធម្មជាតិនោះ ជាធម្មជាតិដែលគប្បីដឹងច្បាស់ ឃើញមិនបាន មិនមានទីបំផុត កំពង់គ្រប់កន្លែងជាធម្មជាតិដែលមិនប្រព្រឹត្តទៅតាម ( អ្វីៗ ) ព្រោះអត្ថថា ទាំងអស់នោះ ជារបស់ធម្មជាតិដូច្នេះ ។

លំដាប់នោះ ព្រហ្មត្រូវព្រះសាស្តាត្រាស់ឲ្យលះបង់វត្ថុដែលប្រកាន់ទុកហើយៗ កាលសម្លឹងមិនឃើញអ្វីដែលគប្បីកាន់យក ក៏ប្រាថ្នានឹងធ្វើលទ្ធិទុក ទើបនិយាយថា បពិត្រព្រះអង្គអ្នកនិរទុក្ខ ណ្ហើយចុះ ខ្ញុំនឹងបំបាត់ខ្លួនអំពីព្រះអង្គឥឡូវនេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ខ្ញុំនឹងបំបាត់ខ្លួន** សេចក្តីថា ព្រហ្មពោលថា ខ្ញុំនឹងធ្វើបាដិហារ្យមិនឲ្យអ្នកណាឃើញខ្លួន ។

ពាក្យថា **បើអ្នកអាច** សេចក្ដីថា បើអ្នកអាច ក៏ចូរធ្វើបាដិហារ្យដែលបំបាត់ខ្លួនបានពិតៗ ដើម្បីសេចក្ដីបាត់ខ្លួនដល់តថាគតមើល ។ ពាក្យថា **អ្នកមិនអាចនឹងបំបាត់ខ្លួនពីតថាគតទេ** សេចក្ដីថា អ្នកនឹងមិនអាចដើម្បីនឹងបំបាត់ខ្លួនដល់តថាគតបានទេ ។ សួរថា ក៏ព្រហ្មនេះជាអ្នកប្រាថ្នានឹងធ្វើអ្វី ? ឆ្លើយថា ជាអ្នកប្រាថ្នាដើម្បីនឹងទៅកាន់បដិសន្ធិដូចដើម ។ ពិតហើយ អត្តភាពដែលបានពីបដិសន្ធិតាំងពីដើមរបស់ពួកព្រហ្ម ជាវត្ថុល្អិត ជាទីពឹងដល់អ្នកដទៃមិនបាន រមែងតាំងនៅដោយកាយដែលត្រូវតាក់តែងយ៉ាងក្រៃលែង (អភិសង្ខារ) នុ៎ះឯង ។ ព្រះសាស្ដាមិនបានប្រទានដើម្បីទៅកាន់បដិសន្ធិដូចដើម ដល់ព្រហ្មនោះ ។ ឬកាលមិនទៅកាន់បដិសន្ធិដូចដើម ព្រហ្មគប្បីធ្វើខ្លួនឲ្យបាត់ទៅ ហើយជាអ្នកដែលមិនមានអ្នកណាមើលឃើញដោយសេចក្ដីងងឹតណា ។ ព្រះសាស្ដាទ្រង់បន្ទោបង់សេចក្ដីងងឹតនោះចេញហើយ ព្រោះដូច្នោះ ព្រហ្មទើបមិនអាចនឹងបំបាត់ខ្លួនបាន ។ កាលគេមិនអាចពួនលាក់ខ្លួនក្នុងវិមាន ទើបពួនលាក់ខ្លួនក្បែរដើមកប្បព្រឹក្ស អន្ធយប្រហោង ។ ពួកព្រហ្ម ក៏ធ្វើការចំអកឡកឡឺយថា ពួកព្រហ្មនេះឯង ពួនលាក់ខ្លួនក្នុងវិមាន ពួនលាក់ខ្លួនក្បែរដើមឈើកប្បព្រឹក្ស អន្ធយប្រហោង ។ ព្រហ្ម ឈ្មោះថា រមែងបង្កឲ្យកើតសញ្ញាថា ខ្ញុំនឹងបាត់ខ្លួន គេត្រូវពួកព្រហ្មចំអកឡកឡឺយ ក៏សែនអៀនខ្មាស បាក់មុខ ។

ពាក្យថា **កាលព្រហ្មនិយាយយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលព្រហ្មនោះពោលយ៉ាងនោះថា ណ្ហើយចុះ បពិត្រព្រះអង្គអ្នកនិរទុក្ខ ខ្ញុំនឹងបំបាត់ខ្លួនអំពីព្រះអង្គក្នុងឥឡូវនេះ តថាគតមើលឃើញថា ព្រហ្មនោះមិនអាចនឹងបំបាត់ខ្លួនបាន ទើបបានពោលពាក្យនេះ ។ ពាក្យថា **តថាគតបានពោលគាថានេះ** សេចក្តីថា សួរថា ហេតុដូចម្តេចទើបព្រះមានព្រះភាគ ទើបត្រាស់ព្រះគាថា ? ឆ្លើយថា ព្រះមានព្រះភាគទ្រង់គិតថា ពួកព្រហ្ម ចូរកុំមានឱកាសពោលយ៉ាងនេះថា អ្នកណានឹងអាចជ្រាបបានយ៉ាងណាថា ក្នុងទីនេះមានព្រះគោតមជាសមណៈ ឬមិនមាន ទើបបានត្រាស់ព្រះគាថា ហើយស្តេចបាត់ព្រះអង្គទៅ ។

ក្នុងពាក្យទាំងនោះ បាទព្រះគាថាថា **តថាគតឃើញភ័យក្នុងភពនោះឯង** សេចក្តីថា តថាគតឃើញភ័យក្នុងភពដោយពិត ។ បាទព្រះគាថាថា **ភវៈ និងអ្នកស្វែងរកវិភវៈ** សេចក្តីថា ឃើញភពរបស់សត្វ សូម្បីទាំងបីយ៉ាង មានកាមភពជាដើមនេះ ឃើញអ្នកស្វែងរកវិភវៈ គឺ ស្វែងរកទីនៅ បានដល់ ស្វែងរកទីនៅដែលជាវិភវៈ និងឃើញ (ភ័យ) ក្នុងភពនុ៎ះឯងរឿយៗ ។ ពាក្យថា **មិនពោលសរសើរ** សេចក្តីថា មិនរៀបរាប់ គឺ មិនស្វែងរកភពណា ៗ ដោយអំណាចតណ្ហា និងទិដ្ឋិ បាទគាថាថា **មិនប្រកាន់មាំដោយសេចក្តីភ្លើតភ្លើន** សេចក្តី

ថា មិនចូលដល់ គឺ មិនបានកាន់យកតណ្ហាក្នុងភព ។ ព្រះសាស្តាកាលទ្រង់ប្រកាសសច្ចៈបួនប្រការ ទ្រង់សម្តែងនូវធម្មៈ ដោយប្រការដូច្នេះ ។

កាលទ្រង់ទេសនាចប់ ព្រហ្មប្រមាណ ១ ម៉ឺនអង្គ ញ៉ាំងវិបស្សនាឲ្យកាន់យកគភ៌ (តាំងផ្ទៃហើយ ក៏ប្រសូត ដូចស្រូវផើមហើយក៏ចេញកួរ) តាមដូវនៃទេសនាហើយ ក៏ផឹកទឹកអម្រឹត គឺ មគ្គផល ។

[១៩៥] ពាក្យថា **ក៏កើតសេចក្តីជាអស្ចារ្យក្នុងចិត្ត** សេចក្តីថា ជាអ្នកកើតអស្ចារ្យ កើតសេចក្តីចម្លែកចិត្ត និងកើតសេចក្តីត្រេកអរហើយ ។ បាទព្រះគាថាថា **ទ្រង់ដកកពព្រមទាំងឫសគល់បានហើយ** សេចក្តីថា ទ្រង់ដក គឺផ្តាច់ផ្តិល បានដល់ ទ្រង់ទាញកន្ទ្រាក់កពព្រមទាំងឫសគល់របស់ទេវតា និងមនុស្សដ៏ច្រើនសូម្បីពួកដទៃ ដោយទេសនានោះៗ របស់ព្រះអង្គត្រង់គល់ពោធិព្រឹក្ស ។

[១៩៦] ក៏ក្នុងសម័យនោះឯង មារអ្នកមានបាប ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ហើយ គិតថា កាលយើងត្រាច់អន្ទោលហើយទុំះឯង ព្រហ្មប្រមាណមួយម៉ឺនអង្គ ប្រព្រឹត្តកន្លងពីអំណាចយើងទៅបាន ព្រោះព្រះសមណគោតមសម្តែងធម៌ ទើបចូលស្ថិតក្នុងរាងកាយរបស់ព្រហ្មបារិសជ្ជៈអង្គណាមួយព្រោះភាពជាអ្នកត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ ដើម្បីទ្រង់សម្តែងមារនោះ

ទើបត្រាស់ពាក្យជាដើមថា **គ្រានោះឯង ម្នាលភិក្ខុទាំងឡាយ** ដូច្នេះ ។

បណ្តាពាក្យទាំងនោះ ពាក្យថា **ប្រសិនបើគេត្រាស់ដឹងតាមយ៉ាងនេះ** សេចក្តីថា បើគេត្រាស់ដឹងតាមសច្ចៈបួនយ៉ាង ដោយខ្លួនយ៉ាងនេះ ។ ពាក្យថា **កុំពន្យល់សាវក** សេចក្តីថា កុំបង្ហោនយកធម៌នោះ ចូលទៅក្នុងសាវកដែលជាគ្រហស្ថ ឬសាវកដែលជាបព្វជិត ។ ពាក្យថា **តាំងនៅក្នុងកាយ ដ៏ថោកទាប** សេចក្តីថា តាំងនៅក្នុងអបាយទាំង ៤ ។ ពាក្យថា **តាំងនៅក្នុងកាយដ៏ប្រណីត** សេចក្តីថា តាំងនៅក្នុងព្រហ្មលោក ។

ព្រះមានព្រះភាគត្រាស់ពាក្យនេះ សំដៅយកពួកបុគ្គលណា ? ត្រាស់សំដៅយកពួកតាបស និងបរិព្វាជកដែលជាអ្នកបួសក្នុងលទ្ធិខាងក្រៅ ។ សេចក្តីពិតថា កាលមិនទាន់កើតយុគៈពុទ្ធុប្បាទ ពួកកុលបុត្របួសជាតាបស មិនពិចារណាអ្វីៗ របស់បុគ្គលណាៗ ត្រាច់ទៅម្នាក់ឯង ញុំាំងសមាបត្តិឲ្យកើត ហើយក៏ចូលដល់ព្រហ្មលោក ។ ព្រះមានព្រះភាគត្រាស់សំដៅយកពួកទាំងនោះ ។ បាទគាថាថា **អ្នកនិរទុក្ខ គេមិនបាននិយាយដល់កុសលឡើយ** សេចក្តីថា អ្នកនិរទុក្ខ គេមិនបាននិយាយដល់កុសល មិនទូន្មាន មិនពោលធម្មកថាដល់បុគ្គលពួកដទៃ ប្រការនោះជាការល្អជាង ។ ពាក្យថា **ចូរកុំប្រៀនប្រដៅអ្នកដទៃ** សេចក្តីថា គេកុំត្រាច់ស្វែងរកមនុស្សលោកជាវេលា ទេវលោកជាវេលា ព្រហ្មលោក

ជាវេលា នាគលោកជាវេលា ចូរអន្ទុយសម្ដាប់វេលា នៅជាសេចក្ដីសុខក្នុងឈាន ក្នុងមគ្គ និងក្នុងផលក្នុងទីតែម្យ៉ា ។ ពាក្យថា **ព្រោះភាពជាអ្នកមិននិយាយរអ៊ូរទាំ** សេចក្ដីថា ព្រោះភាពជាអ្នកមិននិយាយអួតខ្លួនឯង ។ ពាក្យថា **ព្រោះការនិមន្ត របស់ព្រហ្ម** សេចក្ដីថា និងព្រោះពាក្យគោរពអញ្ជើញរបស់ពួកព្រហ្ម ដោយតំណែងនៃព្រហ្មអ្នកមានឱកាស ព្រមដោយន័យជាដើមថា អ្នកនិរទុក្ខ នេះឯងជារបស់ទៀង ។ ពាក្យថា **តស្មា** ប្រែថា ព្រោះហេតុនោះ ។ ពាក្យថា **ព្រហ្មនិមន្តនិក** នុ៎ះឯងជាឈ្មោះ ជាពាក្យសម្រាប់រាប់ ជាពាក្យដែលដឹងព្រមគ្នា ជាពាក្យតែងតាំងកើតហើយពីពាក្យចងក្រងនេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ហើយទាំងអស់ ដូច្នេះឯង ។

“ ចប់អដ្ឋកថា ព្រហ្មនិមន្តនិកសូត្រទី៩ ”

# អ ដ្ឋ ក ថា

## មារតជ្ជនីយសូត្រទី ១០

[១៩៧] មារតជ្ជនីយសូត្រ មានពាក្យចាប់ផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖

ក្នុងបទទាំងនោះ បទថា **ចូលទៅតាមពោះវៀន** សេចក្ដីថា ចូលទៅក្នុងពោះហើយ ចូលទៅតាមលំដាប់ខាងក្នុងពោះវៀនធំ ហើយអង្គុយត្រង់ក្រពះអាហារ ។

បទថា **ដូចជាធ្ងន់ៗ** សេចក្ដីថា រឹងមាំធ្ងន់ដូចទឹងដុំផ្ទាំងថ្ម ។ អធិប្បាយថា អាហារដែលធ្វើដោយសណ្ដែក ឃើញទឹងដូចសណ្ដែកដែលសើម (ដោយប្រេង) ដូចពោះរបស់អ្នកដែលបរិភោគបាយហើយ ដូចការុងដែលពេញដោយសណ្ដែក និងដូចសណ្ដែកដែលសើមជោកហើយ ។

បទថា **ចូលទៅវិហារ** សេចក្ដីថា បើនេះជាសេចក្ដីធ្ងន់ព្រោះទោសរបស់អាហារ ការចង្ក្រមក្នុងទីវាល ក៏នឹងមិនជាសេចក្ដីសប្បាយ ។ ដូច្នោះព្រះថេរៈទើបចុះចាកទីចង្ក្រម ចូលទៅបណ្ណសាលា អង្គុយលើអាសនៈដែលក្រាលទុកតាមប្រក្រតី ។

បទថា **ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាចំពោះខ្លួន** សេចក្តីថា កាលពិចារណាថា នេះអ្វីហ្ន៎ ព្រះថេរៈទើបបានធ្វើទុកក្នុងចិត្តដោយឧបាយរបស់ខ្លួនតែម្យ៉ាង ។ ក៏បើព្រះថេរៈរលឹកដល់សីល យកដៃស្ទាបពោះពិចារណាថា អាហារដែលយើងបរិភោគថ្ងៃម្សិលមិញ ថ្ងៃម្សិលម្ងៃ ឬមុនថ្ងៃម្សិលម្ងៃនោះ មិនរលួយឬថា ទោស ដែលកើតពីអាហារដែលមិនត្រូវចំណែកគ្នាយ៉ាងដទៃណាៗ មានហើយអាហារទាំងអស់នោះចូររលួយទៅ ចូរសុខស្រួលចុះ ។ មារមានចិត្តបាប ក៏តូចចិត្ត ហើយក៏បាត់ពីទីនោះទៅ ។ ព្រះថេរៈមិនបានធ្វើយ៉ាងនោះទេ ទើបបានធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។

[១៩៨] បទថា **អ្នកកុំបៀតបៀនព្រះតថាគតឡើយ** សេចក្តីថា ដូចសេចក្តីថា កាលកូនៗ ត្រូវបៀតបៀន មាតា និងបិតាក៏ជាការត្រូវបៀតបៀនផង កាលសទ្ធិវិហារិក និងអន្តេវាសិកត្រូវបៀតបៀន ឧបជ្ឈាយ៍ និងអាចារ្យក៏ជាការត្រូវបៀតបៀនផង កាលអ្នកជនបទត្រូវបៀតបៀន ព្រះរាជាក៏ជាការត្រូវបៀតបៀនផង យ៉ាងណា កាលសាវករបស់ព្រះតថាគតត្រូវបៀតបៀន ព្រះតថាគតក៏ជាការត្រូវបៀតបៀនផង ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមហាមោគ្គល្លានត្ថេរៈ ទើបពោលថា **អ្នកកុំបៀតបៀនព្រះតថាគតឡើយ** ។

បទថា **បានឈរត្រង់បង្អួច** បានដល់ ឈរត្រង់សន្ទះទ្វារ សន្ទះទ្វារ

លោកហៅថា **អគ្គឡ** មារបានចេញទៅតាមមាត់ ទៅអំពីបណ្ណសាលា ហើយនៅឈរផ្អែកទ្វារបណ្ណសាលា ។

[១៩៩] ព្រោះហេតុអ្វី ព្រះថេរៈទើបប្រារព្ធទេសនានេះថា **មារមានចិត្តបាប រឿងធ្លាប់មានមកហើយ** ន័យថា ព្រះថេរៈគិតថា ក្និនរបស់ពួកមនុស្សរមែងបៀតបៀនពួកអាកាសទេវតាទាំងរយយោជន៍ ។

ក៏ពាក្យនោះ ព្រះថេរៈពោលថា មហារាជ ក្និនពួកមនុស្ស រមែងបៀតបៀនពួកទេវតាទាំងរយយោជន៍ ក៏ព្រោះហេតុនោះ មារនេះ ជាអ្នកក្រុង មានបរិវាររក្សា ដល់ព្រមដោយអានុភាព ជាភជារបស់ពួកទេព ចូលទៅក្នុងពោះរបស់យើង អង្គុយនៅក្នុងក្រពះអាហារខាងក្នុងពោះវៀន ប្រទូសរ៉ាយហួសប្រមាណ ។ ក៏កាលព្រះថេរៈពោលថា នាទីដទៃណានឹងមានដល់អ្នកដែលអាចចូលឱកាសដែលគួររង្កៀស គួរខ្ពើមបែបនេះ មិនខ្វាស់វត្ថុដទៃណា អ្នកមិនមែនញាតិរបស់យើង ។ មារទើបគិតថា ដែលឈ្មោះថា អ្នកដែលមិនដល់សេចក្តីទោរទន់រមែងមិនមាន ណ្ហើយចុះនឹងចាក់ខាងក្រោយញាតិរបស់ព្រះថេរៈនោះ ហើយលែងលោកដោយឧបាយដែលសុភាពតែម្តង ទើបប្រារព្ធការសម្តែងនេះ ។

បទថា **អ្នកនោះជាក្មួយរបស់យើង** សេចក្តីថា អ្នកនោះជាក្មួយរបស់

យើងក្នុងវេលានោះ ។ ព្រះថេរៈពោលពាក្យនេះដោយអំណាចទំនៀម ។ ក៏ឈ្មោះថា ពួកក្រុមរបស់បិតាមារ ដែលជាខ្សែស្រឡាយរបស់តូ គ្រងរាជ្យមិនមានក្នុងទេវលោក ។ បិតារបស់មារនោះ កើតជារាជានៃទេវតាក្នុងទេវលោកដោយអំណាចរបស់បុណ្យ តាំងនៅមួយអាយុហើយចុតិ ទេវតាដទៃមួយអង្គទៀត ដែលកើតជាធំក្នុងទីនោះដោយកម្មដែលខ្លួនធ្វើហើយ ។ សូម្បីមារនោះក៏គប្បីជ្រាបថា វេលានោះឃ្លាតចាកអត្តភាពនោះ ធ្វើកុសលទៀត កើតក្នុងតំណែងអធិបតីវេលានេះ ដូច្នេះឯង ។

បទថា **មានធុរៈទៅប្រាសហើយ** គឺ ប្រាសចាកធុរៈ អធិប្បាយថា មិនដូចពួកអ្នកដទៃៗ ។

ពាក្យថា **មានទុក្ខតិច** គឺ លំបាកតិច ។

ពាក្យថា **អ្នកចិញ្ចឹមសត្វ** គឺ អ្នកចិញ្ចឹមពពែ ចិញ្ចឹមកែះ ។

ពាក្យថា **អ្នកធ្វើដំណើរ** គឺ អ្នកដើរទៅតាមផ្លូវ ។

បទថា **រុំព័ទ្ធកាយ** សេចក្តីថា ចងជាមួយជើងថ្ករជុំវិញ ។

បទថា **ដុតភ្លើងហើយក៏ចៀសទៅ** សេចក្តីថា អ្នកស្រែទាំងឡាយកំណត់ខ្នាតរបស់ជើងថ្ករថា ជើងថ្ករប៉ុណ្ណេះ ភ្លើងក៏នឹងកាន់យកជុំវិញ (ឆេះទូទៅ) ហើយដុតភ្លើងឡើងទាំង ៤ ទិស ចៀសចេញទៅ ។ ជើងថ្ករក៏បានឆេះសន្ធោ-

សន្ទៅដូចអណ្តាតប្រទីប (និង) បានដូចជាវេលាដែលព្រះថេរៈ ចូលឈ្នាងមានទឹកហើយអន្តុយចុះ ។ បទថា **រលាស់ចីវរ** សេចក្តីថា ព្រះថេរៈកាលចេញចាកសមាបត្តិហើយជាន់រងើកភ្លើងដែលមិនមានផ្សែង មានពណ៌ដូចផ្កាចារ បានរលាស់ចីវរហើយ សូម្បីត្រឹមតែចំហាយក្តៅក៏មិនមានក្នុងរាងកាយរបស់លោក ។ សូម្បីត្រឹមតែចំហាយក្តៅក៏មិនឆេះចីវរ ។ នេះឈ្មោះថា ជាផលរបស់សមាបត្តិ ។

[២០០] បទថា **ចូរជេរ** សេចក្តីថា ពួកលោកចូរជេរដោយវត្ថុសម្រាប់ជេរ ១០ ប្រការ ។

បទថា **បរិភាស** បានដល់ ពោលដោយវាចាតិះដៀល ។

បទថា **ចូរជេរបញ្ចិតបញ្ចៀង** បានដល់ ចូរពោលឌឺដង ។

បទថា **ចូរបៀតបៀន** បានដល់ ឲ្យដល់ទុក្ខ ។ ពាក្យទាំងអស់នេះ ជាឈ្មោះរបស់ការប៉ះទង្គិចឌឺដងផ្លូវវាចា ។

បទថា **ដូចមារឈ្មោះថា ទូសី... ចន្លោះនោះ** សេចក្តីថា ដូចមារឈ្មោះថាទូសី (បានចន្លោះ) របស់ពួកព្រាហ្មណ៍ និងគហបតីទាំងនោះ ។

បទថា **ចូរបានចន្លោះ** សេចក្តីថា ពួកលោកចូរបានដឹង គឺ គប្បីបានអារម្មណ៍ដែលជាបច្ច័យនៃការកើតឡើងរបស់កិលេស ។

ក្នុងបទជាដើមថា **ត្រងោល** ដូច្នេះ ពួកព្រាហ្មណ៍ និងគហបតីពោល

ថា មារគប្បីសមគួរពោលនឹងអ្នកមានសិរសៈត្រងោលថា ត្រងោល និងនឹងពួកសមណៈថា សមណៈ ក៏ពួកសមណៈត្រងោលទាំងនេះមើលងាយហើយ ។

ពាក្យថា **គហបតិ** បានដល់ ម្ចាស់ផ្ទះ ។

ពាក្យថា **ខ្មៅ** បានដល់ ងងឹត ។

ព្រហ្ម លោកបំណងយកថា **ញាតិ** ក្នុងបទនេះថា **ពួកក្រុមរបស់ស្តេចមហាព្រហ្ម** ។ ពួកព្រាហ្មណ៍ រមែងស្រែកហៅព្រហ្មសូម្បីនោះថា ជីតា ។ អធិប្បាយថា ពួកក្រុមរបស់អ្នកដែលកើតអំពីជើងទាំងឡាយ ឈ្មោះថា ពួកក្រុមរបស់អ្នកដែលកើតពីជើង ។ គឺ ពួកអ្នកកើតពីខ្នងជើងរបស់ព្រះព្រហ្ម ។

បានឮថា ពួកព្រាហ្មណ៍នោះ មានលទ្ធិយ៉ាងនេះថា ពួកព្រាហ្មណ៍កើតពីមាត់ព្រះព្រហ្ម ក្សត្រិយ៍កើតពីទ្រូង ។ ពួកឈ្មួញកើតពីផ្ចិត ។ ពួកសូទ្រៈកើតពីស្មង ។ ពួកសមណៈកើតពីខ្នងព្រះបាទ ។

បទថា **យើងជាអ្នកមានឈាន ជាអ្នកមានឈាន** សេចក្តីថា ពួកយើងជាអ្នកសម្ងឹង ពួកយើងជាអ្នកផ្តោត ។

បទថា **កើតសេចក្តីធ្លាញ់** បានដល់ កើតសេចក្តីខ្ជិលច្រអូស ។

បទថា **សម្ងឹង** បានដល់ គិត ។

បទថា **សម្ងឹងទូទៅ** ជាដើម លោកពង្រីកដោយអំណាចឧបសគ្គៈ ។

បទថា **រកកណ្តុរ** សេចក្តីថា ស្វែងរកកណ្តុរលើមែកឈើ កណ្តុរដែលចេញចាកដើមឈើដែលមានប្រហោង ដើម្បីរកអាហារវេលាល្ងាច ។

ន័យថា សត្វមៀមនោះ ឈរស្ងៀម ដូចស្ងប់ស្ងៀមហើយ នឹងចាប់កណ្តុរយ៉ាងរហ័សក្នុងវេលាដែលជួបគ្នា ។

បទថា **ខ្លែព្រៃ** បានដល់ ខ្លែចចក ។ អាចារ្យទាំងឡាយពោលថា សត្វស្មាំងខ្វះ ។

បទថា **ជញ្ជាំងផ្ទះ ទបង្ហូរទឹកស្អុយ និងគំនរសម្រាម** សេចក្តីថា ក្បែរជញ្ជាំងផ្ទះផង ទសម្រាប់បង្ហូរទឹកជ្រាំផង គំនរសម្រាមផង ។ ក្នុងទីទាំងនោះ ទីតផ្ទះ ឈ្មោះថា ជញ្ជាំងនៃផ្ទះ ទបង្ហូរទឹកស្អុយជាទីបោចលលាមក ឈ្មោះថា ទសម្រាប់បង្ហូរទឹកស្អុយ ទីដែលបោចលសម្រាម ឈ្មោះ គំនរសម្រាម ។

បទថា **សត្វលានោះស្បើយកម្លាំង** សេចក្តីថា កាលចេញចាកទីកន្តារ សត្វលានោះក៏ទន់កម្លាំង "អស់ជើង" ។

បទថា **ជញ្ជាំងផ្ទះ ទបង្ហូរទឹកស្អុយ និងគំនរសម្រាម** បានដល់ ជញ្ជាំងផ្ទះ ទបង្ហូរទឹកសំអុយ ឬគំនរសម្រាម ។ ក៏លាសូម្បីនោះ បើដុតក៏មិនញ័រ ដូចជា រឹងគាំង ។

បទថា **ចូលដល់នរក** សេចក្តីថា បើមារចូលស្ថិតក្នុងរាងកាយរបស់ពួក

មនុស្ស ពួកមនុស្សមិនគប្បីមានអកុសលកម្ម នឹងគប្បីមានដល់មារប៉ុណ្ណោះ តែមារមិនបានស្ថិតក្នុងរាងកាយ ហើយសម្ដែងវត្ថុដែលមិនត្រូវចំណែកគ្នា និងអារម្មណ៍ដែលឲ្យកើតសេចក្ដីក្ដៅក្រហាយ ។

ប្រាបថា គ្រានោះ មារនោះសម្ដែងភិក្ខុទាំងឡាយ ធ្វើឲ្យដូចជាអ្នកចាប់ត្រី ហើយចាប់ដោយរហ័ស ១ ឲ្យដូចជាអ្នកកាន់សំណាញ់ហើយបង់ត្រី ១ ឲ្យដូចជាអ្នកវាយលុបរហ័ស ហើយចងបក្សីទុក ១ អ្នកត្រាច់ដេញកៀងម្រឹគក្នុងព្រៃនឹងសុនខ ១ អ្នកនាំស្រីមកអង្គុយក្នុងទីផឹក ១ អ្នករបាំ ១ អ្នកច្រៀង ១ ឲ្យដូចជាពួកមនុស្សដែលមិនត្រូវគ្នា អង្គុយ និងឈរ ក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃរបស់ភិក្ខុទាំងឡាយ ១ ។

មនុស្សទាំងឡាយទៅព្រៃខ្លះ ទៅវត្តខ្លះ ឃើញអារម្មណ៍ដែលធ្វើឲ្យក្ដៅក្រហាយ ហើយមកពោលដល់ពួកអ្នកដទៃថា ពួកសមណៈធ្វើកិច្ចដែលមិនសមគួរបែបនេះ កាលពួកយើងបានថ្វាយផ្ទូវដល់សមណៈទាំងនោះ ទីណានឹងបានបុណ្យកុសល ពួកអ្នកកុំបានថ្វាយអ្វីៗ ដល់សមណៈទាំងនោះ ។ មនុស្សទាំងនោះ ជេរភិក្ខុដែលមានសីលទាំងឡាយក្នុងទីដែលខ្លួនឃើញហើយៗ បានទទួលបាប ជាអ្នកដែលញុំាងអបាយឲ្យពេញ ព្រោះហេតុនោះ ព្រះថេរៈទើបពោលថា ពួកមនុស្សបានចូលដល់នរក ។

[២០១] បទថា **ដែលមារឲ្យវិលទៅតាម** បានដល់ ត្រូវមារបន្ទិលដោយទូទៅ ។

បទថា **ផ្សាយទៅហើយ** បានដល់ មិនមែនផ្សាយហើយទៅតែម្យ៉ាង ។ ក៏អ្នកដែលតាំងនៅក្នុងឱវាទរបស់ព្រះមានព្រះភាគព្រះនាមថា កកុសន្ធៈ ញុំាំងព្រហ្មវិហារធម៌ ៤ ទាំងនេះកើតហើយ ចម្រើនវិបស្សនាដែលមានឈានជាបាទ បានតាំងនៅក្នុងព្រះអរហត្ត ។

[២០២] ពាក្យថា **ទីមក ឬទីទៅ** សេចក្តីថា យើងមិនដឹងទីដែលមកដោយអំណាចបដិសន្ធិ ឬទីដែលទៅដោយអំណាចគតិ ។

ពាក្យថា **ចិត្តនឹងគប្បីមានការប្រព្រឹត្តទៅដោយប្រការដទៃ** សេចក្តីថា គប្បីមានការប្រព្រឹត្តទៅដោយប្រការដទៃ ដោយអំណាចសេចក្តីពេញចិត្ត ។

សូម្បីក្នុងបទនេះថា **ចូលដល់ទេវលោកសួគ៌** ក៏គប្បីជ្រាបសេចក្តីតាមន័យមុននោះឯង ។ សេចក្តីថា មារ រមែងសម្តែងអារម្មណ៍ដែលធ្វើឲ្យក្តៅក្រហាយក្នុងកាលមុនយ៉ាងណា ក្នុងពេលឥឡូវនេះក៏យ៉ាងនោះ សម្តែងអារម្មណ៍ធ្វើឲ្យថ្វាថ្នូរផងបាន ។

ជ្រាបថា គ្រានោះ មារនោះ បានបំភ្លឺភិក្ខុទាំងឡាយទុកក្នុងទីដែលប្រាកដដល់អ្នកទាំងឡាយ ធ្វើឲ្យដូចជាទៅក្នុងអាកាស ឈរក្នុងអាកាស ។ អន្ទិយស្ទឹង-

ស្ពានធំ ដូចជាដេរសំពត់ក្នុងអាកាស ដូចជាប្រាប់គម្ពីរក្នុងអាកាស ដូចជាត្រដាងចីវរឲ្យកាយទទួលវដូវក្នុងអាកាស ដូចជាបព្វជិតដែលត្រាច់ទៅក្នុងអាកាស ដូចជា សាមណេរកម្មោះឈររក្សាផ្កាឈើក្នុងអាកាស ។ ពួកមនុស្សទៅព្រៃខ្លះទៅដងព្រៃខ្លះ ទៅវត្តខ្លះ ឃើញការបដិបត្តិនោះរបស់ពួកបព្វជិត រមែងមកប្រាប់ដល់ពួកមនុស្សដទៃថា ក្នុងពួកភិក្ខុ ដោយទីបំផុតសូម្បីសាមណេរ ក៏មានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះ អ្នកដែលថ្វាយទានដល់លោកទាំងនោះឈ្មោះថា មានផលច្រើន ពួកអ្នកចូរថ្វាយ ចូរធ្វើសក្ការៈដល់ពួកលោកទាំងនោះចុះ ។ លំដាប់នោះ ពួកមនុស្សបានសក្ការៈភិក្ខុសង្ឃដោយបច្ច័យ ៤ ធ្វើបុណ្យទុកច្រើន ជាអ្នកដែលញុំាងផ្លូវសួគ៌ឲ្យពេញ ព្រោះហេតុនោះ ព្រះថេរៈទើបពោលថា រមែងចូលដល់លោកសួគ៌ ។

[២០៣] ពាក្យថា **ភិក្ខុទាំងឡាយ ពួកអ្នកចូរមកពិចារណាឃើញដោយសភាពជារបស់មិនស្អាតនៅក្នុងកាយនេះ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់យាងទៅរហូតអស់ជម្ពូទ្វីបដោយទីបំផុត ក៏នៅតែស្តេចបានទៅទីលំនៅរបស់ភិក្ខុ ២ រូបខ្លះ ៣ រូបខ្លះ ទ្រង់សម្តែងអានិសង្សយ៉ាងនេះថា ភិក្ខុទាំងឡាយកាលភិក្ខុមានចិត្ត ដែលអប់រំដោយការសម្គាល់ក្នុងរបស់ដែលមិនស្អាតរឿយៗហើយ ចិត្តរមែងរួញរា សន្កត់ជាប់ ថយត្រឡប់ មិនលាចេញ ភាពព្រងើយ

ព្រងើយ ឬភាពជារបស់បដិកូល រមែងតាំងនៅព្រម ចាកសេចក្ដីដល់ព្រម ដោយមេថុនធម្ម ។ ភិក្ខុទាំងឡាយ កាលភិក្ខុមានចិត្តដែលអប់រំដោយសេចក្ដីសម្គាល់ក្នុងរបស់ដែលមិនល្អច្រើន ចិត្តរមែងរួញរា សន្កត់ជាប់ ថយត្រឡប់ មិនលាចេញ សេចក្ដីប្រងើយ ឬភាពជារបស់បដិកូល រមែងតាំងនៅព្រម ចាកសេចក្ដីចង់ក្នុងរស ភិក្ខុទាំងឡាយ កាលភិក្ខុមានចិត្តដែលអប់រំហើយដោយសេចក្ដីសម្គាល់ថា មិនគួរត្រេកអរក្រៃលែងក្នុងលោកទាំងពួងច្រើន ចិត្តរមែងតក់ស្លុត រួញរា ថយត្រឡប់ មិនលាចេញ សេចក្ដីប្រងើយ ឬភាពជារបស់បដិកូល រមែងតាំងនៅព្រមក្នុងចិត្តដែលប្រកបដោយសេចក្ដីលោភ ។ ភិក្ខុទាំងឡាយ កាលភិក្ខុមានចិត្តដែលអប់រំហើយ ដោយសេចក្ដីសម្គាល់ថា មិនទៀងរឿយៗ ចិត្តរមែងស្លុតរួញរា ថយត្រឡប់ មិនលាចេញ សេចក្ដីព្រងើយ ឬភាពជារបស់បដិកូល រមែងតាំងនៅព្រមក្នុងសេចក្ដីលោភក្នុងលាភ និងសក្ការៈ ហើយត្រាស់កម្មដ្ឋាន ៤ ទាំងនេះថា ភិក្ខុទាំងឡាយ ពួកអ្នកចូរមកពិចារណាឃើញជារបស់មិនស្អាត ជាអ្នកមានការសម្គាល់ក្នុងភាពបដិកូលក្នុងអាហារ ជាអ្នកមានសេចក្ដីសម្គាល់ក្នុងសេចក្ដីមិនត្រេកអរក្រៃលែងក្នុងលោកទាំងពួង ជាអ្នកតាមពិចារណាឃើញថា មិនទៀងក្នុងសង្ខារទាំងពួងក្នុងកាយហើយ ។ ភិក្ខុសូម្បីនោះ ធ្វើកម្មក្នុងកម្មដ្ឋានទាំង ៤ នេះ ធ្វើឲ្យអាសវៈទាំងអស់រលត់ទៅ

តាំងនៅក្នុងកាពជាព្រះអរហន្ត ។ កម្មដ្ឋានទាំង ៤ នេះ ឲ្យរាគៈ ទោសៈ និង មោហៈស្ងប់ កម្ចាត់រាគៈ ទោសៈ និងមោហៈ បានពិតប្រាកដ ។

[២០៤] បទថា **កាន់ដុំគ្រួស** សេចក្តីថា កាន់យកដុំថ្មប្រមាណប៉ុន កណ្តាប់ដៃ ។

ក៏មារនេះបានឲ្យពួកព្រាហ្មណ៍ និងគហបតីជេរភិក្ខុខ្លះ បណ្តាលឲ្យភិក្ខុ សង្ឃកើតលាភ និងសក្ការៈដោយអំណាចព្រាហ្មណ៍ និងគហបតីខ្លះ កាលមិន បានចន្លោះ ឥឡូវនេះ បានមានសេចក្តីប្រាថ្នាដើម្បីនឹងព្យាយាមដោយដៃរបស់ ខ្លួន ទើបស្ថិតក្នុងរាងកាយរបស់ក្មេងណាមួយ ហើយបានកាន់យកដុំថ្មនោះ ។ ព្រះថេរៈសំដៅយកក្មេងនោះ ទើបពោលថា **ចាប់ដុំថ្មហើយ** ។ បទថា **បែក សិរសៈរបស់លោក** សេចក្តីថា ទម្លាយសិរសៈរបស់លោក សេចក្តីថា ទម្លាយ សិរសៈ ។ សាច់រហែកទៅដល់ស្បែកជំជា ២ ចំណែក ។ ក៏ដុំគ្រួសមិនទម្លាយ លលាដ៍ក្បាលដល់ឆ្អឹង ហើយឈប់ទុំះឯង ។

បទថា **ទ្រង់បានក្រឡេកមើលហើយ ទ្រង់មើលដូចដំរី** បានដល់ បាន ពួសំឡេងខ្លាំង ។

ដំរីដ៏ប្រសើរ កាលប្រាថ្នានឹងងាកទៅខាងនេះ ឬខាងនោះ នឹងមិនងាក.ក តែនឹងបែរខ្លួនទាំងអស់ត្រឡប់ក្រឡេកមើលនោះឯង យ៉ាងណា ព្រះសម្មាសម្ពុទ្ធ ព្រះនាមថា កកុសន្ធៈក៏យ៉ាងនោះ ទ្រង់បានត្រឡប់ព្រះសរីរៈទាំងអស់ក្រឡេក

មើល ។ ធ្នឹមទាំងឡាយរបស់មហាជន មានចុងទល់គ្នាតាំងនៅ របស់ព្រះបច្ចេក-ពុទ្ធត្រង់ចុងមានរាងជាទំពក់ ។ តែរបស់ព្រះពុទ្ធទាំងឡាយមិនជាដូច្នោះទេ ជាជួរតែមួយតាំងនៅដូចស្រោមដែក ព្រោះដូច្នោះ វេលាទ្រង់ក្រឡេកមើលខាងក្រោយ ព្រះពុទ្ធទាំងឡាយ ទើបមិនអាចងាកព្រះសូរងទៅបាន ក៏ដំរីដ៏ប្រសើរកាលប្រាថ្នានឹងក្រឡេកមើលចំណែកខាងក្រោយ ទើបបែរកាយទៅទាំងអស់នោះឯង ព្រះពុទ្ធក៏គប្បីបែរទៅដូច្នោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ថយត្រឡប់ព្រះសរីរៈទាំងអស់នោះឯង រមិលមើល ដូចព្រះពុទ្ធរូបមាសដែលវិលទៅដោយគ្រឿងយន្ត ក៏ព្រះសម្មាសម្ពុទ្ធបានប្រថាប់ឈររមិលមើល ត្រាស់ថាឬថា មារ ឈ្មោះទូសីនេះ មិនដឹងប្រមាណ ។ ពាក្យនោះ មានសេចក្តីថាទូសីមារនេះធ្វើបាប មិនដឹងប្រមាណនោះឯង បានធ្វើការឈានកន្លងប្រមាណហើយ ។

បទថា **ទ្រង់ក្រឡេកមើលព្រមគ្នា** សេចក្តីថា ខណៈនោះឯង ព្រមនឹងការក្រឡេកមើលរបស់ព្រះមានព្រះភាគ ព្រះនាមថា កកុសន្ធៈ ។

បទថា **ចុតិចាកទីនោះផង** សេចក្តីថា ចុតិចាកទីក្នុងទេវលោកនោះ ចូលដល់មហានរកហើយ ។

ក៏មារកាលនឹងចុតិ សូម្បីឈរត្រង់ណាទីមួយក៏ចុតិ ព្រោះដូច្នោះ មារនោះ ទើបមិនមកទេវលោកជាន់វសវត្តីវិញ ព្រោះចុតិហើយ ។ មារនោះ មិន

បានដឹងថា ចុតិ ព្រមទាំងពេលដែលព្រះមានព្រះភាគទ្រង់ទតព្រះនេត្រ ។ ទើបមារ

នោះមិនបានទូលលា ក្នុងពាក្យថា **ដោយការក្រឡេកមើល ព្រមគ្នា** ។

ក៏ពាក្យនេះ ត្រឹមតែជាការសម្ដែងវេលាចុតិប៉ុណ្ណោះ ក៏អាយុរបស់មារ

នោះ គប្បីជ្រាបថា អស់ទៅហើយក្នុងទេវលោកជាន់វសវត្តីនោះឯង ដូចការ

ប្រហារដោយពូថៅ ព្រោះខុសក្នុងព្រះមហាសាវក ។

[២០៥] បទថា **មានឈ្មោះ ៣ យ៉ាង** បានដល់ មាន ៣ ឈ្មោះ ។

បទថា **ឈ្មោះថា មានផស្សាយតនៈ ៦** (នរកឈ្មោះថា ផស្សាយតនិកៈ)

សេចក្ដីថា ក្នុងផស្សាយតនៈ ៦ វេទនារមែងមានបច្ច័យ ។

បទថា **ឈ្មោះថា នាំទៅព្រមដោយសូម** (នរក ឈ្មោះថា សង្កុសមាហតៈ)

សេចក្ដីថា ដែលគេនាំទៅព្រមដោយទំពក់ដែក ។

បទថា **សោយអារម្មណ៍ចំពោះខ្លួន** ( នរកឈ្មោះថា បច្ចត្តវេទនិយៈ)

បានដល់ ខ្លួនឯងនុ៎ះឯងឲ្យកើតវេទនា ។

បទថា **លំពែងនឹងលំពែងគប្បីមករួមគ្នាត្រង់ហទយៈ** សេចក្ដីថា លំពែង

ដែក និងលំពែងដែកមករួមគ្នាត្រង់កណ្ដាលបេះដូង ។

បានឮថា កាលអ្នកទាំងនោះកើតក្នុងនរកនោះ មានអត្តភាព ៣ គាវុត

សូម្បីមារក៏ជាដូច្នោះនុ៎ះឯង គ្រានោះពួកនាយនិរយបាលកាន់លំពែងដែកប្រមាណ

ប៉ុនដើមត្នោត ដែលភ្លើងឆេះសន្ធោសន្ធៅឯង ពោលថា ក៏អ្នកឯងនេះគិតហើយ

ទើបធ្វើសេចក្តីអាក្រក់ ទើបកើតក្នុងទីនេះ ហើយជំកណ្តាលបេះដូង ដូចអ្នកជំនំក្នុងស្នូកធ្វើនំ ធ្វើជន ៥០ នាក់ ឲ្យមាននាទីត្រង់ជើង , ៥០ នាក់ ឲ្យមាននាទីលើសីរសៈ លំពែងដែកដោតជាប់យ៉ាងនេះ ៥០០ ឆ្នាំ សូម្បីទាំងសងខាងហើយត្រឡប់ ៥០០ ឆ្នាំ ទៀត ត្រង់កណ្តាលបេះដូង ។ ព្រះថេរៈសំដៅយកលំពែងដែកនោះ ទើបពោលពាក្យនេះទុក ។

បទថា **វេទនាដែលតាំងឡើង** សេចក្តីថា វេទនាដែលតាំងឡើងពីវិបាក ។ បានឮថា ការសោយអារម្មណ៍នោះ មានទុក្ខច្រើនជាងការសោយផលក្នុងមហានរក ។ អាចារ្យទាំងឡាយពោលថា ដូចសេចក្តីថា ការរក្សាទឹកដោះរហូតអស់ ៧ ថ្ងៃ លំបាកជាងការផឹក សេចក្តីមិននឹងនក្នុងការរក្សារហូតអស់ ៧ ថ្ងៃ យ៉ាងណា ការសោយអារម្មណ៍ដែលតាំងឡើងពីវិបាក ព្រោះតណ្ហាដែលកម្រើកឡើង មានទុក្ខច្រើនជាង ទុក្ខក្នុងមហានរក ។

បទថា... **របស់ត្រីសូម្បីយ៉ាងណា** សេចក្តីថា សិរសៈរបស់មនុស្សមូលកាលបុគ្គលប្រហារដោយលំពែង ការប្រហាររមែងមិនចំត្រង់ទីកន្លែង រមែងឃៀងឃាតទៅ សិរសៈរបស់ត្រីមុខវែង ការប្រហាររមែងចំត្រង់ទីកន្លែង ការប្រហារ រមែងជាការដែលធ្វើទុកល្អ ព្រោះធ្វើកម្មមិនខុស ។ ដូច្នោះ សិរសៈទើបមានសភាពដូច្នេះ ។

[២០៦] បទថា **ទល់នឹងព្រះសាវកឈ្មោះថា វិធុរៈ** សេចក្តីថា ប៉ះពាល់

ព្រះសាវក ឈ្មោះថា វិធុរៈ ។

បទថា **ការសោយអារម្មណ៍ចំពោះខ្លួន** សេចក្តីថា ឲ្យកើតការសោយអារម្មណ៍តែម្យ៉ាងចំពោះខ្លួនឯង ។

បទថា **នរកមានដូច្នេះ** សេចក្តីថា គប្បីសម្តែងនរកដោយទេវទូតសូត្រក្នុងទីនេះ ។

បទថា **លោកដល់ទុក្ខដែលកើតពីបាប** គឺ ប្រសព្វទុក្ខដែលកើតពីមារស្លាប់ហើយ ។

បទថា **កណ្តាលស្រះ** បានដល់ បានឮថា វិមានដែលធ្វើឲ្យទឹកជាទីទ្រហើយ កើតត្រង់កណ្តាលមហាសមុទ្រ តាំងនៅរហូតអស់កប្ប ។ វិមានទាំងនោះ មានពណ៌ដូចកែវពិទូរ្យ មានអណ្តាតភ្លើងឆេះសន្ធោសន្ធៅជានិច្ច ដូចគំនរភ្លើងដែលឆេះដើមបបុស ឆេះសន្ធោសន្ធៅលើកំពូលភ្នំ មានរស្មីសុសសាយទៅ ។ សម្បូរណ៍ដោយរស្មីក្នុងវិមានទាំងនោះ មាននាងទេពអប្សរ មានរស្មីផ្សេងៗ គ្នា កំពុងរាំរបាំ ។

បទថា **អ្នកណាដឹងចំពោះរឿងនេះ** សេចក្តីថា អ្នកណាដឹងរឿងវិមាន-វត្ថុនេះ ។

ក្នុងរឿងនេះ ក៏គួរសម្តែងសេចក្តីដោយរឿងវិមានវត្ថុ និងបេតវត្ថុ ដូចគ្នា ។ ពាក្យនេះថា ឲ្យញ័រដោយចុងម្រាមជើង គួរសម្តែងដោយបាសាទកម្បន-

សូត្រនេះ ។

ពាក្យនេះថា **អ្នកណា (ឲ្យ) វេជយន្តញាំវហើយ** គួរសម្តែងដោយចូឡ-តណ្ហាសង្ខយសូត្រ និងវិមុត្តិសូត្រ ។

ពាក្យនេះថា **ព្រះថេរៈនោះសាកសួរស្តេចសក្កៈ** ក៏គួរសម្តែងដោយចូឡតណ្ហាសង្ខយសូត្រ និងវិមុត្តិសូត្រនោះ ដូចគ្នា ។

បទថា **ទីប្រជុំជិតធម្មសភា** សេចក្តីថា ជិតទីប្រជុំឈ្មោះថា សុធម្មា ។ ក៏សុធម្មសភានេះ នៅក្នុងព្រហ្មលោក មិនមែនក្នុងជាន់តាវត្តិង្ស ដែលឈ្មោះថា ទេវលោក ដែលវៀរចាកសុធម្មសភាមិនមាន ។

បទថា **រស្មីដែលសុសសាយទៅក្នុងព្រហ្មលោក** សេចក្តីថា ពន្លឺរបស់ព្រះមានព្រះភាគ ដែលស្តេចយាងទៅជាមួយពួកសាវក មានព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះមហាកស្សបៈជាដើមក្នុងព្រហ្មលោក ហើយអង្គុយចូលតេជោធាតុហើយ ។

សេចក្តីថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់ជ្រាបចិត្តរបស់ពួកព្រហ្មអ្នកអង្គុយ ប្រជុំក្នុងសុធម្មទេវសភាក្នុងព្រហ្មលោក គិតហើយថា មានឬទេហ្ន៎ ដែលសមណៈ ឬព្រាហ្មណ៍ណាៗ អ្នកមានឫទ្ធិច្រើនយ៉ាងនេះ អាចមកក្នុងទីនេះ ទើបស្តេចទៅទីនោះប្រថាប់អង្គុយ ត្រង់បំផុតគណៈរបស់ព្រហ្ម ទ្រង់ចូលតេ-ជោធាតុ ទ្រង់ត្រិះរិះដល់ការមករបស់ព្រះមហាមោគ្គល្លានៈជាដើម ។

ព្រះសាវកទាំងនោះ បានទៅថ្វាយបង្គំព្រះសាស្តាហើយ ទើបអង្គុយចូលគេជាធាតុក្នុងទិសទីមួយៗ ១ អង្គៗ ។ ព្រហ្មលោកទាំងអស់ ទើបមានពន្លឺដូចគ្នាតែមយ៉ាង ។ ព្រះសាស្តាទ្រង់សម្តែងធម៌ ប្រកាសសច្ចៈ ៤ ។ វេលាចប់ទេសនា ព្រហ្មច្រើនពាន់តាំងនៅក្នុងមគ្គ និងផល ។

ព្រះថេរៈសំដៅយកធម៌នេះ ទើបពោលគាថានេះ ។ ក៏សេចក្តីនោះគួរសម្តែងដោយពួកព្រហ្មសូត្រ ។

បទថា **បានពាល់ត្រូវដោយការរួចផុត** បានដល់ ពាល់ត្រូវដោយការរួចផុត គឺ ឈានទុំះឯង ។

បទថា **ព្រៃ** បានដល់ ជម្ពូទ្វីប ។

បទថា **បុព្វវិទេហទ្វីប** បានដល់ ទ្វីបដែលឈ្មោះថា បុព្វវិទេហៈ ។

ពាក្យថា **ពួកនរៈអ្នកដេកលើផែនដីណា** សេចក្តីថា អ្នកអមរគោយានទ្វីប និងអ្នកឧត្តរកុរុទ្វីប ឈ្មោះថា ពួកនរៈអ្នកដេកលើផែនដី មានពាក្យអធិប្បាយថា ពាល់ត្រូវនរៈទាំងអស់នោះ ។

ក៏សេចក្តីនេះ គួរសម្តែងដោយការទូន្មាននន្ទោបនន្ទនាគរាជ រឿងនេះលោកឲ្យពិស្តារហើយ ដោយការពោលអំពីឫទ្ធិ ក្នុងបករណ៍វិសេស ឈ្មោះថា វិសុទ្ធិមគ្គ ។

បទថា **ប្រសព្វវត្ថុដែលមិនមែនបុណ្យ** បានដល់ បានចំពោះវត្ថុដែល

មិនមែនបុណ្យ ។

បទថា កុំបានធ្វើសេចក្តីប្រាថ្នាក្នុងភិក្ខុទាំងឡាយ សេចក្តីថា កុំបានធ្វើសេចក្តីប្រាថ្នានេះថា យើងនឹងឲ្យភិក្ខុនេះវិនាស យើងនឹងបៀតបៀនភិក្ខុ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយស្រួលយល់នោះឯង ។

" ចប់អដ្ឋកថា មារតជ្ជនីយសូត្រ ទី ១០ "

## ចប់ ចូឡយមកវគ្គទី ៥

អដ្ឋកថា ដែលរួមព្រះសូត្រក្នុងគម្ពីរបណ្ណាសកៈ
មាន ២០ សូត្រ គឺ ៖

### មហាយមកវគ្គ

ចូឡគោសិង្គសាល ១ មហាគោសិង្គសាល ២ មហាគោបាល ៣
ចូឡគោបាល ៤ ចូឡសច្ចក ៥ មហាសច្ចក ៦ ចូឡតណ្ហាសង្ខយ ៧
មហាតណ្ហាសង្ខយ ៨ មហាអស្សបុរ ៩ ចូឡអស្សបុរ ១០

### ចូឡយមកវគ្គ

សាលេយ្យក ១ វេរញ្ជក ២ មហាវេទល្ល ៣ ចូឡវេទល្ល ៤
ចូឡធម្មសមាទាន ៥ មហាធម្មសមាទាន ៦ វិមង្សក ៧ កោសម្ពិយ ៨
ព្រហ្មនិមន្តនិក ៩ មារតជ្ជនីយ ១០
ដែលប្រដាប់ដោយ ៥ វគ្គ ចប់ហើយ ។

## បបញ្ចសូទនី នៃអដ្ឋកថា មជ្ឈិមនិកាយ
## មូលបណ្ណាសកវណ្ណនា ចប់

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

## តាមរយៈភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
## នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបាសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូទី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងស្មៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមស្មៀង<br>-ម៉ៅ ប៊ុនសន្ថា ក្ខួយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម គឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គឹម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផាអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក ឃិន ឈួ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

## តាមរយៈភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលប៊ិន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -សូ បូរី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឪ មុយ ឧបាសិកា តែ ចាន់ណារ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាបួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉ោគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃឹម វីឡាត់ | 50 AUS |
| -ឧបាសក តូ សរឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គឹម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គឹម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |

| | |
|---|---|
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភារ ឧបាសិកា កាំង គឹមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារិម | 15 AUS |
| -ថៃស៊ីម,ថៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ៊្គិច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា សា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងីមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វ៉ាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |